មង្គលត្ថទីបនីញ្ប

ភាគ ទី ៣

ប្រែនិងរៀបរៀងដោយ

ភិក្ខុវិនយធរោ (មហាយិន-ឌឿន)

ជំនួយដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា

ឌិង

ឃោះពុម្ពផ្សាយជាធម្មទាន

លើក ទី ២

បំនួន ៥,០០០ ក្សាល

រក្សាសិទ្ធិ

ព.ស. ២៥៥៧ គ.ស. ២០១៣

សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ បំពោះ **ព្រះភិក្ខុនីសង្ឆ វត្តបញ្ញា** ស្ថិតនៅក្នុងសង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញនិង ពុទ្ធបរិស័ទជនជាតិតៃវ៉ាន់ ដែលបានជួយទទួលបោះពុម្ពសៀវភៅ **មន្តលត្តឆីបនីប្រែ** នេះ ដើម្បីចែកផ្សាយជាធម្មទាន ដល់សិក្ខាកាមទាំងឡាយ ។

សូមធម្មទាននេះ បានសម្រេបផល ដល់លោកអ្នកដែលបានចែកហានទៅហើយ មួយបំណែកផង ។

មួយបំណែកទៀត សូមព្រះភិក្ខុនីសង្ឆ ជនជាតិបិន ដែលមានទីស្នាក់ការ នៅប្រទេសកម្ពុជា និង ពួកពុទ្ធបរិស័ទ ដែលបានជួយឧបត្ថម្ភ ក្នុងធម្មទាននេះ បានសម្រេបប្រយោជន៍ តាមសេចក្តីប្រាថ្នា កុំបីខានឡើយ ។

ភិក្ខុចិនយធរោ មហាយិន-ឆៀន

វត្តខ្មែរសាន់តាអាណា

2630 N. Grand Ave.
Santa Ana, CA 92705
U. S. A

ថ្ងៃអាទិត្យ ៨ កើត ខែបុស្ស ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៦

ត្រូវនឹងថ្ងៃទី ១៩ ខែមករា គ.ស. ២០១២

ធម្មទានឈ្នះអស់ទានទាំងពួង

សៀវភៅដែល **ព្រះភិក្ខុនីសង្ឆ** និង ពុទ្ធបរិស័ទ **ជនជាតិតៃវ៉ាន់** បានមានសទ្ធាជ្រះថ្លា និង បានទទួលជួយបោះពុម្ព ចែកផ្សាយជាធម្មទាន នៅពេលនេះ មានចំនួន ដប់បីភាគ (១៣ ភាគ) ក្នុងមួយភាគៗ បោះពុម្ពចំនួនប្រាំពាន់ក្បាប់ (៥,០០០ក្បាប់) ។

សៀវភៅដែលបោះពុម្ពទាំង ១៣ ភាគ នេះ រួមមាន ៖

១- មង្គលត្ថទីបនីប្រែ	ភាគ ទី ១
២- មង្គលត្ថទីបនីប្រែ	ភាគ ទី ២
៣- មង្គលត្ថទីបនីប្រែ	ភាគ ទី ៣
៤- មង្គលត្ថទីបនីប្រែ	ភាគ ទី ៤
៥- វិសុទ្ធិមគ្គប្រែ	ភាគ ទី ១
៦- វិសុទ្ធិមគ្គប្រែ	ភាគ ទី ២
៧- វិសុទ្ធិមគ្គប្រែ	ភាគ ទី ៣
៨- គាថាធម្មបទប្រែ	
៩- សទ្ធានុក្រមបាលី-ខ្មែរ	ភាគ ទី ១
១០- សទ្ធានុក្រមបាលី-ខ្មែរ	ភាគ ទី ២
១១- សទ្ធានុក្រមបាលី-ខ្មែរ	ភាគ ទី ៣
១២- សទ្ធានុក្រមបាលី-ខ្មែរ	ភាគ ទី ៤
១៣- សទ្ធានុក្រមបាលី-ខ្មែរ	ភាគ ទី ៥

រូបំ ជីវតិ មច្ចានំ នាមគោត្តំ ន ជីវតិ

ភិក្ខុវិនយធរោ មហាយិន-ឌឿន

កើត ថ្ងៃទី១០ ខែកក្កដា ១៩៥២

ភូមិទួលព្រំ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

រូបកាយ របស់សត្វទាំងឡាយ តែងបាស់ជរាគ្រាំគ្រា
បំណែក នាមនិងគោត្រ មិនដែលបាស់ជរាឡើយ ។

មង្គលត្ថទីបនីញ្ប

ភាគ ទី៣

សម្រាប់តម្កល់ទុកជាសម្បត្តិសង្ឆ

ក្នុងបណ្ណាល័យ

វត្ត .....

ភូមិ .....

ឃុំ .....

ស្រុក .....

ខេត្ត .....

នៅថ្ងៃ.....*កើត*.....*ភេច* *ខែ*.....

ឆ្នាំ ..... *ព. ស. ២៥៥*.....

អ្នកចែក **តិភ្ទូវិនយធរោ មហាយិន-ឆៀន**

អ្នកទទួល .....

មាតិការឿង

ឈ្មោះធម៌	ទំព័រ
អារម្ភកថា របស់អ្នករៀបរៀង	ក
សេបក្តីថ្លែងអំណរគុណ	ឆ
ពណ៌នាសេចក្តីនៃគាថា ទី ៥	១
ពណ៌នាអំពីទាន	២
ពណ៌នាអំពីការប្រព្រឹត្តិធម៌	៩២
ពណ៌នាអំពីការសង្រ្គោះញាតិ	១៦៤
ពណ៌នាអំពីការងារដែលមិនមានទោស	១៨៣
ពណ៌នាសេចក្តីនៃគាថា ទី ៦	២៥៦
បាបវិរតិមជ្ជបានសំយមកថា	២៥៣
ពណ៌នាអំពីសេបក្តីមិនប្រមាទ	៣៣៤
ពណ៌នាសេចក្តីនៃគាថា ទី ៧	៣៩៩
ពណ៌នាអំពីសេបក្តីគោរព	៤០០
ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន	៤៤៥
ពណ៌នាអំពីសេបក្តីសន្តោស	៤៦១

* ❀ *

អារម្ភកថា

របស់អ្នករៀបរៀង

សៀវភៅ មជ្ឌលត្តធីបនីប្រែ ភាគ ធី៣ នេះ គឺខ្ញុំ **ភិក្ខុវិនយធរោ មហាយិន-នឿន** បំរុងនឹងផ្ទួបផ្ទើមប្រែនិងរៀបរៀងមកជាភាសាខ្មែរយើង ជាយូរណាស់មកហើយ គឺតាំងពីពេលដែលខ្ញុំកំពុងនៅសិក្សាមកម្ល៉ះ (ព.ស. ២៥២៤ គ.ស. ១៩៨១) តែឱកាសពុំបានហុបឱ្យ ព្រោះជាប់រវល់ខ្លាំងពេក ក្នុងការសិក្សាភាសាបាលី ឱ្យបានរីកបំរើនទ្បើងថែមទៀតផង និងក្នុងពេលនោះ នឹងរកឧបករណ៍ក្ឃនប្ឆាប់ ដែលជាទេមរភាសាសម្រាប់ជាជំនួយ ក៏គ្មានផងដែរ ។ គម្រោងការនេះ ខ្ញុំក៏មិនបានបោះបង់ចោលដែរ ទោះបីជាខ្ញុំបានរសាត់អណ្ដែតឆ្ងាយសែនឆ្ងាយ អំពីមាតុភូមិជាទីស្នេហា ហើយបានទៅរស់នៅឯបរទេស ជាប្រទេសដែលមិនកាន់ព្រះពុទ្ធសាសនា មានវប្ឆធម៌ ទំនៀមទំលាប់ខុសប្លែកផ្សេង ពីប្រទេសយើងក៏ដោយ ក៏គម្រោងការនេះ នៅតែដក់ជាប់ក្នុងបិត្តខ្ញុំជានិច្ច ។

នៅក្នុងថ្ងៃពុធ ១១ រោច ខែពិសាខ ឆ្នាំវក បត្ចាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃ ទី២៣ ខែឧសភា គ.ស. ១៩៩២ (ឆ្នាំដែលក្រុមអង្គការសហប្រជាជាតិ ចូលមកជួយរៀបបំ ធ្វើការបោះឆ្នោត នៅប្រទេសកម្ពុជា) ខ្ញុំក៏បានវិលត្រឡប់ ចូលមកទស្សនាមាតុភូមិរបស់ខ្ញុំផងដែរ ហើយបានចូលទៅពិនិត្យមើលការសិក្សា

ព្រះបរិយត្តិធម៌ ទាំងផ្នែកបាលីទាំងផ្នែកព្រះធម្មវិន័យ ដែលព្រះសង្ឆ
កំពុងតែសិក្សា នៅតាមខេត្តនានា ដូចជាវត្តមហាមន្ត្រី វត្តលង្ការ
វត្តនិរោធរង្សី ជាដើម ដោយមាន **សម្តេចមង្គលទេព្វាចារ្យ (អ៊ុំ-ស៊ុំ)**
អគ្គាធិការពុទ្ធិកសិក្សា បានតាំដំណើរជូនទៅផងដែរ ។

ពេលនោះ ខ្ញុំមានសេចក្តីសោមនស្ស រីករាយជាទីបំផុត
ដោយបានឃើញ នូវព្រះសង្ឆ អង្គសាមណេរ ទិតទំយកព្រះទ័យ ទុក
ដាក់ ក្នុងការសិក្សាព្រះបរិយត្តិធម៌ គឺបានឲ្យព្រះភិក្ខុសង្ឆ សាមណេរ
អង្គខ្លះ កំពុងទន្ទេញបាលីវៃយ្យាករណ៍ អង្គខ្លះកំពុងទន្ទេញប្រជុំកង
ធម៌ អង្គខ្លះកំពុងហាត់ប្រែធម្មបទ លោកគ្រូអាចារ្យខ្លះ កំពុងបង្ហាត់
ប្រែលោតប្រយោគ តាមបែបបូរាណ... គំហើញ និង ការឲ្យសូរសព្ទ
ព្រះធម៌ដ៏ពិរោះត្រចៀកនេះ រឹតតែធ្វើឱ្យខ្ញុំរំភើបចិត្តឥតឧបមា ព្រោះ
នឹកសង្ឆឹមថា ព្រះពុទ្ធសាសនា ដែលបានវិនាសសាបសូន្យ ស្ទើរតែ
រលត់អស់ ដោយសារភ្លើងសង្ក្រាម ជាងពីរទស្សវត្សរ៍ មកហើយ
នោះ នឹងបានរីកបំរើនឡើងដោយពិត ហើយបានរំរុញខ្ញុំ ឱ្យរឹតតែ
មានសទ្ធាជ្រះថ្លាឡើងជាភេយ្យោភាព... ។ ម្ជយទៀតសោត ក៏បាន
ធ្វើឱ្យខ្ញុំនឹកគិតថា តើនឹងរកពិធីជួយ ដល់សមណសិស្សបែបណា?
ខ្ញុំយល់ឃើញថា សមណសិស្សដែលកំពុងសិក្សា នៅសាលាពុទ្ធិក-
បឋមសិស្សា (ពេលនោះ) ដូចជាពុំមានបញ្ហាឡើយ ព្រោះមានគ្រូ និង
មានក្ឆូនប្បាប់សម្រាប់ជួយប្រើន តែបំណែកតទៅឆ្នាំក្រោយៗទៀត

នឹងមានសមណសិស្ស សាលាពុទ្ធិកមធ្យមសិក្សា ដោយពិត ឯគ្រូ និង ក្បួនច្បាប់ ខ្ញុំយល់ឃើញថា ដូចជាមានបញ្ហាខ្លះ ព្រោះខ្វះខាតច្រើន ។

ហេតុនេះហើយ ខ្ញុំបានគិតថា នឹងស្រាវជ្រាវរកសៀវភៅ មង្គលត្ថទីបនី ដែលនៅជាភាសាបាលី ទាំង ៤ ភាគ ដើម្បីយកមកប្រែ ជាភាសាខ្មែរយើង និង ដើម្បីជាជំនួយដល់សមណសិស្ស សាលាពុទ្ធិកមធ្យមសិក្សា ដែលនឹងមានក្នុងអនាគតកាល ហើយក៏បានដើរ ស្រាវជ្រាវរក នូវសៀវភៅទាំងនោះ តែរកពុំបានឡើយ សូម្បីតែ សម្តេចព្រះមង្គលទេព្វាចារ្យ (អ៊ុំ-ស៊ុំ) ក៏ព្រះអង្គពុំទាន់មានដែរ ព្រោះ រោងពុម្ព ជប៉ុន ពុំទាន់បានបោះពុម្ពជាជំនួយ ។

ជាបុណ្យកុសលមែន, នៅពេលដែលខ្ញុំវិលត្រឡប់មកកាន់ វត្ត ខេមរពុទ្ធិការាម ទីក្រុងឡុងប៊ិច សហរដ្ឋអាមេរិក វិញ ក៏ស្រាប់ តែមាន ព្រះភិក្ខុមួយរូប ព្រះនាម **ប្លួ-ហ្លួយ** លោកបានយកសៀវភៅ **មង្គលត្ថទីបនី** ភាគទី៣ និង ភាគទី៤ ដែលជាភាសាបាលី មកបង្ហាញ ឲ្យខ្ញុំមើល ហើយខ្ញុំក៏បានសុំខ្ចីលោកសិន ដើម្បីនឹងយកមកបកប្រែ ជាភាសាខ្មែរយើង ដោយបានចាប់ផ្តើមប្រែ នៅថ្ងៃសុក្រ ១០ រោច ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព. ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៩៣ ហើយបានប្រែចប់សព្វគ្រប់ នៅថ្ងៃព្រហស្បតិ៍៨ កើត ខែភទ្របទ ឆ្នាំរកា បញ្ចស័ក ព. ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៣ វេលាព្រឹក ។

លុះប្រែបប់ហើយ ខ្ញុំក៏បានផ្ញើសំណៅមង្គលត្ថទីបនី នេះទៅប្រគេនព្រះតេជព្រះគុណ **ព្រះធម្មលិទិត លាស់-ឡាយ** (១) គង់នៅវត្តសន្សំកុសល ទីក្រុងភ្នំពេញ ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវ... តែ មង្គលទ្ធទីបនី ភាគទី ៣ នេះ ព្រះអង្គពុំអាចជួយត្រួតពិនិត្យបានទេ ព្រោះព្រះអង្គមានការរវល់ប្រើនពេក ក្នុងកិច្ចការផ្សព្វផ្សាយព្រះពុទ្ធសាសនា... ក្រោយមក ខ្ញុំក៏បានយកសំណៅ មង្គលត្ថទីបនី ភាគទី៣ នេះ ទៅប្រគេនព្រះតេជគុណ **អធិបតីសង្ឃ** (**សៅ-ឃន**) ប្រធាន សហគមន៍ព្រះសង្ឃខ្មែរ គង់នៅវត្ត ត្រៃរតនារាម ទីក្រុងឡូវែរ រដ្ឋម៉ាសាឈូសេត សហរដ្ឋអាមេរិក ដើម្បីឲ្យព្រះអង្គជួយត្រួតពិនិត្យជំនួសវិញ ព្រះអង្គក៏បានយល់ព្រម ដោយពេញព្រះទ័យជាទីបំផុត ហើយបានជួយត្រួតពិនិត្យ រហូតបានសម្រេចជាស្ថាពរ ។

ក្នុងការបកប្រែពីភាសាមួយទៅភាសាមួយទៀតនេះ គឺពិតជាមានការពិបាកខ្លាំងណាស់ ហើយពិតជាមានការភ្លាំងភ្លាត់ ខុស ឃ្លាតបាកអំពីអត្ថន័យធម៌អាថ៌ខ្លះ។ ដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ ជាពុំខានឡើយ ។ ក្នុងការបកប្រែនេះសោត គោលគំនិតរបស់ខ្ញុំ គឺប្រែរក្សាទុកភាសាបាលីភាគប្រើន មានន័យថា គឺមិនបង់ឱ្យឃ្លាតបាកអំពីភាសាបាលីប្រើនឡើយ ដើម្បីឱ្យអ្នកសិក្សាធាប់រកសព្ទប្រែបានងាយ តែភាសាខ្មែរ ពិតជាពិបាកស្តាប់បន្តិច ។

១- ភាគទី១-ទី២ ព្រះអង្គបានជួយត្រួតពិនិត្យរហូតចប់សព្វគ្រប់ ។

ហេតុដូច្នេះ ខ្ញុំអ្នកប្រែ សូមមេត្តាខន្តី អភ័យទោស អំពីសំណាក់ព្រះតេជគុណ និង អស់លោកដែលធ្លៀវឈ្លាស ក្នុងអក្សរ-សាស្ត្របាលីក្តី ខ្មែរក្តី បើមានការខុសភ្លាំងភ្លាត់ត្រង់កន្លែងណានីមួយនោះ ហើយសូមមេត្តាជួយឱ្យជាយោបល់ និង ជួយកែតម្រូវ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានរឹងរឹតតែល្អប្រសើរឡើង ។ សង្ឃឹមថា ព្រះតេជៈគុណ អស់លោក នឹងផ្តល់ជាយោបល់ដ៏ល្អ។ ហើយនឹងអភ័យទោសដល់ខ្ញុំជាពុំខាន ។

សូមអរព្រះគុណ និង អរគុណទុកជាមុន ។

តិក្ខុចិនយធរោ (មហាយិន-ឆៀន)

ថ្ងៃសៅរ៍ ១៥ កើត ខែវិសាខ ឆ្នាំកុរ សប្តស័ក ព.ស. ២៥៣៨

ត្រូវនឹងថ្ងៃទី ១៣ ខែឧសភា គ.ស. ១៩៩៥

ចត្តខេមរពុទ្ធិភាពម

2100 W. Willow Street
Long Beach, CA 90810
U.S.A.

ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ដល់សមណសិស្សគ្រប់ព្រះអង្គ និង ពុទ្ធសាសនិកជនទូទៅ សូមយកទៅសិក្សា ឱ្យបានឆាប់បេះឆាប់យល់ ឆ្លៀវឆ្លាត ក្នុងព្រះបរិយត្តិធម៌ ហើយយកព្រះធម៌នោះ ទៅផ្សព្វផ្សាយ ដល់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីលើកស្ទួយ នូវព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនរុងរឿងឡើងជារៀងតទៅ ។

មួយទៀត សូមឱ្យការសិក្សានូវព្រះធម្មវិន័យ របស់សមណសិស្សគ្រប់ៗ រូប និង ពុទ្ធបរិស័ទទាំងអស់ បានសម្រេច សមដូចមនោរថ ដែលបានប្រាថ្នាហើយនោះ កុំបីអាក់ខានឡើយ ។

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតអំពីធម្មទានេះ ជូនដល់បិតា ឈ្មោះ **យិន-យ៉ឿម** មាតា ឈ្មោះ **ហ៊ីង-អម** ព្រមទាំងជីដូនជីតា ញាតិកាទាំង ៧ សន្ធាន និង សព្វសត្វទាំងអស់ ដែលបានបែកឋានទៅហើយនោះ សូមឱ្យវិញ្ញាណក្ខន្ធ របស់លោកអ្នកទាំងនោះ បានទទួល នូវបុណ្យកុសល ដែលខ្ញុំបានឧទ្ទិសផ្សាយ ទៅឱ្យនេះបុះ ហើយសូមឱ្យបានសម្រេច នូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺ ៖ សម្បត្តិមនុស្ស សម្បត្តិទេវតា និង សម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតទៅជាប្រការៈដទៃឡើយ ។

សេចក្ដីផ្ដែងអំណរគុណ

ខ្ញុំសូមផ្ដែងអំណរព្រះគុណ និង អរគុណដ៏ជ្រាលជ្រៅ

-បំពោះ សម្ដេចមង្គលទេព្ធាចារ្យ (អ៊ុំ-ស៊ុំ) អគ្គាធិការពុទ្ធិកសិក្សា វត្តមហាមន្ត្រី ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គ បានផ្ដល់យោបល់ដ៏ល្អៗ និងបានផ្ដល់នូវក្បួនច្បាប់ផ្សេងៗមានសៀវ ភៅមង្គលត្ថទីបនីនេះ និង បទានុក្រមធម្មបទជាដើម តាមត្រូវការ ។

-បំពោះ ព្រះតេជព្រះគុណ ព្រះធម្មលិខិត លាស់-ឡាយ វត្តសន្ធ្ស៊ ក្ដុសល ក្រុងភ្នំពេញ ដែលបានបំណាយពេលវេលា ជួយត្រួតពិនិត្យ កែសម្រួលពាក្យពេជន៍ និង អត្ថន័យផ្សេងៗ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង តាំងពីដើម រហូតដល់ចប់សព្វគ្រប់ ។

-បំពោះព្រះតេជគុណ បណ្ឌិត គង់-ឈាន ចៅអធិការ វត្ត ខេមរ-ពុទ្ធិការាម ទីក្រុងឡុងប៊ិច សហរដ្ឋអាមេរិក ដែលបានជួយផ្ដល់ យោបល់ គំនិត និង ជ្ជវិកា ក្នុងការបោះពុម្ព ។

-បំពោះ ភិក្ខុ ប្ជ-ហ្ជយ ដែលបានឱ្យខ្ជីសៀវភៅមង្គលត្ថទីបនី ភាគ ទី៣ និង ភាគទី៤ ដើម្បីយកមកប្រៃ ។

-បំពោះ ភិក្ខុ អ៊ុង-អ៊ុន វត្តប្រោះស្ន សហរដ្ឋអាមេរិក, ភិក្ខុប្ដាជ-សារាន វត្តឧណ្ណាលោម ក្ដុដ្ជលេខ ៤២ ទីក្រុងភ្នំពេញ និងលោក ក្ជវ៉ីនិពន្ធ ហៀម-ភ្ជឿន ដែលបានជួយយកសំណៅ នៃមង្គលត្ថទីបនី នេះ ទៅប្រគេន ព្រះធម្មលិខិត លាស់-ឡាយ ដើម្បីត្រួតពិនិត្យឱ្យបាន

ល្អត្រឹមត្រូវឡើង ។

-បំពោះ ភិក្ខុ មហាសោម-សុភា វត្តធម្មចក្ការាម ទីក្រុងស៊ីអាថ៊ុល វ៉ាស៊ីតោនស្តេត និង ព្រះតេជគុណ ឯម-ភឿង ព្រះមេគណ ខេត្តកំពត, ព្រះមេគណ សុខ-ឋាន ខេត្តកំបង់ឆ្នាំង ដែលបានជួយត្រួតពិនិត្យនូវអក្ខរាវិរុទ្ធ ដើម្បីធ្វើសៀវភៅនេះឱ្យបានប្រសើរឡើង ។

-បំពោះ ភិក្ខុ ព្រះមហាសម-ស័ក្តិ សុវណ្ណរតនោ ដែលបានយកសៀវភៅនេះ ទៅចូលរោងពុម្ព ដើម្បីបោះពុម្ព ឱ្យបានសម្រេច តាមសេចក្តីត្រូវការ ។

-បំពោះ លោកយឹម-ង៉ែយ និង លោក យ៉ុំ-ឆយ ដែលបានជួយកែសម្រួល និង ជួយដំឡើងគ្រឿងកុំព្យូទ័រ ដោយយកចិត្តទុកដាក់ជាទីបំផុត ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរព្រះគុណ និង អរគុណ ជាទីបំផុត បំពោះព្រះតេជគុណ ព្រះថេរានុថេរៈ អស់លោក លោកស្រី ព្រមទាំងញាតិញោម ជាពុទ្ធបរិស័ទទាំងអស់ ដែលបានជួយឧបត្ថម្ភក្នុងការបោះពុម្ពនេះ ឱ្យបានសម្រេចជាស្ថាពរ ។

សូមប្រគេននូវមគ្គផល ដែលកើតអំពីធម្មទានានិសង្សនេះ ដល់ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ សូមមានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាទីពឹង របស់ពុទ្ធសាសនិកជនទាំងឡាយ តរៀងទៅហោង ។

សូមឱ្យញាតិញោមទាំងឡាយ បានទទួលបុណ្យកុសលនេះ ស្មើៗ គ្នា និង សូមឱ្យបានដួបប្រទះតែនឹងសេចក្ដីសុខ-ចំរើន គ្រប់ប្រការ កុំបីខានឡើយ ។

សូមឱ្យព្រះរាជាណាចក្រកម្ពុជា ជាទីកំសត់ ធាប់បានទទួលនូវសុខសន្ដិភាព ដែលប្រកបដោយព្រះធម៌ នៃអង្គព្រះសម្មាសម្ពុទ្ធ បរមគ្រូ ដោយពិត, សូមឱ្យរាជរដ្ឋាភិបាល គ្រប់ជាន់ថ្នាក់ និង គ្រប់គណៈបក្សទាំងអស់ ដឹកនាំប្រទេសជាតិ ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសម្មាទិដ្ឋិ ដើម្បីជោគជ័យ សេចក្ដីសុខ-ចំរើន និង សុភមង្គល ជូនដល់ប្រជានុរាស្ត្រ ទូទាំងប្រទេស ដែលកំពុងក្រីក្រ លំបាក ស្រេកឃ្លាន នូវសេចក្ដីសុខសន្ដិភាព និង ស្អប់ខ្ពើមបំផុត នូវសង្គ្រាម សព្វថ្ងៃនេះ ។

សូមឲ្យទ្ធិសបុណ្យកុសលនេះផងដែរ ដល់ពួកបញ្ញវន្ត អ្នកស្នេហាជាតិ យុវជន យុវតី ប្រជាពលរដ្ឋ អ្នកស្លូតត្រង់ គ្រប់ជាន់គ្រប់ស្រទាប់ ដែលបានបូជាជីវិត ដើម្បីមាតុភូមិ ដោយចិត្តស្មោះស្ម័គ្រ គ្រប់កាលៈទេសៈ សូមបានទទួលនូវបុណ្យកុសល ដែលកើតអំពីធម្មទានេះ ហើយសូមឱ្យវិញ្ញាណក្ខន្ធ នៃអ្នក បានសោយនូវសុខដ៏ប្រសើរ ក្នុងសុគតិភព កុំបីអាក់ខានឡើយ ។

មង្គលត្ថទីបនីប្រែ

ភាគ ទី ៣

ពណ៌នាសេចក្តីនៃគាថា ទី ៥

(១) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ៥ ។ ចេតនា ជាហេតុឲ្យ ឈ្មោះថា **ទាន** ។ កិរិយាប្រព្រឹត្តិ គឺ កិរិយាធ្វើនូវធម៌ ឈ្មោះថា **ធម្មចរិយា** ។ បទថា " **ញាតកានំ** " មានសេចក្តីថា កិរិយាសង្ត្រោះញាតិទាំងឡាយរបស់ខ្លួន ។ បទថា " **អនវជ្ជានិ** " បានដល់ កម្មទាំងឡាយ មានឧបោសថកម្មជាដើម ដែលមិនមានទោស គឺបណ្ឌិតមិននិន្ទា មិនតិះដៀលហើយ ។ បទថា " **ឯតំ** " មានសេចក្តីថា ម្នាលទេវតា អ្នកចូរសម្គាល់យក ថា " ទាន ១ ការប្រព្រឹត្តិធម៌ ១ ការសង្ត្រោះញាតិ ១ កម្មដែលមិនមានទោស ១, កម្មទាំង ៤ យ៉ាង មានទាន ជាដើមនេះ ជាមង្គលដ៏ឧត្តម " ។

សេចក្តីសង្ខេប ក្នុងគាថា ទី ៥ នេះ មានតែប៉ុណ្ណេះឯង ។
ចំណែកសេចក្តីពិស្តារ ក្នុងគាថា ទី ៥ នេះ មានដូចតទៅនេះ ៖

* * *

-២-

ពណ៌នាអំពីទាន

(ទាន ៣ យ៉ាង)

(២) ឈ្មោះថា ទាន មាន ៣ យ៉ាង ដោយអំណាច នៃ ចាគចេតនា វិរតិ និង ទេយ្យធម៌ ។ ពិតមែន យ៉ាងដូច្នោះ ចាគចេតនា ឈ្មោះថា **ទាន** ក្នុងទានសូត្រ ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយថា " សទ្ធា ១ ភាពជាអ្នកមានហិរិ ១ ទានដែល ជាកុសល ១ " ដូច្នេះជាដើម ។

អដ្ឋកថាទានសូត្រនោះថា "ព្រះអរិយសាវក រមែងឲ្យទាន ដោយសទ្ធាណា, សទ្ធានោះ ព្រះមានព្រះភាគ ទ្រង់អធិប្បាយ ថា **សទ្ធា** ក្នុងគាថានោះ ។ ព្រះអរិយសាវក រមែងឲ្យទាន ដោយហិរិណា, ហិរិនោះឯង ព្រះអង្គ ទ្រង់ត្រាស់អធិប្បាយថា **ហិរីយំ** ។ ទានដែលគ្មានទោស ឈ្មោះថា **ទានជាកុសល** " ។

វិរតិ ឈ្មោះថា **ទាន** ក្នុងអាគតដ្ឋាន ថា " ព្រះអរិយ-សាវក រមែងឲ្យនូវអភ័យ " ។ ក្នុងពាក្យថា " **អភយំ ទេតិ** " នោះ មានសេចក្តីអធិប្បាយថា ព្រះអរិយសាវក រមែងធ្វើអភ័យ ទាន គឺ សមាទាននូវការវៀរចាក ពោលគឺសីល ៥ ។ ទាន គឺ ការវៀរចាកនេះ នឹងមានប្រាកដ ក្នុងមង្គលបទថា **អារតី វិរតី បាបា** នុ៉ះ ។ ទេយ្យធម៌ ឈ្មោះថា **ទាន** ក្នុងអាគតដ្ឋានថា ព្រះ អរិយសាវក រមែងឲ្យទាន គឺបាយ និង ទឹក " ដូច្នេះជាដើម ។

-៣-

មង្គលត្ថទីបនីប្រែ

(វិគ្រោះទាន)

(៣) សូម្បីក្នុងអដ្ឋកថាកថាវត្ថុ លោកពោលថា " បណ្តាទានទាំង ៣ យ៉ាងនោះ ចាគចេតនា ឈ្មោះថា **ទាន** ព្រោះវិគ្រោះថា ចាគចេតនា រមែងឲ្យនូវទេយ្យធម៌, ម្យ៉ាងទៀត ជនទាំងឡាយ រមែងឲ្យទេយ្យធម៌ ដោយចេតនានុ៉ះ ។ វិរតិ ឈ្មោះថា **ទាន** ព្រោះសេចក្តីថា កាត់ផ្តាច់ផ្តិល និង ព្រោះសេចក្តីថា កាត់ ។ មែនពិត វិរតិនោះ កាលកើតឡើង រមែងកាត់ផ្តាច់ និង រមែងកាត់នូវចេតនា របស់បុគ្គលអ្នកទ្រុស្តសីល ពោលគឺ សេចក្តីភិតភ័យ និង សេចក្តីខ្ជាចជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **ទាន** ។ ទេយ្យធម៌ ឈ្មោះថា **ទាន** ព្រោះសេចក្តីថា ដែលបុគ្គលឲ្យ ។ ទាន នេះ សូម្បីមាន ៣ យ៉ាង ដូចដែលបានពោលមកហើយនេះ ដោយសេចក្តី ក៏មាន ២ យ៉ាង គឺ ធម៌ដែលប្រព្រឹត្តទៅ តាមផ្លូវចិត្ត ១ ទេយ្យធម៌ ១ " ។

បណ្តាទានទាំង ២ យ៉ាងនោះ ភាវៈនៃទានជាមង្គល ក្នុងទានដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ទើបត្រឹមត្រូវ, ក្នុងទានដែលមិនប្រព្រឹត្តទៅតាមផ្លូវចិត្ត មិនត្រឹមត្រូវទេ ។ ព្រោះហេតុនោះ **ទាន** គឺទេយ្យធម៌ ដែលមិនប្រព្រឹត្តទៅ តាមផ្លូវចិត្ត ទើបមិនបាន ក្នុងមង្គលបទថា ទាន នេះទេ ។ សូម្បីវិរតិនោះ ក៏រមែងមិនបាន ក្នុង

ពណ៌នាអំពីទាន

*មង្គលបទនេះដែរ ព្រោះវិតិ សូម្បីក្នុងទានដែលប្រព្រឹត្តទៅ តាមផ្លូវចិត្ត ព្រះមានព្រះភាគទ្រង់ប្រកាន់យក ដោយការវៀរចាកបាបនិង ការសង្រ្គមចាកការធីកនូវទឹកស្រវឹង ឲ្ជជ៏ទាងមុខ ។ ព្រោះហេតុនោះ បណ្ឌិត គប្បីយើញសេចក្ដីសន្ទិដ្ឋាន ដោយបារិសេស-នយ័ថា " ចាគចេតនា ឈ្មោះថា **ទាន** ។ ក៏ពាក្យថា " **ចេតនា** " លោកពោលហើយ ដោយអំណាចពាក្យជាប្រធាន ។ ក៏សូម្បីសេចក្ដីមិនលោភ ដែលប្រកបដោយចាគចេតនានោះ ក៏ឈ្មោះថា **ទាន** ព្រោះមានចាគចេតនានោះជាគតិ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា " ចេតនា ជាហេតុបរិច្ចាគទាន ដែលមានវត្ថុ ១០ មានបាយ ជាដើម ដែលមានបញ្ញាគ្រឿងដឹង យល់ដោយប្រពៃ ជាមុន ចំពោះបុគ្គលដទៃ ឈ្មោះថា **ទាន**, ម្យ៉ាងទៀត អលោភ: ដែលប្រកបដោយចាគចេតនានោះ ក៏ ឈ្មោះថា **ទាន** " យ៉ាងដូច្នេះ ។*

*(៤) បណ្ដាបទទាំងនោះ បទថា "**សុពុទ្ធិបុព្ជិកា**" មានសេចក្ដីថា មានសម្មាទិដ្ឋិ ប្រព្រឹត្តទៅទាងមុខ ។ មែនពិត សម្មាទិដ្ឋិ ដែលប្រព្រឹត្តទៅ ដោយនយ័ថា " **ទានដែលទាយកឲ្យហើយ រមែងមានផល** " ដូច្នេះ ជាដើម ឈ្មោះថា បញ្ញា ជាគ្រឿងដឹងយល់ ដោយប្រពៃ ក្នុងបទថា " **សុពុទ្ធិបុព្ជិកា** " នេះ ។ សម្មាទិដ្ឋិកបុគ្គល តែ*

មង្គលត្ថទីបនីប្រែ

ម្នាក់គត់ប៉ុណ្ណោះ ជាអ្នកមានលទ្ធិត្រឹមត្រូវថា " ទាន ដែលបុគ្គលឲ្យហើយ រមែងមានផល " ដូច្នេះ ជឿថា " ឈ្មោះថា ទាន ជាធម្មជាតប្រសើរ បណ្ឌិត មានព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ បណ្ឌិត បានបញ្ញត្តទុកហើយ " ដូច្នេះ រមែងឲ្យទាន ដោយខ្លួនឯងខ្លះ បបួលអ្នកដទៃ ក្នុងទាននោះខ្លះ ។ មិច្ឆាទិដ្ឋិកបុគ្គល មិនមែនជាអ្នកដូច្នោះទេ្លយ ។ ពិតមែនដូច្នោះ គ្រូអ្នកធ្វើលទ្ធិ ដូចជាកំពង់ ឈ្មោះអជិត អ្នកមានលទ្ធិខុសថា " ទាន ដែលទាយកឲ្យហើយគ្មានផល " ដូច្នេះ ពោលយ៉ាងនេះ ថា " ការបូជាទាំងឡាយ មានផេះជាទីបំផុត ទាន នេះឯណា, ទាន នោះ គឺបុគ្គលល្ងង់ខ្ជៅ បញ្ញត្តហើយ " ។

*អដ្ឋកថាសាមញ្ញផលសូត្រ និង អដ្ឋកថាទិដ្ឋិសំយុត្ត ក្នុងខន្ធកវគ្គ ថា " បណ្តាបទទាំងនោះ បទថា **ភស្សន្តា** ប្រែថា មានផេះជាទីបំផុត ។ ម្យ៉ាងទៀត ចាលីក៏ន័យនេះដូចគ្នាដែរ ។ បទថា **ហុតិយោ** មានសេចក្តីថា ទានដែលទាយកឲ្យហើយ ផ្សេងគ្នាដោយសក្ការៈ ដើម្បីភ្ជៀវជាដើមឯណា, ទានទាំងអស់នោះ ជាទានសុទ្ធតែមានផេះជាដើម បំផុតទាំងស្រុង ។ អធិប្បាយថា ទាននោះ ជាទានឲ្យផលផ្សេង ទៅជាដទៃទៀត ចាកភាពជាផេះនោះ មិនបានទេ្លយ ។ បទថា **ទត្តុបញ្ញត្តំ** បានដល់ ដែលបុគ្គលល្ងង់*

ពណ៌នាអំពីទាន

ខ្ញៀ គឺមនុស្សពាល បញ្ញត្តទុកហើយ ។ មានពាក្យដែលគ្រូឈ្មោះ អជិត: ពោលថា គ្រូអជិត:នោះសំដែងថា ទាននេះ គឺពួកមនុស្ស ពាល គឺ ពួកអ្នកដែលមិនដឹង បញ្ញត្តទុកហើយ, មិនមែនពួក បណ្ឌិត បញ្ញត្តទេ, មនុស្សពាល រមែងឱ្យទាន, មនុស្សឆ្លាតទទួល (ទាន) " ។

ដីកាសាមញ្ញផលសូត្រ ថា " ជនទាំងឡាយណា ល្ងង់ខ្ញៀ គឺ រង្វេង ហេតុនោះ ជនទាំឡាយនោះ ឈ្មោះថា ជនល្ងង់ខ្ញៀ គឺ ជនអ្នករង្វេង " ។

(ទានវត្ថុ ១០ យ៉ាង)

*(៥) បទថា " **អន្នាទិទសវត្ថុកា** " មានសេចក្ដីថា មាន វត្ថុដែលជាទេយ្យធម៌ ដែលលោកពោលហើយ យ៉ាងដូច្នេះថា ៖*

" ទានវត្ថុទាំងឡាយ ១០ យ៉ាងនេះ គឺ បាយ ទឹក សំពត់ យាន ជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទី អាស្រ័យ គ្រឿងប្រទីប " ។

*អដ្ឋកថា អវុដ្ឋិកសូត្រ ក្នុងតតិយវគ្គ នៃតិកនិបាទ ឥតិវុត្តក: ថា " បណ្ដាបទទាំងនោះ បទថា **អន្នំ** បានដល់ របស់ដែលគួរ ទំពាស៊ី គឺរបស់ដែលគួរបរិភោគគ្រប់ប្រភេទ ។ បទថា **បានំ** បានដល់ ទឹក សម្រាប់ផឹក មានទឹកស្វាយ ជាដើម ។ បទថា **វត្ថំ**

*បានដល់ គ្រឿងបិទបាំង មានសំពត់សម្រាប់ស្លៀកពាក់ជាដើម ។ បទថា **យានំ** បានដល់ របស់ដែលជួយឱ្យទៅបានសម្រេច មានរថយន្ត និង ស្នែងជាដើម ដោយហោចទៅ រហូតដល់ស្បែកជើង ។ បទថា **មាលា** បានដល់ ផ្កាគ្រប់ប្រភេទ ផ្សេងដោយផ្កាឈើ ដែលក្រងហើយ និង ផ្កាឈើដែលមិនបានក្រង ។ បទថា **គន្ធំ** បានដល់ គ្រឿងក្រអូបគ្រប់យ៉ាង និង គ្រឿងឧបករណ៍ នៃគ្រឿងក្រអូប ដែលគេកិនហើយ និង មិនទាន់បានកិន ។ បទថា **វិលេបនំ** បានដល់ គ្រឿងសម្រាប់លាបស្បែក ។ បទថា **សេយ្យា** បានដល់ របស់ដែលគប្បីប្រើដេក មានគ្រែ និង កៅអីជាដើម និងមានសំពត់បាវ និង កម្រាលព្រំជ៍ីវិសេសជាដើម ។ ក៏ដោយ **សេយ្យ** សព្ទ ក្នុង បទថា **សេយ្យាវសថំ** នេះ គប្បីជ្រាបថា លោកបានកំណត់យកហើយ ទាំងអាសនៈផងដែរ ។ បទថា **អាវសថំ** បានដល់ ទីនៅអាស្រ័យសម្រាប់កំចាត់បង់ នូវអន្ត្រាយ មានខ្យល់ និង កំដៅថ្ងៃ ជាដើម ។ បទថា **បទីបេយ្យំ** បានដល់ គ្រឿងឧបករណ៍នៃប្រទីប មានប្រទីបដែលមានដង ជាដើម " ។*

*(៦) អដ្ឋកថានាគសំយុត្ត ក្នុងខន្ធកវគ្គ ថា " បទថា **អន្ទំ** បានដល់ របស់ដែលគួរទំពាស៊ី និង របស់ដែលគួរបរិភោគ ។ បទថា **បានំ** បានដល់ គ្រឿងក្រេបជញ្ជក់គ្រប់មុខ ។ បទថា*

ពណ៌នាអំពីឆាន

វត្ថំ បានដល់ សំពត់សម្រាប់ស្ងៀកពាក់ ។ បទថា ***យានំ*** បានដល់បច្ចយនៃការធ្វើដំណើរគ្រប់យ៉ាង រាប់តាំងពីធត្រ និង ស្បែកជើងជាដើមឡើងទៅ ។ បទថា ***មាលំ*** បានដល់ ផ្កាឈើគ្រប់យ៉ាង មានកម្រងផ្កាម្ងិះជាដើម ។ បទថា ***គន្ធំ*** បានដល់ គ្រឿងលាបគ្រប់យ៉ាង មានចន្ទន៍ជាដើម ។ ២ បទថា ***សយ្យាវសថំ បទីបេយ្យំ*** បានដល់ ទីដេក មានគ្រែ និង កៅអីជាដើម ទីនៅអាស្រ័យ មានផ្ទះមួយខ្នងជាដើម ។ គ្រឿងឧបករណ៍ នៃប្រទីប មានប្រធេះ និង ប្រេងជាដើម " ។

(៧) ដីកានាគសំយុត្តនោះថា " ឈ្មោះថា ***អន្នៈ*** ព្រោះជារបស់ដែលគួរទំពាស៊ី ។ ឈ្មោះថា ***ខជ្ជៈ*** ព្រោះជារបស់ដែលគួរបរិភោគ ។ ឈ្មោះថា ***បានៈ*** ព្រោះជារបស់គួរផឹក ។ ឈ្មោះថា ***សាយនៈ*** ព្រោះជារបស់ដែលគួរក្រេបជញ្ជក់ គឺទឹកផឹក មានទឹកផ្ងែស្ងាយជាដើម ។ ឈ្មោះថា ***និវាសនៈ*** ព្រោះជារបស់ដែលគួរនឹងស្ងៀក ។ ឈ្មោះថា ***បារុបនៈ*** ព្រោះជារបស់ដែលគួរដណ្តប់ ។ ឈ្មោះថា ***យានៈ*** ព្រោះជាគ្រឿងធ្វើដំណើរទៅ គឺយាន មានស្បែកជើងជាដើម ។ ក៏ដោយ ***អាទិ*** សព្ទ ក្នុងបទថា ***ឧបាហនាទិ*** នេះ សង្ត្រោះវហ៍ និង គ្រែស្នែង ជាដើមផងដែរ ។ ព្រះអដ្ឋកថាចារ្យ ពោលថា ***ធត្ថុបាហនំ*** ព្រោះធ្វើអធិប្បាយថា សូម្បីតែធត្រ ក៏ឈ្មោះ

មង្គលត្ថទីបនីប្រែ

ថា ជាហេតុឲ្យសម្រេចការធ្វើដំណើរបានដែរ ព្រោះជាគ្រឿងការពារទុក្ខព្រោះភ្លៀង និង កំដៅថ្ងៃជូច្នេះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា ***យង្ហិ ញ្ចិ គមនប្ឋ ចូយ*** *។*

ដីកាចតុត្ថវគ្គនៃទុតិយបណ្ណាសក: ក្នុងចតុក្កនិបាត អង្គុត្តរ-និកាយថា " វត្ថុណា ដែលបុគ្គលគប្បីច្រកបញ្ចូល គឺគប្បីនាំទៅក្នុងគ្រឿងប្រទីប គឺវត្ថុសម្រាប់ជុតបំភ្ជ ហេតុនោះ វត្ថុនោះ ឈ្មោះ ថា ***ចទីបេយ្យ:*** *(វត្ថុដែលគប្បីជុត ក្នុងប្រទីប) បានដល់ គ្រឿងឧបករណ៍ មានប្រេងជាដើម ។*

(**ចាន: ១៦ យ៉ាង**)

(៨) ដោយនិទ្ទេសនយ ពាក្យថា ***ចាន:*** *មាន ១៦ យ៉ាង ។ ដោយហេតុនោះ ទើបព្រះធម្មទេសនាបតី ពោលថា " ***ចាន:*** ៨ យ៉ាង [១] គឺ ទឹកផ្ទៃស្វាយ ទឹកផ្ទៃព្រីង ទឹកផ្ទៃចេកមានគ្រាប់ ទឹកផ្ទៃចេកឥតគ្រាប់ ទឹកផ្ទៃស្រគំ ទឹកផ្ទៃចន្ទ ទឹកក្រអៅឈូក ទឹកផ្ទៃមាក់ជ្រាង ។* ***ចាន:*** *៨ យ៉ាង សូម្បីជនៃទៀត គឺ ទឹកផ្ទៃសង្ឃ៍រ ទឹកផ្ទៃពុទ្រាតូច ទឹកផ្ទៃពុទ្រាធំ ទឹកដោះជ្ជា ទឹកគីប្រេង ទឹកដោះស្រស់ ទឹកយាគូ (បបរ) ទឹកវស (ស្ងឹកឈើជាដើម) " ។*

បាលីក្នុងនិទ្ទេសនៃតុវដ្ដកសូត្រ ។

១- សុត្តន្ដបិដក ភាគ ទី១០ ទំព័រទី ១១ ។

ពណ៌នារំពីទាន

(៩) អដ្ឋកថាតុវដ្តកស្រូតនោះថា " ទឹក ដែលគេធ្វើអំពីផ្ទែស្វាយខ្ចីក្តី ទុំក្តី ឈ្មោះថា ទឹកផ្ទែស្វាយ ។ បណ្តាផ្ទែស្វាយខ្ចី និង ទុំទាំង ២ យ៉ាងនោះ ភិក្ខុ កាលធ្វើអំពីផ្ទែស្វាយខ្ចី គប្បីជំកំទេចផ្ទែស្វាយខ្ចីៗ ត្រាំ ក្នុងទឹក ហាលថ្ងៃឲ្យស្ងួត (ឆ្អិន) ព្រោះកំដៅព្រះអាទិត្យ រួចហើយ ត្រងផ្សំធ្វើ ដោយទឹកឃ្មុំ ស្ការក្រួស និង កប៊ូរជាដើម ដែលទទួលប្រគេនទុក ក្នុងថ្ងៃនោះ ។ ទឹកដែលគេធ្វើអំពីផ្ទែព្រីង ឈ្មោះថា ទឹកផ្ទែព្រីង ។ ទឹកដែលគេធ្វើអំពីផ្ទែចេក មានគ្រាប់ ឈ្មោះថា ទឹកផ្ទែចេកមានគ្រាប់ ។ ទឹក ដែលគេធ្វើអំពីផ្ទែចេកឥតគ្រាប់ ឈ្មោះថា ទឹកផ្ទែចេកឥតគ្រាប់ ។ ទឹកដែលគេធ្វើអំពីរសជាតិនៃផ្ទែស្រគំ ឈ្មោះថា ទឹកផ្ទែស្រគំ ។ ក៏ទឹកស្រគំនោះ ផ្សំជាមួយនឹងទឹក ទើបគួរ, សុទ្ធ ៗ មិនគួរឡើយ ។ ទឹកដែលគេច្របាច់ផ្ទែចនូ ក្នុងទឹក ធ្វើជូចទឹកផ្ទែស្វាយ ឈ្មោះថា ទឹកផ្ទែចនូ ។ ទឹក ដែលគេកិនក្រអៅ (មើម) នៃឈូកក្រហម និង ឈូកខៀវ ជាដើមធ្វើ ឈ្មោះថាទឹកក្រអៅឈូក ។ ទឹកដែលគេធ្វើអំពីផ្ទែមាក់ប្រាងជូចជាទឹកផ្ទែស្វាយ ឈ្មោះថា ទឹកមាក់ប្រាង ។ ទឹកដែលធ្វើអំពីផ្ទែសង្ឈ៉រ ឈ្មោះថា ទឹកផ្ទែសង្ឈ៉រ ។ ទឹកដែលគេធ្វើអំពីផ្ទែពុទ្រាតូច ឈ្មោះថា ទឹកផ្ទែពុទ្រាតូច ។ ទឹកដែលគេធ្វើពីពុទ្រាធំ ជូចទឹកផ្ទែស្វាយ ឈ្មោះថា ទឹកផ្ទែពុទ្រាធំ ។ បាន: ១១ យ៉ាងនេះ ត្រជាក់ក្តី

មង្គលត្ថទីបនីប្រែ

ផ្ទ្ចិន ព្រោះព្រះអាទិត្យ្ក្ត ក៏សមគួរ ។ ទឹកដោះរាវ ្ចា ឈ្មោះថា ទឹកដោះ ្ចា ។ ទឹកគឺ ្ចេង ដែលធ្ងើអំពី ្ចេងល្ងជាដើម ឈ្មោះថា ទឹកគឺ ្ចេង ។ ទឹកបបរដែលត្រជាក់ជាដើម ឈ្មោះថា ទឹកបបរ ។ ទឹកដោះស្រស់ ឈ្មោះថា ទឹកដោះស្រស់ ។ ទឹក ដែលផ្ស៉ដោយ រស មានបន្ទ្ចត្រាំជាដើម ឈ្មោះថា ទឹករស " ។

ចេតនា ជាហេតុ ្ចេ មានវត្ថុ ១០ ប្រការ មានជ្ចាយជាដើម ប្រកបដោយអលោភ: ដូ្ចចជ្ចានពោលមកនេះ ឈ្មោះ ្ចា ***ទាន*** *ក្នុ្ចមង្គ្ចលបទ ្ចា " **ទាន** " នេះ ។ ព្រោះ ្ចា បុគ្ក្ចល ប្រគ ្ចេ ្ចេ ្ចនូ្ចវ ្ចត្ថុ ្ចរ ្ចេ ្ចខ្ជ ្ចន ្ចសូ ្ចម ្ចៀ ្ចដោ ្ចយ ្ចអ ្ចលោ ្ចភ: ្ចក ្ចៀ ្ចឈ្ម ្ចោ ្ចះ ្ចា ្ចទ ។ ្ចដោ ្ចយ ្ចហេ ្ចតុ ្ចនោ ្ចះ ្ចក ្ចនុ ្ចង ្ចអ ្ចដ ្ចក ្ចា ្ចលោ ្ចកសំ ្ចដោ ្ចយ ្ចក ្ចទ ្ចនេ ្ចតនា ្ចនិ ្ចង ្ចអ ្ចលោ ្ចភ: ្ចទ ្ចាំ ្ចង ២ ្ចយ ្ចាំ ្ចង ្ចនោ ្ចះ ្ចទ ្ចើ ្ចប ្ចជ ្ចន ្ចពោ ្ចល ្ចា " ្ចទ ្ចនេ ្ចតនា ្ចឈ្ម ្ចោ ្ចះ ្ចា ្ចទ ្ចនេ ្ចសេ ្ចចក ្ចី ្ចា "ជ ្ចហេ ្ចតុ ្ចដែ ្ចលបុ ្ចគ ្ចលឲ ្ចយ" ្ចដូ ្ចច ្ចនេ ្ចះ, ្ចអ ្ចលោ ្ចភ: ្ចឈ្ម ្ចោ ្ចះ ្ចា ្ចទ ្ចនេ ្ចសេ ្ចចក ្ចី ្ចា " ្ចរ ្ចមេ ្ចង ្ចប ្ចគ ្ចល ្ចឲ ្ចយ ្ចនូ ្ចវ ្ចត្ថ ្ចរ ្ចេ ្ចខ្ជ ្ចន ្ចដ ្ចល ្ចបុ ្ចគ ្ចលដ ្ចទ " ្ចដូ ្ចច ្ចនេ ្ចះ ។*

(ទាន ប្រកបដោយអង្គ ៦ យ៉ាង)

(១០) ក៏ទ ្ចានេ ្ចះ ្ចនោ ្ចះ ្ចប ្ចកប ្ចដោ ្ចយ ្ចអ ្ចង្ គ ៦ ្ចយ ្ចាំ ្ចង ្ចប ្ចុ ្ចណ ្ចា ្ចះ ្ចរ ្ចមេ ្ចង ្ចជ ្ចា ្ចទ ្ចានមា ្ចនផ ្ចលច្ ្ចើ ្ចន ។ ្ចដោ ្ចយ ្ចហេ ្ចតុ ្ចនោ ្ចះ ្ចទ ្ចើ ្ចប ្ចព ្ចះ ្ចដ ្ចមា ្ចន ្ចព ្ចះ ្ចភា ្ចគ ្ចទ ្ចង ្ចត ្ចា ្ចស ្ចា ្ចា ្ចា " ្ចម ្ចា ្ចលភ ្ចិ ្ចក ្ចុ ្ចទ ្ចាំ ្ចង ្ចទ ្ចា ្ចយ ្ចក ្ចី ្ចទ ្ចក ្ចិ ្ចណ ្ចា ្ចប ្ចកប

ពណ៌នាអំពីទាន

ដោយអង្គ ៦ តើដូចម្តេច? ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ អង្គ របស់អ្នកឲ្យ មាន ៣, អង្គ របស់អ្នកទទួល មាន ៣ ។ ចុះអង្គរបស់ទាយក ៣ តើដូចម្តេចខ្លះ? ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ទាយក ជាអ្នកមានចិត្តត្រេកអរជាមុន អំពីកាលឲ្យ ១, កំពុងតែឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា ១ លុះឲ្យហើយ មានចិត្តរីករាយ ១ ។ នេះជាអង្គ របស់ទាយក ៣ យ៉ាង ។ ចុះអង្គ របស់បដិគ្គាហៈ ទាំងឡាយ មាន ៣ តើដូចម្តេចខ្លះ? ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាករាគៈ ឬ ប្រតិបត្តិ ដើម្បីបន្ទោបង់នូវរាគៈ ១, ប្រាសចាកទោសៈ ឬ ប្រតិបត្តិ ដើម្បីបន្ទោបង់នូវទោសៈ ១, ប្រាសចាកមោហៈ ឬ ប្រតិបត្តិ ដើម្បីបន្ទោបង់មោហៈ ១ ។ នេះជាអង្គ របស់បដិគ្គាហកៈ ទាំងឡាយ មាន ៣ យ៉ាង ។ អង្គ របស់ទាយក មាន ៣, អង្គ របស់បដិគ្គាហកៈ មាន ៣ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល មិនងាយកំណត់ នូវប្រមាណនៃបុណ្យ របស់ទាន ដែលប្រកបដោយអង្គ ៦ យ៉ាង ដូច្នេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមក នូវសេចក្តីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ មានប៉ុណ្ណេះ រមែងប្រព្រឹត្តទៅ

មង្គលត្ថទីបនីប្រែ

ដើម្បីសេចក្ដីប្រាថ្នា ត្រេកអរ គាប់ចត្តិ ជាប្រយោជន៍ ជាសុខ ដូច្នេះបានឡើយ, ដោយពិតនោះ បុណ្យនោះ គ្រាន់តែដល់នូវការ រាប់ថា គំនរនៃបុណ្យដ៏ច្រើន គប្បីរាប់មិនបាន ប្រមាណមិនកើត ដូច្នេះតែប៉ុណ្ណោះបាន ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាបុគ្គល ដែលមិនងាយ កំណត់នូវប្រមាណនៃទឹក ក្នុងមហាសមុទ្ទ ថា ទឹក ប៉ុណ្ណេះអាឡ្រក ក្ដី, ទឹក ប៉ុណ្ណេះរយអាឡ្រក ក្ដី ទឹក ប៉ុណ្ណេះពាន់ អាឡ្រក ក្ដី ទឹក ប៉ុណ្ណេះសែនអាឡ្រក ក្ដី ដូច្នេះបានឡើយ ដោយ ពិតនោះ ទឹកនោះ គ្រាន់តែដល់ នូវការរាប់ថា គំនរនៃទឹកដ៏ច្រើន គប្បីរាប់មិនបាន ប្រមាណមិនកើត ដូច្នេះ តែប៉ុណ្ណោះបាន យ៉ាង ណាមិញ, ម្នាលភិក្ខុទាំងឡាយ បុគ្គល មិនងាយកំណត់ នូវ ប្រមាណនៃបុណ្យ របស់ទក្ខិណា ដែលប្រកបដោយអង្គ ៦ យ៉ាង ដូច្នេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្ដីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅ ដើម្បីស្ថាន សួគ៌ មានប៉ុណ្ណេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាថ្នា ត្រេអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខ ដូច្នេះ បានឡើយ, ដោយពិតនោះ បុណ្យនោះ គ្រាន់តែដល់នូវការរាប់ថា គំនរនៃបុណ្យដ៏ច្រើន គប្បី រាប់មិនបាន ប្រមាណមិនកើត ដូច្នេះ តែប៉ុណ្ណោះបាន ក៏យ៉ាង ដូច្នោះដែរ " ។

ពណ៌នាអំពីទាន

ព្រះមានព្រះភាគ បានត្រាស់សូត្រនេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបត្រាស់គាថាពន្ធនេះ ទៀតថា ៖

(១១) “ ទាយក ជាអ្នកមានចិត្តរីករាយ ក្នុងវេលាមុន អំពីកាលឲ្យ, កំពុងតែឲ្យគប្បីធ្វើចិត្តឲ្យជ្រះថ្លា, លុះឲ្យរួចហើយ ក៏មានចិត្តត្រេកអរ, នេះជាសេចក្ដីបរិបូណ៌ នៃទាន ។ បដិគ្គាហកៈ ជាអ្នកប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ មានសេចក្ដីសង្រួម ជាព្រហ្មចារី ឈ្មោះថា ជាខេត្ត នៃទាន ដ៏បរិបូណ៌ ។ ទានតុ៎ះ ជាទានមានផលច្រើន ដល់ខ្លួនឯងផង ដល់អ្នកដទៃផង ព្រោះខ្ជាប់ខ្ជួយ ដោយខ្លួនឯង ព្រោះឲ្យដោយដៃខ្លួនឯង, អ្នកមានប្រាជ្ញា ជាបណ្ឌិត ជាអ្នកមានសទ្ធា មានចិត្តផ្ទុតស្រឡះ (ចាកសេចក្ដីកំណាញ់) លុះឲ្យទាន យ៉ាងនេះហើយ រមែងចូលដល់ទេវលោក មិនមានការបៀតបៀន ជាសុខ ” ។

ឆឡង្គទានសូត្រ មកក្នុងចតុត្ថវគ្គ នៃបឋមបណ្ណាសកៈ ក្នុងឆក្ខនិបាត អង្គុត្តរនិកាយ ។

*(១២) អដ្ឋកថាឆឡង្គសូត្រថា “បទថា **ឆឡង្គសមន្នាគតា** ប្រែថា ប្រកបដោយអង្គនៃគុណ ៦ ។ ទាន ឈ្មោះថា ទក្ខិណា ។*

មង្គលត្ថទីបនីប្រែ

ច្រើនបទថា **បុព្វេ វ ទានា សុមនោ** មានសេចក្តីថា រមែងជាអ្នកដល់ហើយនូវសោមនស្ស តាំងអំពី ១ ខែ និង កន្ទះខែមកថា អញ នឹងឲ្យទានដូច្នេះ ។ ក៏បណ្តាចេតនាទាំង ៣ យ៉ាងនេះ បុព្វចេតនា បានដល់ ទាយកអ្នកគិត ចាប់ដើមអំពីចាប់ចងស្រែ ថា អញ នឹងឲ្យទាន ដោយផលដែលបានសម្រេចមក អំពីស្រែនេះ ដូច្នេះ តាំងអំពីវេលាដែលកើតឡើងនៃចិត្តថា អញ នឹងឲ្យទាន ដូច្នេះ ។ ចំណែក មុញ្ចនចេតនា ដែលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះ ថា ទាយក កំពុងឲ្យរមែងញ៉ាំងចិត្តឲ្យជ្រះថ្លា រមែងបាន ក្នុងពេលដែលឲ្យទានន៏ុះឯង ។ ចំណែក អបរាបរចេតនានេះថា លុះឲ្យទានរួចហើយ ក៏រមែងមានចិត្តត្រេកអរ ដូច្នេះ រមែងបានដល់ទាយកអ្នកនឹករលึก តាមជាបន្តបន្ទាប់មក ។ បទថា **វីតរាគា** គឺមានរាគៈ ទៅប្រាសហើយ បានដល់ អស់អាសវៈហើយ ។ ២ បទថា **រាគវិនយាយ វ បដិបន្នា** មានសេចក្តីថា ប្រតិបត្តិ នូវបដិបទាគ្រឿងកំចាត់បង់នូវរាគៈ ។ ក៏ទេសនានេះ សំដែងបដិគ្គាហកៈ យ៉ាងឧក្រិដ្ឋ ។ ក៏ទក្ខិណា ដែលឲ្យដល់ព្រះខីណាស្រពតទាំងឡាយ តែមួយពួក ទើបជាទក្ខិណា ប្រកបដោយអង្គ ៦ ក៏មិនមែនទេ, ទក្ខិណា ដែលឲ្យសូម្បីដល់ព្រះអនាគាមី ព្រះសកទាគាមី និង ព្រះសោតាបន្នទាំងឡាយ ដោយហោចទៅ សូម្បីដល់សាមណេរ អ្នក

ពណ៌នាអំពីទាន

កាន់នូវភណ្ឌ: ដែលបូសក្នុងថ្ងៃនោះ ក៏ប្រកបដោយអង្ត ៦ ដូចគ្នាដែរ ។ ព្រោះថា សូម្បីសាមណេរនោះ ឈ្មោះថា បូសហើយ ដើម្បីសោតាបត្តិមគ្ត មែនពិត " ។

*(១៣) ដីកាធឡង្គសូត្រនោះថា "សម្បត្តិទាំងឡាយ រមែងចំរើន គឺរុងរឿង ដោយគុណជាតិនេះ ហេតុនោះ គុណជាតិនេះ ឈ្មោះថា ទក្ខិណា (ជាគ្រឿងចំរើននៃសម្បត្តិ) គឺ បុណ្យដែលសំរេចដោយការបរិច្ចាគ និង ទេយ្យធម៌ ដែលជាគ្រឿងឧបករណ៍ នៃបុណ្យនោះ ។ តែក្នុងបទថា **ទក្ខិណា** នេះ លោកបំណងយកទេយ្យធម៌ ។ ២ បទថា **ឥតោ ឧដ្ឋិតេន** មានសេចក្តីថា កើតឡើងហើយអំពីស្រែនេះ ។ ភគ: គឺបដិគ្គាហក: តែងកំចាត់ដោយធម៌ន៉ុះ ព្រោះហេតុនោះ ធម៌ន៉ុះ ឈ្មោះថា ភគវិនយ: (ជាគ្រឿងកំចាត់ភគ:) គឺបដិបទាជាហេតុកំចាត់បង់ភគ: ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ប្រតិបត្តិ នូវបដិបទា ដើម្បីបន្ទោបង់នូវភគ: " ដូច្នេះ ។*

*(១៤) អដ្ឋកថាបឋមវគ្ត នៃទុតិយបណ្ណាសក: ក្នុងចតុក្ក-និបាត អង្គុត្តរនិបាតថា " ការហូរមកនៃបុណ្យ ឈ្មោះថា បុញ្ញា-ភិសន្ទា អធិប្បាយថា ការចូលដល់នៃបុណ្យ ។ ពាក្យថា **កុសលាភិសន្ទា** ជាពាក្យវេវចន: នៃពាក្យថា **បុញ្ញាភិសន្ទា** នោះឯង ។*

មន្តលត្ថទីបនីប្រែ

ក៏ការហៀរហូរមក នៃបុណ្យទាំងនោះនុ៉ះ ឈ្មោះថា **សុខស្សាហារា** ព្រោះអត្ថថា នាំសេចក្តីសុខមកឲ្យ ឈ្មោះថា **សោវគ្គិកា** ព្រោះអត្ថថា ឲ្យអារម្មណ៍ទាំងឡាយ មានរូបជាដើម ដ៏ប្រសើរ ដោយប្រពៃ ។ ឈ្មោះថា **សុខវិបាកា** ព្រោះអត្ថថា មានវិបាកជាសុខ ។ កិរិយាកើតឡើង ក្នុងស្ថានសួគិ ឈ្មោះថា **សគ្គៈ** ។ ការហូរមកនៃបុណ្យ ឈ្មោះថា **សគ្គសំវត្តនិកា** ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមដើម្បីការកើតឡើង ក្នុងស្ថានសួគិ " ។

ដីកាបឋមវគ្គនោះថា " ម៉ ្យាងទៀត ស្ទឹងនៃបុណ្យ ឈ្មោះថា **បុញ្ញាភិសន្ទា** ។ ក៏បុណ្យទាំងឡាយ ដែលបុគ្គលឲ្យប្រព្រឹត្តទៅជាប់ជានិច្ច ដោយមិនឲ្យដាច់រយៈ ហៅថា **បុញ្ញាភិសន្ទា** ព្រោះអត្ថថា ជាគ្រឿងហៀរហូរមក " ។

(១៥) អដ្ឋកថាឆឡង្គសូត្រ ថា " ២ បទថា **យញ្ញស្ស សម្ឃទា** គឺសេចក្តីបរិបូណិនៃទាន ។ បទថា **សញ្ញតា** គឺឈ្មោះថា ជាអ្នកសង្រួមហើយ ព្រោះសង្រួមសីល ។ បាទគាថា ថា **សយំ អាចមយិត្វាន** មានសេចក្តីថា ព្រោះលាងដៃ និង ជើងហើយ ឲ្យខ្ពុរមាត់ចេញ ដោយខ្ជួនឯង ។ ២ បទថា **សយេហិ បាណិភិ** គឺ ដោយដៃទាំង ២ របស់ខ្ជួន ។ បាលីថា **សកេហិ** ដូច្នេះក៏មាន ។ បទថា **សទ្ធោ** បានដល់ ជឿគុណព្រះរតនត្រៃ ។

ពណ៌នាអំពីទាន

២ បទថា ***មុត្តេន ចេតសា*** បានដល់ មានចិត្តផុតស្រឡះហើយចាកលោភៈ និង មច្ឆរិយៈ ជាដើម ។ បាទគាថា ថា ***អព្យាបជ្ឈំ សុខំ លោកំ*** បានដល់ ទេវលោក ដែលឥតមានសេចក្តីទុក្ខ មានតែសេចក្តីសុខ និង សោមនស្ស យ៉ាងប្រសើរ ” ។

*(១៦) ដីកាធម្មវឌ្ឍនសូត្រនោះថា “ ២ បទថា **បុព្វេ វ ទានា** មានសេចក្តីថា ក្នុងពេលមុន អំពីមុញ្ចនចេតនា គឺចាប់ដើមអំពីការចាត់ចែងឧបករណ៍នៃទាន ។ បទថា **សុមនោ** មានសេចក្តីថា គប្បីជាអ្នកដល់នូវសោមនស្ស ថា អាត្មាអញ នឹងកប់ នូវកំណប់ទ្រព្យ ដែលជាហេតុនៃសម្បត្តិ មានប្រក្រតីជាប់តាម (ខ្លួន) ទៅបាន ។ បាទគាថាថា **ទទំ ចិត្តំ បសាទយេ** មានសេចក្តីថា ទាយកកំពុងឲ្យ ដាក់នូវទេយ្យធម៌ចំពោះ ក្នុងដៃនៃទក្ខិណេយ្យបុគ្គល គប្បីធ្វើចិត្តរបស់ខ្លួន ឲ្យជ្រះថ្លាថា អាត្មាអញ កំពុងតែធ្វើ នូវការកាន់យកខ្លឹមសារ អំពីទ្រព្យដែលមិនមានខ្លឹមសារ ដូច្នេះ ។ បាទគាថាថា **ទត្វា អត្តមនោ ហោតិ** មានសេចក្តីថា ទាយក បរិច្ចាគទេយ្យធម៌ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយហើយ ជាអ្នកមានចិត្តត្រេកអរ រីករាយសប្បាយ គឺ កើតបីតិសោមនស្ស ថា ទាន ដែលឈ្មោះថា បណ្ឌិត បញ្ញត្តទុកហើយ អាត្មាអញ ក៏បានតាមតម្កល់ទុកហើយ, ឱ ! ទាន របស់អាត្មាអញ សម្រេចប្រយោជន៍ ដោយល្អ*

មង្គលត្ថទីបនីប្រែ

ហើយហ្ន៏ ! ។ បទថា **ឯសា** *មានសេចក្ដីថា សេចក្ដីបរិបូណ៌ នៃ ចេតនា ទាំង ៣ យ៉ាង ដែលទៅតាមនូវការជ្រៀកម្ម និង ផល ដែលសោមនស្ស កាន់កាប់ហើយ ទាំងនេះ គឺ បុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនា នេះឯណា, សេចក្ដីបរិបូណ៌ នៃ ចេតនានេះ ។ បទថា* ***សីលសញ្ញមេន*** *មានសេចក្ដីថា ព្រោះ សេចក្ដីសង្រ្ដួម ដែលប្រព្រឹត្តទៅ តាមផ្លូវកាយ និង ផ្លូវវាចា ។ បទថា* ***ហត្ថបាទេ*** *គឺ ដៃ និង ជើង របស់ទក្ខិណេយ្យបុគ្គលទាំង ឦ្ឆាយ ។ ២ បទថា* ***មុខំ ទ្ធ្ការ លេត្ថ*** *មានសេចក្ដីថា ព្រះ ទក្ខិណេយ្យបុគ្គលទាំងឦ្ឆាយនោះឯងខ្ពុរមាត់, អធិប្បាយថា ព្រោះ ឲ្យនូវទ ឹកខ្ពុរមាត់ ដោយខ្លួនឯង " ។*

(១៧) ក្នុងអធិការនៃចេតនានេះ អាចារ្យអ្នកចោទសួរ បាន ពោលថា "ចេតនាទាំង ៣ យ៉ាងនេះ ជាចេតនាឲ្យបដិសន្ធិឬ?" ។ អាចារ្យអ្នកឆ្លើយ ពោលថា " មែនហើយ ចេតនា ទាំង ៣ យ៉ាងនេះ ឲ្យនូវបដិសន្ធិនោះ ពិតមែន " ។ ក៏ក្នុងសេចក្ដីនេះ មានចេតនា ទាំងឦ្ឆាយ របស់សេដ្ឋី ជាអ្នកមិនមានកូន ជាឧទាហរណ៍ ៖

(រឿងអបុត្ត្រកសេដ្ឋី)

បានឮថា ក្នុងអតីតកាល អបុត្ត្រកសេដ្ឋីនោះ ជាសេដ្ឋី ក្នុង ទីក្រុងពារាណសី ថ្ងៃមួយ បានក្រោកឡើង តាំងតែពីព្រឹកព្រលឹម

ពណ៌នាអំពីឌាន

ស្រាង បរិកោគកត្តស្រេចហើយ ក៏ទៅកាន់ព្រះរាជដំណាក់ បានឃើញព្រះបច្ចេកពុទ្ធ ព្រះនាម តគរសិខី ទើបប្រើឲ្យគេប្រគេនបិណ្ឌាបាត ដល់ព្រះបច្ចេកពុទ្ធអង្គនោះហើយ ក៏ចៀសចេញទៅ ។ សេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានតែប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ គប្បីត្រួតពិនិត្យមើល ក្នុងអដ្ឋកថាមយ្ហកសកុណ-ជាតក ក្នុងទុតិយវគ្គ នៃឆក្កនិបាត និង អដ្ឋកថាទុតិយវគ្គ ក្នុងកោសលសំយុត្ត ។

អបុត្តកសេដ្ឋីនោះ ចូលដល់សុគតិប៉ុណ្ណោះ អស់រាវ: ១៤ ដង ដោយកម្មនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដល់ព្រះបាទកោសលរាជថា " បពិត្រមហារាជ សេដ្ឋីគហបតីនោះ បានផ្គត់ផ្គង់នូវព្រះបច្ចេកពុទ្ធ ទ្រង់ព្រះមានតគរសិខី ដោយបិណ្ឌាបាតឯណា, ព្រោះវិបាកនៃកម្មនោះ សេដ្ឋីនោះ បានចូលដល់សុគតិ សួគ៌ ទេវលោក អស់ពេល ៧ ដង, ព្រោះសេសសល់នៃផល នៃកម្មនោះឯង សេដ្ឋីនោះ គ្រប់គ្រងភាពជាសេដ្ឋី អស់រាវ: ៧ ដង ក្នុងទីក្រុងសាវត្ថីនេះឯង " ដូច្នេះ ។

(១៨) អដ្ឋកថាកោសលសំយុត្តនោះថា " បណ្តាបទទាំងនោះ បទថា **បដិបាទេសិ** បានដល់ ចិញ្ចឹមបីបាច់ ព្រមទាំងបិណ្ឌ-បាត, អធិប្បាយថា បានប្រគេនហើយ នូវបិណ្ឌបាត ។ បទថា

មន្តលត្ថនីបនីប្រែ

សត្តក្ខត្តុំ *គឺ អស់វារ: ៧ ដង ។ ក៏ក្នុងពាក្យថា* ***សត្តក្ខត្តុំ*** *នេះ គប្បីជ្រាបសេចក្តី ដោយអំណាចបុព្វចេតនា និង បច្ឆិមចេតនា ។ មែនពិត ក្នុងពេលប្រគេនបិណ្ឌបាតមួយដង ចេតនា តែមួយដូង ប៉ុណ្ណោះ នឹងឲ្យនូវបដិសន្ធិ ២ ដង មិនបានឡើយ ។ ក៏អបុត្តក-សេដ្ឋីនោះ កើតហើយ ក្នុងស្ថានសួគិ អស់វារ: ៧ ដង ក្នុងត្រកូលនៃសេដ្ឋី អស់វារ: ៧ ដង ព្រោះបុព្វចេតនា និង បច្ឆិម-ចេតនា" ។*

ដីកាកោសលសំយុត្តនោះថា "កាលបើសេដ្ឋីពោលថា ចូរអ្នកប្រគេនបិណ្ឌបាត ដល់សមណ: រូបនេះ ដូច្នេះ, សេចក្តីសម្រេចនៃប្រយោជន៍ រមែងមាន ដោយអំណាចនៃជវនវិថី តែ ១ ដូង ប៉ុណ្ណោះ, តាមពិតនោះ ក្នុងពេលប្រគេនបិណ្ឌបាត មួយគ្រានោះ វារ: នៃជវន: ដែលប្រព្រឹត្តទៅ ព្ធដ៏ខាងដើមក្តី វារ: នៃជវន:ដែលប្រព្រឹត្តទៅ ត្រង់កណ្តាល ព្ធដ៏ខាងក្រោយក្តី រមែងមាន, ព្រះអដ្ឋកថាចារ្យ សំដៅយកជវន:ទាំង ២ នោះ ទើបពោល ថា ***បុព្វបច្ឆិមចេតនា*** *ដូច្នេះ" ។*

(១៩) ព្រោះហេតុនោះ ចេតនាទាំង ៣ គប្បីធ្វើឲ្យបានបរិបូណិ ។ ព្រោះថា កាលធ្វើដូច្នោះ ទាន រមែងមានផលច្រើន ។ ដោយហេតុនោះ ក្នុងអដ្ឋកថា មយ្ហកសកុណជាតក លោកពោល

ថា " ក៏ជម្មតាទាន រមែងមានផលច្រើន ដល់បុគ្គលអ្នកអាចដើម្បីនឹងធ្វើ ចេតនាទាំង ៣ ឲ្យបានបរិបូណ៌ប៉ុណ្ណោះ " ដូច្នេះ ។

(២០) ម៉្យាងទៀត ភាវៈនៃទាននោះ ជាទានមានផលច្រើន គប្បីជ្រាប សូម្បីដោយវេលាមសូត្រ និង ទក្ខិណាវិភង្គសូត្រ ។

មែនពិត ក្នុងវេលាមសូត្រ ក្នុងនវកនិបាត អង្គុត្តរនិកាយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវទាន ១៤ យ៉ាង ដោយប្រភេទ ។

មានសេចក្តីថា វេលាមព្រាហ្មណ៍ បានឲ្យហើយនូវអាហារផ្សេងដោយគ្រឿងគួរទំពាស៊ី និង គ្រឿងបរិភោគជាដើម មិនមានប្រមាណ ដល់លោកិយមហាជន អស់រយៈពេល ៧ ឆ្នាំ ៧ ខែ នៅក្នុងថ្ងៃជាទីបញ្ចប់ បានឲ្យភាជន៍មាស ភាជន៍ប្រាក់ និង ភាជន៍សំរិទ្ធិ ដែលពេញទៅដោយរូបិយៈ មាស និង ប្រាក់ តាមលំដាប់ រាប់បានមួយមុខ ៗ ៨៤,០០០ បានឲ្យដំរី រថ នាងកញ្ញា បល្ល័ង្ក ដែលប្រដាប់ ដោយគ្រឿងអលង្ការទាំងពួង រាប់បាន មួយមុខ ៗ ៨៤,០០០ និង បានឲ្យមេគោ និង សំពត់សាដក រាប់បានមួយមុខៗ ៨៤,០០០ ។ ទាននោះ បានឈ្មោះថា មហាទាន ។ ការប្រគេនបាយ ដល់ព្រះសោតាបន្ន មួយរូប មានផលច្រើនជាងមហាទាននោះទៅទៀត ។ ការប្រគេនបាយ ដល់ព្រះសកទាគាមី មួយរូប មានផលច្រើនជាង ប្រគេនបាយ ដល់ព្រះសោតាបន្ន

១០០ រូប ទៅទៀត ។ ប្រគេនបាយ ដល់ព្រះអនាគামី មួយរូប មានផលច្រើនជាងប្រគេនបាយដល់ព្រះសកទាគামី ១០០ រូប ។ ប្រគេនបាយ ដល់ព្រះអរហន្ត មួយរូប មានផលច្រើនជាងប្រគេនបាយ ដល់ព្រះអនាគামី ១០០ រូប ។ ប្រគេនបាយ ដល់បច្ចេក-ពុទ្ធ មួយអង្គ មានផលច្រើនជាងប្រគេនបាយ ដល់ព្រះអរហន្ត ១០០ រូប ។ ប្រគេនបាយ ដល់ព្រះសម្មាសម្ពុទ្ធ មួយអង្គ មានផលច្រើនជាងប្រគេនបាយ ដល់ព្រះបច្ចេកពុទ្ធ ១០០ អង្គ ។ ប្រគេនបាយ ដល់ព្រះសង្ឆដែលមានព្រះពុទ្ធជាប្រធាន មានផលច្រើនជាងប្រគេន ដល់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។ ប្រគេនវិហារ ដល់ព្រះសង្ឆដែលនិមន្តមក អំពីទិសទាំង ៤ មានផលច្រើនជាងប្រគេនបាយ ដល់សង្ឆដែលមានព្រះសម្មាសម្ពុទ្ធ ជាប្រធាននោះទៅទៀត " ដូច្នេះ ។

(២១) ក៏ក្នុងទក្ខិណាវិភង្គសូត្រ ក្នុងចតុត្ថវគ្គ ឧបវិបណ្ណា-សក: ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទានទុក ២១ យ៉ាង ។ ក៏ បណ្ណាទានទាំង ២១ យ៉ាងនោះ ទានណា ដែលបុគ្គលឲ្យហើយ ដល់សត្វតិរច្ឆាន ដើម្បីនឹងចិញ្ចឹម ដោយអំណាចគុណ មានការ ដល់ព្រម ដោយលក្ខណៈជាដើម និង ដោយអំណាចនៃឧបការ: មានការបានទឹកដោះ និង ការចាំថែរក្សាជាដើម, ទាននោះ ព្រះ

ពណ៌នាអំពីទាន

អង្គ មិនទ្រង់កំណត់យកទេ ព្រោះមិនប្រកប ដោយលក្ខណៈ នៃទាន ។ មែនពិត ការបរិច្ចាគវត្ថុ ដែលគប្បីឲ្យរបស់ខ្លួន ដោយអំណាចសេចក្ដីប្រាថ្នា ដើម្បីសេចក្ដីអនុគ្រោះ និងការបូជា ឈ្មោះថា ទាន ។ ការបរិច្ចាគវត្ថុ ដែលគប្បីឲ្យ ដោយអំណាចការភ័យខ្លាច សេចក្ដីស្រលាញ់ និងប្រាថ្នាការសូកប៉ាន់ជាដើម មិនឈ្មោះថា ទាន ទេ ព្រោះជាទានដែលមានទោស ។ វត្ថុ សូម្បីត្រឹមតែពំនូតបាយ កន្ទុះពំនូតឯណា ដែលបុគ្គលឲ្យហើយ, សូម្បីវត្ថុនោះ ព្រះអង្គ ក៏មិនបានកំណត់យកដែរ ព្រោះមិនអាច ក្នុងការឲ្យផលបាន តាមដែលប្រាថ្នាចង់បាន ព្រោះភាវៈនៃទានដែលលួម ដល់សេចក្ដីត្រូវការនៅមិនទាន់បានបរិបូណ៌ ។ ក៏ទានណាដែលបុគ្គលប្រាថ្នាចំពោះផល ដោយនយជាដើម ថា " បុណ្យ ដែលសម្រេចដោយទាននេះឯង ចូរមាន ដើម្បីសេចក្ដីចំរើន នៃប្រយោជន៍សុខតទៅ " ដូច្នេះហើយ បានឲ្យ ដល់បណ្ដាសត្វតិរច្ឆាន មានសុនខ ជ្រូក មាន់ និង ក្អែក ជាដើម សត្វ ឯណាមួយ ដែលខ្លួនបានជួបប្រទះហើយ លួមដល់សេចក្ដីត្រូវការ, ទាន នោះ ព្រះអង្គ ទ្រង់កំណត់យកហើយថា " ទាន ក្នុងសត្វតិរច្ឆាន " ។ ទាន ក្នុងសត្វតិរច្ឆាននោះ ឈ្មោះថា មានអានិសង្ស ១០០ ដង ព្រោះឲ្យអានិសង្ស ៥០០ គឺ ឲ្យអាយុ ក្នុង ១០០ អត្តភាព, ឲ្យពណ៌-

មង្គលត្ថទីបនីប្រែ

សម្បុរ ឲ្យសេចក្ដីសុខ ឲ្យកម្លាំង ឲ្យបដិភាណ: ក្នុង ១០០ អត្ថភាព ។ គប្បីជ្រាបន័យ សូម្បីក្នុងទានដែលខ្ពស់ឡើង ៗ ទៅ យ៉ាងដូច្នេះដែរ ។ មួយទៀត ជនទាំងឡាយ មានព្រោនសំណាញ់ និង អ្នកចាប់ត្រីជាដើម ដែលចិញ្ចឹមជីវិត ដោយការបៀតបៀន សត្វជទៃ ឈ្មោះថា បុថុជ្ជនទ្រុស្តសីល ។ ទានដែលគេឲ្យហើយ ដល់បុថុជ្ជនទ្រុស្តសីលនោះ មានអានិសង្សមួយពាន់ជង ។ ម្យ៉ាងទៀត បុគ្គលអ្នកមានសីល ដូចជាអ្នកមានសីល ជាអ្នកមិនអួតអាង មិនមានមាយា មិនបៀតបៀន នូវសត្វជទៃ ចិញ្ចឹមជីវិត ដោយកសិកម្ម ឬ ពាណិជ្ជកម្ម ដោយធម៌ ស្មាំស្មើ ឈ្មោះថា បុថុជ្ជនមានសីល ។ ទាន ដែលគេឲ្យ ដល់បុថុជ្ជន មានសីលនោះ មានអានិសង្ស មួយសែនជង ។ មួយទៀត តាបស បានអភិញ្ញា ៥ ដែលជាលោកិយ មានប្រក្រតីពោលកម្ម ជាអ្នកបួសខាងក្រៅ អំពីសាសនា ឈ្មោះថា ជាអ្នកគ្មានសេចក្ដីត្រេកអរ ក្នុងកាមទាំងឡាយ, ទាន ដែលគេបានឲ្យហើយ ដល់តាបស អ្នកមិនមានសេចក្ដីត្រេកអរ ក្នុងកាមទាំងឡាយនោះ មានអានិសង្ស មួយសែនកោដិ ។ ទាន ដែលគេបានឲ្យហើយ ដល់អ្នកទទួលទាំងឡាយ ១០ នេះ គឺ ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីសោតាបត្តិ-ផល ដល់ព្រះសោតាបន្ន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បី

ពណ៌នារំពីទាន

សកទាគាមិផល ដល់ព្រះសកទាគាមី ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីអនាគាមិផល ដល់ព្រះអនាគាមី ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីអរហត្តផល ដល់ព្រះអរហន្ត ដល់ព្រះបច្ចេកពុទ្ធ ដល់ព្រះ សម្មាសម្ពុទ្ធ ជាទានដែលរាប់មិនបាន ដោយផល ។

សួរថា " សេចក្តីប្លែកផ្សេងគ្នា នៃទានដែលគេឲ្យហើយ ដល់បដិគ្គាហក:ទាំង ១០ ពួកនោះ តើដូចម្តេចខ្លះ? " ។ ឆ្លើយថា " ភាវ:នៃទាន ដែលគេឲ្យហើយ ចំពោះបុគ្គលអ្នកដែលប្រតិបត្តិ ដើម្បីប្រយោជន៍ដល់សោតាបត្តិផល មានផលរាប់មិនបាន គប្បីជ្រាប ដូចជាទឹកក្នុងចង្អូរ ជារបស់រាប់មិនបានដូច្នោះ ។ ភាវ:នៃ ទាន ដែលបុគ្គលថ្វាយហើយ ចំពោះព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្ន ជាដើម ជាទានមានផលរាប់មិនបាន ដោយ អំណាចគុណខ្ពស់ក្រៃលែងជាងគ្នា គប្បីជ្រាប ដូចជាទឹកក្នុងមហា-នទី និង ក្នុងមហាសមុទ្ទនោះៗ ជារបស់ដែលរាប់មិនបានដូច្នោះ ។ សេចក្តីនេះ គប្បីជ្រាប សូម្បីក្នុងភាវ: នៃអាចម៍ដី ចាប់ដើមអំពី អាចម៍ដី ក្នុងប្រទេស ដែលមានទំហំស្មើនឹងមណ្ឌលលាន នៃផែន ដី រហូតដល់អាចម៍ដី ពេញទាំងផែនដី ប្រមាណមិនបាន ។ មែន ពិត សូម្បីកាលបើមានភាវ:នៃទានទាំងនោះ ជាទានស្មើគ្នា ដោយ ភាវ:ជាទានមានផល រាប់មិនបាន, ភាវ:នៃទាន ជារបស់តិច និង

មន្ទលត្ថទីបនីប្រែ

ច្រើន រមែងមាន ដូចគ្នា គប្បីជ្រាបដូចជាសំវដ្តកប្បជាដើម ជារបស់រាប់មិនបាន និង ភាវៈនៃមហាកប្ប ក៏ជារបស់ដែលរាប់មិនបានដូច្នោះ ។ បណ្តាអ្នកទទួលនោះ អ្នកទទួលទាំងឡាយ ៨ នេះ គឺ ឧបាសកអ្នកដល់នូវព្រះត្រៃសរណៈ, ឧបាសកអ្នកតាំងនៅក្នុងសីល ៥, ឧបាសកអ្នកតាំងនៅ ក្នុងសីល ១០, សាមណេរដែលបួសក្នុងថ្ងៃនោះ, ភិក្ខុ អ្នកគ្រាន់តែបួសហើយភ្លាម, ភិក្ខុ អ្នកដល់ព្រមដោយវត្ត, ភិក្ខុ អ្នកប្រារព្ធវិបស្សនា, ភិក្ខុ អ្នកតាំងនៅ ក្នុងបឋមមគ្ត ឈ្មោះថា ជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ ដល់សោតាបត្តិផល ។ មែនពិត ការចុះកាន់ព្រះសាសនា ក៏ត្រឹមតែដើម្បីរលាស់ចេញនូវទុក្ខ ក្នុងវដ្តសំសារ និង ត្រឹមតែដើម្បីចាក់ធ្ទុះនូវមគ្គតែប៉ុណ្ណោះ, ព្រោះហេតុនោះ កិរិយាដល់ នូវសរណៈ ការសមាទានសិក្ខាបទ បព្វជ្ជា ឧបសម្បទ ការញ្ចាំងសីល ឲ្យបរិបូណិ ការប្រកបរឿយៗ នូវអធិចិត្តសិក្ខា វិបស្សនា ដែលជាចំណែកនៃការត្រាស់ដឹង សរុបទៅ បដិបទាទាំងនេះ ជាការប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយពិត ។ ប្រៀបដូចជាសមាធិភាវនា ដែលជាចំណែក នៃកិរិយាត្រាស់ដឹង រមែងជាឧបនិស្សយ ដោយភាវៈជាបច្ចយ នៃការសម្រេចនូវអរិយមគ្ត ជាបន្តបន្ទាប់គ្នាទៅ យ៉ាងណាមិញ, ការធ្វើសីលឲ្យបានបរិបូណិ

ពណ៌នាអំពីទាន

ឧបសម្ព័ទ បព្វជ្ជា កិរិយាតាំងនៅ ក្នុងសីល ១០ ឬ សីល ៥ របស់ឧបាសក ដែលជាចំណែកនៃការគ្រាស់ដឹង ដោយហេតុនៅ សូម្បីការដល់នូវសរណៈ ដែលជាចំណែកនៃការគ្រាស់ដឹង រមែង ជាឧបនិស្សយ នៃការបានសម្រេចនូវអរិយមគ្គ ក៏យ៉ាងដូច្នោះដែរ ព្រោះហេតុនោះ បដិបទាទាំងអស់នេះ ព្រះដ៏មានព្រះភាគ ទ្រង់ គ្រាស់ថា " ជាសេចក្តីបដិបត្តិ ដើម្បីប្រយោជន៍ ដល់សោតាបត្តិ-ផល " ដូច្នេះ ។ បណ្តាបជិគ្គាហកៈ ទាំង ៨ ពួកនោះ សូម្បីទាន ដែលបុគ្គលឲ្យហើយ ដល់ឧបាសកអ្នកដល់នូវត្រៃសរណៈ ក៏ រមែងមានផលរាប់មិនបាន ។ ក៏សេចក្តីជ្រះថ្លា ដែលញ្ញាណជម្រះ ហើយ ដែលសង្គ្រោះ ដោយសេចក្តីរាប់អាន និង សេចក្តីគោរព ដ៏ច្រើន ក្នុងព្រះដ៏មានព្រះភាគ ក្នុងព្រះសទ្ធម្ម ក្នុងព្រះសង្ឆ ដោយអាការ យ៉ាងប្រសើរក្រៃលែង ដែលប្រព្រឹត្តទៅហើយ ដោយអាការ ថា ភាវៈជាអ្នកមានព្រះរតនត្រៃនោះ ជាខាងដើម ជា អាទិ៍ថា " ព្រះដ៏មានព្រះភាគ ទ្រង់បានគ្រាស់ដឹង ដោយប្រពៃ ចំពោះព្រះអង្គឯង, ព្រះធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់គ្រាស់ សំដែងហើយដោយល្អ, ព្រះសង្ឆជាអ្នកប្រតិបត្តិហើយដោយល្អ" ដូច្នេះ ឈ្មោះថា សរណគមន៍ ។ បុណ្យ ដែលបុគ្គលធ្វើហើយ ក្នុងសន្ធានដែលខ្ជួនអប់រំហើយ ដោយសេចក្តីជ្រះថ្លា ដែលប្រព្រឹត្ត

មង្គលត្ថទីបនីប្រែ

ទៅ ក្នុងវត្ថុ (ព្រះរតនត្រៃ) នេះ រមែងជាទាន មានផលច្រើន ព្រោះកិរិយាដល់ព្រមនៃទេត្ត ដោយប្រការដូច្នេះឯង ។ ទានដែលបុគ្គលឲ្យហើយ ដល់ឧបាសកអ្នកមានសីល ៥ ជាទានមានផលច្រើន ជាងទាននោះ ។ ព្រោះថា សរណគមន៍ គឺ ជាកិរិយាដល់ព្រម នៃអធ្យាស្ស័យ ព្រោះមានសេចក្ដីជ្រះថ្លា ក្នុងវត្ថុ ៣ យ៉ាង (ព្រះរតនត្រៃ) សរុបសេចក្ដីទៅ សីល ៥ របស់ឧបាសក អ្នកប្រាកដដូច្នោះនោះ ក៏គឺសេចក្ដីសង្រ្ទមកាយវាចា ដែលកិរិយាដល់ព្រម នៃអធ្យាស្ស័យឧបត្ថម្ភហើយ ព្រោះហេតុនោះ ទានដែលបុគ្គលបានឲ្យហើយ ចំពោះឧបាសកអ្នកមានសីល ៥ នោះ ទើបឈ្មោះថា មានផលច្រើនយ៉ាងដូច្នេះ ។ ទានដែលបុគ្គលឲ្យហើយ ដល់ឧបាសកអ្នកដែលមានសីល ១០ មានផលច្រើន ជាងទានដែលគេឲ្យ ដល់ឧបាសកអ្នកមានសីល ៥ នោះ ។ មែនពិត សីល ១០ ឈ្មោះថា សីល របស់ឧបាសក យ៉ាងបរិបូណ៌ ព្រោះហេតុនោះ ទាន ដែលបុគ្គលឲ្យហើយ ចំពោះឧបាសកអ្នកមានសីល ១០ នោះ ទើបមានផលច្រើន ដូច្នេះ ។ ទានដែលបុគ្គលប្រគេនហើយ ដល់សាមណេរ មានផលច្រើនជាងទាននោះ ។ ទាន ដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកគ្រាន់តែបួស ស្រេចហើយភ្ជាម មានផលច្រើន ជាងទាននោះ ។ ទាន ដែលបុគ្គល

ពណ៌នាអំពីទាន

ប្រគេនហើយ ដល់ភិក្ខុអ្នកដល់ព្រមដោយវត្ត មានផលច្រើនជាងទាននោះ ។ ទាន ដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកប្រារព្ធវិបស្សនា មានផលច្រើនជាងទាននោះ ។ ក៏ភាវៈនៃទានដែលបុគ្គលឲ្យហើយ ចំពោះបដិគ្គាហកៈនោះៗ ជាទានមានផលច្រើនប្លែកផ្សេងៗ គ្នា ព្រោះភាវៈនៃគុណ មានសីល របស់សាមណេរជាដើម ប្រសើរជាងគ្នាជាអាទិ៍ ព្រោះគុណដែលប្រសើរខ្ពង់ខ្ពស់ជាងគ្នា ដូច្នេះ ។ ក៏ភាវៈនៃលោកអ្នកដែលព្រមព្រៀង ដោយមគ្គឈ្មោះថា ជាអ្នកមានគុណមិនទាន់ពេញបរិបូណិ ព្រោះលោកជាអ្នកមិនទាន់បានសម្រេចកិច្ច ព្រោះសង្កិលេសធម៌ទាំងឡាយ លោកកំពុងតែលះបង់ និង ព្រោះវៅទានធម៌ទាំងឡាយ គឺលោកកំពុងតែចំរើន ដោយចំណែកនោះៗ, ភាវៈនៃលោកអ្នកដែលព្រមព្រៀងដោយផលទាំងឡាយ ឈ្មោះថា ជាអ្នកមានគុណបរិបូណិហើយ ព្រោះលោកជាអ្នកមានកិច្ចសម្រេចហើយ ព្រោះហេតុនោះគប្បីជ្រាបភាវៈនៃលោកអ្នកដែលតាំងនៅ ក្នុងផល ជាខេត្ត ដ៏ខ្ពង់ខ្ពស់ ជាងលោកអ្នកដែលតាំងនៅ ក្នុងមគ្គនោះៗ ។ មួយទៀតភាវៈនៃលោកអ្នកដែលតាំងនៅ ក្នុងមគ្គខាងលើ ជាអ្នកមានគុណខ្ពង់ខ្ពស់ ជាងលោកអ្នកដែលតាំងនៅ ក្នុងមគ្គខាងក្រោម និងភាវៈនៃលោកអ្នកដែលតាំងនៅ ក្នុងផលខាងលើ ជាអ្នកមាន

មង្គលត្ថទីបនីប្រែ

គុណខ្ពង់ខ្ពស់ ជាងលោកអ្នកដែលតាំងនៅ ក្នុងផលទាងក្រោមប្រាកដហើយ មែនពិត ។ ពិតមែនដូច្នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ការ:នៃទាន ដែលបុគ្គលប្រគេនហើយ ដល់ព្រះអរិយ-បុគ្គលអ្នកមានគុណខ្ពង់ខ្ពស់ទាំងឡាយ ជាទានមានផលច្រើន ។ សួរថា " ឈ្មោះថា ការ:នៃលោកអ្នកដែលព្រមព្រៀងដោយមគ្គ ដែលធម្មតាកំណត់ហើយ ដោយលក្ខណ:នៃមគ្គចិត្ត, ក៏ក្នុងខណ:នោះ ការប្រគេនទាន ក្តី ការទទួលទាន ក្តី នឹងមានព្រម យ៉ាងដូចម្តេច? " ។ ឆ្លើយថា " ភិក្ខុអ្នកប្រារព្ធវិបស្សនា ជាអ្នកឈរនៅ ត្រង់មាត់ទ្វារផ្ទះ ឬ អង្គុយនៅ ក្នុងវិហារ និង សាលាធាន់, ទាយកទទួលបាត្រ របស់លោកហើយក៏ដាក់នូវរបស់ដែលគួរធាន់ គួរបរិភោគចូលទៅ, ក្នុងខណ:នោះ ការចេញ (ចាកកិលេស) ដោយមគ្គ រមែងមានដល់ភិក្ខុ, ទាននេះ ឈ្មោះថា ជាទានដែលប្រគេនហើយ ដល់លោកអ្នកដែលព្រមព្រៀងដោយមគ្គ ។ ទាន ១៤ យ៉ាងនេះ ឈ្មោះថា ចាដិបុគ្គលិកទាន ព្រោះធ្វើវិគ្រោះ ថា " ចំពោះបុគ្គល គឺ ចំពោះបុគ្គលម្នាក់ ឈ្មោះថា ចំពោះបុគ្គល, ទាន ដែលឈ្មោះថា ចាដិបុគ្គលិក ព្រោះអត្ថថា គឺ គេឲ្យដល់បុគ្គលចំពោះនោះ " ។ ក៏ទាន ដែលបុគ្គលប្រគេនហើយ ដល់បុគ្គលទាំង ៧ ពួកនេះ គឺ ដល់ព្រះសង្ឆទាំង ២ ផ្នែក ដែលមាន

ពណ៌នាអំពីទាន

ព្រះពុទ្ធជាប្រធាន ដល់ព្រះសង្ឆទាំង ២ ផ្នែកទាំងស្រុង ដល់ព្រះកិក្ខុសង្ឆ ដល់ភិក្ខុនីសង្ឆ ដល់បជិគ្គាហក: ដែលទាយកនិមន្ត ចំពោះ ចាកព្រះកិក្ខុសង្ឆ ដល់បជិគ្គាហក: ដែលទាយកនិមន្ត ចំពោះចាកព្រះភិក្ខុនីសង្ឆ ឈ្មោះថា ទានដែលប្រព្រឹត្តទៅ ក្នុងព្រះសង្ឆ ។ ទាន ដែលប្រព្រឹត្តទៅ ក្នុងព្រះសង្ឆទាំងអស់នោះ មានផលរាប់មិនបាន ។

ដោយហេតុនោះ ក្នុងអដ្ឋកថា ទក្ខិណាវិភង្គសូត្រ ទើបលោកពោលថា "សូម្បីទក្ខិណា ដែលបុគ្គលប្រគេនហើយចំពោះព្រះសង្ឆ មានព្រះពុទ្ធជាប្រធាន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ឈ្មោះថា ជាទានមានផលរាប់មិនបាន ព្រោះការរាប់ ដោយគុណ" ដូច្នេះ ។ មែនពិត ទក្ខិណាដែលប្រព្រឹត្តទៅ ក្នុងព្រះសង្ឆ រមែងមាន ដល់បុគ្គលដែលអាច ដើម្បីនឹងធ្វើ នូវសេចក្តីគោរពកោតក្រែង ចំពោះសង្ឆ ។ តែកិរិយាធ្វើនូវសេចក្តីគោរពកោតក្រែងចំពោះព្រះសង្ឆ ជាកិច្ចដែលធ្វើបានដោយកម្រ ។ ក៏បុគ្គលណា ចាត់ចែងនូវទេយ្យធម៌ ដោយគិតថា " អាត្មាអញនឹងប្រគេននូវទាន ដែលប្រព្រឹត្តទៅក្នុងព្រះសង្ឆ " ដូច្នេះ ទៅកាន់វត្តហើយពោលថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ ឲ្យនូវព្រះថេរ: មួយរូប ចំពោះចាកព្រះសង្ឆ " ដូច្នេះ, លុះដល់បាន

មង្គលត្ថទីបនីប្រែ

សាមណេរ អំពីព្រះសង្ឆហើយ ក៏រមែងដល់ នូវភាពជាដទៃវិញ អាក់អន់ចិត្ត ថា "អញបានសាមណេរ" ដូច្នេះ, ទក្ខិណា របស់បុគ្គលនោះ រមែងមិនឈ្មោះថា ប្រព្រឹត្តទៅ ក្នុងព្រះសង្ឆទេ ។ សូម្បីកាលបើបានព្រះមហាថេរហើយ ទោះបីជាធ្វើសេចក្តីសោមនស្ស ឲ្យកើតឡើង ថា " អាត្មាអញ បានព្រះមហាថេរ " ដូច្នេះ, ទក្ខិណានោះ ក៏មិនឈ្មោះថា ប្រព្រឹត្តទៅ ក្នុងព្រះសង្ឆ ដូចគ្នាដែរ ។ ចំណែកបុគ្គលណា បាននូវបដិគ្គាហក: ជាសាមណេរ ឬ ឧបសម្ផន្ន ជាកំលោះ ឬ ព្រះថេរ: ជាពាល ឬ បណ្ឌិត រូបណាមួយ អំពីព្រះសង្ឆ ជាអ្នកមិនមានសេចក្តីសង្ស័យ រមែងអាច ដើម្បីនឹងធ្វើ នូវសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឆ ថា "អាត្មាអញប្រគេនដល់ព្រះសង្ឆ" ដូច្នេះ, ទក្ខិណា របស់បុគ្គលនោះ រមែងឈ្មោះថា ជាទានដែលប្រព្រឹត្តទៅ ក្នុងព្រះសង្ឆ ។ សមណ: ដែលទាយកនិមន្ត ចំពោះចាកព្រះសង្ឆ ជាបុថុជ្ជន, ចាជិបុគ្គលិក ជាព្រះសោតាបន្ន, កាលបើបុគ្គល អាចធ្វើសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឆ, ទាន ដែលបុគ្គលប្រគេនហើយ ចំពោះសមណ: ដែលជាបុថុជ្ជន ក៏ជាទានមានផលច្រើនជាង ។ សូម្បីក្នុងពាក្យជាដើម ថា " សមណ: ដែលទាយកនិមន្ត ចំពោះចាកសង្ឆ ជាព្រះសោតាបន្ន ចាជិគ្គាហក: ជាព្រះសកទាគាមី "

ពណ៌នាអំពីទាន

ក៏ន័យនេះ ដូចគ្នាដែរ ។ មែនពិត កាលបើបុគ្គលអាច ដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែង ចំពោះព្រះសង្ឆ, ទានដែលបុគ្គលប្រគេនហើយ សូម្បីចំពោះសមណៈទ្រុស្តសីល ដែលគេនិមន្តចំពោះ (ចាកសង្ឆ) ក៏ជាទានមានផលច្រើនជាង ទានដែលគេប្រគេន ចំពោះព្រខីណាស្រព ដោយពិត ។ ក៏ព្រះតម្រាស់ណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រព្រះមហារាជ ទាន ដែលបុគ្គលប្រគេនហើយ ដល់សមណៈ អ្នកមានសីល ជាទានមានផលច្រើន, ដែលប្រគេនហើយ ដល់សមណៈអ្នកទ្រុស្តសីល មិនមានផលច្រើន យ៉ាងដូច្នោះទេ ដូច្នេះ, ព្រះតម្រាស់នោះ ព្រះអង្គទ្រង់ត្រាស់ លះបង់ន័យនេះចោល " ។

(២២) ដីកាទក្ខិណាវិភង្គសូត្រនោះ ថា " បទថា **គុណ-សង្ខាយ** មានសេចក្តីថា ព្រោះការគណនារាប់ ដោយផលអានិស្ស គឺព្រោះភាវៈនៃទានមានផលច្រើន ។ ទក្ខិណា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានផលរាប់មិនបាន ក៏ព្រោះភាវៈនៃទក្ខិណានោះ គឺបុគ្គលប្រគេនហើយ ចំពោះព្រះសង្ឆ ។ ក៏ការប្រគេន ចំពោះព្រះសង្ឆ រមែងមាន ដោយវិធីណា, ដើម្បីនឹងសំដែង នូវវិធីនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យជាដើមថា **សង្ឆគតា ទក្ខិណា ហិ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា

មន្តលត្ថទីបនីប្រែ

ចិតិការំ បានដល់ សេចក្តីគោរព ។ ចាកព្រះសង្ឆ មិនមែនចាកបុគ្គល ។ បទថា ***អញ្ញថត្តំ*** មានសេចក្តីថា មិនញ្ញុំងចិត្តឲ្យកើតឡើង យ៉ាងនេះថា ទាន ជាទាន គឺអាត្មាអញបានឲ្យហើយដល់បុគ្គលនេះ ដូច្នេះ ហើយចាត់ចែងនូវទេយ្យធម៌ ដោយគិតថា អាត្មាអញនឹងប្រគេន ដល់ព្រះសង្ឆ ដូច្នេះ រមែងដល់នូវភាវៈជាអ្នកមានចិត្តផ្សេង (អន់ចិត្ត) ថា ទាន ឈ្មោះថាជាទានដែលអាត្មាអញគប្បីប្រគេនដល់សាមណេរ ដូច្នេះ, ព្រោះហេតុនោះ ទក្ខិណារបស់បុគ្គលនោះ រមែងមិនឈ្មោះថា ជាទានដែលប្រព្រឹត្តទៅ ក្នុងព្រះសង្ឆឡើយ, ទក្ខិណា រមែងមិនឈ្មោះថា ប្រព្រឹត្តទៅ ក្នុងព្រះសង្ឆបាន ក៏ព្រោះធ្វើចិត្តឲ្យប្រែប្រួលទៅដោយអំណាចនៃបុគ្គល ។ ២ បទថា ***និព្វេមតិកោ ហុត្វា*** មានសេចក្តីថា មិនញ្ញុំងសេចក្តីសង្ឆ័យ ឲ្យកើតឡើងថា ទាន ជាទានដែលអាត្មាអញ បានឲ្យហើយដល់បុគ្គលនេះ ឬ ក៏មិនបានឲ្យហើយឬទេហ្នឹ? ។ ២ បទថា ***សង្ឆេ ចិតិការំ*** មានសេចក្តីថា កាលបើបុគ្គលនឹករលឹក ដល់គុណនៃព្រះសង្ឆ មានភាវៈជាអ្នកប្រតិបត្តិប្រពៃជាដើម ប្រគេនដោយអំណាចនៃសេចក្តីគោរព ដែលកើតឡើងហើយ ក្នុងបុគ្គលនោះ ប្រៀបដូចជាប្រគេន នៅចំពោះមុខព្រះសង្ឆ ដោយសេចក្តីជ្រះថ្នា ក្នុងសង្ឆគុណ, ទាន ដែលបុគ្គលប្រគេនហើយ ចំពោះ

ពណ៌នាអំពីទាន

សមណៈ ជាបុថុជ្ជន ក៏រមែងមានផលច្រើនជាង ។ ទាន ដែលបុគ្គលប្រគេនហើយ ចំពោះសមណៈអ្នកទ្រុស្តសីល រមែងជាទានមានផលច្រើនជាង ទានដែលគេប្រគេនចំពោះព្រះខីណាស្រព ដោយពិត ព្រោះសមណៈនោះ គេនិមន្ត ចំពោះ អំពីព្រះសង្ឆ និង ព្រោះគេប្រគេនហើយ ដោយគិត យ៉ាងនេះថា អាត្មាអញ នឹងប្រគេន ដល់ព្រះសង្ឆ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគត មិនពោលនូវបាដិ-បុគ្គលិកទានថា ជាទានមានផលច្រើន ជាងទក្ខិណា ដែលប្រព្រឹត្ត ទៅ ក្នុងព្រះសង្ឆ ដោយបរិយាយណាមួយសោះឡើយ ដូច្នេះ ។ ព្រះអដ្ឋកថាចារ្យចោទសួរថា ប្រសិនបើទានដែលគេប្រគេនហើយ សូម្បីចំពោះសមណៈទ្រុស្តសីល ដែលគេនិមន្តចំពោះ អំពីព្រះសង្ឆ រមែងជាទានមានផលច្រើនជាង ទានដែលបុគ្គលប្រគេនហើយចំពោះព្រះខីណាស្រព, កាលបើមានយ៉ាងដូច្នោះ, ពាក្យថា បពិត្រព្រះមហារាជ ទាន ដែលបុគ្គលប្រគេនហើយ ដល់បុគ្គលអ្នកមានសីលនុ៎ះឯង ជាទានមានផលច្រើន, ដែលប្រគេន ដល់បុគ្គលទ្រុស្តសីល មិនមានផលច្រើន យ៉ាងដូច្នោះទេ ដូច្នេះ នេះតើយ៉ាងដូចម្តេចហ្ន៎ ! ដូច្នេះហើយ ទើបពោលថា ពាក្យនោះ ព្រះដ៏មានព្រះភាគត្រាស់ហើយ លះបង់នូវនន័យនេះចាល " ដូច្នេះ ។

មន្តលត្ថទីបនីប្រែ

ឆ្លើយថា ពាក្យនោះ ព្រះអង្គទ្រង់លះបង់ចោលនូវវិធីនិមន្តចំពោះ អំពីព្រះសង្ឆ ហើយត្រាស់ ដោយអំណាចការនិមន្តសមណ: អ្នកទ្រុស្តសីល តែម្យ៉ាង ដូច្នេះ " ។

(២៣) ទាននោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃ កិរិយាបានសម្រេចផលដ៏វិសេស ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និងសម្បរាយភព មានភាពជាអ្នកជាទីស្រលាញ់ពេញចិត្ត នៃជនច្រើនជាដើម ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់សេនាបតី ឈ្មោះថាសីហ: ទើបទ្រង់ត្រាស់ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយថា " ម្នាលសីហ: ទាយក អ្នកម្ចាស់ទាន រមែងជាទីស្រលាញ់ ជាទីពេញចិត្ត របស់ជនច្រើន, ម្នាលសីហ: ទាយកអ្នកម្ចាស់ទាន រមែងជាទីស្រលាញ់ ជាទីពេញចិត្ត របស់ជនច្រើន ដោយហេតុណា, ម្នាលសីហ: ហេតុនេះឯង ជាផលនៃទានដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯង ។ ម្នាលសីហ: មួយទៀត ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកទាយកអ្នកម្ចាស់ទាន, ម្នាលសីហ: ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកទាយកម្ចាស់ទាន ដោយហេតុណា, ម្នាលសីហ: ហេតុនេះឯង ជាផលនៃទានដែលបុគ្គលគប្បីឃើញ ជាក់ច្បាស់ ដោយខ្លួនឯង ។ ម្នាលសីហ: មួយទៀត កិត្តិសព្ទ ដ៏

ពណ៌នាអំពីទាន

ពីរោះ របស់ទាយកអ្នកម្ចាស់ទាន រមែងខ្ជះខ្ជាយទៅ, ម្នាលសីហៈ កិត្តិសព្ទដ៏ពីរោះ របស់អ្នកម្ចាស់ទាន រមែងខ្ជះខ្ជាយទៅ ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង។ ម្នាលសីហៈ មួយទៀត ទាយកអ្នកម្ចាស់ទាន ចូលទៅកាន់បរិសទ្យ ណាមួយ ទោះជា ខត្តិយ-បរិសទ្យ ក្តី ព្រាហ្មណបរិសទ្យ ក្តី គហបតិបរិសទ្យ ក្តី សមណ-បរិសទ្យ ក្តី, រមែងជាអ្នកក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ចូលទៅកាន់បរិសទ្យនោះ, ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ចូលទៅកាន់បរិសទ្យ ណាមួយ ទោះជា ខត្តិយបរិសទ្យ ក្តី ព្រាហ្មណ-បរិសទ្យ ក្តី គហបតិបរិសទ្យ ក្តី សមណបរិសទ្យ ក្តី, ជាអ្នកក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស រមែងចូលទៅ កាន់បរិសទ្យនោះ ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ទាយកអ្នកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក, ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទាន មានក្នុងលោកខាងមុខ " ដូច្នេះ ។

មង្គលត្ថទីបនីប្រែ

ក៏ព្រះមានព្រះភាគ លុះទ្រង់ត្រាស់ យ៉ាងនេះហើយ ទើបទ្រង់បានត្រាស់ នូវព្រះគាថាទាំងនេះ ថា ៖

" ទាយកអ្នកឲ្យទាន រមែងជាទីស្រលាញ់ (របស់ជនច្រើនផង), ពួកសប្បុរសជាច្រើន រមែងរាប់រកទាយកនោះផង, ទាយកនោះ រមែងដល់នូវកិត្តិសព្ទផង, យសរមែងចម្រើនដល់ទាយកនោះផង, ឥរជន អ្នកមិនមានសេចក្តីកំណាញ់ ជាអ្នកមិនមានសេចក្តីអៀនខ្មាស មានសេចក្តីក្លៀវក្លា ចូលទៅកាន់បរិសទ្យ, ព្រោះហេតុនោះឯង បណ្ឌិតទាំងឡាយ អ្នកស្វែងរកសេចក្តីសុខ ត្រូវលះបង់នូវមន្ទិល គឺសេចក្តីកំណាញ់ ហើយឲ្យនូវទានទាំងឡាយ, បណ្ឌិតទាំងឡាយនោះ ស្ថិតនៅ ក្នុងស្ថានត្រៃត្រឿ អស់កាលដ៏យូរអង្វែង, បណ្ឌិតទាំងនោះ ដល់នូវភាពជាមួយគ្នានៃពួកទេវតា រមែងរីករាយសប្បាយ, បណ្ឌិតទាំងនោះ ជាអ្នកមានឱកាសធ្វើហើយ មានកុសលធ្វើហើយ ច្យុតអំពីលោកនេះ មានរស្មីខ្លួនឯង អន្ទោលទៅ ក្នុងទីជាទីត្រេកអរ, បណ្ឌិតទាំងនោះ ស្កប់ស្កល់ហើយ ដោយកាមគុណទាំង ៥ ត្រេកអររីករាយសប្បាយ ក្នុងទីជាទីត្រេកអរនោះ ។ ពួកសាវ័កទាំងអស់

ពណ៌នាអំពីទាន

របស់ព្រះសុគត ធ្វើតាមពាក្យ របស់ព្រះតថាគត ព្រះអង្គ
មិនជាប់ ដោយអកុសលធម៌ ទ្រង់ប្រកបដោយតាទិគុណ
ហើយ រមែងរីករាយសប្បាយ [១] ។

សីហសូត្រ ក្នុងសុមនវគ្គទី ៤ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ចប់ ។

*(២៤) ក្នុងអដ្ឋកថា អដ្ឋកនិបាត អង្គុត្តរនិកាយ លោកពោលថា " ពាក្យថា **សីហោ សេនាបតី** បានដល់ ព្រះរាជកុមារ ទ្រង់ព្រះនាមយ៉ាងនោះ ទ្រង់ជាមេបញ្ជាការនៃកងទ័ព ។ មែនពិត ក្នុងក្រុងវេសាលី មានព្រះរាជា ៧,៧០៧ ព្រះអង្គ, ព្រះរាជាទាំងអស់ព្រះអង្គនោះ ទ្រង់ប្រជុំប្រឹក្សាគ្នាថា សូមអ្នកទាំងឡាយជ្រើសរើសរកនូវបុគ្គលម្នាក់ ដែលអង់អាច ដើម្បីនឹងយកចិត្ត របស់ពួកប្រជាជន ហើយរៀបចាត់ចែងរដ្ឋធានីបាន ដូច្នេះ កាលជ្រើសរើសរក ក៏ទ្រង់ឃើញនូវសីហរាជកុមារ ហើយទ្រង់ធ្វើសេចក្តីសម្រេចព្រះទ័យថា ព្រះសីហរាជកុមារអង្គនេះ នឹងអាច ដូច្នេះ ទ្រង់បានព្រះរាជទាន នូវឆត្រនៃសេនាបតី តំណែង ដែលមានពណ៌កែវមណីក្រហម ដែលស្រោប ដោយសំពត់កម្ពល ដល់សីហរាជកុមារនោះ " ។*

*(២៥) អដ្ឋកថាសីហសូត្រនោះ ថា " បទថា **សន្ទិដ្ឋិកំ** បាន*

១- សុត្តន្តបិដក ភាគទី ៤៤ ទំព័រទី ៧៩ ។

មន្តលត្ថនីបនីប្រែ

ដល់ ដែលបុគ្គលគប្បីឃើញ ដោយខ្លួនឯង ។ បទថា **ទាយកោ** បានដល់ អ្នកអង់អាចក្នុងទាន ។ អធិប្បាយថា អ្នកនោះមិនឈប់នៅ ដោយហេតុត្រឹមតែសេចក្តីជឿថា ទាន ញ្ចាំងប្រយោជន៍ ឲ្យសម្រេចប៉ុណ្ណោះទេ រមែងអាចសូម្បីលះបង់បានផង ដូច្នេះ ។ បទថា **ទានបតី** មានសេចក្តីថា បុគ្គលរមែងឲ្យនូវទានណា, រមែងជាម្ចាស់នៃទាននោះឲ្យ, មិនមែនជាខ្ចុំបម្រើនៃទាននោះ, មិនមែនជាសំឡាញ់នៃទាននោះឲ្យទេ ។ មែនពិត បុគ្គលណា បរិភោគនូវរបស់ដែលល្អដោយខ្លួនឯង (តែ) ឲ្យនូវរបស់ដែលមិនល្អ ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថាជាខ្ចុំបម្រើនៃទេយ្យធម៌ ពោលគឺទាន ហើយឲ្យ ។ បុគ្គលណា បរិភោគនូវរបស់ណា ដោយខ្លួនឯង ក៏ឲ្យនូវរបស់នោះឯង (ដល់អ្នកដទៃ), បុគ្គលនោះ ឈ្មោះថាជាសំឡាញ់នៃទានហើយឲ្យ ។ ចំណែក បុគ្គលណា ខ្លួនឯងញ្ចាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយរបស់ឯណាមួយ (តែ) ឲ្យនូវរបស់ដែលល្អ ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាម្ចាស់ ជាធំជាចៅហ្វាយនាយ នៃទានឲ្យ ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកបុគ្គលអ្នកប្រាកដដូច្នេះ ទើបទ្រង់ត្រាស់ថា **ទានបតី** ដូច្នេះ ។ បទថា **អមង្ក្ពុភូតោ** គឺ មិនមែនជាអ្នកប្រាសចាក តេជបារមី ។ បទថា **វិសារទោ** គឺជាអ្នកដល់នូវសោមន្ស ដែលសម្បយុត្ត ដោយ

ពណ៌នាអំពីទាន

ញាណ ។ ២ បទថា **សហព្យតំ គតា** មានសេចក្តីថា ដល់នូវភាពជាមួយគ្នា គឺភាពជាពួកតែមួយ ។ បទថា **កតាវកាសា** មានសេចក្តីថា ឈ្មោះថា ជាអ្នកមានឱកាសដែលធ្វើហើយ ព្រោះជាអ្នកធ្វើកម្ម ដែលជាហេតុមានឱកាស ក្នុងនឱវនោះ ។ ក៏កម្មនោះជាកុសលតែម៉ាង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ជាអ្នកមានកុសល បានធ្វើហើយដូច្នេះ ។ បទថា **មោទរេ** ប្រែថា រមែងត្រេអរ គឺ រីករាយសប្បាយ ។ បទថា **អសិតស្ស** មានសេចក្តីថា របស់ព្រះតថាគតព្រះអង្ត គឺតណ្ហាមិនអាស្រ័យហើយ ។ បទថា **តាទិនោ** បានដល់អ្នកដល់នូវលក្ខណៈ នៃបុគ្គលមិនញាប់ញ័រ " ។

(២៦) ដីកាសីហសូត្រនោះថា " បទថា **សន្ទិដ្ឋិកំ** មានសេចក្តីថា ឈ្មោះថា គឺបុគ្គលគប្បីឃើញ ព្រោះភាវៈជាផលដែលមិនប្រព្រឹត្តទៅ ក្នុងសម្បរាយភព គឺ ដែលបុគ្គលគប្បីសោយដោយខ្លួនឯង ជារបស់ប្រាកដច្បាស់ចំពោះខ្លួន គឺប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន ។ ច្រើនបទថា **សាហុ ទានន្តិ សទ្ធាមត្តកេនេវ តិដ្ឋតិ** មានសេចក្តីថា ទាយកនោះ រមែង (មិន) ឈប់នៅនឹង ដោយហេតុត្រឹមតែសេចក្តីជឿ យ៉ាងដូច្នេះថា ឈ្មោះថា ទាន ជាធម្មជាតឲ្យសម្រេចប្រយោជន៍ ជារបស់ប្រសើរ ដែលបណ្ឌិតទាំងឡាយ

មន្តលត្ថនីបនីប្រែ

មានព្រះពុទ្ធជាដើម ទ្រង់ត្រាស់សរសើរហើយ ។ ច្រើនបទថា **យំ ទានំ ទេតិ** មានសេចក្តីថា បុគ្គលរមែងឲ្យនូវទេយ្យធម៌ណា ដល់បុគ្គលដទៃ ។ ច្រើនបទថា **តស្ស បតី ហុត្វា ទេតិ** មានសេចក្តីថា ទាយកគ្របសង្កត់នូវសេចក្តីលោភលន់បាន ដោយល្អ ឈ្មោះថា ជាម្ចាស់នៃទាននោះឲ្យ ព្រោះភាវៈនៃខ្លួន គឺសេចក្តីលោភនោះគប្បីគ្របសង្កត់មិនបាន ។ ព្រះអដ្ឋកថាចារ្យ ពោលថា **យោ ហិ** ដូច្នេះជាដើម ដើម្បីនឹងសម្តែង នូវពាក្យទាំង ២ យ៉ាងនោះ គឺ **ន ទាសោ ន សហាយោ** ដោយន័យដែលអនុលោម និង បដិលោម ។ ទាយក ឈ្មោះថា ជាខ្ទុំបម្រើ (នៃទាន) ឲ្យ ព្រោះភាវៈនៃខ្លួនជាអ្នកខិតចូលទៅជិត នៃភាពជាខ្ទុំបម្រើនៃតណ្ហា ។ ទាយក ឈ្មោះថា ជាសំឡាញ់ (នៃទាន) ឲ្យ ព្រោះលះបង់នូវភាវៈ នៃរបស់ដែលមិនជាទីស្រលាញ់ នៃទេយ្យធម៌នោះចោលបាន ។ ទាយក ឈ្មោះថា ជាម្ចាស់ (នៃទាន) ឲ្យ ព្រោះរើបម្រះខ្លួនចេញអំពីភាព ជាខ្ទុំបម្រើនៃតណ្ហា ក្នុងទាននោះហើយ ប្រព្រឹត្តគ្របសង្កត់ ។

ម៉ាងទៀត បុគ្គលណា ឈ្មោះថា ជាទាយក ព្រោះឲ្យទានជាប្រក្រតី, បុគ្គលនោះ ដោយប្រភេទនៃកិរិយាប្រព្រឹត្តិទៅ ក្នុងទាន រមែងមាន ៣ ប្រការគឺ ជាខ្ទុំបម្រើនៃទាន ជាសំឡាញ់នៃទាន ជាម្ចាស់នៃទាន, ដើម្បីនឹងសម្តែងវែកញែក បំបែក នូវភាវៈនៃ

ពណ៌នាអំពីទាន

ទាយក ជាអ្នកមាន ៣ ប្រភេទនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យថា ***យោ ហិ*** *ដូច្នេះជាដើម ។ ចាយ និង ទឹកជាដើម ឈ្មោះថា ទាន ព្រោះអត្ថថា ជារបស់ដែលគប្បីឲ្យ ។ បណ្តាទាយកទាំង ៣ ប្រភេទនោះ បុគ្គលបរិភោគនូវវត្ថុណា ដោយខ្លួនឯង, បុគ្គលនោះ ឈ្មោះថា ប្រៀបដូចជាខ្ញុំបម្រើ ព្រោះប្រព្រឹត្តទៅក្នុងអំណាចនៃវត្ថុនោះ ព្រោះភាវៈនៃខ្លួន ត្រូវតណ្ហាគ្របសង្កត់, ឈ្មោះថាប្រៀបដូចជាខ្ញុំបម្រើ ព្រោះប្រព្រឹត្តទៅ ក្នុងអំណាចនៃវត្ថុដែលខ្លួនមិនឲ្យដល់ពួកជនដទៃ ។ ក្នុងបទថា* ***តត្ត*** *ព្រះអដ្ឋកថាចារ្យពោលពាក្យនេះថា ជាខ្ញុំបម្រើនៃទេយ្យធម៌ ពោលគឺ ការឲ្យ ដូច្នេះ ក៏ព្រោះភាវៈនៃចាយ និង ទឹកជាដើម ជារបស់ស្មើគ្នា ។ ទាយកឈ្មោះថា ជាសំឡាញ់ឲ្យ ព្រោះចាត់ចែង នូវរបស់ដែលខ្លួនគប្បីបរិភោគ និង របស់ដែលខ្លួនគប្បីឲ្យ ដល់ពួកជនដទៃទុក ដោយភាពស្មើ ១ គ្នា ។ ទាយក ឈ្មោះថាជាម្ចាស់ (នៃទាន) ឲ្យ ព្រោះមិនប្រព្រឹត្តទៅ ក្នុងអំណាចនៃទេយ្យធម៌ ដោយខ្លួនឯង (ប៉ុន្តែ) ញ៉ាំងទេយ្យធម៌នោះ ឲ្យប្រព្រឹត្តទៅ ក្នុងអំណាចរបស់ខ្លួនទៅវិញ ។*

នយមួយទៀត បុគ្គលណា ខ្លួនឯង បរិភោគ នូវវត្ថុ ដ៏ប្រសើរ ហើយឲ្យនូវវត្ថុមិនប្រសើរ ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាខ្ញុំបម្រើ នៃទាន ព្រោះដល់នូវភាវៈជាបុគ្គលថោកទាប

មង្គលត្ថទីបនីប្រែ

ដែលមានការឲ្យរបស់ថោកទាបនោះ ជានិមិត្ត ។ បុគ្គលណា ខ្លួនឯង បរិភោគវត្ថុបែបណា ឲ្យនូវវត្ថុបែបនោះឯង ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាសំឡាញ់នៃទាន ព្រោះដល់នូវភាពជាអ្នកស្មើគ្នា ដោយលះបង់នូវភាវៈ នៃបុគ្គលជាអ្នកថោកទាប និងជាអ្នកខ្ពង់ខ្ពស់ ដែលមានការឲ្យរបស់ដែលស្មើគ្នានោះ ជានិមិត្ត ។ បុគ្គលណា បរិភោគ នូវវត្ថុថោកទាប ដោយខ្លួនឯង ហើយឲ្យនូវវត្ថុដ៏ប្រណីត ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាម្ចាស់នៃទាន ព្រោះដល់នូវភាពជាបុគ្គលដ៏ប្រសើរ មានការឲ្យនូវវត្ថុ ដ៏ប្រណីតនោះ ជានិមិត្ត ។ មិនមែនជាអ្នកប្រាសចាកតេជ ព្រោះសេចក្តីសម្រេចនៃតេជទេ ។ ទាយកណា តែងទៅ គឺធ្វើដំណើរទៅរួមជាមួយគ្នា ហេតុនោះ ទាយកនោះ ឈ្មោះថា អ្នកទៅរួមគ្នា គឺធ្វើដំណើរទៅរួមគ្នា, ភាវៈនៃបុគ្គលអ្នកទៅរួមគ្នានោះ ឈ្មោះថា **សហាយតា** គឺ ធ្វើដំណើរទៅរួមគ្នា ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **សហការំ ឯកីការំ គតា** ដូច្នេះ ។ មួយទៀត បទថា **អសិតស្ស** បានដល់ ជាអ្នកដែលគ្រឿងចងរឹត គឺតណ្ហា ចងរឹតមិនបាន " ។

(២៧) អដ្ឋកថាមាយសូត្រ ក្នុងសុតនិបាតថា " ២ បទថា **ទាយកោ ទានបតិ** ប្រែថា ជាទាយកផង ជាម្ចាស់នៃទានផង ។

ពណ៌នាអំពីទាន

មែនពិត បុគ្គលណា ត្រូវគេបង្គាប់ ក៏ឲ្យវត្ថុជារបស់នៃបុគ្គលដទៃ, សូម្បីបុគ្គលនោះ ក៏ឈ្មោះថា ជាទាយក, តែមិនបានឈ្មោះថា ជាទានបតីទេ ព្រោះមិនមានឥស្សរៈ ក្នុងទាននោះ ។ ក៏មាយមាណពនេះ តែងឲ្យនូវវត្ថុ ដែលជារបស់នៃខ្លួនតែប៉ុណ្ណោះ, ដោយហេតុនោះ ទើបមាយមាណពនោះពោលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាទានបតី ដោយពិត ដូច្នេះជាដើម ។ សេចក្ដីក្នុងមាយសូត្រនេះ មានតែប៉ុណ្ណោះ ។ ចំណែក ក្នុងទីដទៃទៀត នឹងពោល ដោយនយជាដើមថា ជាអ្នកត្រូវសេចក្ដីកំណាញ់គ្របសង្កត់ ក្នុងចន្លោះៗ បានឈ្មោះថា ជាទាយក, ជាអ្នកដែលសេចក្ដីកំណាញ់ គ្របសង្កត់មិនបាន ឈ្មោះថា ជាទានបតី ដូច្នេះ ក៏គួរ " ។

បឋមនយ ចប់ ។

(២៨) នយមួយទៀត ។ ឈ្មោះថា ទាន មាន ២ យ៉ាង ដោយអំណាចនៃធម្មទាន និង អាមិសទាន ។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងតតិយវគ្គ នៃតតិយបណ្ណាសកៈ ក្នុងទុកនិបាត អង្គុត្តរនិកាយ ថា " ម្នាលភិក្ខុទាំងឡាយ ទាននេះ មាន ២ យ៉ាង ។ ទាន ២ យ៉ាង តើដូចម្ដេចខ្លះ? ។ ទាន មាន ២ យ៉ាងនេះ គឺ អាមិសទាន ១ ធម្មទាន ១ ។ ម្នាលភិក្ខុទាំងឡាយ ទាន មាន ២ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាទាន

មន្ថលត្ថទីបនីប្រែ

ទាំង ២ យ៉ាងនេះ ធម្មទានន៉ុះ ជាទានប្រសើរជាង " ។

ទានសូត្រ ចប់ ។

*(២៩) អដ្ឋកថាទានសូត្រនោះ ថា " ទានវត្ថុ ដោយអំណាចនៃរបស់ដែលបុគ្គលគប្បីឲ្យ ឈ្មោះថាទាន ។ ពាក្យន៉ុះ ជាឈ្មោះនៃទេយ្យធម៌ ។ មួយទៀត ចេតនា ព្រមទាំងវត្ថុ ឈ្មោះថា **ទាន** ។ ពាក្យន៉ុះ ជាឈ្មោះ នៃកិរិយាបរិច្ចាគនូវសម្បត្តិ " ។*

*ដីកាទានសូត្រនោះថា "វត្ថុណា ដែលបុគ្គលឲ្យ ហេតុនោះ វត្ថុនោះ ឈ្មោះថា ទាន ។ ពាក្យន៉ុះ ជាឈ្មោះ នៃទេយ្យធម៌ ។ មួយទៀត ឈ្មោះថា ទាន ព្រោះជាគ្រឿងដែលបុគ្គលឲ្យ ។ ពាក្យន៉ុះ ជាឈ្មោះ នៃចេតនាគ្រឿងបរិច្ចាគ ។ សូម្បីសេចក្តីទាំង ២ យ៉ាងនេះ លោកអធិប្បាយហើយ ក្នុងពាក្យថា **ទាន** នេះ ព្រោះហេតុនោះ ទើបលោកពោលពាក្យថា **ទិយ្យនកវសេន ទានានិ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ទិយ្យនកវសេន** បានដល់ ដោយអំណាចនៃវត្ថុដែលបុគ្គលគប្បីឲ្យ " ។*

*(៣០) អដ្ឋកថាបញ្ចមវគ្គ តិកនិបាត ក្នុងឥតិវុត្តក: ថា "បទថា **អាមិសទានំ** មានសេចក្តីថា បច្ចយ ៤ ឈ្មោះថា អាមិសទានដោយអំណាចនៃវត្ថុដែលបុគ្គលគប្បីឲ្យ ។ មែនពិត បច្ចយទាំង ៤ នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា **អាមិស** ព្រោះជា*

ពណ៌នាអំពីទាន

របស់ដែលគេគប្បីប៉ះពាល់ត្រូវ ដោយកិលេស មានតណ្ហា ជាដើម ។ មួយទៀត ចេតនា ជាគ្រឿងបរិច្ចាគ នូវបច្ច័យទាំង ៤ នោះ ឈ្មោះថា អាមិសទាន " ។

(៣១) ភាវៈនៃអាមិសទាននោះ ជាមង្គល មានប្រការដូចបានពោលមកហើយន៉ុះឯង ។ មួយទៀត អាមិសទាន ឈ្មោះថា ***ជាមង្គល*** *ព្រោះហេតុបានចំពោះ នូវប្រយោជន៍សុខ ដោយពិត ។ ព្រោះថា បុគ្គលអ្នកប្រគេនបច្ច័យ ៤ រមែងបាននូវហិតសុខ ។*

ក្នុងជំណើរនោះ មានរឿងទាំងនេះ (ជាខុទាហរណ៍) ។

(រឿង ព្រះបាទនន្ទៈ)

ក្នុងអតីតកាល កុដុម្ពីក៍ម្នាក់ ជាអ្នកនៅក្នុងក្រុងពារាណសី ត្រាច់ទៅ ក្នុងព្រៃ បានឃើញសំពត់អនុវាត របស់ព្រះបច្ចេកពុទ្ធ លោកកំពុងតែធ្វើចីពរ មិនគ្រប់គ្រាន់ ទើបបានប្រគេន នូវសំពត់ដណ្តប់របស់ខ្លួន ។ កុដុម្ពីក៍នោះ បានទៅកើត ក្នុងភពតាវត្តិង្ស ព្រោះកម្មនោះ សោយនូវទិព្ធសម្បត្តិ ច្យុតចាកភពតាវត្តិង្សនោះ ហើយ ក៏បានមកកើត ក្នុងត្រកូលនៃអាមាត្យ ក្នុងទីប្រមាណ ១ យោជន៍ អំពីក្រុងពារាណសី បានចម្រើនពេញវ័យហើយ ក្នុងថ្ងៃនក្ខត្តឬក្ស បានពោល ថា " បពិត្រអ្នកម្តាយ សូមអ្នកម្តាយឲ្យសំពត់សាដក ដល់ខ្ញុំ, ខ្ញុំ នឹងលេងនក្ខត្តឬក្ស " ។ មាតានោះ បាន

មន្ទលត្ថទីបនីប្រែ

ឲ្យសំពត់ពណិស, (ប៉ុន្តែ) កាលកូននោះ ពោលថា " សំពត់នេះ សាច់មិនល្អទេ " ដូច្នេះ, ទើបបានឲ្យសំពត់ផ្សេងទៀត ។ កូននោះ ហាមនូវសំពត់នោះទៀត ។ ម្តាយនោះ ពោលថា " ក្នុងផ្ទះ របស់យើង គ្មានសំពត់ល្អជាងនេះទេ " ។ កូននោះ ពោលថា "បពិត្រ អ្នកម្តាយ ខ្ញុំនឹងទៅកន្លែងដែលបាន" ។ ម្តាយនោះ បានពោលថា " នែកូន ម្តាយប្រាថ្នាចង់ឲ្យកូនឯងបាន នូវរាជសម្បត្តិ ក្នុងទីក្រុងពារាណសី ក្នុងថ្ងៃនេះទៀតផង " ។ កូននោះ ពោលថា "បពិត្រ អ្នកម្តាយ ប្រពៃហើយ " ដូច្នេះ ថ្វាយបង្គំមាតា ត្រូវនិយាម នៃ បុណ្យជាស់តឿនហើយ ក៏បានទៅកាន់ក្រុងពារាណសី ដេកដណ្តប់ (គ្រប) នូវអវយវ: ព្រមទាំងក្បាល លើផ្ទាំងសីលាដែលជាមង្គល ក្នុងឧទ្យាន ។ ក៏ថ្ងៃនោះ ជាថ្ងៃទី ៧ នៃព្រះរាជា ក្រុងពារាណសី ទ្រង់បានទិវង្គតទៅ ។ ជនទាំងឡាយ មានអាមាត្យជាដើម បានបូជាព្រះសរីរកិច្ច របស់ព្រះរាជាហើយ ទើបប្រឹក្សាគ្នាថា "ព្រះរាជា ទ្រង់មានព្រះធីតា តែមួយព្រះអង្គប៉ុណ្ណោះ, គ្មានព្រះរាជឱរសទេ, រាជសម្បត្តិ ដែលប្រាសចាកព្រះរាជា នឹងតាំងនៅពុំបានឡើយ " ដូច្នេះហើយ កាលនឹងលែង នូវបុស្សរថ (រថមានពណិស) ទៅ បានទឹមសេះសិន្ធព ៤ ដែលមានសម្បុរដូចជាផ្ការកោមុទ ហើយ បានតាំងរាជកុក្ក្ធុធភណ្ឌ ៥ ប្រការ លើរថ ស្រេចហើយ ក៏លែង

ពណ៌នាអំពីឌាន

*រថទៅ ។ រថ បានចេញទៅ តាមមាត់ទ្វារទិសខាងកើត ចូលទៅ
កាន់ឧទ្យាន ធ្វើប្រទក្សិណកុមារហើយក៏បានត្រៀមនឹងកល់ ហើយ
ឈប់នៅ ។ បុរោហិត បានបើកជាយសំពត់ដែលជណ្តប់ ត្រួត
ពិនិត្យមើលផ្ទៃនៃបាទជើង ពោលថា " កុមារនេះ សមគួរហើយ
ដើម្បីគ្រប់គ្រងរាជសម្បត្តិ " ដូច្នេះហើយ ឲ្យគេប្រគំ នូវតូរ្យតន្ត្រី
អស់រាវ: ៣ ជង ។ គ្រានោះ កុមារ បានបើកមុខឡើងហើយ
ពោលថា " បពិត្រលោកឪពុក តើមានហេតុអ្វី? " ។ បុរោហិត
ពោលថា " បពិត្រលោកម្ចាស់ រាជសម្បត្តិ រមែងសម្រេច ដល់
លោកម្ចាស់ " ។ កុមារ សួរថា " ចុះព្រះរាជារបស់ពួកអ្នកទាំង
ឡាយ ស្តេចយាងទៅណា? " ។ បុរោហិត ពោលថា " បពិត្រ
លោកម្ចាស់ ព្រះអង្គទ្រង់ស្តេចទិវង្គតទៅហើយ " ។ កុមារ សួរថា
" កន្ទងទៅ បានប៉ុន្មានថ្ងៃហើយ? " ។ បុរោហិត ពោលថា " ថ្ងៃ
នេះ ជាថ្ងៃ ទី ៧ " ។ កុមារ បានសួរថា " ព្រះរាជឱរសក្តី ព្រះ
រាជធីតាក្តី មិនមានទេឬ? " ។ បុរោហិតពោលថា "បពិត្រលោក
ម្ចាស់ មានតែព្រះរាជធីតា (តែ) ព្រះរាជាឱរស មិនមែនទេ" ។
កុមារ ពោលថា " បើដូច្នោះ ខ្ញុំ នឹងគ្រប់គ្រង នូវរាជសម្បត្តិ " ។
ពួកអាមាត្យទាំងនោះ នាំគ្នាធ្វើមណ្ឌបសម្រាប់អភិសេក ក្នុងពេល
នោះភ្លាម ហើយក៏បានអភិសេក ក្នុងមណ្ឌបនោះ រួចហើយបាន*

មន្តលត្ថនីបនីប្រែ

បង្អោនសំពត់ដែលមានតម្លៃ ១ ពាន់ ចូលទៅថ្វាយ ។ ព្រះរាជាអង្គនោះ មានព្រះរាជឧង្ការ ថា "សំពត់នេះ មានសាច់មិនល្អ អ្នកទាំងឡាយចូរនាំយកកន្ទីទឹកមាសមក, ខ្ញុំនឹងបាននូវសំពត់" ដូច្នេះ ហើយ ស្តេចក្រោកឡើង ទ្រង់យកព្រះហស្តក្សង់ទឹក ហើយទ្រង់សាចទៅទិសខាងកើត ។ ដើមកប្បព្រឹក្ស ៨ ដើម បានទំលាយ ផែនដីដ៏ក្រាស់ ផុសឡើងហើយ ក្នុងពេលនោះភ្លាម ។ ដើមកប្បព្រឹក្ស ៨ ដើម ផុសឡើងហើយ ត្រង់ទិសទក្សិណ, ៨ ដើម ផុសឡើងហើយ ត្រង់ទិសបច្ចិម, ៨ ដើម ផុសឡើងហើយ ត្រង់ទិសឧត្តរ ដោយឧបាយនេះ ។ ដើមកប្បព្រឹក្សទាំងអស់ មាន ៣២ ដើម ដុះឡើងហើយ ដោយប្រការដូច្នេះ ។ ព្រះរាជាអង្គនោះ ទ្រង់ស្លៀកសំពត់ទិព្វមួយ ទ្រង់បានដណ្តប់សំពត់ទិព្វមួយ ទ្រង់ត្រាស់បញ្ជាឲ្យពួកអាមាត្យ រ៉ាយស្តរជ័យ ឃោសនា ក្នុងរដ្ឋធានី របស់ព្រះបាទនន្ទរាជថា "ស្ត្រីទាំងឡាយ កុំត្បាញសូត្រឡើយ" ហើយ ទ្រង់ត្រាស់បញ្ជា ឲ្យលើកឆត្រឡើង ហើយស្តេចឡើងលើ-កដំរីដ៏ប្រសើរ ទ្រង់យាងចូលទៅព្រះនគរ ស្តេចឡើង លើប្រាសាទ ទ្រង់សោយ នូវមហាសម្បត្តិ គ្រប់គ្រងរដ្ឋធានី របស់ព្រះអង្គទាំងអស់ ប្រៀបដូចជាឧត្តរកុរុទ្វីប ទ្រង់បានព្រះរាជទានសំពត់ទិព្វទាំងឡាយ ដល់មនុស្សទាំងឡាយ ដែលបានមកហើយៗ ក្រោយមក

ទ្រង់បានសាងព្រះផ្ទួស ព្រមទាំងព្រះទេវី នៅក្នុងព្រះឧទ្យាន ទ្រង់ញ្ចុំងឈាន ឲ្យកើតឡើងហើយ មានឈានមិនសាបសូន្យហើយ បានទៅកើត ក្នុងព្រហ្មលោក ។ ក្នុងពេលនេះ ព្រះរាជាអង្គនោះ បានកើតជាព្រះមហាកស្សបត្ថេរ, ព្រះទេវី បានមកកើតជានាងកទ្ទូកាបិលានី ដោយប្រការដូច្នេះឯង ។

រឿងព្រះបាទនន្ទរាជ មកក្នុងអដ្ឋកថាសំសារមោចកបេត្តវត្ថុ ។

(រឿង ស្ត្រីអ្នកក្រីក្រ)

(៣២) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី ស្ត្រីអ្នកក្រីក្រម្នាក់ ឃើញស្ត្រីទាំងឡាយ ដែលបរិបូណ៌ ដោយបុណ្យ ស្លៀកសំពត់ដែលជ្រលក់ដោយផ្ការជកគាំ កំពុងលេង ក្នុងថ្ងៃមហោស្រពជាអ្នកប្រាថ្នានឹងស្លៀកសំពត់ដូច្នោះ ហើយលេង (នឹងគេ) បានប្រាប់ដល់មាតាបិតា, កាលបើមាតាបិតា ពោលថា " នែកូនស្រីពួកយើងជាអ្នកក្រីក្រ, សំពត់បែបនេះ នឹងមានដល់ពួកយើង អំពីណាមក? " ដូច្នេះ, ទើបពោលថា "បើដូច្នោះ នាងខ្ញុំនឹងធ្វើនូវការស៊ីឈ្នួល ក្នុងត្រកូលអ្នកស្តុកស្តម្ភមួយ, អ្នកទាំងនោះដឹងនូវគុណរបស់ពួកយើងហើយ ក៏នឹងឲ្យ " ដូច្នេះហើយ បានចូលទៅកត្រកូលមួយ ពោលថា " នាងខ្ញុំ នឹងធ្វើនូវការស៊ីឈ្នួល ព្រោះសំពត់ក្រហម ដែលជ្រលក់ ដោយផ្ការជកគាំ " ។ ជន ក្នុងត្រកូល

មង្គលត្ថទីបនីប្រែ

ទាំងនោះ ពោលថា " កាលបើនាងធ្វើការងារ រហូត ៣ ឆ្នាំហើយ, ពួកយើងនឹងឲ្យដល់នាង " ។ ស្ត្រីអ្នកក្រីក្រនោះ ទទួលព្រម ថា "ល្អហើយ" ហើយបានធ្វើការងារ ។ កាលបើ ៣ ឆ្នាំ មិនទាន់ គ្រប់បរិបូណ៌ហើយនោះឯង, ពួកជនទាំងនោះ ដឹងនូវគុណ របស់ នាងហើយ ក៏បានឲ្យហើយនូវសំពត់សូម្បីឯទៀត ព្រមទាំងសំពត់ ក្រហមដែលជ្រលក់ដោយផ្ការកុសុម្ភៈ ដែលមានសាច់ក្រាស់ ដល់ ស្ត្រីនោះ ។ ស្ត្រីអ្នកក្រីក្រនោះ បានទៅហើយ ដាក់នូវសំពត់ពណ៌ ក្រហម នៅក្បែរមាត់ស្ទឹង ហើយចុះទៅងូតទឹក ។ ក្នុងខណៈនោះ សាវ័ក របស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ មួយអង្គ មាន ចីពរត្រូវចោរលួចយកហើយ ស្ងៀក និង គ្រងនូវមែកឈើ ដែល កាច់មកហើយ បានមកដល់ប្រទេសនោះ ។ នាងគិតថា "ភិក្ខុរូប នេះ នឹងមានចីពរត្រូវចោរលួចយកហើយ, សំពត់សម្រាប់ស្ងៀក របស់អាត្មាអញ ជារបស់រកបានដោយកម្រ ព្រោះអាត្មាអញមិន បានឲ្យហើយ ក្នុងកាលមុន" ដូច្នេះ ហើយក៏បានហែកសំពត់នោះ ត្រង់ពាក់កណ្តាល បានប្រគេនសំពត់មួយកំណាត់ ដល់ព្រះថេរៈ នោះ ។ ព្រះថេរៈ ឈរនៅ ក្នុងទីបិទបាំង ចោលមែកឈើ ដែល កាច់ហើយ ក៏ស្ងៀកកំណាត់សំពត់នោះ មួយចម្រៀក គ្រងមួយ ចម្រៀក និមន្តចេញទៅហើយ ។ គ្រានោះ សរីរៈទាំងអស់ របស់

ពណ៌នាអំពីទាន

ព្រះថេរៈ បានមានវស្សាក្ងីតែមួយ ដូចជាព្រះអាទិត្យដែលខ្ចី ព្រោះអានុភាពនៃសំពត់ ។ នាងបានឃើញព្រះថេរៈនោះហើយ ក៏គិតថា " ជាដំបូង ព្រះគុណម្ចាស់ របស់អាត្មាអញមិនស្រស់ទេ (តែ) ឥឡូវនេះ រមែងរុងរឿង ដូចព្រះអាទិត្យដែលខ្ចីៗ, អាត្មាអញ នឹងប្រគេនទូវសំពត់នេះ ដល់ព្រះគុណម្ចាស់ទ្ញុះឯង " ដូច្នេះហើយ ក៏បានប្រគេន ទូវចំណែកទី ២ ហើយ ក៏បានធ្វើសេចក្ដីប្រាថ្នា ថា " បពិត្រព្រះគុណម្ចាស់ នាងខ្ញុំកាលត្រាច់ផ្ទាត់ទៅ ក្នុងកព គប្បីជាអ្នកទ្រទ្រង់នូវរូបដ៏ស្រស់, បុរស ឯណាមួយ បានឃើញនាងខ្ញុំ ហើយ មិនអាចដើម្បីនឹងស្ថិតនៅ ដោយកាពរបស់ខ្លួនបានឡើយ, ស្ត្រីឯទៀត ។ ឈ្មោះថា ជាអ្នកមានរូបល្អស្អាតជាងនាងខ្ញុំ កុំបីមានឡើយ " ។ ឯព្រះថេរៈ បានធ្វើអនុមោទនា ហើយក៏ចៀសចេញទៅ ។ នាងកាលអន្ទោលទៅកាន់ទេវលោក ចុត អំពីទេវលោកនោះហើយ បានមកកើតជាធីតា របស់សេដ្ឋីអ្នកមានកោគសម្ផត្ដិ ៨០ កោដិ ឈ្មោះថា ឥ្ទិ:ជ:ជ:ចួ: ក្នុងអ:ជ្ជ:ជ:ប:ី ក្នុងសិ:ជ:ជ ។ នាងធីតានោះ ជាអ្នកទ្រទ្រង់រូបដ៏ស្រស់ ដល់នូវភាពជាអ្នកល្អប្រសើរលើស ដោយសេចក្ដីសោភា ញ្ជាំងបុរសអ្នកដែលឃើញខ្លួននាងឲ្យវង្វេងវង្ងាន់ និង មិនឲ្យបុរសនោះ តាំងសតិស្មារតីបានឡើយ ។ ព្រោះហេតុនោះ ជនទាំងឡាយ ទើបបានតាំងឈ្មោះ ឲ្យនាង ថា

មន្តលត្ថនីបនីប្រែ

"នាងឧម្មាទន្តី" ។ ក្នុងពេលដែលនាងមានអាយុ ១៦ ឆ្នាំ នាងមានពណ៌សម្បុរល្អកន្ងងពណ៌សម្បុរនៃមនុស្ស ប្រៀបដូចជានាងទេពអប្សរ ។ ពួកបុថុជ្ជនណាៗ យើញនូវនាងឧម្មាទន្តីនោះ, ពួកបុថុជ្ជននោះៗ មិនអាចដើម្បីនឹងស្ថិតនៅ ដោយភាវៈនៃខ្លួនបានជាអ្នកស្រវឹងហើយ ដោយសេចក្តីស្រវឹងព្រោះកិលេស ដូចជាស្រវឹងព្រោះគ្រឿងស្រវឹង មិនអាចដើម្បីផ្ចង់សតិ ឲ្យស្ថិតនៅបានឡើយ ។ លោកសេដ្ឋីតិរិដិវច្ឆៈ បានចូលទៅគាល់ព្រះបាទសិវិរាជហើយក្រាបទូលថា " បពិត្រព្រះសម្មតិទេព ឥត្ថីរត្ន កើតឡើងហើយ ក្នុងផ្ទះនៃទូលព្រះបង្គំ ជាអ្នកសមគួរ ដល់ព្រះអង្គ តែប៉ុណ្ណោះ, សូមព្រះអង្គទ្រង់បញ្ជូនអ្នកទាយ នូវលក្ខណៈទៅ ហើយទ្រង់ឲ្យត្រួតពិនិត្យមើល នូវស្ត្រីរត្ននោះ " ។ ព្រះរាជា ទ្រង់បានបញ្ជូនពួកព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍ទាំងនោះ ទៅហើយ ត្រូវសេដ្ឋីធ្វើសក្ការៈ និងសេចក្តីរាក់ទាក់ ហើយបរិភោគ ។ ក្នុងខណៈនោះ នាងឧម្មាទន្តី ទៅកាន់សំណាក់ របស់ព្រាហ្មណ៍ទាំងនោះ ។ ព្រាហ្មណ៍ទាំងនោះ បានយើញនាងហើយ ក៏មិនអាចដើម្បីនឹងតាំងសតិស្មារតីនៅបាន ជាអ្នកវង្វេងដោយសេចក្តីវង្វេង ព្រោះកិលេសមិនដឹង នូវការបរិភោគ ដែលខុសប្រក្រតីរបស់ខ្លួន, ពួកខ្លះ យកពំនូតបាយ ដាក់លើក្បាល ដោយគិត ថា " នឹងបរិភោគ " ដូច្នេះ,

ពណ៌នារំពីឆាន

ពួកខ្លះ ជាក់ជញ្ជាំង, ពួកខ្លះ ញាត់ពំនូតបាយ ក្នុងចន្ទោះរន្ធក្ដៀក, ពួកព្រាហ្មណ៍ទាំងអស់ បានជាអ្នកឆ្ពួតវង្វេងហើយ។ នាងឧម្មាទន្តី ឃើញពួកព្រាហ្មណ៍ទាំងនោះហើយ ក៏បានឲ្យគេបណ្តេញចេញ ទៅ ដោយពាក្យថា " បានញ្ញមកថា ពួកព្រាហ្មណ៍ទាំងនេះ នឹងពិចារណា នូវលក្ខណៈរបស់ខ្ញុំ, ចូរអ្នកទាំងឡាយ ចាប់ព្រាហ្មណ៍ទាំងនេះ ត្រង់ក ហើយបណ្តេញចេញទៅ " ។ ព្រាហ្មណ៍ទាំងនោះ ជាអ្នកខ្មាសអៀនហើយ ក្រោធខឹង ចំពោះនាង ក្រាបទូលថា " បពិត្រព្រះសម្មតិទេព ស្ត្រីនោះជាអ្នកកាឡកណ្ណី មិនសមគួរដល់ព្រះអង្គឡើយ " ។ ចំណែកព្រះរាជា មិនបានត្រាស់បញ្ជាឲ្យនាំយកនាងឧម្មាទន្តីនោះមកទេ ព្រោះទ្រង់សម្គាល់ថា " បានញ្ញ ថា នាងជាស្រីកាឡកណ្ណី " ។ ឯ នាងឧម្មាទន្តីនោះ ស្តាប់រឿងនោះហើយ បានចងអាឃាត ចំពោះព្រះរាជាអង្គនោះ ថា " រឿងនោះ លើកទុកសិនចុះ, បើអាត្មាអញចូលគាល់ព្រះរាជអង្គនោះ ក៏គង់តែជឹង " ។ ត្រានោះ សេដ្ឋីបានលើកនាង ឲ្យដល់សេនាបតីឈ្មោះ អភិបារកៈ ជាសំឡាញ់ របស់ព្រះរាជា ។ នាងបានជាទីស្រលាញ់ពេញចិត្ត របស់សេនាបតីនោះ ។ ក្រោយមក ថ្ងៃមួយ សេនាបតី កាលទៅកាន់ទីរក្សា របស់ខ្លួន បានពោលថា " នែនាងដ៏ចម្រើន ថ្ងៃនេះ ជាថ្ងៃមហោស្រព ពេញបូណិមី ខែកត្តិក, ព្រះ

មន្ថលត្ថទីបនីប្រែ

រាជា នឹងទ្រង់ធ្វើប្រទក្សិណព្រះនគរ ទ្រង់ស្តេចយាងមក កាន់ទ្វារផ្ទះនេះជាបឋម, ចូរនាងកុំបង្ហាញខ្ជូន ដល់ព្រះរាជាអង្គនោះឡើយ, ព្រោះរាជាអង្គនោះ ឃើញប្អូនហើយ ក៏នឹងមិនអាចដើម្បីទ្រង់តាំងព្រះសតិស្មារតី ឲ្យស្ថិតនៅបានទេ " ដូច្នេះហើយ ទើបគេចចេញទៅ ។ ចំណែកព្រះរាជា, កាលបើព្រះអាទិត្យ អស្តង្គតទៅហើយ, កាលបើព្រះចន្ទពេញវង់ រះឡើងហើយ, ទ្រង់ធ្វើប្រទក្សិណព្រះនគរ ដោយយសបារមីដ៏ធំ ទ្រង់ស្តេចយាងទៅ កាន់មាត់ទ្វារផ្ទះរបស់សេនាបតី ជាបឋមភ្លាម ទ្រង់បានទតព្រះនេត្រឃើញនាងឧម្មាទន្តី ឈរនៅក្បែរបង្អូច ទ្រង់ជាអ្នកឆ្ពួតវង្វេង ដោយសេចក្តីឆ្ពួតវង្វេងព្រោះកិលេស មិនអាចដើម្បីនឹងទ្រង់តាំងព្រះសតិ ឲ្យស្ថិតនៅបាន មិនទ្រង់ញ្ញាំងព្រះទ័យ ក្នុងការធ្វើប្រទក្សិណព្រះនគរ ឲ្យកើតឡើង ទ្រង់ត្រឡប់អំពីទីនោះ ហើយស្តេចឡើងទៅកាន់ប្រាសាទ ទ្រង់ព្រះបន្ទំ រវើយរវាយប្រារព្ធនាងឧម្មាទន្តី ដោយប្រការផ្សេងៗ ។ សេនាបតី ដឹងរឿងនោះហើយ ក៏គិតថា " ព្រះរាជាអង្គនេះ ទ្រង់មានព្រះទ័យប្រតិព័ទ្ធ ចំពោះនាងឧម្មាទន្តី កាលទ្រង់មិនបាន ក៏នឹងទ្រង់ទិវង្គត, ការដែលអាត្មាអញ ថ្វាយជីវិតដល់ព្រះអង្គ ទើបសមគួរ " ដូច្នេះហើយ បានបង្គាប់ឧបដ្ឋាកម្នាក់ថា " អ្នកចូរទៅ, រុក្ខចេតិយ ដែលមានប្រហោង ក្នុងទីឯណោះមាន,

ពណ៌នាអំពីទាន

ចូរអ្នកកុំឲ្យអ្នកឯណាមួយដឹង ហើយអង្គុយ ព្ធដ៏ខាងក្នុង នៃដើមឈើ, ខ្ញុំទៅក្នុងទីនោះហើយ ក៏នឹងធ្វើនូវពលីកម្មហើយ ពោលយ៉ាងនេះ, គ្រានោះ អ្នកចូរពោល យ៉ាងដូច្នេះ " ។ ឧបដ្ឋាកនោះ ពោលថា "ប្រពៃណាស់" ហើយក៏បានទៅ ក្នុងទីនោះ ។ ចំណែកសេនាបតី លុះស្អែកឡើង ក៏បានទៅក្នុងទីនោះ ធ្វើពលីកម្មស្រេចហើយ ក៏ពោលថា " បពិត្រទេវតា ព្រះរាជា របស់ពួកយើងខ្ញុំ, កាលបើមហោស្រព កំពុងតែប្រព្រឹត្តទៅ, មិនទ្រង់ព្រះក្រសាលស្តេចយាងចូលព្រះក្រឡាបនុំដ៏មានសិរី ទ្រង់បនុំ រវើរវាយហើយ, ព្រះអង្គទ្រង់រវើរវាយ ព្រោះអាស្រ័យរឿងអ្វី? " ។ ឧបដ្ឋាកនោះ ប្រែសំឡេង ហើយពោលថា " ម្នាលសេនាបតី ព្រះរាជា របស់ពួកអ្នក ទ្រង់មានព្រះហប្ចទ័យប្រតិព័ទ្ធ ចំពោះនាងឧម្មាទន្តី ដែលជាភរិយារបស់លោក, បើព្រះអង្គ នឹងបាននាងឧម្មាទន្តីនោះ នឹង មិនទ្រង់ចូលទិវង្គត, បើនឹងមិនបានទេនោះ ក៏នឹងទ្រង់ចូលទិវង្គត, ព្រោះហេតុនោះ ចូរអ្នកថ្វាយនាងឧម្មាទន្តីនោះ ដល់ព្រះរាជាអង្គនោះ " ។ សេនាបតី ពោលថា "ល្អណាស់" ហើយបានចូលទៅគាល់ព្រះរាជា ក្រាបទូលរឿងនោះ ហើយក្រាបទូលថា "បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ សូមថ្វាយនាងឧម្មាទន្តី ដល់ព្រះអង្គ " ។ ព្រះរាជា ទ្រង់សួរថា " នែអភិបារកៈ អ្នកជាសំលាញ់ សូម្បីពួក

មង្គលត្ថទីបនីប្រែ

យក្ស រមែងដឹងនូវការៈ នៃខ្ញុំជាអ្នករវើយរវាយ ព្រោះមានចិត្ត ប្រតិព័ទ្ធ ចំពោះនាងឧម្មាទន្តីឬ? " ។ សេនាបតី ក្រាបទូល ថា " បពិត្រព្រះសម្មតិទេព ពិតមែនហើយ " ។ ព្រះរាជា ទ្រង់ព្រះ តម្រិះថា "បានញ្ញថា ការៈនៃអាត្មាអញជាអ្នកលាមក ប្រជាលោក គ្រប់គ្នា បានដឹងអស់ហើយ" ដូច្នេះ ទ្រង់អៀនខ្មាសព្រះទ័យ ទ្រង់ តាំងនៅហើយ ក្នុងធម៌ ទ្រង់បន្ទោបង់ហើយ នូវព្រះទ័យប្រតិព័ទ្ធ ចំពោះនាងឧម្មាទន្តី ទ្រង់មិនបានទទួលយក នាងឧម្មាទន្តីនោះទេ ។ រឿងស្ត្រីក្រីក្រ មកក្នុងអដ្ឋកថាឧម្មាទន្តីជាតក ក្នុងបញ្ញាសនិបាត ។

ឯរឿងមានជាអាទិ៍ យ៉ាងនេះគឺ រឿងចូឡកសាជព្រាហ្មណ៍ ក្នុងបាបវគ្គ នៃធម្មបទ រឿងមហោកសាកជព្រាហ្មណ៍ ក្នុងអដ្ឋកថា ឯកនិបាត អង្គុត្តរនិកាយ ក៏គប្បីរួមបញ្ចូល ក្នុងចរិយាទាន ។

(**រឿង ព្រះទេវីព្រះនាមគោបាលមាតា**)

(៣៣) ក្នុងបន្ទោះផ្លូវ ទៅកាន់នគរឧជ្ជេនី មាននិគមមួយ ឈ្មោះតេលនាឡ្យ ។ ក្នុងនិគមនោះ មានធីតា របស់សេដ្ឋី ២ នាក់, ធីតាម្នាក់ជាអ្នកក្រីក្រ ដោយកាលកន្ទងទៅនៃមាតាបិតា អាស្រ័យ នូវស្រីមេនំចិញ្ចឹមជីវិត ជាអ្នកមានអត្តភាពស្អាតស្រស់ មានសក់ វែងជាងពួកស្ត្រីឯទៀត, ធីតាម្នាក់ ជាអ្នកស្ពុកស្ពម្ភ (តែ) មិនមាន សក់ ។ ក្នុងគ្រានោះ ព្រះមហាកច្ចាយនត្ថេរ ព្រមទាំងភិក្ខុ ៧ រូប

ពណ៌នារំពីទាន

មានប្រាថ្នានឹងក្រាបទូល នូវការកើតឡើងនៃព្រះពុទ្ធ ដល់ព្រះរាជាទ្រង់ព្រះនាមចណ្ឌបជ្ជោត ទើបនិមន្តទៅកាន់ក្រុងឧជ្ជនី ដល់និគមនោះហើយ ក៏ចូលទៅបិណ្ឌបាត ក្នុងនិគមនោះ (តែ) ឥតបានវត្ថុអ្វីឡើយ ។ សេដ្ឋីធីតា ដែលមានសក់វែង ដឹងរឿងនោះហើយ ក៏បញ្ជូនស្រីមេនំទៅ ដោយប្រាប់ថា " ចូរនាងនិមន្តព្រះថេរៈទាំងឡាយហើយ ឲ្យគង់ក្នុងផ្ទះ " ។ ស្រីមេនំនោះ បានធ្វើហើយយ៉ាងដូច្នោះ ។ សេដ្ឋីធីតា បានចូលទៅកាន់បន្ទប់ហើយ ឲ្យស្រីមេនំកាត់សក់របស់ខ្លួន បញ្ជូនទៅហើយ ដោយប្រាប់ថា " នែនាង ចូរនាងឲ្យសក់ទាំងនេះ ដល់សេដ្ឋីធីតា ដែលមិនមានសក់ ឈ្មោះនុ៉ះ, ធីតារបស់សេដ្ឋីនោះ ឲ្យនូវវត្ថុអ្វី, ចូរនាំយកវត្ថុនោះមក, ពួកយើងនឹងប្រគេនបិណ្ឌបាត ដល់ព្រះគុណម្ចាស់ទាំងឡាយ ដោយវត្ថុនោះ " ។ នាងបានធ្វើ យ៉ាងដូច្នោះហើយ បានទទួលយកទ្រព្យ ៨ កហាបណៈ មកឲ្យហើយ ដល់សេដ្ឋីធីតា ដែលមានសក់ ។ សេដ្ឋីធីតានោះ ធ្វើបិណ្ឌតបាតមួយៗ ឲ្យទៅមួយ ៗ កហាបណៈ ហើយញ្ចាំងបុគ្គលឲ្យប្រគេនហើយ ដល់ព្រះថេរៈទាំងឡាយ ខ្លួនឯង នៅក្នុងបន្ទប់ ។ ព្រះមហាកច្ចាយនត្ថេរ ដឹងហេតុការណ៍នោះ ហើយបានឲ្យបុគ្គលទៅហៅសេដ្ឋីធីតានោះមកហើយ ។ សេដ្ឋីធីតានោះ បានមកហើយ ព្រោះសេចក្តីគោរព ចំពោះព្រះថេរៈ ថ្វាយ

មង្គលត្ថទីបនីប្រែ

បង្គំព្រះថេរៈទាំងឡាយហើយ ក៏បានញ៉ាំងសទ្ធាជ្រះថ្លា ដ៏មានកម្លាំង ឲ្យកើតឡើងហើយ ។ ឈ្មោះថា ទាន ដែលនាងប្រគេនហើយ ក្នុងខេត្តដ៏ល្អ រមែងឲ្យនូវវិបាក ក្នុងបច្ចុប្បន្ន ទាន់ភ្នែក ព្រោះហេតុនោះ សក់ទាំងឡាយ របស់នាងបានដុះឡើងវិញហើយ ក្នុងការៈតាមប្រក្រតីភ្លាម ព្រមជាមួយគ្នា នឹងការថ្វាយបង្គំព្រះថេរៈ ។ ព្រះថេរៈទាំងឡាយ ទទួលបិណ្ឌាតបាតហើយ, កាលសេដ្ឋីធីតានោះ ឃើញនុ៎ះឯង, ក៏ហោះឡើងទៅ កាន់អាកាសវេហាស៍ បានចុះក្នុងឧទ្យានឈ្មោះកាញ្ចនវ័ន ហើយធ្វើនូវកត្តកិច្ច ។ បុគ្គលអ្នករក្សាឧទ្យាន ឃើញព្រះថេរៈទាំងឡាយហើយ ក៏បានក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាស្តេចយាងទៅកាន់ព្រះឧទ្យាន ទ្រង់ទតព្រះនេត្រឃើញព្រះថេរៈទាំងឡាយហើយ ទ្រង់បានត្រាស់សួរថា " បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ក្នុងថ្ងៃនេះ ព្រះគុណម្ចាស់ទាំងឡាយ បានហើយនូវកិច្ចា ក្នុងទីឯណា? " ដូច្នេះហើយ ទ្រង់ព្រះសណ្ដាប់រឿងនោះហើយ ទ្រង់ស្តេចយាងទៅ កាន់ព្រះដំណាក់ ទ្រង់ត្រាស់ឲ្យនាំសេដ្ឋីធីតានោះមក ក្នុងថ្ងៃនោះឯង ហើយទ្រង់បានអភិសេក (នាង) ជាព្រះអគ្គមហេសី ។ ក្នុងកាលក្រោយមក ព្រះនាង ទ្រង់បានប្រសូតព្រះរាជបុត្រ បានយកឈ្មោះ របស់សេដ្ឋីដែលជាអយ្យកា របស់ព្រះរាជឱ្យ ថ្វាយ

ពណ៌នាអំពីឆាន

ព្រះនាម ថា "**គោបាល**" (ចំណែកព្រះនាង) ប្រាកដព្រះនាម ថា "**គោបាលមាតាទេវី**" ដោយអំណាចព្រះនាម របស់ព្រះឧរសទ្រង់ ជ្រះថ្លាហើយយ៉ាងក្រៃលែង ចំពោះព្រះថេរ: ទ្រង់បានឲ្យបុគ្គល កសាងព្រះវិហារ ថ្វាយព្រះថេរ:ហើយ ក្នុងព្រះឧទ្យាន ឈ្មោះ កាញ្ចានវ័ន ដូច្នេះឯង ។ រឿងព្រះនាង គោបាលទេវី មកក្នុង អដ្ឋកថា ឯកនិបាត អង្គុត្តនិកាយ ។

(រឿង ព្រះនាងមល្លិកាទេវី)

(៣៤) ក្នុងក្រុងសាវត្ថី មានធីតា របស់នាយមាលាការ ដែលជាចម្បងជាងគេម្នាក់ ជាស្ត្រីមានរូបឆោមល្អ ប្រសើរជាច់គេ ជាអ្នកមានបុណ្យច្រើន មានអាយុ ១៦ ឆ្នាំ ។ ថ្ងៃមួយ នាងធីតា នោះ បានដាក់នំកុម្មាស ៣ ដុំ ក្នុងកញ្ជើផ្ការឈើ ហើយដើរទៅកាន់ សួនច្បារ ឃើញព្រះសាស្តា ព្រមទាំងព្រះសង្ឆ កំពុងតែស្តេច យាងទៅកាន់ទីក្រុង ដើម្បីទ្រង់បិណ្ឌបាត ក៏មានចិត្តត្រេកអរ ហើយបានដាក់នំទាំងនោះ ក្នុងបាត្រព្រះសាស្តា ថ្វាយបង្គំហើយ ក៏ញ្ចាំងបីតិប្រារព្ធនូវព្រះពុទ្ធជាអារម្មណ៍ ឲ្យកើតឡើងហើយ បាន ឈរនៅ ក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តា កាលទ្រង់ទតព្រះ នេត្រមើលនាងធីតានោះ ទ្រង់ធ្វើនូវការញញឹម ត្រូវព្រះអានន្ទត្ថេរ ក្រាបទូលសួរ នូវហេតុនៃការទ្រង់ញញឹម ទើបទ្រង់ត្រាស់ ថា

មន្តលត្ថនីបនីប្រែ

ម្នាលអានន្ទ នាងកុមារិកានេះ នឹងបានជាព្រះអគ្គមហេសីរបស់ព្រះ
រាជាព្រះនាមកោសល ក្នុងថ្ងៃនេះឯង ព្រោះផលនៃការប្រគេន
នំកុម្មាស " ដូច្នេះហើយ ទើបស្តេចយាងគេចចេញទៅ ។ ឯនាង
ធីតានោះទៅកាន់សួនច្បារហើយ ច្រៀងបណ្តើរ កាច់ផ្ការបណ្តើរ ។
ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់ព្រះនាមកោសល ទ្រង់ច្បាំងជាមួយ
នឹងព្រះបាទអជាតសត្រូវ ទ្រង់បរាជ័យហើយ ស្តេចគេចចេញ
ទ្រង់គង់សេះយាងទៅ ទ្រង់ព្រះសណ្តាប់នូវសំឡេងច្រៀង របស់
នាងធីតានោះ ទ្រង់មានព្រះទ័យ ប្រតិព័ទ្ធហើយ ទ្រង់ស្តេចយាង
ទៅកាន់សួនច្បារ ទ្រង់ជ្រាបថា នាងជាអ្នកមិនមានស្វាមី ទើប
ទ្រង់ឲ្យនាងអង្គុយ លើខ្នងសេះ មានពួកពលចោមរោមហើយ
ស្តេចយាងចូលទៅកាន់ព្រះនគរ ទ្រង់បានបញ្ជូននាង ទៅកាន់ផ្ទះ
នៃត្រកូល ក្នុងពេលល្ងាច ទ្រង់បានត្រាស់ឲ្យនាំមក អំពីទីនោះ
ដោយសក្ការៈដ៏ច្រើន ទ្រង់អភិសេក លើគំនរនៃរតនៈ ទ្រង់បាន
ធ្វើហើយជាព្រះអគ្គមហេសី ។ ព្រះនាង ទ្រង់បានជាទីស្រលាញ់
ជាទីពេញព្រះទ័យ នៃព្រះរាជា ទ្រង់បានជាទីស្និទ្ធស្នាល សូម្បីនៃ
អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ទើបទ្រង់បានប្រាកដ
ព្រះនាម ថា " ព្រះនាងមល្លិកាទេវី " ។

រឿងព្រះនាងមល្លិកាទេវី មកក្នុងអដ្ឋកថាកុម្មាសបិណ្ឌិយជាតក ក្នុងសត្តកនិបាត។

ពណ៌នាអំពីទាន

រឿង ២ ក្នុងសត្តកនិបាតន៉ុះឯង គឺ រឿងព្រះរាជាប្រគេន នំកុម្មាស រឿងព្រះទេវី ដែលទ្រង់ប្រគេនភិក្ខា (និង) រឿងមានជាអាទិ៍ យ៉ាងនេះ គឺ រឿងមហាទុគ្គតសេដ្ឋី ២ រឿង ក្នុងអដ្ឋកថា កុណ្ឌកបូវជាតក ក្នុងឯកាទសមវគ្គ នៃឯកនិបាត ក៏គប្បីប្រមូលយកមកបញ្ចូល ក្នុងបិណ្ឌបាតទាន ។

(រឿង នន្ទិយឧបាសក)

(៣៥) នៅក្នុងក្រុងពារាណសី មានឧបាសកម្នាក់ ឈ្មោះ នន្ទិយ: ជាអ្នកមានសទ្ធាជ្រះថ្លាហើយ ។ ឧបាសកនោះ ស្តាប់អានិសង្សកថា នៃអាវាសទាន របស់ព្រះសាស្តាហើយ ញ្ចាំងបុគ្គលឲ្យកសាងសាលាមានមុខ ៤ ប្រដាប់ប្រដាដោយ ៤ បន្ទប់ ក្បែរមហាវិហារ ក្នុងព្រៃឥសិបតន: ឲ្យតាំងនូវវត្ថុទាំងឡាយ មានគ្រែ និង កៅអីជាដើម កាលនឹងវេរប្រគេន នូវលំនៅនោះ បានប្រគេនភោជនទាន ដល់ព្រះសង្ឆ មានព្រះពុទ្ធជាប្រធាន ស្រោចទឹកទក្ខិណោទក លើព្រះហស្តនៃព្រះសាស្តា វេរប្រគេនហើយ ។ ប្រាសាទទិព្ធ បណ្តោយ និង ទទឹង ១២ យោជន៍ កំពស់ ១០០ យោជន៍ សម្រេចដោយរតន: ៧ ប្រការ សម្បូរដោយពួកនារី បានកើតឡើងហើយ ក្នុងភពតាវត្តិង្ស ព្រមជាមួយគ្នានឹងកិរិយា ស្រោចទឹកទក្ខិណោទក លើព្រះហស្ត របស់ព្រះសាស្តាន៉ុះឯង ។

មន្តលត្ថនីបនីប្រែ

ក្រោយមក នៅថ្ងៃមួយ ព្រះមហាមោគ្គល្លានត្ថេរ និមន្តច្រាច់ទៅ ទេវលោក យើញប្រាសាទនោះហើយ ក៏ត្រឡប់មកវិញ បានក្រាបទូលដល់ព្រះសាស្តា ។ ចំណែក នន្ទិយឧបាសក ស្តាប់នូវការកើតឡើងនៃប្រាសាទដើម្បីខ្លួន ទើបធ្វើបុណ្យទាំងឡាយ មានទានជាដើម ដោយប្រមាណ យ៉ាងក្រែលែង ក្នុងពេលអស់អាយុ ក៏បានទៅកើត ក្នុងប្រាសាទនោះឯង ។

រឿងនន្ទិយឧបាសក មកក្នុងអដ្ឋកថាបិយវគ្គ នៃធម្មបទ និង អដ្ឋកថាវេវតីវិមាន ក្នុងវិមានវត្ថុ ។

រឿងកុដុម្ពីក៍ ឈ្មោះ អបរាជិត អ្នកកសាងព្រះគន្ធកុដិ ដើម្បីព្រះពុទ្ធ ទ្រង់ព្រះនាមវិបស្សី ក្នុងអដ្ឋកថាព្រាហ្មណវគ្គ នៃ ធម្មបទ រឿងគហបតីម្នាក់ អ្នកកសាងបណ្ណសាលា ប្រគេន ដល់ភិក្ខុ អ្នកនៅ ក្នុងព្រៃជាវត្ត ក្នុងអដ្ឋកថាមហាសុទស្សនសូត្រ និង សូម្បីរឿងដទៃទៀត ក្រៅអំពីរឿងនោះ ក៏គប្បីប្រមូលមករួម ក្នុងសេនាសនទាន ផងដែរ ។

(រឿង ព្រះបាទអសោក)

(៣៦) ក្នុងអតីតកាល ក្នុងក្រុងពារាណសី អ្នកលក់ទឹកឃ្មុំ ម្នាក់ បានលក់ទឹកឃ្មុំ ក្នុងផ្សារ ។ គ្រានោះ ព្រះបច្ចេកពុទ្ធ មួយ អង្គ បានកើតរោគរបេង ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធ មួយអង្គ

ពណ៌នាអំពីឌាន

ទៀត កាលនិមន្តទៅបិណ្ឌបាតទឹកឃ្មុំ ដើម្បីធ្វើថ្នាំ ប្រគេនព្រះ
បច្ចេកពុទ្ធអង្គនោះ ក៏បានចុះអំពីភ្នំគន្ធមាទន៍ហើយ និមន្តចូលទៅ
កាន់ទីក្រុងពារាណសី ។ នាងកុម្ភទាសី អ្នកទៅកំពុងទឹក ឃើញ
ព្រះបច្ចេកពុទ្ធ អង្គនោះហើយ ក៏ក្រាបទូលសួរ ស្តាប់រឿងនោះ
ហើយ ទើបលាតដៃចេញ បង្ហាញនូវផ្សារទឹកឃ្មុំ ដោយពាក្យ ថា
" បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន អ្នកលក់ទឹកឃ្មុំ នៅក្នុងទីនោះ,
សូមព្រះគុណម្ចាស់ និមន្តទៅ ក្នុងទីនោះចុះ " ដូច្នេះហើយ ក៏បាន
ឈរគិត នៅក្នុងទីនោះឯងថា " បើអ្នកលក់ទឹកឃ្មុំ មិនប្រគេនទឹក
ឃ្មុំ ដល់ព្រះគុណម្ចាស់ទេ, អាត្មាអញ នឹងទៅក្នុងទីនោះ ហើយ
យកទឹកឃ្មុំ មកប្រគេន ដល់ព្រះគុណម្ចាស់ ក្រោយមក ចាំស្វែង
រកទ្រព្យ មកឲ្យនូវថ្លៃ (នៃទឹកឃ្មុំ) " ដូច្នេះ ។ ព្រះបច្ចេកពុទ្ធ បាន
និមន្តទៅហើយក្នុងផ្សារនោះ ។ អ្នកលក់ទឹកឃ្មុំ ឃើញព្រះបច្ចេក-
ពុទ្ធ ហើយ ក៏មានចិត្តត្រេកអរ បានប្រគេនទឹកឃ្មុំពេញបាត្រ
ឃើញទឹកឃ្មុំហូរហៀរ ស្រក់ចេញអំពីមាត់បាត្រ ធ្លាក់ស្រក់ចុះ
លើផែនដី ជ្រះថ្លាហើយ យ៉ាងខ្លាំង ទើបបានប្រាថ្នាថា " បពិត្រ
ព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា គប្បីគ្រប់គ្រងឯករាជ ក្នុង
ជម្ពូទ្វីប ដោយបុញ្ញកម្មនេះ, ក៏អាជ្ញា របស់ខ្ញុំព្រះករុណា ចូរផ្សព្វ
ផ្សាយទៅ ក្នុងស្ថានទីប្រមាណ ១ យោជន៍ ទាំងលើអាកាស និង

មន្តលត្ថនីបនីប្រែ

លើផែនដី " ដូច្នេះ ។ ព្រះបច្ចេកពុទ្ធ ទ្រង់ត្រាស់ ថា " ម្នាលឧបាសក សេចក្តីប្រាថ្នា របស់អ្នក ចូរសម្រេច យ៉ាងនោះចុះ " ដូច្នេះហើយ ទើបបាននិមន្តមកវិញ ។ នាងកុម្ភទាសីនោះ យើញនូវព្រះបច្ចេកពុទ្ធហើយ ទើបទូលសួរថា " បពិត្រព្រះគុណម្ចាស់ ដ៏ចម្រើន តើព្រះគុណម្ចាស់ បាននូវទកឹយ្ចុំហើយឬ? " ។ ព្រះបច្ចេកពុទ្ធ បានតបវិញ ថា " ម្នាលប្អូនស្រី អ្នកលក់ទឹកយ្ចុំនោះ បានប្រគេនទឹកយ្ចុំ ដល់អាត្មាហើយ ប្រាថ្នាយ៉ាងដូច្នេះ " ។ នាងកុម្ភទាសីនោះ ស្តាប់នូវរឿងនោះហើយ ទើបប្រាថ្នាភាវៈជាអគ្គ-មហេសី នៃអ្នកលក់ទឹកយ្ចុំនោះ ។ បណ្តាជនទាំង ២ នោះ អ្នកលក់ទឹកយ្ចុំ បានជាព្រះអសោកកុមារ ជាអ្នកចម្បងជាងគេបង្អស់ បណ្តាព្រះរាជបុត្រ ១០១ ព្រះអង្ត របស់ព្រះបាទពិនុសារ ក្នុងនគរបាដលីបុត្រ ដោយកាលកន្ងទៅនៃព្រះបិតា បានធ្វើគុតព្រះអនុជទាំងឡាយដទៃអំពីនោះ លើកលែងតែព្រះតិស្សកុមារ ដែលរួមព្រះមាតា ជាមួយគ្នាចេញ នៅមិនទាន់អភិសេកផង ក៏បានគ្រប់គ្រងរាជសម្បត្តិ រហូត ៤ ឆ្នាំ ដោយកន្ងទៅ ៤ ឆ្នាំ ទើបបានដល់នូវការអភិសេក ជាព្រះរាជា ១ ព្រះអង្ត ក្នុងជម្ពូទ្វីបទាំងមូល ក្នុងឆ្នាំ ទី ១៨ ដែលជាឆ្នាំទីបំផុត នៃសតវត្សរ៍ ទី ២ (២១៨) អំពីការបរិនិព្វាន នៃព្រះសាស្តាទៅ ។ ក៏ព្រះរាជប្ចទ្ធិ

ពណ៌នារំពីទាន

ទាំងឡាយនេះ មកហើយ ដល់ព្រះអសោកកុមារនោះ ដោយ អានុភាពនៃការអភិសេក ។ មែនពិត ព្រះរាជឫទ្ធិទាំងឡាយសូម្បី ដែលបុគ្គលគប្បីសម្រេច ដោយអានុភាពនៃបុណ្យ រមែងមក ដោយអានុភាពនៃការអភិសេក ដែលកើត ពីបយោគសម្បត្តិ នុ៉ះ ឯង ប្រៀបដូចជាគុណវិសេសដែលសេសសល់ មានបដិសម្ភិទា ជាដើម ដែលមកហើយ ដោយព្រះអរហត្តមគ្ត ។ ព្ធដ៏ខាងក្រោម នៃផែនដី ព្រះអាជ្ញា ផ្សព្វផ្សាយទៅ ក្នុងទីប្រមាណ ១ យោជន៍, ព្ធដ៏ខាងលើនៃអាកាស ក៏ដូចគ្នាដែរ ។ ទេវតាទាំងឡាយ តែង នាំយកទឹកសម្រាប់សោយ មកអំពីអនោតត្តស្រះ មួយថ្ងៃ ៗ ១៦ ក្អម (និងនាំ) ឈើសូន់ ឈ្មោះនាគលតា មានរសជាតិ ដ៏ទន់រមួត ផ្ងែកន្ធួតព្រៃដែលជាថ្នាំ ផ្ងែសម៉ ដែលជាថ្នាំ និង ផ្ងែស្វាយទុំ ដែលដល់ព្រមដោយក្ងិន និង រសជាតិ មានពណ៌ដូចមាស មក អំពីព្រៃហិមវន្ត រៀងរាល់ថ្ងៃ ។ ផ្ងែកន្ធួតព្រៃដែលជាឧសថ ដែល នាំរបស់ដែលជាទោសទាំងពួងចេញ អាចជម្រះសរីរៈជាដើមបាន ដោយការបរិភោគ តែបន្តិចបន្តួចប៉ុណ្ណោះ ឈ្មោះថា ផ្ងែកន្ធួតព្រៃ ដែលជាថ្នាំ ។ សូម្បីផ្ងែសម៉ដែលជាថ្នាំ ក៏ដូច្នោះដែរ ។ បានព្ថថា ព្រះរាជាទ្រង់សោយ បណ្តាផ្ងែកន្ធួតព្រៃ និង ផ្ងែសម៉ ទាំងពីរមុខ នោះ ផ្ងែណាមួយ តាមព្រះរាជប្រាថ្នា ។ ទេវតាទាំងឡាយនុ៉ះឯង

មង្គលត្ថទីបនីប្រែ

*តែងនាំនូវសំពត់ សម្រាប់ស្បៀកដណ្តប់ មាន ៥ ពណ៌ សំពត់ពណ៌លឿង សំពត់ជូតព្រះហស្ត និង ទឹកដែលជាទិព្ធ មកអំពីទេវវិមាន ដែលស្ថិតនៅក្បែរស្រះ ឈ្មោះឆទ្ទន្ត ជារៀងរាល់ថ្ងៃ ។ អាចារ្យពួកខ្លះ ពោលថា " ឯដើមកប្បព្រឹក្សទាំងឡាយ តែងមានក្បែរស្រះ ឈ្មោះឆទ្ទន្ត, ទេវតាទាំងឡាយ តែងនាមំក អំពីដើមកប្បព្រឹក្សនោះ" ដូច្នេះ ក៏មានដែរ ។ នាគរាជទាំងឡាយ តែងនាំសុគន្ធវារី សម្រាប់ស្រង់ គ្រឿងក្រអូបសម្រាប់លាប សំពត់ផ្ការ៉ូ ដែលមិនបានត្បាញ ដោយអំបោះ ដើម្បីជាប្រយោជន៍ ដល់ការិយាទ្រង់ និង ឱ្យសប សម្រាប់បន្ត្ក់ព្រះនេត្រ ដែលមានតម្លៃដ៏ច្រើន មកអំពីកពង្ការនៃនាគ ជារៀងរាល់ថ្ងៃ ។ សំពត់ទិព្ធ ដែលកើតអំពីដើមកប្បព្រឹក្ស មិនបានត្បាញ ដោយអំបោះ ឈ្មោះថា អសុត្តមយិកៈ, សំពត់នោះ ជាសំពត់សាច់ស្ងួតម៉ដ្ត ក្នុងទីគ្រប់ស្ថាន ឈ្មោះថា ជាសំពត់ផ្ការ៉ូ ព្រោះមានផ្ការ៉ូផ្ការ៉ូ ។ សត្វសេកទាំងឡាយ តែងនាំស្រូវសាលី ៩,០០០ រ៉ាទេ ដែលកើតឯង ក្បែរស្រះឆទ្ទន្ត មកជារៀងរាល់ថ្ងៃ ។ ក៏គប្បីវិនិច្ឆ័យក្នុងបទថា "**ភ**ហសហស្សានិ" នេះ ដូចតទៅ៖ ៤ កំបង់ ត្រូវជា ១ ឧ្ម៉ាៈ, ៤ ឧ្ម៉ាៈ ត្រូវជា ១ ប្ត:, ៤ ប្ត: ត្រូវជា ១ អាឡ្ហកៈ ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ, ៤ ទោណៈ ត្រូវជា ១ មានិកៈ,*

ពណ៌នាអំពីទាន

៤ មានិក: ត្រូវជា ១ ខារី, ២០ ខារី ត្រូវជា ១ ភាហ:, ភាហ: ន៏ុះឯង គឺ ១ រនេះ ។ កណ្តាវទាំងឡាយ តែងកកេរ នូវអង្ករទាំងឡាយ ឲ្យប្រាសចាកអង្ការ និង កណ្ណាក (ក្ងន់) ។ អង្ករដែលបាក់ សូម្បីតែមួយគ្រាប់ ក៏មិនបានមានហើយ ។ សត្វយ៉ុំទាំងឡាយ តែងហើរមក ធ្វើទ៏ីកយ៉ុំ ក្នុងទ៏ីជ៏ិតបង្ហ៏ីយ ។ សត្វខ្ទាយ៉ុំទាំងឡាយ តែងពុះខ្ទស ក្នុងសាលា នៃជាងមាស ។ សត្វកវ៏ីក ទាំងឡាយ តែងមក ស្រែកយ៉ំ បញ្ចេញសំឡេងដ៏ពីរោះ ធ្វើពលីកម្ម ថ្វាយ ដល់ព្រះរាជា ដូចជាអ្នកនគរ ដែលធ្វើពលីកម្ម ក្នុងវារ:ដែលមក ដល់ហើយ យ៉ាងដូច្នោះ ។ អាចារ្យពួកខ្ញ: តែងពោលថា " សត្ត កវ៏ីកទាំងនោះ ហើរមក ធ្វើសំឡេង ឮដ៏អាកាសន៏ុះឯង មិនឲ្យ អ្នកណាស្គាល់ខ្លួន ស្រេចហើយក៏ហើរទៅ " ដូច្នេះក៏មាន ។ អ្នក លក់ទ៏ីកយ៉ុំនោះ បានជាព្រះធម្មរាជា ទ្រង់ព្រះនាម អសោក ទ្រង់ ប្រកបព្រម ដោយព្រះរាជឫទ្ធ៏ិទាំងនេះ ព្រោះការប្រគេនទ៏ីកយ៉ុំ ដ៏ើម្បីធ្វ៏ើថ្នាំ ដូចបានពណ៌ិនាមកហើយ ។ ចំណ៏ែក នាងកុម្ភទាសី នោះ បានកើតជាព្រះអគ្គមហេសី នៃព្រះបាទអសោកធម្មរាជនោះ ទ្រង់ព្រះនាមថាព្រះនាងអសន្ធ៏ិមិត្តា ។ បានញ:ថា ដំណាទាំងឡាយ ត្រ៏ង់ព្រះហស្ត និង ព្រះបាទទាំងឡាយ របស់ព្រះនាង រាបរ៏ាងស្ម៏ើ មិនប្រាកដហើយ ក្នុងកាលឯទ៏ៀត រ៏ៀរ៏ៃលង៏តែកិរ៏ិយាបត់

មន្តលត្ថនីបនីប្រែ

ចូល ព្រោះផលនៃបុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយការខ្ចល់ ខ្ចាយ គឺកិរិយាចង្អុលបង្ហាញនូវផ្សារទឹកឃ្ចុំ ព្រោះហេតុនោះ ព្រះ នាង ទើបទ្រង់មានព្រះនាមថា អសន្ធិមិត្តា ។

រឿង ព្រះបាទអសោក មកក្នុងគម្ពីរមហាវង្ស ជាដើម ។

អបទាន របស់ព្រះពក្កុលត្ថេរ ក្នុងចត្តាលីសមវគ្គ ក្តី អបទាន របស់ព្រះសប្បិទាយកត្ថេរ ក្នុងសត្តរសមវគ្គ ក្តី និង សូម្បីរឿងផ្សេងៗ ទៀត ក្រៅអំពីរឿងនោះ ក្តី ក៏គួរនាំយកមក រួមបញ្ចូលគ្នា ក្នុងភេសជ្ជទាន ផងដែរ ។

(៣៧) បុគ្គលអ្នកប្រគេនបច្ចយ ៤ រមែងបានសេចក្តីសុខ ដូច្នេះឯង ព្រោះហេតុនោះ ទាន គឺបុគ្គលគប្បីឲ្យប្រព្រឹត្តទៅ សូម្បី ខ្ជូនឯង ។ សូម្បីយញ្ញតាមត្រកូល ក៏មិនគប្បីកាត់ផ្តាច់ដែរ, ព្រោះ យញ្ញតាមត្រកូលនោះ ក៏មានផលច្រើនដូចគ្នាដែរ ។ ដោយហេតុ នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ដល់កូដទន្តព្រាហ្មណ៍ ទើបទ្រង់ត្រាស់ថា " ម្នាលព្រាហ្មណ៍ ទានទាំងឡាយ ណាមួយ គឺនិច្ចទាន យញ្ញតាមត្រកូល គឺកុលបុត្រតែងប្រគេនខទ្ទិសចំពោះ បព្វជិត អ្នកមានសីល, ម្នាលព្រាហ្មណ៍ យញ្ញ នេះឯង ។ល។ មានផលច្រើនជាង មានអានិសង្សច្រើនជាង " ដូច្នេះ ។

(៣៨) អដ្ឋកថាកូដទន្តសូត្រនោះ ថា " ទាន យឺនយូរ គឺ

ពណ៌នាអំពីទាន

*និច្ចកត្តទាំងឡាយ ឈ្មោះថា **និច្ចទាន** ក្នុងសូត្រនោះ ។ យញ្ញ ទាំងឡាយ ឯណាមួយ សូម្បីគឺកុលទាយាទ ដែលជាបុរស អ្នកក្រីក្រ ក្នុងកាលជាខាងក្រោយ ធ្វើមនសិការ ថា " និច្ចទាន ទាំងឡាយ គឺបិតា និង ជីតា ជាដើម របស់ពួកយើង បានឲ្យប្រព្រឹត្តទៅ ហើយ " ដូច្នេះ គប្បីឲ្យប្រព្រឹត្តទៅ តាមលំដាប់ នៃវង្សត្រកូល ឈ្មោះថា **យញ្ញ** ដែលប្រព្រឹត្តទៅតាមត្រកូល ។ បានឮថា ជនទាំងឡាយ ក្នុងត្រកូលទាំងនោះ សូម្បីជ្ងាក់ខ្លួនក្រីក្រ រមែងមិនកាត់ផ្តាច់នូវទានជាប្រចាំ ឧទ្ទិសចំពោះអ្នកមានសីល យ៉ាងនោះដែរ ។*

ក្នុងដំណើរនោះ មានរឿងនេះ ជាឧទាហរណ៍

(រឿង អនាថបិណ្ឌិកសេដ្ឋី)

បានឮថា ក្នុងផ្ទះ របស់អនាថបិណ្ឌិកសេដ្ឋី និច្ចកត្ត ៥០០ គឺ បុគ្គលបានប្រគេនហើយ ។ សលាក ដែលធ្វើហើយដោយកូក ៥០០ បានមានហើយ, គ្រាក្រោយមក ត្រកូលនោះ ត្រូវសេចក្តីក្រីក្រ គ្របសង្កត់ហើយ ដោយលំដាប់ ។ នាងទាសិកា ម្នាក់ ក្នុងត្រកូលនោះ មិនអាចដើម្បីនឹងប្រគេន ឲ្យលើសពីមួយសលាកបានឡើយ ។ ចំណែកនាងទាសិកានោះ ខាងក្រោយមក បានទៅកាន់រដ្ឋធានី ឈ្មោះសេតវ៉ាហនៈ បានប្រគេនហើយ នូវសលាកនោះ ដោយធញ្ញជាតិ ដែលខ្លួននាងបោសសំអាតលាន បានហើយ ។

មङ្គលត្ថទីបនីប្រែ

ព្រះថេរៈមួយរូប បានទូលហើយដល់ព្រះរាជា ។ ព្រះរាជា ទ្រង់ បាននាំនាងទាសិកានោះមកហើយ ទ្រង់តែងតាំងហើយ ក្នុងតំណែង នៃព្រះអគ្គមហេសី ។ តាំងអំពីពេលនោះមក ព្រះនាង បានឲ្យ សលាកភត្តទាំង ៥០០ ប្រព្រឹត្តទៅហើយ បន្តទៅទៀត " ។

(៣៩) ដីកាកូដទន្តសូត្រនោះថា " ទាន ដែលបុគ្គលធ្វើឲ្យ យឺនយូរ គឺ ឲ្យស្ថិតស្ថេរ មិនឲ្យជាច់រយៈ ហើយគប្បីប្រគេន ឈ្មោះថា ទានយឺនយូរ ។ ទាន ដែលបុគ្គលអាស្រ័យលំដាប់ នៃ ត្រកូល គឺ អនុលោមទៅតាមត្រកូល ហើយគប្បីឲ្យ ឈ្មោះថា យញ្ញ ដែលប្រព្រឹត្តទៅតាមត្រកូល ។ ដោយហេតុនោះ ទើបព្រះ អដ្ឋកថាចារ្យ ពោលថា "**អម្ហាកំ**" ជូច្នេះជាដើម ។ ទាន ដែល បុគ្គលកំណត់ គឺ និយមហើយ ឲ្យប្រព្រឹត្តទៅ ដោយអំណាច នៃ ប្រពៃណី ឈ្មោះថា ទានយឺនយូរស្ថិតស្ថេរ ។ បុគ្គលទាំងឡាយ តែងកត់ឈ្មោះ នៃទាយកទុក ក្នុងសលាកឯណា, សលាកដែល បុគ្គលឲ្យប្រព្រឹត្តទៅ ដោយភ្ជុកជំរីនោះ ឈ្មោះថា សលាកធ្វើអំពី ភ្ជុកជំរី ។ បទថា **រញ្ញោ** បានដល់ ព្រះបាទសេតវាហនៈ " ។

ពណ៌នាអំពីអាមិសទាន ចប់ ។

(៤០) អដ្ឋកថា ទុកនិបាត អង្គុត្តរនិកាយ ថា " បទថា **ធម្មទានំ** មានសេចក្ដីថា ព្រះធម្មកថិកអង្គខ្លះ ក្នុងព្រះសាសនានេះ

ពណ្ណនារំពីទាន

រមែងសម្តែង នូវបដិបទា ជាហេតុឲ្យសម្រេចអមត: ហើយទើបឲ្យ, នេះ ឈ្មោះថា ***ធម្មទាន*** *" ។*

ដីកាទុកនិបាត អង្គុត្តរនិកាយនោះថា "បទថា ***អមតប្បត្តិ-ប្បដិបទំ*** *បានដល់ បដិបទាត្រូវ ដែលជាហេតុសម្រេចអមត: " ។*

(៤១) អដ្ឋកថាឥតិវុត្តក: ថា " ព្រះធម្មកថិកអង្គខ្ទះ ក្នុងព្រះសាសនានេះ ចែកនូវកម្មបថដែលជាកុសល និង អកុសល ថា ធម៌ទាំងឡាយនេះ ជាកុសល, ធម៌ទាំងឡាយនេះ ជាអកុសល, ធម៌ទាំងឡាយនេះ មានទោស, ធម៌ទាំងឡាយនេះ មិនមានទោស, ធម៌ទាំងឡាយនេះ គឺវិញ្ញូជន តិះដៀលហើយ, ធម៌ទាំងឡាយនេះ គឺវិញ្ញូជនសរសើរហើយ, ធម៌ទាំងឡាយនេះ គឺបុគ្គលសមាទានឲ្យបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនមែនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ, ធម៌ទាំងឡាយនេះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដូច្នេះ ធ្វើនូវកម្ម និង វិបាក នៃកម្ម ឲ្យប្រាកដ ដូចជាសម្តែងប្រាប់ នូវលោកនេះ និង លោកខាងមុខ ដោយជាក់ច្បាស់ ញ្ចាំងបុគ្គលអ្នកស្តាប់ ឲ្យត្រឡប់ (ចិត្តគំនិត) អំពីអកុសលធម៌ទាំងឡាយ ឲ្យស្ថិតនៅស៊ប់ ក្នុងកុសលធម៌ទាំងឡាយ សម្តែងនូវធម៌, កិរិយាធ្វើយ៉ាងនេះ ឈ្មោះថា ***ធម្មទាន*** *។ តែព្រះធម្មកថិក អង្គណា ប្រកាសនូវសច្ចៈទាំងឡាយ ថា ធម៌*

មង្គលត្ថទីបនីប្រែ

ទាំងឡាយនេះ បុគ្គលគប្បីដឹងយ៉ាងក្រៃលែង, ធម៌ទាំងឡាយនេះ បុគ្គលគប្បីកំណត់ដឹង, ធម៌ទាំងឡាយនេះ បុគ្គលគប្បីលះបង់ចោល, ធម៌ទាំងឡាយនេះ បុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់, ធម៌ទាំងឡាយនេះ បុគ្គលគប្បីចម្រើន ដូច្នេះ សម្តែងនូវបដិបត្តិធម៌ ដើម្បីសម្រេចនូវអមត:, កិរិយាធ្វើយ៉ាងនេះ ឈ្មោះថា ***ធម្មទាន*** *ដែលដល់ហើយនូវភាវ:ជាកំពូល ។ បទថា* ***ឯតទគ្គំ*** *កាត់បទជា* ***ឯតំ អគ្គំ*** *។ បទថា* ***យទិទំ*** *មានសេចក្តីថា បណ្តាទានទាំង ២ យ៉ាងនេះ ធម្មទាន ដែលព្រះធម្មកថិកនោះ សម្តែងន៉ុះ ជាធម្មទាន ដ៏លើស ដ៏ប្រសើរខ្ពង់ខ្ពស់ ។ មែនពិត បុគ្គលអាស្រ័យនូវធម្មទានដែលញ្ចុាំងសត្វឲ្យដល់នូវវិវដ្ត: រមែងរួចផុតស្រឡះ អំពីសេចក្តីអន្តរាយ គ្រប់បែបយ៉ាងបាន, រមែងកន្ងងផុត នូវសេចក្តីទុក្ខ ក្នុងវដ្ត:ទាំងអស់ ។ ក៏ធម្មទាន ដែលជាលោកិយ រមែងជាដើមហេតុនៃទានទាំងឡាយទាំងពួង ជាឬសគល់ នៃទ្រព្យសម្បត្តិ គ្រប់បែបយ៉ាង ។ សូម្បីអភ័យទាន ក៏គប្បីយើញថា៖ ព្រះដ៏មានព្រះភាគទ្រង់សង្ត្រោះហើយ ដោយធម្មទាន បណ្តាទានទាំង ២ យ៉ាងនេះ ដូចគ្នាដែរ ដោយប្រការដូច្នេះ" ។*

ក្នុងអដ្ឋកថា មង្គលសូត្រនេះ លោកពោលថា " ក៏ការសម្តែងធម៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រកាសហើយ ដែល

ពណ៌នាអំពីទាន

ជាហេតុអស់ទៅ នៃសេចក្ដីទុក្ខ និង នាំសេចក្ដីសុខមកឲ្យ ក្នុងលោកនេះ និង លោកខាងមុខ ដើម្បីភាពជាអ្នកជ្រាជ្ញាប្រយោជន៍សុខ ដល់បុគ្គលដទៃ ឈ្មោះថា ***ធម្មទាន*** *" ។*

(៤២) មែនពិត ធម្មទាន ចាត់ថាជាទានដ៏លើស ដ៏ប្រសើរ ក៏ព្រោះឈ្នះ នូវអាមិសទានទាំងពួង ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ ដល់សក្ដទេវរាជ ដែលជាស្ដេចនៃទេវតា ទើបទ្រង់ត្រាស់ទុក ក្នុងតណ្ហាវគ្គ នៃធម្មបទ ថា ៖

" ធម្មទាន រមែងឈ្នះនូវទានទាំងពួង, ធម្មរស រមែងឈ្នះនូវរសទាំងពួង, សេចក្ដីត្រេកអរ ក្នុងធម៌ រមែងឈ្នះនូវសេចក្ដីត្រេកអរទាំងពួង, កិរិយាអស់ទៅនៃតណ្ហា រមែងឈ្នះនូវទុក្ខទាំងពួង " ។

ជីកាទេវតាសំយុត្ត ក្នុងសគាថវគ្គ ថា " អាមិសទាន អភ័យទាន តាមដែលពោលមកហើយ ឈ្មោះថា ទានទាំងពួង ។

បទថា ***ធម្មទានំ*** *បានដល់ ការសម្ដែងនូវធម៌ " ។*

(៤៣) អដ្ឋកថាធម្មបទ ថា " ក៏ប្រសិនបើ បុគ្គលគប្បីប្រគេននូវចីពរទាំងឡាយ ដូចជាស្រទាប់ត្រយូងចេក ដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះទីណាស្រពទាំងឡាយ ដែលបានគង់ជាប់ៗគ្នា ក្នុងផ្ទៃនៃចក្រវាឡ រហូតទៅទល់គ្នានឹងព្រហ្មលោក, កិរិយា

មង្គលត្ថទីបនីប្រែ

អនុមោទនា ដែលព្រះពុទ្ធជាដើម ទ្រង់បានធ្វើហើយ ដោយព្រះគាថាប្រកបដោយ ៤ បាទ ក្នុងសមាគមនោះឯង ប្រសើរបំផុត ។ ព្រោះថា ទាននោះ រមែងមិនដល់តម្លៃនូវចំណែកទី ១៦ នៃព្រះគាថានោះទេ ។ ការសម្តែងក្តី ការប្រាប់ក្តី ការស្តាប់ក្តី នូវធម៌ ជាធម្មជាតិមានផលច្រើនយ៉ាងដូច្នេះ ។ មួយទៀត បុគ្គលឯណាមួយ ឲ្យគេធ្វើការស្តាប់ធម៌នោះ, អានិសង្ស ដ៏ច្រើន រមែងមាន ដល់បុគ្គលនោះពិត ។ ធម្មទានដែលព្រះពុទ្ធជាដើមទ្រង់បានឲ្យប្រព្រឹត្តទៅហើយ សូម្បីដោយអំណាចនៃអនុមោទនា ដោយហោចទៅដោយព្រះគាថា ប្រកបដោយ ៤ បាទប៉ុណ្ណោះ ជាធម្មជាត ដ៏ប្រសើរ សូម្បីជាងទាន ដែលទាយកញ៉ាំងបាត្រឲ្យពេញ ដោយបិណ្ឌបាតដ៏ប្រណីតហើយ ប្រគេនដល់បរិសទ្យអ្នកប្រាកដ ដូច្នោះឯង សូម្បីជាងកេសជ្ជទាន ដែលទាយកញ៉ាំងបាត្រឲ្យពេញដោយទឹកដោះរាវថ្ងា និង ប្រេងជាដើមហើយប្រគេន សូម្បីជាងសេនាសនទាន ដែលទាយកញ៉ាំងបុគ្គល ឲ្យសាងព្រះវិហារទាំងឡាយ ដូចជាព្រះមហាវិហារ និង ប្រាសាទទាំងឡាយ ដូចជាលោហប្រាសាទ រាប់ច្រើនសែនខ្នង ជាអនេក ហើយប្រគេន សូម្បីជាងការបរិច្ចាគ ដែលអនាថបិណ្ឌិកសេដ្ឋី ប្រារព្ធព្រះវិហារធ្វើហើយ ។ ព្រោះហេតុអ្វី? ។ ព្រោះថា បុគ្គលទាំងឡាយ កាលនឹងធ្វើបុណ្យ

ពណ៌នាអំពីទាន

យ៉ាងដូច្នេះ ត្រូវតែស្តាប់ធម៌សិនហើយ ទើបធ្វើទៅបាន, មិនបានស្តាប់ធម៌ហើយ ក៏មិនបានធ្វើដែរ ។ ក៏ប្រសិនបើសត្វទាំងនេះ មិនគប្បីស្តាប់ធម៌ទេ, ក៏មិនគប្បីប្រគេន សូម្បីនូវបបរ ត្រឹមតែមួយក្បាយ សូម្បីនូវបាយ ត្រឹមតែមួយវែកដែរ, ហេតុនេះ ធម្មទានន៏ុះឯង ជាទានប្រសើរជាងទានទាំងពួង ។ មួយទៀត លើកលែងតែព្រះពុទ្ធ និង ព្រះបច្ចេកពុទ្ធទាំងឡាយ ចេញហើយ សូម្បីព្រះសាវ័កទាំងឡាយ មានព្រះសារីបុត្រជាដើម ជាអ្នកប្រកប ដោយបញ្ញាដែលអាច ដើម្បីនឹងរាប់តំណក់ទឹកភ្លៀងទាំងឡាយបាន កាលបើភ្លៀងកំពុងធ្លាក់រហូតកប្បទាំងមូល ក៏មិនអាចដើម្បីនឹងសម្រេចសោតាបត្តិផលជាដើម ដោយធម្មតា របស់ខ្លួនបានឡើយ, លុះតែស្តាប់ធម៌ ដែលព្រះអស្សជិត្ថេរជាដើម សំដែងហើយ ទើបធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលបាន, (និង) ធ្វើឲ្យជាក់ច្បាស់ នូវសាវ័កបារមីញាណ ដោយព្រះធម៌ទេសនា របស់ព្រះសាស្តាបាន ។ បពិត្រព្រះមហារាជ ព្រោះហេតុនោះឯង ធម្មទានន៏ុះឯងជាទានដ៏ប្រសើរបំផុត ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា **ធម្មទាន រមែងឈ្នះ នូវទានទាំងពួង** ដូច្នេះជាដើម ។ មួយទៀត រស គ្រប់យ៉ាង មានរសដែលកើតអំពីគល់ជាដើម ដោយឧក្រិដ្ឋ សូម្បីរសនៃសុធាភោជន៍ របស់ទេវតាទាំង

មង្គលត្ថទីបនីប្រែ

ទ្ធាយ រមែងជាបច្ចយ នៃកិរិយាញ៉ាំងសត្ត ឲ្យធ្លាក់ចុះទៅ ក្នុងសំសារវដ្ត ហើយសោយសេចក្ដីទុក្ខ ដោយពិត ។ ចំណែកព្រះធម៌ ពោលគឺ ពោធិបក្ខិយធម៌ ៣៧ ប្រការក្ដី ពោលគឺ ព្រះលោកុត្តរធម៌ ៩ ប្រការ ក្ដី នេះឯង ប្រសើរជាងរសទាំងពួង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ ថា **ធម្មោ សេ រមែងឈ្នះ នូវរសទាំងពួង** យ៉ាងដូច្នេះឯង " ។

ជីកាសគាថាវគ្គថា " ឥតិ និង ជ្ជោមោជ្ជ: ដែលព្រះសទ្ធម្ម សន្ធ្ងរហើយ ឈ្មោះថា រសនៃព្រះធម៌ " ។

(៤៤) អដ្ឋកថាធម្មបទ ថា " មួយវិញទៀត សូម្បីសេចក្ដីត្រេកអរចំពោះបុត្រ សេចក្ដីត្រេកអរចំពោះធីតា សេចក្ដីត្រេកអរចំពោះស្ត្រី និង សេចក្ដីត្រេកអរមានប្រភេទជាអនេក ផ្សេងដោយសេចក្ដីត្រេកអរចំពោះការលេង មានការរាំ ច្រៀង និង ប្រគំ ជាដើមនោះឯង រមែងជាបច្ចយ នៃកិរិយាញ៉ាំងសត្ត ឲ្យធ្លាក់ចុះទៅក្នុងវដ្ត: ហើយសោយសេចក្ដីទុក្ខ ដោយពិត ។ ចំណែកសេចក្ដីផ្ទ្រេតចិត្ត នេះឯណា ដែលកើតឡើង ពួជ្ជ៍ខាងក្នុង (ចិត្ត) នៃបុគ្គលអ្នកសម្ដែងធម៌ក្ដី អ្នកស្ដាប់ធម៌ក្ដី រមែងញ៉ាំងភាពជាអ្នកមានចិត្តខ្ពស់ ឲ្យកើតឡើង, ញ៉ាំងទឹកភ្នែកឲ្យស្រក់ចុះ ញ៉ាំងការព្រឺព្រួចរោម ឲ្យកើតឡើង, សេចក្ដីផ្ទ្រេតចិត្តនេះនោះ រមែងធ្វើទីបំផុត នៃ

ពណ៌នាអំពីឌាន

សំសារវដ្ដ: មានព្រះអរហន្ដជាទីបំផុត ព្រោះហេតុនោះ សេចក្ដីត្រេកអរ ក្នុងព្រះធម៌យ៉ាងដូច្នេះឯង ជាសេចក្ដីត្រេកអរដ៏ប្រសើរជាងសេចក្ដីត្រេកអរទាំងពួង ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ***សេចក្ដីត្រេកអរ ក្នុងព្រះធម៌ រមែងឈ្នះនូវសេចក្ដីត្រេកអរទាំងពួង*** *ដូច្នេះ" ។*

ជីកាសគាថាវគ្គថា "សេចក្ដីត្រេកអរ ក្នុងព្រះធម៌ គឺសមថ: និង វិបស្សនា ឈ្មោះថា សេចក្ដីត្រេកអរ ក្នុងព្រះធម៌ " ។

អដ្ឋកថា ធម្មបទនោះថា " ចំណែកកិរិយាអស់ទៅនៃតណ្ហា គឺព្រះអរហត្ត ដែលកើតឡើង ក្នុងទីបំផុត នៃការអស់ទៅ នៃតណ្ហា, ព្រះអរហត្តនោះ ប្រសើរជាងអ្វីគ្រប់បែបយ៉ាង ដោយពិត ព្រោះគ្របសង្កត់នូវសេចក្ដីទុក្ខ ក្នុងវដ្ដ: ទាំងមូលបាន ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា ***កិរិយាអស់ទៅ នៃតណ្ហា រមែងឈ្នះនូវសេចក្ដីទុក្ខទាំងពួង*** *ដូច្នេះ" ។*

(៤៥) ព្រះធម្មកថិក សូម្បីកាលនឹងសម្ដែងធម៌ គប្បីជាអ្នកមានចិត្ដទន់ ផ្សព្វផ្សាយទៅ ដើម្បីជាប្រយោជន៍ ដោយពិត មិនគប្បីជាអ្នកធ្ងន់ ក្នុងលាភ ។ ព្រោះថា ធម្មទាន របស់ព្រះធម្មកថិកអ្នកធ្ងន់ ក្នុងលាភ រមែងមិនមានផលច្រើនឡើយ ។ ដោយហេតុនោះ ទើបលោក ពោលទុកហើយ ក្នុងអដ្ឋកថាសង្គីតិសូត្រ ថា

មន្តលត្ថនីបនីប្រែ

“ ព្រះធម្មកថិក មួយរូប ស្ថិតនៅក្នុងសេចក្តីប្រាថ្នាថា បុគ្គលទាំងឡាយ នឹងដឹង នូវអាត្មាអញ ថា ជាព្រះធម្មកថិក ដោយប្រការយ៉ាងនេះ ដូច្នេះហើយ ជាអ្នកធ្ងន់ ក្នុងលាភ សម្តែង (នូវធម៌), ធម្មទាននោះ មិនមានផលច្រើនឡើយ ។ ព្រះធម្មកថិក មួយរូប មិនប្រាថ្នា (យ៉ាងដូច្នោះ) ឡើយ សម្តែងធម៌ ដែលខ្ជួនស្ទាត់ជំនាញ ដល់ជនទាំងឡាយឯទៀត ធម្មទាននេះ ឈ្មោះថា បុញ្ញកិរិយាវត្ថុ ដែលសម្រេចមក អំពីការសម្តែងធម៌ ” ។

ដីកាសង្គីតិសូត្រនោះថា “ ធម្មទាននោះ ឈ្មោះថា មិនមានផលច្រើន ព្រោះត្រូវតណ្ហាប៉ះពាល់ត្រូវហើយ ។ បណ្ឌិត គប្បីនាំយកនូវពាក្យ ថា **បរេសំ ទេសេតិ ហិតផរណេន មុទុចិត្តេន** មកសម្ពន្ធ ចូលជាមួយគ្នា ” ។

(៤៦) មែនពិត ព្រះធម្មកថិក កាលនឹងសម្តែងធម៌ គប្បីតម្កល់ធម៌ ៥ យ៉ាង ទុក ក្នុងខ្ជួនឲ្យបាន ។ សមដូចជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុក ក្នុងបឋមវគ្គ នៃចតុត្ថបណ្ណាសក: ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ [1] ថា “ ម្នាលអានន្ទ ការសម្តែងធម៌ ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ, ម្នាលអានន្ទ កាលភិក្ខុ សម្តែងធម៌ ដល់ជនដទៃ គប្បីតម្កល់ធម៌ ៥ យ៉ាង ឲ្យមាន ក្នុង

១- សុត្តន្តបិដក ភាគទី ៤៥ ទំព័រទី ១១១ ។

ពណ៌នាអំពីទាន

ខ្ជួនសិន ទើបគួរសម្តែងធម៌ ដល់ជនដទៃ, ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ? ។ គឺកិក្ខុត្រូវសម្តែងធម៌ដល់ជនដទៃ ដោយតាំងចិត្តថា អាត្មាអញ នឹងសម្តែងនូវអនុបុព្វិកថា ១, ... អាត្មាអញ នឹងសម្តែងពាក្យលើកអាងហេតុផល ១, ... អាត្មាអញ នឹងសម្តែងពាក្យដោយអាស្រ័យ នូវសេចក្តីអាណិត (ដល់អ្នកស្តាប់) ១, ... អាត្មាអញ នឹងមិនអាស្រ័យអាមិសជាហេតុ សម្តែងធម៌ ១, កិក្ខុត្រូវសម្តែងធម៌ ដល់ជនដទៃ ដោយតាំងចិត្តថា អាត្មាអញ នឹងសម្តែងធម៌ ដោយមិនបានបៀតបៀនខ្ជួនឯង និងបុគ្គលដទៃ ១ ។ ម្នាលអានន្ទ ការសម្តែងធម៌ ដល់ជនដទៃ មិនអាចធ្វើបាន ដោយងាយទេ, ម្នាលអានន្ទ កាលកិក្ខុសម្តែងធម៌ ដល់ជនដទៃ គប្បីតម្ណល់ធម៌ ៥ យ៉ាងនេះ ឲ្យមាន ក្នុងខ្ជួនសិន ទើបគួរសម្តែងធម៌ដល់ជនដទៃ " ។

ឧទាយីសូត្រ ចប់ ។

(៤៧) អដ្ឋកថាឧទាយីសូត្រនោះ ថា "បទថា **អនុបុព្វីកថំ** មានសេចក្តីថា ព្រះធម្មកថិក គប្បីញ្ចុំងចិត្តឲ្យតាំងនៅ ថា អាត្មាអញ នឹងសម្តែងនូវទេសនាអនុបុព្វីកថា យ៉ាងនេះថា សីល ក្នុងលំដាប់នៃទាន ស្ថានសួគ៌ ក្នុងលំដាប់នៃសីល ដូច្នេះជាដើម ឬថាបទព្រះសូត្រ ឬ បទព្រះគាថាណាៗ ជាបទដែលតាំងទុកហើយ,

មង្គលត្ថទីបនីប្រែ

(នឹងសម្តែង) ពាក្យដែលសមគួរ ដល់បទនៃសូត្រ និង គាថា នោះៗ ដូច្នេះហើយ ទើបគួរសម្តែងធម៌ ដល់ជនដទៃ ។ បទថា **បរិយាយទស្សាវី** មានសេចក្តីថា កាលសម្តែង នូវហេតុនោះ ៗ នៃផលនោះ ៗ ។ ក៏ហេតុ លោកពោលថា បរិយាយ ក្នុងបទថា **បរិយាយទស្សាវី** នេះ ។ ២ បទថា **អនុទ្ទយតំ បដិច្ច** មានសេចក្តីថា អាស្រ័យសេចក្តីអនុគ្រោះថា អាត្មាអញ នឹងដោះលែង នូវសត្វទាំងឡាយ ដែលដល់នូវសេចក្តីចង្អៀតចង្អល់ចិត្ត ដ៏ច្រើន ចេញពីសេចក្តីចង្អៀតចង្អល់ចិត្ត ។ បទថា **ន អាមិសន្តរោ** បានដល់ មិនមានអាមិសជាហេតុ ។ អធិប្បាយថា មិនប្រាថ្នានូវការបានបច្ច័យ ៤ ដើម្បីខ្លួនឡើយ ។ ច្រើនបទថា **អត្តានញ្ច បរញ្ច អនុបហច្ច** មានសេចក្តីថា មិនបានចូលទៅបៀតបៀនខ្លួនឯង និងជនដទៃ ដោយចំណាចការលើកតម្តើងខ្លួនឯង និង បន្ទាបបន្ទោកជនដទៃ ដោយការប៉ះទង្គិចគុណ " ។

ក៏អនុបុព្វីកថា អ្នកប្រាថ្នា (ចង់ដឹង) សេចក្តីនោះ ដោយពិស្តារ គប្បីទាញយក អំពីអដ្ឋកថាអម្ពដ្ឋសូត្រ ក្នុងសីលក្ខន្ធវគ្គ អំពីអដ្ឋកថាឧបាលីសូត្រ ក្នុងបឋមវគ្គ នៃមជ្ឈិមបណ្ណាសក: និង អំពីអដ្ឋកថាទុតិយសូត្រ ក្នុងទុតិយវគ្គ នៃអដ្ឋកនិបាត អង្គុត្តរ-និកាយ ។

ពណ៌នាអំពីឌាន

ព្រះធម្មកថិក គប្បីតម្កល់ធម៌ ៥ យ៉ាង ទុក ក្នុងខ្លួន យ៉ាងដូច្នេះហើយ ទើបគួរសំដែងធម៌ ដល់ជនដទៃ ដោយពិត ។

មែនពិត ការសំដែងក្តី ការប្រាប់ក្តី (នូវធម៌) ដល់ជនដទៃ រមែងប្រព្រឹត្តទៅ ដើម្បីកិរិយាតាំងនៅស៊ាប់ នៃព្រះសាសនា ។

(៤៨) ប៉ុន្តែ ការមិនសំដែង (ធម៌) ជាដើម រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ នៃព្រះសាសនានោះ ។ ហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយនុ៎ះឯង ថា " ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ មិនរៀនធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ ទី១ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនសំដែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ, ម្នាលភិក្ខុទាំងឡាយ នេះ ជាធម៌ ទី២ . . . ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនបង្ហាញនូវធម៌ តាមដែលបានស្តាប់

មន្តលត្តទីបនីប្រែ

មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ, ម្នាលកិក្ខុទាំងឡាយ នេះ ជាធម៌ ទី៣ . . . ម្នាលកិក្ខុទាំងឡាយ មួយទៀត កិក្ខុទាំងឡាយ មិនធ្វើនូវការទន្ទេញនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដោយពិស្តារ, ម្នាលកិក្ខុទាំងឡាយ នេះជាធម៌ ទី៤ ... ម្នាលកិក្ខុទាំងឡាយ មួយទៀត កិក្ខុទាំងឡាយ មិនត្រិះរិះរឿយ ៗ មិនពិចារណារឿយ ៗ ដោយចិត្ត មិនជញ្ជឹងរឿយ ៗ ក្នុងចិត្ត នូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក, ម្នាលកិក្ខុទាំងឡាយ នេះជាធម៌ ទី៥ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលកិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសាន្យ អន្តរធានទៅ ។ ម្នាលកិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម ឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ? ។ ម្នាលកិក្ខុទាំងឡាយ កិក្ខុទាំងឡាយ ក្នុងព្រះសាសនានេះ រមែងរៀនធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ ... វេទល្លៈ, ម្នាលកិក្ខុទាំងឡាយ នេះជាធម៌ ទី១ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលកិក្ខុទាំងឡាយ មួយទៀត កិក្ខុទាំងឡាយ សំដែងធម៌ តាមដែលបាន

ពណ៌នាអំពីឆាន

ស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ, បន្តាញនូវធម៌ ... ដល់បុគ្គលដទៃ ដោយពិស្តារ, ធ្វើនូវការ ស្វាធ្យាយនូវធម៌ ... ដោយពិស្តារ, ត្រិះរិះរឿយៗ ពិចារណា រឿយៗ ដោយចិត្ត ជញ្ជឹងគិតរឿយៗ ក្នុងចិត្ត នូវធម៌ តាម ដែលបានស្តាប់មក តាមដែលបានរៀនមក, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ ទី៥ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ... ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៥ យ៉ាងនេះឯង រមែង ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិន អន្តរធានទៅ [(១)] " ។

សូត្រទី ៥ ចប់ ។

*(៤៩) អដ្ឋកថាទសមវគ្គ ឯកនិបាត អង្គុត្តរនិកាយ ថា "បទថា **សទ្ធម្មស្ស** បានដល់ ធម៌ល្អ អធិប្បាយថា សាសនា ។ បទថា **សម្មោសាយ** បានដល់ ដើម្បីសេចក្តីវិនាស ។ បទថា **អន្តរធានាយ** បានដល់ ដើម្បីមិនឲ្យប្រាកដ " ។*

*អដ្ឋកថានៃសូត្រខាងដើម អំពីបញ្ចមសូត្រនោះ ក្នុងបញ្ចក-និបាត អង្គុត្តរនិកាយ ថា " បទថា **ន បរិយាបុណន្តិ** បានដល់ រមែងមិនសិក្សារៀនសូត្រ " ។*

១- សុត្តន្តដិបក ភាគទី ៤៥ ទំព័រទី ៩៦ ។

មន្តលត្ថទីបនីប្រែ

(៥០) ក៏ព្រោះធម្មទាន ជាបទដ្ឋាន នៃគុណ មានភាវ: ជាអ្នកដឹងជាក់ច្បាស់នូវអត្ថជាដើម, ហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា " **ជាមង្គល** " ។ សមដូចជាព្រះអង្គទ្រង់ត្រាស់ទុក ក្នុងតតិយវគ្គ បឋមបណ្ណាសក: ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយថា "ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬ ភិក្ខុ ជាសព្រហ្មចារី ណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនសម្តែងធម៌ ដល់ភិក្ខុសោះឡើយ, ក៏ប៉ុន្តែថា ព្រះសាស្តា ឬ ភិក្ខុ ជាសព្រហ្មចារីនោះ សម្តែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្តែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ ដោយប្រការណាៗ, ភិក្ខុនោះ រមែងជាអ្នកដឹងច្បាស់នូវអត្ថផង ជាអ្នកដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះៗ ដោយប្រការនោះ ៗ, កាលបើភិក្ខុនោះ ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌, បាមោជ្ជ: ក៏កើតឡើង, បើមានបាមោជ្ជ: ហើយ, បីតិ ក៏កើតឡើង, កាលបើមានចិត្តប្រកបដោយបីតិហើយ កាយ ក៏ស្ងប់រម្ងាប់, ភិក្ខុ អ្នកមានកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលសេចក្តីសុខ, ចិត្ត របស់ភិក្ខុដែលមានសេចក្តីសុខ តែងតម្កល់មាំ ។ ម្នាលភិក្ខុទាំងឡាយ នេះ ជាវិមុត្តាយតន: ទី២ ដែល

ពណ៌នាអំពីឌាន

ជាគុណជាត សម្រាប់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តស្ទុងទៅ (កាន់ព្រះនិព្វាន) នៅ, ចិត្ត ដែលមិនទាន់រួចស្រឡះ ក៏រមែងរួចស្រឡះផង អាសវៈដែលមិនទាន់អស់ទៅ ក៏រមែងដល់នូវការអស់ទៅផង ចិត្ត ដែលមិនទាន់ដល់ នូវធម៌ជាគ្រឿងក្សេមចាកយោគៈ ដ៏ប្រសើរ ក៏រមែងដល់ផង [១] " ។

បាលីវិមុត្តិសូត្រ ចប់ ។

*(៥១) អដ្ឋកថាវិមុត្តិសូត្រនោះថា " បទថា **ធម្មំ** បានដល់ រមែងសម្តែងនូវធម៌ គឺ សច្ចៈ ៤ ។ បទថា **អត្ថប្បដិសំវេទិនោ** បានដល់ អ្នកដឹងសព្វនូវសេចក្តីនៃបាលី ។ បទថា **ធម្មប្បដិសំ-វេទិនោ** បានដល់ អ្នកដឹងសព្វគ្រប់នូវបាលី ។ បីតិ ដែលទន់ៗ ឈ្មោះថា ចាមោជ្ជៈ ។ បីតិ ដ៏មានកម្លាំង ដែលមានអាការត្រេកអរ ឈ្មោះថា បីតិ ។ នាមកាយ ឈ្មោះថា កាយ ។ បទថា **បស្សម្ភតិ** ប្រែថា តែងស្ងប់រម្ងាប់ ។ ២ បទថា **សុខំ វេទេតិ** មានសេចក្តីថា រមែងបានចំពោះនូវសេចក្តីសុខ ។ បទថា **សមាធិ យតិ** មានសេចក្តីថា ចិត្ត រមែងតម្កល់មាំ ដោយសមាធិ ដែលសម្បយុត្ត ដោយព្រះអរហត្តផល ។ មែនពិត ភិក្ខុនេះ កាល*

១- សុត្តន្តបិដក ភាគ ទី ៤៥ ទំព័រ ទី ៤១ ។

មន្តលត្ថទីបនីប្រែ

ស្តាប់ធម៌នោះ រមែងដឹងច្បាស់នូវឈាន វិបស្សនា មគ្ត និង ផល ក្នុងឋានៈដែលមកហើយៗ, កាលបើភិក្ខុនោះ ដឹងយ៉ាងដូច្នេះ, បីតិ រមែងកើតឡើង, ភិក្ខុនោះ កាលមិនឲ្យដើម្បីបន្ធូរបន្ថយ ក្នុងចន្ទោះ នៃបីតិនោះបានទេ ជាអ្នកប្រកបដោយ ឧបចារកម្មដ្ឋាន ចំរើន វិបស្សនា ហើយ រមែងសម្រេច នូវព្រះអរហត្ត, ព្រះដ៏មានព្រះ ភាគ ទ្រង់សំដៅយកព្រះអរហត្តនោះ ទើបទ្រង់ត្រាស់ព្រះតម្រាស់ ថា **ចិត្តំ សមាធិយតិ** ដូច្នេះ" ។

(៥២) នយ មកក្នុងអដ្ឋកថានៃវិមុត្តិសូត្រនោះថា " បទថា **វិមុត្តាយតនំ** បានដល់ ហេតុនៃការរួចផុត ។ បទថា **យត្ត** មាន សេចក្តីថា ក្នុងហេតុនៃការរួចផុតណា " ។

ដីកាវិមុត្តិសូត្រនោះថា " ២ បទថា **បាលិអត្ថំ អាជានន្តស្ស** មានសេចក្តីថា ជាអ្នកដឹង នូវសេចក្តីនៃបាលីនោះៗ តាមសេចក្តី ពិត ដោយនយជាដើមថា សីល មកហើយ ក្នុងបាលីប្រទេសនេះ, សមាធិ មកហើយ ក្នុងបាលីប្រទេសនេះ, បញ្ញា មកហើយ ក្នុង បាលីប្រទេសនេះ ដូច្នេះ ឈ្មោះថា ជាអ្នកដឹងសព្វគ្រប់ នូវបាលី ព្រោះបាលីជាគ្រឿងដឹង នូវសេចក្តី នៃបាលីនោះ ។ ២ បទថា **តរុណា បីតិ** មានសេចក្តីថា បីតិ ដ៏ស្រាល គ្រាន់តែកើតឡើង រមែងកើតឡើង ។ សួរថា តើកើតឡើងដូចម្តេច? ។ ឆ្លើយថា

ពណ៌នាអំពីឆាន

ជាមោជ្ជ: ដែលមានសេចក្តីរីករាយសប្បាយជាលក្ខណ: រមែងកើតឡើង ដល់ភិក្ខុដែលពិចារណានូវធម៌ តាមដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ជាអ្នកប្រកាន់យកនូវសមាចារខាងផ្លូវកាយ វាចា និង ចិត្ត របស់ខ្លួន ដែលសមគួរដល់ធម៌ នោះឯង និង សម្រេចសោមនស្ស ។ ២ បទថា **តុដ្ឋាការភូតា ពលវប្បីតិ** មានសេចក្តីថា បីតិដ៏មានកម្លាំង ឈ្មោះថា មានអាការត្រេកអរ យ៉ាងក្រៃលែង ព្រោះភាវ:ជាបីតិ ដែលមានអាសេវន: ដែលបានហើយ ដោយអំណាចនៃបីតិ ដែលកើតមុន ឈ្មោះថា អាចដើម្បនឹងជាបច្ចយនៃបស្សទ្ធិ ព្រោះអាចរម្ងាប់នូវសេចក្តីខ្ងល់ខ្ងាយខាងផ្លូវកាយ និង ចិត្តបាន ។ ព្រោះកាលបើនាមកាយ ស្ងប់រម្ងាប់, សូម្បីរូបកាយ ក៏រមែងស្ងប់រម្ងាប់ផងដែរ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល យ៉ាងនេះថា **នាមកាយោ បស្សម្ភតិ** ដូច្នេះ ។ ២ បទថា **សុខំ បដិលភតិ** មានសេចក្តីថា រមែងបានចំពោះនូវនិរាសមិសសុខ ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ដែលអាចដើម្បីនឹងជាបច្ចយ នៃការតាំងមាំ នៃចិត្ត ដែលកំពុងតែពោល ។ ក្នុងបទថា **សមាធិយតិ** នេះ ព្រះអដ្ឋកថាចារ្យ កាលនឹងសម្តែងថា ព្រះមានព្រះភាគ ទ្រង់មិនអធិប្បាយសមាធិទូទៅទេ, តាមពិតហើយ ទ្រង់អធិប្បាយសមាធិ ដ៏ខ្ពង់ខ្ពស់ ដូច្នេះ ទើបពោលថា

មន្តលត្ថទីបនីប្រែ

អរហត្តផលសមាធិនា សមាធិយតិ ។ ពាក្យថា ***អយញ្ហិ*** ជាដើម ជាគ្រឿងប្រកាស នូវភាវៈនៃទេសនា របស់ភិក្ខុនោះ ជាហេតុឲ្យ បុគ្គលដូច្នោះ បានចំពោះសមាធិ ដូចបានពោលមកហើយ, ព្រោះ ទេសនានោះ ជាហេតុនៃវិមុត្តិ ។ បទថា ***ឧសក្កិតុំ*** គឺ ដើម្បី វិនាស " ។

(៥៣) នយដីកានៃវិមត្តិសូត្រនោះថា " ទីកើត គឺហេតុ នៃ វិមុត្តិ គឺ ការរួចផុតអំពីវដ្តទុក្ខ ឈ្មោះថា វិមុត្តាយតនៈ ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា ***វិមុចូនការណំ*** ដូច្នេះ " ។

គប្បីឃើញសន្និដ្ឋាន ថា " ការស្តាប់ធម៌ និង អភ័យទាន ព្រះមានព្រះភាគ ទ្រង់សង្ត្រោះ ដោយធម្មទាន ដូចគ្នា ក៏ពិតមែន, ទោះបីជាដូច្នោះ ការស្តាប់ធម៌ និង អភ័យទានទាំង ២ នោះ រមែងមិនបាន ក្នុងមង្គលបទនេះទេ ព្រោះបណ្តាការស្តាប់ធម៌ និង អភ័យទាន ទាំង ២ នោះ អភ័យទាន ខ្ញុំ នឹងកំណត់យក ក្នុង មង្គលបទថា ***អារតី វិរតី បាបា*** នេះ និង ការស្តាប់ធម៌ក្រៅពីនេះ ខ្ញុំ នឹងពោល ក្នុងមង្គលបទថា ***កាលេន ធម្មស្សវនំ*** ដូច្នេះឯង " ។

ពណ្ណិនាអំពីបទថា ទាន ចប់ ។

❋ ❋ ❋

ពណ៌នាអំពីការប្រព្រឹត្តិធម៌

(៥៤) ព្រះអដ្ឋកថាចារ្យ ពោល ក្នុងអដ្ឋកថា មង្គលសូត្រ នេះ ថា " ការប្រព្រឹត្តិកុសលកម្មបថ ១០ ប្រការ ឈ្មោះថា **ធម្មចរិយា** " ។

អដ្ឋកថានៃឆដ្ឋសូត្រ ក្នុងទុតិយវគ្គ នៃទុកនិបាត អង្គុត្តរ-និកាយ ថា " កុសលកម្មបថ ១០ ប្រការ ឈ្មោះថា ការប្រព្រឹត្តិ ធម៌ និង កិរិយាប្រព្រឹត្តិដ៏សមគួរ " ។

កុសលកម្មបថ ១០ ប្រការ ក្នុងអដ្ឋកថាទាំង ២ នោះ ខ្ញុំ បានពោលហើយ ក្នុងអាគារិយវិនិច្ឆ័យ ឯ្ងដ៏ខាងក្រោយទ្ចុះឯង ។

ព្រះអដ្ឋកថាចារ្យ ពោលពាក្យនេះ ក្នុងអដ្ឋកថានៃមង្គល សូត្រនេះ ថា " ការប្រព្រឹត្តិធម៌ ឬ ការប្រព្រឹត្តិ ដែលមិនច្រាស ចាកធម៌ ឈ្មោះថា ធម្មចរិយា " ។

នយដែលមក ក្នុងអដ្ឋកថាសាលេយ្យកសូត្រ ថា " ការ ប្រព្រឹត្តិធម៌ ឈ្មោះថា ធម្មចរិយា គឺ កិរិយាធ្វើតាមធម៌ " ។

នយដែលមក ក្នុងដីកា នៃសាលេយ្យកសូត្រនោះ ថា "ចេតនា ដែលប្រព្រឹត្តទៅហើយយ៉ាងដូច្នោះ ឈ្មោះថា ធម្មចរិយា ព្រោះអត្ថវិគ្រោះថា បុគ្គល រមែងប្រព្រឹត្តធម៌ ដោយចេតនាទ្ចុះ ។ មួយទៀត ប្រយោគ ដែលមានចេតនានោះ ជាសមុដ្ឋាន បណ្ឌិត គប្បីឃើញថា ជាធម៌ ។ មួយទៀត ធម្មជាតិ ឯណា មិនទៅ

មង្គលត្ថទីបនីប្រែ

ប្រាសចាកធម៌ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ធម៌, ធម៌ និង កិរិយាប្រព្រឹត្តិធម៌នោះ ហេតុនោះ ទើបឈ្មោះថា ធម្មចរិយា " ។

(៥៥) កិរិយាប្រព្រឹត្តិធម៌នោះ បណ្ឌិត គប្បីជ្រាប ថា " ជាមង្គល " ព្រោះជាហេតុ នៃឥដ្ឋផល មានការកើត ក្នុងឋានសួគ៌ ជាដើម ។

ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ដល់ព្រាហ្មណ៍ និង គហបតីទាំងឡាយ អ្នកឈ្មោះថាសាលេយ្យក: ព្រោះជាអ្នកអាស្រ័យនៅ ក្នុងសាលគ្រាម ក្នុងកោសលរដ្ឋ ទើបទ្រង់ត្រាស់ទុកហើយ ក្នុងសាលេយ្យកសូត្រ ក្នុងបញ្ចមវគ្គ នៃមូលបណ្ណាសក: [១] ថា ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយ ខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅ កើតក្នុងលោក គឺ (មនុស្ស) សុគតិ ឋានសួគ៌ ព្រោះហេតុតែកិរិយាប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ កិរិយាប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌ ដោយកាយ មាន ៣ ប្រការ ដោយវាចា មាន ៤, កិរិយាប្រព្រឹត្តិស្មើ ពោលគឺ ការប្រព្រឹត្តិ តាមធម៌ ដោយចិត្ត មាន ៣ ប្រការ ។

១- សុត្តន្តបិដក ភាគទី ២២ ទំព័រទី ២៤០ ។

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ ក៏កិរិយាប្រព្រឹត្តិស្មើ ពោលគឺ ការប្រព្រឹត្តិតាមធម៌ ដោយកាយ មាន ៣ ប្រការ តើ ដូចម្តេច? ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ បុគ្គលពួក មួយ ក្នុងលោកនេះ លះបង់ចាណាតិបាត រៀងស្រឡះចាក ចាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ជាអ្នកដាក់ចុះនូវសស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះ ដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់នៅ, ជាអ្នកលះបង់ អទិន្នាទាន រៀរស្រឡះចាកអទិន្នាទាន ដូចជាគ្រឿងឧបករណ៍ គឺ សម្បត្តិនៃបុគ្គលឯណា ដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ក៏ ជាអ្នកមិនកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យនោះ ដោយចំណែក នៃចិត្តលួចឡើយ, ជាអ្នកលះបង់នូវកាមេសុមិច្ឆាចារ រៀរស្រឡះ ចាកកាមេសុមិច្ឆាចារ ទោះបីស្ត្រីទាំងឡាយណា ដែលមាតារក្ស បិតារក្ស បងប្អូនប្រុសរក្ស បងប្អូនស្រីរក្ស ញាតិរក្ស មាន ស្វាមី ប្រកបដោយអាជ្ញា ដោយហោចទៅ សូម្បីតែស្ត្រី ដែល បុរសបំពាក់កម្រងផ្កាឲ្យ ក៏ជាអ្នកមិនដល់ នូវការប្រព្រឹត្តិកន្ទ ក្នុង ស្ត្រីទាំងឡាយ មានសភាពដូច្នោះឡើយ, ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ កិរិយាប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិ តាម ធម៌ ដោយកាយ ៣ ប្រការដូច្នេះឯង ។ ម្នាលព្រាហ្មណ៍ និង

មន្តលត្ថនីបនីប្រែ

គហបតីទាំងឡាយ កិរិយាប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិ តាមធម៌ ដោយវាចា មាន ៤ ប្រការ តើដូចម្តេច? ។ ម្នាលព្រាហ្មណ៍និង គហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកលះបង់នូវមុសាវាទ រៀរស្រឡះចាកមុសាវាទ ទោះឋិតនៅ ក្នុងរោងសភា ក្តី ឋិតនៅ ក្នុងបរិសទ្យ ក្តី ឋិតនៅ កណ្តាលញាតិ ក្តី ឋិតនៅ កណ្តាលសេនីយ៍ ក្តី ឋិតនៅ កណ្តាលរាជត្រកូល ក្តី គេនាំទៅធ្វើជាសាក្សីហើយ សួរថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ, អ្នកដឹងនូវហេតុណា ចូរនិយាយប្រាប់នូវហេតុនោះ ដូច្នេះ, បុរសនោះ កាលមិនដឹង ក៏និយាយថា ខ្ញុំមិនដឹងទេ ឬ កាលដឹង ក៏និយាយប្រាប់ថា ខ្ញុំដឹង កាលមិនឃើញ ក៏និយាយប្រាប់ថា ខ្ញុំមិនឃើញ ឬ កាលឃើញ ក៏និយាយប្រាប់ថា ខ្ញុំឃើញ ដូច្នេះ ជាអ្នកមិនពោលនូវពាក្យកុហក ទាំងដឹងខ្លួន ដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះតែសំណូក គឺអាមិសបន្តិចបន្ពួចក្តី ជាអ្នកលះបង់នូវបិសុណវាចា រៀរស្រឡះចាកបិសុណវាចា គឺ ឲ្យពាក្យអំពីជននេះហើយ មិននាំទៅប្រាប់ជនឯណោះ ដើម្បីបំបែកជនទាំងនេះផង ឲ្យពាក្យអំពីជនឯណោះហើយ មិនមកប្រាប់ជនទាំងនេះ ដើម្បីបំបែកជនឯណោះផង ជាអ្នកផ្សះផ្សានូវពួកជន ដែលបែកគ្នាហើយផង ជាអ្នកទំនុកបំរុងនូវពួកជន ដែលព្រម

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ព្រៀងគ្នា ស្រាប់ហើយផង ជាអ្នកត្រេកអរ តែក្នុងសេចក្តីព្រម ព្រៀងគ្នា ជាអ្នកមានតម្រេក តែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នក រីករាយ តែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នកពោលនូវវាចា ដែល ធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ដោយប្រការដូច្នេះ, ជាអ្នកលះ បង់ផរុសវាចា រៀរស្រឡះចាកផរុសវាចា គឺ វាចាណា មិនមាន ទោស ជាសុខដល់ត្រចៀក គួរឲ្យកើតសេចក្តីស្រលាញ់ ចូលទៅ កាន់ហឫទ័យ ជាវាចាអ្នកបុរី ជាទីស្រលាញ់ដល់ជនច្រើន ជាទី ពេញចិត្តដល់ជនច្រើន ជាអ្នកពោលនូវវាចា មានសភាពដូច្នោះ, ជាអ្នកលះបង់ នូវសម្ផប្បលាបៈ រៀរស្រឡះ ចាកសម្ផប្បលាបៈ ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជា អត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យដែលជាវិនយ ជាអ្នក ពោលពាក្យ ដែលគួរឲ្យតាំងទុក ក្នុងហឫទ័យ ត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយ ប្រយោជន៍, ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ កិរិយាប្រព្រឹត្តិ ស្មើ ពោលគឺការប្រព្រឹត្តិ តាមធម៌ ដោយវាចា មាន ៤ ប្រការ យ៉ាងដូច្នេះឯង ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ កិរិយា ប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិ តាមធម៌ ដោយចិត្ត មាន ៣ ប្រការ តើដូចម្តេច? ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ

មន្តលត្តនីបនីប្រែ

បុគ្គល ពួកមួយ ក្នុងលោកនេះ ជាអ្នកមិនច្រើន ដោយអភិជ្ឈា, គ្រឿងឧបករណ៍ ដែលជាសម្បត្តិ នៃបុគ្គលដទៃឯណា, ក៏ជាអ្នកមិនគយគន់ នូវគ្រឿងឧបករណ៍នោះថា ឫហ្នុ៎ គ្រឿងឧបករណ៍ ដែលជាសម្បត្តិ នៃបុគ្គលដទៃឯណា, គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញ ដូច្នេះទ្បើយ, មួយទៀត ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្ត ដែលទោសមិនប្រទូស្តហើយថា សត្វទាំងឡាយនេះ ចូរកុំមានពៀរ កុំមានព្យាបាទ កុំមានទុក្ខ រក្សាខ្លួនឲ្យបានសេចក្តីសុខចុះ ដូច្នេះ, មួយវិញទៀត ជាអ្នកមានគំនិតយល់ត្រូវ យើញនូវសេចក្តីមិនវិបរិត ថា ទាន ដែលបុគ្គល ឲ្យហើយ មានផល, ការបូជាធំ មានផល, ការបូជាតូច មានផល, ផលនិង វិបាក នៃកម្មទាំងឡាយ ដែលបុគ្គលធ្វើល្អ និង អាក្រក់ មាន, លោកនេះមាន, លោកខាងមុខមាន, មាតា មានគុណ, បិតា មានគុណ, សត្វទាំងឡាយ ដែលជាឧបបាតិកកំណើត មាន, ពួកសមណព្រាហ្មណ៍ ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិ ដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា ចំពោះខ្លួនឯង នូវលោកនេះ និង លោកខាងមុខ ហើយប្រកាស ក៏មាន ដូច្នេះ, ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ កិរិយាប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិ តាមធម៌ ដោយចិត្ត មាន ៣ ប្រការ ដូច្នេះឯង ។

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ សត្វទាំងឡាយ ពួកខ្ញុះ ក្នុងលោកនេះ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្ដី ស្លាប់ទៅ រមែងចូលទៅ កាន់សុគតិ សួគ៌ ទេវលោក យ៉ាងនេះ ព្រោះតែកិរិយាប្រព្រឹត្តិស្មើ ពោលគឺ ការប្រព្រឹត្តិ តាមធម៌ យ៉ាង ដូច្នេះឯង ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ បើបុគ្គលជា អ្នកប្រព្រឹត្តតាមធម៌ ជាអ្នកប្រព្រឹត្តស្មើ គប្បីប្រាថ្នាថា ឱហ្ន៎ អាត្មា អញលុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈទៅ សូមបាន ចូលទៅ កាន់ភាពជាអ្នកនៅរួមគ្នា ជាមួយនឹងពួកខត្តិយមហា-សាលទាំងឡាយ ដូច្នេះ, ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏ បានសម្រេច ព្រោះថា បុគ្គលនោះ លុះទម្លាយរាងកាយ ខាងមុខ បន្ទប់អំពីមរណៈទៅ ក៏បានចូលទៅកាន់ភាពជាអ្នកនៅរួម ជាមួយ គ្នានឹងខត្តិយមហាសាលទាំងឡាយមែន, សេចក្ដីនោះ ព្រោះហេតុ ដូចម្ដេច? ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តតាមធម៌ ជា អ្នកប្រព្រឹត្តស្មើ ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ បើ បុគ្គលឯណា ជាអ្នកប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ គប្បីប្រាថ្នា ថា ឱហ្ន៎ ខ្ញុនអាត្មាអញ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ទៅ សូមឲ្យបានចូលទៅ កាន់ភាពជាអ្នកនៅរួម ជាមួយនឹងពួក ព្រាហ្មណ៍មហាសាល ..... ពួកគហបតីមហាសាល ..... ពួកទេវតា

មន្តលត្តទីបនីប្រែ

ជាន់ចាតុមហារាជិកា..... ពួកទេវតាជាន់តាវត្តិង្ស..... ពួកទេវតាជាន់យាមា..... ពួកទេវតាជាន់តុសិត..... ពួកទេវតាជាន់និម្មានរតី..... ពួកទេវតាជាន់បរនិម្មិតវសវត្តី..... ពួកទេវតាជាន់ព្រហ្មកាយិកា..... ពួកទេវតាជាន់អាភា..... ពួកទេវតាជាន់បរិត្តាភា..... ពួកទេវតាជាន់អប្បមាណាភា..... ពួកទេវតាជាន់អាភស្សរា..... ពួកទេវតាជាន់សុភា..... ពួកទេវតាជាន់បរិត្តសុភា.... ពួកទេវតាជាន់អប្បមាណសុភា ... ពួកទេវតាជាន់សុភកិណ្ហា .... ពួកទេវតាជាន់រៃហប្ផលា .... ពួកទេវតាជាន់អវិហា ... ពួកទេវតាជាន់អតប្បា ... ពួកទេវតាជាន់សុទស្សា... ពួកទេវតាជាន់សុទស្សី ... ពួកទេវតាជាន់អកនិដ្ឋកា... ពួកទេវតាដែលកើតក្នុងវអាកាសានញ្ចាយតនៈ .... ពួកទេវតាដែលកើត ក្នុងវិញ្ញាណញ្ចាយតនៈ ... ពួកទេវតាដែលកើតក្នុងអាកិញ្ចញ្ញាយតនៈ.. ពួកទេវតា ដែលកើត ក្នុងនេវសញ្ញានាសញ្ញាយតនៈ យ៉ាងដូច្នេះ, ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយ ខាងមុខបន្ទប់អំពីមរណៈទៅ ក៏បានទៅកើត ជាមួយគ្នានឹងពួកទេវតាទាំងឡាយ ដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈ មែន, សេចក្តីនោះ ព្រោះហេតុដូចម្តេច? ព្រោះហេតុថា បុគ្គលនោះ ជាប្រព្រឹត្តតាមធម៌ ជាអ្នកប្រព្រឹត្តស្មើ ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ បើបុគ្គល

ពណ៌នារំពីការប្រព្រឹត្តិធម៌

ជាអ្នកប្រព្រឹត្ត តាមធម៌ ប្រព្រឹត្តស្មើ គប្បីប្រាថ្នា ថា ឯហ្នាំ ខ្ជួន អាត្មាអញ សូមធ្វើឲ្យបានជាក់ច្បាស់ហើយ សម្រេចចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលគ្មានអាសាវ: ព្រោះការអស់ទៅនៃអាសវ:ទាំងឡាយ ដោយប្រាជ្ញា ចំពោះខ្ជួនឯង ក្នុងបច្ចុប្បន្ននេះនុ៉ះ ដូច្នេះ, ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ គប្បីធ្វើឲ្យជាក់ច្បាស់ហើយ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវ: ព្រោះការអស់ទៅ នៃអាសវ: ទាំងឡាយ ដោយប្រាជ្ញា ចំពោះខ្ជួនឯង ក្នុងបច្ចុប្បន្ននេះ, សេចក្តីនោះ ព្រោះហេតុដូចម្តេច? ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្ត តាមធម៌ ជាអ្នកប្រព្រឹត្តស្មើ " ។

ចាលី ចប់ ។

(អដ្ឋកថា)

(៥៦) នយដែលមក ក្នុងអដ្ឋកថាទុកនិបាត អង្គុត្តរនិកាយ ថា " បទថា ***ធម្មចរិយសមចរិយហេតុ*** *គឺ មានការប្រព្រឹត្តិ ស្មាំស្មើ ពោលគឺ ការប្រព្រឹត្តិតាមធម៌ជាហេតុ, អធិប្បាយថា ព្រោះហេតុនៃការប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌នោះ បានដល់ មានការប្រព្រឹត្តិស្មើ ពោលគឺ ការប្រព្រឹត្តិតាមធម៌នោះ ជាបច្ចយ " ។*

មន្តលត្ថទីបនីប្រែ

អដ្ឋកថាសាលេយ្យកសូត្រថា " បទថា **តិវិធំ** គឺ ដោយ ចំណែកទាំងឡាយ ៣ ។ បទថា **កាយេន** គឺ ដោយកាយទ្វារ " ។

ន័យដែលមកក្នុងអដ្ឋកថាសាលេយ្យកសូត្រ និង ទុកនិបាត អង្គុត្តរនិកាយ ថា " កិរិយាប្រព្រឹត្តិស្មាំស្មើ ឬ កិរិយាប្រព្រឹត្តិ នូវ កម្ម ដែលត្រឹមត្រូវ ហេតុនោះ ទើបឈ្មោះថា ការប្រព្រឹត្តិស្មើ ។ ការប្រព្រឹត្តិតាមធម៌ និង ការប្រព្រឹត្តិស្មើនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ការប្រព្រឹត្តិតាមធម៌ និង ការប្រព្រឹត្តិស្មើ, អធិប្បាយ ថា កិរិយាប្រព្រឹត្តិស្មើ ពោលគឺកិរិយាប្រព្រឹត្តិតាមធម៌ " ។

(៥៧) អដ្ឋកថាចូឡហត្ថិបទោបមសូត្រ ក្នុងតតិយវគ្គ នៃ មូលបណ្ណាសក: និង អដ្ឋកថាចតុត្ថបណ្ណាសក: ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ ថា " បទថា **បាណាតិបាតំ បហាយ** គឺ លះបង់ ភាពនៃទោសគ្រឿងទ្រុស្តសីល ពោលគឺចេតនា ដែលញ្ចាំងសត្ថ មានជីវិតឲ្យជ្លាក់ចុះកន្ថង ។ បទថា **បដិវិរតោ** មានសេចក្តីថា រមែងជាអ្នកវៀរចាក គឺ វៀរស្រឡះ ចាកភាពជាអ្នកមានទោស នៃគ្រឿងទ្រុស្តសីលនោះ ចាប់ដើមអំពីពេលដែលខ្ជូន លះបង់ ហើយ ។ ២ បទថា **និហិតទណ្ឌោ និហិតសត្ថោ** មានសេចក្តីថា ឈ្មោះថា ជាអ្នកមានដំបង ទម្លាក់ចោលហើយ និង ជាអ្នកមាន សស្ត្រាវុធ ទម្លាក់ចោលហើយ ព្រោះមិនប្រព្រឹត្តកាន់យកនូវដំបង

ពណ៌នារំពីការប្រព្រឹត្តិធម៌

និង សស្ត្រាវុធ ដើម្បីប្រយោជន៍ ដល់ការចូលទៅសម្ងាប់សត្វ ដទៃ ។ ក៏គ្រឿងឧបករណ៍ ដែលសេសសស់ទាំងអស់ លើកលែង តែដំបងចេញ គប្បីជ្រាបថា សស្ត្រា ក្នុងបទថា **និក្ខិត្តសត្ថោ** នេះ ព្រោះជាគ្រឿងបៀតបៀន នូវសត្វទាំងឡាយ ។ ប៉ុន្តែថា ពួកភិក្ខុ ទាំងឡាយកាន់យកនូវឈើច្រត់ របស់មនុស្សចាស់ក្តី ឈើជម្រះ ធ្មេញក្តី កាំបិតព្រាក្តី កាំបិតបត់ក្តី ឯណាមួយ ត្រាច់ចរទៅ, វត្ថុ មានឈើច្រត់ជាដើមនោះ មិនចាត់ថាជារបស់សម្រាប់បៀតបៀន បុគ្គលដទៃទ្បើយ, ព្រោះហេតុនោះ ភិក្ខុទាំងនោះ រមែងដល់នូវការ រាប់ថា ជាអ្នកមានដំបងទម្ងាក់ចុះហើយ មានសស្ត្រាវុធទម្ងាក់ចុះ ហើយមែនពិត ។ បទថា **លជ្ជី** គឺជាអ្នកប្រកបដោយសេចក្តី អៀនខ្មាស ដែលមានការខ្ពើមរអើមបាប ជាលក្ខណៈ ។ បទថា **ទយាបន្នោ** គឺ ដល់នូវសេចក្តីអាណិត បានដល់ នូវភាពជាអ្នក មានចិត្តមេត្តា ។ បទថា **សព្វប្បាណភូតហិតានុកម្បី** គឺ ជាអ្នក អនុគ្រោះពួកសត្វទាំងពួង ដោយប្រយោជន៍សុខ, អធិប្បាយថា ឈ្មោះថា ជាអ្នកមានចិត្តប្រកប ដោយប្រយោជន៍ ដល់ពួកសត្វ ទាំងឡាយទាំងពួង ព្រោះជាអ្នកមានសេចក្តីអាណិតនោះឯង ។ បទថា **វិហរតិ** គឺ រមែងញ្ចុាំងអត្តភាព ឲ្យប្រព្រឹត្តទៅ បានដល់ ចិញ្ចឹមជីវិត" ។

មង្គលត្ថទីបនីប្រែ

(៥៨) អដ្ឋកថាសាលេយ្យកសូត្រ ថា " ពាក្យថា **យន្ត្ថ បរេស្ស** គឺ ទ្រព្យ ដែលជារបស់អ្នកដទៃ ឯណានីមួយ ។ បទថា **ឧបវិត្ត្ថុបការណំ** គឺ វត្ថុជាឧបការណ៍ ដល់ទ្រព្យគ្រឿងចេញចិត្ត បានដល់ ទ្រព្យសម្បត្តិដែលជាបរិក្ខារ ដែលញ៉ាំងសេចក្តីត្រេកអរឲ្យកើតឡើង របស់បុគ្គលដទៃនោះឯង ។ បទថា **គាមគតំ វ** គឺ ដែលបុគ្គលតាំងទុកខាងក្នុងនៃស្រុកក្តី ។ បទថា **អរញ្ញគតំ វ** គឺ ដែលបុគ្គលដាក់ទុក ក្នុងព្រៃ គឺក្នុងទីទាំងឡាយ មានបង្គាបនៃដើមឈើ និងលើកំពូលភ្នំជាដើម ។ បទថា **អទិន្ន** គឺ ដែលបុគ្គលទាំងឡាយដទៃនោះ មិនបានឲ្យហើយ ដោយកាយ និង ដោយវាចា ។ ក្នុងបទថា **ថេយ្យសង្ខ្យាតំ** នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖ ចោរ បុគ្គលហៅថា អ្នកលួច, ភាពនៃបុគ្គលអ្នកលួចឈ្មោះថា ភាពនៃចោរ ។ បទថា **ថេយ្យ** ន្ទុ ជាឈ្មោះ នៃចិត្តដែលជាគ្រឿងលួច ។ បទថា **សង្ខ្យាតំ** ន្ទុ ដោយសេចក្តី ជាឈ្មោះនៃចំណែកមួយ ដូចជា **សង្ខ្យាត** សព្ព ក្នុងឧទាហរណ៍ ទាំងឡាយ ថា ក៏ចំណែកនៃធម៌គ្រឿងយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ដូច្នេះជាដើម ។ ចំណែកនោះផង ភាពនៃចិត្តលួចផង ព្រោះហេតុនោះ ទើបឈ្មោះថា **ថេយ្យសង្ខ្យាតំ**, អធិប្បាយថា ចំណែក នៃចិត្តមួយ ដែលជាចំណែក នៃចិត្តលួច " ។ ក៏ពាក្យថា

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ថេយ្យសង្ខាតំ *ន ុ៎ះ ជាបឋមវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ, ព្រោះ ហេតុនោះ បណ្ឌិតគប្បីឃើញ ដោយសេចក្តីថា ដោយចំណែក នៃចិត្តលួច ។ បទថា* ***មាតុរក្ខិតា*** *មានសេចក្តីថា មាតា ប្រតិបត្តិ ស្ត្រីណា, កាលបើបិតាបាត់បង់ទៅក្តី ស្លាប់ចោលហើយក្តី, ដោយ សង្គ្រហវត្ថុទាំងឡាយ មានអាហារ និង គ្រឿងស្លៀកពាក់ជាដើម ថែរក្សា ដោយតាំងចិត្តថា អាត្មាអញ នឹងឲ្យនូវធីតា របស់អាត្ម អញ ដែលចម្រើនវ័យហើយ ក្នុងផ្ទះនៃត្រកូល ដូច្នេះ, ស្ត្រីនេះ ឈ្មោះថា ស្ត្រី ដែលមាតារក្សាហើយ ។ សូម្បីស្ត្រីដែលបិតារក្ស ជាដើម បណ្ឌិតក៏គប្បីជ្រាប ដោយឧបាយន ុ៎ះ ។ ចំណែកត្រកូល ទាំងឡាយ, សូម្បីកាលបើពួកសត្ត ដែលកើតក្នុងគភ៌ កើតហើយ ក្នុងផ្ទៃពោះ, ក៏ធ្វើកតិកាគ្នាថា បើខ្ញុំមានកូនប្រុស, អ្នកមានកូនស្រី ធីតារបស់អ្នក នឹងមិនបាន ដើម្បីនឹងទៅ ក្នុងត្រកូលដទៃ, ចូរបាន ដល់កូនប្រុសរបស់ខ្ញុំ យ៉ាងដូច្នេះ, ស្ត្រី ដែលមាតា និង បិតា បាន ដណ្តឹងទុកហើយ សូម្បីក្នុងផ្ទៃពោះយ៉ាងនេះ ក៏ឈ្មោះថា ស្ត្រីដែល មានស្វាមី ។ មួយទៀត ស្ត្រី ដែលមានអាជ្ញា ដែលឥស្សរជន មានព្រះរាជាជាដើម បានតាំងទុកផ្តាតចំឈ្មោះក្តី ផ្ទះក្តី ផ្ទាវ ថ្ម ល់ក្តី យ៉ាងនេះ ថា បុរសណា កន្ទ ងនូវស្ត្រី អ្នកមានឈ្មោះយ៉ាងនេះ, អាជ្ញា មានប្រមាណប៉ុណ្ណ ុ៎ះ នឹងបានដល់បុរសនោះ យ៉ាងដូច្នេះ*

មង្គលត្ថទីបនីប្រែ

ឈ្មោះថា ស្ត្រី ដែលមានអាជ្ញាជុំវិញខ្លួន ។ ២ បទថា **អន្ត្ថមេសោ មាលាគុឡ្ឍបរិក្ខិតាបិ** មានសេចក្ដីថា ដោយកំណត់ទីបំផុត នៃកំណត់ទាំងពួង ស្ត្រី ដែលបុរសខ្ទះបោះផ្ការមែងទៅ ពួងជ៏ខាងលើ ក្បាលនៃស្ត្រីនោះ ដោយសំគាល់ថា ស្ត្រីនេះ ជាភរិយា របស់ខ្ញុំ ដូច្នេះ បំពាក់សូម្បីដោយវត្ថុ ត្រ៏មតែកម្រងផ្ការ ។ ច្រើនបទ **តថារូបាសុ ចារិត្តំ អាបជ្ជិតា** មានសេចក្ដីថា រ៉ាមែងជាអ្នកធ្វើការ ល្មើស ក្នុងស្ត្រីបែបនោះ ដោយអំណាចលក្ខណៈ នៃមិច្ឆាចារ ដែលព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងសម្ម៉ាទិដ្ឋិសូត្រ ។ បទថា **សកគ្គតោ** គ៏ នៅហើយ ក្នុងរោងសភា ។ បទថា **បរិសគ្គតោ** គ៏ នៅហើយក្នុងបរិស័ទនៃអ្នកស្រុក ។ បទថា **ញាតិមជ្ឌ្ឍគតោ** គ៏ នៅហើយ ក្នុងកណ្ដាលនៃបុគ្គលអ្នកទទួលទ្រព្យមត៌ាកទាំងឡាយ ។ បទថា **បូគមជ្ឌ្ឍគតោ** គ៏ នៅហើយ ក្នុងកណ្ដាល នៃសេនាទាំងឡាយ ។ បទថា **រាជកុលមជ្ឌ្ឍគតោ** គ៏ នៅហើយ ក្នុងកណ្ដាលរាជត្រកូល បានដល់ ក្នុងរោងវិនិច្ឆ័យដ៏ធំ ។ បទថា **អានីតោ** គ៏ ត្រូវគេនាំទៅ ដើម្បីនឹងជណ្ដ៏ាងសួរ ។ ២ បទថា **សក្ខ៏ បុដ្ឋោ** គ៏ ត្រូវគេអាងធ្វើជាសាក្ស៏ីហើយយកចោទសួរ ។ ពាក្យថា **ឯហាម្ភោ បុរិសា** ន៏ុ គ៏ជាពាក្យអាលបន: ។ ពាក្យថា **អត្ថហេតុ វា បរហេតុ វា** មានសេចក្ដីថា ព្រោះហេតុនៃអាយវ: មានដៃ និង

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ដើងជាដើម ឬ ព្រោះហេតុនៃទ្រព្យរបស់ខ្លួន ឬ របស់អ្នកដទៃ ។ ក្នុងបទថា **អាមិសកិញ្ចិក្ខហេតុ រ៉ា** នេះ លាភ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អធិប្បាយហើយ ។ បទថា **កិញ្ចិក្ខំ** គឺ រ៉ត្ថុណានីមួយ បានដល់រ៉ត្ថុបន្តិចបន្តួច ។ អធិប្បាយថា ព្រោះហេតុនៃថ្ងៃឈ្នួល ដោយហោចទៅ សូម្បីរ៉ត្ថុបន្តិចបន្តួច មានសត្វទទា សត្វក្រួច ទឹកដោះរាវថ្ងា មួយពែង និង ទឹកដោះខាប់ មួយដុំជាដើម ។ បទថា **សម្បជានមុសាភាសិតា** គឺ ជាអ្នកដឹងខ្លួនន៉ុះឯង ធ្វើការពោលពាក្យកុហក ។ ២ បទថា **ឥមេសំ ភេទាយ** គឺ ខ្លួនស្តាប់ពាក្យ ក្នុងសំណាក់ នៃពួកជនណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា **ឥតោ** ដូច្នេះ, ដើម្បីបំបែកជនទាំងឡាយនោះ ។ ២ បទថា **អមូសំ ភេទាយ** គឺ ខ្លួនបានស្តាប់ពាក្យ ក្នុងសំណាក់ នៃជនទាំងឡាយណា ដែលព្រះមានព្រះគាគ ទ្រង់ត្រាស់ថា **អមុត្រ** ដូច្នេះ, ដើម្បីបំបែកបំបាក់ជនទាំងឡាយនោះ" ។

(៥៩) អដ្ឋកថាហត្ថិបទោបមសូត្រជាដើម ថា " ច្រើនបទ ថា **កិន្នានំ រ៉ា សន្ធាតា** មានសេចក្តីថា កាលបើជនទាំងឡាយ ២ ពួកដែលជាមិត្រនឹងគ្នា ឬ ជាអ្នកដែលជាប់ទាក់ទងគ្នា មានរួមព្រះ ឧបជ្ឈាយ៍ជាមួយគ្នាជាដើម បែកបាក់គ្នាហើយ ដោយហេតុឯណា នីមួយន៉ុះឯង, បុគ្គល អ្នកប្រព្រឹត្តស្មើ ពោលគឺ ប្រព្រឹត្តតាមធម៌

មង្គលត្ថទីបនីប្រែ

ចូលទៅរកពួកមួយៗ ហើយ និយាយធ្វើសេចក្តីផ្ទះផ្សាគ្នាទ្បើងវិញ មានជាអាទិ៍ថា រឿងយ៉ាងដូច្នេះ មិនសមគួរ ដល់ពួកអ្នកទាំងឡាយ ដែលកើតក្នុងត្រកូល យ៉ាងនេះ ជាពហុស្សុត យ៉ាងដូច្នេះ សោះឡ្ហើយ ដូច្នេះ ។ បទថា **អនុប្ឋ្ទាតា** គឺ ជាអ្នកទំនុកបំរុងនូវជនដែលផ្ទះផ្សាគ្នាហើយ, អធិប្ប្ហាយថា ធម្មចារិសមចារីបុគ្គលឃើញជនទាំង ២ ពួក មានការព្រមព្រៀង សាមគ្គីក្នា ហើយ និយាយ ធ្វើឲ្យបានរ៉ឹងប៉ុ៉ងមាំមួន មានជាអាទ៍ ថា កិច្ចការនេះ ជាកិច្ចការដ៏សមគួរហើយ ដល់ពួកអ្នកទាំងឡ្ហាយ ដែលកើត ក្នុងត្រកូល យ៉ាងនេះ អ្នកដល់ព្រម ដោយគុណបែបនេះ ដូច្នេះ ។ សេចក្តីសាមគ្គី ជាទីមកត្រេកអរ មានដល់បុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានសេចក្តីសាមគ្គី ជាទីមកត្រេកអរ, អធិប្ប្ហាយថា ពួកជនអ្នកសាមគ្គីគ្នា មិនមាន ក្នុងទីណា, ធម្មចារិ-សមចារីបុគ្គល រ៉ាមង៉ាមិនប្ប្ហាថ្នា សូម្ប្ហីដើម្ប្ហីនឹ៉ងរស់នៅ ក្នុងទីនោះ ឡ្ហើយ ។ ចាលីថា **សមគ្គ្ហ្ហ្ហ្ហ្ហ** ដូច្នេះក៏មានខ្ញុ៉ះ ។ សេចក្តីក៏មានន័យដូចគ្នាដែរ ។ បទថា **សមគ្ គ្ហ្ហ** គឺ ជាអ្នកត្រេកអ្ហ្ហ្ហ្ហ ក្នុងពួកជន ដែលព្រមព្រៀងគ្នាហើយ, អធិប្ប្ហាយថា ធម្មចារិ-សមចារីបុគ្គល រ៉ាមង៉ាមិនប្ប្ហាថ្នា សូម្ប្ហីដើម្ប្ហីនឹ៉ងលះបង់ចោល នូវពួកជនអ្នកព្រមព្រៀងគ្នាហើយទាំងនោះ ហើយទៅ ក្នុងទីដទ៉ៃទ្ហៀត

ទ្បើយ ។ ឈ្មោះថា ជាអ្នកត្រេកអរ ក្នុងពួកជនដែលព្រមព្រៀងគ្នាហើយ ព្រោះវិគ្រោះថា ធម្មចារិសមចារីបុគ្គល បានឃើញក្តី បានស្តាប់ក្តី នូវពួកជនព្រមព្រៀងហើយ រមែងត្រេកអរ ។ ពាក្យថា **សមគ្គការណ៌ រាជ កាសិតា** មានសេចក្តីថា រាជាណាមួយ តែងធ្វើនូវសត្វទាំងឡាយ ឲ្យជាអ្នកមានការព្រមព្រៀងគ្នាទ្បើងវិញ, ធម្មចារិសមចារីបុគ្គល រមែងពោលនូវរាជានោះ ដែលជារាជាសម្តែងគុណ នៃសេចក្តីសាមគ្គីគ្នា តែម្យ៉ាងប៉ុណ្ណោះ, តែងមិនពោល នូវរាជាផ្សេងទៀត ក្រៅអំពីនេះទ្បើយ " ។

(៦០) អដ្ឋកថាសាលេយ្យកសូត្រ និង និក្ខេបកណ្ឌ ថា " ពាក្យថា **ផរុសំ រាជ បហាយ** មានសេចក្តីថា រាជា ឯណានីមួយ ជារាជាគ្រោតគ្រាត រ៉ឹងគ្ងឹង ក្តៅក្រហាយ ដល់អ្នកដទៃ ប៉ះទង្គិច ដល់បុគ្គលដទៃ ជិតដល់សេចក្តីក្រោធ១ីង មិនប្រព្រឹត្តទៅដើម្បីសមាធិ, លះបង់ចោលនូវរាជាបែបនោះ ។ បណ្តារាជាទាំងនោះ រាជា គ្រោតគ្រាត ដោយពាក្យជេរប្រទេច និង ពាក្យជិះជាន់សង្កត់សង្កិនជាដើម ព្រោះជារាជាដែលមានទោស ប្រៀបដូចជាក្រម៉ ដែលកើតទ្បើង លើដើមឈើ ដែលមានស្នាមដំបៅ យ៉ាងដូច្នោះឯង ឈ្មោះថា រាជា គ្រោតគ្រាត ដូចជាដុំក្រម៉ ។ ពាក្យពោលអាក្រក់ ឈ្មោះថា រាជារ៉ឹងគ្ងឹង ។ រាជាអាក្រក់នោះ ជារាជា

មជ្ឈលត្តនីបនីប្រែ

ដែលរីងរូស ដូចជាចូលទៅមុតនូវត្រចៀក ប្រៀបឧបមាដូចជាដើមឈើ ដែលស្អុយ ជាឈើរីង មានល្អង កំទេច ធ្លាក់ចេញជូច្នោះ, ព្រោះហេតុនោះ ទើបលោកពោល ថា ជាវាចារីងគ្ងីង ដូច្នេះ ។ វាចាក្តៅក្រហាយ គឺវាចាមិនជាទីពេញចិត្ត ដល់បុគ្គលទាំងឡាយ ដទៃ ជាវាចាដែលញ៉ាំងទោសឲ្យកើតឡើង ដល់បុគ្គលទាំងឡាយ ឯទៀត ឈ្មោះថា ជាវាចាធ្វើឲ្យក្តៅក្រហាយដល់បុគ្គលដទៃ ។ វាចាដែលប៉ះទង្គិច ដល់ជនទាំងឡាយដទៃ គឺវាចាដែលធ្វើសេចក្តីថ្នាំងថ្នាក់ចិត្ត មិនឲ្យដើម្បីនឹងទៅ សូម្បីដល់បុគ្គលទាំងឡយ អ្នកដែលប្រាថ្នានឹងធ្វើដំណើរទៅបានឡើយ ព្រោះចាត់ដោត ក្នុងវត្ថុដែលជាទីស្រលាញ់ទាំងឡាយ ឧបមាដូចជាចុងបន្ទាដែលកោង ជូច្នោះ ឈ្មោះថា វាចាប៉ះទង្គិច ដល់បុគ្គលដទៃ ។ វាចា ដែលជិតដល់សេចក្តីក្រោធ ១ីង ឈ្មោះថា វាចាជិតដល់សេចក្តីក្រោធ ។ វាចាដែលមិនប្រព្រឹត្តទៅ ដើម្បីអឋានាសមាធិ ឬ ឧបចារសមាធិ ឈ្មោះថា វាចា ដែលមិនប្រព្រឹត្តទៅ ដើម្បីសមាធិ ។ ពាក្យទាំងឡាយទាំងពួង មានពាក្យថា **អណ្ហកា** ជាដើម នេះឯង ជាពាក្យវេវចនៈ នៃវាចាដែលមិនមានទោស យ៉ាងដូច្នេះឯង " ។

(៦១) អដ្ឋកថានៃសូត្រ មានចូឡហត្ថិបទោបមសូត្រ ជាដើមថា "ក្នុងបទថា **នេឡា** ដូច្នេះ ទោស លោកហៅថា **នេឡំ**,

ពណ៌នាអំពីការប្រព្រឹត្តិធម៌

*ទោស របស់វាចានោះ មិនមាន ហេតុនោះ វាចានោះ ឈ្មោះថា វាចាមិនមានទោស, អធិប្បាយថា ជាវាចាដែលគ្មានទោស ។ បទ ថា **នេឡា** នោះ ប្រៀបដូចជា **នេឡ** សព្ទ ដែលព្រះដ៏មានព្រះ ភាគ ទ្រង់ត្រាស់ហើយ ក្នុងគាថានេះថា **នេឡង្គោ សេតបច្ឆាទោ** ដូច្នេះជាដើម ។ វាចា ឈ្មោះថា នាំសេចក្ដីសុខ មកដល់ត្រចៀក គឺមិនញ៉ាំងសេចក្ដីចាក់ដោត ដល់ត្រចៀក ដូចជាត្រូវមួលចាត់ដោត ឲ្យកើតឡើង ព្រោះជាវាចាដែលពីរោះ ដោយព្យញ្ជនៈ ឈ្មោះថា ជាវាចាដែលសប្បាយដល់ត្រចៀក ។ វាចាណា មិនញ៉ាំងសេចក្ដី ក្រោធខឹងឲ្យកើតឡើង ញ៉ាំងសេចក្ដីស្រលាញ់ឲ្យកើតឡើង ក្នុង សរីរៈរាងកាយទាំងមូល ព្រោះជាវាចាដែលពីរោះ ដោយសេចក្ដី ព្រោះហេតុនោះ វាចានោះ ទើបឈ្មោះថា ជាវាចាដែលគួរឲ្យកើត សេចក្ដីស្រលាញ់ ។ ឈ្មោះថា ជាវាចាចូលទៅ ដល់ហឫទ័យ ព្រោះវិគ្រោះថា វាចានោះ រមែងដល់ទូវហឫទ័យ គឺ មិនប៉ះទង្គិច ចូលទៅដល់ចិត្ត ដោយសប្បាយ ។ ឈ្មោះថា ជាវាចាអ្នកក្រុង ព្រោះវិគ្រោះថា វាចានោះ មាននៅ ក្នុងក្រុង ព្រោះវាចាដែល បរិបូណ៌ដោយគុណ ។ ឈ្មោះថា ជាវាចាអ្នកក្រុង ព្រោះវិគ្រោះ ថា វាចានោះ ជាវាចាដ៏ទន់ភ្ញន់ ប្រៀបដូចជានារីដែលចម្រើន ក្នុង បូរី ដូច្នេះខ្ញុះ ។ ឈ្មោះថា ជាវាចាអ្នកក្រុង ព្រោះវិគ្រោះថា វាចា*

មន្តលត្ថទីបនីប្រែ

នោះ ជាវាចារបស់អ្នកទីក្រុង ដូច្នេះក៏មាន ។ ២ បទថា ***បរស្សឯសា*** *មានសេចក្តីថា ជាវាចារបស់អ្នកនគរទាំងឡាយ ។ ព្រោះថា អ្នកនគរទាំងឡាយ រមែងជាអ្នកមានវាចាដ៏សមគួរ គឺ តែងហៅ នូវបុគ្គលអ្នកល្មមសមជាបិតាបាន ថា ជាបិតា អ្នកល្មមសមជាមាតាបាន ថា ជាមាតា អ្នកល្មមសមជាបងប្អូនបាន ថា ជាបងប្អូន ដូច្នេះ ។ ឈ្មោះថា ជាវាចាជាទីស្រលាញ់ ដល់ជនច្រើន ព្រោះវិគ្រោះថា វាចាបែបនេះឯង រមែងជាវាចា ដែលជនច្រើនស្រលាញ់ ។ ឈ្មោះថា ជាវាចាជាទីពេញចិត្តដល់ជនច្រើន ព្រោះវិគ្រោះថា វាចានោះ ជាវាចាជាទីពេញចិត្ត គឺ ធ្វើសេចក្តីចម្រើននៃចិត្ត ដល់ជនច្រើន ព្រោះជាវាចាដែលជនច្រើនពេញចិត្ត " ។*

(៦២) បទថា " ***សម្ជប្បលាបំ*** *" មានសេចក្តីថា វាចា ណានីមួយ ជាវាចាមិនមានពំស្ពុតាង មិនមានទីអាងដល់ មិនមានទីបំផុត មិនប្រកបដោយប្រយោជន៍, លះបង់ នូវវាចាបែបនោះចោល " ។*

(ព្រះធម្មកថិកពួរជ្រៃ)

ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាសាលេយ្យកសូត្រថា " បទថា ***អនិជានវតឹ*** *គឺនូវវាចាដែលមិនសមគួរ ដើម្បីនឹងកប់ទុក ក្នុងហិប គឺហប្ចទ័យបានឡើយ ។ បទថា* ***អនបទេសំ***

ពណ៌នាអំពីការប្រព្រឹត្តិធម៌

គឺ ប្រាសចាកទីអាងដល់ ពោលគឺសូត្រ ។ បទថា ***អបរិយន្តវតី*** *គឺ នូវវាចាដែលមិនមានកំណត់ ។ ព្រះធម្មកថិក លើកឡើងនូវ សូត្រ ឬ ជាតក ហើយនាំមកនូវឧបារម្ភកថា ឬ ឧបមា ឬក៏ រឿង នៃសូត្រ ឬ ជាតកនោះហើយ ក៏ត្រឡប់ទៅជាសម្តែងរឿងខាង ក្រៅវិញ, សូត្រ ឬ ជាតក ដែលព្រះធម្មកថិកនោះ លើកឡើង ហើយ ក៏គ្រាន់តែបានលើកយកមកប៉ុណ្ណោះឯង, ព្រះធម្មកថិក នោះ រមែងដល់នូវភាពជាអ្នកដែលជនទាំងឡាយ គប្បីពោលថា ព្រះធម្មកថិករូបនេះ សម្តែងនូវសូត្រអ្វីហ្ន៎? នូវជាតកអ្វីហ្ន៎?, ពួក យើងទាំងឡាយ មិនឃើញ នូវទីបំផុត ឬ ចុងផុត នៃសូត្រ ឬ ជាតកនោះសោះឡើយ ដូច្នេះ ។ ពួរជ្រៃទាំងឡាយ រមែងលូតចុះ មក ក្នុងទីនៃមែកជ្រៃទាំងឡាយ លូតលាស់ទៅហើយៗ ដល់ក្នុង ទីកន្លែងដែលខ្ជួនលូតលាស់ចុះហើយៗ រមែងលូតលាស់ ចម្រើន ឡើង ជាថ្មីម្តងទៀតដូចដើម, ដើមជ្រៃទាំងឡាយ តែងដុះធំរាល ទៅៗ ដោយប្រការដូច្នេះឯង រហូតដល់ទៅកន្ទុះយោជន៍ខ្ទុះ, ១ យោជន៍ខ្ទុះ, ក៏កាលបើ ពេលវេលា កន្ទុងផុតទៅៗ, ដើមចាស់ ក៏រមែងវិនាសស្លាប់ទៅ, ពន្ធកថ្មីទាំងឡាយនុ៎ះឯង ក៏រមែងដុះឡើង យ៉ាងណាមិញ, ចំណែក ព្រះធម្មកថិក ពួរជ្រៃនេះ ក៏ដូច្នោះដែរ រមែងឈ្មោះថា ជាព្រះធម្មកថិក ពួរជ្រៃ, ព្រះធម្មកថិកនេះ រមែង*

មន្តលត្ថទីបនីប្រែ

ធ្វើនូវសូត្រ ឬ ជាតក ដែលខ្ជួនលើកឡើងហើយ ឲ្យគ្រាន់តែខ្ជួន លើកឡើងហើយប៉ុណ្ណោះឯង ហើយក៏គេចបង្វាងទៅដោយខាងៗ វិញ ។ ក៏ព្រះធម្មកថិក រូបណា សូម្បីពោលពាក្យ យ៉ាងច្រើន ក៏អាចដើម្បីនឹងលើកទាញយកមក ឲ្យជនទាំងឡាយ យល់បាន ថា ព្រះសូត្រនេះ មានសេចក្តីយ៉ាងនេះ ដូច្នេះ, កិរិយាសម្តែង របស់ធម្មកថិករូបនោះ ទើបសមគួរ ។ បទថា **អនត្ថសញ្ហិតំ** គឺ មិនអាស្រ័យនូវប្រយោជន៍ឡើយ " ។

(៦៣) អដ្ឋកថាចូឡហត្ថិបទោបមសូត្រ ជាដើមថា " បុគ្គល ឯណា តែងពោល ក្នុងកាល ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះ ថា កាលវាទី, អធិប្បាយថា បុគ្គលនោះ កំណត់នូវកាលដែលគួរ ពោលហើយទើបពោល ។ បុគ្គលណា រមែងពោលនូវពាក្យពិត គឺពាក្យត្រង់ បានដល់ ពាក្យពិតត្រង់តែម៉ាង ហេតុនោះ បុគ្គល នោះ ឈ្មោះថា ភូតវាទី ។ ឈ្មោះថា ជាអ្នកមានប្រក្រតីពោល អាស្រ័យអត្ថ ព្រោះអត្ថថា បុគ្គលនោះ រមែងពោល ធ្វើឲ្យជា ពាក្យអាស្រ័យប្រយោជន៍ ដែលជាទិដ្ឋធម្មិក: និង សម្ឆរាយិក: តែម៉ាង ។ ឈ្មោះថា ជាអ្នកមានប្រក្រតីពោលអាស្រ័យធម៌ ព្រោះ អត្ថថា បុគ្គលនោះ រមែងពោល ធ្វើឲ្យជាពាក្យអាស្រ័យលោកុត្តរ-ធម៌ ៩ ប្រការ ។ ឈ្មោះថា ជាអ្នកមានប្រក្រតីពោលអាស្រ័យ

ពណ៌នាអំពីការប្រព្រឹត្តិធម៌

វិនយ ព្រោះអត្ថថា បុគ្គលនោះ រមែងពោល ធ្វើឲ្យជាពាក្យ អាស្រ័យសំវរវិនយ និង បហានវិនយ ។ ឱកាសដែលជាទីតាំង បណ្ឌិតពោលថា ព័ស្ត្ពុតាង ។ ព័ស្ត្ពុតាង នៃវាចានោះ មាន ហេតុ នោះ វាចានោះ ឈ្មោះថា ជាវាចាមានព័ស្ត្ពុតាង, អធិប្បាយថា ធម្មចារិសមចារីបុគ្គល រមែងជាអ្នកពោលនូវវាចា ដែលសមគួរ ដើម្បីនឹងកប់ទុក ក្នុងហប្ចទ័យ ។ បទថា ***កាលេន*** *មានសេចក្តីថា ក៏ធម្មចារិសមចារីបុគ្គល សូម្បីកាលពោល នូវពាក្យដូច្នេះ រមែងមិនពោល ដោយកាលមិនគួរទេ ដោយគិតថា អាត្មាអញ នឹងពោលពាក្យ ដែលមានព័ស្ត្ពុតាង ដូច្នេះ, តែពិចារណា នូវ កាលដែលសមគួរហើយ ទើបពោល ។ បទថា* ***សាបទេសំ*** *មាន សេចក្តីថា មានឧបមា មានហេតុ ។ បទថា* ***បរិយន្តបតឺ*** *មាន សេចក្តីថា ការកំណត់នៃវាចានោះ រមែងប្រាកដបាន ដោយ ប្រការណា, ធម្មចារិសមចារីបុគ្គល រមែងពោលសំដែងហើយ ៗ នូវការកំណត់ ដោយប្រការនោះ ។ បទថា* ***អត្ថសញ្ហិតំ*** *គឺ ឈ្មោះ ថា ជាវាចាដល់ព្រមដោយប្រយោជន៍ ព្រោះវាចានោះ គឺបុគ្គល អ្នកចំណែក ដោយនយសូម្បីជាអនេក ក៏មិនគប្បីអាច ដើម្បីនឹង ឲ្យកំណត់យកបានឡើយ ។ មួយទៀត មានសេចក្តីថា បុគ្គល អ្នកមានប្រក្រតីពោលអត្ថនោះ តែងពោល នូវប្រយោជន៍ណា,*

មន្តលត្ថទីបនីប្រែ

ធម្ម្ចារិសមចារីបុគ្គល រមែងពោលនូវវាចា ដែលឈ្មោះថា ជាវាចាប្រកដោយប្រយោជន៍ ព្រោះវាចានោះ ជាវាចាប្រកបហើយ ដោយប្រយោជន៍នោះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់អធិប្បាយ ទុកថា ធម្ម្ចារិសមចារីបុគ្គល មិនលើកយកពាក្យ ណាមួយ ហើយ ទៅពោលពាក្យដទៃទៀតឡើយ ដូច្នេះ " ។

(៦៤) អដ្ឋកថាភយភេរវសូត្រថា " បទថា **អភិជ្ឈាលុ** គឺ ជាអ្នកមានប្រក្រតីសំឡឹងរំពៃ នូវទ្រព្យសម្បត្តិ របស់បុគ្គលដទៃ ទាំងឡាយ " ។

អដ្ឋកថាសាលេយ្យកសូត្រ ថា " ២ បទថា **អភិជ្ឈាតា ហោតិ** គឺ រមែងជាអ្នកក្រឡេកមើលហើយ ដោយកិរិយាសំឡឹងរំពៃ ។ ក៏សពូ ក្នុងបទថា **អហោ វត** ន៉ុះ ជាសពូនិបាត ។ ក៏ការបែកធ្លាយនៃកម្ម្ចបថ ក្នុងមនោកម្ម្នេះ រមែងមិនមាន ដោយ អាការត្រឹមតែក្រឡេកមើល ដោយកិរិយាសំឡឹងរំពៃ ។ ក៏ប៉ុន្តែ ក្នុងពេលណា បុគ្គលបង្អោន (នូវភណ្ឌៈរបស់ជនដទៃ) មកដើម្បីខ្ជូន ដោយគិតថា ធ្វើដូចម្តេចទៅហ្នឹ? ទ្រព្យរបស់អ្នកដទៃនេះ គប្បីបានមកជារបស់អញ, អញគប្បីញ្ចុាំងអំណាច ឲ្យប្រព្រឹត្តទៅ ក្នុងទ្រព្យរបស់ន៉ុះ ដូច្នេះ, ពេលនោះ ការបែកធ្លាយកម្ម្ចបថ ទើបមាន ។ សេចក្តីនេះ ព្រះមានព្រះគាគ ទ្រង់បានអធិប្បាយហើយ

ពណ៌នារំពីការប្រព្រឹត្តិធម៌

ក្នុងពាក្យថា **អកិជ្ឈាតា ហោតិ** នេះ ។ បទថា **ព្យាបន្នចិត្តោ** គឺ ជាអ្នកមានចិត្តវិបត្តិហើយ បានដល់ មានចិត្តជាធម្មជាតស្អុយ ។ បទថា **បទុដ្ឋមនសង្កប្បោ** គឺ ជាអ្នកមានសេចក្តីត្រិះរិះ ក្នុងចិត្ត ដែលទោសប្រទូសរ៉ាយហើយ " ។

(៦៥) អដ្ឋកថាភយភេរវសូត្រថា " បទថា **ព្យាបន្នចិត្តា** គឺ ឈ្មោះថា ជាអ្នកមានចិត្តវិបត្តិហើយ ព្រោះលះបង់នូវភាវ: នៃចិត្ត ជាប្រក្រតីចោល ។ ក៏ចិត្តដែលប្រកបទៅតាមកិលេស រមែងលះ បង់នូវភាពនៃចិត្តជាប្រក្រតីចោល, រមែងជាចិត្តស្អុយ ប្រៀបដូច ជាបាយ និង សម្ងដែលផ្អូមដូច្នោះ ។ បទថា **បទុដ្ឋមនសង្កប្បា** គឺ ជាអ្នកមានសេចក្តីត្រិះរិះក្នុងចិត្ត ត្រូវទោសប្រទូសរ៉ាយហើយ បាន ដល់ ជាអ្នកប្រកបព្រមហើយ ដោយសេចក្តីត្រិះរិះ ក្នុងចិត្ត ដែល មិនចំរើន គឺដែលធ្វើសេចក្តីវិនាសឲ្យកើតឡើង ដល់ពួកជនដទៃ" ។

ពាក្យថា **អនកិជ្ឈាលុ** ជាដើម បណ្ឌិត គប្បីកាន់យក ដោយបដិបក្ខន័យ នឹងពាក្យដែលខ្ចុំពោលហើយ ។

ក៏ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាបដិសម្ភិទា មគ្ត ថា " បទថា **អវេរា** គឺ រៀរចាកពៀរវេរាហើយ ។ បទថា **អព្យាបជ្ឈា** គឺ រៀរចាកព្យាបាទ ។ បទថា **អនីតិកា** គឺ មិនមាន សេចក្តីទុក្ខ ។ បាលីថា **អនីឃា** ដូច្នេះ ក៏មាន ។ ពាក្យថា **សុខី**

មង្គលត្ថទីបនីប្រែ

អត្តានំ បរិហរន្តុ *មានសេចក្តីថា សត្វទាំងឡាយ ចូរជាអ្នកមានសេចក្តីសុខ ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅចុះ ។ បណ្ឌិត គប្បីជ្រាបសម្ពន្ធ នៃពាក្យ ក្នុងបទថា* ***អវេរ*** *ជាដើមនោះ យ៉ាងដូច្នេះ ថា ក៏ព្រះសារីបុត្រ សំដែងភាពជាអ្នកមិនមានពៀរវេរ ព្រោះអាស្រ័យពួកជនដទៃ ដែលជាប់ទាក់ទងនឹងខ្លួន និង ព្រោះអាស្រ័យពួកជនដទៃ ក្រៅពីនេះ ដែលជាប់ទាក់ទងនឹងជនដទៃ ដោយបទថា* ***អវេរ*** *ដូច្នេះ ។ សំដែងសេចក្តីមិនមានការអាក់អន់ចិត្ត ដែលមានការមិនមានពៀរវេរនោះ ជាមូលហេតុ ព្រោះការមិនមានពៀរវេរ ដោយបទថា* ***អព្យាបជ្ឌា*** *។ សម្តែងការមិនមានសេចក្តីទុក្ខ ដែលមានការមិនអាក់អន់ចិត្តនោះ ជាមូល ព្រោះមិនមានការអាក់អន់ចិត្ត ដោយបទថា* ***អនីឃា*** *។ សម្តែងការបរិហារអត្តភាពដោយសេចក្តីសុខ ព្រោះមិនមានសេចក្តីទុក្ខ ដោយបទថា* ***សុខី អត្តានំ បរិហរន្តុ*** *ដូច្នេះ” ។*

(៦៦) នយមកហើយ ក្នុងអដ្ឋកថាសល្ងេ១សូត្រ ថា “ ការយោយើញត្រឹមត្រូវ គឺ ល្អប្រពៃ ដែលវិញ្ញូជនសរសើរហើយ របស់បុគ្គលនោះ មាន ហេតុនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានការយល់យើញត្រឹមត្រូវ, មានសេចក្តីអធិប្បាយថា បុគ្គលជាសម្មាទិដ្ឋិក៍នោះ ជាអ្នកក្របកព្រមហើយ ដោយទិដ្ឋិ ដែលជា

ពណ៌នាអំពីការប្រព្រឹត្តិធម៌

កម្មស្សកតាញ្ញាណ មានយើញថា ទានដែលបុគ្គលឲ្យហើយ មានផល ដូច្នេះជាដើម ដែលរាប់បញ្ចូល ក្នុងកម្មបថ និង ដោយទិដ្ឋិដែលសម្បយុត្ត ដោយមគ្គ ដែលរាប់បញ្ចូល ក្នុងសេចក្ដីត្រឹមត្រូវ ទៀងទាត់ " ។

*អដ្ឋកថាសាលេយ្យកសូត្រ និង អដ្ឋកថាតតិយបណ្ណាសក: ក្នុងតិកនិបាត អង្គុត្តនិកាយថា " បុគ្គល ជាអ្នកមានសេចក្ដីយល់ឃើញខុស ពោលសំដៅយក នូវការមិនមានផល នៃទានថា **នត្ថិ ទិន្នំ** ដូច្នេះ ។ មហាយញ្ញ ព្រះមានព្រះគាគទ្រង់ត្រាស់ថា **យិដ្ឋំ** ។ សក្ការ: ដែលបុគ្គលគប្បីធ្វើដល់ភ្ញៀវ ព្រះអង្គត្រាស់អធិប្បាយហើយ ក្នុងបទថា **ហុតំ** ។ មិច្ឆាទិដ្ឋិកបុគ្គល សំដៅយកនូវមហាយញ្ញ និង យញ្ញ តូចទាំង ២ យ៉ាងនោះ ថា មិនមានផលពិតទើបបានហាម ។ បទថា **សុកតទុក្ខដានំ** មានសេចក្ដីថា នៃកម្មដែលបុគ្គលធ្វើល្អ និង ធ្វើអាក្រក់ទាំងឡាយ គឺ នៃកុសលកម្ម និង អកុសលកម្មទាំងឡាយ ។ មិច្ឆាទិដ្ឋិកបុគ្គល ពោលថា ធម្មជាតិណា ដែលគេហៅថា ផល ឬ វិបាក ដូច្នេះ, ធម្មជាតិនោះ រមែងមិនមាន ដូច្នេះ ដោយបទថា **ផលវិបាកោ** ។ ពាក្យថា **នត្ថិ អយំ លោកោ** មានសេចក្ដីថា លោកនេះ របស់បុគ្គលអ្នកស្ថិតនៅ ក្នុងបរលោក រមែងមិនមាន ។ ពាក្យថា **នត្ថិ បរោ លោកោ** មាន*

មន្ទលត្ថទីបនីប្រែ

សេចក្តីថា លោកខាងមុខ សូម្បីរបស់បុគ្គលអ្នកស្ថិតនៅហើយ ក្នុងលោកនេះ ក៏មិនមាន ។ មិច្ឆាទិដ្ឋិកបុគ្គល សម្តែងថា សត្វ ទាំងឡាយ ទាំងពួង តែងបាត់សូន្យ ក្នុងភពនោះ ៗ តែម្តង ។ មិច្ឆាទិដ្ឋិកបុគ្គល រមែងពោលថា **និត្ថ មាតា និត្ថ បិតា** ដោយ អំណាចនៃការមិនមានផល នៃការប្រតិបត្តិ ត្រឹមត្រូវ និង ការ ប្រតិបត្តិខុស ក្នុងមាតាបិតាទាំងនោះ ។ មិច្ឆាទិដ្ឋិកបុគ្គល រមែង ពោលថា ធម្មតាសត្វដែលច្យុតហើយ កើតមកវិញ (ទៀត) តែង មិនមាន ដូច្នេះ ដោយបទថា **នត្ថិ សត្តា ឧបបាតិកា** ដូច្នេះ" ។

អដ្ឋកថាទិដ្ឋុបាទាននិទ្ទេស ក្នុងនិក្ខេបកណ្ឌ ថា " ២ បទថា **សម្មគ្គតា សម្មាបដិបន្នា** មានសេចក្តីថា សមណៈ និង ព្រាហ្មណ៍ អ្នកតាំងនៅ ក្នុងធម៌ទាំងឡាយ ជាអ្នកប្រតិបត្តិបដិបទាដ៏សមគួរ" ។

អដ្ឋកថាសាលេយ្យកសូត្រ " ពាក្យថា **សយំ អភិញ្ញា សច្ឆិកត្វា** មានសេចក្តីថា មិច្ឆាទិដ្ឋិកបុគ្គល សម្តែងនូវការមិនមាន នៃព្រះសព្វញ្ញូពុទ្ធទាំងឡាយ ថា សមណៈ និង ព្រាហ្មណ៍ ទាំង ឡាយណា រមែងប្រកាសនូវលោកនេះ និង លោកខាងមុខ ធ្វើឲ្យ ជាក់ច្បាស់ទាំងពួង ដោយបញ្ញា ដ៏ប្រសើរក្រៃលែង, សមណៈ និង ព្រាហ្មណ៍ទាំងឡាយនោះ មិនមានឡើយ ដូច្នេះ" ។

ពាក្យថា **នត្ថិ ទិន្នំ** ដូច្នេះជាដើម បណ្ឌិត គប្បីប្រកាន់យក

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ដោយបដិបក្ខនយ នឹងពាក្យដែលខ្ញុំពោលហើយ ។

(៦៧) ក៏អដ្ឋកថាបឋមវគ្ត ក្នុងកោសលសំយុត្ត ថា " ខត្តិយមហាសាល គឺ ក្សត្រទាំងឡាយ អ្នកបរិបូណិ ដោយទ្រព្យដែលមានខ្ជឹមសារជាច្រើន ឈ្មោះថា ក្សត្រមហាសាល ។ អធិប្បាយថា មែនពិត ក្សត្រទាំងឡាយណា មានទ្រព្យសម្បត្តិជាដើមទុន ប្រមាណ ១០០ កោដិ ដោយយ៉ាងទាបបំផុត មានកហាបណៈ ប្រមាណ ៣ កុម្ភៈ ធ្វើឲ្យជាគំនរកប់ទុក ក្នុងកណ្តាលឃ្លាំង ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់, ក្សត្រទាំងឡាយនោះ ឈ្មោះថា ក្សត្រមហាសាល ។ ព្រាហ្មណ៍ទាំងឡាយណា មានទ្រព្យសម្បត្តិ កប់ទុកជាដើមទុន ចំនួន (យ៉ាងទាប) ៨០ កោដិ មានកហាបណៈ ប្រមាណកន្ទះកុម្ភៈ ធ្វើឲ្យជាគំនរ កប់ទុក ត្រង់កណ្តាលផ្ទះ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ ព្រាហ្មណ៍ទាំងឡាយនោះ ឈ្មោះថាព្រាហ្មណ៍មហាសាល ។ គហបតីទាំងឡាយណា មានទ្រព្យសម្បត្តិ កប់ទុកជាដើមទុន ប្រមាណ ៤០ កោដិ មានកហាបណៈ ប្រមាណ ១ កុម្ភៈ ធ្វើឲ្យជាគំនរ បក់ទុក ត្រង់កណ្តាលផ្ទះ ដើម្បីប្រយោជន៍ ដល់ការប្រើប្រាស់, គហបតីទាំងឡាយនោះ ឈ្មោះថា គហបតីមហាសាល " ។

អដ្ឋកថាសាលេយ្យកសូត្រ ថា " ពាក្យថា **សហព្យតំ**

មង្គលត្ថទីបនីប្រែ

ឧបបជ្ជេយ្យុ *គឺ គប្បីចូលដល់ភាពជាសំឡាញ់ ។ ២ បទថា* ***ព្រហ្មកាយិកានំ ទេវានំ*** *គឺ នៃទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងបឋមឈាន ។ ទេវតា មួយផ្នែក ឈ្មោះថា អាភា ក្នុងពាក្យថា* ***អាភានំ ទេវានំ*** *ដូច្នេះ មិនមាន ។ ពាក្យថា អាភានោះ ជាឈ្មោះនៃបរិត្តាភាទេវតា អប្បមាណាភាទេវតា និង អាភស្សរាទេវតាទាំងឡាយ ។ ចំណែក ពាក្យថា* ***បរិត្តាភានំ*** *ជាដើម ជាគ្រឿងប្រកាន់យកនូវទេវតាទាំងឡាយនោះឯង ដោយប្រភេទ ព្រោះមិនប្រកាន់យក ដោយចំណែកមួយ ។ សូម្បីក្នុងបទទាំងឡាយ មានបទថា* ***សុភានំ បរិត្តសុភានំ*** *ដូច្នេះជាដើម ក៏នយនេះដូចគ្នា " ។*

(៦៨) អដ្ឋកថាអាកង្ខេយ្យសូត្រ ក្នុងបឋមវគ្គ នៃមូលបណ្ណាសក: ថា " ២ បទថា ***អាសវានំ ខយា*** *គឺ ព្រោះកិរិយាអស់ទៅ នៃកិលេសទាំងពួងទាំងឡាយ ដោយអរហត្តមគ្គ ។ បទថា* ***អនាសវំ*** *គឺ ប្រាសចាកអាសវ: ។ ក្នុង ២ បទនេះ ថា* ***ចេតោវិមុត្តឺ បញ្ញាវិមុត្តឺ*** *ដូច្នេះ ព្រះមានព្រះភាគទ្រង់ត្រាស់សមាធិដែលសម្បយុត្ត ដោយអរហត្តផល ដោយចេតោសពូ និង ព្រះអង្គ ទ្រង់ត្រាស់បញ្ញា ដែលសម្បយុត្ត ដោយអរហត្តផលនោះ ដោយបញ្ញាសពូ ។ ក៏បណ្ដាធម៌ទាំង ២ យ៉ាងនោះ សមាធិ បណ្ឌិត គប្បីជ្រាប ថា ចេតោវិមុត្តិ ព្រោះជាធម្មជាតដែលរួចផុត*

ពណ៌នាអំពីការប្រព្រឹត្តិធម៌

*អំពីសេចក្តីតម្រេក, បញ្ញា បណ្ឌិតគប្បីជ្រាបថា បញ្ញាវិមុត្តិ ព្រោះ រួចផុតស្រឡះអំពីអវិជ្ជា ។ មែនពិត ព្រះមានព្រះភាគទ្រង់ត្រាស់ ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ក៏សមាធិឯណា គប្បីមានបាន, សមាធិនោះ គប្បីជាសមាធិន្ទ្រីយ៍, ម្នាលភិក្ខុទាំងឡាយ បញ្ញា ឯណា គប្បីមានបាន, បញ្ញានោះ គប្បីជាបញ្ញិន្ទ្រីយ៍, ម្នាលភិក្ខុ ទាំងឡាយ សមាធិ ឈ្មោះថា ចេតោវិមុត្តិ ព្រោះសម្រេករាគៈ, បញ្ញា ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះសម្រេកអវិជ្ជា យ៉ាងដូច្នេះឯង ។ ម្យ៉ាងទៀត បណ្តាវិមុត្តិទាំង ២ យ៉ាងនោះ ផលនៃសមថៈ បណ្ឌិត គប្បីជ្រាបថា ចេតោវិមុត្តិ, ផលនៃវិបស្សនា បណ្ឌិត គប្បីជ្រាបថា បញ្ញាវិមុត្តិ ។ ២ បទថា **ទិដ្ឋេ ធម្មេ** គឺ ក្នុងអត្តភាពនេះឯង ។ ពាក្យថា **សយំ អភិញ្ញា សច្ឆិកត្វា** គឺ ធ្វើឲ្យជាក់ច្បាស់ ដោយ បញ្ញា ដោយខ្លួនឯងពិត, អធិប្បាយថា ដឹង ដោយមិនមានបុគ្គល ដទៃ ជាបច្ច័យ ។ បទថា **ឧបសម្បជ្ជ វិហរេយ្យុं** គឺ គប្បីបាន សម្រេច គឺ គប្បីធ្វើឲ្យបានសម្រេច ហើយនៅ " ។*

(ទេវណោក ២០ ជាន់)

(៦៩) អដ្ឋកថាសាលេយ្យកសូត្រ ថា " ព្រះមានព្រះភាគ ត្រាស់សម្តែងការអស់ទៅ នៃអាសវៈហើយ ទ្រង់ញុំងព្រះធម្ម-ទេសនា ឲ្យចប់ ដោយធម៌ជាកំពូល គឺព្រះអរហត្ត ដូច្នេះឯង ។

មង្គលត្ថទីបនីប្រែ

ក៏ទេវលោក បណ្ឌិត គប្បីប្រមូលមករួបរួមទុក ក្នុងនិទ្ទេស នៃធម្មចរិយសមចរិយា នេះ ។ ទេវលោក ១៨ ជាន់ គឺ ៖ ព្រហ្មលោក ៩ ជាន់ ដោយអំណាចនៃភូមិនៃឈានទាំងឆ្លាយ ៣ ជាមុន, សុទ្ធាវាស ៥ ជាន់ ត្រូវជា ៩ ជាមួយគ្នានឹងអរូបព្រហ្ម ៤ ជាន់ផង, ទេវលោកទាំង ១៨ ជាន់នោះ ត្រូវជា ១៩ ជាន់ ព្រមទាំងជាន់វេហប្ផលាផង, រួមបញ្ចូលទាំងអសញ្ញីព្រហ្មផង ទើបត្រូវជាព្រហ្ម ២០ ជាន់ ។ មួយអន្ទើដោយកាមាវចរ ៦ ជាន់ផង ទើបឈ្មោះថា ទេវលោក ២៦ ជាន់ ដោយប្រការដូច្នេះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់សំដែងកិរិយាកើតឡើង សូម្បីនៃពួកទេវតាពួងនោះ ដោយកុសលកម្មបថ ១០ ប្រការ ។ ក្នុងទេវលោកទាំង ២៦ ជាន់នោះ ការកើតឡើង ក្នុងកាមាវចរ ៦ ជាន់ រមែងមានដោយផលនៃសុចរិត ៣ យ៉ាងនុ៎ះឯង ។ ក៏កម្មបថទាំងនេះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយអំណាចនៃឧបនិស្សយ នៃទេវលោកជាន់ខ្ពស់ៗ ទាំងឆ្លាយ ។ មែនពិតកុសលកម្មបថ ១០ ប្រការ ឈ្មោះថា សីល, ការបរិកម្មកសិណ រមែងសម្រេចបាន ដល់បុគ្គលអ្នកមានសីល តែប៉ុណ្ណោះ ព្រោះហេតុនោះ បុគ្គលស្ថិតនៅ ក្នុងសីលហើយ ធ្វើបរិកម្មកសិណ ញ្ជាំងបឋមឈាន ឲ្យកើតឡើងហើយ រមែងកើតឡើង ក្នុងភូមិ

ពណ៌នាអំពីការប្រព្រឹត្តិធម៌

នៃបឋមឈាន, បុគ្គល ចម្រើនឈានខ្ពស់ៗ មានទុតិយឈាន ជាដើមហើយ រមែងកើតឡើង ក្នុងភូមិនៃឈាន មានតតិយឈាន ជាដើម, បុគ្គល ធ្វើរូបាវចរឈាន ឲ្យជាបាទ ចម្រើនវិបស្សនាហើយ តាំងនៅក្នុងអនាគាមិផល រមែងទៅកើតក្នុងជាន់សុទ្ធាវាសទាំង ៥ ជាន់, បុគ្គលធ្វើរូបាវចរឈាន ឲ្យជាបាទ ញុាំងអរូបាវចរសមាបត្តិ ឲ្យកើតឡើងហើយ រមែងទៅកើត ក្នុងអរូបព្រហ្មទាំង ៤ ជាន់, បុគ្គលធ្វើរូបឈាន និង អរូបឈាន ឲ្យជាបាទ ចម្រើនវិបស្សនាហើយ រមែងសម្រេចព្រះអរហត្ត ។ ចំណែក ភពដែលជាទីនៅ របស់អសញ្ញីសត្ត គឺ តាបស និង បរិព្វាជកទាំងឡាយដែលជាអ្នកបួស ខាងក្រៅសាសនា បានប្រព្រឹត្តមកហើយ ហេតុនោះ ទើបព្រះមានព្រះភាគ មិនបានសំដែង ក្នុងសូត្រនេះ" ។

អដ្ឋកថា ចប់ ។

*(៧០) ដីកាសាលេយ្យកសូត្រថា " **វិធ** សពួ មាន **កោដ្ឋា** សពួ ជាសេចក្តី ដូច **វិធ** សពួ ក្នុងប្រយោគទាំងឡាយថា **ឯក-វិធេន ញាណវត្ថុំ** ដូច្នេះជាដើម ។ មួយទៀត **វិធ** សពួនោះ មាន **តិ** សពួ ជាបទដើម ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **តិវិធំ** ដូច្នេះ ដោយអំណាចនៃបឋមាវិភត្តិ ឯកវចន: ព្រោះធ្វើបឋមាវិភត្តិ និង ឯកវចន: ឲ្យវិបល្លាស ។ ក៏ប៉ុន្តែ សេចក្តី បណ្ឌិតគប្បីយើញ*

មន្តលត្ថទីបនីប្រែ

ដោយអំណាច នៃតតិយាវិភត្តិ ពហុវចន: ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **តិវិធន្តិ តីហិ កោដ្ឋាសេហិ** ដូច្នេះ ។ កាយ ដែលកម្រើកបាន ព្រះមានព្រះភាគ ទ្រង់អធិប្បាយហើយ ថា កាយ ក្នុងបទថា **កាយេន** នេះ ។ ក៏ចោបនកាយនោះ ឈ្មោះ ថា ជាមាត់ទ្វារផ្ទូវ នៃការប្រព្រឹត្តិធម៌ ព្រោះប្រាសចាកកាយទ្វារ នោះហើយ ការប្រព្រឹត្តិធម៌នោះ ក៏ប្រព្រឹត្តទៅមិនបានឡើយ ។ ក៏បទថា **កាយេន** ន៉ុះ ជាតតិយាវិភត្តិ ចុះក្នុងហេតុ ។ មែនពិត វិញ្ញត្តិនោះ ជាសមុដ្ឋាន នៃចេតនា ពោលគឺការប្រព្រឹត្តិធម៌, ប៉ុន្តែ វិញ្ញត្តិនោះ មិនមែនជាបច្ចយ នៃចេតនា ដោយជាបច្ចយ សូម្បីបច្ចយ ១ បណ្តាបច្ចយទាំង ២៤ យ៉ាង ដែលមកហើយ ក្នុងបករណ៍ឈ្មោះបដ្ឋានឡើយ ក៏ពិតមែន, ទោះជាដូច្នោះ រមែងគ្រាន់ តែជាពាក្យវោហា ប្រៀបដូចជាហេតុ នៃចេតនា និង ជាគ្រឿងធ្វើ នូវចេតនានោះ ព្រោះភាវ:នៃចេតនានោះ គឺបុគ្គលគប្បីកំណត់ បានដោយទ្វារនោះ ព្រោះសេចក្តីថា សេចក្តីប្រព្រឹត្តិទៅនៃចេតនា ដែលមានឈ្មោះថា កាយកម្ម ដែលកំពុងតែប្រព្រឹត្តទៅ រមែងមាន ព្រោះសេចក្តីប្រព្រឹត្តិទៅ នៃវិញ្ញត្តិនោះ ។ ម៉្យាងទៀត បទថា **កាយទ្វារេន** នោះ គឺ ព្រោះប្រកាន់យកសេចក្តីថា មានកាយទ្វារ ដូច្នេះ ទើបជាតតិយាវិភត្តិ ចុះក្នុងឥត្ថម្ភូត " ។

ពណ៌នាអំពីការប្រព្រឹត្តិធម៌

*នយមកហើយ ក្នុងដីកាទុកនិបាត អង្គុត្តរនិកាយថា "សពួ ថា **សមំ** ជាសពួសម្តែងការ: នៃនបុំសកលិង្គ " ។*

នយមកហើយ ក្នុងអដ្ឋកថាសាលេយ្យកសូត្រ ថា " មួយ ទៀត ការប្រព្រឹត្តិដូចគ្នា គឺជ៏សមគួរ ដល់ភាពជាសមណ: ដោយ អត្ថថា រម្ងាប់ចោល នូវធម៏ដែលជាសឹកសត្រូវ ព្រោះហេតុនោះ សេចក្តីប្រព្រឹត្តិនោះ ទើបឈ្មោះថា ត្រ៏មត្រូវ គឺ សុចរិត ។ ការ ប្រព្រឹត្តិនោះឯង ឈ្មោះថា សមចរិយា " ។

*(៧១) ដីកានៃចូឡហត្ថិបទោបមសូត្រ និង ចតុក្ក្ជនិបាត អង្គុត្តរនិកាយ ថា " បទថា **បជហិត្វា** គឺ លះបង់ហើយ ដោយ អំណាចនៃការសមាទាន ។ ព្រះអដ្ឋកថាចារ្យ សម្តែងនូវការ:នៃ ការលះបង់ និង ការវៀរចាក ថា ជាកិរិយាដែលមានកាល មិន ស្មើគ្នា ដោយពាក្យនេះថា **ឧហីនកាលតោ... វិរតោ វា** ដូច្នេះ ។ មានពាក្យចោទសួរថា ប្រសិនបើ កាលបើអដ្ឋកថាចារ្យ បាន ប្រកាន់យក យ៉ាងនេះហើយ, សពួថា **ឧហាយ** ជាសពួសម្តែង នូវបុរិមកាលបាន យ៉ាងដូចម្តេច? ។ មានពាក្យឆ្លើយថា **ឧហាយ** សពួ ជាសពួសម្តែងបុរិមកាលបាន ដោយការប្រៀបធៀបនូវការ: នៃកាល ដែលបុគ្គលគប្បីប្រកាន់យក យ៉ាងដូច្នោះ ។ មែនពិត កាលបើអាចារ្យសំឡ៏ងយកការ:នៃធម៏ទាំងឡាយ ដែលជាបច្ច័យ*

មង្គលត្ថទីបនីប្រែ

និង អាស្រ័យបច្ច័យកើតឡើង, កិរិយាប្រកាន់យក សូម្បីនូវធម៌ទាំងឡាយ ដែលកើតឡើងព្រមជាមួយគ្នា រមែងមាន ដោយការកើតឡើងជាមុន និង ខាងក្រោយ ចានដូចគ្នា ព្រោះការៈនៃធម៌ទាំងឡាយជាបច្ច័យ និង អាស្រ័យបច្ច័យកើតឡើង ព្រោះហេតុនោះ ពាក្យពោលនូវបុរិមកាល ដោយបហានកិរិយា ព្រោះធម៌ទាំងឡាយ មានហិរិ ឱ្ត្តប្ប: និង ញាណជាដើម ដែលជាបច្ច័យ និង ពាក្យពោល នូវអបរកាល ដោយវិមណកិរិយា ព្រោះវិតិទាំងឡាយ ដែលអាស្រ័យបច្ច័យ កើតឡើង រមែងមាន ដោយអំណាចនៃអាការៈនៃកិរិយាប្រកាន់យក និង កិរិយាប្រព្រឹត្ត ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ***ឧហាយ ឧជ្ជិវិតោ*** *ដូច្នេះ ។ ម្យ៉ាងទៀត បទថា* ***ឧហាយ*** *ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយអំណាចនៃការធ្វើ ក្នុងវេលាសមាទាន ។ បទថា* ***ឧជ្ជិវិតោ*** *ព្រះអង្គ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃការជួបប្រទះ នូវវត្ថុដែលខ្ជួនគប្ជីកន្ធ ក្នុងកាលជាខាងក្រោយ ។ មួយទៀត បទថា* ***ឧហាយ*** *បណ្ឌិត គប្ជីជ្រាប ដោយអំណាច នៃសមានកាល ដូចជាសមានកាល ក្នុងប្រយោគទាំងឡាយ មានអាទ៑ យ៉ាងដូច្នេះ ថា ៖*

ព្រះអាទិត្យ គ្រាន់តែរះឡើងភ្លាម ក៏កំចាត់ផ្ទៃវាគំនរ

ពណ៌នាអំពីការប្រព្រឹត្តិធម៌

នៃសេបក្តីងងឹតបាន និង ប្រយោគថា ព្រះបន្ទ រះឡើង
ភ្លឺស្វាងហើយ រមែងភ្លឺស្វាងត្រចះត្រចង់ ដូច្នេះ ។

ម៉ាងវិញទៀត ពាក្យថា ***បហាយ បដិវិរតោ*** *បណ្ឌិត គប្បីជ្រាបសេចក្តីថា សត្ត គឺបុគ្គល តែងសម្លាប់ ដោយចេតនាធម៌ន៉ុះ ហេតុនោះ ចេតនាធម៌ន៉ុះ ទើបឈ្មោះថា បាណាតិបាត គឺ សង្ក៏លេសធម៌ មានចេតនាជាប្រធាន ដែលប្រកបដោយការមិនខ្មាសបាប មិនខ្លាចបាប ទោសៈ មោហៈ និង ការបៀតបៀន ជាដើម ដែលជាហេតុឲ្យសម្លាប់សត្ចមានជីវិត ។ ធម្មចារិសមាចារី-បុគ្គល លះបង់ចោល នូវបាណាតិបាតនោះ ដោយអំណាចនៃការសមាទាន រមែងជាអ្នកវៀរចាក ជាច់ស្រឡះ អំពីបាណាតិបាតនោះ ។ ព្រះអដ្ឋកថាចារ្យ សម្តែងនូវភាវៈនៃវិរតិនោះ ថា ជាកិរិយាមិនមានទីបញ្ចប់ ដោយអំណាច នៃកាលជាដើម ដោយអវធារណសព្ទ ក្នុងបទថា* ***វិរតោ វ*** *ដូច្នេះ ។ ប្រៀបដូចជាបុគ្គលទាំងឡាយឯទៀត សូម្បីជាអ្នកមានវិរតិ គឺខ្ជួនសមាទានហើយ រមែងទំលាយ នូវការសមាទានចោល ព្រោះហេតុ នៃវត្ថុដែលជាទីស្រឡាញ់ មានលាភ និង ជីវិត ជាដើម ព្រោះភាពនៃខ្ជួនជាអ្នកមានចិត្តមិនរឹងប៉ឹង យ៉ាងណាមិញ, ធម្មចារិសមចារីបុគ្គលនេះ មិនមែនជាយ៉ាងដូច្នោះឡើយ ។ តែ ធម្មចារិសមចារីបុគ្គល នេះ*

មន្តលត្ថទីបនីប្រែ

រមែងជាអ្នកវៀរចាក ចាប់ដើមអំពីកាលដែលខ្ជូនសមាទាន រួចហើយ ទើបឈ្មោះថា ជាអ្នកវៀរចាកស្រឡះហើយ ដូច្នេះឯង ។ សូម្បីក្នុងពាក្យទាំងឡាយមានពាក្យថា **អទិន្នាទានំ បហាយ** ដូច្នេះជាដើម បណ្ឌិតគប្បីជ្រាបសេចក្តី ដោយន័យនេះ ដូចគ្នាដែរ ។ វត្ថុដែលជាគ្រឿងញុាំងសត្វឲ្យធ្លាក់ចុះ គឺ ជំបង ឈ្មោះថា ទណ្ឌៈ បានដល់ គ្រឿងប្រហារពិសេល មានអន្ជូងជាដើម ព្រោះហេតុនោះ គ្រឿងប្រហារពិសេស ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អធិប្បាយហើយ ក្នុងបទថា **និហិតទណ្ឌោ** នេះ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **ឋបេត្វា ទណ្ឌំ សព្វម្បិ អវសេសំ ឧបករណំ** ដូច្នេះ ។ ក៏កិរិយាពោល ដល់ការទម្លាក់ចោល នូវជំបង និង សស្ត្រា ក៏ដើម្បីនឹងសម្តែងភាវៈ នៃគ្រឿងបៀតបៀន នូវបុគ្គលដទៃ ពោលគឺ គ្រឿងដាក់ទណ្ឌកម្ម ដែលធម្មចារិសមចារីបុគ្គល បានលះបង់ហើយ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **បរុបឃាតត្ថាយ** ដូច្នេះជាដើម ។ មិនមែនពោល ដើម្បីភាវៈជាគ្រឿងបៀតបៀនឡើយ ។ សូម្បីសេចក្តីខ្លាចបាប បណ្ឌិតគប្បីជ្រាបថា ព្រះអដ្ឋកថាចារ្យ ពោលហើយ ដោយលជ្ជាសពូ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងបទថា **លជ្ជី** នេះ ។ សេចក្តីខ្លាចបាប របស់បុគ្គលអ្នកប្រកប

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ដោយសេចក្តីស្អប់ខ្ពើមបាប រមែងជាការមិនភ័យខ្លាចបាបក៏ទេដែរ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **លជ្ជី** ដូច្នេះ តែប៉ុណ្ណោះ ។ មានពាក្យសួរថា ព្រះអដ្ឋកថាចារ្យ ពោលថា **ទយំ មេត្តចិត្តតំ អាបន្នោ** ដូច្នេះ ព្រោះហេតុអ្វី?, **ទយា** សព្ទ រមែងប្រព្រឹត្តទៅ ក្នុងអត្ថនៃករុណាសព្ទ ដូចជាករុណាសព្ទ ក្នុងពាក្យទាំងឡាយ មានពាក្យថា **អទយាបន្នោ** ដូច្នេះជាដើម មិនមែនទេឬ? ។ មានពាក្យឆ្លើយថា ដំណើរនោះ ពិតមែន ។ ប៉ុន្តែថា **ទយា** សព្ទនេះ ធ្វើនូវផលត្រឹមតែការតាមបែរក្សា ឲ្យជាកិច្ចដែលខ្ជួននាំទៅហើយ ព្ធដ៏ខាងក្នុង កាលប្រព្រឹត្តទៅ រមែងប្រព្រឹត្តទៅ ក្នុងអត្ថនៃមេត្តាសព្ទ និង ករុណាសព្ទ ព្រោះហេតុនោះ ព្រះអដ្ឋកថា-ចារ្យ ទើបពោល **ទយា** សព្ទ ដែលប្រព្រឹត្តទៅ ក្នុងអត្ថនៃ **មេត្តា** សព្ទ ទុកក្នុងទីនេះ ។ ធម្មជាតិ ណា ដែលបុគ្គលស្រលាញ់ គឺ ស្នេហា ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា មេត្តា, មេត្តា របស់ចិត្តនុ៎ះ រមែងមាន ហេតុនោះ ចិត្តនោះ ទើបឈ្មោះថា មានមេត្តា, ចិត្ត មានមេត្តា របស់បុគ្គលនោះ មាន ហេតុនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានចិត្ត មានមេត្តា, ភាវៈនៃបុគ្គលជាអ្នកមានចិត្តមានមេត្តានោះ ឈ្មោះថា ភាវៈនៃបុគ្គលជាអ្នកមានចិត្ត មានមេត្តា, បណ្ឌិត គប្បីជ្រាបសេចក្តី ដោយប្រការដូច្នេះ ។ ព្រះ

មន្ទលត្ថទីបនីប្រែ

មានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវភាវ:នៃវិរតិនោះ ជាកិរិយាមិន មានទីបញ្ចប់ ដោយអំណាចនៃសត្ត ដោយពាក្យថា ***សព្វប្បាណ-ភូតហិតានុកម្បិ*** *នេះ ។ បទថា* ***បាណភូតេ*** *គឺនូវសត្វទាំងឡាយ ។ បទថា* ***អនុកម្បកោ*** *គឺ ជាអ្នកប្រព្រឹត្តនូវករុណា ។ ក៏មេត្តា រមែងមានបច្ចុយ ខុសប្លែកផ្សេងអំពីករុណា ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា* ***តាយ ឯវ ទយា-បន្នតាយ*** *ដូច្នេះ ។ បណ្ឌិតគប្បីយើញសេចក្តី ក្នុងពាក្យថា* ***ទយំ មេត្តចិត្តតំ អាបន្នោ*** *នោះ យ៉ាងដូច្នេះ ថា កិរិយាវៀរចាកបាណា-តិបាត រមែងសម្រេចបាន ដោយធម៌ទាំងឡាយណា, ព្រះអដ្ឋកថាចារ្យ សម្តែងភាវ: នៃបុគ្គលជាអ្នកប្រកបព្រម ដោយធម៌ទាំងឡាយនោះ គឺ សេចក្តីខ្ចាស មេត្តា និង ករុណា ព្រមជាមួយគ្នានឹងធម៌ ដែលប្រព្រឹត្តទៅ ព្ធដ៏ខាងក្រោយ ។ ព្រះអដ្ឋកថាចារ្យ ពោលចោទសួរ ក្នុងសេចក្តីនេះថា ព្រះមានព្រះភាគ ទ្រង់ធ្វើសព្ទសម្តែងឯកវចន: ក្នុងបាលី ថា* ***បាណាតិបាតំ បហាយ*** *ដូច្នេះ ព្រោះហេតុអ្វី?, ការវៀរចាកកិរិយាញុាំងសត្វទាំងឡាយ ដែលមិន មានសេសសល់ ឲ្យធ្លាប់ចុះកន្ថង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អធិប្បាយហើយ ក្នុងពាក្យនេះ មិនមែនទេឬ? ។ ពិតមែន យ៉ាងដូច្នោះ ព្រះអង្គទ្រង់ត្រាស់ហើយថា* ***សព្វប្បាណភូតហិតានុកម្បី***

ពណ៌នាអំពីការប្រព្រឹត្តិធម៌

វិហរតិ ដូច្នេះ ។ ដោយហេតុនោះឯង ព្រះអដ្ឋកថាចារ្យ ទើបពោល ក្នុងអដ្ឋកថា ថា ព្រះមានព្រះភាគ គប្បីធ្វើសពូ សម្តែងជាពហុវចន: ថា ***សពេ ចាណកូតេ ហិតេន អនុកម្បកោ*** ដូច្នេះ ។ គប្បីជ្រាបវិសជ្ជនាថា ពាក្យដែលលោកពោលហើយនុ៉ះពិតមែន ។ ក៏ប៉ុន្តែថា ព្រះមានព្រះភាគ សូម្បីទ្រង់ធ្វើសពូ ក្នុងពាក្យនោះ ឲ្យជាសពូសម្តែង ជាឯកវចន: តាំងអំពីដើមមក ក្នុងព្រះបាលី ដោយអំណាចនៃភាវ:ជាសត្វស្មើគ្នា ដោយភាពជាសត្ត ដែលមានជីវិត, បុគ្គល នឹងជឹងបានថា ជាពហុវចន: ក៏ដោយការសន្និដ្ឋានសពូ នុ៉ះឯង ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបមិនបានធ្វើ ឲ្យជាសពូ សម្តែងស្មើគ្នា ហើយបានពោលសេចក្តី ក្នុងអដ្ឋកថា ដោយអំណាចជាពហុវចន:ដើម្បីនឹងសម្តែងសេចក្តីនោះ ដោយអំណាចប្រាថ្នាចង់ឲ្យមានវចន: ផ្សងអំពីគ្នា ។ បណ្ឌិត គប្បីជ្រាបសេចក្តីបន្តិចបន្ពូច ដោយក្រៃលែងថា ព្រះអដ្ឋកថាចារ្យ បានធ្វើការប្រែកផ្សងអំពីគ្នា នៃវចន:នេះ ដើម្បីនឹងសម្តែង នូវសេចក្តីប្រែកផ្សងគ្នានេះ ថា សំវរសមាទាន ដោយភាពជាសមាទានទូទៅ សេចក្តីខុសប្រែកផ្សងគ្នា នៃសំវរ: ជាអាការប្រែកផ្សងពី សំវរសមាទាននោះ ។ បទថា ***វិហរតិ*** មានសេចក្តីថា ធម្មចារិសមចារីបុគ្គល ជាអ្នកមានប្រការដូចពោលហើយ រមែងបំបាត់ នូវទុក្ខដែលកើតឡើង

ហើយ ព្រោះឥរិយាបថ ១ ដោយឥរិយាបថមួយទៀត នាំអត្ថភាពទៅ គឺ តែងញ៉ាំងអត្ថភាពឲ្យប្រព្រឹត្តទៅ បានដល់ ឲ្យរស់នៅ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា ***ឥរិយតិ ឋាលេតិ*** *ដូច្នេះ " ។*

(៧២) ដីកានៃសាលេយ្យកសូត្រថា " សពូថា ***ឋាសេ*** *ជាសពូសម្តែងឆន្ទជ្ជីវិកត្តិ ដោយអំណាចនៃទ្រព្យឯណា, ទ្រព្យនោះ ព្រះមានព្រះភាគ ទ្រង់កំណត់យកហើយ មែនពិត ដោយភាពជាទ្រព្យស្មើគ្នា ដោយបទថា* ***យន្ត*** *ដូច្នេះ ជាទ្រព្យដែលព្រះអង្គទ្រង់ប្រកាសហើយ ដោយសម្តែងជាឆន្ទជ្ជីវិកត្តិនុ៎ះឯង ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា* ***ឋាសន្តកំ*** *ដូច្នេះ ។ មួយទៀត ពាក្យថា* ***ឋាសេ ឋានុបការណំ*** *នោះ ជាបទសមាស តែមួយនុ៎ះឯង ។ អធិប្បាយថា ទ្រព្យជារបស់ជនដទៃ ឯណានីមួយ ឬ ទ្រព្យដែលជាឧបការណ៍គ្រឿងពេញចិត្ត របស់ជនដទៃ ដោយភាពជាទ្រព្យផ្សេងៗ គ្នា ។ ២ បទថា* ***តេហិ ឋានេហិ*** *គឺ ទ្រព្យដែលជារបស់ នៃជនទាំងឡាយណា, គឺ ជនទាំងឡាយនោះ (មិនបានឲ្យ ហើយ) ។ បុគ្គល ដែលគេហៅថា អ្នកលួច ដោយអំណាចនៃចិត្តណា, ចិត្តនោះ ឈ្មោះថា ថេយ្យ: (ចិត្តគិតនឹងលួច) ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា* ***អវហារណចិត្តស្សតំ***

ពណ៌នាអំពីការប្រព្រឹត្តិធម៌

អធិវចនំ *ដូច្នេះ ។ បុគ្គល រមែងជាអ្នកកាន់យក នូវរបស់នៃជនដទៃ ដោយចំណែកនៃចិត្តគិតនឹងលួច, អធិប្បាយថា មិនមែនជាអ្នកកាន់យក ដោយអំណាចនៃសេចក្ដីបរិសុទ្ធិ មានសេចក្ដីស្និទ្ធស្នាលគ្នា និង សុំខ្ចី ជាដើមឡើយ ។* ***វា*** *សព្ទ ក្នុងបទថា* ***មាតេវា*** *ជាវិកប្បត្ថៈ ដែលលោកមិនបានពោលទុកហើយ ។ ដោយហេតុនោះ* ***វា*** *សព្ទនោះ ទើបសង្គ្រោះនូវហេតុ មានភាពជាបព្វជិតជាដើម បញ្ចូលជាមួយផងដែរ ។ ព្រះអដ្ឋកថាចារ្យ ពោលថា* ***តេនុប្បាយេន*** *ដូច្នេះ សំដៅយកពាក្យ មានជាអាទិ៍ យ៉ាងនេះថា កាលបើមាតា ស្លាប់ហើយក្ដី វិនាសបាត់ទៅហើយក្ដី, បិតា រក្សានូវកូនស្រីណា, កូនស្រីនោះ ឈ្មោះថា ស្ត្រីដែលបិតា ថែរក្សាហើយ, កាលបើមាតា និង បិតាទាំង ២ នាក់ មិនមានទេ, បងប្អូនប្រុស ថែរក្សា នូវស្ត្រីណា, ស្ត្រីនោះ ឈ្មោះថា ស្ត្រីដែលបងប្អូនប្រុស ថែរក្សាហើយ ដូច្នេះ ។ បទថា* ***សភាគកុលានិ*** *គឺត្រកូលទាំងឡាយ ដែលស្មើភាពគ្នា ដោយការធ្វើអាវាហៈ និងវិវាហមង្គល " ។*

(៧៣) មែនពិត ព្រះមានព្រះភាគ ទ្រង់មិនបានសម្ដែង នូវពាក្យនេះ ថា " ***គោត្តរក្ខិតា ធម្មរក្ខិតា សារក្ខា*** *" ដូច្នេះ ទុកក្នុងព្រះបាលីទេ, ប៉ុន្តែ ពាក្យថា "* ***សស្សាមិកា*** *" នេះ មកហើយ ក្នុង*

មន្ត្លសត្ត្ទីបនីប្រែ

ទីស្ថានៃ **សារ**ក្ខ សពួ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងជីកាសម្មាទិដ្ឋិសូត្រ ជាដើម ថា " **សស្សាមិកា សារ**ក្ខា " ដូច្នេះ ។

(៧៤) ជីកាសាលេយ្យកសូត្រ ថា " ឥស្សរជន ទាំងឡាយ មានព្រះរាជា ជាដើម បានតាំងអាជ្ញាទុក ចំពោះថ្នល់ ឈ្មោះនុ៎ះ ឬ ផ្ទះ ឈ្មោះនុ៎ះ ។ បទថា **សម្មាទិដ្ឋិសុ**ត្ត គឺ បុគ្គល រមែងជាអ្នក ធ្វើនូវសេចក្ដីល្មើស ដោយអំណាចលក្ខណៈ នៃការប្រព្រឹត្ដិខុស ដែលព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រ យ៉ាងដូច្នេះថា ចេតនា ជាហេតុកន្ទងល្មើស នូវអគមនីយដ្ឋាន ដែលប្រព្រឹត្ដទៅ តាមកាយទ្វារ ដោយប្រាថ្នានឹងសេពនូវអសទ្ធម្ម ដូច្នេះ ។ បទថា **ហត្ថបាទាទិហេ**តុ គឺ ព្រោះហេតុនៃការត្រូវកាត់ នូវអវយវៈ មានដៃ និង ជើង ជាដើម ។ បទថា **ធនហេ**តុ គឺ ព្រោះហេតុ នៃការបានទ្រព្យសម្បត្ដិ និង ព្រោះហេតុនៃការសាប សូន្យចាកទ្រព្យ ។ ភោគៈ មានអាហារ និង គ្រឿងស្លៀកពាក់ ជាដើម ឈ្មោះថា លាភ ។ ឈ្មោះថា លាភ ព្រោះវិគ្រោះ ថា ដែលបុគ្គលតែងបាន ដូច្នេះ ។ បទថា **កិញ្ចិ**ក្ខំ គឺ នូវអាមិស មាន ប្រមាណបន្ដិចបន្ដួច ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យជាអាទិ៍ថា **យំ វ** ដូច្នេះ ។ បទថា **សម្ប្ជានន្ដោ ว**

គឺ ទាំងដឹង ថា ជាពាក្យកុហក បានដល់ (ដឹង) ថា វត្ថុនោះ ជារបស់មិនពិតនោះឯង " ។

*(៧៥) ដីកានៃចូឡហត្ថិបទោបមសូត្រ ជាដើមថា " បទថា **អនុប្បទាតា** គឺអ្នកតាមផ្តល់ឲ្យនូវកម្ទាំង, មួយទៀត ជាអ្នកជួយឧបត្ថម្ភ ដោយអំណាចនៃការប្រព្រឹត្តិតាម ។ មានពាក្យសួរ ថា ក៏ការប្រព្រឹត្តិតាម និង ការជួយឧបត្ថម្ភនូវអ្វី? ដូច្នេះ, បណ្ឌិត រមែងជ្រាបពាក្យវិនិច្ឆ័យ ថា ការប្រព្រឹត្តិតាម និង ការជួយឧបត្ថម្ភ នូវពាក្យព្រមព្រៀងគ្នា ព្រោះពាក្យថា **សមាហិតានំ** ព្រះមានព្រះភាគ ទ្រង់បានត្រាស់ហើយ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថា-ចារ្យ ពោលថា **សន្ធានានុប្បទាតា** ដូច្នេះ ។ មួយទៀត ការផ្តល់ឲ្យក្តី ការប្រគល់ឲ្យក្តី ការថែរក្សាក្តី នូវការព្រមព្រៀងគ្នា ដោយអំណាចការប្រព្រឹត្តិតាម ឈ្មោះថា ជាការធ្វើឲ្យបានមាំមួន ព្រោះហេតុណា ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យថា **ទ្វេ ជនេ សមគ្គេ ទិស្សា** ដូច្នេះជាដើម ។ ជនទាំងឡាយ រមែងត្រេកអរក្រៃលែង ក្នុងការព្រមព្រៀងគ្នានេះ ព្រោះហេតុនោះ ការព្រមព្រៀងគ្នានេះ ទើបឈ្មោះថា **អាវាសោ** គឺ ឋានៈ ដែលបុគ្គលគប្បីត្រេកអរ ។ ក៏ព្រោះសេចក្តីនេះ សូម្បីប្រាសចាក **អា** អក្សរ ក៏ប្រើការបាន, ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលបាលីថា*

មន្តលត្តនីបនីប្រែ

សមគ្គភាមោ *ដូច្នេះ ក៏មានខ្ទះ ។ សេចក្ដី ក៏ដូចគ្នានេះដែរ " ។*

*(៧៦) ដីកាសាលេយ្យកសូត្រ " ដុំពកទាំងឡាយ ដូចជាក្រមរ ពួជដ៏ដើមឈើ គេហៅថា អណ្ហកា, ក្រមរទាំងឡាយនោះ ជារបស់រឹង មិនរាបស្មើ និង ជារបស់ដែលចោះទម្ទុះ ចានដោយក្រយ៉ាងណា, សូម្បីវាចា ដែលប្រព្រឹត្តទៅហើយ ដោយអំណាចការពោលមួលបង្ក្ដាច់ និង ការពោលសង្ក្ដត់សង្ក្ដិន ក៏យ៉ាងដូច្នោះដែរ ។ ព្រោះហេតុនោះ វាចានោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **អណ្ហកា** ។ ដោយហេតុនោះ ទើបលោកពោលថា **យថា សាទោសេ រុក្ខេ** ដូច្នេះជាដើម " ។*

*ដីកានៃសង្ខ្ដីតិសូត្រ និង ទុកនិបាត អង្គុត្តរនិកាយ ថា " បុគ្គលទាំងឡាយ រមែងហៅនូវដុំ នៃជ័ររឈើទាំងឡាយ (ជ័ររុង) ឬ ពួជ មានផ្សែតក្ឍាលពណ៌ជាដើម ដែលកើតឡើងហើយ ពួជដ៏ដើមឈើពុកស្ងួយ គឺមានដំបៅថា **អណ្ហកា** ដូច្នេះ ។ មួយទៀត ដុំនៃលំអិត ឬ ដុំពកនៃដើមឈើ ដែលមានក្រមរ មានដំបៅឃ្ងង់ កើតឡើង ដូចជាដុំពក ឈ្មោះថា **អណ្ហកា** ។ ក៏ក្នុងវចីកម្មនេះ បណ្ឌិត គប្បីឃើញវាចា ដែលឈ្មោះថា **អណ្ហកា** ដោយមានចំណែកដូចជាក្រមរ ព្រោះភាវៈជាវាចាឲ្យបានដល់ នូវសេចក្ដីវិនាស និង ជាវាចារឹងរូស ជាដើម, វាចា ដែលចូលទៅប៉ះត្រចៀក*

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ប្រៀបដូចជាដើម (ទង) បទុម បណ្ឌិត គប្បីយើញថា ជាវាចាអាក្រក់ " ។

ដីកានៃសាលេយ្យកសូត្រថា " បទថា **កក្កសា** គឺ ជាវាចាអាក្រក់នុ៉ះឯង ។ ក៏ភាវៈនៃវាចានោះ ជាវាចាអាក្រក់នោះ ព្រោះមានព្យាបាទជាគ្រឿងសម្គាល់ ឈ្មោះថា ជាវាចាស្អុយ ព្រោះវាចានោះជាវាចាអាក្រក់ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យថា **យថា នាម** ដូច្នេះជាដើម ។ បទថា **កដុកា** គឺ ជាវាចា ដែលបុគ្គលមិនប្រាថ្នាហើយ ។ បទថា **អមនាបា** គឺ ជាវាចា មិនជាទីចម្រើន ដល់ចិត្ត ។ ព្រោះជាវាចា មិនជាទីចម្រើនដល់ចិត្តនោះឯង ទើបជាវាចាញ្ចាំងទោសឲ្យកើតឡើង គឺ ជាវាចាដែលញ្ចាំងទោស ឲ្យកើតឡើងក្នុងចិត្ត ។ បទថា **មម្មេសុ** គឺ ក្នុងការជេរទាំងឡាយ មានជាតិជាដើម ប្រៀបបីដូចជា របស់ដែលស្រលាញ់ ព្រោះសេចក្តីទុក្ខកើតឡើងបាន ដោយការចាក់ដោត ។ បទថា **លគ្គនការី** គឺ ជាវាចា ធ្វើនូវសេចក្តីជាប់ជំពាក់ ដោយសេចក្តីប្រាថ្នាថា អាត្មាអញ នឹងពោលយ៉ាងនេះ ដូច្នេះ, មិនមែនជាវាចា ធ្វើនូវសេចក្តីជាប់ជំពាក់ ដោយអំណាចនៃការមិនធ្វើ នូវសេចក្តីយល់ព្រមទេ ។ ឈ្មោះថា ជាវាចា ជិតដល់សេចក្តីក្រោធ ឯង ព្រោះជាហេតុនៃសេចក្តីក្រោធនោះ " ។

មង្គលត្ថទីបនីប្រែ

ដីកានៃសង្គ្ហតិសូត្រ និង ទុកនិបាត អង្គុត្តរនិកាយថា " ជាវាចាកើតឡើង ព្រោះសេចក្តីក្រោធ គឺ ជាបរិវារ នៃសេចក្តីក្រោធ នោះ ឈ្មោះថា ជាវាចា ជិតដល់សេចក្តីក្រោធ " ។

*ដីកានៃសាលេយ្យកសូត្រថា " បទថា **សាទោសវាចាយ** គឺ បទទាំងឡាយ មាន **អណ្ហកា** ជាដើម ជាឈ្មោះ នៃវាចាដែលមានទោស ដោយអំណាចញ៉ាំងទោស ឲ្យកើតឡើង ដល់ខ្លួន " ។*

*(៧៧) ដីកានៃចូឡហត្ថិបទោបមសូត្រ ជាដើមថា " បទថា **ឯត្ត** មានសេចក្តីថា ក្នុងគាថានេះ ថា ៖*

" រថណា មានតួមិនមានទោស មានដំបូលពណ៌ស មានកាំ
តែមួយ ប្រព្រឹត្តទៅ, ចូរអ្នកមើលនូវរថនោះ ដែលបង្ហៀត
កាត់ខ្សែ នៃតណ្ហាចោលបាន មិនមានគ្រឿងបង ដែល
កំពុងប្រព្រឹត្តទៅ " ដូច្នេះ,

*ក៏សីល ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយថា មានអង្គមិនមានទោស ក្នុងគាថានេះ ។ ដោយហេតុនោះឯង ទើបចិត្តគហបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា **នេឡង្គំ** នេះឯងជាឈ្មោះនៃសីលទាំងឡាយ ដូច្នេះ ។ បទថា **កុសុមាវ** គឺឈ្មោះថា ជាវាចាដែលទន់ភ្ញន់ ព្រោះជាវាចាមិនអាក្រក់ ។ ក្នុងពាក្យថា **បុរិសេ ឯសា** ន ៖ **បុរ** សព្ទ បណ្ឌិតគប្បីឃើញថា ជាសព្ទបញ្ជាក់*

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ដល់បុគ្គលអ្នកនៅអាស្រ័យ ក្នុងបុរីនោះ ដូចជា **គាម** សព្ទ ក្នុងប្រយោគទាំងឡាយថា **គាមោ អាគតោ** ដូច្នេះ ជាដើម ។ ដោយហេតុនោះឯង ទើបព្រះអដ្ឋកថាចារ្យពោលថា **នគរវាសីនំ** ដូច្នេះ ។ វាចាណា ញ្ចាំងចិត្ត ឲ្យរីករាយសប្បាយ គឺ ញ្ចាំងចិត្ត ឲ្យចម្រើនហេតុនោះ វាចានោះ ឈ្មោះថា ជាវាចាញ្ចាំងចិត្ត ឲ្យចម្រើន ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា ជាវាចាធ្វើឲ្យចម្រើនចិត្ត ដូច្នេះ ។

(៧៨) ដីកាសាលេយ្យកសូត្រថា " បទថា **ហទយមញ្ជុ-សាយ** គឺ នូវវាចា ដែលមិនគួរ ដើម្បីនឹងញ្ចាំងចិត្ត ឲ្យត្រេកអររក្សាទុកបានឡើយ ព្រោះជាវាចា មិនមានប្រយោជន៍ ។ បទថា **អនបទេសំ** គឺ ប្រាសចាកទីអាង គឺសូត្រថា ពាក្យយ៉ាងនេះ ព្រះមានព្រះភាគ ទ្រង់បានត្រាស់ទុកហើយ ក្នុងព្រះសូត្រ ឈ្មោះនុ៉ះ ដូច្នេះ ។ បទថា **អបរិច្ឆេទំ** គឺ ប្រាសចាកការកំណត់ ។ ក៏វាចារមែងជាវាចាប្រាសចាកកំណត់ ដោយប្រការណា, ដើម្បីសម្តែងនូវប្រការនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យថា **សុតំ វា** ដូច្នេះជាដើម ។ បទថា **ឧបារម្ភំ** គឺ ពាក្យដែលប្រកបតាម, សូត្រ ឬ ជាតក ដែលប្រាសចាកការប្រកប ដោយពាហិរកថា ដែលឧ្ជូនបានលើទុកហើយ, ព្រះធម្មកថិក មិនបានទាញយក នូវពាក្យ

មន្តលត្ថទីបនីប្រែ

ដែលជាដើមបទ នៃសូត្រ ឬ ជាតក នោះមកទេ ពោលតែពាក្យ ដែលមាននៅខាងក្រៅ នៃសូត្រ ឬ ជាតកនោះ តែប៉ុណ្ណោះ ។ បទថា **សម្បជ្ជិត្វា** គឺ ដល់ហើយនូវសេចក្តីចម្រើនឡើង ។ បទថា **បវេណិជាតា វ** គឺ ឬស នៃដើមជ្រៃ ដែលកើតតៗ គ្នាទាំងឡាយ ន៉ុះឯង រមែងដុះឡើង ។ បទថា **អាហរិត្វា** គឺ នាំយកមកសូម្បីនូវពាក្យដទៃ អំពីសូត្រ ដែលខ្ជួនបានលើកយកមកហើយ ឲ្យជាវាចាប្រកបដោយសូត្រនោះ ដោយអំណាចការសាកសួរ ឧបមានិងរឿង ។ បទថា **ជានាបេតុំ** មានសេចក្តីថា ព្រះធម្មកថិក រូបណា តែងអាចដើម្បីនឹងញ្ចាំងអ្នកស្តាប់ ឲ្យយល់បានថា ព្រះសូត្រនេះ មានសេចក្តីយ៉ាងនេះ ដូច្នេះ, ព្រះធម្មកថិកនោះ នឹងសម្តែងក៏សមគួរ ។ ព្រះធម្មកថិករូបនោះ គឺអ្នកប្រាកដដូច្នោះ សូម្បីជាសម្តែងច្រើន ក៏សមគួរ ។ បទថា **អនត្ថសញ្ហិតំ** គឺ មិនមែនជាប្រយោជន៍ ដល់ខ្ជួន និង ជនដទៃ " ។

(៧៩) ដីកាចូឡហត្ថិបទោបមសូត្រ ជាដើម ថា " ពាក្យថា **កាលវាទី** ជាដើម ជាពាក្យសម្តែងនូវសេចក្តីប្រតិបត្តិ នៃបុគ្គលដែលវៀរចាកពាក្យរាយមាយ ឥតប្រយោជន៍ ។ មែនពិត វាចាសូម្បីប្រកបដោយប្រយោជន៍ (តែ) មិនគប្បីជាវាចា ដែលនាំនូវប្រយោជន៍មកឲ្យ ព្រោះប្រកប ក្នុងពេលដែលមិនគួរ ព្រោះហេតុ

ពណ៌នាអំពីការប្រព្រឹត្តិធម៌

នោះ ទើបអនុលោម ដល់វាចាដែលញ៉ាំងអ្នកស្តាប់ ឲ្យស្គាល់កាលដែលមិនមានប្រយោជន៍, ហេតុនោះ បុគ្គលអ្នកលះបង់ នូវវាចាពោយពាយឥតប្រយោជន៍ គប្បីចៀសវាងភាពជាអ្នកពោល ក្នុងវេលាមិនសមគួរចេញ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា ***កាលវាទី*** *ដូច្នេះ ។ សូម្បីបុគ្គលពោល ក្នុងកាលដ៏សមគួរ ក៏គប្បីវៀរចាកពាក្យដែលមិនពិត ព្រោះមិនញ៉ាំងឲ្យបានសម្រេចប្រយោជន៍ទាំង ២ ផ្នែក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា* ***ភូតវាទី*** *ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា* ***អត្ថវាទី*** *ដូច្នេះ ដើម្បីនឹងទ្រង់សម្តែងថា ក៏បុគ្គលកាលពោល នូវពាក្យពិតត្រង់ គប្បីពោលពាក្យ ដែលញ៉ាំងប្រយោជន៍សុខ ក្នុងលោកនេះ និងលោកខាងមុខ ឲ្យបានសម្រេចដោយពិត ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា* ***ធម្មវាទី*** *ដូច្នេះ ដើម្បីនឹងទ្រង់សម្តែងថា បុគ្គលសូម្បីពោលពាក្យដែលមានប្រយោជន៍ មិនត្រូវពោលពាក្យ ដែលអាស្រ័យលោកិយធម៌ តែម៉ាង គប្បីពោលពាក្យ ធ្វើឲ្យជាពាក្យអាស្រ័យលោកុត្តរធម៌ ផងដែរ ដូច្នេះ ។ ក៏សេចក្តី រមែងជាពាក្យអាស្រ័យលោកុត្តរធម៌បានដោយប្រការណា, ដើម្បីទ្រង់សម្តែងនូវប្រការនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា* ***វិនយវាទី*** *ដូច្នេះ ។ ព្រោះថា សេចក្តីដែល*

មង្គលត្ថទីបនីប្រែ

បុគ្គលកំពុងពោល ដោយអំណាចនៃ សំវរវិនយ ៥ ប្រការ និង បហានវិនយ ៥ ប្រការ ឈ្មោះថា ជាសេចក្ដីអាស្រ័យលោកុត្តរ-ធម្ម ព្រោះជាហេតុឲ្យបានសម្រេចនូវព្រះនិព្វាន ហេតុនោះ ទើប ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ***និធានវតី វាចំ ភាសិតា*** *ដូច្នេះ ដើម្បីទ្រង់សម្ដែងថា ក៏សេចក្ដីដែលប្រកប ដោយគុណវិសេស សូម្បីយ៉ាងនេះ ដែលព្រះធម្មកថិកកំពុងពោល, កាលបើភាពជា អ្នកឆ្ងាត ក្នុងការសម្ដែងមាន, រមែងពីរោះ និង រមែងជាអ្នកធ្វើ កិច្ច, មិនមែនជាអ្នកប្រព្រឹត្ដទៅ ដោយប្រការដទៃទៀយ ដូច្នេះ ។ ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យថា* ***ការេន*** *ដូច្នេះជា ដើម ដើម្បីទ្រង់ប្រកាសនូវភាពជាអ្នកឆ្ងាត ក្នុងការសម្ដែងនោះ ។ វាចាដែលប្រកបដោយប្រយោជន៍ ក្នុងបទថា* ***ការេន*** *ជាដើមនេះ បណ្ឌិតគប្បីជ្រាប យ៉ាងនេះថា ក៏ព្រះធម្មកថិក កំណត់ នូវវិភាគ នៃព្យាករណ៍ មាន ឯកំសព្យាករណ៍ ជាដើម ក្នុងរឿងនៃវាចា ដែលសាកសួរបាន ដោយអំណាចនៃហេតុ មានការចោទសួរ ជា ដើម ហើយញ្ជាំងបុគ្គលដទៃឲ្យតាំងនៅ ក្នុងធម្ម តាមសេចក្ដីពិត សមគួរដល់កម្ទាំងនៃការចេះដឹង ដោយពាក្យដែលញ្ជាំងអ្នកស្ដាប់ ឲ្យយល់ច្បាស់បាន តាមសមគួរ ដល់ហេតុនោះៗ ដោយឧបមា ហេតុ ឧទាហរណ៍ និង ការប្រៀបធៀប ជាពាក្យមានរូបសេចក្ដី*

ដែលបុគ្គលប្រមាណ និង កំណត់ចាន ជាកថាដែលសង្គ្រោះដោយ ពាក្យដែលបរិបូណ៌ ជ្រាលជ្រៅក្រៃលែង ខ្ជិឡ្ឍរិក មានសេចក្តី យ៉ាងក្រៃលែង និង ពិស្តារ ទើបលោកហៅថា ជាអ្នកឆ្ងាត ក្នុង ទេសនា ដូច្នេះ " ។

*(៨០) ដីកានៃកយកេវសូត្រថា " **ឈា** សព្ទ មាន **អកិ** ជាបទខាងដើម មានការសំឡឹងរំពៃជាសេចក្តី ហេតុនោះ ព្រះ អដ្ឋកថាចារ្យ ទើបពោលថា **ឋានេ ហេតុម្ហិ អកិជ្ឌាយនសីលា** " ។*

*ដីកានៃសាលេយ្យកសូត្រថា " ភាគច្រើន ការសំឡឹងរំពៃ រមែងមាន ដោយអំណាចនៃកិរិយាឃើញទ្រព្យ ដែលជារបស់ នៃ បុគ្គលដទៃ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា **អកិជ្ឌាយ ឧលោកេតា ហោតិ** ។ ម្យ៉ាងទៀត រមស់ (ឯណា) ដែលខ្ជួនសំឡឹងរំពៃហើយ ដោយអកិជ្ឌា, បុគ្គល រមែងសំឡឹង រំពៃនូវរមស់នោះ ដូចជាបុគ្គលឃើញវត្ថុ ដែលគេតាំងទុក ក្នុងទី ណាមួយ ដោយជាក់ច្បាស់យ៉ាងនោះឯង ព្រោះហេតុនោះ ទើប ព្រះអដ្ឋកថាចារ្យពោលថា **អកិជ្ឌាយ ឧលោកេតា ហោតិ** " ។ ពាក្យថា **កម្មូបថកេ០ ន ហោតិ** មានសេចក្តីថា ការបែកធ្លាយ នៃកម្មូបថ រមែងមិនមាន ដោយហេតុត្រឹមតែសេចក្តីលោភ តែ មួយយ៉ាង ព្រោះសេចក្តីលោភនោះ មិនប្រព្រឹត្តទៅ ដោយអំណាច*

មន្តលត្ថទីបនីប្រែ

នៃកិរិយាបង្អោនចូលមកឡើយ ។ ការបែកធ្លាយនៃកម្ចបថ រមែងមាន ដោយវិធីណា, ដើម្បីនឹងសម្តែងនូវវិធីនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **យទា បន** ដូច្នេះជាដើម ។ បុគ្គល រមែងបង្អោនចូលមក ដោយភាពជាទ្រព្យរបស់ខ្លួន ក្នុងកាលណា ការបែកធ្លាយនៃកម្ចបថ រមែងមាន ក្នុងកាលនោះ ។ បទថា **វិបន្នចិត្តោ** គឺ ជាអ្នកមានចិត្ត ត្រូវសេចក្តីព្យាបាទ ឲ្យដល់ហើយ នូវសេចក្តីវិបត្តិ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **បូតិ-ភូតចិត្តោ** ។ ព្រោះថា សេចក្តីព្យាបាទ រមែងញ្ចុាំងភាពមិនល្អ (ស្អុយ) នៃចិត្ត ឲ្យកើតឡើង ប្រៀបដូចជាថ្នាំពិស ញ្ចុាំងលោហិត (មិនល្អ) ឲ្យកើតឡើង ដូច្នោះ ។ ២ បទថា **ទោសេន ទុដ្ឋចិត្ត-សង្កប្បោ** មានសេចក្តីថា ជាអ្នកមានសេចក្តីត្រិះរិះ ក្នុងចិត្ត ត្រូវសេចក្តីក្រោធប្រទូសរ៉ាយហើយ ប្រៀបដូចជាភេសជ្ជ: មានទឹកដោះរាវថ្លាជាដើម ត្រូវថ្នាំពិសចូលជ្រៀតជ្រែកហើយ " ។

ជីកានៃភយភេរវសូត្រ ថា " បទថា **បកតិភាវវិជហនេន** គឺ ព្រោះលះបង់នូវភាពជាប្រក្រតី ពោលគឺ ភវង្គចិត្តដែលបរិសុទ្ធនិង ពោលគឺភាពជាចិត្តដែលមិនមានទោស ។ ក៏បុគ្គលអ្នកច្រើនដោយអភិជ្ឈា រមែងជាអ្នកលះបង់ភាពនៃចិត្តមិនមានទោសចោលព្រោះញ្ចុាំងធម៌ដែលមានទោស ឲ្យកើតឡើង ។ បទថា **វិបន្នចិត្តា**

ពណ៌នាអំពីការប្រព្រឹត្តិធម៌

គឺ ឈ្មោះថា ជាអ្នកមានចិត្តខូច ព្រោះភាពជាអ្នកមានចិត្ត គឺភាវៈនៃសេចក្តីមិនល្អ គឺ កិលេសប្រទូសរ៉ាយហើយ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា ***កិលេសានិគតញ្ហិ... បូតិកំ ហោតិ*** *។ បទថា* ***បទុដ្ឋចិត្តសង្កប្បា*** *គឺ ជាអ្នកមានចិត្ត ត្រូវទោសប្រទូសរ៉ាយហើយ ប្រៀបដូចទឹកមូត្រស្អុយ ដែលផ្សំគ្នា ដោយថ្នាំពិស ដូច្នោះ " ។*

(៨១) ដីកាសល្វេខសូត្រថា " បទថា ***សម្មា*** *គឺ មិនវិបរិត្ត, ទិដ្ឋិ ដែលឈ្មោះថាល្អ គឺប្រសើរ ព្រោះមិនវិបរិត្តនោះឯង, ឈ្មោះថា វិញ្ញូជនសរសើរហើយ ព្រោះភាវៈជាទិដ្ឋិ គឺពួកវិញ្ញូជន មានព្រះពុទ្ធជាដើមសរសើរហើយ ។ ក៏ទិដ្ឋិ នោះ ឈ្មោះថា ដល់ភាពជាកម្មបថ តែម្តង ព្រោះភាវៈនៃទិដ្ឋិនោះ រាប់ចូល ក្នុងកម្មបថ " ។*

ដីកានៃសាលេយ្យកសូត្រ និង តិកនិបាត អង្គុត្តរនិកាយ ថា " មិច្ឆាទិដ្ឋិកបុគ្គល ពោលទានថា ***ទិន្នំ*** *ដូច្នេះ សំដៅយកទេយ្យធម៌ជាប្រធាន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលថា* ***ទានស្ស ផលាភាវំ សន្ធាយំ វទតិ*** *ដូច្នេះ ។ ក៏ មិច្ឆាទិដ្ឋិក-បុគ្គល រមែងហាមនូវវត្ថុដែលបុគ្គលឲ្យហើយ យ៉ាងដូចម្តេច ។ នយ សូម្បីក្នុងពាក្យថា* ***យិដ្ឋំ ហុតំ*** *នេះ ក៏នយនេះ ដូចគ្នាដែរ ។ មហាទាន ដែលទូទៅ ដល់ជនទាំងពួង ឈ្មោះថា* ***មហាយាគៈ*** *។*

មង្គលត្ថទីបនីប្រែ

សក្ការៈ ដែលគេគប្បីធ្វើ ដើម្បីពួកក្មៀវ ឈ្មោះថា បហោនក-សក្ការៈ ។ ផល គឺអានិសង្ស និង ផលជាគ្រឿងហូរចេញ ឈ្មោះថា ផល ។ ផលដូចគ្នាឈ្មោះថា វិបាក ។ ពាក្យថា ***បរលោកេ ឋិតស្ស អយំ លោកោ នត្ថិ*** *មានសេចក្តីថា លោកនេះ គឺបុគ្គលអ្នកស្ថិតនៅ ក្នុងបរលោក គប្បីបាន ព្រោះកម្ម រមែងមិនមាន ។ ពាក្យថា* ***ឥធលោកេ ឋិតស្សាបិ បរលោកោ នត្ថិ*** *មានសេចក្តីថា បរលោក គឺបុគ្គលស្ថិតនៅ ក្នុងលោកនេះ គប្បីបាន ព្រោះកម្ម រមែងមិនមាន ។ មិច្ឆាទិដ្ឋិកបុគ្គល ពោលហេតុ ក្នុងឥធលោក និង បរលោកនោះ ថា សត្វទាំងឡាយទាំងពួង រមែងខាតសូន្យ ក្នុងកពនោះៗ ឯង ដូច្នេះ ។ សត្វ ទាំងឡាយនេះ ស្ថិតនៅ ក្នុងទីណា ៗ មានកព កំណើត និង គតិ ជាដើម រមែងខាតសូន្យ គឺ រមែងវិនាសទៅ ដោយសេចក្តីវិនាស ដែលមិនមានពូជបន្ត ក្នុងទីនោះៗ ឯង ។ បទថា* ***ផលាការវិសេន*** *គឺ មិច្ឆាទិដ្ឋិកបុគ្គលពោលថា មាតា និង បិតា មិនមាន ដោយអំណាចការមិនមានផលនៃការប្រតិបត្តិត្រូវ និង ការប្រតិបត្តិខុស ក្នុងមាតាបិតា ទាំងឡាយ ។ មិនមែនពោល ដោយអំណាចនៃការមិនមានមាតាបិតាទេ ។ ទាំងមិនមែនពោល ដោយអំណាចនៃការមិនមាន នៃការប្រតិបត្តិត្រូវ និង ការប្រតិបត្តិខុស ក្នុងមាតាបិតាទាំងឡាយនោះ*

ពណ៌នារំពីការប្រព្រឹត្តិធម៌

ឡើយ ព្រោះការប្រតិបត្តិត្រូវ និង ការប្រតិបត្តិខុស ក្នុងមាតាបិតាទាំងនោះ ជាកិច្ចជាក់ច្បាស់ដល់លោក ។ មិច្ឆាទិដ្ឋិកបុគ្គលពោលថា សត្ត ដែលអណ្តែតឡើងមកកើត មិនមាន ដើម្បីសម្តែង ថាធម្មតាការកើតឡើង នៃសត្ទទាំងឡាយនេះ ប្រៀបដូចជាការកើតឡើងនៃដុំពពុះទឹក, មិនមែនមានការចុតិ ជាខាងដើម តែម៉ាងឡើយ ដូច្នេះ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **ចវិត្វា ឧបបជ្ជនកសត្តា នាម នត្ថីតិ វទតិ** ដូច្នេះ ។ ព្រះអដ្ឋកថា-ចារ្យ ពោលថា **យេ ឥមញ្ច.... ទីបេតិ** ដូច្នេះ ដើម្បីនឹងសម្តែងសេចក្តីបំណង របស់មិច្ឆាទិដ្ឋិកបុគ្គលថា ធម្មតា បុគ្គលអ្នកឈ្មោះថា ជាសមណៈ កាលដឹង តាមសេចក្តីពិតត្រង់ មិនគួរពោល នូវពាក្យអ្វីៗ ដល់អ្នកណាមួយឡើយ គប្បីជាអ្នកសង្រេមួ, ឈ្មោះថាសេចក្តីអួតអាង គប្បីមាន ដោយប្រការដទៃ ។ ក៏បុគ្គលដទៃ នឹងប្រាប់អ្វី ដល់បុគ្គលដទៃន៉ុះ? ។ ការជឿដល់វាទៈ របស់ខ្ជួន យ៉ាងដូច្នោះ រមែងមិនមាន ដល់អ្នកណាមួយឡើយ ព្រោះសេចក្តីខាតសូន្យ ក្នុងទីនោះៗ ឯង យ៉ាងដូច្នេះ" ។

(៨២) ដីកាកោសលសំយុត្ត ថា " ដោយបទថា **មហា-សារា** នេះ ព្រះអដ្ឋកថាចារ្យ សម្តែងថា ព្រះមានព្រះភាគ ទ្រង់អាទេស នូវ **រ** អក្សរ ឲ្យទៅជា **ល** អក្សរ ហើយទ្រង់ត្រាស់ ថា

មហាសាលា *យ៉ាងដូច្នេះ ដូចជាឧទាហរណ៍ ថា* ***បុរត្ថិយោ*** *ជា* ***បុលត្ថិយោ*** *ដូច្នោះ ។ បទថា* ***មហាសារប្បត្តា*** *គឺ ដល់នូវទ្រព្យដែលមានខ្លឹមសារច្រើន បានដល់ មានទ្រព្យប្រមាណ ១០០ កោដិ ។ ម្យ៉ាងទៀត ចាបៈ ក៏យ៉ាងដូច្នេះដែរ ។ អាចារ្យពួកខ្លះ ពោលថា ៦ អម្ពណៈ ឈ្មោះថា ១ តុម្ពៈ (១ ផ្ដីល) " ។*

(៨៣) ព្រះអាចារ្យ ឈ្មោះ មោគ្គល្លានៈ ពោលទុក ក្នុងវេស្សវគ្គ ថា " ១០ អម្ពណៈ ត្រូវជា ១ កុម្ភៈ " ដូច្នេះ ។

នយ នៃដីកាវេស្សវគ្គនោះ ថា " ១ ទូកដៃ ឈ្មោះថា ១ កុឌុវៈ, ៤ កុឌុវៈ ត្រូវជា ១ បត្ថៈ, ៤ បត្ថៈ ត្រូវជា ១ អាឡ្ហកៈ, អាចារ្យពួកខ្លះ ពោលថា តុម្ពៈ ដូច្នេះក៏មាន, ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ, ១១ ទោណៈ ត្រូវជា ១ អម្ពណៈ, អាចារ្យពួកខ្លះ ពោលថា អម្ម្ពណៈ ដូច្នេះខ្លះក៏មាន ។ ១០ អម្ពណៈ ប្រមាណ ១១០ ទោណៈ ឈ្មោះថា ១ កុម្ភៈ ។ ព្រះអដ្ឋកថាចារ្យ សម្ដែងគ្រឿងរង្វាស់ យ៉ាងពិសេស ១ យ៉ាង ឈ្មោះថា បត្ថៈ ដោយឈ្មោះថា ឃដៈ ដោយបទថា ***កុម្ភោ*** *ដូច្នេះ " ។*

(៨៤) ដីកានៃសាលេយ្យកសូត្រ " ទេវតា ណា តែងទៅជាមួយគ្នា គឺ ទៅរួមគ្នា ហេតុនោះ ទេវតានោះ ឈ្មោះថា ជាអ្នកទៅជាមួយគ្នា គឺជាអ្នកប្រព្រឹត្តទៅរួមគ្នា, ភាវៈនៃទេវតាអ្នកទៅជា

ពណ៌នាអំពីការប្រព្រឹត្តិធម៌

មួយគ្នានោះ ឈ្មោះថា **សហព្យតា** បានដល់ សេចក្តីប្រព្រឹត្តិទៅ
រួមជាមួយគ្នា ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលហើយ
ថា **សហភាវំ ឧបគច្ឆេយ្យំ** ដូច្នេះ ។ ពួក គឺ ប្រជុំ នៃព្រហ្មទាំង
ឡាយ ហេតុនោះ ឈ្មោះថា ពួកនៃព្រហ្មទាំងឡាយ, ទេវតាទាំង
ឡាយណា ទៅហើយ ក្នុងពួកនៃព្រហ្មនោះ ហេតុនោះ ទេវតា
ទាំងឡាយនោះ ឈ្មោះថាជាអ្នកទៅហើយ ក្នុងពួកនៃព្រហ្ម ព្រោះ
ទេវតាទាំងឡាយនោះ ជាអ្នករាប់បញ្ចូល ក្នុងពួកនៃព្រហ្មនោះ ។
ក៏ពាក្យថា **ព្រហ្មកាយិកា** នោះ គប្បីជាឈ្មោះ របស់ព្រហ្មទាំង
អស់នោះ ក៏ពិតមែន ។ ទុកជាដូច្នោះ ពាក្យថា **ព្រហ្មកាយិកា** នេះ
ជាឈ្មោះ របស់ទេវតាទាំងឡាយ ដែលសេសសល់ អំពីទេវតា
ជាន់ខ្ពស់ៗ មានទេវតាជាន់ទុតិយជ្ឈាន ជាដើមនោះ បណ្ឌិតគប្បី
ជ្រាប ដោយពលិវទូនយ ដែលព្រះមានព្រះភាគ ទ្រង់ចាត់ទុក
ហើយ ក្នុងជាន់ខ្ពស់ ដោយបទថា **អាភានំ** ដូច្នេះជាដើម ព្រោះ
ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **ព្រហ្មកាយិកានំ
ទេវានន្តិ បឋមជ្ឈានភូមិទេវានំ** ដូច្នេះ ។ ទេវតា ឈ្មោះថា អាភា
ផ្នែកមួយ រមែងមិនមាន ព្រោះទេវតាមានទេវតាឈ្មោះថា បរិត្តាភា
ជាដើមនុ៉ះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ រួមបញ្ចូលជាមួយគ្នា
ដោយភាពស្មើគ្នា នៃភាពជាអ្នកមានរស្មី ។ ពាក្យថា **អាភា** នុ៉ះ

មន្តលត្ថទីបនីប្រែ

ជាឈ្មោះ របស់ទេវតាឈ្មោះ បរិត្តាភា ជាដើម ដូចជាពាក្យថា **ព្រហ្មកាយិកា** ជាឈ្មោះ របស់ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា និង មហាព្រហ្មទាំងឡាយ យ៉ាងដូច្នោះ ។ ព្រះអដ្ឋកថាចារ្យ រួបរួមព្រះបាលីនេះថា **អប្ឋមាណាភានំ ទេវានំ អាភស្សរានំ ទេវានំ** ដូច្នេះ ចូលជាមួយ **អាទិ** សព្ទ ក្នុងពាក្យថា **បរិត្តាភានន្តិ អាទិ បន** ដូច្នេះ ។ ២ បទថា **ឯកតោ អគ្គហេត្វា** គឺ មិនកំណត់យកទេវតា ឈ្មោះ បរិត្តាភា ជាដើម ដោយភាពជាពួកជាមួយគ្នា ថាមានរស្មី ឬថា មានកាយជាសភាពតែមួយ និង មានសញ្ញា ជាធម្មជាតិផ្សេងៗ គ្នា ដូច្នេះ ។ កំណត់យក ដោយភាពផ្សេងៗ គ្នា នៃទេវតាទាំងឡាយនោះតែប៉ុណ្ណោះ គឺ ទេវតាដែលព្រះអដ្ឋកថា-ចារ្យ ពោលហើយថា **អាភា** ដូច្នេះ តែប៉ុណ្ណោះ ។ ២ បទថា **ភេទតោ គហណំ** គឺ កិរិយាផ្សេងពីគ្នា បានដល់ ការប្រែកផ្សេងគ្នា នៃហេតុ គឺ ភាវៈនៃហេតុ ជាបច្ចុយផ្សេងគ្នា, កំណត់យកទេវតា មានទេវតា ឈ្មោះថា បរិត្តាភា ជាដើម ដោយអំណាចភាវៈនៃហេតុ ជាបច្ចុយប្រែកផ្សេងអំពីគ្នានោះ" ។

(៨៥) ដីកាអាកង្ខេយ្យសូត្រ ថា " ២ បទថា **អាសវានំ ខយា** គឺ ព្រោះកិរិយាគាស់រំលើងបានដាច់ខាត នូវអាសវៈទាំងឡាយ ដែលនៅសេសសល់អំពីអាសវៈ ដែលព្រះអរិយៈឲ្យអស់

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ទៅហើយ ដោយមគ្គខាងក្រោម ដោយព្រះអហេត្តមគ្គ ។ ក៏ ព្រោះអរហត្តមគ្គ មិនមែនញ្ចុាំងអាសវ: ឲ្យអស់ទៅ តែម៉ូាង ប៉ុណ្ណោះទេ, តាមពិត រមែងញ្ចុាំងកិលេសទាំងពួងដែលនៅសេស សល់ ឲ្យអស់ទៅផងដែរ, ហេតុដូច្នោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **សព្វក្ពិលេសានំ ខយា** ដូច្នេះ ។ តាមពិត **អាសវ:** សព្ទ ក្នុងពាក្យថា **អាសវានំ ខយា** នេះ គ្រាន់តែជាគ្រឿងចូលទៅ កំណត់ ។ ឈ្មោះថា មិនមានអាសវ: ព្រោះអាសវ:ទាំងឡាយ មិនចូលទៅដល់ សូម្បីភាពជាអារម្មណ៍បាន ។ ក៏ព្រោះសូម្បីការ នៅសេសសល់ នៃអាសវ:ទាំងឡាយ ក្នុងពាក្យថា **អាសវានំ ខយា** នេះ រមែងមិនមាន, ហេតុដូច្នោះ ព្រះអដ្ឋកថាចារ្យ ទើប ពោលថា **អាសវវិរហិតំ** ដូច្នេះ ។ អធិប្បាយថា សមាធិ ព្រះ មានព្រះភាគ ទ្រង់ត្រាស់ ដោយទ្រង់យកចិត្តជាប្រធាន ដូចជា ឧទារហណ៍ថា នរជន ជាអ្នកមានបញ្ញា តាំងនៅ ក្នុងសីល គប្បី ញ្ចុាំងចិត្ត និង បញ្ញា ឲ្យបានចំរើនឡើង យ៉ាងដូច្នោះ ។ ពាក្យថា **រាគតោ វិមុត្តត្តា អវិជ្ជាយ វិមុត្តត្តា** នេះ បណ្ឌិតគប្បី យើញថា ជាពាក្យសម្តែង នូវធម៌ ដែលស្ងប់រម្ងាប់ ចាកធម៌ ដែលជាសឹក សត្រូវ ដោយត្រង់ ព្រោះបាបធម៌ទាំងឡាយ ឯទៀតក្រៅអំពីនោះ ជាធម៌ស្ងប់រម្ងាប់នឹងថ្ពល់ ។ ឥឡូវនេះ ព្រះអដ្ឋកថាចារ្យ ពោល

មន្តលត្ថទីបនីប្រែ

ថា **វុត្តញ្ញេតំ** ដូច្នេះ ជាដើម ដើម្បីនឹងសំដែង នូវភាវៈនៃសមាធិ និង បញ្ញា ជាធម៌ដែលជាសឹកសត្រូវ ចំពោះរាគៈ និង អវិជ្ជា នោះឯង ដោយជាទីមក ។ បទថា **សមថផលំ** មានសេចក្តីថា ចេតោវិមុត្តិ ឈ្មោះថា ជាផល របស់សមថៈ ព្រោះមានផល ដូចគ្នានឹងផល នៃលោកុត្តរសមថៈ ដែលមានកម្ចាំង គឺ សមថភាវនា ដែលជាលោកិយៈ នាំបញ្ជូនឲ្យទៅដល់ វិបស្សនា ។ សូម្បីក្នុងពាក្យថា **វិបស្សនាផលំ** នេះ ក៏នយនេះ ដូចគ្នាដែរ ។ បទថា **អត្តនាយេវ** ជាដើម គឺ ធ្វើនូវចេតោវិមុត្តិ និង បញ្ញាវិមុត្តិ ឲ្យបានជាក់ច្បាស់ ដោយបញ្ញារបស់ខ្លួន ដែលរួចផុតនូវការអាស្រ័យអ្នកដទៃ និងការប្រកាន់យកនូវនយរបស់អ្នកដទៃ ហើយបានសម្រេចភាវនា ដែលមិនបានសិក្សា អំពីពាក្យរបស់បុគ្គលដទៃ ប្រៀបដូចជាធ្វើឲ្យជាក់ច្បាស់ ដោយញាណ មានសុតមយញាណ ជាដើម, អធិប្បាយថា មិនមែន ដោយបញ្ញា ដែលជាញាណ របស់ព្រះសយម្ភូ ទ្បើយ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **អបរប្បច្ចយេន ញត្វា** " ។

(៨៦) ដីកាសាលេយ្យកសូត្រថា " ពាក្យថា **ឥតិ ភគវា អាសវក្ខយំ ទស្សេត្វា** មានសេចក្តីថា ព្រះមានព្រះភាគ កាលនឹងចំណែកនូវធម្មចរិយសមចរិយា ឲ្យជាផ្លូវប្រតិបត្តិ ដែលញ្ចុាំងសត្ត

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ឲ្យទៅដល់សុគតិ ដែលអាស្រ័យវដ្ត: ឲ្យទៅជាផ្លូវប្រតិបត្តិ ញុំងសត្វឲ្យដល់ នូវការអស់ទៅនៃអាសវ: ដែលអាស្រ័យ នូវវិវដ្ត: ឈ្មោះថា ទ្រង់សែម្ពង នូវធម៌ជាទីអស់ទៅនៃអាសវ: ទ្រង់ញុំងធម៌ទេសនា ឲ្យចប់ហើយ ដោយធម៌ដែលជាកំពូល គឺព្រះអរហន្ត យ៉ាងដូច្នេះ ។ ២ បទថា ***ឥធ ឋត្វា*** *គឺ តាំងទុកហើយ ក្នុងនិទ្ទេសនៃកិរិយាប្រព្រឹត្តិស្មើ ពោលគឺ ការប្រព្រឹត្តិ តាមធម៌នេះ ។ ២ បទថា* ***ទេវលោកា សមានេតញ្ច*** *គឺ បណ្ឌិតគប្បីរួបរួមទេវលោកទាំង ២៦ ជាន់មក ។ ២ បទថា* ***វីសតិ ព្រហ្មានោ*** *មានសេចក្តីថា ព្រហ្មលោក ២០ ជាន់ ដោយអំណាចនៃពួកព្រហ្ម ដែលរាប់បញ្ចូល ក្នុងកពនោះ។ ។ បទថា* ***កុសលកម្មបថេហិ*** *មានសេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងការកើតឡើង ក្នុងទេវលោក ព្រោះកុសលកម្មបថទាំងឧ្លាយ ដែលជាកម្មប្ប្ចច័យ និង ឧបនិស្សយប្ប្ចច័យ និង ជាឧបនិស្សយប្ប្ចច័យតែម្យ៉ាង ។ ២ បទថា* ***តិណ្ណ្ហ សុចរិតានំ*** *គឺ នៃសុចរិតដែលជាកាមាវចរ ៣ ប្រការ ។ ក៏សពួ ថា* ***កាមាវចរ*** *ក្នុងបទសមាសនេះ លោកពោលហើយ ដោយការសំឡីងយកនូវម�ុចរិត ។ ដោយបទថា* ***វិបាកេនេវ*** *នេះ ព្រះអដ្ឋកថាចារ្យ សម្ដែងថា ការកើតឡើង រមែងមានបាន ព្រោះការញ្ជាំងវិបាក ឲ្យកើតឡើង តែប៉ុណ្ណោះ, មិនមែនមាន*

មង្គលត្ថទីបនីប្រែ

ព្រោះហេតុត្រឹមតែកាពជាឧបនិស្សយ៉ាយ៉ាយ ដូច្នេះ ។ ព្រះអដ្ឋ-
កថាចារ្យ ពោលពាក្យជាអាទិ៍ ថា **ទស កុសលកម្មបថា** ដូច្នេះ
ដើម្បីនឹងបើកបង្ហាញសេចក្ដី ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា
ឧបនិស្សយវសេន តែម្យ៉ាង ។ បណ្ឌិត គប្បីនាំបទថា **សីលេ
បតិដ្ឋាយ** ដូច្នេះ មកសម្ពន្ធ សូម្បីក្នុងបទទាំងឡាយថា **ទុតិយាទីនិ
ការេត្វា** ដូច្នេះជាដើម ។ មានបុច្ឆាថា ក៏ព្រោះហេតុអ្វី? ព្រះអដ្ឋ-
កថាចារ្យ ទើបពោលថា **ឧបនិស្សយវសេន** ដូច្នេះ ក្នុងដំណើរ
នេះ, ក្នុងបដិសម្ភិទាមគ្គ ព្រះសារីបុត្តត្ថេរ បានលើកយកសីល
មក ព្រោះឈានទាំងឡាយ សូម្បីព្រះយោគីបានហើយ ដោយ
ន័យថា ការលះនូវនីវណៈទាំងឡាយ ដោយបឋមឈាន ឈ្មោះ
ថា សីល, ការវៀរចាក ឈ្មោះថា សីល, ចេតនា ឈ្មោះថា
សីល, ការសង្រួម ឈ្មោះថា សីល, ការមិនប្រព្រឹត្តិកន្ទ្ធ ឈ្មោះ
ថា សីល ដូច្នេះជាដើម មិនមែនទេឬ? ហេតុនោះ កិរិយាកើត
ឡើង សូម្បីនៃពួកទេវលោក ជាន់ខ្ពស់ៗ ព្រោះវិបាក ដោយ
អំណាចនៃសីលនោះ ទើបសមគួរ ដូច្នេះ ។ មានវិសជ្ជនា ថា
ព្រះអដ្ឋកថាចារ្យ ពោលថា **ឧបនិស្សយវសេន** ដូច្នេះ ក្នុងអធិការ
នេះ ព្រោះសីលនោះ ជាបរិយាយទេសនា ។ ក៏ព្រះអដ្ឋកថាចារ្យ
ទាំងឡាយ ប្រកាសភាពនៃសីលនោះ ជាបរិយាយទេសនា ក្នុង

ពណ៌នាអំពីការប្រព្រឹត្តិធម៌

វិសុទ្ធិមគ្គ និង អដ្ឋកថានៃវិសុទ្ធិមគ្គនោះ ដោយពាក្យថា **ឯត្ថ ច ឋហានំ** *ដូច្នេះជាដើម មែនពិត ។ ពិតមែនយ៉ាងដូច្នោះ សូម្បីក្នុងអធិការនេះ ព្រះអដ្ឋកថាចារ្យ ពោលការកើតឡើង ដែលប្រកាសភាពនៃសីលនោះ ជាឧបនិស្សយ នៃរូបកព និង អរូបកព ទាំងឡាយ ដោយពាក្យថា* **កុសលកម្មបថា ហិ សីលំ** *ដូច្នេះជាដើម ។ ព្រះអដ្ឋកថាចារ្យពោលថា* **អសញ្ញិកវោ បន ន ទិទ្ធិជ្ជោ** *ដូច្នេះ ក៏ដើម្បីនឹងឆ្លើយបញ្ហា ដែលគប្បីមានថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ កាលទ្រង់ចំណែក នូវសេចក្តីប្លែកផ្សេងគ្នានៃកព ដោយការប្រព្រឹត្តិធម៌ ដែលមានភាវនា ជាលក្ខណៈ ទើបមិនទ្រង់យកអសញ្ញិកព មកបញ្ចូលរួម ក្នុងសាលេយ្យកសូត្រផងដែរ?” ។*

(៨៧) ធម្មចរិយា មកហើយ ក្នុងសាលេយ្យកសូត្រ និងវេរញ្ជកសូត្រ ដែលជាលំដាប់ នៃសាលេយ្យកសូត្រ នោះឯង ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងថា “ ឧបនិស្សយ គឺសីល រមែងញុំងសត្វឲ្យសម្រេចសូម្បីនូវព្រះអរហត្តបាន” យ៉ាងដូច្នេះឯង ។

(ឧបនិស្សយ ៣ យ៉ាង)

ចំណែក ក្នុងអដ្ឋកថាបឋមបណ្ណាសកៈ ក្នុងខន្ធកវគ្គ ព្រះអដ្ឋកថាចារ្យ ពោលថា ឧបនិស្សយទាំងនេះ មាន ៣ យ៉ាង គឺ ទានូបនិស្សយ សីលូបនិស្សយ ភាវនូបនិស្សយ ។ បណ្តា

មន្ទលត្ថទីបនីប្រែ

ឧបនិស្សយ ទាំង ៣ យ៉ាងនោះ ទានូបនិស្សយ និង សីលូប-និស្សយ មានកម្លាំងខ្សោយ, ភាវនូបនិស្សយ មានកម្លាំង (ខ្លាំង) ។ ព្រោះថា ទានូបនិស្សយ និង សីលូបនិស្សយ រមែងញ្ចាំងសត្វឲ្យសម្រេច (តែ) មគ្គ ៣ និង ផល ៣ (ប៉ុណ្ណោះ), (ចំណែក) ភាវនូបស្សយ រមែងញ្ចាំងសត្វ ឲ្យបានសម្រេចនូវព្រះអរហត្ត ។ ភិក្ខុ អ្នកស្ថិតនៅ ក្នុងឧបនិស្សយ ដែលមានកម្លាំងខ្សោយ កាលព្យាយាមប្រឹងប្រែង រមែងកាត់ផ្តាច់នូវគ្រឿងចង ដែលជាចំណែកខាងទាប ៥ ប្រការ ចោលហើយ ញ្ចាំងមគ្គ និង ផលទាំងឡាយ ៣ ឲ្យកើតឡើងបាន ដោយប្រការដូច្នេះ ហើយពោលរឿងព្រះមិលក្ខត្ថេរ ។

(**រឿង ព្រះមិលក្ខត្ថេរ**)

(៨៨) បានព្ថមកថា ព្រះមិលក្ខត្ថេរនោះ ក្នុងពេលនៅជាគ្រហស្ថ ចិញ្ចឹមជីវិត ដោយការធ្វើបាណាតិបាត ដាក់ចម្រូងអន្ទាក់ និង អង្គប់ មួយមុខ ១០០ ក្នុងព្រៃ សន្សំនូវបាបដ៏ច្រើន ។

ក្រោយមក ថ្ងៃមួយ នាយមិលក្ខៈនោះ បរិភោគនូវសាច់ ដែលអាំងឆ្អិនហើយ ព្ធដ៏រងើកភ្លើង ត្រាច់ទៅ ក្នុងទីដាក់អន្ទាក់ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ទើបបើកក្អមទឹក ដែលតាំងនៅ ក្នុងទីមិនឆ្ងាយ នៃព្រះថេរៈ អ្នកនៅក្នុងព្រៃមួយរូប កំពុង

ពណ៌នាអំពីការប្រព្រឹត្តិធម៌

តែដើរចង្ក្រម កាលមិនឃើញទឹកសូម្បីត្រឹមតែទទឹកដៃ ក៏ក្រោធ ខឹង ហើយពោលថា " ម្នាលកិក្ខុ អ្នកបរិភោគកិក្ខា ដែលគ្រហស្ថ ទាំងឡាយ ប្រគេនហើយ ក៏សិងលក់, អ្នក មិនដងទឹក ជាក់ក្នុង ពាងទឹក គ្រាន់ធ្វើជាថ្នាំក្អែកខ្ទុះ, ការធ្វើយ៉ាងនេះ មិនសមគួរទេ " ។ ព្រះថេរៈ គិត ថា " អាត្មាអញ បានដងទឹក ជាក់ពាង ពេញអស់ ហើយ, ហេតុអ្វីទៅហ្ន៎ ទើបនាយមិលក្ខៈ នេះ ពោលដូច្នេះ? " ដូច្នេះហើយ ក៏ទិមន្តទៅមើល បានឃើញពាងទឹក ពេញព្រៀប ហើយ ក៏យកស័ង្ខសម្រាប់ដងទឹក ដងចាក់ឲ្យពេញហើយ ទើប ឲ្យ ។ នាយមិលក្ខៈនោះ ផឹកទឹកគ្រប់ ៣២ ស័ង្ខ ហើយ មានចិត្ត សង្វេគថា " ធម្មតាពាងទឹកដែលមានទឹកពេញហើយ យ៉ាងដូច្នេះ អាស្រ័យកម្ម របស់អាត្មាអញ ទើបបានកើតឡើង ប្រៀបដូចជា អំបែងក្បឿងដ៏ក្តៅ, អត្តភាព របស់អញ ក្នុងអនាគតកាល នឹង កើតទៅជាយ៉ាងដូចម្តេចហ្ន៎? " ដូច្នេះហើយ ក៏ពោលថា " បពិត្រ លោកម្ចាស់ សូមលោកម្ចាស់ មេត្តាញ៉ាំងខ្ញុំព្រះករុណា ឲ្យបាន បួសផង " ។ ព្រះថេរៈ ប្រាប់កម្មដ្ឋាន មានស្បែកជាគម្រប់ ៥ ហើយ បានញ៉ាំងនាយមិលក្ខៈនោះឲ្យបួសហើយ ។ ស្ថានទីដែល នាយមិលក្ខនោះ សម្ងាប់សត្វម្រ៉ីគ និង ជ្រូកជាច្រើន និង ស្ថានទី ដែលនាយមិលក្ខនោះ ជាក់អន្ទាក់ និង អង្គប់ ទាំងឡាយ រមែង

មន្ទលត្ថទីបនីប្រែ

ប្រាកដ ដល់ភិក្ខុមិលក្ខៈនោះ ដែលកំពុងតែធ្វើសមណធម៌, កាល
បើភិក្ខុមិលក្ខៈនោះ តាមរលឹកនូវកម្ម ដែលបានធ្វើហើយនោះ,
សេចក្តីក្តៅក្រហាយ ក៏កើតឡើងក្នុងសរីររាងកាយ ។ ចិត្ត រមែង
មិនដើរទៅកាន់វិថីនៃកម្មដ្ឋាន ដូចជាគោកោង មិនព្រមដើរទៅកាន់
នង្គ័ល ដូច្នោះ ។ ភិក្ខុមិលក្ខៈនោះ ត្រូវសេចក្តីមិនត្រេកអរ គ្រប
សង្កត់ហើយ ដោយគិតថា " អាត្មាអញ នឹងធ្វើអ្វី ដោយភាពជា
ភិក្ខុ? " ដូច្នេះហើយ ទៅកាន់សំណាក់ព្រះថេរៈ ថ្វាយបង្គំហើយ
ពោលថា " បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណា មិនអាចធ្វើសមណ-
ធម៌ បានឡើយ " ។ ព្រះថេរៈ ពោលថា " ចូរអ្នកធ្វើនូវហត្ថកម្ម
ចុះ " ។ ភិក្ខុនោះ បានទៅកាត់ដើមឈើស្រស់ មានដើមឧទុម្ពរ
ជាដើម មកធ្វើជាគំនរ យ៉ាងធំ ហើយសួរថា " ឥឡូវនេះ ខ្ញុំព្រះ
ករុណា នឹងធ្វើអ្វី? " ។ ព្រះថេរៈ បានប្រាប់ថា " ចូរអ្នកដុតគំនរ
ឈើនោះចោល " ។ ភិក្ខុនោះ ដុតភ្លើង ក្នុងទិសទាំង ៤ ហើយ
ក៏មិនអាច ដើម្បីដុតឲ្យធេះបានឡើយ ។ ព្រះថេរៈ ពោលថា "បើ
ដូច្នោះ ចូរអ្នកគេចចេញទៅ " ហើយធ្វើប្រឹថពី ឲ្យបែកចេញ ជា
ពីរផ្នែកហើយ នាំយកភ្លើង មានពន្លឺ ប្រមណស្មើនឹងពន្លឺអំពិល
អំពែក អំពីអវិចីនរក មកដាក់លើគំនរឈើនោះឯង ។ ព្រះថេរៈ
នោះ ដុតគំនរឈើ ដែលមានទំហំប្រមាណប៉ុណ្ណោះ ឲ្យធេះ មួយ

ពណ៌នាអំពីការប្រព្រឹត្តិធម៌

រំពេច ដូចជាដុតស្ទឹកឈើស្ងួតដូច្នោះ ។ គ្រានោះ ព្រះថេរ: លុះសម្តែងអវិចីនរកហើយ ទើបញ្ជាំងសេចក្តីសង្វេគ ឲ្យកើតឡើងដល់ភិក្ខុមិលក្ខ:នោះ ថា " បើអ្នកនឹងសឹក, អ្នកនឹងឆេះ នៅក្នុងអវិចីនរកន៉ុះ " ។ ភិក្ខុមិលក្ខ:នោះ ចាប់ដើមតាំងអំពីបានឃើញអវិចីនរកមក ក៏ភ័យស្ទុតស្ទន់ ទើបសួរថា " បពិត្រលោកម្ចាស់ ដ៏ចម្រើន តើព្រះពុទ្ធសាសនា ជាហេតុនាំសត្វឲ្យចេញ ចាកទុក្ខឬ? " ដូច្នេះ ។ ព្រះថេរ: ប្រាប់ថា " ម្នាលអ្នកដ៏មានអាយុ មែនហើយ " ។ ភិក្ខុនោះ ពោលថា " បពិត្រលោកម្ចាស់ ដ៏ចម្រើន កាលបើព្រះពុទ្ធសាសនា ជានិយ្យានិក:, មិលក្ខ: នឹងធ្វើនូវការរើខ្ជូន ឲ្យទាល់តែរួច, ចូរលោកម្ចាស់ កុំកង្វល់ឡើយ " ដូច្នេះ តាំងអំពីពេលនោះមក លោកធ្វើនូវសមណធម៌ ប្រឹងប្រែង ព្យាយាមបំពេញវត្តប្រតិបត្តិ, កាលបើសេចក្តីងោកងុយគ្របសង្កត់, ក៏បានដាក់ចំបើងទទឹក លើក្បាលហើយ គង់ទម្លាក់ជើងទាំង ២ ចូលទៅក្នុងស្រះទឹក ។ ថ្ងៃមួយ ភិក្ខុនោះ ត្រងទឹកហើយ ដាក់ក្អមទឹកនៅលើភ្លៅ បានឈរ រង់ចាំការស្រក់ដាច់អស់ទៅ នៃទឹកពាង ។ លំដាប់នោះឯង ព្រះថេរ: ឲ្យនូវនិទ្ទេសនេះ ដល់សាមណេរ ថា៖

យស រមែងបម្រើនកុះការ ដល់បុគ្គលអ្នកមានសេចក្តីប្រឹង
ប្រែង មានស្មារតី មានការងារស្អាត ជាអ្នកពិចារណា រួប

មង្គលត្ថទីបនីប្រែ

ហើយទើបធ្វើ ជាអ្នកសង្ស្ងួម រស់នៅដោយធម៌ មិនមានសេចក្ដីប្រមាទ ។

ភិក្ខុមិលក្ខ:នោះ បានបង្ហោនទូវគាថា ទាំង ៤ បាទនោះ មកទុក ក្នុងខ្ជនទ្ទ:ឯងថា "ធម្មតាបុគ្គលអ្នកមានសេចក្ដីប្រើងប្រែង គប្បីដូចជាអាត្មាអញ, សូម្បីបុគ្គលអ្នកមានសតិស្មារតី ក៏គប្បីជាអ្នកដូចជាអាត្មាអញដែរ ។លម។ សូម្បីបុគ្គលអ្នកមិនប្រមាទ ក៏ជាអ្នកគប្បីដូចជាអាត្មាអញផងដែរ " ។ ភិក្ខុមិលក្ខ:នោះ លុះបង្ហោនគាថានោះ មកទុកក្នុងខ្ជន យ៉ាងដូច្នេះហើយ ឈរនៅ ក្នុងជំហានជើងនោះឯង កាត់ផ្តាច់នូវសំយោជន: ដែលជាចំណែកខាងក្រោម ៥ យ៉ាង ហើយ ញ្ចុំងមគ្ត និង ផលទាំងឡាយ ៣ ឲ្យកើតឡើងហើយ ។ រឿង ព្រះមិលក្ខត្ថេរ ក្នុងអដ្ឋកថាទុតិយវគ្ គ ឯកនិបាត អង្គុត្តរនិកាយ ។

(៨៩) ជីកានៃបឋមបណ្ណាសក: ក្នុងខ្ជនកវគ្គនោះ ថា " ឧបនិស្សយ គឺទាន ឈ្មោះថា ទានូបនិស្សយ, ន័យ សូម្បីក្នុងឧបនិស្សយ ដ៏វិសេសសស់ ក៏ន័យនេះ ដូចគ្នាដែរ ។ បណ្ណាឧបនិស្សយ ទាំង ៣ យ៉ាងនោះ ទានូបនិស្សយ រមែងមាន ព្រោះការគ្រេបសង្កត់ នូវសេចក្ដីលោភ ដ៏មានកម្ចាំង ក្នុងវត្ថុទាំងឡាយ មានបាយ ជាដើម, ព្រោះហេតុដូច្នោះ បុគ្គល អ្នកច្រើន ដោយ

ពណ៌នាអំពីការប្រព្រឹត្តិធម៌

ទានូបនិស្សយ កាលប្រកបវិបស្សនារឿយៗ រមែងសម្រេច នូវ
ព្រះអនាគាមិផលបាន ក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកមាន
សេចក្តីត្រៀម បានធ្វើទុកហើយ ក្នុងការលះបង់ នូវកាមរាគៈ ។
បុគ្គលអ្នកមានសីលូបនិស្សយ ដ៏បរិសុទ្ធ ក៏យ៉ាងដូច្នោះដែរ គឺ
កាលប្រកបនូវវិបស្សនារឿយៗ រមែងសម្រេច នូវព្រះអនាគាមិ-
ផលបាន ក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកមានសេចក្តីត្រៀម
បានធ្វើទុកហើយ ក្នុងការស្អប់ខ្ពើម អំពីទោស គឺ កាមគុណ ។
មានពាក្យចោទសួរថា ប្រសិនជា កាលបើទានូបនិស្សយ និង
សីលូបនិស្សយ ជាហេតុឲ្យបុគ្គលបានសម្រេចអនាគាមិផល ក្នុង
កាលមិនយូរ យ៉ាងដូច្នេះហើយ, ព្រោះហេតុអ្វី ឧបនិស្សយទាំង
២ យ៉ាងនេះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា មានកម្លាំង
ខ្សោយ ដូច្នេះ ។ គប្បីឆ្លើយថា ព្រោះឧបនិស្សយទាំង ២ យ៉ាង
នោះជាបច្ចយនៃវិជ្ជូរបមញ្ញាណតែម្យ៉ាង ។ មែនពិត ទានូបនិស្សយ
និង សីលូបនិស្សយ ទាំង ២ នោះ នឹងទៅជាឧបនិស្សយ ដែល
មានកម្លាំងបាន ក៏ព្រោះបាននូវភាវនូបនិស្សយ ជាសំឡាញ់នុ៎ះឯង,
ភាវនូបនិស្សយ មិនមែនជាសំឡាញ់ របស់ឧបនិស្សយទាំង ២
យ៉ាងនោះតែម្យ៉ាងឡើយ, ក៏ភាវនា ឈ្មោះថាជាឧបនិស្សយដែល
មានកម្លាំង ព្រោះជាហេតុ យ៉ាងពិសេស នៃការត្រាស់ដឹង ។

មន្ទលត្ថទីបនីប្រែ

*ពិតមែន យ៉ាងដូច្នោះ ភាវនានោះ ជាបច្ចយយ៉ាងពិសេស របស់ វិជ្ជូរបមញ្ញាណ រមែងញ្ចាំងសត្ត ឲ្យសម្រេចព្រះអរហត្តបាន ។ បទថា **សោ** នោះ សំដៅយកព្រះមិលក្ខត្ថេរ ។ ស្ថានទីសម្ងាប់ សត្ត និង ជ្រូកជាច្រើន និង ស្ថានទីដែលជាក់អន្ទាក់ និង អង្គប់ ទាំងឡាយ រមែងប្រាកដ ដោយខណៈចិត្ត តែមួយ, ចិត្ត របស់ ព្រះមិលក្ខត្ថេរ មិនចូលទៅកាន់វិថីនៃកម្មដ្ឋាន ដូចជាគោកោង មិន ព្រមដើរទៅ តាមគន្ធងនង្គ័លដូច្នោះ ។ បទថា **តត្ត** គឺ ក្នុងគំនរ ឈើស្រស់ ។ បទថា **ឧទកមណិកានំ** គឺ នៃខ្សែទឹកទាំងឡាយ ។ ព្រះមិលក្ខត្ថេរ ឈ្មោះថា បានបង្អោនគាថានោះ មកទុក ក្នុងខ្ជូន នុ៉ះឯង ព្រោះភាវៈនៃធម៌ទាំងឡាយ ដែលព្រះថេរៈសម្តែងហើយ ដោយគាថា ព្ធដ៏ខាងដើម ជាធម៌ដ៏បរិបូណិ មាននៅក្នុងខ្ជូន តាំង ពីពេលបួសមកហើយ ។ ហេតុនោះ ព្រះមិលក្ខត្ថេរ ទើបពោល ពាក្យថា **ឧដ្ឋានវតា នាម** ដូច្នេះជាដើម ។ ក៏ព្រះមិលក្ខត្ថេរនេះ ជាអ្នកមានការគោរព មានការជឿស្តាប់ ចំពោះការសិក្សា ជាអ្នក បំពេញវត្ត និង វត្តតប ជាអ្នកមានសីលដ៏បរិសុទ្ធស្ថិតនៅ, ព្រោះ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **ទុព្ធលូបនិស្សយេ ឋិតោ** ដូច្នេះ" ។*

ពណ៌នាអំពីការប្រព្រឹត្តិធម៌ ចប់ ។

ពណ៌នាអំពីការសម្រ្ទាះញ្ញាតិ

(៩០) ព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងមង្គលត្ថទីបនីនេះ ថា " ជនទាំងឡាយ ដែលជាប់ទាក់ទងគ្នា ខាងបិតាក្តី ខាងមាតាក្តី រហូតដល់យុគ នៃបិតាមហ: ទី ៧ ឈ្មោះថា **ញ្ញាតិ** " ។

អដ្ឋកថានៃចង្កីសូត្រ អដ្ឋកថានៃបឋមវគ្គ នៃទុតិយបណ្ណាសក: ក្នុងតិកនិបាត អង្គុត្តរនិកាយ និង អដ្ឋកថានៃចតុត្ថវគ្គ នៃតតិយបណ្ណាសក: ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយថា " បណ្តាពាក្យទាំងនោះ ក្នុងពាក្យថា **យាវ សត្តមា បិតាមហយុគា** នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖ បិតារបស់បិតា (ជីតា) ឈ្មោះ ថា បិតាមហ:, យុគ នៃបិតាមហ: ឈ្មោះថា បិតាមហយុគ ។ ប្រមាណនៃអាយុ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា **យុគ** ។ ក៏ ពាក្យថា **យុគ** នោះ គ្រាន់តែជាពាក្យពោលចំពោះប៉ុណ្ណោះ, ប៉ុន្តែ ដោយសេចក្តី បិតាមហ: ប៉ុណ្ណោះ ឈ្មោះថា បិតាមហយុគ ។ បុព្វបុរសទាំងឡាយទាំងពួង បន្ទាប់អំពីបិតាមហ:នោះ ឡើងទៅ ព្រះមានព្រះភាគទ្រង់កំណត់យក ដោយបិតាមហ:សព្ទន៉ុះឯង " ។

ជីកានៃចង្កីសូត្រថា " បិតា និង មាតា ឈ្មោះថា បិតរោ (បិតា និង មាតាទាំងឡាយ), បិតា និង មាតា របស់បិតា និង មាតា ទាំងឡាយ ឈ្មោះថា បិតាមហ:, យុគ នៃបិតាមហ:ទាំងឡាយ នោះ ឈ្មោះថា បិតាមហយុគ ។ ព្រោះហេតុនោះ បណ្ឌិតគប្បី

មន្តលត្ថទីបនីប្រែ

យើញសេចក្តី ក្នុងពាក្យនេះ យ៉ាងនេះថា រហូតដល់បិតាមហយុគ ទី៧ ។ ក៏ **យុគ** សព្ទ ក្នុងបទថា **បិតាមហយុគា** នុ៉ះ បណ្ឌិតគប្បីយើញ ដោយឯកទេសន័យ ថា យុគ និង យុគ ឈ្មោះថា យុគា ដូច្នេះ ។ ក៏ដោយអធិប្បាយ យ៉ាងនេះ ទើបបានជាលោក កំណត់យកហើយជាបន្ទាប់ទ្បើងទៅ ក្នុងយុគនោះៗ ដោយពិត ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **តតោ ឧទ្ធំ សព្វេបិ បុព្វបុរិសា បិតាមហគ្គហណេនេវ គហិតា** ដូច្នេះ ។ មួយទៀត **បុរិស** សព្ទ ក្នុងបទថា **បុព្វបុរិសា** នុ៉ះ បណ្ឌិតគប្បីយើញថា លោកធ្វើហើយ ដោយអំណាចនៃការសម្តែងបុព្វបុរសថ្នាក់ខ្ពស់បំផុត ។ ពាក្យបាលីថា **មាតិតោ** ក៏រមែងសម្រេចសេចក្តីយ៉ាងដូច្នេះឯង " ។

(៩១) ដីកានៃតិកនិបាត អង្គុត្តរនិកាយថា " បិតា និង ... យុគ នៃបិតាមហ: ទាំងឡាយនោះ ឈ្មោះថា បិតាមហយុគ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីយើញសេចក្តី ក្នុងពាក្យនុ៉ះ យ៉ាងដូច្នេះថា រហូតដល់យុគនៃបិតាមហ: គឺ គូនៃបិតាមហ: ទី៧ ។ ប៉ុន្តែព្រះអដ្ឋកថាចារ្យ មិនបានកំណត់យកគូ ទើបពោលទុក ក្នុងអដ្ឋកថាថា **យុគន្តិ អាយុប្បមាណំ វុច្ចតិ** ដូច្នេះ ។ លោកបានសម្តែងភាវ:នៃយុគសព្ទ ជាសព្ទមិនមានប្រយោជន៍ថា បិតាមហ:

ពណ៌នារំពីការសម្ថោះញាតិ

ប៉ុណ្ណោះ ឈ្មោះថា បិតាមហយុគ ។ មួយទៀត **បុរិស** សព្ទ ក្នុងបទថា **បុព្វបុរិសា** ន៉ុះ រមែងសម្រេចសេចក្តីយ៉ាងនេះ " ។

ជីកាបញ្ចកនបិតា អង្គុត្តរនិកាយថា " បិតា និង ... យុគ នៃបិតាមហ:ទាំងនោះ ឈ្មោះថា បិតាមហយុគ ។ ព្រោះហេតុនោះ បណ្ឌិត គប្បីយើញសេចក្តី ក្នុងពាក្យនោះ យ៉ាងដូច្នេះ ថា បិតា និង... រហូតដល់យុគ នៃបិតាមហ: គឺ គូនៃបិតាមហ: ទី៧ ដូច្នេះ ។ ដោយអធិប្បាយ យ៉ាងដូច្នេះឯង សូម្បីមាតាមហ: លោកប្រកាន់យកហើយ ដោយ **បិតាមហ** សព្ទ ដូចគ្នាដែរ ។

ក្នុងអដ្ឋកថា មាតាមហសព្ទនោះ លោកមិនបានលើកយកមកសម្តែងហើយមួយផ្នែក ។ ក៏ **យុគ** សព្ទ ក្នុងបទថា **បិតាមហ-យុគា** នោះ បណ្ឌិតគប្បីយើញ ដោយឯកទេសន័យថា គូ និង គូ ឈ្មោះថា **យុគា** ដូច្នេះ ។ ដោយអធិប្បាយ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់ប្រកាន់យក ដោយ **បិតាមហ** សព្ទន៉ុះឯង ។ មួយទៀត **បុរិស** សព្ទ ក្នុងបទថា **បុព្វបុរិសា** ន៉ុះ ... រមែងសម្រេចសេចក្តី យ៉ាងដូច្នេះឯង " ។

(៩២) ជនទាំងឡាយ អ្នកជាប់ទាក់ទងគ្នា ទាំងអស់នោះ ឈ្មោះថា ជាញាតិ ព្រោះអត្ថថា គប្បីស្គាល់គ្នា ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា " ជនទាំងឡាយនេះ គេ

មង្គលត្ថទីបនីប្រែ

រមែងដឹង ថា (ជាញាតិ) របស់ពួកយើង ដូច្នេះ ព្រោះហេតុនោះ ជនទាំងឡាយនេះ ឈ្មោះថា ជាញាតិ " ។

ដីកានៃតតិយវគ្គ នៃទុតិយបណ្ណាសក: ក្នុងតិកនិបាត អង្គុត្តរនិកាយ ថា "ជនទាំងឡាយណា រមែងដឹង និង គេក៏ស្គាល់ បាន យ៉ាងនេះថា ជនទាំងឡាយនេះ ជាអ្នកនៅខាងក្នុង ដូច្នេះ ហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា ញាតិ " ។

អដ្ឋកថាបណ្ណរជាតក ថា " បទថា **សបក្ខា** គឺ ពួកញាតិ ទាំងឡាយ ដែលជាពួកស្មើគ្នា មានបេយ្យក: (តាទួត ឬ ជីតា) ឪពុកមា និង ឪពុកធំខាងម្តាយ បងប្អូនស្រីរបស់ឪពុក ម្តាយមីង និង ម្តាយធំ ខាងម្តាយជាដើម " ។

ដីកានៃនវវគ្គ ថា " តាទួត ឬ ជីតា របស់បិតា និង មាតា ទាំងឡាយ ឈ្មោះថា បេយ្យក:, បងប្អូនប្រុស របស់មាតា ឈ្មោះ ថា បិតុច្ឆា, បងប្អូនស្រី របស់មាតា ឈ្មោះថា មាតុច្ឆា " ។

(៩៣) ការជួយឧបត្ថម្ភ នូវពួកញាតិទាំងនោះ ដែលត្រូវ សេចក្តីសាបសូន្យ នៃភោគសម្បត្តិ ឬ សេចក្តីសាបសូន្យ ព្រោះ ព្យាធិ គ្រុបសង្កត់ហើយ ជាអ្នកមកហើយកាន់សំណាក់ របស់ខ្លួន ដោយគ្រឿងបរិភោគ គ្រឿងស្លៀកពាក់ ទ្រព្យ និង ធញ្ញាហារ ជា ដើម តាមកម្លាំង ឈ្មោះថា ការសង្គ្រោះ ។ ការសង្គ្រោះញាតិ

ពណ៌នាអំពីការសង្គ្រោះញាតិ

*នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "**ជាមង្គល**" ព្រោះជាហេតុ ជានសម្រេច នូវគុណវិសេសទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុ័យ មានការសរសើរជាដើម និង ដែលប្រព្រឹត្តទៅ ក្នុងសម្បរាយភព មានការទៅកាន់សុគតិជាដើម ។ ព្រោះហេតុនោះ ការសង្គ្រោះញាតិនោះ បុគ្គលគប្បីធ្វើ ដោយពិត ។ មួយទៀត បុគ្គលអ្នកធ្វើការសង្គ្រោះញាតិនោះ ឈ្មោះថា រមែងធ្វើ តាមព្រះពោធិសត្ត ។ មែនពិត ព្រះពោធិសត្តទាំងឡាយ កាលប្រព្រឹត្ត នូវការប្រព្រឹត្តិជាប្រយោជន៍ ដល់ញាតិ ក៏ជានធ្វើហើយ នូវការសង្គ្រោះញាតិនុ៎ះឯង ។*

ក្នុងដំណើរនោះ មានរឿងទាំងឡាយនេះ (ជាឧទាហរណ៍) ៖

(រឿង សត្វសុនខ)

(៩៤) ក្នុងអតីតកាល ព្រះពោធិសត្ត សោយព្រះជាតិជាសត្វសុនខ មានសត្វសុនខជាច្រើនចោមរោម នៅហើយ ក្នុងព្រៃស្មសានដ៏ធំ ។ ក្រោយមកថ្ងៃមួយ ព្រះរាជាក្រុងពារាណសី ទ្រង់ព្រះក្រសាល ក្នុងព្រះឧទ្យាន រហូតមួយថ្ងៃ, កាលបើព្រះអាទិត្យអស្តង្គតហើយ, ទើបស្តេចយាងទៅកាន់ព្រះនគរ ដោយរាជរថដ៏ប្រសើរ ។ ពួកមនុស្ស ជានបញ្ឈប់រាជរថនោះ ត្រង់ទីព្រះលានៃព្រះរាជា ។ កាលបើភ្ជៀងធ្លាក់ រហូតរាត្រី, សត្វសុនខ ដែល

មន្តលត្ថនីបនីប្រែ

គេចិញ្ចឹម ក្នុងព្រះរាជត្រកូលទាំឡាយ ក៏នាំគ្នាចុះ អំពីប្រាសាទ នៃព្រះរាជា មកកកេរស៊ី នូវស្បែកសម្រាប់រុំព័ទ្ធ និង ស្បែកសម្រាប់ចងរាជរថ ។ ក្នុងថ្ងៃស្អែកឡើង ពួកមនុស្ស បានក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព សុនខទាំងឡាយចូលមក តាមផ្លូវបង្ហូរទឹកហើយ បានកកេរស៊ី នូវស្បែកសម្រាប់រុំព័ទ្ធ និង ស្បែកសម្រាប់ចងរាជរថអស់ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យ របស់មនុស្សទាំងនោះហើយ ស្តេចទ្រង់ព្រះពិរោធ ចំពោះសត្វសុនខទាំងឡាយ ទើបទ្រង់ត្រាស់ថា "ពួកអ្នកទាំងឡាយ ចូរសម្លាប់សត្វសុនខទាំងឡាយចោល ក្នុងទីកន្លែង ដែលពួកអ្នកឃើញហើយៗ " ។ តាំងពីពេលនោះមក សត្វសុនខទាំងឡាយមានភ័យកើតឡើងហើយ ត្រូវមនុស្សសម្លាប់ ក្នុងទីកន្លែងដែលគេឃើញហើយៗ ក៏បានគេចរត់ទៅកាន់សំណាក់ព្រះពោធិសត្ត ។ ព្រះពោធិសត្ត ដឹងហេតុនោះហើយ ក៏គិតថា " ឧកាស រមែងមិនមាន ដល់សុនខដែលនៅខាងក្រៅទាំងឡាយ ក្នុងទីកន្លែងដែលគេថែរក្សា, កម្មនោះ នឹងពិតជាកម្ម របស់សត្វសុនខ ដែលគេចិញ្ចឹម ក្នុងរាជត្រកូលទាំងឡាយ ព្ធដ៏ខាងក្នុងព្រះរាជវាំងនុ៉ះឯង " ដូច្នេះហើយ ក៏ប្រាថ្នានឹងធ្វើនូវការសង្គ្រោះ ដល់ញាតិ ទើបនឹករព្រក ដល់បារមីទាំងឡាយ ធ្វើនូវមេត្តាភាវនា ឲ្យប្រព្រឹត្តទៅ ខាង

ពណ៌នាអំពីការសង្គ្រោះញាតិ

មុខហើយ អធិដ្ឋានថា "សូមកុំឲ្យអ្នកណាមួយ ហ៊ានបោះជុំដី ឬក៏អន្ទង ពួកខ្ញុំ(ខ្លួន)ខ្ញុំទ្បើយ " យ៉ាងដូច្នេះហើយ ក៏ដើរចូលទៅកាន់ព្រះនគរតែម្នាក់ឯងប៉ុណ្ណោះ ។ គ្រានោះ បុគ្គលអ្នកដែលបានឃើញព្រះពោធិសត្វនោះហើយ ឈ្មោះថា ក្រេកមើល ព្រោះក្រោធខឹង សូម្បីតែម្នាក់ ក៏មិនមានទ្បើយ ។ ព្រះពោធិសត្ត្ব ស ុះចូលទៅ ពួកខ្ញុំងក្រោមព្រះរាជអាសនៈ នៃព្រះរាជាទ្រង់ស្តេចគង់នៅហើយ ក្នុងសាលាវិនិច្ឆ័យ ។ លំដាប់នោះ រាជបុរសទាំងឡាយ ប្រារព្ធដើម្បីនឹងបណ្តេញព្រះពោធិសត្ត្ব នោះចេញ ។ ព្រះរាជា ទ្រង់ហាមរាជបុរសទាំងនោះ ។ ព្រះពោធិសត្ត្ব សម្រាកបន្ទិចហើយ ក៏ចេញពីក្រោមព្រះទីនាំង ថ្វាយបង្គំព្រះរាជាហើយ ទើបក្រាបទូលសួរថា "ព្រះអង្គទ្រង់បានត្រាស់បញ្ជា ឲ្យរាជបុរសសម្ងាប់សត្ត្ব សុនខទាំងឡាយមែនឬ?" ។

ព្រះរាជា. អើមែនហើយ យើងឲ្យសម្ងាប់ ។

ព្រះពោធិសត្ត្ব. បពិត្រព្រះអង្គ ជាធំជាងនរជន តើសត្ត្ব សុនខទាំងនោះ មានសេចក្តីខុសគ្នាង យ៉ាងដូចម្តេចទៅ? ។

ព្រះរាជា. ពួកវាខាំ ស៊ីស្បែកជ្រាម និង ស្បែកចងរាជរថ ។

ព្រះពោធិសត្ត្ব. ព្រះអង្គទ្រង់ជ្រាបសុនខដែលកកេរ ស៊ីឬ?។

ព្រះរាជា. យើងមិនបានដឹងទេ ។

មន្តលត្ថនីបនីប្រែ

ព្រះពោធិសត្ត. បពិត្រព្រះសម្ចតិទេព ការដែលព្រះអង្គ មិនទ្រង់ជ្រាបហើយ ត្រាស់បញ្ជា ឲ្យរាជបុរសសម្ងាប់សុនខទាំងឡាយ ក្នុងទីកន្លែងដែលគេយើញហើយៗ ន៉ុះឯង មិនសមគួរឡើយ ។

ព្រះរាជា. យើងបញ្ជាឲ្យសម្ងាប់សុនខថា អ្នកទាំងឡាយ ចូរសម្ងាប់ពួកសុនខទាំងអស់ ក្នុងទីកន្លែងដែលខ្ជួនយើញហើយៗ ន៉ុះឯង ព្រោះសុនខទាំងឡាយ ខាំស៊ីស្បែកជ្រាមរាជរថ ។

ព្រះពោធិសត្ត. ក៏មនុស្សទាំងឡាយនោះ សម្ងាប់សុនខ បានទាំងអស់ឬ ឬក៏ ពួកសុនខដែលមិនបានត្រូវសម្ងាប់ មានសល់? ។

ព្រះរាជា. ពួកសុនខដែលមិនបានត្រូវសម្ងាប់នៅមាន, ពួកសត្វសុនខដែលចិញ្ចឹម ក្នុងសំណាក់របស់ពួកយើង មិនបានត្រូវសម្ងាប់ ។

ព្រះពោធិសត្ត ក្រាបបង្គំទូលថា " បពិត្រព្រះមហារាជ ក្នុងពេលឥឡូវនេះឯង ព្រះអង្គទ្រង់ត្រាស់ថា យើងបញ្ជាឲ្យរាជបុរសសម្ងាប់សុនខថា ពួកអ្នកចូរសម្ងាប់សុនខទាំងឡាយ ក្នុងទីដែលខ្ជួនយើញហើយៗ ទាំងអស់តែម្តង ដូច្នេះ ឥឡូវនេះ ទ្រង់ត្រាស់ទៀតថា ពួកសត្វសុនខដែលចិញ្ចឹម ក្នុងសំណាក់ របស់យើង មិន

-๑๗๒-

ពណ៌នាអំពីការសម្រាះញាតិ

បានត្រូវសម្ងាប់ ដូច្នេះ, កាលបើយ៉ាងដូច្នោះ ព្រះអង្គទ្រង់ដល់នូវអគតិ ដោយអំណាចនៃឆន្ទាគតិ ជាដើម មិនមែនទេឬ? ក៏ឈ្មោះថា កិរិយាដល់នូវអគតិ មិនសមគួរទេ និង មិនមែនជារាជធម៌ទ្បើយ, ឈ្មោះថា ព្រះរាជាទ្រង់ជាអ្នកស្វែងរកហេតុ និង មិនមែនជាហេតុ និង ទ្រង់ជាអ្នកដូចជាជញ្ជីងទើបសមគួរ " ។ ព្រះរាជាទ្រង់ត្រាស់សួរ ថា " ម្នាលបណ្ឌិត ក៏អ្នកដឹងថា សុនខ ឈ្មោះ ឯណោះ កកេរស៊ីស្បែក នៃរថឬ? " ។ ព្រះពោធិសត្ត ទូលថា "ពិតមែនហើយព្រះអង្គ ទូលព្រះបង្គំដឹង ស្បែករាជរថនោះ ពួកសុនខដែលព្រះអង្គចិញ្ចឹម ក្នុងរាជត្រកូល កកេរស៊ីហើយ, សូមព្រះអង្គត្រាស់ឲ្យរាជបុរសនាំយកទឹកដោះរាវជូរ និង ស្មៅចិញ្ចៀនមកបានបន្តិច ហើយត្រាស់ឲ្យច្របាច់ (លាយចូលគ្នា) ហើយឲ្យបញ្ចុកសុនខទាំងឡាយនោះ " ។ ព្រះរាជា ទ្រង់បានធ្វើហើយយ៉ាងដូច្នោះ ។ សុនខទាំងឡាយ បានក្អួតនូវទឹកដោះរាវជូរ និង ស្មៅចិញ្ចៀនដែលខ្ជួនបានផឹកហើយៗ ចេញមកព្រមទាំងស្បែក ។ ព្រះរាជា ទ្រង់ត្រេកអរហើយថា "ព្យាការណ៍របស់ស្តេចសុនខនេះ ប្រៀបដូចជាព្យាការណ៍ របស់ព្រះសព្វញ្ញូពុទ្ធ " ហើយ ទ្រង់បានបូជាព្រះពោធិសត្វដោយស្វេតច្ឆត្រ ។ ព្រះពោធិសត្វសម្តែងធម៌ដល់ព្រះរាជា ដោយធម្មចរិយគាថាទាំងឡាយ ១០ មានជាអាទ៍ ថា

មង្គលត្ថទីបនីប្រែ

" បពិត្រព្រះមហារាជ ដ៏ជាកូរ្ត្រ សូមព្រះអង្គទ្រង់ប្រព្រឹត្ត ធម៌ បំពេញព្រះជនក និង ព្រះជនី ចុះ ... " ដូច្នេះហើយ ទូលថា "សូមព្រះអង្គ ទ្រង់ស្តេចកុំបីប្រមាទឡើយ" ដូច្នេះហើយ បានញ៉ាំងព្រះរាជាឲ្យទ្រង់ស្ថិតនៅ ក្នុងបញ្ចសីល ថ្វាយសេ្វតច្ឆត្រ ត្រឡប់ទៅព្រះរាជាវិញហើយ ក៏បានគេចចេញទៅ ។

ព្រះរាជាទ្រង់បានប្រទានអភ័យ ដល់សព្វសត្វហើយ ទ្រង់តាំងនូវនិច្ចកត្ត ដូចជាព្រះក្រយាស្ងោយ របស់ព្រះអង្គនុ៎ះឯង ដល់សុនខទាំងឡាយទាំងពួង បន្ទាប់ពីព្រះពោធិសត្វចុះមក ។ ជនទាំងឡាយ ស្ថិតនៅក្នុងឱ្យាទ របស់ព្រះពោធិសត្វហើយ បំពេញកុសលទាំងឡាយ មានទានជាដើម ក៏បានទៅកើត ក្នុងទេវលោកហើយ ។ ក្ដីភេរ៉ាទ បានប្រព្រឹត្តទៅហើយ រហូត ១ ម៉ឺនឆ្នាំ យ៉ាងនេះឯង ។

រឿងសត្វសុនខ ក្នុងអដ្ឋកថាកុក្ករជាតក ក្នុងតតិយវគ្គនៃឯកនិបាត ចប់ ។

(រឿង សត្វក្អែក)

(៩៥) ក្នុងអតីតកាល ព្រះពោធិសត្ត បានសោយព្រះជាតិជាសត្វក្អែក មានក្អែកប្រមាណ ៨ ម៉ឺន ចោមរោមហើយ រស់នៅ ក្នុងព្រៃស្នសានដ៏ធំ ។ ក្រោយមកថ្ងៃមួយ បុរោហិត របស់ព្រះរាជាក្រុងពារាណសី ងូតទឹក ក្នុងស្ទឹង ខាងក្រៅព្រះនគរ ហើយ

ពណ៌នាអំពីការសម្ឆោះញាតិ

ចូលទៅកាន់ព្រះនគរ ។ ក្នុងកាលនោះ មានសត្វក្អែកពីរ ទំលើ
កំពូលខ្វោងទ្វារព្រះនគរ ។ បណ្តាសត្វក្អែកទាំង ២ នោះ ក្អែក ១
ពោលថា "នែសំឡាញ់ ខ្ញុំនឹងបន្ទោបង់ខច្ចារៈ លើក្បាលព្រាហ្មណ៍
នេះ " ។ ក្អែកក្រៅនេះ ហាមថា " ចូរអ្នកកុំធ្វើឡើយ, បុគ្គលនេះ
ជាឥស្សរជន, ធម្មតាពៀរវេរា ជាមួយនឹងឥស្សរជន ជាបាបធ្ងន់,
ព្រោះថា ព្រាហ្មណ៍នេះ ក្រោធហើយ ក៏នឹងញ្ញាំងក្អែកទាំងអស់
ឲ្យវិនាសអស់" ។ ក្អែកនោះមិនជឿតាម ក៏បានធ្វើយ៉ាងដូច្នោះ ។
ព្រាហ្មណ៍ ក្រោធហើយបានចងពៀរវេរា ចំពោះក្អែកទាំងឡាយ ។
គ្រានោះ ស្ត្រីម្នាក់ហាលស្រូវព្ធដ៏កំដៅថ្ងៃ នៅរក្សា បានយកអង្កត់
ក្ងើងមកវាយសត្វពពែ ដែលមកស៊ីស្រូវ ។ ក្ងើងបានចាប់ (ធេះ)
រោមទាំងឡាយ របស់សត្វពពែនោះ ។ សត្វពពែ គិតថា " អញ
នឹងធ្វើឲ្យក្ងើងរលត់" ដូច្នេះហើយ ក៏បោលទៅ កាន់រោងដំរី យ៉ាង
លឿន ត្រជុសខ្ជូន ត្រង់ខូមស្មៅមួយ ក្បែររោងដំរី ។ ខូមនោះ ក៏
ធេះឡើង ។ អណ្តាតក្ងើង ធេះផ្ងា ចេញអំពីខូមស្មៅនោះ ចាប់
(ធេះ) រោងដំរី ។ កាលបើរោងដំរីត្រូវក្ងើងធេះ, ដំរី ជាច្រើន មាន
ខ្ជូនជាផ្ងែដំបៅហើយ ។ ពួកពេទ្យដំរី មិនអាចរក្សាឲ្យជាបាន ទើប
ទៅក្រាបទូល ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់ត្រាស់សួរបុរោហិត
ថា " តើអ្នកចេះថ្នាំរក្សាអ្វីខ្ងះដែរឬទេ?" ។ បុរោហិត ក្រាបទូលថា

មង្គលត្ថទីបនីប្រែ

បពិត្រព្រះមហាវជ ទូលព្រះបង្គំចេះ, ការបាន១ខ្ញាញ់ភ្ជ រ បស់ក្អែក ទើបសមគួរ " ។ ព្រះរាជា ទ្រង់ត្រាស់បញ្ជាថា " បើដូច្នោះ ចូរពួកអ្នកសម្ងាប់ក្អែកហើយ នាំយកខ្ញាញ់ភ្ជ រ មក " ។

ចាប់ដើមពីពេលនោះមក ពួកមនុស្ស នាំគ្នាសម្ងាប់ក្អែកទាំងឡាយហើយ (តែ) មិនបានខ្ញាញ់ភ្ជ រ ទើបធ្វើជាគំនរទុក ក្នុងទីកន្លែងនោះ១ ១ ១ ។ សត្វក្អែកទាំងឡាយបានកើតភ័យធំហើយ ។ ព្រះពោធិសត្ត ដ៏ងហេតុនោះហើយ ប្រាថ្នានឹងធ្វើការសង្គ្រោះញាតិ ទើបនឹកវញ្ចកជល់ចារមីទាំងឡាយ បានធ្វើមេត្តាចារមី ឲ្យប្រព្រឹត្ត ទៅ ១ងមុ១ ហើរទៅ យ៉ាងលឿនគ្ងោ ចូលទៅ តាមប្រទ្ធោះបង្ហ្ជ ដ៏ធំ ដែលកំពុងបិទហើយ ក៏ចូលទៅ ក្រោមព្រះទីនាំង របស់ព្រះ រាជា ។

គ្រានោះ មនុស្សម្នាក់ បានប្រាថ្នា នឹងចាប់ព្រះពោធិសត្ត នោះ ។ ព្រះរាជាទ្រង់ត្រាស់ហាមមនុស្សនោះ ។ ព្រះពោធិសត្ត បានឈប់សម្រាកបន្ដិចហើយ ក៏ចេញពីក្រោមព្រះទីនាំង មក ក្រាបទូលថា " បពិត្រព្រះមហាវជ ធម្មតា ព្រះរាជា គ្រប់គ្រងរាជសម្ជត្ដិ មិនទ្រង់លុះអគតិដោយអំណាចឆន្ទាគតិជាដើម ទើបត្រឹមត្រូវ, ក៏ព្រះរាជកិច្ចណានីមួយ១ ជាព្រះរាជកិច្ចដែលព្រះអង្គ ត្រូវបំពេញ, ព្រះរាជកិច្ចនោះ១ ទាំងអស់ ព្រះអង្គទ្រង់ពិចារណា

ពណ៌នាអំពីការសង្គ្រោះញ្ញាតិ

ជាមុនហើយ ទ្រង់បំពេញ ទើបត្រឹមត្រូវ, មួយទៀត ព្រះរាជកិច្ច ឯណា កាលព្រះអង្គបំពេញ នឹងសម្រេចប្រយោជន៍បាន, ព្រះរាជ កិច្ចនោះឯង ព្រះអង្គបំពេញ ទើបត្រឹមត្រូវ, ព្រះរាជកិច្ចក្រៅពីនេះ ព្រះអង្គទ្រង់បំពេញ មិនត្រឹមត្រូវឡើយ, មែនពិត ព្រះរាជាទាំង ឡាយ ក្នុងកាលមុន តែងមិនទ្រង់បំពេញ នូវព្រះរាជកិច្ច ដែល កាលទ្រង់បំពេញទៅ ក៏មិនបានសម្រេចប្រយោជន៍នោះ, បុរោហិត ជាអ្នកលុះ នៅក្នុងអំណាចនៃពៀរវេរ ទើបបានពោលមុសាវាទ, ធម្មតាខ្ញាញ់ភាវ របស់សត្វក្អែកទាំងឡាយ មិនមានទេ ” ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់មានព្រះ រាជហឫទ័យត្រេកអរ បានឲ្យក្អែកព្រះពោធិសត្វនោះ ទំនៅលើ ទីនាំងមាស ដ៏ប្រសើរ ទ្រង់ត្រាស់ឲ្យរាជបុរស លាបចន្ទោះស្ថាប ទាំងឡាយ ដោយប្រេង ដែលស្រូហើយ ១ រយដង ១ ពាន់ដង ហើយ ទ្រង់ត្រាស់ឲ្យព្រះរាជទាន នូវកោជនដ៏ប្រសើរ ដែលសម គួរ ដល់ព្រះរាជា ក្នុងចានមាស ទ្រង់ឲ្យផឹកទឹកហើយ ទើបទ្រង់ ត្រាស់សួរព្រះតម្រាស់នេះ នឹងព្រះពោធិសត្វនោះ ដែលផ្ទ្រតស្ដាប់ ស្ដាប់ហើយថា “ ម្នាលបណ្ឌិត ព្រោះហេតុអ្វី ទើបខ្ញាញ់ភាវរបស់ ក្អែកទាំងឡាយ មិនមាន? ” ។

ព្រះពោធិសត្ត្ব កាលទ្រង់សម្ដែងធម៌ ដែលប្រកាសហេតុ

មន្ទលត្ថទីបនីប្រែ

ដល់ព្រះរាជាអង្គនោះ ក៏បានពោលគាថា ក្នុងកាកជាតក ក្នុងវគ្គទី ១៤ នៃឯកនិបាត ថា ៖

(៩៦) " ក្អែកទាំងឡាយ ជាសត្វមានហប្រទ័យ [1] ភ្ញាក់ផ្អើលជានិច្ច ត្រូវមនុស្សលោកទាំងពួង បៀតបៀនហើយ ព្រោះហេតុនោះ បានជាខ្លាញ់រាវ នៃពួកក្អែក ជាញាតិ នៃពួកទូលព្រះបង្គំនោះ មិនមាន " ។

បណ្តាបទទាំងនោះ បទថា " **ឧព្វិគ្គហទយា** " មានសេចក្តីថា បពិត្រព្រះមហារាជ ធម្មតាក្អែកទាំងឡាយ ជាសត្វមានចិត្តភ្ញាក់ផ្អើល គឺ ជាសត្វដល់ហើយនូវភ័យ រស់នៅជានិច្ច ។ បទថា " **សព្វលោកវិហេសិតា** " មានសេចក្តីថា ត្រូវប្រជាលោក គឺពួកមនុស្សទាំងឡាយទាំងពួង បៀតបៀនហើយ ព្រោះហេតុនោះ គឺ ព្រោះហេតុ ២ ប្រការនេះ ធម្មតា ខ្លាញ់រាវនៃពួកក្អែកទាំងនោះ គឺ ដែលជាញាតិ របស់ពួកទូលព្រះបង្គំ បានដល់ អ្នកដែលស្គាល់គ្នា របស់ពួកទូលព្រះបង្គំ មិនចេះមានឡើយ, សូម្បីក្នុងអតីតកាល ក៏មិនធ្លាប់មានឡើយ, ក្នុងអនាគតកាល ក៏នឹងមិនមានដែរ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់បូជាព្រះពោធិសត្ត ដោយរាជសម្បត្តិ ។ ព្រះពោធិសត្វនោះ បានថ្វាយ

---

[1] សុត្តន្តបិដក ភាគទី ៥៨ ទំព័រ ទី៦១ ។

ពណ៌នាអំពីការសង្រ្គោះញ្ញាតិ

នូវរាជសម្បត្តិ ដល់ព្រះរាជា ត្រឡប់ដូចដើមវិញ ញ្ញាំងព្រះរាជា ឲ្យទ្រង់ស្ថិតនៅ ក្នុងបញ្ចសីល បានទូលសុំអភ័យ ដល់សព្វសត្វ ហើយ ក៏គេចចេញទៅ ។ ព្រះរាជា ទ្រង់បានព្រះរាជទានអភ័យ ដល់ពួកសព្វសត្វហើយ ទើបទ្រង់បានតាំងនូវទានជាប្រចាំ ដល់ក្អែកទាំងឡាយ ។ ព្រះអង្គទ្រង់ឲ្យដាំបាយ ប្រមាណ ១ អម្ពណៈ នៃអង្ករ ផ្សំដោយអាហារ ដែលមានរសជាតិដ៏ឆ្ងាញ់ផ្សេងៗ ហើយ ឲ្យដល់ពួកក្អែក រៀងរាល់ថ្ងៃ ។ ចំណែកព្រះក្រយាស្ងោយនៃព្រះ រាជានុ៉ះឯង ទ្រង់ព្រះរាជទាន ដល់ព្រះពោធិសត្ត យ៉ាងនេះឯង ។

រឿង សត្វក្អែក ចប់ ។

មហាកបិជាតក ក្នុងទុតិយវគ្គ សត្តកនិបាតក្តី ភទូសាល ជាតក ក្នុងទ្វាទសកនិបាតក្តី បណ្ឌិតគប្បីសម្តែងផងដែរ ។

(៩៧) ចំណែកបុគ្គលឯណា រួបរួមទ្រព្យសម្បត្តិបានច្រើន ហើយ ខ្ជូនឯង មិនបរិភោគឡើយ, មិនបានសង្ត្រោះពួកញ្ញាតិ, បុគ្គលនោះ បណ្ឌិតហៅថា "ជាអ្នកស្មើនឹងសត្វមយ្ហក: " ។

មានរឿងសម្តែងនូវសេចក្តីនោះ ដូចតទៅនេះ ៖

(រឿង សត្វមយ្ហក:)

ក្នុងអតីតកាល ព្រះពោធិសត្ត កើតជាបត្រុនៃសេដ្ឋី មាន ទ្រព្យប្រមាណ ៨០ កោធិ ក្នុងក្រុងពារាណសី ដោយកាលកន្ងន

មន្តលត្ថនីបនីប្រែ

ទៅ នៃមាតាបិតា ក៏បានសង្ត្រោះនូវប្អូនប្រុស ចំណាយទ្រព្យ ឲ្យគេសាងសាលាទាន ក្បែរទ្វារផ្ទះ ថ្វាយមហាទាន នៅគ្រប់គ្រងផ្ទះ ក្នុងពេលដែលបុត្រដើរបាន ឃើញទោសក្នុងកាម និង អានិសង្ស នៃបព្វជ្ជា ហើយ ក៏បានប្រគល់ទ្រព្យទាំងអស់ ព្រមទាំងបុត្រ និង ភរិយា ឲ្យដល់ប្អូនប្រុស បួសជាតាបសឥសី ញ្ចាំងឈាន និង អភិញ្ញា ឲ្យកើតឡើងហើយ ក៏អាស្រ័យនៅក្នុងហិមវន្តប្រទេស ។ ចំណែកប្អូនប្រុស របស់តាបសនោះ បានកូនប្រុសមួយ ក៏គិតថា " កាលបើកូនប្រុស របស់បងប្រុសអញ មានជីវិតរស់នៅ, ទ្រព្យសម្បត្តិ ក៏នឹងចែកជាពីរចំណែក, អញនឹងសម្ងាប់កូនប្រុស របស់បងប្រុសចោល " ដូច្នេះហើយ ថ្ងៃមួយ ក៏បានចាប់កូននោះជ្រមុជក្នុងទឹកស្ទឹង ឲ្យស្ងាប់ហើយ ងូតទឹករួចស្រេច ទើបទៅផ្ទះ ត្រូវភរិយារបស់បងប្រុសសួរហើយ ក៏ឆ្លើយថា " កូននោះ លេងក្នុងទឹកស្ទឹង, ក្នុងពេលនោះ បងបានរាវរក តែមិនបានឃើញសោះឡើយ" ។ នាងបានស្រែកយំហើយក៏នៅស្ងៀម ។ ព្រះពោធិសត្វដឹងរឿងនោះហើយ ទើបគិតថា " អាត្មាអញ នឹងធ្វើកិច្ចនេះ ឲ្យបានប្រាកដ " ដូច្នេះហើយ ក៏បានហោះទៅផ្ទះប្អូនប្រុស តាមអាកាសឆាន់ នូវភោជន៍ ដ៏ប្រសើរ ដែលប្អូនប្រុសប្រគេនហើយ សួរថា " ក្មេងនោះ ទៅទីណាហើយ?" ។ ប្អូនប្រុស ឆ្លើយថា " បពិត្រ

ពណ៌នាអំពីការសង្គ្រោះញាតិ

លោកម្ចាស់ ក្មេងនោះស្លាប់ហើយ ក្នុងទីកន្ទែងលេងទឹក" ។ ព្រះពោធិសត្វ ពោលថា "នែអសប្បុរស កិច្ចដែលអ្នកធ្វើហើយ បានប្រាកដហើយដល់យើង, អ្នកសម្លាប់ក្មេងនោះ ព្រោះហេតុឈ្មោះនេះ មិនមែនទេឬ?, អ្នកគប្បីអាចដើម្បីនឹងថែរក្សានូវទ្រព្យ ដែលកំពុងតែសាបសូន្យ ដោយអំណាចភ័យ មានរាជភ័យជាដើម បានដែលឬទេ?, កិរិយាធ្វើ របស់សត្វបក្សីឈ្មោះមយ្ហកៈ និង ខ្ញុំនអ្នកនឹងផ្សេងគ្នា យ៉ាងដូចម្តេចទៅ " ដូច្នេះ កាលសម្តែងធម៌ ដោយពុទ្ធលីលា ដល់ប្អូនប្រុសនោះ បានពោលគាថាទាំងនេះ ក្នុងមយ្ហកសកុណជាតក [១] ថា ៖

(៩៨) " សត្វស្លាប ឈ្មោះមយ្ហកៈ ហើរទៅ តាមញក និង ប្រកភ្នំ ទៅទំដើមលៀប ដែលមានផ្លែទុំ ស្រែកយំកន្តក់កន្ត្រេញថា របស់អញៗ ដូច្នេះ ។ កាលបើសត្វមយ្ហកៈនោះ ស្រែកយំការពារ យ៉ាងដូច្នេះ, ពួកសត្វទិជជាតិ ក៏មកប្រជុំគ្នា ស៊ីផ្លែលៀបហើយ ទើបហើរទៅ, សត្វនោះ ក៏នៅតែស្រែកយំ ការពារនុ៎ះឯង យ៉ាងណាមិញ ។ បុគ្គលពួកខ្លះក្នុងលោកនេះ ក៏យ៉ាងដូច្នោះដែរ ប្រមូលមក នូវទ្រព្យ មានប្រមាណច្រើន ហើយមិនបាត់បែង នូវទ្រព្យឱ្យសមគួរ ដល់

១- សុត្តន្តបិដក ភាគទី ៥៩ ទំព័រទី ៦០ ។

មន្តលត្ថនីបនីប្រែ

បំណែក ដើម្បីខ្លួន, មិនទំនុកបម្រុង ដល់ញាតិទាំងឡាយ ។ បុគ្គលនោះ រមែងមិនបានប្រើប្រាស់ នូវគ្រឿងស្លៀកពាក់ និង បាយ មិនបានទ្រទ្រង់ នូវកម្រងផ្កា មិនបានលាបនូវគ្រឿងលាប មិនបានប្រើប្រាស់ នូវវត្ថុណាមួយ ជារបស់ខ្លួនទេ ទាំងមិនបានសង្រ្គោះនូវញាតិទាំងឡាយទ្បើយ ។ កាលបើបុគ្គលនោះ ពោលរៀបរាប់ ហ្លងហែងថា របស់អញៗ យ៉ាងនេះ, ស្រាប់តែ ពួកព្រះរាជា ឬ ពួកចោរ និង ពួកជន អ្នកត្រូវទទួលមតិក អ្នកមិនជាទីស្រលាញ់ ក៏នាំយកទ្រព្យនោះទៅ, បុគ្គលនោះ ក៏នៅតែពោលរៀបរាប់នុ៉ះឯង ។ ឯអ្នកប្រាជ្ញ បានសូវភោគៈហើយ រមែងសង្រ្គោះ នូវញាតិទាំងឡាយ, អ្នកប្រាជ្ញនោះ រមែងបាន នូវសេចក្ត្តីសរសើរ ដោយការសង្រ្គោះញាតិនោះ និង លុះលះលោកនេះហើយ រមែងរីករាយសប្បាយ ក្នុងឋានសួគិ " ។

នយមក ក្នុងអដ្ឋកថាមយ្ហកសុណជាតក ក្នុងឆដ្ឋនិបាត ថា "បណ្តាបទទាំងនោះ បទថា ***មយ្ហកោ*** *គឺ សត្វស្លាប ដែលបានឈ្មោះយ៉ាងនោះ ដោយអំណាចការស្រែកយំថា របស់អញៗ ។ ក្នុងបទថា* ***គិរិសានុទរីចរោ*** *មានវិគ្រោះថា សត្វ ណា រមែងហើរ*

ពណ៌នាអំពីការសង្គ្រោះញាតិ

ត្រាច់ទៅ ក្នុងញក និង ប្រកក្នុំ ទាំងឡាយ ហេតុនោះ សត្វនោះ ឈ្មោះថា សត្វដែលហើរត្រាច់ទៅ ក្នុងញក និង ប្រកនៃភ្នំ ។ ២ បទថា **បក្កំ បិប្ផលឹ** គឺ ដើមល្វៀបដែលសម្បូរ ដោយផ្លែមួយដើម ក្នុងព្រៃហិមវន្តប្រទេស ។ បទថា **កន្ទតិ** មានសេចក្តីថា ហើរទៅ ស្រែកយំថា របស់អញៗ ដូច្នេះ ដើម្បីហាមប្រាមពួកសត្វទាំង ឡាយ ដែលចោមរោម នូវដើមឈើនោះហើយ ស៊ីផ្លែដែលទុំៗ ។ ២ បទថា **តស្សេវំ វិលបន្តស្ស** គឺ កាលបើសត្វនោះ យំស្រែក យ៉ាងនោះឯង ។ បាទគាថា ថា **កុត្វាន បិប្ផលឹ យន្តិ** មានសេចក្តី ថា ហ្វូងបក្សី នាំគ្នាមកស៊ីផ្លែល្វៀបនោះហើយ ក៏ហើរទៅរកដើម ឈើផ្សេងទៀតដែលសម្បូរផ្លែ ។ បទថា **វិលបតេវ** មានសេចក្តីថា ចំណែកទិជជាតិនោះ ក៏នៅតែស្រែកយំទ្រុំះឯង ។ បទថា **យថោធឹ** គឺ តាមសមគួរដល់ចំណែក បានដល់ ចំណែកឯណាៗ (ដែលខ្លួន ត្រូវឲ្យ) ដល់មាតាបិតា បងប្អូនប្រុសស្រី បុត្រ និង ធីតា ជាដើម ដោយអំណាចជាគ្រឿងឧបភោគ និង បរិភោគ, មិនឲ្យនូវចំណែក នោះៗ ។ បទថា **សកឹ** គឺ ខ្លួនឯង ក៏មិនបានប្រើប្រាស់ សូម្បីម្តង ឡើយ ។ អធិប្បាយថា មិនបានប្រើប្រាស់នូវវត្ថុ ដែលជារបស់ ខ្លួន ។ បទថា **ន សង្គណ្ហាតិ** គឺ មិនបានសង្គ្រោះ (នូវពួកញាតិ) ដោយអំណាចនៃវត្ថុ មានអាហារ គ្រឿងស្លៀកពាក់ ពូជ និង

មន្តលត្ថទីបនីប្រែ

*នង្គ័លជាដើម ។ បទថា **វិលបតេវ** មានសេចក្តីថា កាលបើជន*
ទាំងឡាយ មានព្រះរាជាដើមនោះ នាំយកទ្រព្យទៅ, បុរសនោះ ក៏
*នៅតែពោលរៀបរាប់ តែម៉ូាងនុ៉ះឯង ។ បទថា **ធីរោ** បានដល់*
*បណ្ឌិត ។ បទថា **សង្គណ្ហាតិ** គឺ រមែងសង្គ្រោះ នូវញាតិដែល*
ទុព្វលភាពទាំងឡាយ សូម្បីមកកាន់សំណាក់ របស់ខ្ជួនហើយ
ដោយការឲ្យវត្ថុ មានអាហារ គ្រឿងស្លៀកពាក់ ពូជ និង នង្គ័ល
*ជាដើម ។ បទថា **តេន** មានសេចក្តីថា សប្បុរសជននោះ រមែង*
បាននូវកិត្តិយស និង ការពោលសរសើរខ្ជួន ក្នុងកណ្តាលបរិស័ទ
ទាំង ៤ ដោយការសង្គ្រោះ នូវញាតិទាំងឡាយនោះ, សប្បុរស
នោះ លះលោកនេះទៅហើយ រមែងរីករាយសប្បាយ ក្នុងឋានសួគ៌
គឺ ក្នុងនគរនៃទេវតា ។

(៩៩) ព្រះពោធិសត្ធ លុះសម្តែងធម៌ ដល់ប្អូនប្រុសនោះ
រួចស្រេចហើយ បានញុាំងប្អូនប្រុស ឲ្យធ្វើទានដែលគាត់បានកាត់
ផ្តាច់ហើយ ឲ្យនៅតាមប្រក្រតីវិញ ទើបទៅកាន់ហិមវន្តប្រទេស
ដូចដើម ជាអ្នកមិនសាបសូន្យចាកឈាន បានទៅកើត ក្នុងព្រហ្ម-
លោកហើយ ។ ចំណែកប្អូនប្រុសរបស់ព្រះពោធិសត្ធនោះ ឥឡូវ
នេះ បានកើតមានឈ្មោះជា អាគន្តុកសេដ្ឋី នោះ ។ អាគន្តុកសេដ្ឋី
នោះ មិនបានធ្វើបុណ្យ រហូតមួយជីវិត ធ្វើកាលកិរិយាទៅហើយ

ពណ៌នារំពឹការសឡ្លោះញាតិ

ក៏បានទៅកើត ក្នុងរោរុវនរក ។ ទ្រព្យសម្បត្តិ ដែលជារបស់បុគ្គល អ្នកមិនមានបុត្រ របស់អាគន្ត្ពុកសេដ្ឋី ណា, ពួករាជបុរស ក៏បានប្រមូលទ្រព្យសម្បត្តិ របស់អាគន្ត្ពុកសេដ្ឋីនោះ បញ្ជូលទៅកាន់ព្រះឃ្លាំង របស់ព្រះបាទបសេនទិកោសល អស់ ៧ ថ្ងៃ ៧ យប់ " ។

ចំណែក ក្នុងកោសលសំយុត្ត ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា " បពិត្រព្រះមហារាជ សេដ្ឋីគហបតីនោះ បានផ្តាច់បង់កូនប្រុសម្នាក់ របស់បងប្រុស ចាកជីវិត ព្រោះហេតុនៃទ្រព្យសម្បត្តិ ព្រោះកម្មឯណា, ព្រោះវិបាកនៃកម្មនោះ សេដ្ឋីនោះ ទើបត្រូវភ្លើងធេះ ក្នុងនរក អស់ច្រើនឆ្នាំ គឺ អស់ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ច្រើនសែនឆ្នាំ, ព្រោះវិបាកដ៏សេសសល់ នៃកម្មនោះឯង ពួករាជបុរស ទើបប្រមូលទ្រព្យសម្បត្តិ ដែលរកបុត្រមិនមានរហូត ថ្ងៃ ទី៧ នេះ បញ្ជូលទៅកាន់ព្រះឃ្លាំងនៃព្រះរាជា ។ បពិត្រព្រះមហារាជ ក៏ក្នុងថ្ងៃនេះ សេដ្ឋីគហបតី ក៏ត្រូវភ្លើងធេះ ក្នុងមហារោរុវនរក " ។

(១០០) អដ្ឋកថា នៃកោសលសំយុត្តនោះ ថា " ពាក្យថា **សាបតេយ្យស្ស ការណា ជីវិតា រៅរោបេសិ** មានសេចក្តីថា បានញ្ចថា ក្នុងកាលនោះ កាលបើទ្រព្យសម្បត្តិ មិនទាន់បានបែងចែកគ្នានៅឡើយ, មាតាបិតា និង បងប្រុស របស់សេដ្ឋីនោះ ក៏

មង្គលត្ថទីបនីប្រែ

បានធ្វើកាលកិរិយាចាលហើយ ។ សេដ្ឋីនោះ ក៏បាននៅរួមជាមួយនឹងភរិយា របស់បង់ប្រុសនោះឯង ។ ក៏បង់ប្រុសរបស់សេដ្ឋីនោះ មានកូនប្រុសមួយ ។ មនុស្សទាំងឡាយ ប្រាប់ក្មេងនោះដែលកំពុងតែលេង លើថ្ពល់ថា " ខ្ញុំបម្រើប្រុសនេះ ខ្ញុំបម្រើស្រីនេះ យានេះ ទ្រព្យនេះ ជាសម្បត្តិ របស់អ្នក " ។ ក្មេងនោះ ជឿស្តាប់ពាក្យ របស់មនុស្សទាំងនោះហើយ ពោលពាក្យជាអាទិ៍ ថា " ខ្ញុំបម្រើប្រុសនេះ ជារបស់អាត្មាអញ " ដូច្នេះ ។

លំដាប់នោះ ឪពុកមា របស់ក្មេងនោះ គិតថា " ក្នុងកាលឥឡូវនេះ ក្មេងតូចនេះ រមែងពោល យ៉ាងនេះឯង, ក្នុងពេលវាធំឡើង វា នឹងគប្បីឲ្យបែងចែកទ្រព្យសម្បត្តិ ត្រង់ពាក់កណ្តាល, អញនឹងធ្វើកិច្ចដែលត្រូវធ្វើ ដល់ក្មេងនោះ ក្នុងពេលនេះតែម្តង" ។ ក្នុងពេលថ្ងៃមួយ ឪពុកមា ទាញយកកាំបិតហើយ ពោលថា "នែកូន អ្នកចូរមក, យើងនឹងទៅព្រៃ" ដូច្នេះហើយ ក៏នាំក្មេងនោះទៅព្រៃ សម្ងាប់ក្មេងនោះ ដែលកំពុងតែស្រែកយំក្តែងៗ ហើយចោះចាល ទៅក្នុងអន្ទុង បានយកអាចម៍ដី លប់កប់ហើយ " ។

ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាជាតក ថា " សូម្បីអាគន្ធុកសេដ្ឋី ដល់ភាពជាសេដ្ឋីបាន ក៏ព្រោះកិរិយាថ្វាយទាន ដល់ព្រះបច្ចេកពុទ្ធ ទ្រង់ព្រះនាមថា តគរសីខី ដូចជាសេដ្ឋី

ពណ៌នាអំពីការសឡ្លោះញាតិ

(ដែលបានសម្ងាប់ក្ជូយក្នុងព្រៃ) នេះ យ៉ាងដូច្នេះឯង" ។

ព្រោះហេតុដូច្នោះ បើសេដ្ឋីទាំង ២ នាក់នុ៉ះ ជាបុគ្គលតែមួយ ដោយសេចក្តី, សេចក្តីនៃមយ្ហកសកុណជាតក ក៏ខុស, បើផ្សេងពីគ្នា ក៏គួរតែត្រឹមត្រូវ, ពាក្យដែលពោលមកនេះ អ្នកមានប្រាជ្ញា គប្បីត្រួតពិនិត្យមើលផងចុះ" ។

រឿង សត្វស្ពាបឈ្មោះមយ្ហកៈ ចប់ ។

ពណ៌នាអំពីការសឡ្លោះញាតិ ចប់ ។

សាសនាបម្រើន ព្រោះមានអ្នកសិក្សាត្រឹមត្រូវ

និង

ប្រតិបត្តិត្រឹមត្រូវតាមការសិក្សា ។

ប្រែចប់ ថ្ងៃពុធ ១៣ កើត ខែដេស្ត ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦

ត្រូវនឹងថ្ងៃ ទី២ ខែមិថុនា គ.ស.១៩៩៣

ពណ៌នាអំពីកម្មដែលមិនមានទោស

(១០១) ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថា នៃ មង្គលត្ថទីបនីនេះ ថា " ការងារទាំងឡាយ មានការសមាទាន នូវ អង្គនៃឧបោសថ ការធ្វើកិច្ចជួយខ្ទល់ខ្ទាយ ការបណ្តុះដាំដើមឈើ ក្នុងវត្តអារាម និង ការសាងស្ពានជាដើម ឈ្មោះថា ការងារដែល មិនមានទោស " ។

(ឧបោសថកម្ម ២ យ៉ាង)

បណ្តាកម្មទាំងនោះ ឧបោសថកម្ម មាន ២ យ៉ាង ដោយ អំណាចនៃបកតិឧបោសថ និង បដិជាគរឧបោសថ ។ ពិតមែន យ៉ាងដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាពជសូត្រ ក្នុងបឋមបណ្ណាសក: នៃតិកនិបាត អង្គុត្តរនិកាយថា " ២ បទថា **ឧបោសថំ ឧបវសន្តិ** មានសេចក្តីថា ជនទាំងឡាយ រមែងអធិដ្ឋាន នូវអង្គ នៃឧបោសថទាំងឡាយ ១ ខែ ៨ ដង ។ បទថា **បដិ-ជាគរេ**ន្តិ មានសេចក្តីថា រមែងធ្វើឧបោសថកម្ម ឈ្មោះថា បដិជាគរ: ។ ជនទាំងឡាយ កាលធ្វើនូវបដិជាគរឧបោសថនោះ រមែងធ្វើ ដោយអំណាចនៃការទទួល និង ការជូនដំណើរ នូវថ្ងៃ ឧបោសថទាំងឡាយ ៤ ថ្ងៃ ក្នុងកន្លះខែមួយ។ កាលបើទទួលនូវ ឧបោសថ ក្នុងតិបី ទី ៥ រមែងជាអ្នករក្សាឧបោសថ ក្នុងតិបី ទី ៤, កាលបើជូនដំណើរ រមែងជាអ្នករក្សានូវឧបោសថ ក្នុងតិបី ទី ៦ ។

ពណ៌នាអំពីកម្មដែលមិនមានទោស

កាលនឹងទទួលនូវឧបោសថ ក្នុងតិបី ទី៨ រមែងជាអ្នករក្សា នូវឧបោសថ ក្នុងតិបី ទី៧, កាលនឹងជូនដំណើរ រមែងជាអ្នករក្សានូវឧបោសថ ក្នុងតិបី ទី៩ ។ កាលនឹងទទួលនូវឧបោសថ ក្នុងតិបី ទី ១៤ រមែងជាអ្នករក្សានូវឧបោសថ ក្នុងតិបី ទី ១៣, កាលនឹងជូនដំណើរនូវឧបោសថ ក្នុងតិបី ទី ១៥ រមែងជាអ្នករក្សា នូវឧបោសថ ក្នុងថ្ងៃបាដិបទ (ថ្ងៃ ១ រោច)" ដូច្នេះ ។

*(១០២) ដីការាជសូត្រនោះថា " ២ បទថា **អដ្ឍ ១ រ** គឺ រហូត ៨ ដង យ៉ាងដូច្នេះ គឺ៖ ក្នុងកន្ទុះខែមួយ ៤ ដង, ក្នុងកន្ទុះខែ ក្រៅអំពីនេះ ក៏យ៉ាងដូច្នោះដែរ ។ បទថា **អធិដ្ឋហន្តិ** ប្រែថា រមែងតាំងចិត្តខ្ជាប់ ។ បទថា **បដិជាគរោន្តិ** ប្រែថា រមែងភ្ញាក់រពឹកដោយលំដាប់ ។ មែនពិត សត្វទាំងឡាយកាលនឹងធ្វើបុណ្យទាំងឡាយ ឈ្មោះថា រមែងភ្ញាក់រពឹក ព្រោះភាពជាអ្នកខ្ជាប់ខ្ជាយក្នុងកិច្ចការដែលខ្លួនត្រូវធ្វើ ។ ប៉ុន្តែ សត្វក្រៅអំពីនេះ ឈ្មោះថា រមែងដេកលក់ ព្រោះភាពជាអ្នកគេចមុខចេញ អំពីប្រយោជន៍របស់ខ្លួន និងប្រយោជន៍របស់អ្នកដទៃ ។ ការទទួលនូវឧបោសថ ក្នុងតិបី ទី១៥ រមែងមិនបាន ដូចជាការជូនដំណើរ នូវឧបោសថ ក្នុងតិបី ទី ១៤ ទេ ព្រោះមិនមានថ្ងៃ" ។*

*សទ្ទនីតិបករណ៍ បានកែថា "**ជាគ** ធាតុ ប្រព្រឹត្តទៅ*

មន្តលត្ថនីបនីប្រែ

ក្នុងការអស់ទៅ នៃការដេរលក់, រូប នៃពួកធាតុ មាន **ភូ** ធាតុ ជាដើមថា **ជាគរតិ** ដូច្នេះ, រូបនៃពួកធាតុ មាន **តន** ធាតុ ជាដើមថា **ជាគរោតិ** ដូច្នេះ ។

(១០៣) ចំណែកក្នុងកាល នៃខបោសថនេះ មានការសន្និដ្ឋាន ដូចតទៅនេះ ៖ ៨ ថ្ងៃ នៃមួយខែ (១ ខែ ៨ ថ្ងៃ) គឺ ក្នុងជុណ្ហបក្ខ (ខាងខ្នើត) ៤ ថ្ងៃ គឺ ថ្ងៃ ៥ កើត ៨ កើត ១៤ កើត ថ្ងៃ ១៥ កើត, ក្នុងកាឡបក្ខ (ខាងរនោច) ក៏យ៉ាងដូច្នោះដែរ គឺ ថ្ងៃ ៥ រោច ៨ រោច ១៤ រោច ថ្ងៃ ១៥ រោច ចាត់ជាកាល នៃបកតិខបោសថ ។ ១១ ថ្ងៃនៃមួយខែ (មួយខែ ១១ ថ្ងៃ) គឺ ក្នុងជុណ្ហបក្ខ មាន ៥ ថ្ងៃ គឺ ថ្ងៃ ៤ កើត ៦ កើត ៧ កើត ៩ កើត ១៣ កើត, និង ក្នុងកាឡបក្ខ មាន ៦ ថ្ងៃ គឺ ថ្ងៃ ១ រោច ៤ រោច ៦ រោច ៧ រោច ៩ រោច ១២ រោច ឬក៏ ថ្ងៃ ១៣ រោច ចាត់ជាកាល នៃបដិជាគរខបោសថ ។ ១០ ថ្ងៃ ក្នុងខែដែលខ្វះ, ១១ ថ្ងៃ ក្នុងខែដែលពេញ ដែលក្រៅអំពីថ្ងៃទាំងនោះ មិនចាត់ជាកាលនៃខបោសថ ទេ ។

(១០៤) ការដែលបុគ្គលមិនសមាទាន នូវខបោសថ រក្សាសីល ៥ រហូតទាំង ១ ខែ ក៏សមគួរ ព្រោះហេតុនោះ ខែទាំងអស់ ទើបចាត់ជាកាលនៃសីល ៥ នោះ ។ ប៉ុន្តែ បញ្ចសីលនេះ

លោកពោលហើយ ដោយអំណាចនៃបុគ្គលអ្នកដែលមិនធ្វើ នូវ ចាជិហារិយបក្ខ ។

(ចាជិហារិយបក្ខឧបោសថ)

ចំណែក ខែក្នុងរដូវក្ដៀង ៤ ខែ ចាត់ជាកាលនៃបុគ្គលអ្នកធ្វើចាជិហារិយបក្ខនោះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាវាជសូត្រថា " ឧបោសថជាប្រចាំ រហូត អស់ ៣ ខែ ពួកដ៏ខាងក្នុងនៃរដូវក្ដៀង ឈ្មោះថា ចាជិហារិយបក្ខ, កាលបើមិនអាចអស់ទាំង ៣ ខែនោះទេ, ឧបោសថជាប្រចាំ រហូត អស់មួយខែ ក្នុងចន្លោះ នៃថ្ងៃបវារណាទាំង ២ ឈ្មោះថា ចាជិ-ហារិយបក្ខ, កាលបើមិនអាច អស់ទាំង ១ ខែ នោះទេ, ចាប់ពីថ្ងៃបវារណា ខាងដើមមក កន្លះខែមួយ ក៏ឈ្មោះថា ចាជិហារិយ-បក្ខ ដូចគ្នាដែរ " ។

ដីកានៃវាជសូត្រនោះថា " ឧបោសថ ជាប្រចាំ ឈ្មោះថា ចាជិហារិយបក្ខ ព្រោះយើងត្រូវតែនាំទៅ តាមលំដាប់ គឺ ព្រោះ យើងត្រូវឲ្យប្រព្រឹត្តទៅ ជារៀងរាល់ឆ្នាំ " ។

អដ្ឋកថា ឧត្តរវិមាន ថា " បទថា **ចាជិហារិយបក្ខញ្ច** មានសេចក្ដីថា រហូត ឧបនីហរណកបក្ខ និង បក្ខ ដែលប្រតិបត្តិ ឧបោសថសីល ដោយអំណាចនៃការទទួល និង ការជូនដំណើរ ថ្ងៃ

មន្តលត្ថទីបនីប្រែ

ទី១៤, ១៥ និង ថ្ងៃទី ៨ តាំងតែពីដើម និង ទីបំផុត តាមលំដាប់, អធិប្បាយថា និង ក្នុងថ្ងៃ ទី១៣ ថ្ងៃ ទី១ ថ្ងៃ ទី៧ និង ក្នុងថ្ងៃ ទី៩ " ។

(១០៥) អដ្ឋកថាធម្មិកសូត្រ ក្នុងទុតិយវគ្គ សុត្តនិបាត ថា "ខែទាំងឡាយ ៥ នេះ គឺ ខែអាសាឡ្ហៈ (ខែ ៨) ក្នុងចំណែកខាងដើម នៃថ្ងៃវស្សូបនាយិកា (ថ្ងៃចូលវស្សា), ខែទាំងឡាយ ៣ ព្ធដ៏ខាងក្នុងវស្សា, ខែកត្តិក (ខែ ១២) ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា បាដិហារិយបក្ខ ។ អាចារ្យពួកខ្លះពោលថា ខែអាសាឡ្ហៈ (ខែ ៨) ខែកត្តិក (ខែ ១២) ខែផគ្គុណ (ខែ ៤) តែ ៣ ខែ ប៉ុណ្ណោះ (ឈ្មោះថា បាដិហារិយបក្ខ) ដូច្នេះ ។ អាចារ្យពួកខ្លះពោលថា ក្នុងមួយបក្ខៗ មាន ៤ ៗ ថ្ងៃ ពោលគឺ ថ្ងៃទី១៣ ថ្ងៃទី១ ថ្ងៃទី៧ និង ថ្ងៃទី៩ ដោយអំណាចនៃថ្ងៃខាងដើម និង ថ្ងៃខាងចុងនៃថ្ងៃឧបោសថ ក្នុងបក្ខ (ឈ្មោះថា បាដិហារិយបក្ខ) ដូច្នេះ ។ បណ្ឌិត ចូលចិត្តវិធីណាមួយ, គប្បីកាន់យកវិធីនោះចុះ ។ ក៏អ្នកប្រាថ្នាបុណ្យ ត្រូវធ្វើគ្រប់វិធី " ។

(១០៦) ចំណែកពាក្យណា ដែលលោកពោលហើយ ក្នុងអដ្ឋកថាគន្ធមាលជាតក ក្នុងអដ្ឋកនិបាតថា " បុត្រ និង ភរិយា ក្តី ជនដែលជាបរិវារ ក្តី របស់សេដ្ឋីនោះ ដោយហោចទៅ សូម្បីអ្នកគន្ធលគោ ក្នុងផ្ទះនោះៗ ទាំងអស់គ្នា តែងចូលរក្សាឧបោសថ ១

ពណ៌នាអំពីកម្មដែលមិនមានទោស

ខែ ៦ ថ្ងៃ " ដូច្នេះ, ពាក្យនោះ លោកពោលហើយ សំដៅយកនូវ ឧបោសថដែលបាន ដោយកាលផ្សេង ក្រៅអំពីកាលនៃព្រះពុទ្ធ ។ បានញ្ចថា ក្នុងកាលនោះ ការរក្សា ពោលគឺការមិនបរិភោគអាហារ នុ៉ះឯង លោកហៅថា ឧបោសថ ដូច្នេះ, មិនមែនអង្ត ៨ ទេ ។ ពិតមែន អង្ត ៨ នោះ រមែងរកបាន តែក្នុងសម័យ នៃការឧបត្ថិ ទ្បើង នៃព្រះពុទ្ធប៉ុណ្ណោះ ។

(១០៧) ចំណែក ក្នុងដីកាគង្គមាលជាតកនោះ លោក ពោលហើយ ថា " មួយខែ មានថ្ងៃឧបោសថ ៦ ថ្ងៃ គឺ ក្នុង សុក្កបក្ខ (ខាងខ្នើត) មាន ៣ ថ្ងៃ គឺ ថ្ងៃអមាវាសី ថ្ងៃទី៨ ថ្ងៃទី ១១, សូម្បីក្នុងកណ្ហបក្ខ (ខាងរនោច) ក៏មាន ៣ ថ្ងៃ ដូចគ្នាដែរ " ។

សូម្បីក្នុងអដ្ឋកថា រវស្សន្តរជាតក លោក ក៏បានសំដៅយក នូវថ្ងៃឧបោសថ ផ្សេងក្រៅអំពីពុទ្ធកាលនេះឯង ហើយពោល ថា " ព្រះមហាសត្ត ទ្បើងទ្រង់លើ-កជំរី ដ៏ប្រសើរ ស្តេចត្រួតពិនិត្យ មើលរោងទាន ៦ កន្ទែង មួយខែៗ ៦ ដង " ដូច្នេះ ។

*ក៏ក្នុងដីកាគង្គមាលជាតកនេះ សូម្បីថ្ងៃបុណ្ណមី លោក ក៏ បានកំណត់យកហើយ ដោយបទថា " **អមាវាសី** " នេះ ។*

*ចំណែកក្នុងដីកានៃសគ្គកណ្ឌ លោកពោលថា "ថ្ងៃបណ្ណ-រសី (ថ្ងៃទី១៥) ដែលជាថ្ងៃខាងកាឡបក្ខ លោកហៅថា **អមាវសី***

មង្គលត្ថទីបនីប្រែ

ដូច្នេះខ្ញុំ ហៅថា **អមាវាសី** ដូច្នេះខ្ញុំក៏មាន ។ ព្រះអាទិត្យ និង ព្រះចន្ទ រមែងនៅរួមគ្នា គឺ ជាមួយគ្នា ក្នុងតិថី ឯណា, តិថីនោះ ឈ្មោះថា អមាវសី និង ឈ្មោះថា អមាវាសី ព្រោះធ្វើទីយៈ ។ **អមា** សព្ទ មាន **សហ** សព្ទជាសេចក្តី ជាអព្យយៈ សព្ទ (គឺសព្ទ ដែលចែកនឹងវិភត្តិនាម មិនបាន) " ។

(១០៨) បណ្ឌិត គប្បីដល់សេចក្តីយល់ព្រម ក្នុងកាលនៃ ឧបោសថនេះ ថា " ថ្ងៃទាំងឡាយ ៨ នៃមួយខែ មានថ្ងៃបញ្ចមី (ថ្ងៃ ទី៥) ជាដើម ចាត់ជាកាលនៃបកតិឧបោសថ, ថ្ងៃទាំងឡាយ ១១ មានថ្ងៃចតុត្ថី (ថ្ងៃ ទី៤) ថ្ងៃឆដ្ឋី (ថ្ងៃ ទី៦) ជាដើម ដែល ជាថ្ងៃខាងដើម និង ខាងចុង នៃថ្ងៃទាំងឡាយ ទាំង ៨ នោះ ចាត់ ជាកាលនៃ បាដិជាគរឧបោសថ, ខែក្នុងរដូវក្ដៀងទាំងអស់ ចាត់ ជាកាល នៃបាដិហារិយឧបោសថ " ដោយប្រការដូច្នេះឯង ។

ចំណែកអាចារ្យពួកខ្ញុំ ពោលថា " ការធ្វើឧបោសថ ក្នុង ថ្ងៃណាមួយ ក៏សមគួរដែរ " ។ ពាក្យនោះ មិនសមឡើយ ព្រោះ ថ្ងៃដែលបណ្ឌិតលោកកំណត់ទុក នឹងដល់ភាពជាថ្ងៃដែលមិនមាន ប្រយោជន៍ ។ ព្រោះថា កាលបើដូច្នោះ ថ្ងៃដែលបណ្ឌិតលោក កំណត់ទុកថា ថ្ងៃចាតុទ្ទសី (ថ្ងៃ ទី១៤) ជាដើម គប្បីជាថ្ងៃដែល មិនមានប្រយោជន៍, ប៉ុន្តែ ថ្ងៃដែលបណ្ឌិត លោកកំណត់ទុកនុ៎ះ

មិនមែនជាថ្ងៃ ដែលមិនមានប្រយោជន៍ទេ ។ ដោយហេតុនោះ ក្នុងអដ្ឋកថាឧត្តរវិមាន ព្រះអដ្ឋកថាចារ្យ ទើបសម្តែងភាវៈ នៃឧបោសថកម្មនោះ ជាកិច្ចដែលបុគ្គលគប្បីធ្វើ ក្នុងថ្ងៃដែលបណ្ឌិតលោកបានកំណត់ទុកប៉ុណ្ណោះ យ៉ាងនេះ ថា " ឧបោសកម្ម នោះ បុគ្គលគប្បីរក្សា ក្នុងថ្ងៃទាំងឡាយណា, ឧបោសថកម្ម ដូចម្តេច ដែលបុគ្គលគប្បីរក្សា ដោយប្រការណា, នាងឧត្តរា កាលនឹងសម្តែង នូវថ្ងៃទាំងនោះ ឧបោសថកម្ម ដូច្នោះ និង ប្រការដូច្នោះនោះ ទើបពោលថា ***ចាតុទ្ទសឹ*** *ដូច្នេះជាដើម ។*

(១០៩) សូម្បីក្នុងអដ្ឋកថាធម្មិកសូត្រ ព្រះអដ្ឋកថាចារ្យ ពោលថា " ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងកាលនៃឧបោសថ ទើបត្រាស់ថា ***តតោ ច បក្ខស្ស*** *ដូច្នេះជាដើម " ។*

បាលី ក្នុងធម្មិកសូត្រនោះ [១] *មានដូចតទៅនេះ ៖*

" ក៏ វិញ្ញូជន អ្នកមានចិត្តជ្រះថ្លាហើយ រក្សានូវឧបោសថ ដែលប្រកបដោយអង្គ ៨ ធ្វើឱ្យមានអង្គគ្រប់ពេញបរិបូរ រហូតតិថី ទី១៤ តិថី ១៥ និង តិថីទី ៨ នៃបក្ខ និង រហូតបាដិហារិយបក្ខ " ។

អដ្ឋកថាធម្មិកសូត្រនោះ ថា " សព្ទថា ***តតោ*** *ក្នុងគាថា*

១- សុត្តន្តបិដក ភាគទី ៤១ ទំព័រទី ១០៧ ។

នោះ ជានិបាត ចុះក្នុងសេចក្ដីគ្រាន់តែធ្វើបទឲ្យពេញ ។ បទថា ***ឧក្ខិត្តបរិវិត្តោ*** *ន ុ ះ បណ្ឌិតគប្បីប្រកប ដោយបទខាងចុងថា រក្ខាឧបោសថ គឺ ចូលរក្ខាឧបោសថ ដែលប្រកបដោយអង្គ ៨ ន ុ ះឯង រហូតទាំង ៣ ថ្ងៃនេះ គឺ តិបីទី ១៤ តិបីទី ១៥ តិបីទី ៨ នៃបក្ខ ដូច្នេះ ។ បទថា* ***ឧក្ខិត្តបរិវិត្តោ*** *ន ុ ះ បណ្ឌិត គប្បីសម្ពន្ធចូលគ្នា យ៉ាងដូច្នេះថា វិញ្ញូជន អ្នកមានចិត្តជ្រះថ្លាហើយ មិនបោះបង់ចោលនូវឧបោសថ ដែលប្រកបដោយអង្គ ៨ សូម្បីតែមួយថ្ងៃ ធ្វើឲ្យមានរូបគ្រប់បរិបូរ គឺ ធ្វើឲ្យមានអង្គគ្រប់បរិបូរណ្ណ ឈ្មោះថា រក្ខាឧបោសថ ប្រកបដោយអង្គ ៨ (ធ្វើឲ្យមានអង្គពេញលេញ) រហូត ជាដិហារិយបក្ខ ផង ដូច្នេះ" ។*

(១១០) អដ្ឋកថាកយកេរវសូត្រ ក្នុងមូលបណ្ណាសក: ថា " បទថា ***ចាតុទ្ទសី*** *បានដល់ រាត្រី ១ ជាទីពេញ នៃថ្ងៃទាំងទ្វាយ ១៤ ចាប់ដើមអំពីថ្ងៃខាងដើមនៃបក្ខទៅ ។ ថ្ងៃទី ១៥ និងថ្ងៃទី ៨ ក៏យ៉ាងដូច្នោះដែរ ។ បទថា* ***ឧក្ខិត្ត*** *មានសេចក្ដីថា រាត្រីទាំងទ្វាយ ៦ បែងចែករាត្រីទាំងនោះ នៃសុក្កបក្ខ និងកណ្ហបក្ខ ឲ្យទៅជាបក្ខមួយ ៗ មាន បី ៗ ។ ព្រោះហេតុនោះ ពាក្យថា* ***ឧក្ខ*** *បណ្ឌិត គប្បីប្រកប ក្នុងគ្រប់ ៗ បទថា* ***ឧក្ខិត្ត ចាតុទ្ទសី ឧក្ខិត្ត បញ្ចទសី ឧក្ខិត្ត អដ្ឋមី*** *ដូច្នេះ" ។*

ពណ៌នាអំពីកម្មដែលមិនមានទោស

*ដីកាកយកេវវសូត្រនោះ ថា " ២ បទថា **បឋមទិវសតោ បកូតិ** គឺ ចាប់ដើមអំពីថ្ងៃ ១ រោច ជាដើមទៅ " ។*

*តិថីទី ៥ មិនបានមកហើយ ក្នុងបាលី ក៏ពិតមែនហើយ, ប៉ុន្តែ តិថី ទី៥ នោះ ក៏គប្បីកំណត់យក ដោយពិត ព្រោះភាវៈជាថ្ងៃដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានតាំងទុកហើយ ។ សេចក្តីនេះ នឹងមានជាក់ច្បាស់ ក្នុងមង្គលបទនេះ ថា " **កាលេន ធម្មស្សវនំ** " ដូច្នេះ ។*

ពណ៌នាអំពីកាលនៃឧទោសថ ចប់ ។

(អង្គនៃឧបោសថ ៨ យ៉ាង)

(១១១) ក៏អង្គទាំង ៨ នៃឧបោសថនោះ មានចេតនា ជាគ្រឿងវៀរចាក បាណាតិបាត ជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ដល់នាងវិសាខា ទ្រង់ត្រាស់ហើយ ក្នុងទុតិយវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ ថា ៖

"បុរស ឬ ស្រី មិនគប្បីសម្លាប់សត្ត ១ មិនគប្បីលួចទ្រព្យ ដែលម្ចាស់គេមិនបានឱ្យ ១ មិនគប្បីនិយាយកុហកគេ ១ មិនគប្បីក្រេបផឹក ន្ទវទឹកស្រវឹង ១ គប្បីវៀរចាកមេថុន ដែលមិនមែនជាសេចក្តីប្រព្រឹត្តិ ដ៏ប្រសើរ ១ មិនគប្បី

មន្តលត្ថនីបនីប្រែ

បរិភោគភោជន ក្នុងវេលារាត្រី និង ភោជន ក្នុងវេលាខុសកាល ១ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់គ្រឿងក្រអូប ១ គប្បីដេកលើគ្រែ (ដែលត្រូវប្រមាណ) ឬ កម្រាល ដែលក្រាលផ្ទាល់នឹងផែនដី ១ (បណ្ឌិតទាំងឡាយ ពោលសរសើរ) ឧបោសថ ដែលប្រកប ដោយអង្គ ៨ ន៉ុះឯង ដែលព្រះពុទ្ធទ្រង់ដល់នូវទីបំផុតទុក្ខ ទ្រង់ប្រកាសទុក [1] ហើយ " ។

បាលី ក្នុងឧបោសថសូត្រ ចប់ ។

បាលីក្នុងធម្មិកសូត្រ ក្នុងទុតិយវគ្គ នៃសុត្តនិបាត ក៏យ៉ាងដូច្នោះដែរ ។

*(១១២) អដ្ឋកថា នៃធម្មិកសូត្រ ថា " បណ្តាបទទាំងនោះ បទថា **អព្រហ្មចរិយា** គឺ ដែលជាសេចក្តីប្រព្រឹត្តិ មិនប្រសើរ ។ បទថា **មេថុនា** គឺ ចាកការដល់ព្រម នៃមេថុនធម្ម " ។*

*អដ្ឋកថាឈ្មោះកង្ខាវិតរណី ថា " ២ បទថា **មេថុនំ ធម្មំ** បានដល់ ធម៌ របស់បុគ្គល ២ នាក់ ដែលស្មើគ្នា ដោយការរាលដាលឡើង នៃសេចក្តីតម្រេក " ។*

ដីកានៃកង្ខាវិតរណីនោះ ថា " ធម៌នេះ ជាធម៌របស់បុគ្គល

---

[1]- សុត្តន្តបិដក ភាគទី ៤១ ទំព័រទី ១៨២ ។

គូគ្នាទាំងឡាយ ព្រោះដល់ការៈដូចគ្នា ដោយការរាលដាលឡើងនៃរាគៈ ព្រោះហេតុនោះ ធម្មិទ្ធុ:ឯង ព្រះមានព្រះភាគទ្រង់ត្រាស់មេថុន ហេតុនោះ ព្រះអដ្ឋកថាចារ្យ ពោលថា ***រាគបរិយុដ្ឋានេន*** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* ***រាគបរិយុដ្ឋានេន*** *ប្រែថា ដោយការរាលដាលឡើងនៃរាគៈ ។ អធិប្បាយថា ដោយភាពជាអ្នកមានចិត្ត ត្រូវសេចក្តីប្រព្រឹត្តិទៅ នៃសេចក្តីត្រេកត្រអាល ក្នុងមេថុន រួបរឹតហើយ ។ អជ្ឈាចារ (គឺការប្រព្រឹត្តិល្មើសប្រពៃណី) ឈ្មោះថា ធម្ម ” ។*

ដីកានៃចូឡហត្ថិបទោបមសូត្រថា “ ធម្មនេះ ជាធម្មរបស់បុគ្គលដែលគូគ្នាទាំងឡាយ គឺ ជាគូ ៗ ដោយអាការដែលពោលមកហើយ ហេតុនោះ ទើបឈ្មោះថា មេថុន ” ។

(១១៣) អដ្ឋកថាធម្មិកសូត្រ ថា “ បាទគាថា ថា ***រត្តឺ ន ភុញ្ជេយ្យ វិកាលភោជនំ*** *មានសេចក្តីថា មិនគប្បីបរិភោគ ទាំងក្នុងវេលារាត្រី, មិនគប្បីបរិភោគភោជនកន្ទងហួសពេលទៅហើយ ទាំងក្នុងវេលាថ្ងៃ ។ សូម្បីវត្ថុទាំងឡាយ មានលំអិតគ្រឿងលាបជាដើម បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់កំណត់យកហើយ ដោយគន្ធសពូ ក្នុងពាក្យថា* ***ន ច គន្ធំ*** *ដូច្នេះជែរ ។ បទថា* ***មញ្ចេ*** *គឺ គ្រែដែលសមគួរ ។ បទថា* ***សន្ថតេ*** *បានដល់*

មន្តលត្ថនីបនីប្រែ

ដែលបុគ្គលក្រាលហើយ ដោយគ្រឿងកម្រាលដែលសមគួរ មានកន្ទេលទន់ៗ ជាដើម ។ មួយទៀត (ការដែលទទួលទានដំណេក) លើផែនដី សូម្បីក្រាលហើយ ដោយសំពត់រោមសត្វជាដើម ក៏សមគួរ " ។

(១១៤) អដ្ឋកថាឧបោសថសូត្រថា "បាទគាថា ថា **មញ្ចេ ធមាយំ រ សយេថ សន្ថតេ** មានសេចក្តីថា គប្បីដេក លើគ្រែដែលសមគួរ ដែលមានជើងប្រមាណមួយគក់ ឬ លើផែនដីដែលបូកលាប ដោយកំបោរពណ៌-ស ជាដើម ឬ លើទីកម្រាលដែលគេក្រាលស្មៅ ស្ជឹកឈើ និង ចំបើង ជាដើម ហើយធ្វើទុក " ។

អដ្ឋថាធម្មិកសូត្រថា " បទថា **អន្ឋន្ត្ពំ** គឺ មិនរួចផុតអំពីអន្ត ៨ ដូចជាតន្ត្រី ដែលប្រកបដោយអន្ត ៨ ប្រការដូច្នោះ ។ បទថា **ទុក្ខន្តគុនា** គឺ អ្នកដល់នូវទីបំផុត នៃវដ្តទុក្ខហើយ " ។

(១១៥) អដ្ឋកថា នៃឧទូកបាឬ: ថា " បណ្តាអន្តទាំងនោះ ចេតនា ជាហេតុកន្ធងឬាន: ដោយប្រាថ្នានឹងសេពអសទ្ធម្ម ដែលប្រព្រឹត្តទៅ តាមកាយទ្វារ ឈ្មោះថា កិរិយាប្រព្រឹត្តិមិនប្រសើរ " ។

ដីកាព្រហ្មជាលសូត្រ ថា " ចេតនា ដែលញ្ចាំងការដល់ចំពោះមគ្គដោយមគ្ត ឲ្យកើតឡើង ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយប្រាថ្នានឹងសេព នូវអសទ្ធម្ម ឈ្មោះថា កិរិយាប្រព្រឹត្តិ មិន

ពណ៌នាអំពីកម្មដែលមិនមានទោស

ប្រសើរ ។ អព្រហ្មចរិយ: នោះ មានអង្ត ២ គឺ ចិត្ត ប្រកប ដោយភាពជាអ្នកប្រាថ្នានឹងសេព ១ ការញ្ចាំងមគ្ត ដោយមគ្ត ឲ្យ ដល់គ្នា ១ " ។

អដ្ឋថាឈ្មោះកង្ខាវិតណីថា " អព្រហ្មចរិយ: នោះ មាន អង្ត ២ គឺ ចិត្តគិតនឹងសេព ១ ការញ្ចាំងមគ្ត៲ឲ្យដល់មគ្ត ១ " ។

អដ្ឋកថាខុទ្ទកបាឋ: ថា " អព្រហ្មចរិយ: មាន អង្ត ៤ គឺ វត្ថុដែលគប្បីប្រព្រឹត្តកន្ងង (គឺមគ្តទាំងបី) តែងមាន ១ ចិត្តគិត នឹងសេព ក្នុងអជ្ឈាចរណីយវត្ថុនោះ ជាធម្មជាតិប្រាកដហើយ ១ សេចក្តីព្យាយាម ដែលជាបច្ចយនៃការសេព រមែងដល់ព្រម ១ សេចក្តីត្រេកអរ ១ " ។

(១១៦) មគ្តទាំងឡាយ ៣០ ឈ្មោះថា អជ្ឈាចរណីយវត្ថុ ។ សមដូចជាពាក្យ ដែលព្រះអដ្ឋកថាចារ្យ បានពោលហើយ ក្នុង អដ្ឋកថាឈ្មោះកង្ខាវិតរណីថា "ក៏ស្ត្រី មាន ៣ ពួក ដោយអំណាច នៃស្ត្រីដែលជាមនុស្ស អមនុស្ស និង សត្វតិរច្ឆានញ្ចី, មគ្ត របស់ ស្ត្រីមនុស្ស អមនុស្ស និង សត្វតិរច្ឆាន ទាំងនោះ ចែកជាមួយ ពួក ៗ មាន ៣ ៗ ដោយអំណាច វច្ចមគ្ត បស្សាវមគ្ត និង មុខ-មគ្ត ត្រូវជា ៩ ។ មគ្ត របស់ពួកខភតោព្យញ្ជនក: ទាំងឡាយ ក៏យ៉ាងដូច្នោះដែរ ។ ចំណែក មគ្ត របស់បុរសទាំងឡាយ ចែកជា

ពួកមួយៗ មាន ២ ៗ ដោយអំណាច វចីមគ្គ និង មុខមគ្គ ត្រូវជាមគ្គ ៦ ។ មគ្គ របស់ពួកបណ្ណាក ក៏យ៉ាងដូច្នោះដែរ រួមត្រូវជាមគ្គ ៣០ ដោយប្រការដូច្នេះឯង " ។

ពាក្យដែលសេសសល់ ដែលខ្ញុំគប្បីពោល ក្នុងសិក្ខាបទនេះ និង ក្នុងសិក្ខាបទ ទី១ ទី២ ទី៤ និង ទី៥ បណ្ឌិតគប្បីជ្រាបដោយនយដែលខ្ញុំពោលហើយ ក្នុងអាគារិយវិនយ ខាងក្រោយ ។

(១១៧) អដ្ឋថាវិកាលភោជនសិក្ខាបទ ថា " ដោយបទថា ***កាលោ*** *លោកអធិប្បាយកាលជាទីធាន់ របស់ភិក្ខុទាំងឡាយ ។ ក៏កាលនោះ ដោយកំណត់យ៉ាងទាបបំផុត គឺ ជាវេលាថ្ងៃត្រង់ ។ ព្រោះហេតុនោះ ក្នុងបទភាជន:នៃសិក្ខាបទនោះ ព្រះឧបាលី ទើបពោលថា ឈ្មោះថា វិកាល គឺ កាលបើវេលាថ្ងៃត្រង់ កន្ទងផុតទៅហើយ រហូតដល់ព្រះអាទិត្យរះឡើង ដូច្នេះ ។ សូម្បីវេលាថ្ងៃត្រង់ ក៏រមែងដល់ នូវការសង្គ្រោះ ក្នុងកាល ។ ក៏ចាប់ដើមអំពីវេលាថ្ងៃត្រង់នោះទៅ ភិក្ខុមិនអាចដើម្បីទំពា ឬក៏ ធាន់បានឡើយ, ប៉ុន្តែ ភិក្ខុ គប្បីអាច ដើម្បីនឹងផឹក (ធាន់) ដោយរួសរាន់បាន, តែភិក្ខុអ្នកមានសេចក្តីរង្គៀសសង្ស័យ មិនគួរធ្វើឡើយ " ។*

ដីកាព្រហ្មជាលសូត្រចូឡហត្ថិបទោបមសូត្រ និងឧបោសថសូត្រថា " ចាប់ដើមតាំងពីព្រះអាទិត្យរះឡើងមក រហូតដល់ពេល

ពណ៌នាអំពីកម្មដែលមិនមានទោស

ថ្ងៃត្រង់ កាលនេះ រមែងជាកាលបរិភោគ ដែលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធ ជាដើម បានសន្សំអប់រំមកហើយ, កាលផ្សេងក្រៅអំពីកាលនោះ ចាត់ជា វេលាវិកាល " ។

ដីកាមហាឋ្ឋកៈ ថា " វត្ថុដែលឈ្មោះថា ភោជនៈ ព្រោះអត្ថថា គឺបុគ្គលគប្បីបរិភោគ គឺវត្ថុដែលជាយាវកាលិក គ្រប់ប្រភេទ យ៉ាង មានយាគូ និង ភត្ត ជាដើម ។ ប្រៀបដូចជា ការបរិភោគក្នុងវេលាពេត្រី ក្នុងពាក្យថា **រត្តូបរតោ** នេះ លោកពោលថា **រត្តិ** ព្រោះលុបបទខាងក្រោយ យ៉ាងណា, ការលេបនូវភោជនៈ ចូលទៅ ក្នុងពាក្យថា **វិកាលភោជនា** នេះ លោកក៏ពោលថា **ភោជនំ** ដូច្នេះ ព្រោះលុបបទខាងក្រោយ ក៏យ៉ាងនោះដែរ ។ ការបរិភោគភោជនៈ ក្នុងវេលាវិកាល ឈ្មោះថា វិកាលភោជនៈ " ។

(១១៨) អដ្ឋកថាឈ្មោះកង្ខាវិតរណីថា "ក្នុងវិកាលភោជនសិក្ខាបទនេះ មានអង្គទាំងឡាយ ៣ នេះ គឺ ភាពជាវេលាវិកាល ១ ភាពនៃវត្ថុជាយាវកាលិក ១ ការលេបចូលទៅ ១ " ។

អដ្ឋកថាខុទ្ទកបាឋៈ ថា " វិកាលភោជនៈ មានអង្គ ៤ គឺ វេលាវិកាល ១ វត្ថុជាយាវលិក ១ ការលេបចូលទៅ ១ ភាពជាអ្នកមិនមែនជាមនុស្សឆ្កួត ១ ។ ការចំណែកអង្គសូម្បីនៃសិក្ខាបទទាំងឡាយដ៏សេស បណ្ឌិតគប្បីជ្រាប ដោយទំនងនេះដែរ " ។

មន្តលត្ថទីបនីប្រែ

ក៏អង្គថា "ភាពជាអ្នកមិនមែនជាមនុស្សឆ្ពួត" នុ៉ះប្រសើរ ។ សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា " មិនត្រូវអាបត្តិ ដល់ភិក្ខុជាអ្នកឆ្ពួត " ។

(១១៩) ចំណែកអង្គ ទី៧ មាន **នច្ចគីត** ជាដើម បណ្ឌិតគប្បីត្រួតពិនត្យមើល ដោយពិស្តារ ក្នុងអដ្ឋកថាខុទ្ទកបាឬ: និងអដ្ឋកថា ព្រហ្មជាលសូត្រ ជាដើម ។ ចំណែក ក្នុងអធិការនេះ មានសេចក្តីសង្ខេប ដូចតទៅនេះ ៖

អដ្ឋកថាព្រហ្មជាលសូត្រ និង ឧបោសថសូត្រ ថា " ក៏ កិរិយាប្រកប ដោយខ្ជូនឯងក្តី កិរិយាប្រើឲ្យគេប្រកបក្តី នូវរបាំជាដើម ការមើលនូវរបាំ ដែលគេប្រកបហើយក្តី មិនសមគួរ ដល់ភិក្ខុ ភិក្ខុនីទាំងឡាយឡើយ " ។

អដ្ឋកថាខុទ្ទកបាឬ: ថា " ក៏កាលបើបុគ្គលចូលទៅ ដោយមានបំណងនឹងមើល ហើយមើលនុ៉ះឯង, សេចក្តីល្មើស ទើបមានក្នុងសិក្ខាបទនេះ ។ តែកាលបើបុគ្គលមើលនូវការរាំជាដើម ដែលមកហើយ ក្នុងឧកាសដែលខ្ជូនឈរ អង្គុយ និង ដេកក្តី កំពុងតែដើរទៅ ឃើញរបាំជាដើម ដែលមកប៉ះគន្ធងនៃចក្ខុក្តី, សេចក្តីសៅហ្មង គប្បីមាន, សេចក្តីល្មើស មិនមានឡើយ " ។

(១២០) ជីកាព្រហ្មជាលសូត្រ ចូឡហត្ថិបទោបមសូត្រ

ពណ៌នាអំពីកម្មដែលមិនមានទោស

និង ឧបោសថសូត្រថា " ការស្តាប់ចម្រៀង ដែលមិនមែនជាសីកសត្រូវ រមែងសមគួរ ក្នុងពេលខ្លះ ។ ពិតមែនដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាខុទ្ទកបាឋ: ឈ្មោះបរមត្ថជោតិកាថា ក្ងេងចម្រៀង ដែលប្រកបដោយធម៌ ទើបសមគួរ, ធម៌ដែលប្រកប ដោយក្ងេងចម្រៀង មិនសមគួរទេ " ដូច្នេះ ។

ពិតមែន ការដែលស្តាប់ក្ងេងចម្រៀង ដែលមិនមែនជាសីកសត្រូវ រមែងសមគួរ ។ ហេតុនោះ ក្នុងអដ្ឋកថាសក្ខបញ្ញ-សូត្រ ទើបលោកពោលថា " កាលបើបុគ្គលស្តាប់ នូវសំឡេងសូម្បីដែលមានអក្ខរ:ដ៏វិចិត្រ និង មានព្យញ្ជន:ដ៏វិចិត្រ ណាមួយ, កិលេសទាំងឡាយមានរាគ: ជាដើម រមែងកើតឡើង, សំឡេងដូច្នោះនោះ បុគ្គលមិនគួរសេព ។ ប៉ុន្តែបើបុគ្គលស្តាប់នូវសំឡេងដែលអាស្រ័យអត្ត អាស្រ័យធម៌ សូម្បីជាក្ងេងចម្រៀង របស់នាងកុម្ភទាសី, សេចក្តីជ្រះថ្លារមែងកើតឡើងបាន ឬ សេចក្តីធុញទ្រាន់ រមែងប្រាកដ, សំឡេង យ៉ាងដូច្នោះនោះ បុគ្គលគួរសេព" ។

(១២១) ដីកាសក្ខបញ្ញសូត្រនោះ ថា " ព្រះអដ្ឋកថាចារ្យ សំដៅយកក្ងេងចម្រៀង ដែលប្រាកដឡើង ដោយការ:នៃក្ងេងចម្រៀងដែលពីរោះចាប់ចិត្ត ដោយអំណាចនៃការកំណត់ ដែលប្រព្រឹត្តទៅ យ៉ាងដូច្នោះ ព្រោះការ:ជាទីប្រជុំ នៃក្ងេងចម្រៀង

មន្តលត្ថទីបនីប្រែ

ដែលវិច្រិត ដោយអំណាចនៃការនិពន្ធនូវពាក្យកំណាព្យ និង ភ្ជង ចម្រៀង មានភ្ជងចម្រៀង របស់អ្នករបាំជាដើម និង ដោយ អំណាចនៃការច្រៀងជូនដំណើរ ទើបពោលថា **យំ ចិត្តក្ខរចិត្ត-ព្យញ្ជានម្បិ** ... **ខប្បជ្ជន្តិ** ដូច្នេះ ។ បទថា **អត្តនិស្សិតំ** គឺ ដែល អាស្រ័យប្រយោជន៍ ដែលប្រព្រឹត្តទៅ ក្នុងភពខាងមុខ ។ បទថា **ធម្មនិស្សិតំ** គឺ អាស្រ័យធម៌ ដែលមិនត្រឡប់វិញ (ព្រះនិព្វាន) ។ ការជឿ ក្នុងព្រះរតនត្រ័យក្តី ការជឿ ក្នុងកម្ម និង ផល នៃកម្មក្តី ឈ្មោះថា សេចក្តីជ្រះថ្លា ។ បទថា **និព្វិទា វា** គឺ ឬថា សេចក្តី ធុញទ្រាន់ចាកវដ្ត: ដោយអំណាចអនិច្ចសញ្ញា ជាដើម " ។

ចំណែកពាក្យណា ដែលលោកបានសរសេរទុកហើយ ក្នុង គម្ពីរអដ្ឋកថាខុទ្ទកបាឋ: ថា " ក៏ក្នុងអង្ត ទី៧ នេះ ភ្ជងចម្រៀង សូម្បីដែលប្រកបដោយធម៌ក្តី រមែងមិនសមគួរ, ចំណែកធម៌ ដែលប្រកប ដោយភ្ជងចម្រៀង ទើបសមគួរ " ដូច្នេះ ។ ពាក្យ នោះ រមែងមិនសម នឹងពាក្យដែលលោកនាំយកមកហើយ ក្នុង ជីកានៃព្រហ្មជាលសូត្រ ជាដើម ។

(១២២) អដ្ឋកថាព្រហ្មជាលសូត្រ និង ខបោសថសូត្រ ថា " ទីដេក ដែលខ្ពស់ហួសប្រមាណ ឈ្មោះថា ខច្ចាសយន: ។ ទី ដេក ដែលក្រាលដោយគ្រឿងកម្រាលដែលមិនសមគួរ ឈ្មោះថា

មហាសយនៈ" ។

*ដីកាព្រហ្មជាលសូត្រ និង ឧបោសថសូត្រនោះថា "ទីដេកដែលខ្ពស់ និង ទីដេកដែលធំ ព្រះមានព្រះភាគ ទ្រង់ព្រះបំណងយកទីដេក ដែលប្រាសចាកសមណសារូប ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **ឋមាណាតិក្កន្តំ អបក្ឍិយត្ថតំ** ដូច្នេះ" ។*

អដ្ឋកថាខុទ្ទកបាឋៈ ថា " ទីដេក ដែលមិនសមគួរ និងគ្រឿងកម្រាល ដែលមិនសមគួរ ឈ្មោះថា មហាសយនៈ" ។

*ដីកាព្រហ្មជាលសូត្រជាដើមថា " សព្ទថា **ឧច្ចា** ជាសព្ទពិសេសមួយ ដែលមានសេចក្ដីស្មើនឹង **ឧច្ច** សព្ទ ។ បុគ្គលតែងដេក ក្នុងទីនុ៎ះ ហេតុនោះ ទីនុ៎ះ ឈ្មោះថា ទីជាទីដេក គឺ អាសន្ទិជាដើម ។ ក៏អាសនៈ លោកសង្គ្រោះហើយ ដោយ **សយន** សព្ទ ក្នុងបទថា **ឧច្ចាសយនមហាសយនំ** នុ៎ះ ដូច្នេះ" ។*

*(១២៣) អដ្ឋកថាចម្មក្ខន្ធកៈ ថា " អាសនៈ ដែលខ្ពស់ហួសប្រមាណ ឈ្មោះថា **អាសន្ទិ** " ។*

ព្រះបាលីសេនាសនក្ខន្ធកៈ ថា " ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតតាំងដែលមានជ្រុង ៤ សូម្បីខ្ពស់ក៏ដោយ " ។

*អដ្ឋកថាសេនាសនក្ខន្ធកៈ នោះថា "តាំងមានរាង ៤ ជ្រុងស្មើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា **អាសន្ទិកៈ**" ។*

មន្តលត្ថនីបនីប្រែ

ក៏ព្រោះព្រះបាលីថា **ឧច្ចកម្ជិ អាសន្ទិកំ** តាំងរាងវែង ដោយចំណែកមួយនុ៎ះឯង មានជើងប្រមាណ ៨ ផ្ទាប់ ទើបសមគួរ ។ មួយទៀត អាសន្ទិ ៤ ជ្រុងចតុរស សូម្បីហួសប្រមាណ ក៏គប្បីជ្រាបថា គួរ ។

ដីកាឈ្មោះវិមតិវិនោទនីថា " តាំងមានរាង ៤ ជ្រុងស្មើគ្នា ឈ្មោះថា **ចតុរស្សៃ**ប៉ាំ ។ ពាក្យថា **ឧមាណាតិក្កន្តាបិ** លោកពោលសំដៅយកតាំងដែលមានរាង ៤ ជ្រុងស្មើគ្នា ជូចគ្នាដែរ ។ ចំណែកឯតាំងដែលមានអង្គ ៧ និង តាំងដែលមានអង្គ ៥ ដែលមានរាង ៤ ជ្រុងស្មើ មានជើងខ្ពស់ មិនសមគួរទេ " ។

(១២៤) ពិតមែន ជើងគ្រែ និង ជើងតាំងមានប្រមាណ ៨ ផ្ទាប់ ដោយផ្ទាប់ នៃព្រះសុគតប៉ុណ្ណោះ ទើបសមគួរ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា " មួយទៀត ភិក្ខុកាលនឹងឲ្យគេធ្វើគ្រែ ឬ តាំងថ្មី គប្បីឲ្យគេធ្វើ ឲ្យមានជើងបានប្រមាណ ៨ ផ្ទាប់ ដោយផ្ទាប់នៃព្រះសុគត រៀរលែងតែមេគ្រែខាងក្រោយចេញ, កាលបើភិក្ខុធ្វើឲ្យខ្ពស់ លើសហួសប្រមាណនោះ ត្រូវបាចិត្តីយ៍ មានការឲ្យកាត់ចេញ ជាវិន័យកម្ម " ។

(១២៥) ក៏ព្រោះព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាកុដិការសិក្ខាបទ ក្នុងកង្ខាវិតរណី ថា " ៣ ចំអាម របស់

ពណ៌នាអំពីកម្មដែលមិនមានទោស

មជ្ឈិមបុរស ក្នុងពេលឥឡូវនេះ ឈ្មោះថា ១ ចំអាម នៃព្រះសុគត ត្រូវជា ១ ហត្ថ ១ ចំអាម ដោយហត្ថ នៃជាងឈើ " ដូច្នេះ ព្រោះហេតុនោះ ៣ ផ្នាប់ របស់មជ្ឈិមបុរស ត្រូវជា ១ ផ្នាប់ នៃព្រះសាស្តា ព្រោះហេតុនោះ ៨ ផ្នាប់ នៃសាស្តា ទើបត្រូវជា ២៤ ផ្នាប់ នៃមជ្ឈិមបុរស ។ ២៤ ផ្នាក់ នៃមជ្ឈិមបុរសនោះ ត្រូវជាមួយគក់ ។

*ព្រោះហេតុនោះ ក្នុងដីកានៃឧបោសថសូត្រ ទើបលោកពោលថា " បទថា **មុដ្ឋិហត្ថបាទកេ** គឺ មានជើងប្រមាណមួយគក់ រាប់តាំងអំពីផ្ទៃនៃបាទជើងឡើងទៅ រហូតដល់ទីបំផុត ខាងក្រោម នៃមេរ៉ៃគ្រ ។ ក៏មួយគក់ ដែលមានឈ្មោះថា ហត្ថ របស់ជាងឈើ ក្នុងពេលឥឡូវនេះ ស្មើគ្នានឹងហត្ថរបស់មជ្ឈិមបុរស ។ ក៏ព្រោះមួយផ្នាប់កន្ទុះ របស់បុរស តាមធម្មតា ត្រូវជា មួយផ្នាប់ របស់មជ្ឈិមបុរស, ចំអាម ហត្ថ លូក និង ព្យាម ក៏យ៉ាងដូច្នោះដែរ, ព្រោះហេតុនោះ បណ្ឌិតគប្បីដល់ការយល់ព្រម ក្នុងអធិការនេះថា មួយគក់ របស់មជ្ឈិមបុរស ត្រូវជា មួយគក់ មួយចំអាម នៃបុរស តាមធម្មតា " ។*

(១២៦) ចំណែកទ្រនាប់ត្រ ៨ ផ្នាប់ ដោយផ្នាប់នៃមនុស្ស (ធម្មតា) ប៉ុណ្ណោះ ទើបសមគួរ ។ ដោយហេតុនោះ ព្រះមានព្រះ

មន្តលត្ថទីបនីប្រែ

ភាគ ទើបទ្រង់ត្រាស់ ក្នុងសេនាសនក្ខន្ធក: ថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនត្រូវប្រើទ្រនាប់គ្រែដែលខ្ពស់, ភិក្ខុណា គប្បីប្រើ, ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាត ទ្រនាប់គ្រែ មិនលើសអំពី ៨ ជ្នាប់ឡើងទៅ " ។

ចំណែកក្នុងអដ្ឋកថាសេនាសនក្ខន្ធក:នោះ លោកពោលថា " ៨ ជ្នាប់ គឺ ជ្នាប់ដែលជាប្រមាណ របស់ពួកមនុស្សនុ៉ះឯង " ។

ព្រោះហេតុនោះ គ្រែ និង តាំង ដែលផ្សេងក្រៅពីអាសន្ទិ ដែលមាន ៤ ជ្រុងស្មើគ្នា មានទ្រនាប់ខ្ពស់ជាង ១ ហត្ថ ១ ចំអាម និង គ្រែ ដែលមានទ្រនាប់ខ្ពស់ជាង ៨ ជ្នាប់ ឡើងទៅ ឈ្មោះថា ទីដេកដែលខ្ពស់ហួសប្រមាណ ។ គ្រែ និង តាំង ដែលគេក្រាល ដោយកម្រាលមិនសមគួរ ជារបស់ខ្ពស់ក្តី ទាបក្តី, គ្រែ និង តាំង នោះ ឈ្មោះថា ទីដេកធំហួសប្រមាណ ។ ទីដេកខ្ពស់ និង ទីដេក ធំហួសប្រមាណ ទាំង ២ យ៉ាងនោះ រមែងមិនសមគួរ ។

ព្រោះហេតុនោះ ក្នុងអដ្ឋកថាខុទ្ទកបាឋ: ទើបលោកពោល ថា " ទីដេកខ្ពស់ និង ទីដេកធំហួសប្រមាណ សូម្បីទាំង ២ យ៉ាង នោះ រមែងមិនសមគួរ ដោយបរិយាយ ណាមួយ ដល់ភិក្ខុអ្នក ត្រេកអរ " ។

(១២៧) ក៏គ្រឿងកម្រាល ដែលមិនសមគួរ ដែលបុគ្គល

ពណ៌នាអំពីកម្មដែលមិនមានទោស

ក្រាល លើគ្រែ និង តាំង រមែងមិនសមគួរ, គ្រឿងកម្រាលផ្សេង ដទៃទៀត មិនសមគួរក៏ទេ គឺសមគួរ ។ ដោយហេតុនោះ ក្នុង អដ្ឋកថាធម្មិកសូត្រ ទើបលោកពោលថា " ក៏ការដេក លើផែនដី សូម្បីក្រាលដោយកម្រាលពេមសត្វជាដើម ក៏សមគួរ " ។

ជីកាព្រហ្មជាលសូត្រ និង ឧបោសថសូត្រថា "ក៏កាលបើ គ្រឿងទ្រនាប់ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហាមហើយ, កិរិយា ប្រើប្រាស់ នូវគ្រឿងទ្រនាប់នោះ រមែងជារបស់ដែលព្រះអង្គទ្រង់ ត្រាស់ហាមហើយដែរ ព្រោះហេតុនោះ ទើបព្រះអង្គ ទ្រង់ត្រាស់ ថា **ឧច្ចាសយនមហាសយនា** ដូច្នេះ ។ ប៉ុន្តែដោយសេចក្តី ការ រៀរចាកការអង្គុយ និង ដេក ដែលជាការប្រើប្រាស់ នូវទីដេក ខ្ពស់ និង ទីដេក ធំហួសប្រមាណនោះ បណ្ឌិតគប្បីជ្រាបថា ព្រះ អង្គ ទ្រង់ត្រាស់សម្តែងហើយ ដូច្នេះ " ។

(១២៨) ព្រោះរួមអង្គ ទី ៧ និង ទី ៨ ទាំង ២ អង្គ ចូល ជាមួយគ្នា ទើបមានអង្គ ៨ យ៉ាងដូច្នេះឯង ។ ដោយហេតុនោះ ក្នុងអដ្ឋកថាខុទ្ទកបាឋ: ទើបលោកពោលថា " អង្គទាំងឡាយ ២ ខាងដើម និង អង្គ ទី ៤ ទី ៥ ជាអង្គដែលទូទៅ ចំពោះឧបាសក និង សាមណេរទាំងឡាយ ដោយអំណាចនៃនិច្ចសីល ។ អង្គទាំង ឡាយទាំងពួង រួមទាំងអង្គ ទី៧ និង ទី៨ របស់ឧបាសក ទាំង

មន្តលត្ថទីបនីប្រែ

ឡាយ ជាអង្គមួយ ដោយអំណាចនៃឧបោសថ រៀរចាកអង្គចុងក្រោយគេបង្អស់ នៃអង្គទាំងពួង ជាអង្គទូទៅ នឹងសាមណេរទាំងឡាយ ។ តែអង្គចុងក្រោយនៃអង្គទាំងពួង ជាអង្គពិសេស ចំពោះសាមណេរទាំងឡាយ ប៉ុណ្ណោះ " ។

ចំណែកក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គ លោកពោលថា " សីលរបស់គ្រហស្ថ យ៉ាងនេះ គឺ សម្រាប់ពួកឧបាសក និង ឧបាសិកាមានសិក្ខាបទ ៥ ដោយអំណាចជានិច្ចសីល, ឬ កាលបើមានសេចក្តីព្យាយាម, ក៏គប្បីរក្សាទាំង ១០ សិក្ខាបទ, មានសិក្ខាបទ ៨ ដោយអំណាចជាអង្គនៃឧបោសថ " ។

*ជីកាគម្ពីរ ឈ្មោះវិសុទ្ធិមគ្គនោះ ថា " ២ បទថា **សតិ រ៉ា ឧស្សាហេ** គឺ កាលបើសេចក្តីព្យាយាម ដើម្បីនឹងព្យាយាមហើយ រក្សានូវសីល មាន ។ ដោយបទថា **ទស** ព្រះពុទ្ធឃោសាចារ្យ ពោលនូវសីល ដែលសាមណេរទាំងឡាយគប្បីរក្សា ដូចជាសីលរបស់យជិការឧបាសក ដូច្នោះជាដើម " ។*

ក្នុងជីកាមហាឧន្ធក:កែ ថា "ក៏ពាក្យណា ដែលលោកពោលហើយ ក្នុងអដ្ឋកថា ឈ្មោះឧទ្ទកបាឋ:នេះថា ប៉ុន្តែអង្គចុងក្រោយនៃអង្គទាំងពួង ជាអង្គដ៏ពិសេស សម្រាប់សាមណេរទាំងឡាយ ប៉ុណ្ណោះ ដូច្នេះ, ពាក្យនេះ រមែងមិនសម ដោយពាក្យនេះថា ឬ

ពណ៌នាអំពីកម្មដែលមិនមានទោស

កាលបើមានការព្យាយាម, ក៏គួរក្សាទាំង១០ សិក្ខាបទ ដូច្នេះ" ។

ពណ៌នាអំពីអង្គ ៨ ចប់ ។

(១២៩) អដ្ឋកថាឧបោសថសូត្រ ថា " ក៏បុគ្គលកាលនឹងក្សា នូវឧបោសថសីលនោះ គប្បីតាំងចិត្ត ថា ក្នុងថ្ងៃស្អែកនេះ អាត្មាអញ នឹងជាអ្នកក្សាឧបោសថ ដូច្នេះហើយ គប្បីចាត់ចែងនូវការងារ មានការចាត់ចែងអាហារជាដើម ក្នុងថ្ងៃនេះ ឲ្យស្រេចតែម្តង ដោយប្រាប់ថា ពួកអ្នកគប្បីធ្វើកិច្ចការនេះផង នុ៎ះផង ។ ក្នុងថ្ងៃឧបោសថ គប្បីបញ្ចេញសំឡេង សមាទានអង្គនៃឧបោសថទាំងឡាយ ក្នុងសំណាក់នៃភិក្ខុ ឬ ភិក្ខុនី នៃឧបាសក ឬ ឧបាសិកា អ្នកដឹងនូវលក្ខណៈសីល ១០ តាំងពីព្រលឹមស្រាង ។ ប៉ុន្តែកាលបើមិនចេះបាលី គប្បីអធិដ្ឋានថា អាត្មាអញ អធិដ្ឋានទូវឧបោសថដែលព្រះពុទ្ធ ទ្រង់បញ្ញត្តទុកហើយ ដូច្នេះ ។ កាលបើមិនបានអ្នកជទ្រ គប្បីអធិដ្ឋាន ដោយខ្លួនឯងក៏បានដែរ, តែគប្បីធ្វើការបញ្ចេញវាចាដោយពិត ។ កាលក្សានូវឧបោសថ មិនគប្បីចាត់ចែងការងារ ដែលទាក់ទង ដោយការបៀតបៀនអ្នកជទ្រឡើយ ។ គប្បីធ្វើការរាប់អាយុ និង វ័យ ញ្ចាំងពេលវេលាឲ្យកន្ធងផុតទៅ, មួយទៀត គប្បីជាអ្នក ដូចជាភិក្ខុអ្នកមានកត្តជាប្រចាំ បានអាហារ ក្នុងផ្ទះ បរិភោគស្រេចហើយ គប្បីទៅវត្ត ស្តាប់ធម៌, ឬ គប្បីធ្វើទុក

មន្ថលត្ថទីបនីប្រែ

ក្នុងចិត្ត អារម្មណ៍ណាមួយ បណ្តាអារម្មណ៍ទាំង ៣៨ ប្រការ " ។

(១៣០) ដីកានៃឧបោសថសូត្រនោះថា " ចាត់ដើមអំពីការសមាទានសីល អ្នករក្សាឧបោសថ មិនគួរធ្វើកិច្ចការ ដទៃទៀត គប្បីញុាំងពេលវេលា ឲ្យកន្ងងផុតទៅ ដោយការស្តាប់ធម៌ ឬ ធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋាន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ***តម្បន ឧបវសន្តេន*** *។ល។* ***វិចារេតព្វំ*** *ដូច្នេះ ។ ក្នុង ២ បទថា* ***រាចំ ភិនូិត្វា*** *គប្បីជ្រាបវិនិច្ចយ ដូចតទៅនេះ អ្នករក្សាឧបោសថ គប្បីធ្វើការកំណត់កាល ថា (អាត្មាអញ នឹងរក្សា នូវឧបោសថ) អស់យប់នេះ និង ថ្ងៃនេះ ដូច្នេះហើយ ធ្វើដោយការរួមជាមួយគ្នា ដោយអំណាចអង្គឧបោសថថា អាត្មាអញសមាទាន នូវសិក្ខាបទទាំង ៨ យ៉ាងដូច្នេះហើយ គប្បីធ្វើការបញ្ចេញវាចាសមាទានអង្គឧបោសថ ជាបច្ចេកសមាទាន (ចំពោះអង្គ) តាមបាលី យ៉ាងនេះថា* ***បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ*** *។ល។* ***ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ*** *ដូច្នេះ ។ ប៉ុន្តែកាលបើមិនចេះបាលី គប្បីសមាទានជាបច្ចេកសមាទាន តាមភាសា របស់ខ្លួន ឬ ដោយអំណាចការអធិដ្ឋាន ដោយរួមគ្នាថា អាត្មាអញ អធិដ្ឋានឧបោសថ ដែលព្រះពុទ្ធ ទ្រង់បានបញ្ញត្តទុកហើយ ដូច្នេះ ។ បើមិនបានអ្នកដទៃ គប្បី*

ពណ៌នាអំពីកម្មដែលមិនមានទោស

អធិដ្ឋាន ដោយខ្លួនឯងក៏បាន ។ ពិតមែន សីល របស់ឧបាសក គឺបុគ្គលអ្នករក្សាឧបោសថ សមាទាន ដោយខ្លួនឯងក្តី ឈ្មោះ ថា បានសមាទានហើយ, សមាទាន ក្នុងសំណាក់ នៃបុគ្គលដទៃក្តី ឈ្មោះថា បានសមាទានហើយ, សមាទានរួមគ្នា (ជាឯកជ្ឈសមា ទាន) ក្តី សមាទាន ជាបច្ចេកសមាទាន (ចំពោះអង្គមួយៗ) ក្តី ក៏ ឈ្មោះថា បានសមាទានស្រេចហើយ ដូចគ្នាដែរ ។

សួរថា សេចក្តីខុសប្លែកអំពីគ្នា នឹងមានយ៉ាងដូចម្តេច? ។

*ឆ្លើយថា បើបុគ្គលសមាទាន ជាឯកជ្ឈសមាទាន (រួមគ្នា) វិរតি ក៏ដូចគ្នាតែមួយប៉ុណ្ណោះ, ចេតនា ក៏មានមួយដូងដូចគ្នាដែរ ។ ប៉ុន្តែ វិរតি និង ចេតនា ទាំង ២ នោះ ផ្ទើកិច្ច នៃវិរតি និង ចេតនា គ្រប់ប្រៃបយ៉ាង ព្រោះហេតុនោះ សិក្ខាបទទាំងអស់ ចាត់ទុកថា គឺ បុគ្គលអ្នករក្សាឧបោសថ បានសមាទានហើយ ដោយពិត ដោយ ការសមាទាន រួមគ្នានោះឯង ។ មួយទៀត បើបុគ្គលសមាទានជា បច្ចេកសមាទាន វិរតি និងចេតនា ដែលផ្សេងៗ គ្នា តែងកើតឡើង តាមនាទី របស់ខ្លួន ដោយអំណាចនៃកិច្ច ។ ក៏ក្នុងការសមាទាន គ្រប់យ៉ាង គប្បីធ្វើការបញ្ជាក់ថា ដោយពិតប្រាកដ ។ បទថា **ឧរោឧរោធប្បដិសំយុត្តា** គឺ ដែលជាប់ទាក់ទង ដោយការបៀត បៀនអ្នកដទៃ " ដូច្នេះ ។*

ពណ៌អំពីការសមាទានអង្គឧបោសថ ចប់ ។

មន្តលត្ថទីបនីប្រែ

(១៣១) ការសមាទានអង្គឧបោសថនោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុ នៃការកើតឡើង ក្នុងឋានសួគ៌ ជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា " ម្នាលនាងវិសាខា [1] ប្រៀបដូចបុគ្គល ឯណាមួយ គប្បីគ្រងរាជសម្បត្តិ ជាឥស្សរិយាធិបតី នៃមហាជនបទទាំង ១៦ នេះ ដែលមានរតន: ៧ ប្រការដ៏ច្រើន, មហាជនបទទាំង ១៦ គឺ អង្គ: មគធ: កាសី កោសល វជ្ជី មល្ល: ចេតី វង្ស: កុរុ បញ្ចាល: មច្ច: សុរសេន: អស្សក: អវន្ទី គន្ធារ: កម្ពោជ:, ការគ្រងរាជសម្បត្តិនុ៉ះ របស់បុគ្គលនោះ មិនមានតម្លៃ ស្មើនឹងចំណិត ទី១៦ ៗ នៃឧបោសថ ដែលប្រកបដោយអង្គ ៨ ឡើយ ។ ដំណើរនោះព្រោះហេតុអ្វី? ។ ម្នាលនាងវិសាខា រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខ ដែលជាទិព្ធ (ឃើញ) ស្ពួចស្តើងណាស់ ។

ម្នាលនាងវិសាខា ៥០ ឆ្នាំ របស់មនុស្ស ត្រូវជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់ចាតុម្មហារាជិក:, រាប់រាត្រីនោះ ៣០ រាត្រី ជាមួយខែ, រាប់តាមខែនោះ ១២ ខែ ជាមួយឆ្នាំ, រាប់តាមឆ្នាំនោះ ៥០០ ឆ្នាំទិព្ធ ជាប្រមាណនៃអាយុ របស់ពួកទេវតា ជាន់ចាតុម្មហារាជិក: ។ ម្នាលនាងវិសាខា ក៏ហេតុនុ៉ះឯង រមែងមាន

១- សុត្តន្តបិដក ភាគទី ៤១ ទំព័រទី ២៧៨ ។

ពណ៌នាអំពីកម្មដែលមិនមានទោស

ប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬ បុរសពួកខ្ញុះ ក្នុងលោកនេះ រក្សាឧបោសថប្រកបដោយអង្ត ៨ ហើយ លុះដល់ទម្ងាយរាងកាយ ស្ងាប់ទៅ កើតរួមជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិក: ។

ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការកើតរួម ជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិក: ន៉ុះឯង ទើបបានពោលពាក្យនេះ ថា រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខដ៏ជាទិព្ធ (យើញ) ស្ពួចស្តើងណាស់ ។

ម្នាលនាងវិសាខា ១០០ ឆ្នាំ របស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតា ជាន់តាវត្តិង្ស ។ល។ រាប់តាមឆ្នាំនោះ ១,០០០ ឆ្នាំទិព្ធ ជាប្រមាណនៃអាយុ របស់ពួកទេវតា ជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬ បុរសពួកខ្ញុះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយអង្ត ៨ ហើយ លុះដល់ទម្ងាយរាងកាយ ស្ងាប់ទៅ កើតរួម ជាមួយនឹងពួកទេវតា ជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការកើតរួមជាមួយទេវតា ជាន់តាវត្តិង្សទាំងឡាយន៉ុះឯង ទើបពោលពាក្យនេះថា រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខដ៏ជាទិព្ធ (យើញ) ស្ពួចស្តើងណាស់ ។

ម្នាលនាងវិសាខា ២០០ ឆ្នាំ របស់មនុស្ស ជាមួយយប់

មន្ទលត្ថទីបនីប្រែ

មួយថ្ងៃ របស់ពួកទេវតា ជាន់យាម: ។ល។ រាប់តាមឆ្នាំនោះ ២,០០០ ឆ្នាំទិព្ធ ជាប្រមាណអាយុ នៃពួកទេវតា ជាន់យាម: ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬ បុរសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយ អង្ត ៨ ហើយ លុះដល់ទម្លាយរាងកាយ ស្លាប់ទៅ កើតរួមជា មួយនឹងពួកទេវតា ជាន់យាម: ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការទៅកើត រួមជាមួយនឹងពួកទេវតា ជាន់យាម:ន៉ុះឯង ទើបបានពោលថា រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹង សេចក្តីសុខ ដ៏ជាទិព្ធ (ឃើញ) ស្ត្ងួចស្តើងណាស់ ។

ម្នាលនាងវិសាខា ៤០០ ឆ្នាំ របស់មនុស្ស ជាមួយយប់ មួយថ្ងៃ របស់ពួកទេវតា ជាន់តុសិត ។ល។ រាប់តាមឆ្នាំនោះ ៤,០០០ ឆ្នាំទិព្ធ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តុសិត ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬ បរុសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយ អង្ត ៨ ហើយ លុះដល់ទម្លាយរាងកាយស្លាប់ទៅ កើតរួមជា មួយនឹងពួកទេវតា ជាន់តុសិត ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការទៅកើតរួម ជាមួយនឹងពួកទេវតា ជាន់តុសិតន៉ុះឯង ទើបបានពោល ថា រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹង

ពណ៌នាអំពីកម្មដែលមិនមានទោស

សេចក្តីសុខ ដ៏ជាទិព្ធ (យើញ) ស្ពួចស្តើងណាស់ ។

ម្នាលនាងវិសាខា ៨០០ ឆ្នាំ របស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតា ជាន់និម្មានរតី ។ល។ រាប់តាមឆ្នាំនោះ ៨,០០០ ឆ្នាំទិព្ធ ជាប្រមាណអាយុ នៃពួកទេវតា ជាន់និម្មានរតី ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬ បុរសពួកខ្ងះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយអង្ត ៨ ហើយ លុះដល់ទម្ងាយរាងកាយស្ងាប់ទៅ កើតរួមជាមួយនឹងពួកទេវតា ជាន់និម្មានរតី ។ ម្នាលនាងវិសាខា ក៏តថាគតសំដៅយកការទៅកើត រួមជាមួយនឹងពួកទេវតា ជាន់និម្មានរតីន៉ុះឯង ទើបបានពោលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធ្រៀបនឹងសេចក្តីសុខ ដ៏ជាទិព្ធ (យើញ) ស្ពួចស្តើងណាស់ ។

ម្នាលនាងវិសាខា ១,៦០០ ឆ្នាំ របស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតា ជាន់បរនិម្មិតវសវត្តី, រាប់តាមរាត្រីនោះ ៣០ រាត្រី ជាមួយខែ, រាប់តាមខែនោះ ១២ ខែ ជាមួយឆ្នាំ, រាប់តាមឆ្នាំនោះ ១៦,០០០ ឆ្នាំទិព្ធ ជាប្រមាណនៃអាយុ របស់ពួកទេវតា ជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬ បុរសពួកខ្ងះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយអង្ត ៨ ហើយ លុះដល់ទម្ងាយរាង

មន្តលត្ថទីបនីប្រែ

កាយស្ងាប់ទៅ កើតរួមជាមួយនឹងពួកទេវតា ជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការទៅកើត រួមជាមួយពួកទេវតា ជាន់បរនិម្មិតវសវត្តី នុ៉ះឯង ទើបបានពោលថា រាជ-សម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខ ដ៏ជាទិព្ធ (ឃើញ) ស្ពួចស្តើងណាស់ ។

បាលី ឧបោសថសូត្រ ចប់ ។

(១៣២) អដ្ឋកថានៃឧបោសថសូត្រនោះថា "បទថា ***បហូតរត្តរតនានំ*** *គឺ ប្រកបដោយរតន: ពោលគឺ វត្ថុដែលញ្ជាំងសេចក្តីត្រេកអរឲ្យកើតដ៏ច្រើន ។ អធិប្បាយថា ពេញដោយរតន:ទាំង ៧ ប្រការ មានប្រមាណត្រឹមចង្កេះ ធ្វើផ្ទៃជម្ពូទ្វីបទាំងមូល ឲ្យដូចជាផ្ទៃនៃស្ពរ ។ បទថា* ***ឥស្សរិយាធិបច្ចំ*** *គឺ ដោយភាពជាឥស្សរ: និង ដោយភាពជាអធិបតី, មិនមែន ដោយភាពជាព្រះរាជា ថ្នាក់ទាបទេ ។ ម៉ាងទៀត ភាពជាអធិបតី គឺ ភាពឥស្សរ: ឈ្មោះថាឥស្សរាអធិបតី ព្រោះក្នុងរាជសម្បត្តិនេះ មិនមានកម្មដែលប្រព្រឹត្តដោយសេចក្តីគំរាមកំហែង ។ ២ បទថា* ***រជ្ជំ ការេយ្យ*** *គឺ គប្បីគ្រងចក្រពត្តិរាជ យ៉ាងនោះ ។ ពាក្យថា* ***អន្តានំ*** *ដូច្នេះជាដើម ជាឈ្មោះនៃជនបទទាំងនោះ ។ ច្រើនបទថា* ***កលំ នាគ្ឆតិ សោឡសឹ*** *មានសេចក្តីថា បុណ្យនៃឧបោសថ ដែលបុគ្គលរក្សា អស់ថ្ងៃមួយ*

ពណ៌នាអំពីកម្មដែលមិនមានទោស

និង យប់មួយ ។ រមែងមិនដល់នូវចំណែកមួយ ចាកចំណែក ទី ១៦ នោះ ព្រោះបែងចែកឲ្យទៅជា ១៦ ចំណែក ។ អធិប្បាយថា ផល គឺវិបាក នៃចំណែក ទី១៦ នៃខុបោសថ អស់រាត្រីមួយណា, ផល គឺវិបាក នៃចំណែក ទី១៦ នៃខុបោសថ អស់រាត្រីមួយនោះ ឯង ជាផលច្រើន ជាងចក្រពត្តិរាជនោះ ។ បទថា **កឋណ** គឺ បន្ទិចបន្ទួច "។

(១៣៣) ដីកានៃខុបោសថសូត្រនោះ ថា " **រតន** សព្ទ ជា បរិយាយ នៃ **រតន** សព្ទ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើប ពោលថា បទថា **ឧហូតរត្តរតនានំ** គឺ ប្រកបដោយរតនៈ ពោល គឺ រត្ថដែលញ្ជាំងសេចក្តីត្រេកអរ ឲ្យកើតដ៏ច្រើន ។ ប៉ុន្តែ ក្នុងព្រះ បាលី បាឋៈ ថា **ឧហូតសត្តរតនានំ** ដូច្នេះ តែងប្រាកដមានខ្ទះ ។ ២ បទថា **ភេរិតលសទិសំ កត្វា** គឺ ធ្វើឲ្យស្មើ ដូចជាផ្ទៃនៃស្គរ ។ ច្រើនបទថា **តតោ ឯកំ ភាគំ ន អគ្ឆតិ** គឺ ចក្រពត្តិរាជ តាម ដែលបានពោលមកហើយ រមែងមិនដល់ នូវចំណែកមួយ ចាក ចំណែក ទី១៦ នោះ ។ ២ បទថា **តតោ ពហុតរំ** គឺ រមែងច្រើន ជាងសិរី នៃចក្រពត្តិរាជ ។ ក្នុងបទថា **ចាតុម្មហារាជិកានំ** ដូច្នេះ ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៩ លានឆ្នាំ ជាប្រមាណ នៃអាយុ របស់ពួកទេវតា ជាន់ចាតុម្មហារាជិកៈ ដោយការរាប់

មន្តលត្ថទីបនីប្រែ

របស់មនុស្ស ។ ៣ កោដិ ៦ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់តាវត្តិង្ស ។ ១៤ កោដិ ៤ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតា ជាន់យាម: ។ ៥៧ កោដិ ៦ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់តុសិត ។ ២៣០ កោដិ ៤ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតា ជាន់និម្មានរតី ។ ៩២១ កោដិ ៦ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតា ជាន់បរនិម្មិតវសវត្តី" ។

(រឿង បុរោហិត)

(១៣៤) កន្នុអតីតកាល ព្រះពោធិសត្ត សោយព្រះជាតិជាព្រះរាជាក្រុងពារាណសី ព្រះអង្គមិនទ្រង់ប្រមាទ ដោយព្រះអង្គ ឯង ក្នុងទាន សីល និង ឧបោសថកម្ម ទ្រង់បបួលអាមាត្យ ជាដើម សូម្បីដែលសេសសល់ ក្នុងទានជាដើម ។ ចំណែកបុរោហិត របស់ព្រះពោធិសត្វនោះ ត្រូវព្រះពោធិសត្ត តែងតាំងហើយ ក្នុងតំណែងវិនិច្ឆ័យ ជាអ្នកស៊ីសាច់ធ្អឹងឧង របស់ជនដទៃ ដោយការស៊ីសំណូក ទើបមិនសមាទាន ។ នៅក្នុងថ្ងៃឧបោសថ ថ្ងៃមួយ បុរោហិតនោះ ទទួលសំណូក កាត់ក្តីកោង រហូតមួយថ្ងៃ ហើយ បានទៅកាន់ទីឧបដ្ឋានព្រះរាជា ត្រូវព្រះរាជាត្រាស់សួរថា "ម្នាលអាចារ្យ លោក រក្សាឧបោសថឬ?" ដូច្នេះហើយ ក្រាបទូលកុហក

ពណ៌នាអំពីកម្មដែលមិនមានទោស

ថា " ពិតមែនហើយ ព្រះអង្គដ៏ចម្រើន " ហើយ ក៏បានចុះអំពីប្រាសាទ ។ គ្រានោះ អាមាត្យម្នាក់ ចោទបុរោហិតនោះថា "លោកជាអ្នកមិនរក្សាឧបោសថ មិនមែនទេឬ?" ។ បុរោហិតនោះ ពោលថា " ខ្ញុំបរិភោគ តែក្នុងវេលាតែប៉ុណ្ណោះ ទៅផ្ទះហើយ ខ្ពុរមាត់ស្រេច នឹងអធិដ្ឋាននូវឧបោសថ មិនបរិភោគ ក្នុងវេលាល្ងាច, ខ្ញុំនឹងរក្សាសីល ក្នុងវេលារាត្រី, បើដូច្នេះ ឧបោសថកម្ម ពាក់កណ្តាល នឹងមានដល់ខ្ញុំ " ដូច្នេះហើយ ក៏ទៅផ្ទះ បានធ្វើហើយយ៉ាងដូច្នោះឯង ។ ក្នុងថ្ងៃឧបោសថ ថ្ងៃមួយទៀត ស្ត្រី អ្នកមានសីលម្នាក់ កំពុងកាត់សេចក្តី កាលមិនបាន ដើម្បីនឹងទៅផ្ទះបានក៏គិតថា "អាត្មាអញ នឹងមិនកន្ងង នូវឧបោសថកម្ម" ដូច្នេះ, កាលបើវេលា ចូលខិតមកជិតហើយ, ក៏បានប្រារព្ធ ដើម្បីនឹងលាងមាត់ ។ បុរោហិតនោះ ដឹងថា ស្ត្រីនោះ ជាអ្នករក្សាឧបោសថ ទើបពោលថា "ចូរនាងបរិភោគផ្ទែស្ងាយនេះ ហើយរក្សាឧបោសថចុះ" ហើយក៏បានឲ្យផ្ទែស្ងាយដល់ស្ត្រីនោះ ។ កម្ម របស់បុរោហិតមានតែប៉ុណ្ណេះ ។ ក្នុងកាលក្រោយមក បុរោហិតនោះ បានធ្វើមរណកាលហើយ បានកើតជាវេមានិកប្រេត មាននាងទេវកញ្ញា ១ ម៉ឺន ៦ ពាន់ ចោមរោមហើយ ក្នុងវិមានមាស ក្នុងព្រៃស្ងាយប្រវែង ៣ យោជន៍ ក្បែរមាត់ទន្ងេគង្គា ក្នុងព្រៃហិមវន្តប្រទេស ។

មន្ទលត្ថទីបនីប្រែ

ក៏វេមានិកប្រេតនោះ សោយសម្បត្តិ តែក្នុងវេលារាត្រីប៉ុណ្ណោះ, កាលបើព្រះអរុណរះឡើង, ក៏ចូលទៅកាន់ព្រៃស្វាយ ។ ក្នុងពេលដែលវេមានិកប្រេតនោះ ចូលទៅនុ៉ះឯង, អត្តភាពដែលជាទិព្ធ ក៏អន្តរធានបាត់ទៅ, អត្តភាព មានទំហំប៉ុនដើមត្នោត ប្រវែង ៨០ ហត្ថ ក៏កើតឡើង ។ សរីរៈទាំងអស់ ត្រូវភ្ជើងឆេះ បានដូចជាផ្ការលួសផ្អុង (ផ្ការចារ) ដែលរីកក្រហមច្រាល ។ ក្នុងដៃទាំង ២ មានម្រាមដៃ ម្ខាងមួយៗ ប៉ុណ្ណោះ ។ លើម្រាមដៃនោះ មានក្រចកទំហំប៉ុនចបដ៏ធំ ។ វេមានិកប្រេតនោះ យកក្រចកទាំងនោះ ហែកសាច់ខ្នង របស់ខ្លួន ខ្វេះទាញមកហើយៗ ទំពាស៊ី បានទទួលសេចក្តីឈឺចាប់ ស្រែកយំក្តែងៗ សោយនូវសេចក្តីទុក្ខ ។ កាលបើព្រះអាទិត្យ អស្តង្គតទៅហើយ, សរីរៈនោះ ក៏អន្តរធានបាត់ទៅ, សរីរៈដែលជាទិព្ធ ក៏កើតឡើង ។ ស្ត្រីអ្នករបាំ ដ៏ជាទិព្ធទាំងឡាយ អ្នកប្រដាប់តាក់តែងហើយ ក៏នាំគ្នាកាន់តន្ត្រីផ្សេងៗ មកចោមរោម នូវវេមានិកប្រេតនោះ ។ វេមានិកប្រេតនោះ សោយនូវមហាសម្បត្តិ ឡើងកាន់ប្រាសាទទិព្ធ ក្នុងព្រៃស្វាយ ដែលជាទីមនោរម្យ ។ វេមានិប្រេតនោះ បានព្រៃស្វាយប្រវែង ៣ យោជន៍ ព្រោះផលនៃការឲ្យផ្ជែស្វាយ ដល់ស្ត្រីអ្នករក្សាឧបោសថ, គាត់ខ្វេះ ហែកសាច់ខ្នងស៊ី ព្រោះផលនៃការទទួលសំណូកហើយ កាត់

ពណ៌នាអំពីកម្មដែលមិនមានទោស

សេចក្ដីមិនបានយុត្តិធម៌, គាត់បានសោយ នូវយសដ៏ធំ ក្នុងវេលាយប់ ព្រោះផលនៃការរក្សានូវឧបោសថកម្ម ពាក់កណ្ដាល ដោយប្រការដូច្នេះ ។

សូម្បីព្រះសាស្ដា កាលទ្រង់សម្ដែងធម៌ ដល់ពួកឧបាសក អ្នករក្សាឧបោសថ ទើបទ្រង់ត្រាស់ថា "ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយ រក្សាឧបោសថ ធ្វើកម្មប្រសើរហើយ, បូរាណក-បណ្ឌិតទាំងឡាយ បានសោយនូវយសដ៏ធំ ព្រោះផលនៃការរក្សានូវឧបោសថកម្ម ពាក់កណ្ដាល " ដូច្នេះ ទ្រង់ញ៉ាំងរឿងនេះ ឲ្យបានពិស្ដារ ហើយទ្រង់ត្រាស់ក៏ឆន្ទជាតក ដែលជាជាតកខាងដើមនៃជាតកទាំងពួង ក្នុងតិសនិបាត ទ្រង់បានប្រកាសសច្ចៈហើយ ។ ក្នុងវេលាចប់សច្ចៈ បណ្ដាឧបាសកទាំងឡាយ ឧបាសកពួកខ្លះ បានជាសោតាបន្ន, ពួកខ្លះ បានជាសកទាគামី, ពួកខ្លះ បានជាអនាគামី ។

រឿងបុរោហិត ចប់ ។

(រឿង ព្រះរាជាព្រះនាមឧទ័យ)

(១៣៥) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី បានមានសេដ្ឋី ឈ្មោះថាសុចិបរិវារ មានទ្រព្យ ៨០ កោដិ ជាអ្នកត្រេកអរក្នុងបុណ្យ មានទានជាដើម ។ បុត្រ និង ភរិយាក្ដី ជនជាបរិវារក្ដី

មង្គលត្ថទីបនីប្រែ

របស់សេដ្ឋីនោះ ដោយហោចទៅ សម្បីអ្នកចិញ្ចឹមគោ ក្នុងផ្ទះនោះ គ្រប់គ្នាទាំងអស់ តែងរក្សានូវឧបោសថ មួយរៃ ៦ ថ្ងៃ ។

គ្រានោះ បុរស ទីទ័លក្រម្នាក់ ចិញ្ចឹមជីវិត ដោយការស៊ីឈ្នួលគេបានចូលទៅរកសេដ្ឋីនោះ ថ្វាយបង្គំរួចបានឈរហើយ ។

សេដ្ឋី សួរថា “ នែអ្នកដ៏ចម្រើន តើអ្នកមកដើម្បីអ្វី? ” ។

បុរសនោះ ឆ្លើយថា “ ខ្ញុំមក ដើម្បីបំណង នឹងធ្វើការងារ ដើម្បីថ្លៃឈ្នួល ក្នុងផ្ទះរបស់លោកសេដ្ឋី ” ។

សេដ្ឋី បានប្រាប់ ក្នុងថ្ងៃដែលពួកអ្នកស៊ីឈ្នួលឯទៀត មកហើយនុ៎ះ ថា “ អ្នកទាំងឡាយ កាលធ្វើការងារ ក្នុងផ្ទះនេះ កាលបើអាចដើម្បីរក្សាសីលបាន ចូរធ្វើការងារចុះ ” ។ តែសេដ្ឋី មិនបានធ្វើសញ្ញា ក្នុងការប្រាប់នូវការរក្សាសីល ដល់បុរសក្រីក្រនោះ ហើយ បានប្រាប់ ថា “ នែអ្នក ប្រពៃហើយ, ចូរអ្នកធ្វើការងារ តាមការចេះដឹងរបស់ខ្លួន ដើម្បីថ្លៃឈ្នួលចុះ” ។ បុរសនោះ តាំងពីពេលនោះមក ជាអ្នកដែលគេប្រដៅងាយ មិនបានទឹកគិតដល់សេចក្ដីលំបាករបស់ខ្លួន ធ្វើកិច្ចការគ្រប់ប្រែបយ៉ាង ទៅធ្វើការងារ តាំងពីព្រឹកព្រលឹម ហើយមកវិញ ក្នុងពេលល្ងាច ។

ក្រោយមកថ្ងៃមួយ សេដ្ឋី បានបញ្ជានាងទាសីថា “ថ្ងៃនេះ ជាថ្ងៃឧបោសថ, ចូរនាងដាំបាយ ឲ្យពួកកម្មករ ក្នុងផ្ទះ តាំងអំពី

ពណ៌នាអំពីកម្មដែលមិនមានទោស

ព្រឹកព្រលឹម, ពួកគេនឹងបរិភោគទាន់ពេលវេលាតែម្តង ហើយជា អ្នករក្សាឧបោសថ" ។ នាងទាសីនោះ បានធ្វើហើយយ៉ាងដូច្នោះ ។ ឯបុរស ក្រីក្រនោះ ក្រោកឡើងពីព្រលឹមហើយ ទៅធ្វើការងារ ។ អ្នកណាមួយ ក៏មិនបានប្រាប់ថ្ងៃឧបោសថ ដល់បុរសនោះដែរ ។ ជនទាំងឡាយ មានសេដ្ឋីជាដើម គ្រប់ៗ គ្នា បរិភោគ តាំងពីព្រឹក ព្រលឹម ជាអ្នករក្សាឧបោសថ អង្គុយពិចារណាសីល ក្នុងទីកន្លែង របស់ខ្លួន (រៀងខ្លួន) ។ បុរស ទីទ័លក្រ ធ្វើការងារ រហូតពេញ មួយថ្ងៃ បានត្រឡប់មកវិញ ក្នុងវេលាដែលព្រះអាទិត្យអស្តង្គត, កាលដែលគេបង្ហោនកត្តចូលមក, ទើបសួរថា " ក្នុងថ្ងៃ ដទៃទៀត (ថ្ងៃមុនៗ) ក្នុងវេលានេះ បានមានសំឡេងចៀវចាវ យ៉ាងខ្លាំង, (តែ) ថ្ងៃនេះ តើពួកគេបានទៅណា បាត់អស់ហើយ? " ។

នាងទាសី ប្រាប់ថា " នែអ្នក ពួកគេទាំងអស់គ្នា ជាអ្នក រក្សាឧបោសថ បានទៅកាន់ទីកន្លែង របស់គេរៀងៗ ខ្លួនហើយ " ។

បុរសនោះ គិតថា " ក្នុងចំណោម នៃពួកបុគ្គលអ្នកមាន សីល មានប្រមាណប៉ុណ្ណេះ អាត្មាអញ ម្នាក់ឯង នឹងមិននៅជា មនុស្សទ្រុស្តសីលឡើយ " ហើយ ទើបមិនបរិភោគកត្ត ចូលទៅ រកសេដ្ឋី ហើយសួរ ថា " បពិត្រលោកម្ចាស់ កាលបើខ្ញុំអធិដ្ឋាន ឧបោសថ ក្នុងថ្ងៃឧបោសថ ពេលនេះ, តើឧបោសថកម្ម នឹងមាន

ឬមិនមាន?" ។ សេដ្ឋីឆ្លើយថា "នែអ្នក ព្រោះអ្នកមិនបានអធិដ្ឋានតាំងអំពីព្រឹកព្រលឹម ឧបោសថកម្មទាំងអស់ ទើបមិនមាន, តែឧបោសថកម្ម ពាក់កណ្តាល នឹងមាន" ។ បុរសនោះ គិតថា "សូម្បីតែប៉ុណ្ណេះ ក៏គ្រប់គ្រាន់ ដល់អាត្មាអញដែរ " ហើយជាអ្នកសមាទានសីល ក្នុងសំណាក់ នៃសេដ្ឋី អធិដ្ឋានឧបោសថ ហើយក៏បានទៅកាន់ទីកន្លែងរបស់ខ្លួន ដេកពិចារណានូវសីលហើយ ។

គ្រានោះ ខ្យាល់ក្នុងពោះ កើតឡើងហើយ ដល់បុរសនោះ ក្នុងចន្លោះនៃបច្ឆិមយាម ព្រោះភាវៈនៃខ្លួនជាអ្នកអត់អាហារ អស់រយៈពេលពេញមួយថ្ងៃ ។ សេដ្ឋី បាននាំយកកេសជ្ជៈផ្សេងៗ មកពោលថា "ចូរអ្នកបរិភោគចុះ" ។ បុរសនោះ គិតថា "អាត្មាអញនឹងមិនទំលាយឧបោសថទេ " ហើយ ពោលថា "ខ្ញុំ នឹងសមាទានធ្វើជីវិតឲ្យមានទីបំផុត " ហើយមិនព្រមបរិភោគ ។ វេទនា ដ៏មានកម្លាំង កើតឡើងហើយ ។ បុរសនោះ មិនអាច ដើម្បីនឹងញ៉ាំងសតិឲ្យតាំងនៅបានឡើយ ក្នុងវេលាព្រះអរុណរះឡើង ។ ពេលនោះ ជនទាំងឡាយ ពោលថា " ឥឡូវនេះ បុរសនេះ នឹងស្លាប់ " ហើយ ទើបបាននាំបុរសនោះចេញមក ឲ្យដេកហើយក្នុងផ្ទះតូច ។ ក្នុងខណៈនោះ ព្រះរាជាក្រុងពារាណសី ទ្រង់ប្រទក្សិណព្រះនគរ ស្តេចយាងដល់ទីនោះ ។ បុរសទីទ័លក្រ ឃើញព្រះរាជាហើយ

ពណ៌នាអំពីកម្មដែលមិនមានទោស

ញ្ជាំងសេចក្តីលោភ ឲ្យកើតឡើង ប្រាថ្នាចង់បានរាជសម្បត្តីហើយ ក៏បានស្ងាប់ទៅ ចាប់បដិសន្ធិ ក្នុងព្រះឧទរ នៃព្រះអគ្គមហេសី របស់ព្រះរាជាអង្គនោះ ព្រោះផលនៃឧបោសថកម្ម ពាក់កណ្តាល ដោយកន្ងងទៅបាន ១០ ខែ ទើបប្រសូតចេញមក ។ ព្រះមាតានិង ព្រះបិតា ទ្រង់បានតាំងព្រះនាម ដល់ព្រះរាជកុមារនោះ ថា "ឧទ័យកុមារ" ដូច្នេះ ។ ព្រះឧទ័យកុមារនោះ ទ្រង់ចម្រើនវ័យ ហើយ ដល់នូវការសម្រេច ក្នុងសិល្បសាស្ត្រគ្រប់យ៉ាង ទ្រង់ រលឹកដល់បុព្វកម្មរបស់ព្រះអង្គបាន ដោយព្រះញាណ គឺការរព្ចកជាតិ ទើបទ្រង់បានបញ្ចេញព្រះឧទានឡើង ជារឿយៗ ថា " នេះ គឺ ជាផល នៃកម្មដែលមានប្រមាណតិចតួច របស់អាត្មាអញ " ។ ព្រះ ឧទ័យរាជកុមារអង្គនោះ ដោយកាលកន្ងងទៅនៃព្រះបិតា ទ្រង់បាន ទទួលរាជាសម្បត្តិ ប្រាកដព្រះនាមថា "ព្រះបាទឧទ័យ" ។

ឯព្រះសាស្តា កាលទ្រង់សម្តែងធម៌ ដល់ឧបាសកទាំងឡាយ អ្នករក្សាឧបោសថ ទ្រង់បានត្រាស់ថា " ម្នាលឧបាសក ទាំងឡាយ អ្នកទាំងឡាយ កាលរក្សាឧបោសថ ឈ្មោះថា បាន ធ្វើកម្មប្រសើរហើយ, ឧបារាណកបណ្ឌិត ទាំងឡាយ អាស្រ័យ ឧបោសថកម្ម ពាក់កណ្តាលមួយ បានហើយនូវយសដ៏ធំ " យ៉ាង ដូច្នេះហើយ ទ្រង់បានញ្ជាំងរឿងនេះ ឲ្យពិស្តារហើយ ទ្រង់ត្រាស់

មង្គលត្ថទីបនីប្រែ

*នូវគង្គ*មាលជាតក ។

រឿង ព្រះបាទឧទ័យ ចប់ ។

សូម្បីរឿងនៃអ្នកស៊ីឈ្នួល *ដែ*លនៅអាស្រ័យសេដ្ឋី ឈ្មោះ *អ*នាថបិណ្ឌិក ចិញ្ចឹ*ម*ជីវិត *ដោ*យការ*ស*ុ*ី*ឈ្នួ*ល* ***ប*ា*ន*** *ទ*ៅ*ក*ើ*ត* *ជ*ាទ*េ*វ*តា* *ល*ើ*ដ*ើ*ម*ជ្រៃ *ក*្នុ*ង*ជ*ង*ព្រៃ*ព*្រ*ឹ*ក*្ស* *ព*្រ*ោ*ះ*ផ*ល *ន*ៃ*ឧ*ប*ោ*ស*ថ-*ក*ម្ម *ព*ាក់*ក*ណ្ដា*ល* *ក*៏*គ*ួ*រ*ស*ម*្ដ*ង*ផ*ង*ដ*ែ*រ ។ *រ*ឿ*ង*នោ*ះ* *ប*ណ្ឌិ*ត* *ค*ป្ប*ី* *ត*្រ*ួ*ត*ព*ិ*ន*ិ*ត*្យ*ម*ើ*ល* *ក*្នុ*ង*អ*ដ*្ឌ*ก*ថ*ា*ន*ៃ*ค*ាថ*ា*ថ*ា* “***អ*ប្ប*ម*ា*ទ*ោ *អ*ម*ត*ំ *ប*ទ*ំ*** ” *ដ*ូ*ច*្ន*េ*ះ*ជ*ា*ដ*ើ*ម *ก*្នុ*ง*អ*ป*្ป*ม*ា*ท*ว*ค*ฺ *ន*ៃ*ธ*ม*ฺ*ป*ท ។

(*រ*ឿ*ง* ***ព*ระ*ร*ាជ*ា*ព*ระ*ន*ាម*ส*ាធ*ิ*ន:)

*(*១*)* *ก*ុ*ง*អ*ต*ี*ต*ก*ว*ล *ព*ระ*ព*ោ*ธ*ิ*ส*ត្ *ว* *ป*ាន*ส*ោ*យ*ព*ระ*ជ*ា*ต*ិ *ช*ា*ព*ระ*ร*ាជ* า*ទ*ង*់*ព*ระ*ន*ាម*ป*ា *ส*ាធ*ิ*ន: *ก*ុ*ง*ទ*ี*ก*ร*ុ*ง*ม*ิ*ธ*ิ*ล*ា *ท*ង*់*ค*ร*ាស*់*ป*ញ*ា*ญ*ា*ព*ระ*ร*ាជ*ป*ុ*ร*ស *ก*ส*า*ง*ส*ា*ล*ា*ท*ាន ៦ *ก*ន*ែ*ង *ท*ង*់*ញ*ុ*ំ*ง* *ม*ห*า*ท*ាน *ช*ួ*ย*ป*ร*ព*ឹ*ត*្ត*ទ*ៅ *ដ*ោ*យ*ก*ារ*ป*ริ*ช*ា*ค*ព*ระ*ร*ាជ*ท*ร*ัพ*ย ៦ *ส*ែ*ន* *ช*ា*ว*ៀ*ง*រ*ាស*់*ថ*ៃ *ท*ង*់*ร*ก*ษ*ា*ส*ីល ៥ *ข*ុ*ง* *ท*ង*់*ร*ก*ษ*ា*ឧ*ป*ោ*ส*ថ*ข*ុ*ง* ។ *ส*ូ*ม*ីព*ว*ก*ช*ន*អ*ក*ន*ៅ*ก*ុ*ง*ដ*ែ*ន *ก*៏*ส*ិ*ต*ិ*ต*ៅ*ก*ុ*ง*ព*ระ*ข*ิ*ร*ាទ*ร*ប*ส*់*ព*ระ*អ*ង*្ค *ធ*្ម*ើ*ป*ุ*ณ*ฺ*ย*ม*ាន*ท*ាន*ช*ា*ដ*ើ*ม *ส*ា*ป*់*ท*ៅ*ป*ើ*យ*ៗ *ก*៏*ป*ាន*ท*ៅ*ก*ើ*ต* *ก*ុ*ง* *ท*េ*ว*ป*ู*ร*ី*ท*ាំ*ง*អ*ส*់ *ท*ៅ*ก*ាន*ส*ុ*ธ*ម*ฺ*ม*ท*េ*ว*ส*ก*ា *អ*ង*ฺ*ค*ុ*យ *ន*ាំ*ค*ា*ต*ណ*ิ*ន*ា *ค*ุ*ณ* *ม*ាន*ส*ីล *ธ*ิ*ง* *อ* า*ช*ารៈ*ช*ា*ដ*ើ*ม *ร*ប*ส*់*ព*ระ*ร*ាជ*ន*ុ*ং*ង*ង* ។

ពណ៌នាអំពីកម្មដែលមិនមានទោស

ចំណែក ពួកទេវតាដែលសេសសល់ បានស្តាប់គុណកថា នោះហើយ មានសេចក្តីប្រាថ្នាចង់ឃើញព្រះរាជា ។ ស្តេចសក្ក-ទេវរាជ ទ្រង់ជ្រាបចិត្ត របស់ពួកទេវតាទាំងនោះហើយ ទើបទ្រង់ត្រាស់បញ្ជា នូវមាតលីទេវបុត្រថា "ចូរអ្នកទៅ នាំយកព្រះរាជា ព្រះនាមសាធិនៈ ដោយវេជយន្តរថមក" ។ មាតលីទេវបុត្រនោះ ក៏បានទៅកាន់ទីក្រុងមិថិលា នាំយកព្រះរាជា ព្រះនាម សាធិនៈ នោះ មកហើយ ។ ពួកទេវតា ព្រមទាំងព្រះឥន្ទ ឃើញព្រះបាទ សាធិនៈនោះហើយ ក៏មានចិត្តត្រេកអរ បានធ្វើការទទួលហើយ ។ ត្រានោះ សក្កទេវរាជ បានបែងទេវនគរ នាងទេពអប្សរ ២ កោដិ កន្ទ: និង វេជយន្តប្រាសាទ ត្រង់ពាក់កណ្តាល ថ្វាយដល់ព្រះបាទ សាធិនៈអង្គនោះ ។ កាលបើព្រះបាទសាធិនៈអង្គនោះ កំពុងតែ សោយទិព្វសម្បត្តិ, ៧០០ ឆ្នាំ បានកន្ទ:ផុតទៅហើយ ដោយការ រាប់ឆ្នាំនៃមនុស្ស ។ តមក បុណ្យដែលជាហេតុនៅ ក្នុងទេវលោក ដោយអត្តភាពនោះ របស់ព្រះបាទសាធិនៈព្រះអង្គនោះ បានអស់ ហើយ, សេចក្តីមិនត្រេកអរ បានកើតឡើងហើយ ។ ស្តេចសក្ក-ទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់បានបញ្ជា នូវមាតលី ទេវបុត្រ ថា " អ្នកចូរទៅ ចូរនាំព្រះបាទសាធិនៈ ទៅកាន់ទីក្រុង មិថិលា ហើយឲ្យចុះត្រង់ព្រះឧទ្យាន" ។ មាលីទេវបុត្រនោះ បាន

មន្តលត្ថនីបនីប្រែ

ធ្វើហើយយ៉ាងដូច្នោះ ។ បុរសអ្នករក្សាព្រះឧទ្យាន យើញព្រះបាទសាធិន:អង្គនោះហើយ បានក្រាបទូលសួរហើយ ក៏បានក្រាបទូលដល់ព្រះរាជាព្រះនាមនារទ: ។ បានញ្ចថា ព្រះរាជា ព្រះនាមនារទ: ត្រូវជាព្រះបនត្តា(ថៅ) ទី៧ របស់ព្រះបាទសាធិន:អង្គនោះ ។ បានញ្ចថា កាលនោះ ជាកាលនៃសត្វដែលមានអាយុ ៧០០ ឆ្នាំ ។ ក៏ព្រះពោធិសត្ត ញ្ចាំងកាលមានប្រមាណប៉ុណ្ណេះ ឲ្យកន្ទងផុតទៅហើយ ដោយផលបុណ្យរបស់ព្រះអង្គ ។ ចំណែកព្រះបាទនារទ: ស្តេចយាងមក ថ្វាយបង្គំព្រះអង្គហើយ ទ្រង់បានបបួល ដោយរាជសម្បត្តិ ។ ព្រះបាទសាធិន:អង្គនោះ ទ្រង់ត្រាស់ថា " បពិត្រព្រះអង្គ ទូលបង្គំមិនត្រូវការ ដោយសម្បត្តិទេ, ក៏ទូលបង្គំមក ក្នុងទីនេះ ដើម្បីប្រយោជន៍ ដល់រាជសម្បត្តិ ក៏ទេដែរ, (តែ) ទូលបង្គំមកហើយ ដើម្បីប្រយោជន៍ ដល់ការធ្វើបុណ្យ, ហេតុនោះ ទូលបង្គំ ជាអ្នកប្រាថ្នា ដើម្បីនឹងឲ្យទាន ដែលបានបញ្ឈប់ចោល អស់ពេល ៧០០ ឆ្នាំ ដោយ ៧ ថ្ងៃ តែប៉ុណ្ណោះ " ។ ព្រះបាទនារទ: ទ្រង់ត្រាស់ថា "ប្រពៃណាស់" ហើយ ទ្រង់បានចាត់ចែងនូវមហាទាន ។ ព្រះពោធិសត្ត ទ្រង់បានឲ្យទាន រហូតដល់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ទិវង្គតហើយ ទ្រង់បានទៅកើត ក្នុងភពតាវត្តិង្សន៉ុះឯង ។

រីឯព្រះសាស្តា កាលនឹងទ្រង់សម្តែងធម៌ ដល់ឧបាសក

ពណ៌នាអំពីកម្មដែលមិនមានទោស

ទាំងឡាយ អ្នករក្សាឧបោសថ ទើបទ្រង់ត្រាស់ថា "ម្នាលឧបាសក ទាំងឡាយ ឈ្មោះថា ឧបោសថកម្ម ជាធម្មជាតិ គួរបុគ្គលគប្បីរក្សា, បូរាណកបណ្ឌិតទាំងឡាយ អាស្រ័យឧបោសថកម្ម របស់ខ្លួនហើយ ទៅកាន់ទេវលោក ទាំងសរីរៈ ជាមនុស្សតែម្តង នៅហើយ អស់កាលដ៏យូរ " ដូច្នេះហើយ ទ្រង់សំដែងសាធិនជាតក ទី១១ ក្នុងបកិណ្ណកវគ្គ ទ្រង់ប្រកាសហើយ នូវសច្ចៈទាំងឡាយ ។

ក្នុងទីបញ្ចប់នៃសច្ចៈ បណ្តាឧបាសកទាំងឡាយ ឧបាសកពួកខ្លះ បានជាព្រះសោតាបន្ន, ពួកខ្លះ បានជាព្រះសកទាគামី ។

រឿង ព្រះបាទសាធិនៈ ចប់ ។

(អ្នករក្សាឧបោសថ ដើម្បីសង្កត់កិលេស)

(១៣៧) ក្នុងអតីតកាល ក្នុងហិមវន្តប្រទេស តាបស ១ រូប អាស្រ័យជាតិ ទើបជាអ្នកធ្លាក់ ក្នុងអំណាចនៃមានៈ មិនអាចដើម្បីនឹងញ្ជាំងឈាន ឲ្យកើតឡើងបានឡើយ ។ ថ្ងៃមួយ តាបសនោះ គិតថា "មានៈ របស់អាត្មាអញនេះ កាលចម្រើនឡើង ក៏នឹងនាំទៅនរក, ឥឡូវនេះ អញសង្កត់សង្កិនកិសេលនេះ មិនបានហើយ នឹងមិនទៅ ដើម្បីប្រយោជន៍ ដល់ផលានុផល " ដូច្នេះហើយ ក៏អង្គុយ សមាទាន នូវឧបោសថ ដើម្បីគ្របសង្កត់ ញ្ជាំញ៉ី នូវមានៈ ។ ចំណែក សត្វព្រាបមួយ ត្រូវសេចក្តីក្តៅក្រហាយ ព្រោះ

មង្គលត្ថទីបនីប្រែ

ភគ: ជុតរោលរាល ទើបគិតថា " ឥឡូវនេះ អញសង្គ្ដត់សង្ដ្ដិនភគ:នេះ មិនបានហើយ នឹងមិនហើរទៅ ដើម្បីរកចំណី " ដូច្នេះហើយ ទើបហើរទៅកាន់សំណាក់តាបស បានសមាទានឧបោសថ ដើម្បីសង្ដ្ដត់សង្ដ្ដិនភគ: ហើយដេក ក្នុងទីសមគួរមួយ ។ ចំណែកពស់មួយ ក៏សមាទានឧបោសថ ដើម្បីសង្ដ្ដត់សង្ដ្ដិនសេចក្ដីក្រោធ, ឯត្នែចចកមួយ ក៏សមាទានឧបោសថ ដើម្បីសង្ដ្ដត់សង្ដ្ដិនសេចក្ដីលោភ, ចំណែក ខ្ទាឃ្ម ក៏សមាទានឧបោសថ ដើម្បីសង្ដ្ដត់សង្ដ្ដិនការប្រាថ្នាច្រើន (ម្នាក់ៗ) បានដេក ក្នុងទីសមគួរមួយ យ៉ាងដូច្នេះឯង ។ បណ្ឌិត គប្បីឃើញថា "ឧបោសថកម្ម រមែងប្រព្រឹត្ដទៅ ដើម្បីសង្ដ្ដត់សង្ដ្ដិននូវបាបបាន ដោយប្រការដូច្នេះឯង " ។

ឯព្រះសាស្ដា កាលទ្រង់សម្ដែងធម៌ ដល់ពួកឧបាសកដែលរក្សាឧបោសថ ទើបទ្រង់ត្រាស់ ថា " ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយ បានធ្វើកម្មប្រសើរហើយ, ធម្មតាឧបោសថនុ៎ះ ជាប្រពៃណី របស់ពោធិសត្ដ្ដបណ្ឌិតទាំងឡាយ, ព្រោះថា ពោធិសត្ដ្ដ-បណ្ឌិតទាំងឡាយ រក្សាឧបោសថ ដើម្បីសង្ដ្ដត់សង្ដ្ដិន នូវកិលេសមានភគ: ជាដើម " ហើយ ទ្រង់ត្រាស់ បញ្ជ្ជាតកថា ទី៧ ក្នុងបកិណ្ណកវគ្គ ។ រឿងជន ៥ នាក់ ចប់ ។

ពណ្ណនាអំពីឧបោសថ ចប់ ។

ពណ៌នាអំពីកម្មដែលមិនមានទោស

(១៣៨) ចំណែកកិរិយាធ្វើកិច្ចខ្ជល់ខ្វាយ តែងបានដោយអំណាចការធ្វើវត្តនិងវត្តតបជាដើម ដល់បុគ្គលដែលចាស់ជាង ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ពួក ៣ ក្នុងសង្គីតិសូត្រ ទើបលោកពោលថា "បណ្ឌិតគប្បីជ្រាបកម្ម ដែលប្រកបព្រមដោយការខ្ជល់ខ្វាយ ដោយអំណាចនៃការធ្វើវត្ត និង វត្តតប ដល់បុគ្គលដែលមានវ័យចាស់ជាង ១ ដោយអំណាចនៃការឃើញ នូវភិក្ខុដែលចូលទៅកាន់ផ្ទះដើម្បីបិណ្ឌបាត ទទួលបាត្រហើយបបួលអ្នកស្រុកហើយបង្ហាន នូវអាហារចូលទៅ ១ ដោយអំណាចនៃការស្តាប់ថា " អ្នកចូរទៅ, ចូរនាំបាត្រ របស់ភិក្ខុទាំងឡាយមក " ដូច្នេះហើយ ក៏ប្រញាប់ប្រញាល់ ទៅទទួលយកបាត្រមកជាដើម ១ " ។

ដីកានៃសង្គីតិសូត្រនោះថា " បុគ្គល រមែងជាអ្នកខ្ជល់ខ្វាយ ក្នុងវត្ត និង វត្តតប ដល់បុគ្គលអ្នកចម្រើនហើយ ដោយវ័យ និងគុណទាំងឡាយ ដោយចេតនា ឯណា, ចេតនានោះ ឈ្មោះថា វេយ្យាវច្ចៈ (ចេតនាជាហេតុខ្ជល់ខ្វាយ), វេយ្យាវច្ចៈនុ៎ះឯង ឈ្មោះថា ការប្រកបព្រម ដោយចេតនាជាហេតុខ្ជល់ខ្វាយ ។ ម្យ៉ាងវិញទៀត កម្មដែលទៅហើយ គឺ ដែលប្រព្រឹត្តទៅហើយ ព្រមដោយអំណាចនៃការញ្ជាំងវត្តប្រតិបត្តិ ពោលគឺចេតនា ជាហេតុខ្ជល់ខ្វាយ ឲ្យកើតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា វេយ្យាវច្ចសហគតៈ

មង្គលត្ថទីបនីប្រែ

(កម្ម ដែលប្រព្រឹត្តទៅហើយ ព្រមដោយចេតនាជាហេតុខ្ងល់ខ្ងាយ) រៀយ្យាវច្ចៈ ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ យ៉ាងដូច្នោះ ជាវត្ថុជាទីតាំងនៃកិរិយាបំពេញបុណ្យ " ។

(១៣៩) រៀយ្យាវច្ចៈ នោះឯង ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការបាន នូវពាហនៈដ៏ប្រសើរ ក្នុងមង្គលត្ថទីបនីនេះ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រះរាជាព្រះនាមចណ្ឌបជ្ជោត)

ក្នុងអតីតកាល ឥស្សរជនម្នាក់ងូតទឹកខាងក្រៅនគរ កាលត្រឡប់មកវិញ ក៏បានឃើញព្រះបច្ចេកពុទ្ធ ១ អង្គ ក្នុងចន្ទោះផ្លូវ ។ បានញ្ចថា ព្រះបច្ចេកពុទ្ធអង្គនោះ និមន្តទៅបិណ្ឌបាត ក្នុងទីក្រុងមិនបានហើយនូវភិក្ខា ព្រោះអ្នកក្រុងទាំងអស់ ត្រូវមារបង្វែងចិត្តហើយ ទើបនិមន្តចេញមកហើយ ដោយបាត្រដែលខ្ជូនលាងហើយ យ៉ាងណា (ដោយបាត្រទទេ) ។ ឥស្សរជន ឃើញនូវព្រះបច្ចេកពុទ្ធអង្គនោះហើយ ថ្វាយបង្គំ ទូលសួរថា " បពិត្រព្រះអង្គដ៏ចម្រើន តើព្រះអង្គបានវត្ថុអ្វីៗ ខ្ងះដែរឬទេ? " ។

ព្រះបច្ចេកពុទ្ធ ទ្រង់ត្រាស់ថា " ម្នាលអ្នកដ៏មានអាយុ អាត្មាបានចូលទៅ ត្រឡប់មកវិញហើយ " ។

ឥស្សរជននោះ គិតថា " ព្រះគុណម្ចាស់ដ៏ចម្រើន មិន

ពណ៌នាអំពីភម្ចជែលមិនមានទោស

ឆ្លើយតប នូវពាក្យដែលអាត្មាអញសួរទេ ទៅពោលពាក្យដទៃវិញ, វត្ថុអ្វីៗ ព្រះគុណម្ចាស់ដ៏ចម្រើន នឹងមិនបានហើយ " ដូច្នេះហើយ ទើបក្រឡេកមើលបាត្រ យើញបាត្រទទេហើយ ជាអ្នកក្លៀវក្លា (តែ) មិនអាចដើម្បីនឹងទទួលយកបាត្រ ព្រោះមិនដឹងថា ភត្ត ក្នុងផ្ទះ បានសម្រេចហើយ ឬក៏ មិនបានសម្រេច ទើបក្រាបទូល ថា " បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សូមព្រះគុណម្ចាស់ និមន្តចាំ បន្តិចសិនចុះ" ហើយប្រញាប់ប្រញាល់ទៅផ្ទះ ដឹងថា ភត្តសម្រេចហើយ ទើបបានបញ្ជូនអ្នកបម្រើម្នាក់ទៅ ដោយប្រាប់ថា " នែអ្នកអ្នកចូរទៅ, ចូរទៅទទួលយកបាត្រ របស់ព្រះគុណម្ចាស់ មកយ៉ាងប្រញាប់ " ។ អ្នកបម្រើនោះ ក៏ស្ទុះទៅ ទទួលយកបាត្រ ហើយ ។ ចំណែក ឥស្សរជន ដាក់ភត្ត ពេញបាត្រហើយ បានពោលថា " អ្នកចូរញ្ចាំងភត្តនេះ ឲ្យដល់ព្រម ដល់ព្រះគុណម្ចាស់ ដ៏ចម្រើន យ៉ាងប្រញាប់, ខ្ញុំ នឹងឲ្យ នូវចំណែកបុណ្យ អំពីភត្តនេះ ដល់អ្នក" ។ អ្នកបម្រើនោះ ទៅហើយយ៉ាងលឿន ប្រគេនបាត្រ ដល់ព្រះបច្ចេកពុទ្ធហើយ ថ្វាយបង្គំ ក្រាបទូលថា "បពិត្រព្រះអង្គ ដ៏ចម្រើន ខ្ញុំព្រះករុណា ទៅ និង មកហើយ ដោយសន្ទុះជើង យ៉ាងលឿន ដោយគិតថា ពេលវេលា ជិតចូលមកដល់ហើយ ដូច្នេះ, ដោយផលនៃសន្ទុះជើង របស់ខ្ញុំព្រះករុណានុ៉ះ សូមពាហនៈទាំង

មន្តលត្ថនីបនីប្រែ

ឡាយ ដែលអាច សុះទៅបាន ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ ចូរកើតមានឡើង, កាលខ្ញុំព្រះករុណា កំពុងមក និង កំពុងទៅ, សរីរៈរាងកាយ ក្តៅហើយ ព្រោះកំដៅនៃព្រះអាទិត្យ, ដោយផលនៃសរីរៈដែលក្តៅហើយ ព្រោះកំដៅនៃព្រះអាទិត្យនោះ សូមឲ្យអាជ្ញា របស់ខ្ញុំព្រះករុណា ចូរប្រាកដស្មើ ដោយកំដៅនៃព្រះអាទិត្យ ក្នុងទីដែលខ្ញុំព្រះករុណា បានកើតឡើងហើយៗ, ចំណែកបុណ្យ គឺម្ចាស់ (របស់ខ្ញុំ) បានឲ្យហើយ ដល់ខ្ញុំព្រះករុណា ក្នុងបិណ្ឌបាតនេះ, ដោយផលនៃចំណែកបុណ្យនោះ ខ្ញុំព្រះករុណា គប្បីជាអ្នកមានចំណែក នៃធម៌ ដែលព្រះអង្គបានឃើញហើយ " ។ ព្រះបច្ចេកពុទ្ធ ត្រាស់ថា "សូមសេចក្តីប្រាថ្នា ដែលអ្នកប្រាថ្នាហើយ ចូរបានសម្រេចយ៉ាងនោះចុះ" ដូច្នេះហើយ ទើបបានអនុមោទនា ដោយគាថា នៃព្រះបច្ចេកពុទ្ធទាំងឡាយ ហើយ ក៏និមន្តគេចចេញទៅ ។ អ្នកបម្រើនោះ កាលអន្ទោលទៅ ក្នុងពុទ្ធុប្បាទនេះ បានជាព្រះរាជា ទ្រង់ព្រះនាមថា ចណ្ឌបជ្ជោត ក្នុងនគរឈ្មោះឧជ្ជនី ។ ពាហនៈទាំងឡាយ ៥ យ៉ាង កើតឡើងហើយដល់ព្រះអង្គ ព្រោះផលនៃកម្មនោះឯង គឺ ដំរីញីមួយ ឈ្មោះ ភទ្ទវតី រមែងដើមទៅបាន ៥០ យោជន៍ ក្នុងមួយថ្ងៃ, អ្នកបម្រើ ម្នាក់ ឈ្មោះ កាកៈ រមែងធ្វើដំណើរទៅបាន ៦០ យោជន៍, សេះ

ពណ៌នាអំពីកម្មដែលមិនមានទោស

ទាំងឡាយ ២ គឺ សេះ ឈ្មោះវេលកំសិ ១ សេះ ឈ្មោះមុញ្ជកេសិ ១ ដើរទៅបាន ១០០ យោជន៍, ដំរី ឈ្មោះ នាឡាគិរី ដើរទៅបាន ១២០ យោជន៍ ។

រឿងព្រះរាជា ទ្រង់ព្រះនាម ចណ្ឌបជ្ជោត មកក្នុងអដ្ឋកថានៃគាថា ថា " **អប្ប្ឃមាតោ អមតំ បទំ** " ដូច្នេះជាដើម ។

(១៤០) សូម្បីការបង្ហាញផ្លូវ ដល់ពួកយាចក អ្នកសុំទាន ក៏ឈ្មោះថា វេយ្យាវច្ចៃ ។ សូម្បីវេយ្យាវច្ចៃនោះ ក៏ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការបានទូវបាទដៃ ដ៏ពិសេស ជាដើម ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ។

(**រឿង ជាងជុល**)

ក្នុងអតីតកាល ក្នុងនគរឈ្មោះអសិតញ្ជៃ ក្នុងឧត្តរាបថ-ជនបទ ព្រះរាជាទ្រង់ព្រះនាម មហាកំសៃ ទ្រង់មានព្រះរាជធីតាព្រះនាមថា ទេវគណ្ហា ។ ព្រះរាជធីតាអង្គនោះ ទ្រង់អាស្រ័យព្រះរាជកុមារ ព្រះនាមឧបសាគរៃ ដែលជាព្រះរាជបុត្ររបស់ព្រះរាជាព្រះនាម មហាសាគរៃ ដែលទ្រង់ជាអធិបតី ក្នុងឧត្តរាបថជនបទ ទ្រង់បានហើយ នូវព្រះរាជបុត្រទាំងឡាយ ១១ ព្រះអង្គ គឺ ព្រះរាជធីតា ទ្រង់ព្រះនាមថា អញ្ជនទេវី ១ ព្រះរាជបុត្រ ទ្រង់ព្រះនាមថា ភ្ជសុទេត ១ ពលទេត ១ ចន្ទទេត ១ សុរិយទេត ១

មន្តលត្ថនីបនីប្រែ

អគ្គិទេព ១ វរុណទេព ១ អជ្ជុន ១ បជ្ជុន ១ យតបណ្ឌិត ១ អន្ធុរ: ១ ។ បណ្តាព្រះរាជបុត្រទាំងនោះ ព្រះកាតាទាំង ១០ ព្រះអង្គ មានព្រះវាសុទេព ជាដើម បានធ្វើគុតព្រះរាជាទាំងអស់ ក្នុងព្រះនគរ ៦ ម៉ឺន ៣ ពាន់ ក្នុងជម្ពូទ្វីបទាំងមូល មាននគរ ឈ្មោះអសិតញ្ជន: ជាដើម មាននគរទ្វារាវតី ជាទីបំផុតហើយ ទ្រង់គង់នៅ ក្នុងនគរទ្វារាវតី ទ្រង់បានចែកទ្រព្យសម្បត្តិជា ១០ ចំណែក មិនទ្រង់នឹករលឹកដល់ព្រះជេដ្ឋភគិនីសោះឡើយ ។ កាលព្រះរាជាទាំងនោះ ទ្រង់បាននឹករលឹក ម្តងទៀត ទើបទ្រង់ត្រាស់ថា " ពួកយើងនឹងចែក ឲ្យទៅជា ១១ ចំណែក " ដូច្នេះ, ព្រះរាជបុត្រ ព្រះនាមអន្ធុរ: ដែលជាព្រះកនិដ្ឋានៃព្រះរាជាគ្រប់ព្រះអង្គ ទ្រង់ត្រាស់ថា "សូមព្រះម្ចាស់បងទាំងឡាយ ព្រះរាជាទាននូវចំណែក របស់ទូលព្រះបង្គំ ដល់ព្រះជេដ្ឋភគិនីនោះចុះ, ទូលព្រះបង្គំ នឹងធ្វើការលក់ដូរហើយ ចិញ្ចឹមជីវិត, សូមព្រះម្ចាស់បងទាំងឡាយ ទ្រង់លះបង់នូវពន្ធដារ ក្នុងជនបទរបស់ខ្ជួន ដល់ទូលព្រះបង្គំតែម៉ាង " ។ ព្រះរាជាទាំងនោះ ទ្រង់ត្រាស់ថា "ប្រពៃហើយ" ទ្រង់បានព្រះរាជទាននូវចំណែក របស់ព្រះអន្ធុរ:នោះ ដល់ព្រះភគិនីហើយ ទ្រង់គង់នៅ ក្នុងនគរទ្វារាវតី មួយអន្ទើដោយព្រះភគិនីនោះ ។

សេចក្តីសង្ខេប ក្នុងរឿងនេះ មានតែប៉ុណ្ណេះ ។ ចំណែក

ពណ៌នាអំពីកម្មដែលមិនមានទោស

សេចក្ដីពិស្ដារ បណ្ឌិត គប្បីត្រួតមើល ក្នុងយតបណ្ឌិតជាតក ក្នុងទសកនិបាត ។

(១៤១) ក៏ព្រះរាជាព្រះនាមអង្ករ: កាលទ្រង់ធ្វើនូវការលក់ដូរ ទ្រង់បានថ្វាយហើយនូវមហាទាន ជានិច្ច ។ ក៏អ្នកបម្រើ របស់ព្រះអង្គម្នាក់ ជាអ្នករក្សាព្រះឃ្លាំង ជាអ្នកប្រាថ្នាប្រយោជន៍ ។ ព្រះបាទអង្ករ: ទ្រង់បាននាំកុលធីតាមួយរូបមក ព្រះរាជទាន ដល់អ្នករក្សាព្រះឃ្លាំងនោះ ។ អ្នករក្សាព្រះឃ្លាំងនោះ, កាលបើកូននៅក្នុងផ្ទៃនុ៎ះឯង, ក៏បានធ្វើមរណកាលហើយ ។ ក៏កាលបើកូនរបស់អ្នករក្សាឃ្លាំងនោះ ធំពេញវ័យហើយ, ការវិនិច្ឆ័យ បានកើតឡើងហើយ ក្នុងរាជត្រកូលថា " ក្មេងនេះ ជាបាវព្រាវ ឬក៏ មិនមែនជាបាវព្រាវ " ។ ព្រះនាងអញ្ជនទេវី ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់បានធ្វើឧបមាដោយមេគោកូនខ្ចី ទ្រង់ត្រាស់ថា "សូម្បីកូនរបស់មាតា ដែលជាបាវព្រាវ ក៏ជាបាវព្រាវដដែល " ហើយទ្រង់បានដោះលែង អំពីភាពជាបាវព្រាវ ។ តែក្មេងនោះ មិនអាចដើម្បីនឹងរស់នៅ ក្នុងទីនោះបាន ព្រោះសេចក្ដីអៀនខ្មាស ទើបទៅកាន់នគរ ឈ្មោះពារុវ: ហើយទទួលយកកូនស្រី របស់ជាងជុលក្នុងទីនោះ សម្រេចការនៅ ក្នុងទីជិតផ្ទះ របស់មហាសេដ្ឋី ឈ្មោះអសយ្ហ: បានចិញ្ចឹមជីវិត ដោយការងារ របស់នាយជាងជុល ។

មង្គលត្ថទីបនីប្រែ

ក្នុងពេលនោះ អសយ្ហមហាសេដ្ឋី បានញ៉ាំងមហាទាន ឲ្យប្រព្រឹត្ត ទៅហើយដល់មហាជន ។ ប្រសិនបើពួកយាចកឯណា មិនស្គាល់ផ្លូវទៅកាន់ផ្ទះ របស់អសយ្ហមហាសេដ្ឋី, ពួកយាចកទាំងនោះតែងសួរនូវនាយជាងជុលនោះ ។ សូម្បីជាងជុលនោះ ក៏គិតថា "អាត្មាអញ ព្រោះជាអ្នកមិនបានធ្វើបុណ្យទុកមកហើយ ក្នុងកាលមុន ឥឡូវនេះ ទើបជាអ្នកមិនអាច ដើម្បីនឹងឲ្យវត្ថុអ្វីៗ ដល់ពួកជនអ្នកប្រាកដ ដូច្នេះបាន, ប៉ុន្តែ ក្នុងពេលនេះ អាត្មាអញ កាលសម្តែងនូវរោងទាន ដល់ជនទាំងនេះ ញ៉ាំងបីតិ ឲ្យកើតឡើង ដោយការប្រាប់ឧបាយនៃលាភ នឹងប្រសព្ធ នូវបុណ្យដ៏ច្រើន សូម្បីដោយហេតុមានប្រមាណប៉ុណ្ណេះ " ហើយ ញ៉ាំងសេចក្តីកោតក្រែង និងសេចក្តីគោរព ឲ្យកើតឡើងហើយ បានលាតដៃស្តាំចេញ សម្តែងប្រាប់ថា " សូមពួកអ្នកទាំងនោះ ទៅក្នុងទីនោះហើយ ចូរបាននូវវត្ថុដែលខ្ជួនគប្បីបានចុះ " ។ ក្នុងកាលក្រោយមក ជាងជុលនោះ ធ្វើមរណកាលហើយ ក៏បានទៅកើតជាកុម្ភទេវតា លើដើមជ្រៃមួយដើម មានម្ជុលយ៉ាងត្រឈឹងត្រៃឈ មានឫសច្រើនពាន់ មានប្រមាណ ៤ យោជន៍ ដោយបណ្តាយទទឹង និង កំពស់ ក្នុងទន្ទ្រឦ្ឍ ដែលជាច់ស្រយាល ។ ដៃស្តាំ របស់ទេវតានោះ ជាដៃ ដែលឲ្យនូវវត្ថុជាទីប្រាថ្នា ។

ពណ៌នាអំពីកម្មដែលមិនមានទោស

ក្នុងកាលជាខាងក្រោយមក ព្រះរាជាព្រះនាមអង្ករ: ទ្រង់យកពន្ធ១ទាំង ៥០០ មកជីកនូវកណ្ដ:ទៅ ដើម្បីលក់ដូរ ទៅដល់ទីជាច់ស្រយាលនោះហើយ ក៏ទ្រង់រ:ង្ងៃងផ្ទ:ដ ស្ដេចយាងទៅ ក្នុងទីនោះឯង អស់ច្រើនថ្ងៃ ទ្រង់មានស្មៅ ទឹក និង អាហារ អស់រលីងហើយ ។ ពេលនោះ រុក្ខទេវតា បាននឹករលឹកដល់ឧបការ:ដែលព្រះបាទអង្ករ: ទ្រង់បានធ្វើហើយ ដល់ខ្លួន ក្នុងកាលមុន ទើបបានសម្ដែងនូវដើមជ្រៃ របស់ខ្លួន ដល់ព្រះបាទអង្ករ:អង្គនោះ ។ ព្រះរាជា ព្រះនាមអង្ករ: ទ្រង់ទតព្រះនេត្រឃើញនូវដើមជ្រៃនោះហើយ ទ្រង់មានព្រះទ័យត្រេកអរ:ីកាយ ទ្រង់បានសម្រេចកិរិយាគង់នៅ ក្រោមដើមជ្រៃ ។ ទេវតា លាតដៃស្ដាំចេញហើយ ជាបឋមញ្ជាំងជនគ្រប់ៗ គ្នា ឲ្យផ្ដែតស្ដាប់ស្ដាល់ ដោយទឹកផឹក ។ តអំពីនោះមក ជនឯណាៗ ប្រាថ្នានូវតុ្ណាៗ ទីមួយ, ទេវតានោះ បានឲ្យហើយនូវតុ្ណនោះៗ ដល់ជននោះ ។ ។ ព្រះបាទអង្ករ: ទ្រង់ទតព្រះនេត្រឃើញទេវតានោះហើយ កាលទ្រង់ត្រាស់សួរ ទើបទ្រង់ត្រាស់គាថា (នេះ) ក្នុងរឿងនៃអង្ករប្រេត ថា ៖

(១៤២) “ ដៃទាំងអស់ របស់អ្នក មានសម្ប:ដ្ឋិ:ចជាមាស ទ្រទ្រង់ន្ទ:ូវវ:ត្ថុជាទីប្រាថ្នា ដោយអង្គុលីទាំង ៥ បញ្ជ:ូញ្ជ:ូ រសផ្ដែម, ផ្ទ:ាលបុណ្ យ:ូសម្រេច ក្នុងដៃ:ូរបស់អ្នក ដោយ

មង្គលត្ថទីបនីប្រែ

ការប្រព្រឹត្តិនូវធម៌ ដ៏ប្រសើរ ដូចម្តេច [១] ។

*បណ្តាវបទទាំងនោះ ២ បទថា "**ចាណិ តេ**" បានដល់ ដៃស្តាំ (របស់អ្នក) ។ បទថា "**សព្វសោវណ្ណា**" គឺ សម្រេចហើយ អំពីមាស ដោយប្រការទាំងពួង ។ បទថា "**ឋ្ឋាតោ**" គឺ ឈ្មោះថា ទ្រទ្រង់នូវវត្ថុជាទីប្រាថ្នា ដោយអង្គុលីទាំង ៥ ព្រោះអត្ថវិគ្រោះថា ពំនួក នៃវត្ថុដែលពួកជនដទៃប្រាថ្នា ដោយអង្គុលីទាំង ៥ របស់ទេវតានុ៎ះមាន ។ បទថា "**មធុស្សរោ**" បានដល់ ជាដែនហូរចេញ នៃរសដ៏ផ្អែម ។ ព្រោះថា រសទាំងឡាយ ផ្សេងៗ មានរសហ៊ីរ និង រសជូរ ជាដើម ជាប្រកេទ រមែងហូរចេញ គឺ ស្រក់ចេញ អំពីសំណុំនៃអង្គុលីទាំង ៥ នោះ ។ ២ បទថា "**កេន តេ**" មានសេចក្តីថា ផលបុណ្យ ក្នុងដៃរបស់អ្នកនេះ គឺ ប្រាកដដូច្នេះ រមែងសម្រេច គឺ រមែងផ្តល់ផល ក្នុងពេលឥឡូវនេះ ព្រោះកិរិយាប្រព្រឹត្តិ នូវធម៌ដ៏ប្រសើរដូចម្តេច?, សូមអ្នកប្រាប់ នូវហេតុនោះ ។ ក៏ផលបុណ្យ ព្រះបាទអង្គុរ: ទ្រង់ព្រះបំណងយកហើយ ថា "បុណ្យ" ក្នុងគាថានេះ ព្រោះលុបបទខាងចុង ។*

គ្រានោះ ទេវតា បានក្រាបទូលនូវសេចក្តីនេះ ដល់ព្រះបាទអង្គុរ:នោះ ថា "ក្នុងជាតិមុន ទូលព្រះបង្គំ កើតជាងជុល ក្នុង

១- សុត្តន្តបិដក ភាគទី ៥០ ទំព័រទី ៤០-៤៧ ។

ពណ៌នាអំពីកម្មដែលមិនមានទោស

នគរ ឈ្មោះរោរុវៈ អាស្រ័យការរស់នៅ ក្នុងទីជិតផ្ទះនៃមហាសេដ្ឋី ឈ្មោះថាអសយ្ហៈ, មួយទៀត វត្ថុ ដែលគួរឲ្យបន្ទិចបន្ទួច របស់ទូលព្រះបង្គំក៏គ្មាន, ពួកយាចក មិនដឹងផ្លូវទៅកាន់រាងទាន របស់អសយ្ហៈសេដ្ឋី ទើបសួរទូលព្រះបង្គំ, ទូលព្រះបង្គំ បានប្រាប់ផ្លូវ ដល់ពួកយាចកទាំងនោះ " ដូច្នេះហើយ កាលសម្តែង ថា " ផលនេះ រមែងសម្រេច ព្រោះកម្មនោះ " ដូច្នេះ ទើបពោលគាថា ថា ៖

(១៤៣) " ដៃ របស់ទូលព្រះបង្គំ អាចឱ្យសម្រេចសេចក្តីប្រាថ្នា ដោយហេតុនោះ, ដៃរបស់ទូលព្រះបង្គំ ជាដែនហូរចេញ នៃរសដ៏ផ្អែមបាន ដោយហេតុនោះ, ផលបុណ្យក៏រមែងសម្រេចក្នុងដៃ របស់ទូលព្រះបង្គំ ព្រោះការប្រព្រឹត្តិដ៏ប្រសើរនោះ " ។

*បណ្តាបទទាំងនោះ បាទគាថាថា "**តេន បាណិ កាមទទោ**" មានសេចក្តីថា ដៃរបស់ទូលព្រះបង្គំ ក្នុងពេលឥឡូវនេះ ហូរចេញ នូវរបស់ដែលប្រាថ្នា គឺ ឲ្យនូវរបស់ដែលគេត្រូវការហើយៗ ដូចជាដើមកប្បព្រឹក ព្រោះហេតុនោះ គឺ ព្រោះហេតុត្រឹមតែកិរិយាអនុមោទនា នូវទានដែលបុគ្គលដទៃ ធ្វើហើយ ក្នុងកាលនោះ ដោយគោរព ។ ដៃរបស់ទូលព្រះបង្គំ ជាដៃដែលអាចឲ្យសម្រេចសេចក្តីប្រាថ្នា និង ជាដែនហូរចេញ នៃរសដ៏ផ្អែម គឺ ជាដែនហូរ*

ចេញ នៃវត្ថុដែលជាទីប្រាថ្នា ។

*(១៤៤) ក្នុងអដ្ឋកថាអង្គុរប្រតវត្ថុ ព្រះអដ្ឋកថាចារ្យ បានសម្តែងខ្លួន នៃ **ត** សព្ទ យ៉ាងដូច្នេះ ក្នុងគាថានេះហើយ ពោលក្នុងគាថាខាងមុខ ម្តងទៀតថា " ដៃនេះ អាចឲ្យសម្រេចសេចក្តីប្រាថ្នា ដោយហេតុត្រឹមតែកិរិយាប្រាប់ផ្លូវ ដែលទៅកាន់ផ្ទះ របស់ទានបតី ដែលមានការអនុមោទនា នូវបុណ្យដែលបុគ្គលដទៃបានធ្វើហើយ ជាខាងដើម " ដូច្នេះ ។*

*ដីកានៃមហាសីហនាទសូត្រ ថា " បានគាថា ថា **តេន មេ ព្រហ្មចរិយេន** គឺ ដោយកិរិយាប្រព្រឹត្តិដ៏ប្រសើរ ពោលគឺ កម្ម គឺភាពជាអ្នកឲ្យ ល់ឲ្យាយខាងផ្លូវកាយ ដូចបានពោលមកហើយ របស់ទូលព្រះបង្គំនោះ " ។*

*ក៏ភាពជាអ្នកឲ្យ ល់ឲ្យាយ ឈ្មោះថា កិរិយាប្រព្រឹត្តិដ៏ប្រសើរ ក្នុងគាថានេះ ។ ក៏សេចក្តីនេះ នឹងមានប្រាកដ ក្នុងមង្គលបទ ថា " **តបោ ច ព្រហ្មចរិយញ្ច** " នេះ ។*

ព្រះរាជាព្រះនាមអង្គុរ: ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទើបស្តេចយាងទៅ តាមព្រះបំណង ។ សេចក្តីសង្ខេប ក្នុងរឿងនេះ តែប៉ុណ្ណោះ ។ ចំណែកឯសេចក្តីពិស្តារ អ្នកសិក្សា គប្បីត្រួតពិនិត្យមើល ក្នុងអង្គុរប្រតវត្ថុ ។ រឿង ជាង ជុល ចប់ ។

ពណ៌នាអំពីវេយ្យាវច្ច: ចប់ ។

ពណ៌នាអំពីកម្មដែលមិនមានទោស

(១៤៥) សូម្បីកិច្ច មានការដាំសួនច្បារ ដាំដើមឈើ និង សង់ស្ពាន ជាដើម ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃកិរិយា កើតឡើង ក្នុងឋានសួគ៌ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(រឿង នៃឧបាសក)

ក្នុងទីក្រុងសាវត្ថី ឧបាសកម្នាក់ ធ្វើនូវទីកន្លែង ដែលមិនរាបស្មើ ឲ្យបានរាបស្មើ ក្នុងផ្លូវជាទីនិមន្តមកកាន់ផ្ទះ ដើម្បីបិណ្ឌបាត ដល់ភិក្ខុទាំងឡាយ អ្នកនៅក្នុងព្រៃជាវត្ត នាំបន្ទាបចេញ ជម្រះនូវឈើតូចៗ និង គុម្ពឈើទាំងឡាយ, ក្នុងពេលទឹកជន់ សង់ស្ពាន ក្នុងប្រឡាយទាំងឡាយ, ក្នុងទីដែលមិនមានដើមឈើ ក៏ដាំដើមឈើ ដែលមានម្លប់ទាំងឡាយ, ជីកដី ក្នុងទីសម្រាប់ឃាំងទឹកឡើង ធ្វើឲ្យទូលាយ និង ជ្រៅ, ធ្វើកំពង់ទាំងឡាយ ឲ្យដល់ព្រម, ថ្វាយទាន តាមសមគួរ ដល់ទ្រព្យសម្បត្តិ និង រក្សាសីល ។ ក្នុងកាលតមក ឧបាសកនោះ ធ្វើមរណកាលហើយ ក៏ទៅកើត ក្នុងវិមានមាស មានប្រវែង ១២ យោជន៍ ក្នុងកពតាវត្តិង្ស ។ ព្រះមហាមោគ្គល្លានត្ថេរ បានចូលទៅរកទេវបុត្រនោះ ហើយសួរដោយគាថាទាំងឡាយ ថា ៖

មន្ទលត្ថទីបនីប្រែ

(១៤៦) " វិមាន ដ៏ខ្ពស់នេះ មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍, មានផ្ទះកំពូល ៣០០ ដ៏ឱឡារិក មានសសរកែវពិទូរ្យ ដែលក្រាលកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ, អ្នករមែងបិតនៅ ផឹក និង ស៊ី ក្នុងវិមាននោះ, ពិណជាទិព្ធ លាន់ឌ្ឍ ដ៏ពីរោះ, កាមគុណ ៤ មានរស ជាទិព្ធ ក៏មាន ក្នុងវិមាននេះផង, ព្ធកនារីដែលប្រស់ព្រំដោយគ្រឿងមាស ក៏រាំក្នុងវិមាននេះផង, សម្ឃុររបស់អ្នកប្រាកដដូច្នោះ តើសម្រេប ដោយបុណ្យអ្វី?, ផលនៃសុបរិត រមែងសម្រេបដល់អ្នក ក្នុងវិមាននេះផង, ភោគ:ទាំងឡាយណា នីម្ចយជាទីគាប់បិត្ត, ភោគ:ទាំងឡាយនោះ រមែងកើតឡើងដល់អ្នកផង តើដោយបុណ្យដូបម្តេប?, នែទេវតា អ្នកមានអានុភាពប្រើន អាត្មា ស្ទរអ្នក, តើអ្នកកាលកើតជាមនុស្ស្ម បានធ្វើបុណ្យអ្វី ទើបមានអានុភាពរុងរឿង យ៉ាងដូច្នេះ?, ទាំងសម្ឃុររបស់អ្នក ក៏ភ្លឺប្ឆាស់ សព្ធទិសទី តើសម្រេប [1] ដោយបុណ្យអ្វី ? " ។

អដ្ឋកថាកក្ពជរសទាយកវិមាន ក្នុងបញ្ចមវគ្គថា " បណ្ណា

១- សុត្តន្តបិដក ភាគទី ៥៥ ទំព័រទី ១៥៨ ។

*បទទាំងនោះ បទថា **ឧជុं** គឺ ខ្ពស់គ្រលួច ។ បទថា **មណិថូណំ** គឺ ដែលស្រោចហើយ ដោយកែវមណី មានកែវទទឹម ជាដើម ។ បទថា **សមន្ត្តតោ** គឺ សូម្បីក្នុងជ្រុងទាំងឡាយ ៤ ។ បទថា **រុចិរត្ត្ត** គឺ ក្រាលដោយផ្ការ៉ាងមាស លើផ្ទៃកម្រាលនោះ ។ ដោយ ២ បទថា **ចិវសិ ទ្ទ** ព្រះមហាមោគ្គល្លានត្ថេរ ពោលសំដៅយកទឹក ដែលមានក្លិនក្រអូប និង ភោជនដ៏ប្រសើរ ដែលប្រើប្រាស់ រៀងរាល់ពេល ។ បទថា **ឧ** គឺ រមែងលាន់ញ្ជ ឡើង ។ ជាទគាថាថា **ទិព្ទ្ទ ១ ១ ១ ១** មានសេចក្ដីថា កាមគុណទាំង ៥ ដែលមានរសជាទិព្ទ គឺ មិនមែនតិចតួច ក៏មានព្រម ក្នុងវិមាននេះ គឺ ក្នុងវិមាន របស់អ្នកនេះ ។ បទថា **ស** គឺ ប្រដាប់តាក់តែង ដោយគ្រឿងអាភរណៈ ដែលសម្រេចហើយ ដោយមាស " ។*

*(១៤៧) ន័យ ក្នុងអដ្ឋកថាបិដ្ឋវិមាន ដែលជារឿងទីមួយ នៃ រឿងទាំងពួងថា " បទថា **ក** ជាតតិយាវិភត្ដិ ប្រើក្នុងអត្ថ នៃ ហេតុ ។ មានសេចក្ដីថា ព្រោះហេតុអ្វី? ។ មានពាក្យដែលលោក អធិប្បាយថា ព្រោះបុណ្យយ៉ាងពិសេសដូចម្ដេចដែលជាហេតុ? ។ បទថា **ត** គឺ របស់អ្នក ។ បទថា **ឯ** ជាប់ ប្រាកដ ដូច្នោះ, អធិប្បាយថា តាមដែលប្រាកដមាន ក្នុងពេលឥឡូវនេះ ។*

មន្តលត្ថទីបនីប្រែ

ពណិសម្បុរ នៃស្បែក ឈ្មោះថា វណ្ណៈ ។ អធិប្បាយថា សម្បុរ នៃសរីរៈ ដែលអាចក្ខឹ ផ្សាយទៅបាន ១២ យោជន៍ ។ បាទគាថា ថា **កេន តេ ឥធ ឥជ្ឈតិ** គឺ ផលនៃសុចរិត ដ៏ឱឡារិក ដែលអ្នកកំពុងបាន ក្នុងទីនេះ ក្នុងពេលនេះ រមែងសម្រេច គឺ រមែងសម្រេចផលដល់អ្នក ដោយបុណ្យដ៏ប្រសើរ ដូចម្តេច? ។ បទថា **ឧប្បជ្ជន្តិ** ប្រែថា រមែងកើត ។ អធិប្បាយថា រមែងប្រព្រឹត្តទៅ ខ្ពស់ឡើងៗ ដោយអំណាចមិនដាច់រយៈ ។ គ្រឿងឧបករណ៍ នៃ ទ្រព្យគ្រឿងពេញចិត្ត ដ៏ពិសេស មានសំពត់ និង គ្រឿងអាភរណៈ ជាដើម ដែលបានឈ្មោះថា ភោគៈ ព្រោះអត្ថថា គឺបុគ្គលគប្បី ប្រើប្រាស់ ឈ្មោះថា ភោគៈ ។ សព្ទថា **យេ** ជាសព្ទសម្តែង សេចក្តីមិននិយម ដោយភាពជាទ្រព្យទូទៅ ។ សព្ទថា **កេចិ** ជា សព្ទ សម្តែងសេចក្តីមិននិយម សំដៅយកការប្ជែកផ្សេងគ្នា នៃ ប្រការៈ ។ លោកសង្ត្រោះរួបរួមនូវភោគៈទាំងឡាយប្រាកដដូច្នោះ ផ្សេងដោយភោគៈ ដែលប្រណីតជាងគ្នា ជាដើម ដែលទេវតាបាន ក្នុងវិមាននោះ ដោយមិនសេសសល់ ដោយបទ ទាំង ២ យ៉ាង ។ ក៏និទ្ទេសនេះ ជានិទ្ទេសដែលរួបរួមសេចក្តី ដោយមិនមានសេស សល់ ដូចជាឧទាហរណ៍ថា សង្ខារទាំងឡាយឯណានីមួយ ដូច្នេះ ឯង ។ ២បទថា **មនសោ បិយា** បានដល់ ដែលចិត្ត គប្បី

ពណ្ណនាអំពីកម្មដែលមិនមានទោស

ស្រលាញ់, អធិប្បាយថា ជាទីស្រលាញ់នៃចិត្ត ។ ក៏លោកសំដែងការដល់ព្រម នៃពណ្ណិសម្បុរ ដែលរាប់បញ្ចូល ក្នុងអត្តភាព នៃទេវបុត្រនោះ ដែលពិសេស ដូចបានពោលមកហើយ ព្ធដ៏ខាងក្រោម ដោយ ២ បទនេះថា **ឯតាទិសោ វណ្ណោ** ក្នុងគាថានេះ ។ លោកសម្តែងការដល់ព្រម នៃកាមគុណ មានរូប សំឡេង ក្ខិនរស ផោដ្ឋព្ធ: ដែលជាទិព្ធ ជាប្រភេទ ដែលជាទីតាំង នៃគ្រឿងឧបភោគ និង គ្រឿងបរិភោគ ដោយបទថា **ភោគា** នេះ ។ លោកសម្តែងភាវ:នៃរូបទាំងឡាយជាដើមនោះ ថា ជាទីប្រាថ្នា ជាទីត្រូវការ និង ជាទីពេញចិត្ត ដោយ ២ បទថា **មនសោ បិយា** នេះ ។ លោកសម្តែងការដល់ព្រម នៃអាយុ ពណ្ណិសម្បុរ យសសក្តិ សេចក្តីសុខ និង ភាពជាអធិបតី ដែលជាទិព្ធ ដោយ ២ បទថា **ឥធ ឥជ្ឈតិ** នេះ ។ បទថា **បុច្ឆាមិ** គឺ អាត្មាសូមតាំងនូវបញ្ហា ។ អធិប្បាយថា អាត្មា ប្រាថ្នា ដើម្បីនឹងចង់ដឹង ។ ក៏ពាក្យសួរនេះ ជាពាក្យសួរ ដែលមានសម្បត្តិ គឺព្រះថេរ: បានយើញហើយ ជាគ្រឿងប្រៀបធៀប មែនពិត ។ បទថា **មនុស្សភូតោ** បានដល់កើត គឺ កើតហើយ ក្នុងមនុស្ស ឬថា ដល់ហើយ នូវភាពជាមនុស្ស ។ ២ បទថា **កិមកាសិ បុញ្ញំ** មានសេចក្តីថា អ្នកបានធ្វើ គឺ សន្សំនូវកុសលកម្ម ដែលជាសុចរិត ដែលបានឈ្មោះថា បុណ្យ

មន្តលត្ថនីបនីប្រែ

ព្រោះញ្ញាំងផលឲ្យកើត ក្នុងភពដែលគេបូជា និង ព្រោសំអាត គឺ ជម្រះ នូវសន្តាន ដែលជាទីកើតឡើង នៃខ្ជួនអ្វី គឺ ដូចម្តេច ក្នុងកុសលកម្ម មានទាន និង សីលជាដើម ជាប្រភេទៗ, អធិប្បាយ ថា ញ្ញាំងកុសលកម្ម ដូចម្តេច ឲ្យកើតឡើង? ។ បទថា ***ជលិតានុភាវោ*** *គឺ មានបុញ្ញឫទ្ធិ រុងរឿង ដោយប្រការទាំងពួង " ។*

(១៤៨) ទេវបុត្រ ត្រូវព្រះថេរៈសួរ យ៉ាងដូច្នេះ ហើយ កាលនឹងព្យាករនូវបញ្ហា ទើបបានពោលគាថាទាំងនេះ ថា ៖

"ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានកសាង [1] ទី បង្ក្រុម ត្រង់ផ្លូវ ក្នុងព្រៃផង ដាំដើមឈើ ជាស្ពានប្បារផង, ពួកអ្នកមានសីល បានជាទីស្រលាញ់នៃខ្ញុំផង, ខ្ញុំ មានបិត្ត ជ្រះថ្លា បានឱ្យនូវបាយ និង ទឹក ដែលជាទាន ដ៏ធំទូលាយ ដោយគោរព ។ សម្ឃុរ របស់ខ្ញុំ បានប្រាកដដូច្នោះ ព្រោះ បុញ្ញកម្មនោះ, ផលនៃសុបរិត រមែងសម្រេប ដល់ខ្ញុំ ក្នុង វិមាននេះ ព្រោះបុញ្ញកម្មនោះ, ម្ហយទៀត ភោគៈទាំងឡាយ ណានីម្ហយ ជាទីគាប់បិត្ត, ភោគៈទាំងឡាយនោះ រមែងកើត ឡើង ដល់ខ្ញុំ ព្រោះបុញ្ញកម្មនោះ ។ ខ្ញុំ ជាអ្នកមានអានុភាព

១- សុត្តន្តបិដក ភាគទី ៥៥ ទំព័រទី ១៥៩ ។

ពណ៌នាអំពីកម្មដែលមិនមានទោស

ដ៏រុងរឿង យ៉ាងនេះ និង សម្បុរ របស់ខ្ញុំ រមែងភ្លឺច្បាស់
សព្វទិសទី ព្រោះបុញ្ញកម្មនោះ" ។

*(១៤៩) អដ្ឋកថានៃមណិថិណ្ឌវិមាន ក្នុងសត្តមវគ្គ ថា បណ្តាបទទាំងនោះ បទថា **រិវនេ** បានដល់ ក្នុងព្រៃ ។ បទថា **អារាមរុក្ខានិ** បានដល់ ដើមឈើ ដែលជាទីរីករាយ, ម៉ាងទៀត បានដល់ ដើមឈើ ក្នុងសួនច្បារ ។ អធិប្បាយថា ខ្ញុំសាងសួនច្បារហើយ ក៏បានដាំដើមឈើទុក ក្នុងសួនច្បារនោះ" ។*

*អដ្ឋកថានៃខត្តរវិមាន ក្នុងឆដ្ឋមវគ្គ ថា " ពាក្យដែលសេសសល់ ថា **បរិច្ចជន្តោ** អ្នកសិក្សា គប្បីនាំយកមកសម្ពន្ធ ចូលគ្នាដោយ ២ បទថា **អន្នញ្ចា បានញ្ចា** ។ ម៉ាងទៀត គប្បីប្រកបពាក្យថា ខ្ញុំបានឲ្យទាន ដ៏បរិបូណិ ។ សួរថា បានឲ្យទាន យ៉ាងដូចម្តេច? ។ ឆ្លើយថា បានឲ្យដោយគោរព ។ សួរថា ទាន ដូចម្តេច? ។ ឆ្លើយថា ទាន គឺបាយ និង ទឹក ដូច្នេះ" ។*

រឿង ឧបាសក ក្នុងអដ្ឋកថាមណិថូណវិមាន ចប់ ។

(១៥០) ក្នុងអដ្ឋកថាសេរីសកវិមាន ក្នុងសត្តមវគ្គន៉ុះឯងលោកពោលថា "ក្នុងអតីតកាល ក្នុងកាលនៃព្រះពុទ្ធ ព្រះនាមថាកស្សបៈ, ព្រះខីណាស្រពមួយអង្គ និមន្តទៅ ក្នុងស្រុកមួយ ដើម្បីបិណ្ឌបាត បានធ្វើភត្តកិច្ច ក្នុងទីកន្លែងមួយ ខាងក្រៅស្រុក ជា

មន្តលត្ថនីបនីប្រែ

រៀងរាល់ថ្ងៃ ។ អ្នកចិញ្ចឹមគោម្នាក់ បានឃើញព្រះខីណាស្រព នោះហើយ ក៏គិតថា ព្រះគុណម្ចាស់ដ៏ចំរើន តែងលំបាក ព្រោះកំដៅ នៃព្រះអាទិត្យហើយ មានចិត្តជ្រះថ្លា បានធ្វើមណ្ឌបមែកឈើ ដោយសសរដើមច្រេស ៤ ដើម បានប្រគេនហើយ ។ អាចារ្យ ពួកខ្លះ ពោលថា អ្នកចិញ្ចឹមគោនោះ ដាំដើមច្រេស ក្បែរមណ្ឌប យ៉ាងដូច្នេះក៏មានដែរ ។ អ្នកចិញ្ចឹមគោនោះ ធ្វើមរណកាលហើយ ក៏បានទៅកើត ក្នុងពួកទេវតា ជាន់ចាតុមហារាជិក: ដោយបុញ្ញកម្ម នោះឯង ។ ព្រៃច្រេស ដ៏ល្អ ស្រស់បំព្រង សព្វៗ កាល ដោយ ផ្ការ ដល់ព្រមដោយពណ៌ និង ក្លិន ដែលបង្ហាញ នូវកម្មអំពីកាល មុន របស់ទេវបុត្រនោះ កើតឡើងហើយ ក្បែរទ្វារ នៃវិមាន ។ ព្រោះហេតុនោះ វិមាននោះ ទើបប្រាកដថា សេរីសក: ។ ក៏ទេវ-បុត្រនោះ អន្ទោល ទៅមក ក្នុងទេវតា និង មនុស្សទាំងឡាយ អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ ជាអ្នកឈ្មោះថា គវម្បតិ ក្នុង ចំណោមសំឡាញ់ ដែលជាគ្រហស្ថទាំង ៤ នាក់ របស់ព្រះ យសត្ថេរ មានវិមល: ជាដើម ស្ថិតនៅហើយ ក្នុងព្រះអរហត្ត ព្រោះធម៌ទេសនា របស់ព្រះមានព្រះភាគ " ។

(១៥១) ចំណែក ក្នុងអដ្ឋកថាបាយាសិសូត្រ ក្នុងមហាវគ្គ ក្នុងទីឃនិកាយ លោកពោលថា " បានញ្ញមកថា ព្រះថេរ: ក្នុងពេល

ពណ៌នាអំពីកម្មដែលមិនមានទោស

ជាមនុស្ស ក្នុងកាលមុន កើតជាប្រធាន នៃពួកក្មេងចិញ្ចឹមគោ បានសំអាតគល់ នៃដើមច្រេសដ៏ធំ ហើយរោយដីឆ្សាច់ ស្រេចហើយនិមន្តព្រះថេរ: មួយរូប ដែលប្រព្រឹត្តបិណ្ឌបាតជាវត្ត ឲ្យគង់នៅក្រោមដើមឈើ បានប្រគេនអាហារ ដែលខ្ជួនបានហើយ ច្យុតពីទីនោះហើយ ក៏បានទៅកើត ក្នុងវិមានប្រាក់នោះ ដោយអានុភាពនៃកម្មនោះ ។ ដើមច្រេសនោះ បានស្ថិតនៅហើយ ក្បែរមាត់ទ្វារនៃវិមាន ។ ដើមច្រេសនោះ តែងចេញផល ដោយ ៥០ ឆ្នាំ ។ គ្រានោះ ទេវបុត្រ ដល់នូវសេចក្តីសង្វេគ ថា ៥០ ឆ្នាំ កន្ងងផុតទៅហើយ ។ ទេវបុត្រនោះ បានមកកើត ក្នុងពួកមនុស្ស ក្នុងកាលនៃព្រះមានព្រះភាគ របស់យើងទាំងឡាយ បានស្តាប់នូវព្រះធម្មកថា របស់ព្រះសាស្តាហើយ ក៏បានសម្រេចព្រះអរហត្ត " ។

ដីកានៃបាយាសិសូត្រនោះថា " បទថា **តស្សានុភាវេន** គឺ ដោយអានុភាពនៃទាននោះ ។ ដើមច្រេស ដែលជាទិព្ធ បរិបូណិ ដោយដើម ប្រគាប មែក និង សន្ទឹក ជាទីផ្សាយពេញ នៃរស្មីសម្តែងនូវផលដែលជាទីគាប់ចិត្ត ឈ្មោះថា សិរីសរុក្ខ: ។ បទថា **អដ្ឋាសិ** មានសេចក្តីថា ដើមច្រេសនោះ បានដុះ ស្ថិតនៅហើយ ក្បែរមាត់ទ្វារនៃវិមាន សំដែងនូវភាវ:នៃផល ដែលបណ្ឌិតគប្បីយើញសមស្មើដោយកម្ម " ។ **រឿង អ្នកចិញ្ចឹមគោ ចប់ ។**

មន្តលត្ថទីបនីប្រែ

(១៥២) កម្ម ដែលមិនមានទោសទាំងឡាយ មានកិរិយាសមាទាន នូវអង្គនៃខុបោសថ ជាដើម បណ្ឌិត គប្បីជ្រាបថា ជា ***មង្គល*** *ព្រោះជាហេតុនៃការបានសម្រេច នូវប្រយោជន៍សុខ មានការកើត ក្នុងឋានសួគិជាដើម មានប្រការផ្សេងៗ យ៉ាងដូច្នេះឯង ។*

ពណ៌នាអំពីកម្មដែលមិនមានទោស ចប់ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ពួក ៤ នៃមង្គល គឺ ទាន ១ កិរិយាប្រព្រឹត្តិធម៌ ១ កិរិយាសង្គ្រោះនូវញាតិ ១ ការងារដែលមិនមានទោស ១ ដោយព្រះគាថានេះឯង ដោយប្រការដូច្នេះ ។

ក្នុងគាថា ទី ៥ នេះ បាទខាងដើម មានអក្សរ ៩ តួ, បាទ ទី ២ ត្រឹមត្រូវ តាមលក្ខណៈ នៃបាទ ទី ២ នៃបឋ្យាវត្ត, កន្ទះគាថា ទី ២ ជាបឋ្យាវត្ត ដូច្នេះឯង ។

ពណ៌នាសេចក្ត្តីនៃគាថា ទី ៥ ចប់ ។

ប្រែចប់ ថ្ងៃព្រហស្សតឹ ១៣ រោច ខែជេស្ឋ ព.ស. ២៥៣៦

ពណ៌នាសេចក្តីនៃគាថា ទី ៦

(១៥៣) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ៦ ។ ការវៀរ ឈ្មោះ ថា **អារតិ** ។ ការវៀរស្រឡះ ឈ្មោះថា **វិរតិ** ។ ម្យ៉ាងទៀត ជនទាំងឡាយ រមែងវៀរ ដោយចេតនាទុ៎ះ ព្រោះហេតុនោះ ចេតនាទុ៎ះ ឈ្មោះថា វិរតិ ។ បទថា "**បាបា**" គឺ ចាកបាប បានដល់ ចាកអកុសល ។ បទថា "**មជ្ជបានា**" គឺ ចាកការផឹក បានដល់ ចាកការលេបចូល នូវសុរា និង មេរ៉ាយ ដែលឈ្មោះថា មជ្ជៈ ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ។ សេចក្តីសង្រ្ទួម ឈ្មោះ ថា **សញ្ញមៈ** ។ សេចក្តីមិនប្រមាទ ឈ្មោះថា **អប្បមាទៈ** ។ បទថា "**ធម្មេសុ**" គឺ ក្នុងកុសលធម៌ទាំងឡាយ ។ បទថា "**ឯតំ**" ជាដើម មានសេចក្តីថា " ម្នាលទេវតា អ្នកចូរសម្គាល់យក ថា កិរិយាមិនត្រេកអរ កិរិយាវៀរ ចាកបាប ១ សេចក្តីសង្រ្ទួម ចាកការផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ក្នុងធម៌ទាំងឡាយ ១, កម្មទាំង ៣ យ៉ាង មានកិរិយាវៀរ ចាកបាប ជាដើមនេះ ជាមង្គល ដ៏ឧត្តម ដូច្នេះ " ។

សេចក្តីសង្ខេប ក្នុងគាថា ទី ៦ នេះ មានតែប៉ុណ្ណេះឯង ។

ចំណែកសេចក្តីពិស្តារ ក្នុងគាថា ទី ៦ នេះ មានដូចតទៅនេះ ៖

១០ បវិរតិមជ្ឈបានសំយមកថា

(វិរតិ ៣ យ៉ាង)

(១៥៤) សេចក្ដីមិនត្រេកអរក្រៃលែង ក្នុងចិត្ដនុ៎ះឯង នៃបុគ្គលអ្នកមានប្រក្រតីយើញទោស ក្នុងបាប ឈ្មោះថា អារតី ។ កិរិយាវៀរ ចាកបាប ដោយកាយ និង វាចា ដោយអំណាច នៃកម្ម និង ទ្វារ ឈ្មោះថា វិរតិ ។ វិរតិ នោះ មាន ៣ យ៉ាង គឺ សម្ផត្ដវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ។ ឥឡូវនេះ ខ្ញុំ នឹងពោលបំព្ងេញ វិរតិ ទាំង ៣ យ៉ាង តាមន័យដែលព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាអដ្ឋសាលិនី ជាដើម ។

(១៥៥) ន័យដែលមក ក្នុងអដ្ឋកថា នៃអដ្ឋសាលិនី និងសម្ផាទិដ្ឋិសូត្រ ថា " បណ្ដាវិរតិ ទាំង ៣ នោះ វិរតិ ដែលកើតឡើង ដល់បុគ្គលទាំងឡាយ អ្នកដែលមិនបានសមាទានសិក្ខាបទ (តែ) បានពិចារណានូវហេតុ:ទាំងឡាយ របស់ខ្លួន មានជាតិ វ័យ និង ពាហុសច្ចៈ ជាដើមហើយ មិនបានកន្ទ្ងន់ នូវវត្ដុដែលមកជួបប្រទះ ដោយនឹកគិតថា ការធ្វើយ៉ាងដូច្នេះ មិនសមគួរហើយ ដល់ពួកយើង ដូច្នេះ បណ្ឌិត គប្បីជ្រាបថា សម្ផត្ដវិរតិ ដូចជាវិរតិ របស់ឧបាសក ឈ្មោះថា ចក្ខនៈ ក្នុងកោះសីហឬ: ដូច្នោះឯង " ។

បានឮមកថា ក្នុងកាលដែលចក្ខនឧបាសកនោះ នៅក្នុងនុ៎ះឯង រោគ កើតឡើងហើយ ដល់មាតា ។ ក៏ត្រូវពេទ្យ ប្រាប់ថា

១០០ និងវិតិមជ្ឈបានសំយមកថា

" ការបាន នូវសាច់ទន្សាយស្រស់ៗ (មកផ្សុំថ្នាំ) ទើបគួរ " ។ គ្រានោះ បងប្រុស របស់កុមារចក្ខុនៈនោះ បានបញ្ជូន នូវកុមារ ចក្ខុនៈ ទៅដោយប្រាប់ថា "នែប្អូន អ្នកចូរទៅស្រែស្វែងរកចុះ" ។ កុមារ ចក្ខុនៈនោះ បានទៅ ក្នុងស្រែនោះហើយ ។ ពេលនោះ ទន្សាយមួយ មកដើម្បីស៊ីស្រូវខ្ចី ឃើញកុមារចក្ខុនៈហើយ ទើប ចោលទៅ យ៉ាងលឿន ត្រូវវ័ណ្ណិតន្ទ្ធហើយ ទើបស្រែកឮ ថា កិរិ កិរិ ដូច្នេះ ។ កុមារចក្ខុនៈ បានឮសំឡេងនោះហើយ ក៏ទៅចាប់ មក ដោយគិតថា អញ នឹងធ្វើថ្នាំឲ្យមាតា ដូច្នេះ (តែ) គិតថា ការ ដែលអាត្មាអញ គប្បីផ្តាច់បង់សត្វដទៃ ចាកជីវិត ព្រោះហេតុ នៃ ជីវិត របស់មាតានោះ មិនសមគួរ ដល់អាត្មាអញសោះឡើយ ដូច្នេះហើយ ក៏បានដោះលែងទៅ ដោយពោលថា អ្នកចូរទៅ ចុះ, ចូរស៊ីស្មៅ ផឹកទឹក ជាមួយនឹងទន្សាយទាំងឡាយ ក្នុងព្រៃ ចុះ ។ កុមារចក្ខុនៈនោះ ទៅផ្ទះ ត្រូវបងប្រុសសួរហើយ ក៏ប្រាប់ រឿងនោះ ត្រូវបងប្រុសនោះ ជេរប្រទេច ទើបទៅកាន់សំណាក់ របស់មាតាហើយ បានឈរ ពោលពាក្យសច្ចៈ មានជាអាទិ៍ ថា តាំងអំពីកាលដែលអាត្មាអញ កើតហើយ ដោយជាតិ មិនចេះ ក្ងែងផ្តាច់ផ្តិលជីវិតសត្វឡើយ ។ ក្នុងខណៈនោះភ្លាម មាតា របស់ កុមារចក្ខុនៈនោះ ក៏ជាអ្នកបានជាសះស្បើយពីរោគអស់ហើយ ។

មង្គលត្ថទីបនីប្រែ

ដីកាសម្មាទិដ្ឋសូត្រ ថា " សាច់ទន្សាយដែលរស់ ឈ្មោះថា សាច់ទន្សាយស្រស់ៗ ព្រោះជាសាច់ដែលប្រឡាក់ដោយឈាម ។ កុមារចក្ខនៈនោះ ដោះលែងទន្សាយទៅ ព្រោះកិរិយាធ្វើស្មើគ្នា ចំពោះសត្វគ្រប់ជំពូក ។ កុមារចក្ខនៈនោះ ពោលពាក្យសច្ចៈ ថា ដោយកិរិយាពោលពាក្យសច្ចៈនេះ សូមឲ្យរោគ របស់មាតា នៃខ្ញុំ ចូរស្ងប់រម្ងាប់ទៅ " ។

(១៥៦) អដ្ឋកថាកូដទន្តសូត្រ ថា " បុគ្គល ណា មិនបាន ទទួលនូវសិក្ខាបទទាំងឆ្លាយទេ តែនឹករលឹកដល់ឋានៈទាំងឆ្លាយ របស់ខ្លួន មានជាតិ គោត្រ ត្រកូល និង ប្រទេស ជាដើម តែម្យ៉ាង ហើយ មិនធ្វើអកុសលកម្មទាំងឆ្លាយ មានបាណាតិបាត ជាដើម លះបង់នូវវត្ថុដែលបានជួបប្រទះ ដោយគិតថា កម្មនេះ មិនសម គួរ ដល់អាត្មាអញទេ្ឋយ ដូច្នេះ ឈ្មោះថា រៀរ លះបង់ ចាកវត្ថុ នោះ, ការរៀរនោះ របស់បុគ្គលនោះ បណ្ឌិត គប្បីជ្រាបថា ជា សម្ឆត្តវិរតិ ។ ចំណែក វិរតិ របស់បុគ្គលអ្នកដែលទទួលយក សិក្ខាបទទាំងឆ្លាយ ដោយនយ័ដូច្នេះ ថា ក្នុងពេលមានថ្ងៃនេះ ជា ដើមទៅ អាត្មាអញ នឹងមិនស្ងាប់សត្វ សូម្បីព្រោះហេតុ នៃជីវិត ដូច្នេះជាដើមក្តី ថា អាត្មាអញ នឹងរៀរ ចាកបាណាតិបាត ដូច្នេះ ជាដើម ក្តី ថា អាត្មាអញ សមាទានចេតនាជាហេតុរៀរ ដូច្នេះ ក្តី

បណ្ឌិត គប្បីជ្រាបថា សមាទានវិរតិ ដូច្នេះ" ។

ដីកានៃកូដទន្តសូត្រនោះថា " បទថា ***បរិហរតិ*** *គឺ រមែង វៀរ ដោយអំណាចការមិនប្រព្រឹត្តិកន្លង ។* ***ឥតិ*** *សព្ទ ក្នុងបទថា* ***នហនាមិ*** *នេះ មាន* ***អាទិ*** *សព្ទ ជាអត្ថ ។ បណ្ឌិត គប្បីធ្វើការ សង្គ្រោះសិក្ខាបទទាំងឡាយ មានជាអាទិ៍ យ៉ាងដូច្នេះថា* ***អទិន្នំ នាទិយាមិ*** *ដូច្នេះ ដោយ* ***ឥតិ*** *សព្ទនោះ ។ ម្យ៉ាងទៀត គប្បី ធ្វើការសង្គ្រោះសិក្ខាបទទាំងឡាយនោះ ដោយ* ***វា*** *សព្ទ (ក៏បាន ដែរ) ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា* ***សិក្ខាបទានិ គណ្ហន្តស្ស*** *ដូច្នេះ" ។*

(១៥៧) ន័យ ក្នុងអដ្ឋកថា នៃសម្មាទិដ្ឋិសូត្រ ជាដើម ថា " ក៏វិរតិ ដែលកើតឡើង ដល់ជនទាំងឡាយ អ្នកដែលសមាទាន នូវសិក្ខាបទហើយ ព្រមលះបង់សូម្បីជីវិត របស់ខ្លួន ទាំងក្នុងពេល សមាទានសិក្ខាបទ ទាំងក្នុងពេលដទៃក្រៅអំពីនោះ មិនប្រព្រឹត្ត កន្លងនូវវត្ថុ បណ្ឌិតគប្បីជ្រាបថា សមាទានវិរតិ ដូចជាវិរតិ របស់ ឧបាសកអ្នកនៅក្បែរភ្នំ ឈ្មោះទន្តវឌ្ឍមានៈ ដូច្នោះ" ។

បានឮថា ឧបាសកនោះ ទទួលសិក្ខាបទ ក្នុងសំណាក់ នៃ ព្រះបិង្គលពុទ្ធរក្ខិតត្ថេរ អ្នកនៅក្នុងអម្ពរិយវិហារ ហើយភ្ជួរស្រែ កាលបើគោបាត់ហើយ ក៏ស្វែងរកគោនោះ បានឡើងទៅ លើភ្នំ

មន្តលត្ថទីបនីប្រែ

ឈ្មោះទន្តរវឌ្ឍមានៈ ហើយ ។ ពស់ ដ៏ធំ លើភ្នំនោះ បានរូបរឹត ឧបាសកនោះហើយ ។ ឧបាសកនោះ គិតថា " អាត្មាអញ នឹងកាត់ក្បាលពល់នោះ ដោយកំបិតដ៏មុតនេះ" ដូច្នេះ បានគិតហើយ គិតទៀត ដល់ទៅលើក ទី៣ យ៉ាងនេះ ថា " ការដែលអាត្មាអញ គប្បីទទួលសិក្ខាបទ ក្នុងសំណាក់នៃគ្រូអ្នកដែលគួរសសើរហើយ គប្បីទំលាយចោលនោះ មិនសមគួរ ដល់អាត្មាអញសោះឡើយ" ដូច្នេះហើយ បានកាត់ចិត្តថា " អាត្មាអញ នឹងលះបង់នូវជីវិត, នឹងមិនលះបង់នូវសិក្ខាបទឡើយ " ហើយ ក៏បានបោះកំបិតព្រាដ៏មុតដែលលីលើស្មា ចោលក្នុងព្រៃហើយ ។ ក្នុងខណៈនោះឯង ពស់ដ៏ធំ ក៏បានរលាត វារទៅហើយ ភ្លាមមួយរំពេច " ។

ដីកានៃសម្មាទិដ្ឋិសូត្រ ថា " ពស់ថ្លាន់ ឈ្មោះថា ពស់ដ៏ធំ, ពស់ដ៏ធំនោះ បានរលាត វារទៅហើយ ដោយតេជនៃសីល " ។

(១៥៨) អដ្ឋកថានៃសម្មាទិដ្ឋិសូត្រ ជាដើម ថា " ក៏សូម្បីសេចក្តីគិត ថា អាត្មាអញ នឹងសម្លាប់សត្ធ ដូច្នេះ រមែងមិនកើតឡើង ដល់ព្រះអរិយបុគ្គលទាំងឡាយ ចាប់ដើមតាំងអំពីការកើតឡើងនៃវិរតិ ណា, វិរតិ នោះ សម្បយុត្ត ដោយអរិយមគ្ត បណ្ឌិតគប្បីជ្រាបថា សមុច្ឆេទវិរតិ ដូច្នេះ " ។

ក៏ក្នុងពាក្យទាំងនេះ ដោយពាក្យថា "**ចិត្តម្បិ ន ឧប្បជ្ជតិ**"

ឧបវិរតិមជ្ឈឧានសំយមកថា

ជូច្នេះនុ៉ះ ព្រះអដ្ឋកថាចារ្យ សម្តែង ថា " ចិត្ត ដែលជាហេតុបង្ក ពៀរ ៥ យ៉ាង ស្ងប់រម្ងាប់ហើយ មែនពិត " ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា "ភ័យ ពៀរទាំងឡាយ ៥ យ៉ាង របស់ព្រះអរិយសាវ័ក ជាធម្មជាតស្ងប់រម្ងាប់អស់ហើយ ចាប់ ដើមតាំងអំពីសេចក្តីប្រព្រឹត្តិទៅ នៃ វិរតិ ឯណា, វិរតិ នោះ សម្បយុត្ត ដោយអរិយមគ្ត ឈ្មោះថា **សមុច្ឆេទវិរតិ** ។

បណ្តាបទទាំងនោះ ចេតនា ជាហេតុបង្កភ័យ និង ពៀរ ទាំងឡាយ ឈ្មោះថា ភ័យ ពៀរទាំងឡាយ ។

សរុបវិរតិ ៣ យ៉ាង ចប់ ។

(កម្មកិលេស ៤ យ៉ាង)

(១៥៩) អកុសលកម្ម ៤ យ៉ាង ពោលគឺ កម្មកិលេស ឈ្មោះថា បាប ។ សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់បានត្រាស់ ក្នុងសិគាលសូត្រ ថា " កម្មកិលេសទាំងឡាយ ៤ ឯណា នីមួយ ជាកម្មកិលេសដែលព្រះអរិយសាវ័កនោះ លះបង់ បានហើយ ។ ម្នាលគហបតីបុត្រ គឺ ការសម្ងាប់សត្វមានជីវិត ជាកម្មកិលេស ការយកទ្រព្យរបស់អ្នកដទៃ ដែលគេមិនបានឲ្យ ជាកម្មកិលេស ការប្រព្រឹត្តិខុស ក្នុងកាមទាំងឡាយ ជាកម្ម-កិលេស ការពោលពាក្យកុហក ជាកម្មកិលេស, កម្មកិលេស

មន្ទលត្ថទីបនីប្រែ

ទាំង ៤ យ៉ាងនេះ ជាបាបកម្ម ដែលព្រះអរិយសាវកនោះ លះបង់បានហើយ " ។

ព្រះដ៏មានព្រះភាគ បានត្រាស់សូត្រនេះហើយ លុះព្រះសុគត ជាសាស្តា ទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបទ្រង់ត្រាស់គាថាពន្ធនេះ តទៅទៀត ថា ៖

" បណ្ឌិតទាំងឡាយ តែងមិនសរសើរកម្មកិលេស ៤ យ៉ាង គឺ បាណាតិបាត ១ អទិន្នាទាន ១ មុសាវាទ ១ ការគប់រកភរិយា របស់អ្នកដទៃ ១ ដែលបណ្ឌិតហៅថា (ជាកម្ម-កិលេស) " ។

*ជីកានៃសិគាលសូត្រនោះ ថា " បទថា **កតមស្ស** កាត់បទជា **កតមេ អស្ស** " ។*

*បណ្តាបទទាំងនោះ បទថា " **អស្ស** " បានដល់ ដែលព្រះអរិយសាវក ជាព្រះសោតាបន្ន ។*

*(១៦០) ព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថានៃសិគាលសូត្រនោះថា " បទថា **កម្មក្កិលេសា** នេះ មានវិនិច្ឆ័យ ថា៖ សត្វទាំងឡាយ រមែងសៅហ្មង ព្រោះកម្មកិលេសទាំងឡាយនោះ ព្រោះហេតុនោះ កម្មកិលេសទាំងឡាយនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា កម្មកិលេស " ដូច្នេះហើយ ពោល*

១០ និវត្តិមជ្ឈបានសំយមកថា

*បន្តទៅទៀតថា " កម្មនោះផង ឈ្មោះថា ជាកិលេស ព្រោះភាវៈជាកម្ម ដែលសម្បយុត្ត ដោយកិលេសផង ហេតុនោះ ទើបឈ្មោះថា កម្មកិលេស ។ មែនពិត បុគ្គលអ្នកមានកិលេសប៉ុណ្ណោះ រមែងសម្ងាប់សត្វ, បុគ្គលអ្នកមិនមានកិលេស រមែងមិនសម្ងាប់សត្វទ្បើយ ព្រោះហេតុនោះ ចាណាតិបាត ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាកម្មកិលេស ។ សូម្បីក្នុងអទិន្នាទាន ជាដើម ក៏នយនេះ ដូចគ្នាដែរ ។ បទថា **អថាបរំ** បានដល់ គាថាពន្ធ សូម្បីដទៃទៀត គឺ ដែលសម្តែងនូវសេចក្តីនោះឯង " ។*

*(១៦១) ដីកានៃសិគាលសូត្រនោះថា "កិលេសទាំងឡាយ ដែលជាតួកម្ម ឈ្មោះថា កម្មកិលេស ។ បទថា **កិលិស្សន្តិ** ប្រែថា សៅហ្មង គឺ មួហ្មង, អធិប្បាយថា សត្វទាំងឡាយ ជាអ្នកត្រូវកម្មកិលេសនោះ ចៀតចៀន និង ដុតរោលហើយ ។ បទថា **តស្មា** បានដល់ ព្រោះភាវៈនៃកម្មនោះ មានសេចក្តីសៅហ្មង ជានិមិត្ត ។ ២ បទថា **កិលេសសម្បយុត្តត្តា កិលេសោ** ព្រះអដ្ឋកថាចារ្យ ពោលភាវៈនៃកម្មប្រព្រឹត្តទៅ មួយអន្ទ្ធ ដោយកិលេសនោះ ព្រោះប្រកបដោយកិលេសនោះ ដូចជាឧទាហរណ៍ថា បឋមឈាន មាន ប៉ីតិ និង សុខ និង ថា សំពត់មានពណ៌ខៀវយ៉ាងដូច្នេះ ។ ក៏ភាវៈនៃកម្មសម្បយុត្ត ដោយកិលេស ក្នុងបទថា*

មង្គលត្ថទីបនីប្រែ

កម្មកិលេសោ នេះ បណ្ឌិតគប្បីជ្រាប ដោយការៈនៃកម្មដែលមានសេចក្ដីដូចគ្នាតែមួយនឹងកិលេសនោះ, មិនគប្បីជ្រាប ដោយការៈជាកម្មដែលកើតឡើង ក្នុងខណៈជាមួយគ្នា ជាដើមឡើយ ។ ក៏ព្រោះធ្វើសេចក្ដីអធិប្បាយ យ៉ាងដូច្នេះ ការៈនៃកម្មគឺបាណាតិបាតជាធម្មជាតិសៅហ្មងហើយ សូម្បីព្រោះកិលេសទាំងឡាយ មានទិដ្ឋិ មានៈ និង លោភៈជាដើម ទើបជាការសម្រេចហើយ ។ ការៈនៃមិច្ឆាចារ ជាបាបធម៌សៅហ្មងហើយ ព្រោះកិលេសមានទោសៈជាដើម ក៏យ៉ាងដូច្នោះដែរ ។ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើម ថា ***សក្តិលេសោ យេវ*** ដូច្នេះ ។ ចំណែកឯ ការពោលបរិយាយនូវកម្មទាំងនោះ ថា ជាកិលេស រមែងបាន សូម្បីដោយទីចំពោះមុខតែម្ដង ដោយអំណាចនៃសេចក្ដី ដែលបានពោលហើយក្នុងកាលមុន ។ បទថា ***តទត្ថបរិទីបកមេវ*** គឺ សេចក្ដីឯណាមួយ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយនយជាដើមថា ***បាណាតិបាតោ ទោ*** ដូច្នេះ, ដែលសម្ដែងសេចក្ដីនោះឯង ។ ដើម្បីនឹងចៀសវាងបញ្ហា ថា បើដូច្នោះ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ម្ដងទៀត? ដូច្នេះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា ***គាថាពន្ធំ*** ដូច្នេះ ។ អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះតម្រាស់ ជាគាថាពន្ធទុក ដើម្បីកំណត់យក

សេចក្ដីនោះ បានដោយងាយស្រួល ដូច្នេះ " ។

*(១៦២) ព្រោះព្រះបាលីថា " **កម្មុក្ខិលេសា** " ដូច្នេះ ទើបគួរប្រកាន់យកអកុសលធម៌ មានបាណាតិបាត ជាដើម ដែលដល់ភាពជាកម្មបថប៉ុណ្ណោះ, មិនគួរប្រកាន់យកអកុសលធម៌ ដែលគ្រាន់តែជាទុច្ចរិតទ្បើយ ។ ព្រោះថា អកុសល ដែលមិនមែនជាកាយកម្ម និង វចីកម្ម គប្បីពោលថា "ទុច្ចរិត" ដូច្នេះ ក៏មាន ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ពោលហើយថា ក្នុងអដ្ឋកថា ឈ្មោះថាអដ្ឋសាលិនី ថា " ក៏អកុសល ដល់នូវការកម្រើក ញាប់ញ័រ ក្នុងកាយទ្វារ និង វចីទ្វារ ទាំងឡាយហើយ សូម្បីមិនដល់នូវកម្មបថ ក៏មាន, មួយទៀត អកុសល ដែលដល់នូវការផ្ទុសឡើងក្នុងមនោទ្វារហើយ សូម្បីមិនដល់នូវកម្មបថ ក៏មាន, បណ្ឌិតទាំងឡាយ ប្រកាន់យកអកុសល ដែលមិនទាន់ដល់ភាពជាកម្មបថនោះ ហើយ ទើបបានធ្វើឲ្យទៅជាបក្សពួក នៃទ្វារនោះ ៗ ប៉ុណ្ណោះ ។*

ក្នុងពាក្យនោះ មានន័យ ដូចតទៅនេះ គឺ ៖

បុគ្គល គិតថា " អាត្មាអញ នឹងដេញសត្វម្រ៉ីគ " ហើយត្រៀមនូវធ្នូ រ៉ាមនូវខ្សែ សំលៀងចួក បរិភោគអាហារ ស្ងៀកសំពត់, ព្រោះហេតុមានប្រមាណប៉ុណ្ណេះឯង អកុសល រមែងជាធម្មជាតិ ដល់នូវការកម្រើក ញាប់ញ័រ ក្នុងកាយទ្វារ ។ បុរស

មន្តលត្ថនីបនីប្រែ

នោះត្រាច់ទៅ ក្នុងព្រៃ អស់មួយថ្ងៃ តែងមិនបាន ដោយហោចទៅ សូម្បីត្រឹមតែទន្សាយ និង ខ្លាត្រី, សួរថា អកុសលនេះ នឹងឈ្មោះ ថា ជាកាយកម្ម ឬក៏ មិនមែនជាកាយកម្ម? ។ ឆ្លើយថា អកុសល នេះ មិនឈ្មោះថា កាយកម្មទេ ។ ព្រោះហេតុអ្វី ទើបមិនមែនជា កាយកម្ម? ។ ព្រោះមិនទាន់ដល់កម្មបថ ។ តែ អកុសលនេះ បណ្ឌិត គប្បីជ្រាបថា ឈ្មោះថា ជាកាយទុច្ចរិច តែម៉ាង ។ សូម្បី ក្នុងប្រយោគទាំងឡាយ មានការចាប់ត្រីជាដើម ក៏នយនេះ ដូចគ្នា ដែរ ។ គប្បីជ្រាបវិនិច្ឆយ សូម្បីក្នុងវចីទ្វារ (ដូចតទៅនេះ) ៖ កាលបើ បុគ្គលបញ្ជា ថា ខ្ញុំ នឹងទៅ ដេញសត្វម្រឹគ, ពួកអ្នកចូរ រៀបចំនូវសស្ត្រាវុធ មានធ្នូជាដើម ដោយប្រញាប់ ដូច្នេះហើយ មិន បានអ្វីៗ ក្នុងព្រៃ ដោយនយមុន ដូចគ្នាដែរ, អកុសល ដល់នូវ ការកម្រើក ក្នុងវចីទ្វារ ក៏ពិតមែនហើយ, ទោះបីជាដូច្នោះ ក៏មិន ទាន់ចាត់ថា ជាវចីកម្មដែរ ព្រោះមិនទាន់ដល់នូវកម្មបថ, ប៉ុន្តែគប្បី ជ្រាបថា ឈ្មោះថា ជាវចីទុច្ចរិត តែម៉ាង ។ ប៉ុន្តែកាលបើចេតនា អ្នកគិតនឹងសម្លាប់ គ្រាន់តែកើតឡើងហើយ ក្នុងមនោទ្វារ, ការ បែកធ្លាយនៃកម្មបថ ក៏រមែងមាន ។ ក៏ការបែកធ្លាយ នៃកម្មបថ នោះឯង រមែងមាន ដោយអំណាចនៃព្យាបាទ, មិនមែនមាន ដោយអំណាច នៃបាណាតិបាត ទេ ។ ព្រោះកាយកម្ម ដែលជា

ឧបាទិរតិមជ្ជបានសំយមកថា

អកុសល រមែងតាំងឡើង ក្នុងកាយទ្វារ និង វចីទ្វារ ទាំងឡាយ, មិនមែនតាំងឡើង ក្នុងមនោទ្វារទេ ។ វចីកម្ម ដែលជាអកុសល ក៏ជូច្នោះដែរ ។ ចំណែក មនោកម្ម ដែលជាអកុសល រមែងតាំងឡើង ក្នុងទ្វារសូម្បីទាំង ៣ ។ កាយកម្ម វចីកម្ម មនោកម្ម ទាំងឡាយ ផ្នែកខាងកុសល ក៏ជូច្នោះដែរ " ។

(១៦៣) ជីកានៃអដ្ឋកថា អដ្ឋសាលិនីនោះ ថា " ចេតនា ដែលញ្ចុាំងប្រយោគ ឲ្យសម្រេច ដែលជល់ភាពជាកម្មបថន៉ុះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **កម្ម** ដោយព្រះបាលីថា៖ ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ទាំង ៣ ប្រការ គឺ ជាកាយកម្ម ចំណែកខាងអកុសល ជូច្នេះជាដើម ព្រោះហេតុនោះ ចេតនា ដែលមានខាងដើមទាំងអស់ ព្រះអដ្ឋកថាចារ្យ ទើបពោលថា មិនមែនជាកាយកម្ម ។ ពាក្យថា **អាណាបេត្វា** ។បេ។ **អលកន្តស្ស** ព្រះអដ្ឋកថាចារ្យ ពោលសំដៅយកភាវៈនៃសត្វនោះ គឺ អ្នកដែលត្រូវគេបង្គាប់មិនបានសម្ងាប់ ។ អធិប្បាយថា អកុសលនោះ ឈ្មោះថា វចីទុច្ចរិត ព្រោះភាវៈមិនមែនជាកម្មបថ " ។

ក៏ការរៀរចាកបាបនោះ ដែលខ្ញុំសរុបពោល ចប់ ។

(១៦៤) វត្ថុជាហេតុនៃសេចក្តីស្រវឹង ១០ យ៉ាង ដោយអំណាចនៃសុរា ៥ យ៉ាង និង មេរ័យ ៥ យ៉ាង ឈ្មោះថា ទឹក

មន្តលត្ថទីបនីប្រែ

ស្រវឹង ។ សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងសុភបានសិក្ខាបទវិភង្គ ថា "សុភ ធ្វើដោយម្សៅ ១ សុភធ្វើដោយនំ ១ សុភធ្វើដោយបាយ ១ សុភដែលគេដាក់ពូជសុភ ១ សុភដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេង ៗ ១ ឈ្មោះថា **សុភ** ។ ទឹកត្រាំដែលគេធ្វើដោយផ្តាឈើ ១ ទឹកត្រាំដែលគេធ្វើដោយផ្ទែឈើ ១ ទឹកត្រាំ ដែលគេធ្វើដោយផ្ទែចន ឬគេធ្វើដោយទឹកឃ្មុំ ១ ទឹកត្រាំដែលគេធ្វើ ដោយទឹកអំពៅ ១ ទឹកត្រាំដែលប្រកបដោយគ្រឿងផ្សំផ្សេងៗ ១ ឈ្មោះថា **មេរ័យ** " ។

(១៦៥) ដីកាឈ្មោះថាសារត្ថទីបនី និង ដីកាសិគាលសូត្រ ថា " សុភដែលគេដាក់ម្សៅ ក្នុងភាជនៈហើយ ថែមទឹកឲ្យសមគួរដល់ម្សៅនោះ ច្របាច់ធ្វើ ឈ្មោះថា សុភធ្វើដោយម្សៅ ។ សុភដែលដាក់នំក្តី បាយក្តី ក្នុងភាជនៈ ហើយថែមទឹក ឲ្យល្មមសមគួរដល់នំ ឬ បាយនោះ ច្របាច់ធ្វើ យ៉ាងដូច្នោះ លោកហៅថា សុភធ្វើដោយនំ សុភធ្វើដោយបាយ ។ ក៏ពូជ នៃសុភនោះ ឈ្មោះថាពូជ (មេដំបែ) ។ ពូជទាំងឡាយណា ដែលគេហៅថា មេដំបែនៃសុភ ដូច្នេះខ្ញុះ, សុភ ដែលគេដាក់នូវពូជទាំងឡាយនោះ ហើយធ្វើ ឈ្មោះថា សុភដែលដែលដាក់ពូជសុភ ។ សុភ ដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេង ៗ មានផ្ទែសម៉ និង គ្រាប់ស្ពៃ ជាដើម

១០ និងវិនិមជ្ឈបានសំយមកថា

ឈ្មោះថា សុភ ដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ " ។

ដីកាវិមតិវិនោទនីថា "សុភដែលគេដាក់វត្ថុមានមេរ្យ និង ទំ ជាដើម ហើយដាក់ពូជ (ពេ) សុភ មានពន្ធកស្រូវជាដើមដែលរាប់ ថា ជាពូជ ហើយធ្វើ ឈ្មោះថា សុភដែលគេដាក់ពូជសុភ ។ សុភ ដែលគេប្រកបព្រម ដោយគ្រឿងផ្សំច្រើនយ៉ាង មានគ្រាប់ស្ពៃជា ដើម ឈ្មោះថា សុភដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ" ។

(១៦៦) អដ្ឋកថាសុភបានសិក្ខាបទ ថា " បានជាត ដែល គេដាក់ពូជមេរ្យ ឈ្មោះថា សុភ, បានជាត ដែលគេធ្វើ ដោយ រសជាតិ សូម្បីនៃផ្លែជូងជាដើម រមែងដល់ នូវការរាប់ថា សុភ ជូចគ្នាដែរ ។ អាចារ្យពួកខ្លះ ពោលថា កាលបើគេជង់យករស ដ៏ ប្រសើរ (ទឹកថ្នា) នៃសុភដែលគេដាក់ពូជ (ពេ) នោះឯងហើយ, សុភ ដែលនៅសល់ ក៏រមែងដល់ នូវការរាប់បញ្ចូលថា ជាមេរ័យ មួយរំពេច ។ ទឹកត្រាំ ដែលគេធ្វើ ដោយរសជាតិ នៃផ្លាឈើទាំង ឡាយ មានផ្លាចន់ជាដើម ឈ្មោះថា ទឹកត្រាំ ដែលគេធ្វើដោយផ្លា ឈើ ។ ទឹកត្រាំ ដែលគេច្រចាច់ផ្លែឈើទាំងឡាយ មានផ្លែចន់ ជា ដើម ហើយធ្វើដោយរសជាតិ នៃផ្លែចន់ទាំងឡាយនោះ ឈ្មោះថា ទឹកត្រាំ ដែលគេធ្វើ ដោយផ្លែឈើ ។ ទឹកត្រាំ ដែលគេធ្វើរសជាតិ នៃផ្លែចន់ទាំងឡាយ ឈ្មោះថា ទឹកត្រាំ ដែលគេធ្វើដោយផ្លែចន់ ឬ

មន្ទលត្ថទីបនីប្រែ

គេធ្វើដោយទឹកឃ្ចុំ ។ អាចារ្យពួកខ្លះ ពោលថា គេធ្វើដោយទឹកឃ្ចុំខ្លះ ដូច្នេះ " ។

(១៦៧) ជីកានៃអដ្ឋកថាទាំងពួង តាមដែលបានពោលមកហើយថា "រសជាតិនៃផ្ការឈើ មានផ្ការចន ផ្ការត្នោត ផ្ការដូងជាដើម ដែលគេត្រាំទុក យ៉ាងយូរ ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយផ្ការឈើ ។ រសជាតិផ្លែឈើ មានផ្លែខ្នុរជាដើម ដែលគេត្រាំទុក យូរ ដូច្នោះ ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ ។ រសជាតិ នៃផ្លែចន ដែលគេត្រាំទុកយូរ ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយផ្លែចន ។ រសជាតិ នៃអំពៅ ដែលគេត្រាំទុកយូរ ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ ។ រសជាតិ នៃគ្រឿងផ្សំផ្សេងៗ មានផ្លែសម៉ កន្ធួតព្រៃ និង គ្រឿងក្តៅជាដើម ដែលត្រាំទុកយូរ ឈ្មោះថា ទឹកត្រាំ ដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេង ៗ " ។

ជីកានៃសិគាលសូត្រ ព្រមទាំងអដ្ឋកថា ថា " វត្ថុទាំង ១០ យ៉ាង សូម្បីទាំងអស់នោះ ឈ្មោះថា ទឹកស្រវឹង ដោយអំណាចជាហេតុនៃសេចក្តីស្រវឹង ព្រោះធ្វើវិគ្រោះថា រមែងញ្ចាំងអ្នកផឹកឲ្យស្រវឹង ដូច្នេះ " ។

(១៦៨) អដ្ឋកថាខុទ្ទកបាឬ: ថា "សុរា និង មេរយទាំង ២ យ៉ាងនោះឯង ឈ្មោះថា ទឹកស្រវឹង ព្រោះអត្ថថា ជាទីតាំង នៃ

១០០ និងវិនិមជ្ឈបានសំយមកថា

សេចក្តីស្រវឹង, ក៏ម្យ៉ាងទៀតថា បានៈ អ្វីមួយ សូម្បីផ្សេងទៀត ដែលជាតាំងនៃសេចក្តីស្រវឹង រមែងមាន, បានៈនោះ ក៏ឈ្មោះថា ទឹកស្រវឹង, បុគ្គលជាអ្នកស្រវឹង រង្វេងហើយ ព្រោះបានៈ ណា ដែលខ្ជួនផឹកហើយ, បានៈ នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា ទឹកស្រវឹង ដូច្នេះ" ។

អដ្ឋកថាអាមកធញ្ញបេយ្យាល ក្នុងមហាវគ្គសំយុត្តនិកាយ ថា " សុរា និង មេរ័យទាំង ២ យ៉ាងនោះឯង ឬក៏ បានៈសូម្បីផ្សេងទៀត ដែលរួចផុតអំពីសុរា និង ទឹកត្រាំ ដែលជាទីតាំងនៃសេចក្តីស្រវឹង ឈ្មោះថា ទឹកស្រវឹង " ។

*ដីកានៃអាមកធញ្ញបេយ្យាលនោះ ថា "បទថា **សុរាសរ-វិនិមុត្តំ** គឺ រួចផុតចាកសុរា និង មេរ័យ តាមដែលពោលហើយ " ។*

*(១៦៩) ចេតនា ជាហេតុផឹក ពោលគឺ ជាទីតាំងនៃសេចក្តីប្រមាទ ឈ្មោះថា បានៈ ។ ពិតមែនដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាអាមកធញ្ញបេយ្យាល ថា " បុគ្គល ទាំងឡាយ រមែងផឹកនូវទឹកស្រវឹងនោះ ដោយចេតនា ឯណា, ចេតនានោះ ឈ្មោះថា ជាទីតាំងនៃសេចក្តីប្រមាទ ព្រោះជាហេតុ នៃសេចក្តីប្រមាទ" ។ អដ្ឋកថាខុទ្ទកបាឋៈ និង អដ្ឋថាសិគាលសូត្រ ក៏យ៉ាងដូច្នោះដែរ ។ ការវៀរ ឈ្មោះថា **សំយមៈ** ។ ដោយហេតុ*

មង្គលត្ថទីបនីប្រែ

នោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុក ក្នុងអដ្ឋកថា ថា " ឈ្មោះ ថា ការសង្រ្ជួម ចាកការផឹកនូវទឹកស្រវឹង គឺខ្ទុំនឹងពោល ។ ពាក្យ ថា ***មជ្ជបានសញ្ញមោ*** *នេះ ជាឈ្មោះ នៃចេតនាគ្រឿងវៀរចាក ហេតុជាទីតាំង នៃសេចក្តីប្រមាទ ព្រោះទឹកស្រវឹង គឺ សុរា និង មេរ័យ " ។*

ការសង្រ្ជួមចាកការផឹកទឹកស្រវឹង គឺខ្ទុំសរុបពោល ចប់ ។

*(១៧០) ក៏ប្រៀបដូចជា ការផឹកនូវសុរា ព្រះដ៏មានព្រះ ភាគ មិនទ្រង់ប្រកាន់យក ក្នុងពាក្យថា "**កម្មកិលេស**" នេះ ក្នុង សិគាលសូត្រនោះ យ៉ាងណា, សូម្បីក្នុងមង្គលបទថា " **អារតី វិរតី បាបា** នេះ បណ្ឌិត មិនគួរប្រកាន់យក នូវការផឹកទឹកស្រវឹង នោះ ក្នុងបទថា "**បាបា**" នេះ ក៏យ៉ាងនោះដែរ ។ ហេតុក្នុងការ មិនទ្រង់ចាត់សុរាបាន:នោះ ចូលក្នុងសិគាលសូត្រនោះ មានន័យ ដែលព្រះដីកាចារ្យពោលហើយ ក្នុងដីកាសិគាលសូត្រនុ:ឯង ។ ក៏អាចារ្យអ្នកវចនាគម្ពីរដីកា ពោល យ៉ាងនេះថា " សុរាបាន: គឺ ឧបាសកទាំងឡាយគប្បីវៀរស្រឡះ ដោយការ:ជាពៀរ ៥ ប្រការ ក៏ពិតមែន, ទោះជាដូច្នោះ ព្រះមានព្រះភាគ ទ្រង់លះបង់ចោល នូវ សុរាបាន:នោះ ហើយទ្រង់ត្រាស់សំដៅយក នូវអកុសលធម៌ មានបាណាតិបាត ប៉ុណ្ណោះ ថា កម្មកិលេស ៤ យ៉ាង ព្រោះទ្រង់*

១០ និងវិនិច្ឆ័យ

ព្រះបំណងនឹងត្រាស់ ១ ១ មុ១ ព្រោះការ:នៃសុរាបាន:នោះ ជាផ្លូវ
នៃសេចក្ដីវិនាសកោគ: " ដូច្នោះហើយ ពោលទៀតថា " អាចារ្ យ
មួយពួកទៀត ពោលថា ក៏ព្រោះការ:នៃសុរាបាន:នោះ មិនមែន
ជាកម្មបថ មួយផ្នែក ដូច្នេះ ។ អាចារ្យពួក១ ១ ពោលថា សូម្បីការ
ផឹកសុរា មកហើយ ដោយការ:ជាកម្មបថ មួយផ្នែក ព្រោះព្រះ
បាលីថា ម្នាលភិក្ខុទាំងឡាយ ការផឹកនូវសុរា ដែលបុគ្គលសេព
អប់រំ ធ្វើឲ្យច្រើនហើយ ជាកម្មញ្ជាំងសត្វឲ្យប្រព្រឹត្តទៅ ក្នុងរនក
ដូច្នេះជាដើម ។ ពិតមែនដូច្នោះ ការផឹកនូវសុរានោះ ជាទុច្ចរិត
ទៀងទាត់ហើយ ក្នុងភាពជាផ្លូវសម្រាប់ញ្ជាំងសត្វឲ្យទៅកាន់ទុគ្គតិ
ដូច្នេះ ។ តាមមតិ របស់កេចិអាចារ្យទាំងនោះ កម្មបថ គប្បីមាន
១១ យ៉ាង, ព្រោះហេតុនោះ បណ្ឌិត គប្បីឃើញការបូកបញ្ចូល
សុរាបាន: ក្នុងកម្មបថទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់
បានត្រាស់ទុកហើយនុ៎ះឯង ដោយអំណាចភាពជាឧបការ: និង
ភាពស្មើគ្នា ព្រោះហេតុនោះ ពាក្យថា **ឯ**ស**ុ** **ក**ម្ម**ប**ថ**ការ**ណ**ោ** **ច**
ដូច្នេះនុ៎ះ ជាពាក្យដែលអាចារ្យដទៃទៀតពោលល្អហើយ" ដូច្នេះ ។
ក៏ក្នុងមង្គលបទថា "**អ**ារ**ា** **ឯ**ារ**ា** **ប**ាប**ា**" នេះ សូម្បីការផឹក
សុរា នឹងជាបាប ក៏ពិតមែន, ទោះបីជាដូច្នោះ ព្រះមានព្រះភាគ
ទ្រង់ប្រាជ្ញា ដើម្បីនឹងត្រាស់កម្មកិលេស ក្រៅអំពីការផឹកសុរានោះ

មន្តលត្ថទីបនីប្រែ

ដោយភាវៈជាបាបហើយ ទើបទ្រង់ត្រាស់ការផឹក នូវសុរានោះ ដោយភាវៈជាទឹកស្រវឹង ខាងមុខ ព្រោះហេតុណា, ព្រោះហេតុនោះ បណ្ឌិតគប្បីយើញសន្និដ្ឋានថា "មិនគួរប្រកាន់យកសុរាបានៈ នោះ ក្នុងបទថា **បាបា** នេះទេ ។ មួយទៀត វិរតិ មានមេថុន-វិរតិ ជាដើមក្តី មគ្គក្តី ឈ្មោះថា ការប្រព្រឹត្តិប្រសើរ ក្នុងគាថាទី ៩ ថា **តបោ ច ព្រហ្មចរិញ្ច** នេះ ក៏ពិតមែន, ទោះជាយ៉ាងដូច្នោះ ព្រហ្មចរិយៈ ដែលសល់អំពីមគ្គនោះ ឈ្មោះថា គឺព្រះមានព្រះភាគ ទ្រង់កំណត់យកហើយ ព្រោះភាវៈនៃមគ្គ គឺព្រះអង្គទ្រង់កំណត់យកហើយ ខាងមុខ ដោយកិរិយាយើញ នូវអរិយសច្ចៈ យ៉ាងណាមិញ, សេចក្តីឧបមេយ្យ ជាគ្រឿងញ្ចាំងអត្ត ឲ្យដល់ព្រមនេះ បណ្ឌិតគប្បីយើញ យ៉ាងដូច្នោះដែរ ។

(១៧១) ចេតនា ជាហេតុបង្ក ពៀរទាំង ៥ យ៉ាង មានបាណាតិបាត ជាដើម ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបទទាំង ២ ថា "**បាបា មជ្ជបានា**" ។ ចេតនា ជាហេតុវៀរចាកពៀរទាំង ៥ យ៉ាងនោះ ព្រះអង្គទ្រង់ត្រាស់ ដោយបទទាំង ២ ថា "**វិរតិ សំយមោ**" ដោយប្រការដូច្នេះ ។ បណ្តាពៀរទាំង ៥ យ៉ាងនោះ បាបធម៌ ៤ យ៉ាង មានបាណាតិបាត ជាដើម អ្នកសិក្សាគប្បីជ្រាប តាមនយដែលខ្ញុំពោលហើយ ក្នុងអាគារិយវិនយ

ចាបវិរតិមជ្ឈបានសំយមកថា

ឲ្ជដ៏ខាងក្រោយ ។ ម្យ៉ាងទៀត អ្នកសិក្សា គប្បីជ្រាប សូម្បីតាមនយ័ដែលព្រះអដ្ឋកថាចារ្យ បានពោលទុកហើយ ក្នុងអដ្ឋកថា នៃមហាឲ្ជក: ។ ពិតមែន ក្នុងអដ្ឋកថាមហាឲ្ជក:នោះ លោកបានពោលហើយថា "ប្រៀបដូចជាអាបត្តិផ្សេងៗ រមែងមាន ដល់ភិក្ខុទាំងឡាយ ព្រោះទោស មានបាណាតិបាត ជាដើម យ៉ាងណា, ទីងមាន ដល់សាមណេរទាំងឡាយ យ៉ាងដូច្នោះ ក៏មិនមែនដែរ ។ ព្រោះ សាមណេរ សម្ងាប់ស្រមោចខ្មៅ និង ស្រមោចក្រហម ក្តី ញ្ជេចពងសង្ក្ដីច ក្តី រមែងដល់ នូវភាពជាអ្នក គឺភិក្ខុគប្បីធ្វើ ឲ្យវិនាស គឺឲ្យសឹកចេញក្ដាម ។ សរណគមន៍ ក្តី ការកាន់យកព្រះឧបជ្ឈាយ៍ ក្តី ការកាន់យកនូវសេនាសន: ក្តី របស់សាមណេរនោះ ក៏រមែងស្ងប់រម្ងាប់ ក្នុងខណ:ទ្ុ:ឯង ។ សាមណេរនោះ រមែងមិនបានលាភរបស់សង្ឆ ។ មានត្រឹមតែភេទ មួយប៉ុណ្ណោះទេ ដែលជាលក្ខណ:នៅសល់ ។ សាមណេរនោះ មិនមែនជាសមណ: ព្រោះវត្ថុសូម្បីត្រឹមតែសរសៃស្នៅ ក្នុងអទិន្នាទានសិក្ខាបទ, មិនមែនជាសមណ: ព្រោះប្រតិបត្តិខុស ក្នុងមគ្គណាមួយ បណ្ដាមគ្គទាំង ៣ ក្នុងអព្រហ្មចរិយសិក្ខាបទ, មិនមែនជាសមណ: ព្រោះពោលមុសា សូម្បីដោយប្រាថ្នា ទីងសើចលេង ក្នុងមុសាវាទ-សិក្ខាបទ " ។

មន្តលត្ថនីបនីប្រែ

(១៧២) ក្នុងដីកានៃវិមតិវិនោទនី លោកពោលថា " ព្រះអដ្ឋកថាចារ្យ សម្តែងនូវការខាតវស្សា ដោយ ២ បទនេះ ថា **សេនាសនគ្គាហោ ច ឧជ្ជិ្ឌ្ឍ** ដូច្នេះ ។ បណ្ឌិត គប្បីជ្រាបថា ការកាន់យកសេនាសនៈ សូម្បីនៃឧបសម្បន្នទាំងឡាយ ឈ្មោះថា រមែងស្ងប់រម្ងាប់ ព្រោះត្រូវអាបត្តិបារាជិក, ការកាន់យកសេនាសនៈ របស់សាមណេរ រមែងស្ងប់រម្ងាប់ ព្រោះការកំចាត់បង់ សូម្បីនូវគុណគ្រឿងជាសាមណេរ មានសរណគមន៍ជាដើម, សាមណេរទាំងនោះ រមែងមិនបានសូម្បីនូវសង្ឃលាភ" ។

(១៧៣) ចំណែកការផឹកទឹកស្រវឹង អ្នកសិក្សា គប្បីជ្រាបដោយនយដែលលោកពោលហើយ ក្នុងអដ្ឋកថា នៃខុទ្ទកបាឋៈ ថា " ចេតនា ដែលជាហេតុលេបចូលទៅ នូវទឹកស្រវឹង គឺសុា និង មេរ័យ ដែលប្រព្រឹត្តទៅ តាមកាយទ្វារ ដោយមានបំណងនឹងលេបចូលទៅ បណ្ឌិត គប្បីជ្រាបថា ហេតុជាទីតាំង នៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុា និង មេរ័យ ។ ក៏សុាមេរ័យ-មជ្ជប្បមាទដ្ឋាន មានអង្គ ៤ យ៉ាងនេះ គឺ បណ្តាសុាជាដើម ទឹកស្រវឹង ណាមួយ ដែលជាទីតាំងនៃសេចក្តីស្រវឹង ១ ចិត្តមានភាពជាអ្នកប្រាថ្នានឹងផឹក ប្រាកដឡើង ១ អ្នកផឹក ដល់នូវសេចក្តីព្យាយាម ដែលកើតឡើងអំពីចិត្តនោះ ១ ទឹកស្រវឹងដែលខ្ជួនផឹក

១០០ និងវិតិមជ្ឈបានសំយមកថា

ហើយ រមែងហូរចូលទៅ ១ " ។

ចំណែក ក្នុងជីកាសុរាបានសិក្ខាបទ លោកពោលហើយ ដោយអំណាចការផឹកសុរា របស់ភិក្ខុថា "ក៏ក្នុងសុរាបានសិក្ខាបទ នេះ មានអង្គ ២ យ៉ាងនេះ គឺ ភាពជាទឹកស្រវឹង ១ ការផឹកនូវទឹក ស្រវឹងនោះ ១ " ។

(១៧៤) ក៏ពាក្យណា ដែលព្រះអដ្ឋកថាចារ្យ ពោលទុក ហើយ ក្នុងអដ្ឋកថាសុរាបានសិក្ខាបទថា "ក៏ក្នុងសុរាបានសិក្ខាបទ នេះ បណ្ឌិត គប្បីជ្រាបភាវៈនៃការផឹកសុរានោះ ជាអចិត្តកៈ (មិន មានចិត្ត) ព្រោះមិនដឹងនូវវត្ថុ ក៏ត្រូវអាបត្តិ ។ ភាវៈនៃការផឹក សុរានោះ ឈ្មោះថា ជាលោកវជ្ជៈ (ទោសខាងផ្លូវលោក) ព្រោះ ភាវៈជាទឹកស្រវឹង ដែលបុគ្គលគប្បីផឹក ដោយចិត្ត ដែលជា អកុសល មែនពិត " ។ ក្នុងពាក្យនោះ ភាវៈនៃការផឹកសុរានោះ ជាអចិត្តកៈ រមែងបាន ដោយអំណាចនៃភិក្ខុ ។ ព្រោះហេតុនោះ ឯង ទើបលោក ពោលហើយ ក្នុងអដ្ឋកថាមហាឋន្ធកៈ ថា " ក៏ក្នុង ការផឹកទឹកស្រវឹង សម្រាប់ភិក្ខុអ្នកមិនដឹងហើយ ផឹកទឹកស្រវឹង តាំងអំពីពូជ(ដើម) ឡើងទៅ ត្រូវអាបត្តិបាចិត្តិយៈ ។ ឯសាមណេរ កាលដឹងហើយផឹក រមែងដល់នូវការដាច់នៃសីល, មិនដឹងហើយ ផឹក មិនដល់នូវការដាច់សីលឡើយ ។ សម្រាប់ពួកសាមណេរ

មន្ទលត្ថទីបនីប្រែ

ការផឹងសុរា ជាសចិត្តក: ជាវត្ថុនៃបារាជិក ” ។

ក្នុងដីកានៃវិមតិវិនោទនី នៃសុរាបានសិក្ខាបទនោះ លោកពោលថា “សាមណេរ មិនដឹងហើយផឹក រមែងមិនដល់ នូវការដាច់សីលទាំងពួង មានការវៀរចាកបាណាតិបាតជាដើម និង ការដាច់សរណ: ។ តែអកុសល បណ្ឌិតគប្បីយើញថា ការដាច់សីលគឺ ចេតនា ជាហេតុវៀរចាកការផឹកសុរាប៉ុណ្ណោះ រមែងមាន ដូចជាការដាច់សីល ព្រោះការប្រដាប់នូវផ្តាកម្រងជាដើម ដូច្នេះ ” ។

(១៧៥) ក៏ប្រសិនបើ មានពាក្យសួរថា “ សីល គឺចេតនា ជាហេតុវៀរចាកការផឹកសុរា រមែងដាច់, កាលបើយ៉ាងដូច្នោះ ព្រោះហេតុអ្វី សីលក្រៅអំពីនេះ ទើបមិនដាច់? ” ។ គប្បីឆ្លើយថា “ក៏ការផឹកសុរា ព្រះអដ្ឋកថាចារ្យ បានពោលហើយ ក្នុងអដ្ឋកថាថា ជាវត្ថុនៃបារាជិក ដូច្នេះ និង សីលអ្វីៗ រមែងមិនមាន ដល់សាមណេរដែលបារាជិកឡើយ ” ។ សូម្បីក្នុងអដ្ឋកថាខុទ្ទកបាឋ: លោក ក៏បានពោលថា “ ក៏បណ្តាសិក្ខាបទទាំង ៥ ខាងដើមនុ៉ះ សម្រាប់សាមណេរ កាលបើសិក្ខាបទមួយ ដាច់ហើយ សិក្ខាបទទាំងឡាយ សូម្បីទាំងអស់ ក៏តែងដាច់ ដូចគ្នាផងដែរ ។ ព្រោះសិក្ខាបទទាំង ៥ ខាងដើមនោះ ជាសិក្ខាបទ ដែលស្ថិតនៅ ក្នុងឋាន: នៃបារាជិក ” ។ ព្រោះហេតុនោះ បណ្ឌិត គប្បីពិចារណា

ចាបវិរតិមជ្ឈបានសំយមកថា

ពាក្យថា "***សុរាបានវេរមណីសីលកេ០ ១ ហោតិ*** " ។

(១៧៦) ក្នុងអដ្ឋកថា សុរាបានសិក្ខាបទ លោកពោល ថា " ថ្នាំត្រាំពិសេសឯណា ឈ្មោះថា អរិដ្ឋ: មិនមែនជាទឹកស្រវឹង, មិនត្រូវអាបត្តិ ព្រោះថ្នាំត្រាំពិសេស ឈ្មោះអរិដ្ឋ:នោះទេ ។ បានឮ ថា ជនទាំងឡាយធ្វើថ្នាំត្រាំពិសេស ឈ្មោះអរិដ្ឋ:នោះ ដោយរស នៃផ្លែកន្ទួតព្រៃជាដើមនុ៎ះឯង, ក៏ថ្នាំត្រាំពិសេស ឈ្មោះអរិដ្ឋ:នោះ មានសម្បូរ ក្ងិន និង រស ប្រហែលគ្នានឹងទឹកស្រវឹង, តែមិនមែន ជាទឹកស្រវឹងទេ, ចំណែក រស ឯណា ដែលគេជាក់គ្រឿងផ្សំ ចាត់ ថា ជាទឹកស្រវឹង, រសនោះ មិនសមគួរ ចាប់ដើមពីពូជឡើងទៅ" ។

ដីកានៃវិមតិវិនោទនី នៃសុរាបានសិក្ខាបទនោះថា " បទថា ***ពីជតោ*** គឺ ចាប់តាំងអំពីពេលដែលគេជាក់ម្សៅជាដើម តាមដែល បានពោលហើយ ចូលទៅ ក្នុងកាជន: ដើម្បីប្រយោជន៍ ដល់ទឹក ស្រវឹង " ។

ដីកានៃសុរាបានសិក្ខាបទថា " បទថា ***ពីជតោ*** គឺ ចាប់ ដើមតាំងអំពីពេលដែលគេចាត់ចែងគ្រឿងផ្សំហើយ ដាក់ចូលទៅ ក្នុងកាជន: និង ចាប់ដើមតាំងអំពីពេល, កាលបើ រសនៃផ្លាឈើ ទាំងឡាយ មានត្នោត និង ដូងជាដើម ដែលគេត្រងទុក, រសនោះ នៅថ្មីៗ សុទ្ធតែម្ជុង ។ ចំណែក ថ្នាំត្រាំពិសេស ដែលបុគ្គលផ្សំ

ដោយគ្រឿងកេសជ្ជៈ ច្រើនយ៉ាង មិនមែនជាទឹកស្រវឹង ឈ្មោះថា លោណសោចិរកសុត្តៈ " ។

ក៏ពាក្យថា "**អកិនវកាលតោ**" ក្នុងជីកាសុរាបានសិក្ខាបទ នុ៎ះ រមែងខុស ចាកពាក្យនេះថា "**ចិរបារិវាសិតោ**" ដូច្នេះ ។ ព្រោះរសនៃផ្លាឈើ ដែលកើតឡើងថ្មីៗ នុ៎ះ មិនគួរ ដើម្បីនឹងពោលថា " ដែលគេត្រាំទុកយូរឡើយ " ដូច្នេះ ។

(១៧៧) ក៏កម្មកិលេស ៤ យ៉ាង តាមដែលពោលហើយ គឺ ជាតួរចេតនា ដោយធម៌ មែនពិត ។ ដោយហេតុនោះ ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រ ជាដើម ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលទុកហើយ ក្នុងអធិការ នៃអកុសលកម្មបថ ថា " កម្មបថ ទាំង ៧ យ៉ាង ដោយលំដាប់ ជាចេតនាធម៌ " ដូច្នេះ ។

បទថា " **សត្ត** " បានដល់ កម្មបថទាំង ៧ ដោយអំណាចនៃកាយកម្ម ៣ និង វចីកម្ម ៤ ។

ពណ្ណនាអំពីពៀរ ៥ យ៉ាង ចប់ ។

(អារម្មណ៍របស់កម្មបថ)

(១៧៨) សូម្បីចេតនា ជាហេតុវៀរចាកពៀរ ៥ យ៉ាងនោះ បណ្ឌិតគប្បីជ្រាប ដោយនយ ដែលខ្ញុំបានពោលមកហើយ ក្នុងអធិការ នៃអកុសលកម្មបថ ពួកដ៏ទាងក្រោយនុ៎ះឯង ។ ចំណែក

ឧបនិរតិមជ្ឈឧានសំយមកថា

អារម្មណ៍ របស់វេរមណីនោះ លោកពោលហើយ ក្នុងអដ្ឋកថា
ទាំងឡាយ ។ ពិតដូច្នោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ សំដៅយក
លោកិយវិរតិ ទើបពោលហើយ ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រ ជា
ដើមថា " អារម្មណ៍ របស់បាបធម៌ទាំងឡាយ មានបាណាតិបាត
ជាដើមន៉ុះឯង ជាអារម្មណ៍ របស់អកុសលកម្មបថ ទាំងនោះ ដូច
គ្នាដែរ ។ ព្រោះថា ការវៀរចាកវត្ថុ ដែលគប្បីប្រព្រឹត្តកន្ងងន៉ុះឯង
ជាកិរិយាឈ្មោះថា វេរមណី " ។

អដ្ឋកថាកូដទន្តសូត្រថា " បណ្តា វិរតិ ទាំង ៣ យ៉ាងនោះ
វិរតិ ២ យ៉ាង ខាងដើម ធ្វើវត្ថុមានជីវិតិន្ទ្រីយ៍ជាដើម ដែលខ្ជូន
គប្បីប្រព្រឹត្តកន្ងង ដោយអំណាចនៃកិរិយាមានការផ្តាច់បង់ (ជីវិត)
ជាដើម ឲ្យជាអារម្មណ៍ហើយ ប្រព្រឹត្តទៅ, វិរតិ ចុងក្រោយគេ
មានព្រះនិព្វាន ជាអារម្មណ៍ តែម៉ាង " ។

(១៧៩) សមាទានវិរតិ សូម្បីក្នុងសិក្ខាបទទាំងពួង រមែង
សមគួរ ក្នុងវេលាដែលវៀរចាកវត្ថុ ដែលមកជួបប្រទះ ព្ធដ៏ខាង
ក្រោយ អំពីខណៈដែលទទួលសិក្ខាបទប៉ុណ្ណោះ, មិនសមគួរ ក្នុង
ខណៈដែលទទួលសិក្ខាបទនោះឡើយ ។ ព្រោះថាក្នុងខណៈនោះ
សមាទានវិរតិ មានអកុសលដែលខ្ជូនគប្បីវៀរ ជាអារម្មណ៍ តែ
ម៉ាង ។ ដោយហេតុនោះឯង ក្នុងអដ្ឋកថាខុទ្ទកបាឋៈ ទើបលោក

មន្តលត្ថទីបនីប្រែ

ពោលថា " ក្នុងពាក្យថា **វិរមតោ** នេះ អាចារ្យអ្នកចោទ ពោលថា បុគ្គល កាលនឹងវៀរ ចាកអកុសលធម៌ទាំងឡាយ មានបាណាតិបាត ជាដើម ឈ្មោះថា រមែងវៀរ ចាកបាបធម៌អ្វី ? ។ ខ្ញុំ នឹងឆ្លើយ ។ បុគ្គល កាលនឹងវៀរ ដោយអំណាចសមាទានវិរតិ ឈ្មោះថា រមែងវៀរ ចាកបាបកុសលធម៌ មានបាណាតិបាត ជាដើម របស់ខ្លួន ឬ របស់ជនទាំងឡាយឯទៀតជាមុន ។ ប្រាវព្ធអ្វី? ។ ខ្លួន រមែងវៀរ ចាកអកុសលណាមួយ, ប្រាវព្ធអកុសលន៉ុះឯង ។ បុគ្គល កាលនឹងវៀរ សូម្បីដោយអំណាចសម្បត្តវិរតិ ក៏ឈ្មោះថា វៀរ ចាកអកុសល មានប្រការដូចបានពោលមកហើយ ដូចគ្នា ។ ប្រាវព្ធអ្វី? ។ ប្រាវព្ធអារម្មណ៍ នៃអកុសលធម៌ មានបាណាតិបាត ជាដើម ដែលបានពោលមកហើយន៉ុះឯង " ។

ចំណែក អាចារ្យពួកខ្លះ ពោលថា " បុគ្គល ប្រាវព្ធសង្ខារ ពោលគឺទឹកស្រវឹងហើយ រមែងវៀរចាកហេតុជាទីតាំង នៃសេចក្តីប្រមាទ ព្រោះទឹកស្រវឹង ។ បណ្តាសត្ធ និង សង្ខារទាំងឡាយ សត្ធ និង សង្ខារណា គឺខ្លួនគប្បីលួច និងគប្បីបំបាក់បំបែក, បុគ្គល ប្រាវព្ធសត្ធ និង សង្ខារនោះ វៀរចាកអទិន្នាទាន និង មុសាវាទ, ប្រាវព្ធតែសត្ធទាំងឡាយប៉ុណ្ណោះ រមែងវៀរចាកបាណាតិបាត និង អព្រហ្មចរិយ: " ។ ពាក្យ របស់អាចារ្យ ពួកខ្លះនោះ រមែងត្រូវ

ឧបនិរតិមជ្ឈឧានសំយមកថា

ដោយបរិយាយ ។ អាចារ្យដទៃទៀត ក្រៅអំពីកេចិអាចារ្យនោះ ពោលថា " កាលបើយ៉ាងដូច្នោះ បុគ្គលគិតកិច្ចផ្សេង (តែ) គប្បីធ្វើកិច្ចផ្សេង, មួយទៀត ខ្ជួនលះនូវអកុសលណាមួយ, មិនគប្បីដឹងនូវអកុសលនោះ" ដូច្នេះហើយ កាលមិនពេញចិត្ត ទើបពោលថា " ខ្ជួនលះអកុសល ចំពោះខណាមួយ, ប្រារព្ធអកុសល មានបាណាតិបាត ជាដើម ខនោះ របស់ខ្ជួនន៉ុះឯង ហើយវៀរ " ។ ពាក្យ របស់អាចារ្យដទៃ ក្រៅអំពីកេចិអាចារ្យនោះ មិនត្រឹមត្រូវ ។ ព្រោះហេតុអ្វី? ។ ព្រោះភាវៈនៃអកុសល មានបាណាតិបាត ជាដើមនោះ មិនមានអារម្មណ៍ជាបច្ចុប្បន្ន និង ព្រោះមិនមានអារម្មណ៍ជាខាងក្រៅ ។ ក៏ភាវៈនៃសិក្ខាបទទាំងឡាយ មានអារម្មណ៍ ជាបច្ចុប្បន្ន និង មានអារម្មណ៍ជាខាងក្រៅ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងវិភង្គបាឬ: យ៉ាងនេះថា " ធម៌ទាំងឡាយ មានអារម្មណ៍ជាបច្ចុប្បន្ន, មានអារម្មណ៍ជាខាងក្រៅ " ដូច្នេះ ។ ព្រះតម្រាស់នោះ រមែងមិនសមគួរ ដល់អ្នកប្រារព្ធអកុសល មានបាណាតិបាត ជាដើមនោះ របស់ខ្ជួន ហើយវៀរ ។ មួយទៀត ពាក្យឯណា ដែលអាចារ្យពួកខ្ជះពោលថា "**អញ្ញំ ចិន្តេន្តោ**" ដូច្នេះ ជាដើម, ពាក្យនោះ មិនត្រឹមត្រូវ ។ ព្រោះបុគ្គលកាលប្រព្រឹត្ត ដោយអំណាច នៃការញ្ញាំងកិច្ចឲ្យសម្រេច បណ្ឌិត តែងមិនហៅ

មន្តលត្ថទីបនីប្រែ

ថា " គិតកិច្ចដទៃ (តែ) ធ្វើកិច្ចដទៃ " ដូច្នេះ ឬថា " ខ្ជូនលះ នូវអកុសលបែបណា, រមែងមិនដឹងនូវអកុសលបែបនោះ" ដូច្នេះ ។

ក៏ព្រះអរិយបុគ្គលអ្នកតាំងនៅ ក្នុងមគ្គ ប្រារព្ធនូវអមតធមិ ហើយ លះបង់នូវបាបទាំងពួង គប្បីដាឧទាហរណ៍ ក្នុងរឿងនេះបាន ។

សេចក្តីទាំងអស់នេះ គឺខ្ញុំបានមក អំពីអដ្ឋកថាខុទ្ទកបាឋ: ។

(១៨០) សូម្បីក្នុងអដ្ឋកថា សម្មាទិដ្ឋិសូត្រ ជាដើម ក៏ព្រះអដ្ឋកថាចារ្យទាំងឡាយ សំដៅយកការចោទ ថា " កម្មបថ ទាំងឡាយ មានទោសគ្រឿងទ្រុស្តសីល ជាអារម្មណ៍ និង មានជីវិ-តិន្ទ្រីយ៍ ជាដើម ជាអារម្មណ៍ រមែងលះទោសគ្រឿងទ្រុស្តសីលបាន យ៉ាងដូចម្តេច?" ដូច្នេះ ទើបពោលថា "ប្រៀបដូចជាអរិយមគ្គ មានព្រះនិព្វាន ជាអារម្មណ៍ រមែងលះកិលេសទាំងឡាយ បាន យ៉ាងណា, កម្មបថ ទាំងឡាយន៉ុះ មានជីវិតិន្ទ្រីយ៍ ជាដើម ជាអារម្មណ៍ បណ្ឌិត គប្បីជ្រាបថា រមែងលះទោសគ្រឿងទ្រុស្តសីល មានបាណាតិបាត ជាដើមបាន ក៏យ៉ាងដូច្នោះដែរ ដូច្នេះ " ។

(១៨១) នយ ក្នុងអដ្ឋកថាខុទ្ទកបាឋ: ថា " សូម្បីសិក្ខាបទ ទាំងឡាយន៉ុះ ដែលសាមណេរ សមាទាន ក្នុងសំណាក់ នៃភិក្ខុ ប៉ុណ្ណោះ ជាសិក្ខាបទ ដែលបានសមាទានហើយ ។ ចំណែកឯ

ឧបនិរតិមជ្ជបានសំយមកថា

ឧបាសក (និង ឧបាសិកា) សមាទានរួមគ្នាក្តី ចំពោះអង្គក្តី ដោយ ខ្ជូនឯង ឬ ក្នុងសំណាក់ នៃបុគ្គលដទៃ ក៏ជាសិក្ខាបទ ដែលបាន សមាទានហើយ ។

សួរថា " ក៏ (ការសមាទាន រួមគ្នា និង ការសមាទាន ចំពោះអង្គមួយ ៗ) មានការប្រែកគ្នា យ៉ាងដូចម្តេច?" ។

ឆ្លើយថា " កាលបើ ឧបាសក (ឧបាសិកា) សមាទាន រួមគ្នា, វិរតិ ក្តី ចេតនា ក្តី ដូចគ្នាតែម្តង, តែភាវៈនៃវិរតិ និង ចេតនា ទាំងឡាយនោះ មាន ៥ យ៉ាង ព្រះមានព្រះភាគ ទ្រង់ បញ្ញត្ត ដោយអំណាចនៃកិច្ច ។ កាលបើ ឧបាសក (ឧបាសិកា) សមាទាន ចំពោះអង្គមួយៗ, វិរតិ ក្តី ចេតនា ក្តី ក៏ (ចែកចេញ) ជា ៥ ផងដែរ ។ ក៏បណ្តាសិក្ខាបទទាំង ៥ ខាងដើមនេះ របស់ ពួកសាមណេរទាំងឡាយ, កាលបើសិក្ខាបទមួយ ដាច់ហើយ, សិក្ខាបទសូម្បីទាំងអស់ ក៏ជាសិក្ខាបទដាច់ហើយដែរ ។ ព្រោះ សិក្ខាបទទាំង ៥ នោះ តាំងនៅ ក្នុងឋានៈ នៃបារាជិក ។ សិក្ខាបទ នោះ ឯណានីមួយ ជាវិតិក្កមៈ ដែលសាមណេរទាំងឡាយនោះ ប្រព្រឹត្តកន្ងងហើយ, កម្មពន្ធ រមែងមាន ព្រោះសិក្ខាបទនោះ ប៉ុណ្ណោះ ។ ចំណែក សម្រាប់ពួកគ្រហស្ត, កាលបើសិក្ខាបទមួយ ដាច់ហើយ, ក៏តែងដាច់ហើយ តែសិក្ខាបទមួយប៉ុណ្ណោះ, ព្រោះ

មង្គលត្ថទីបនីប្រែ

ហេតុដែលសីលប្រកបដោយអង្គ ៥ រមែងសម្រេច ដល់គ្រហស្ថ ទាំងឡាយនោះ បានម្តងទៀត ក៏ដោយការសមាទានទូវសិក្ខាបទ ទាំងនោះនុ៎ះឯង ។ សិក្ខាបទនោះ ឯណានីមួយ សូម្បីដែលពួក គ្រហស្ថទាំងឡាយនោះ បានប្រព្រឹត្តកន្ទងហើយ, កម្មពន្ធ រមែង មាន ព្រោះសិក្ខាបទនោះ តែប៉ុ៎ណ្ណោះ ។

ចំណែក អាចារ្យមួយពួកទៀត ពោលថា "បណ្តាសិក្ខាបទ ទាំងឡាយ ដែលពួកគ្រហស្ថទាំងនោះ បានសមាទានហើយផ្សេងៗ គ្នា, កាលបើសិក្ខាបទមួយ ដាច់ហើយ, ក៏រមែងដាច់ហើយ តែ សិក្ខាបទ មួយប៉ុ៎ណ្ណោះ ។ ក៏ប៉ុ៎ន្តែ កាលបើពួកគ្រហស្ថទាំងនោះ សមាទាន រួមជាមួយគ្នា យ៉ាងដូច្នេះ ថា " អាត្មាអញ សមាទាន ទូវសីល ដែលប្រកបដោយអង្គ ៥ " ដូច្នេះ, កាលបើសិក្ខាបទ មួយដាច់ហើយ, សិក្ខាបទសូម្បីទាំងអស់ ក៏រមែងដាច់ហើយដែរ ។ ព្រោះហេតុអ្វី? ។ ព្រោះការសមាទាន មិនញែកចេញពីគ្នា " ។

*(១៨២) ក៏ពាក្យថា " **ឋបេ** " នុ៎ះ ព្រះអដ្ឋកថាចារ្យ ពោល សំដៅយកអាចារ្យអ្នកសម្តែងគម្ពីរទីឃនិកាយ ។ ពិតដូច្នោះ ក្នុង អដ្ឋកថាកូដទន្តសូត្រ ព្រះអដ្ឋកថាចារ្យ ពោលហើយ ថា " អ្នក ណា ទទួលសិក្ខាបទទាំង ៥ រួមជាមួយគ្នា, កាលបើសិក្ខាបទមួយ របស់អ្នកនោះ ធ្លុះធ្លាយហើយ, សិក្ខាបទសូម្បីទាំងអស់ ក៏រមែង*

ធាបទិរតិមជ្ជិមានសំយមកថា

ចុះផ្លាយហើយដែរ, អ្នកណា ទទួលយក ចំពោះអង្គមួយៗ, អ្នកនោះ រមែងប្រព្រឹត្តកន្លង នូវសិក្ខាបទណាមួយ, សិក្ខាបទនោះតែប៉ុណ្ណោះ រមែងចុះផ្លាយ ” ។

ដីកានៃកូដទន្តសូត្រនោះ ថា “ សិក្ខាបទ សូម្បីទាំងអស់ឈ្មោះថា រមែងចុះផ្លាយហើយ ព្រោះភាវៈនៃសិក្ខាបទ ដែលបានសមាទានរួមជាមួយគ្នា ។ សិក្ខាបទនោះប៉ុណ្ណោះ ឈ្មោះថា រមែងចុះផ្លាយ ព្រោះភាវៈនៃសិក្ខាបទដែលបានសមាទានផ្សេងៗ គ្នា ។ ក៏ពិធីនុ៎ះ លោកបានពោលហើយ ដោយអំណាចគ្រហស្ថ ” ។

(១៨៣) លោកិយវិរតិ តែប៉ុណ្ណោះ មានសភាពចុះផ្លាយ, លោកុត្តរវិរតិ មិនមានសភាពចុះផ្លាយសោះឡើយ ។ ព្រោះហេតុនោះឯង ក្នុងអដ្ឋកថាកូដទន្តសូត្រ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយថា “ ក៏ឈ្មោះថា ការចុះផ្លាយ នៃសេតុឃាតវិរតិ រមែងមិនមាន ។ ព្រោះព្រះអរិយសាវ័ក រមែងមិនសម្លាប់សត្វ មិនផឹកសុរា សូម្បីព្រោះហេតុនៃជីវិត សូម្បីក្នុងចន្លោះនៃភព ។ សូម្បីប្រសិនបើ ជនទាំងឡាយ ផ្សំនូវសុរា និង ទឹកដោះស្រស់ ប្រកបញ្ចូលទៅ ក្នុងមាត់ របស់លោក, ទឹកដោះស្រស់ប៉ុណ្ណោះ រមែងហូរចូលទៅ, សុរា មិនបានហូរចូលទៅទេ, ដូចជាបានឮមកថា កាលបើទឹក ដែលផ្សំដោយទឹកដោះស្រស់ របស់សត្វក្រៀលទាំង

មន្តលត្ថទីបនីប្រែ

ឡាយ ទឹកដោះស្រស់ប៉ុណ្ណោះ រមែងហូរចូលទៅ, ទឹកមិនបាន ហូរចូលទៅទេ ។ ការដែលទឹក មិនបានហូរចូលទៅ ក្នុងមាត់ នៃសត្វក្រៀសនេះ បណ្ឌិត គប្បីជ្រាបថា សម្រេច ដោយកំណើត ដូច្នេះ, ការដែលសុរា មិនហូរចូលទៅ ក្នុងមាត់នៃព្រះអរិយសាវ័ក ក្រៅពីនេះ បណ្ឌិតគប្បីជ្រាបថា សម្រេចដោយធម្មតា ដូច្នេះ " ។

*ដីកាកូដទន្តសូត្រនោះ ថា " ឈ្មោះថា ការធ្ទុះធ្លាយ នៃសេតុឃាតវិរតិ រមែងមិនមាន ព្រោះមានការមិនកម្រើកជាសភាព ព្រោះកាត់បាន យ៉ាងដាច់ខាត នូវធម៌ដែលជាសឹកសត្រូវ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យមានជាអាទិ៍ ថា " **កវន្តរេបិ** " ដូច្នេះ ។*

*បទថា "**យោនិសិទ្ធំ**" មានសេចក្តីថា សម្រេចដោយជាតិ ប្រៀបដូចជា ភាវៈនៃមនុស្ស មានអវយវៈវែង ទៅខាងខ្ពស់ និងសត្វតិរច្ឆាន មានអវយវៈវែង ទៅខាងទទឹងដូច្នោះឯង ។ សេចក្តីសម្រេចតាមធម្មតា គឺតាមសភាពន៉ុះឯង ឈ្មោះថា សម្រេចដោយធម្មតា ដូចជាសីលសម្រេច ដល់មាតា របស់ព្រះពោធិសត្ត កាលដែលព្រះពោធិសត្ត ឋិតនៅ ក្នុងគភ៌ យ៉ាងនោះឯង ។ ម៉ ្យាងទៀត សេចក្តីសម្រេច ដោយធម្មតានៃមគ្ត គឺ តាមអនុភាពនៃអរិយមគ្ត ឈ្មោះថា សម្រេចដោយធម្មតា " ។*

ឧបនិរតិមជ្ជឧនសំយមកថា

ក៏ វិរតិ ជាប្រធាន ក្នុងការវៀរចាកពៀរនោះៗ ព្រោះហេតុណា, ព្រោះហេតុនោះ ចេតនា ដែលឈ្មោះថា វេរមណី ក្នុងសិក្ខាបទទាំងពួង ទើបលោកពោល ថា " វិរតិ " ។ មួយទៀត សូម្បីចេតនា ក៏ឈ្មោះថា វេរមណី ។ ដោយហេតុនោះឯង ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រ ជាដើម ទើបព្រះអដ្ឋកថាចារ្យ ពោលថា " បណ្តាកម្មបថ ទាំង ១០ នុ៉ះ កម្មបថ ៧ ខ ដោយលំដាប់រមែងសមគួរ ទាំងចេតនា ទាំងវិរតិ " ។

(១៨៤) អាចារ្យអ្នកចោទ បានចោទ ក្នុងមង្គលបទនេះ ថា " ចេតនា ជាហេតុវៀរចាកពៀរនោះៗ ព្រះមានព្រះភាគទ្រង់បានត្រាស់ហើយ ដោយបទថា **វិរតិ** នេះ មិនមែនទេឬ?, ដើម្បីប្រយោជន៍អ្វី ទើបទ្រង់ត្រាស់ថា **អារតី** ដូច្នេះ (ម្តងទៀត) ? " ។ អាចារ្យអ្នកឆ្ងើយ បានឆ្ងើយថា " ព្រះអង្គ ទ្រង់ត្រាស់ថា **អារតី** ដូច្នេះ (ទៀត) ក៏ដើម្បីទ្រង់សម្តែងនូវភាវៈនៃចិត្ត ដែលមិនត្រេកអរក្រៃលែង ក្នុងបាប " ។ ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថា ថា " សេចក្តីមិនត្រេកអរក្រៃលែង ដោយចិត្ត នុ៉ះឯង របស់បុគ្គលអ្នកឃើញទោសប្រក្រតី ក្នុងបាប ឈ្មោះថា **អារតី** " ។ មែនពិត សូម្បីហេតុត្រឹមតែការកើតឡើង នៃចិត្ត ដោយអំណាច នៃការវៀរចាកបាប រមែងមានឧបការៈច្រើន ។

មङ្គលត្ថទីបនីប្រែ

ដោយហេតុនោះឯង ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ដល់ព្រះមហាចុន្ទត្ថេរ ទើបទ្រង់សម្តែងធម៌ ជាគ្រឿងជុសខាត់ ដោយអាការ ៤៤ យ៉ាង មានជាអាទិ៍យ៉ាងនេះថា "ម្នាលចុន្ទ ក៏ធម៌ ជាគ្រឿងជុសខាត់ ក្នុងសាសនានេះឯង គឺអ្នកទាំងឡាយ គប្បីធ្វើ ។ អ្នកទាំងឡាយ គប្បីធ្វើធម៌ជាគ្រឿងជុសខាត់ ថា ជនទាំងឡាយ ឯទៀត នឹងជាអ្នកបៀតបៀនគ្នា, យើងទាំងឡាយ នឹងជាអ្នកមិនបៀតបៀនគ្នា ព្រោះរឿងនេះ ដូច្នេះ, អ្នកទាំងឡាយគប្បីធ្វើធម៌ជាគ្រឿងជុសខាត ថា ជនទាំងឡាយឯទៀត នឹងជាអ្នកសម្ងាប់សត្ត, យើងទាំងឡាយ នឹងជាអ្នកវៀរ ចាកការសម្ងាប់សត្ត ព្រោះរឿងនេះ " ដូច្នេះហើយ កាលទ្រង់សម្តែង នូវការៈសូម្បី នៃចិត្តប្បាទ ក្នុងធម៌ជាគ្រឿងជុសខាតនោះ ជាធម្មជាតមានឧបការៈច្រើន ម្តងទៀត ទើបទ្រង់ត្រាស់ នូវព្រះតម្រាស់មានជាអាទិ៍ ថា " ម្នាលចុន្ទ តថាគត ពោលសូម្បីចិត្តប្បាទថា មានឧបការៈច្រើន ក្នុងកុសល-ធម៌ទាំងឡាយ, នឹងចាំបាច់ពោលធ្វើអ្វី ក្នុងការធ្វើរឿយ ៗ ដោយកាយ និង ដោយវាចា ។ ម្នាលចុន្ទ ព្រោះហេតុនោះ ក្នុងរឿងនេះ អ្នកទាំងឡាយ គប្បីញ៉ាំងចិត្ត ឲ្យកើតឡើង ថា ជនទាំងឡាយ ឯទៀត នឹងជាអ្នកបៀតបៀនគ្នា, យើងទាំងឡាយ នឹងជាអ្នកមិនបៀតបៀនគ្នា ក្នុងរឿងនេះ ដូច្នេះ ។ អ្នកទាំងឡាយ គប្បីញ៉ាំងចិត្ត

ឆាបវិរតិមជ្ឈានសំយមកថា

ឲ្យកើតឡើងថា ជនទាំងឡាយ ឯទៀត នឹងជាអ្នកសម្លាប់សត្ត, យើងទាំងឡាយ នឹងជាអ្នកវៀរ ចាកការសម្លាប់សត្ត ក្នុងរឿងនេះ ដូច្នេះ" ។

*(១៨៥) នយអដ្ឋកថា សាលេ្យ១សូត្រនោះ ថា " បណ្ដាបទទាំងនោះ បទថា **ឥធ** ន្ទុះ ជាបទសំដែងរឿងមានវិហិង្សាជាដើម ។ ២ សពួថា **ទ្វេ បន** គ្រាន់តែជាសពួនិបាត ។ បទថា **ឥធ** ជាឆដ្ឋីវិភត្តិ ចុះ ក្នុងអត្ត នៃតតិយាវិភត្តិ ។ សេចក្ដីសង្ខេប ក្នុងសាលេ្យ១សូត្រនោះ មានដូចតទៅនេះ ថា តថាគត ពោលរឿងមានវិហិង្សា ជាដើម ន្ទុះ ណាមួយ ដោយនយជាអាទិ៍ ថា ជនទាំងឡាយ ឯទៀត នឹងជាអ្នកបៀតបៀនគ្នា ដូច្នេះ, ម្នាលចុន្ទ អ្នកទាំងឡាយ គប្បីធ្វើធម៌ជាគ្រឿងជុសខាត់ ក្នុងរឿងនេះ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបំណងនឹងញ្ជាំងសេចក្ដី ដែលទ្រង់ត្រាស់ហើយ ដោយសង្ខេប ឲ្យពិស្តារ ទើបទ្រង់ត្រាស់ព្រះតម្រាស់ មានជាអាទិ៍ ថា **ឯវ វិហិ_សកា** ដូច្នេះ ។*

(ចិត្តុប្បាទ មានឧបការៈច្រើន)

*បណ្ដាបទទាំងនោះ បទថា **ឯវ** បានដល់ បុគ្គលទាំងឡាយឯណា ជាអ្នកប្រកបសាលេ្យ១ធម៌នេះ ។ បទថា **វិហិ_សកា** មានសេចក្ដីថា នឹងជាអ្នកបៀតបៀនសត្ត្វទាំងឡាយ ដោយបាតដៃ*

មង្គលត្ថទីបនីប្រែ

ឬ ដោយវត្ថុមានជុំជីជាដើម ។ បទថា **មយមេត្ត** មានសេចក្តីថា ចំណែក យើងទាំងឡាយ នឹងជាអ្នកមិនបៀតបៀនគ្នា ព្រោះរឿងដែលសត្វទាំងឡាយ ឯទៀតនុ៎ះឯង ជាអ្នកបៀតបៀនគ្នា គឺ នឹងញ៉ាំងការមិនបៀតបៀនគ្នា ឲ្យកើតឡើងហើយ រស់នៅ ។ ពាក្យថា **ឥតិ សល្លេខោ ការណីយោ** មានសេចក្តីថា ធម៌ជាគ្រឿងជុសខាត់ ពោលគឺការមិនបៀតបៀន គឺ អ្នកទាំងឡាយ គប្បីធ្វើយ៉ាងដូច្នេះ ។ ព្រោះថា អរិហិង្សា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា ធម៌ជាគ្រឿងជុសខាត់ ព្រោះវិគ្រោះថា ធម៌ណា រមែងជុសខាត់ គឺ រមែងកាត់ផ្តាច់ នូវសេចក្តីបៀតបៀនបាន ។ នយ ក្នុងអាការទាំងពួង ក៏នយនេះដែរ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងថា ក៏ការធ្វើរឿយៗ ដោយកាយ និង ដោយវាចា នុ៎ះឯណា, គឺ ការធ្វើ នូវធម៌ទាំងឡាយនោះ ដោយកាយ ឬ ការបង្ហាប់ថា អ្នកទាំងឡាយចូរធ្វើ ដោយវាចា ដូច្នេះ ឬ កិច្ចទាំងឡាយ មានការសិក្សា និងការសាកសួរជាដើម ដូចជាចិត្តជួង ទី១ ដែលបានកើតឡើងហើយដូច្នោះឯង ។ នឹងចាំបាច់ពោលធ្វើអ្វី ក្នុងកិច្ច មានការធ្វើរឿយៗជាដើមនោះឡើយ, ព្រោះថា ការប្រកបរឿយៗនោះ មានឧបការៈច្រើន ដោយចំណែកមួយ មែនពិត ដូច្នេះ ដោយបទថា **អនុវិធិ-យនាសុ** ។

ឧបនិរតិមជ្ជឧនសំយមកថា

សួរថា ក៏ព្រោះហេតុអ្វី សូម្បីចិត្តុប្បាទ ក្នុងកុសលធម៌ទាំងឡាយនេះ ទើបមានឧបការៈច្រើន? ។

ឆ្លើយថា ព្រោះជាហេតុនាំប្រយោជន៍ និង សេចក្តីសុខមកប្រគល់ឲ្យ ដោយចំណែកមួយ និង ព្រោះជាហេតុនៃកិរិយាប្រកបរឿយៗ ផង ដូច្នេះ ។

ពិតដូច្នោះមែន សេចក្តីកើតឡើងនៃចិត្តថា អាត្មាអញ នឹងឲ្យទាន ដូច្នេះ រមែងជាហេតុនាំប្រយោជន៍ និង សេចក្តីសុខមកឲ្យ ដោយចំណែកមួយ ដោយខ្លួនឯងខ្លះ ជាហេតុនៃការប្រកបរឿយៗ ខ្លះ ។ ក៏ព្រោះភាវៈនៃខ្លួនជាអ្នកមានចិត្តកើតឡើង យ៉ាងដូច្នេះឯង ក្នុងថ្ងៃទី ២ និង ទី៣ បុរសនោះ ទើបបានចាត់ចែង នូវពិធីយ៉ាងធំធ្វើមហាមណ្ឌប ហើយថ្វាយទាន ដល់ភិក្ខុ ១០០ រូប ឬ ១,០០០ រូប, បញ្ជានូវពួកជនជាបរិវារ ថា អ្នកទាំងឡាយ ចូរនិមន្ត ចូរបូជាចូរអង្គាសភិក្ខុព្រះសង្ឆ ដូច្នេះ, ការកើតឡើង នៃចិត្ត ថា អាត្មាអញ នឹងថ្វាយចីវរ សេនាសនៈ ភេសជ្ជៈ ដល់សង្ឆ ដូច្នេះ រមែងជាហេតុនាំប្រយោជន៍ និង សេចក្តីសុខមកឲ្យ ដោយចំណែកមួយ ដោយខ្លួនឯងខ្លះ ជាហេតុនៃការប្រកបរឿយៗ ខ្លះ ដោយប្រការដូច្នេះ ។ ក៏ព្រោះភាវៈជាអ្នកមានចិត្តកើតឡើង យ៉ាងដូច្នេះឯង បុរសនោះ ទើបចាត់ចែង ទើបថ្វាយខ្លួនឯង និង ឲ្យអ្នកដទៃ

មន្តលត្ថនីបនីប្រែ

ថ្វាយនូវបរិក្ខារទាំងឡាយ មានចីវរជាដើម ។ នយ ក្នុងកុសល ទាំងឡាយ មានសរណគមន៍ជាដើម ក៏នយនេះដែរ ។ ក៏បុគ្គល ញុាំងចិត្ត ឲ្យកើតឡើងថា អាត្មាអញ នឹងដល់នូវសរណ: ដូច្នេះ មុន ក្រោយមក ក៏ទទួលសរណ: ដោយកាយ ឬ ដោយវាចា ។ មួយទៀត បុគ្គលញុាំងចិត្ត ឲ្យកើតឡើងថា អាត្មាអញ នឹង សមាទានសីលប្រកបដោយអង្ត ៥ អង្ត ៨ អង្ត ១០ ដូច្នេះ មុន ហើយសមាទាន ដោយកាយ ឬ ដោយវាចា (ជាខាងក្រោយ) ។ បុគ្គលញុាំងចិត្ត ឲ្យកើតឡើងថា អាត្មាអញ នឹងបួស ហើយតាំង នៅ ក្នុងសីល ៤ ដូច្នេះមុន ហើយបំពេញសីល ដែលខ្ជួនត្រូវ បំពេញ ដោយកាយ ឬ ដោយវាចា (ជាខាងក្រោយ) ។ បុគ្គល ញុាំងចិត្ត ឲ្យកើតឡើងថា អាត្មាអញ នឹងរៀនព្រះពុទ្ធវចន: ដូច្នេះ មុន ហើយរៀន ១ និកាយ ២-៣-៤ ឬ ៥ និកាយ ដោយកាយ ឬ ដោយវាចា ។ រូបមន្ត នៃចិត្តុប្បាទ បណ្ឌិតគប្បីនាំទៅ ដោយ អំណាចការសមាទានធុតង្ត រៀនកម្មដ្ឋាន បរិកម្មកសិណ ឈាន សមាបត្តិ វិបស្សនា មគ្ត ផល បច្ចេកពោធិញ្ញាណ និង សម្មា-សម្ពោធិញ្ញាណ ដោយនយដែលបានពោលមកហើយនេះ ។ ក៏ ចិត្តុប្បាទថា អាត្មាអញ នឹងជាព្រះពុទ្ធ ដូច្នេះ រមែងជាហេតុនាំ ប្រយោជន៍ និង សេចក្តីសុខមកប្រគល់ឲ្យ (ទាំង) ជាហេតុនៃការ

១០ និងវិនិច្ឆ័យ

ប្រកបរឿយៗ ផង ។ ក៏ព្រោះជាអ្នកមានចិត្ត កើតឡើងហើយ យ៉ាងដូច្នេះឯង ដោយសម័យក្រោយមកទៀត បុរសនោះ ទើប បំពេញការមីទាំងឡាយ ដោយកាយ ឬ ដោយវាចា អស់ពេល ៤ អសង្ខ្យេយ្យ ក្រៃលែងដោយ ១ សែនកប្ប ទើបញ្ជាំងលោក (នេះ) ព្រមទាំងទេវលោក ឲ្យធ្លងផុត ត្រាច់ចរទៅ ។ សូម្បី ចិត្តុប្បាទ ក្នុងកុសលធម៌ទាំងពួង រមែងមានឧបការៈច្រើន យ៉ាង ដូច្នេះ, ចំណែកការប្រកបរឿយ ៗ ដោយកាយ ឬ វាចា បណ្ឌិត គប្បីជ្រាបថា មានឧបការៈច្រើន ក្រៃលែងមែនពិត ។ ព្រះមាន ព្រះភាគ លុះទ្រង់សម្តែង នូវការៈសូម្បីនៃចិត្តុប្បាទ ក្នុងកុសល-ធម៌ទាំងឡាយថា ជាគុណធម៌មានឧបការៈច្រើន យ៉ាងដូច្នេះហើយ ឥឡូវនេះ កាលទ្រង់បបួល (នូវវេនេយ្យសត្វទាំងឡាយ) ក្នុង ចិត្តុប្បាទនោះ ទើបទ្រង់ត្រាស់ព្រះតម្រាស់ ថា **តស្មាតិហ ចុន្ទ** ដូច្នេះជាដើម " ។

(១៨៦) ដីកាសម្ភេទសូត្រនោះ ថា " បទថា **អាការេហិ** គឺ ដោយប្រការ ៤៤ យ៉ាង មានអវិហិង្សាជាដើម ។ ២ បទថា **កុសលេសុ ធម្មេសុ** គឺក្នុងធម៌ដែលមិនមានទោស តាមដែលបាន ពោលហើយ មានអវិហិង្សាជាដើម ។ បទថា **វិហ៊ីសាទិវត្ថុំ** មាន សេចក្តីថា តថាគត ពោលវត្ថុ នៃអកុសលធម៌ មានវិហិង្សា ជា

មង្គលត្ថទីបនីប្រែ

ដើម នេះឯណា, ក្នុងវត្ថុនៃអកុសលធម៌មានវិហិង្សាជាដើមនេះ ។ ការប្រកបរឿយៗ នូវចិត្តុប្បាទ ដោយកាយ ឬ វាចា ឈ្មោះថា **អនុវិធិយនា** ។ ២ បទថា **តេសំ ធម្មានំ** គឺ នូវធម៌ទាំងឡាយ មានការមិនបៀតបៀនជាដើម, មួយទៀត សំដៅយកធម៌ទាំងឡាយ ដែលឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃចិត្តុប្បាទទាំងនោះ ។ ឥឡូវនេះ ដើម្បីសម្តែងនូវសេចក្តី តាមដែលបានពោលមកហើយ ដោយពិស្តារ ទើបព្រះអដ្ឋកថាចារ្យ ផ្តើមពាក្យថា **កស្មា បន** ជូច្នេះជាដើម ។ ពាក្យថា **កាយេន** ព្រះអដ្ឋកថា ពោលហើយ ដោយអំណាច នៃបុគ្គលអ្នកមិនអាច ដើម្បីប្រកាសសូមសរណ-គមន៍ ដោយវាចាបាន ។ នយសូម្បីក្នុងពាក្យថា **សីលំ កាយេន សមាទិយតិ** នេះ ក៏នយនេះជូចគ្នាដែរ" ។

សេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានតែប៉ណ្ណេះ ។ ចំណែក សេចក្តីពិស្តារ អ្នកសិក្សាគប្បីត្រួតមើល ក្នុងសល្ដេខ-សូត្រ ក្នុងបឋមវគ្គ នៃមូលបណ្ណាសកៈចុះ ។ សូម្បីចិត្តុប្បាទ ដោយអំណាច នៃការវៀរចាកបាប ក៏ជាគុណធម៌ មានឧបការៈ ច្រើន ដោយប្រការជូច្នេះ, ព្រោះហេតុនោះឯង ភាវៈនៃចិត្តុប្បាទ នោះ ជាមង្គល ទើបសមគួរ, ព្រោះហេតុនោះ ពាក្យថា "**អារតី**" នេះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ យ៉ងដូច្នេះឯង ។

ឧបនិរតិមជ្ជឧនសំយមកថា

ពណ្ណិនាអំពីវិភាគនៃបកិណ្ណក: មានអារម្មណ៍ ជាដើម នៃ វិរតិ ទាំងឡាយ ចប់ ។

(១៨៧) អដ្ឋកថាខុទ្ទកបាឋ: ថា " ក៏ក្នុងសិក្ខាបទទាំង ៥ នេះ បាណាតិបាត អទិន្នាទាន អព្រហ្មចរិយ: ជាកាយកម្ម តែម្យ៉ាង ដល់ភាពជាកម្មបថ ទាំងអស់ ។ មុសាវាទ ជាវចីកម្ម តែម្យ៉ាង ។ តែ មុសាវាទ ណា កំចាត់បង់នូវប្រយោជន៍, មុសាវាទនោះ រមែងដល់នូវភាពជាកម្មបថ, មុសាវាទក្រៅអំពីនេះ ជាកម្ម ប៉ុណ្ណោះ ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ជាកាយកម្មតែម្យ៉ាង ។ មួយទៀត បណ្តា រវរមណីទាំង ៥ យ៉ាងនេះ រវរមណីទាំង ៤ យ៉ាង គឺជាកាយកម្ម ទាំងអស់ ។ កិរិយាវៀរ ចាកមុសាវាទ ជាវចីកម្ម " ។

(១៨៨) បណ្តាពៀរ ចេតនា និង ការផឹកទឹកស្រវឹង ទាំងនោះ ចេតនា ជាហេតុបង្ក នូវពៀរ រមែងនាំមកនូវទុក្ខ ដែលសត្វគប្បីសោយក្នុងអបាយ ក្នុងទុគ្គតិភព និង រមែងនាំមក នូវភាពជាអ្នកមានអាយុខ្លី ក្នុងសុគតិភព ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងសព្វលហុសសូត្រ ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយថា "ម្នាលភិក្ខុទាំងឡាយ បាណាតិបាត ដែលបុគ្គលសេពថ្នឹកហើយ ចម្រើនហើយ ឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅ

មង្គលត្ថទីបនីប្រែ

ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីប្រេតវិស័យ, ផល នៃបាណាតិបាត ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីមានអាយុខ្លី ដល់បុគ្គលអ្នកកើតជាមនុស្ស, ម្នាលភិក្ខុទាំងឡាយ អទិន្នាទាន ដែលបុគ្គលសេពថ្នឹកហើយ..... រមែងប្រព្រឹត្តទៅ ដើម្បីប្រេតវិស័យ, ផលនៃអទិន្នាទានដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសនៃភោគៈ ដល់បុគ្គលអ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ កាមេសុមិច្ឆាចារ ដែលបុគ្គលសេពថ្នឹកហើយ .... ផល នៃកាមេសុមិច្ឆាចារ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីសត្រូវ និង ពៀរ ដល់បុគ្គលអ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ មុសាវាទ ដែលបុគ្គលសេពថ្នឹកហើយ .... ផល នៃមុសាវាទ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីគេពោលបង្ក្នាច់ ដោយពាក្យដែលមិនពិត ដល់បុគ្គលអ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ការផឹកទូវសុរា និង មេរ័យ ដែលបុគ្គលសេពថ្នឹកហើយ.... ផលនៃការផឹកទូវសុរា និង មេរ័យ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីភាពជាអ្នកឆ្កួត ដល់បុគ្គលអ្នកកើតជាមនុស្ស ” ។

(១៨៩) អដ្ឋកថាសព្វលហុសសូត្រនោះ ថា “ បណ្ណាបទ

ឧបនិរតិមជ្ជឧនសំយមកថា

ទាំងនោះ ចេតនា ជាហេតុសម្ថាប់សត្ត ឈ្មោះថា ឧាណាតិឧាត ។ បទថា ***សព្វលហុសោ*** *គឺ ដែលស្រាលជាងផលទាំងអស់ ។ បទថា* ***អប្ឋាយុកសំវត្តនិកោ*** *មានសេចក្តីថា បុគ្គលជាអ្នកមានអាយុខ្ជី ព្រោះផលនៃកម្មដ៏តិចតួចនោះ, គឺកាលបើបដិសន្ធិ គ្រាន់តែជនកកម្ម ឲ្យផលហើយ, បុគ្គលនោះរមែងរលាយទៅ ឬ គ្រាន់តែប្រសូតពេញ អំពីផ្ទៃពោះ នៃមាតាហើយ ក៏រលាយទៅវិញ ។ ក៏ផលប្រាកដដូច្នេះ នឹងជាផលរបស់កម្មអ្វីដទៃទៀត ក៏មិនមែនទេ, ផលប្រាកដដូច្នោះនេះ ជាផ្ទូវនៃឧាណាតិឧាត ន៉ុះឯង ទៅហើយ ។ បទថា* ***ភោគព្យសនសំវត្តនិកោ*** *មានសេចក្តីថា ទ្រព្យត្រឹមតែមួយកាកណិក រមែងមិនជាប់នៅក្នុងដៃ យ៉ាងណា, ផលនៃអទិន្នាទានរមែងញ្ជាំងសេចក្តីវិនាសភោគ: ឲ្យប្រព្រឹត្តទៅព្រម យ៉ាងដូច្នោះ ។ បទថា* ***សបត្តវេរសំវត្តនិកោ*** *មានសេចក្តីថា ផល នៃកាមេសុ-មិច្ឆាចារ រមែងញ្ជាំងពៀរ ឲ្យប្រព្រឹត្តទៅ ព្រមទាំងពួកសត្រូវ ។ មែនពិត ពួកសត្រូវ របស់កាមេសុមិច្ឆាចារីបុគ្គលនោះ រមែងមានច្រើន, ក៏បុគ្គលឯណាៗ រមែងជួបប្រទះ នូវកាមេសុមិច្ឆាចារី-បុគ្គលនោះ, បុគ្គលនោះ ៗ រមែងញ្ជាំងពៀរន៉ុះឯង ឲ្យកើតឡើងគឺមិនឲ្យរលត់ ក្នុងកាមេសុមិច្ឆាចារីបុគ្គលនោះ ។ ក៏ផលប្រាកដដូច្នេះ ជាផលនៃការប្រព្រឹត្តិខុស ក្នុងកណ្ឌ: ដែលបុគ្គលដទៃ ថែ*

មន្ទលត្ថទីបនីប្រែ

រក្សាគ្រប់គ្រងហើយ ។ ២ បទថា ***អកូតព្ពក្ខានសំវត្តនិកោ ហោតិ*** *មានសេចក្តីថា ផលនៃមុសាវាទ រមែងញ្ចុាំងការពោលមួលបង្កាច់ ដោយពាក្យមិនពិត ឲ្យប្រព្រឹត្តទៅព្រម, គឺកម្មដែលបុគ្គលឯណា មួយធ្វើហើយ រមែងជ្ជាក់ទៅ លើមុសាវាទីបុគ្គលនោះតែប៉ុណ្ណោះ ។ ២ បទ ថា* ***ឧម្មត្តកសំវត្តនិកោ ហោតិ*** *មានសេចក្តីថា ផលនៃការ ផឹកនូវសុរា និង មេរ័យ រមែងញ្ចុាំងភាពជាអ្នកឆ្ពួត ឲ្យប្រព្រឹត្តទៅ ព្រម ។ មែនពិត មនុស្ស ជាអ្នកឆ្ពួតក្តី ជាអ្នកមានចិត្តរវើរវាយក្តី ជាអ្នកឆ្ពួតទឹកមាត់ក្តី ក៏ព្រោះវិបាក នៃការផឹកសុរា និង មេរ័យ នោះឯង, នេះ គឺជាផលនៃការផឹកសុរា " ។*

(១៩០) ចំណែក ទោសនៃការផឹកទឹកស្រវឹង មកហើយ ដោយពិស្តារ ក្នុងកុម្ភជាតក និង ក្នុងសិគាលសូត្រ ។ ពិតដូច្នោះ ព្រះមានព្រះភាគ ត្រាស់ ក្នុងសិគាលសូត្រថា "ម្នាលគហបតីបុត្រ កិរិយាប្រកបរឿយៗ នូវកិរិយាផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ដែលជាទីតាំង នៃសេចក្តីប្រមាទ ជាផ្ជូវនៃសេចក្តីវិនាស នៃភោគៈ ទាំងឡាយ " ដូច្នេះហើយ ដើម្បីទ្រង់សម្តែង នូវទោសនៃការផឹក នូវទឹកស្រវឹងនោះ ទើបទ្រង់ត្រាស់ថា "ម្នាលគហបតីបុត្រ ទោស នៃកិរិយាប្រកបរឿយ ៗ នូវការផឹក នូវទឹកស្រវឹង គឺ សុរា និង មេរ័យ ដែលជាទីតាំង នៃសេចក្តីប្រមាទ មាន ៦ យ៉ាងនេះឯង គឺ

ឧបនិរតិមជ្ជបានសំយមកថា

ជាហេតុនៃការខូចខាតទ្រព្យ ដែលបុគ្គលគប្បីយើញទាន់ភ្នែក ១ ជាហេតុបង្ក្នរូវជំលោះ ១ ជាទីកើតឡើងនៃរោគទាំងឡាយ ១ ជាហេតុញ្ចុាំងកេរ្តិ៍ឈ្មោះមិនល្អ ឲ្យកើតឡើង ១ ជាហេតុបើកកេរ្តិ៍ខ្មាស ឲ្យគេយើញប្រាកដ ១ បទជាទីគម្រប់ ៦ ថា ជាហេតុធ្វើបញ្ញា ឲ្យចុះឌ្ឍនថយ ១ " ។

(១៩១) អដ្ឋកថាសិគាលសូត្រនោះ ថា " បណ្តាបទទាំងនោះ បទថា **អបាយមុខំ** ប្រែថា ជាផ្លូវនៃសេចក្តីវិនាស ។ ការតាមប្រកប គឺ ការធ្វើរឿយៗ នូវការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទនោះ ឈ្មោះថា អនុយោគោ ។ ក៏ព្រោះ កាលបើបុគ្គលប្រកបរឿយៗ នូវការផឹកនូវទឹកស្រវឹងនោះ, ភោគៈទាំងឡាយដែលកើតឡើងហើយនុ៉ះឯង រមែងសាបសូន្យអស់ទៅ និង ភោគៈទាំងឡាយ ដែលមិនទាន់បានកើតឡើងហើយ រមែងមិនកើតឡើង, ដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា **ភោគានំ អបាយមុខំ** ។ បទថា **សនិដ្ឋិកា** គឺ ដែលបុគ្គលគប្បីយើញខ្លួនឯង បានដល់ ដែលប្រាកដមាន ក្នុងលោកនេះ ។ បទថា **ធនជានិ** ប្រែថា ជាហេតុសាបសូន្យនៃទ្រព្យ ។ បទថា **កលហប្បវឌ្ឍនី** មានសេចក្តីថា ជាហេតុបង្ក្នការឈ្លោះវិវាទគ្នា ដោយវាចា និង ការឈ្លោះវិវាទគ្នា ដោយកាយ មានការ

មន្តលត្ថនីបនីប្រែ

ចំបាប់គ្នា ដោយដៃជាដើម ឲ្យកើតឡើង ។ ២ បទថា **រោគានំ អាយតនំ** គឺ ជាខេត្តនៃរោគទាំងឡាយនោះៗ មានរោគភ្នែក ជាដើម ។ បទថា **អកិត្តិសញ្ញនន៊ី** មានសេចក្តីថា មែនពិត បុគ្គលពាលទាំងឡាយ ផឹកសុរាហើយ ប្រហារមាតាក៏បាន, បិតា ក៏បាន, ពោលពាក្យ ដែលមិនគួរពោលដទៃទៀត បានយ៉ាងច្រើន, ធ្វើនូវកិច្ចដែលមិនគួរធ្វើ, ព្រោះកម្មនោះ ពួកគេ តែងដល់ នូវការតិះដៀលខ្លះ អាជ្ញាខ្លះ ដល់នូវការកាត់អវយវ: មានដៃ និង ជើងជា ដើមខ្លះ, រមែងដល់នូវការខូចឈ្មោះ ទាំងក្នុងលោកនេះ ទាំងក្នុងបរលោក ។ សុរានោះ របស់បុគ្គលពាលទាំងនោះ ទើបឈ្មោះថាជាហេតុបង្ក្ការខូចឈ្មោះ ឲ្យកើតឡើង យ៉ាងដូច្នេះឯង ។ បទថា **កោបិនន៊ិទ្ទំសន៊ី** មានសេចក្តីថា ព្រោះទីកំបាំង ដែលបុគ្គលកំពុងបើក រមែងញ្ជាំងការអៀនខ្មាសឲ្យកម្រើក ហេតុដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **កោបិនំ** ដូច្នេះ ។ ក៏ពួកបុគ្គល អ្នកស្រវឹង ព្រោះស្រវឹងសុរា រមែងដើរបើក នូវអវយវ:នោះ, ព្រោះហេតុនោះ សុរា របស់បុគ្គលទាំងនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា **កោបិនន៊ិទ្ទំសន៊ី** ព្រោះជាហេតុបើកបង្ហាញ នូវអវយវ: ដែលញ្ជាំងការអៀនខ្មាសឲ្យកម្រើក ។ ២ បទថា **បញ្ញាយ ទុព្ទ-លីករណី** មានសេចក្តីថា សុរានោះ រមែងធ្វើនូវកម្មស្សគតាបញ្ញា

ឧបនិរតិមជ្ជឧនសំយមកថា

ឲ្យមានកម្ចាំងឧនថយ ដូចជាសុរារបស់ព្រះសគាតត្ថេរ ដូច្នោះឯង, ហេតុដូច្នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ***បញ្ញាយ ទុព្ធលីករណី*** *ដូច្នេះ ។ តែសុរានោះ រមែងមិនអាច ដើម្បីនឹងធ្វើ នូវមគ្គបញ្ញា ឲ្យមានកម្ចាំងឧនថយបានឡើយ ។ ព្រោះសុរានោះ រមែងមិនហូរចូលទៅក្នុងមាត់ នៃបុគ្គលដែលបានសំរេចមគ្គហើយ ន៉ុះឯង ។ ២ បទថា* ***ឆដ្ឋំ បទំ*** *បានដល់ ហេតុជាគម្រប់ ៦ " ។*

(១៩២) ដីកានៃសិគាលសូត្រនោះថា " ភោគ:ទាំងឡាយ រមែងអស់ទៅ គឺ រមែងវិនាសទៅ ម៉ាងទៀត ភោគ:ទាំងឡាយ រមែងសាបសូន្យអស់ទៅ ព្រោះទោសន៉ុះ ហេតុនោះ ទោសន៉ុះ ឈ្មោះថា ជាហេតុវិនាសនៃភោគ:ទាំងឡាយ ។ ម៉ាងទៀត ការ ប្រកបរឿយៗ នូវការផឹកសុរានោះ ជាផ្លូវ គឺ អបាយ បានដល់ ជាទ្វារ នៃសេចក្តីវិនាសភោគ: ព្រោះហេតុនោះ ការប្រកបរឿយៗ នូវការផឹកសុរានោះ ឈ្មោះថា ជាផ្លូវនៃសេចក្តីវិនាសនៃភោគ: ។ សូម្បីក្នុងបទថា ***វិនាសមុខំ*** *នេះ ក៏នយនោះឯង។ ទីតាំងនៃសេចក្តី ប្រមាទ ព្រោះទឹកស្រវឹង គឺសុរា និង មេរ័យ ឈ្មោះថា សុរាមេ-រយមជ្ជប្បមាទដ្ឋាន ។ ភាវ:ជាអ្នកប្រកបព្រម ដោយការប្រកប រឿយៗ នូវសុរាមេរយមជ្ជប្បមាទដ្ឋាននោះ ឈ្មោះថា អនុយោគ: ។ ដោយហេតុដូច្នោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា* ***បុនប្បុនំ***

មន្តលត្ថទីបនីប្រែ

ការណំ ។ មានសេចក្តីថា ប្រព្រឹត្តទៅហើយញឹកញាប់ ។ ភោគ: ទាំងឡាយ ដែលកើតឡើងហើយនុ៉ះឯង ឈ្មោះថា រមែងវិនាសទៅ ព្រោះធ្វើសេចក្តីវិនាស ដោយសេចក្តីវិនាស ព្រោះការផឹក ។ និង ភោគ:ទាំងឡាយ ដែលមិនទាន់កើតឡើង ឈ្មោះថា រមែងមិនកើតឡើង ព្រោះភាវ:នៃបុគ្គលអ្នកស្រវឹងហើយ មិនមានការខ្ចល់ខ្ចាយ ក្នុងការងារទាំងឡាយ ។ បទថា ***ភោគានំ*** បានដល់ កាមគុណទាំងឡាយ ដែលបានឈ្មោះថា ភោគ: ព្រោះអត្ថថា គឺបុគ្គលគប្បីបរិភោគ ។ ផលឯណា ដែលបុគ្គលអ្នកផឹកគប្បីឃើញ ដោយខ្លួនឯង ព្រោះហេតុនោះ ផលនោះ ឈ្មោះថា ដែលបុគ្គលអ្នកផឹកគប្បីឃើញដោយខ្លួនឯង ។ សន្ទិដ្ឋ:នុ៉ះឯង គឺជាសន្ទិដ្ឋិក: ។ ក៏ព្រះមានព្រះភាគ ទ្រង់ធ្វើនិទ្ទេស ដោយអំណាច នៃឥត្ថីលិង្គ ព្រោះទ្រង់សំឡឹងរំពៃដល់ ***ធនជានិ*** សព្ទ ។ ក្នុងបទថា ***សន្ទិដ្ឋិកំ*** នេះ មានសេចក្តី ដូចតទៅនេះថា ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន ដូច្នេះ, ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា ***ឥធលោក-ភាវិនី*** ។ ម៉ាងទៀត សេចក្តីវិនាសទ្រព្យនោះ គឺបុគ្គលគប្បីឃើញ ព្រមគ្នា គឺរួមគ្នា (នឹងការផឹកសុរានោះ) ហេតុនោះ ទើបឈ្មោះថា ដែលបុគ្គលគប្បីឃើញ ព្រមជាមួយគ្នា ។ អធិប្បាយថា ប្រាកដ ផល ក្នុងវេលា ព្រមជាមួយគ្នានឹងការផឹក ។ ឈ្មោះថា ជាហេតុ

១០០ និងវិតិមជ្ឈបានសំយមកថា

បង្ហូរនូវសេចក្តីឈ្លោះវ៉ៃទគ្នា ព្រោះការៈនៃបុគ្គលអ្នកស្រវឹងហើយ ច្រើនតែមិនឃើញទោស ក្នុងសេចក្តីឈ្លោះវ៉ៃទគ្នា ។ ឈ្មោះថា ជាទ្វេគ្ត (នៃរោគ) ព្រោះការៈនៃស្ថានទីដែលកើតឡើង ។ ម្យ៉ាងទៀត បទថា ***អាយតនំ*** *ប្រែថា ជាហេតុ, អធិប្បាយថា ជាទីកើតឡើង ។ បុគ្គល អ្នកផឹកសុរាទាំងឡាយ ឈ្មោះថា រមែងដល់នូវការខូចឈ្មោះ ទាំងក្នុងលោកនេះ ព្រោះការជួបប្រទះនូវកម្ម ដែលញ៉ាំងការខូចឈ្មោះ ឲ្យប្រព្រឹត្តទៅ, មួយទៀត កម្ម ក្នុងទីស្ងាត់កំបាំង គឺបុគ្គលមិនគប្បីធ្វើ ដោយភាពជារបស់បើកបង្ហាញ ឈ្មោះថា* ***កោបិនៈ*** *។ បណ្ឌិត គប្បីឃើញសេចក្តី ក្នុងដំណើរនេះ យ៉ាងដូច្នេះថា ក៏បុគ្គលអ្នកស្រវឹង ព្រោះស្រវឹងសុរា ក្នុងពេលដែលខ្លួនមិនស្រវឹង បិទបាំងនូវកម្មដូច្នោះ ដែលខ្លួនធ្វើហើយ ក្នុងពេលមុន ដើរទៅ ក្នុងពេលស្រវឹងហើយ រមែងបើកបង្ហាញ គឺធ្វើឲ្យប្រាកដ សូម្បីដល់ជនទាំងឡាយ ដែលជាសឹកសត្រូវ ដោយហេតុនោះ សុរានោះ របស់ជនទាំងនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា* ***កោបិនានិទ្ទំសនី*** *ព្រោះការបើកបង្ហាញនូវអវយៈ ដែលជាហេតុញ៉ាំងហិរិឲ្យកម្រើកនោះ ។ បទថា* ***កម្មស្សកតប្បញ្ញំ*** *បណ្ឌិតគប្បីឃើញថា គ្រាន់តែជាឧទាហរណ៍ ។ អ្នកណា ក៏អាចដើម្បីនឹងដឹងបានថា សុរា រមែងធ្វើនូវបញ្ញា ណាមួយ ដែលជា*

មង្គលត្ថទីបនីប្រែ

លោកិយ: ឲ្យមានកម្លាំងចុះខ្ជិនថយ ដោយពិត ។ ពិតមែនដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលពាក្យថា **មគ្គឃ្ឃញ្ញមន** ដូច្នេះជាដើម ដើម្បីនឹងទទួលស្គាល់នូវសេចក្ដីនោះ ដោយមុខដែលមានសេចក្ដីផ្ទុយផ្សេងគ្នា ។ ដោយពាក្យថា **អន្ត្ថោ មុខមេវនឃ្ឃវិសតិ** នេះ ព្រះអដ្ឋកថាចារ្យ ពោលនូវភាវ:នៃការដែលសុភ ធ្វើមគ្គបញ្ញា ឲ្យមានកម្លាំងចុះខ្ជិនថយ ជាទោសត្រូវមគ្គបញ្ញា លើកឡើងផុតឆ្ងាយហើយ ។

សួរថា ក៏ភាវ:ដែលសុភបំផ្ងាញ នូវភាពជាអ្នកអាច ក្នុងការធ្វើបញ្ញានោះ ឲ្យមានកម្លាំងខ្ជិនថយ យ៉ាងដូច្នេះ ជារឿងដែលព្រះអដ្ឋកថាចារ្យ មិនបានចោទប្រកាន់ហើយ ព្រោះភាវ:នៃការមិនចូលទៅខ្ជប់ខ្ជាំងសុភ នៃព្រះអរិយ:ទាំងឡាយ គឺលោកបានជំទាស់ស្រេចហើយ មិនមែនទេឬ ? ។

ឆ្លើយថា រឿងនេះ មិនមែនដូច្នេះទេ ។ ព្រោះលោកបានពោលសេចក្ដីនេះហើយថា ឈ្មោះថា សូម្បីការចូលទៅ ប្រកបនូវសុភនោះ រមែងមិនមាន ដល់ព្រះអរិយ:ទាំងឡាយនោះ ការធ្វើកិច្ច នឹងមានមកពីណាបាន ។ ក៏ប្រសិនបើការប្រកបសុភនោះ គប្បីមាន ក្នុងពេលខ្ះ ដោយអំណាចនៃការកំណត់ដែលមិនសមគួរ, សូម្បីជាដូច្នោះ សុភនោះ ក៏ឈ្មោះថា មិនអាច ដើម្បីនឹងធ្វើ

មគ្គបញ្ញានោះឲ្យចុះថយកម្លាំង សូម្បីបន្តិចបន្តួចបានឡើយ ព្រោះភាវៈនៃមគ្គបញ្ញានោះ តាំងនៅខ្ជាប់ខ្ជួនហើយ ដោយភាពជាគុណជាតិធ្ងាយ ចាកធម៌ដែលជាសឹកសត្រូវ ដោយត្រឹមត្រូវមែនពិត ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **មគ្គប្បញ្ញម្បន ទុព្វលំ កាតុំ ន សក្កា** ដូច្នេះ ។ ក៏គប្បីឃើញសន្និដ្ឋាន ក្នុងអធិការនៃការធ្វើបញ្ញា ឲ្យមានកម្លាំងឱនថយនេះ ដោយធម៌ជាប្រធាន គឺមគ្គបញ្ញា ថា ភាវៈនៃសុភជាធម្មជាតិមិនអាច ក្នុងការញ៉ាំងបញ្ញាដែលជាលោកិយៈ និង លោកុត្តរៈ សូម្បីទាំងអស់ របស់ព្រះអរិយៈទាំងឡាយ ឲ្យដល់នូវភាពជាគុណជាតិ មានកម្លាំងចុះថយបាន គឺព្រះអដ្ឋកថាចារ្យ សម្តែងទុកហើយ ។ ផល រមែងសម្រេច ដោយធម្មជាតនុ៎ះឯង ហេតុនោះ ធម្មជាតនុ៎ះ ឈ្មោះថា ជាគ្រឿងដល់ គឺជាហេតុ ” ។

ក៏កុម្ភជាតក បណ្ឌិតគប្បីត្រួតមើល ក្នុងតឹសនិបាត ។

(១៩៣) ចេតនាជាហេតុបង្កពៀរ ឈ្មោះថា ជាអពមង្គល ព្រោះជាហេតុនាំមក នូវអនិដ្ឋផល មានទុក្ខដែលប្រព្រឹត្តទៅ ក្នុងអបាយជាដើម ដោយប្រការដូច្នេះ ។ ចំណែក ចេតនា ដែលជាហេតុវៀរចាកពៀរ ឈ្មោះថា ជាមង្គល ព្រោះខុសផ្សេងអំពីគ្នាចាកចេតនា ជាហេតុបង្កពៀរនោះ ។ ដោយហេតុនោះ ទើបព្រះ

មន្តលត្ថទីបនីប្រែ

អដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថា ថា " ការវៀរ និង ការ
វៀរស្រឡះ ចាកបាបនោះ សូម្បីទាំងអស់ន៉ុះ ព្រះដ៏មានព្រះភាគ
ទ្រង់ត្រាស់ថា ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការលះបង់
មានការលះបង់ភ័យ និងពៀរ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និង
ប្រព្រឹត្តទៅ ក្នុងសម្បរាយិកភពជាដើម និង ជាហេតុនៃការបាន
សម្រេចនូវគុណវិសេសផ្សេងៗ ។ ក៏ព្រោះហេតុដែលបុគ្គលអ្នក
ផឹកទឹកស្រវឹង រមែងមិនដឹងអត្ត មិនដឹងធម៌ រមែងធ្វើសេចក្តី
អន្តរាយ ដល់មាតា ដល់បិតា រមែងធ្វើសេចក្តីអន្តរាយសូម្បីដល់
ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះសាវ័ក របស់ព្រះតថាគតទាំង
ឡាយ, រមែងដល់នូវការតិះដៀលក្នុងបច្ចុប្បន្ន រមែងដល់នូវទុគ្គតិ
ក្នុងសម្បរាយភព រមែងដល់នូវភាពជាអ្នកឆ្ពួត ក្នុងភពជាបន្តៗ
ទៅ, ចំណែក ការសង្រួម ចាកការផឹកនូវទឹកស្រវឹង រមែងដល់នូវ
ការស្ងប់រម្ងាប់ទោសទាំងឡាយនោះ និង គុណសម្បត្តិ ដែលខុស
ផ្សេងពីគ្នាអំពីទោសនោះ ព្រោះហេតុនោះ ការសង្រួម ចាកការ
ផឹកទឹកស្រវឹងនេះ បណ្ឌិតគប្បីជ្រាបថា ជាមង្គល ដូច្នេះ ។

(១៩៤) មែនពិត សូម្បីព្រះមានព្រះភាគកាលទ្រង់សម្តែង
ធម៌ ដល់អនាថបិណ្ឌិក: ទ្រង់ត្រាស់ ក្នុងបឋមភយសូត្រ ក្នុងវគ្គ
ទី ៤ នៃនិទានវគ្គ យ៉ាងដូច្នេះ ថា " ភ័យ ពៀរទាំងឡាយ ៥ យ៉ាង

១០ និងវិតិមជ្ឈ១០ និងសំយមកថា

ដូចម្តេចខ្លះ រមែងស្ងប់រម្ងាប់ហើយ? ។ ម្នាលគហបតី បុគ្គលអ្នក
សម្ងាប់សត្វរមែងបាននូវកំ្ចយ នូវពៀរ ជាបច្ចុប្បន្នផង រមែងបាន
នូវកំ្ចយ នូវពៀរ ទៅខាងមុខផង រមែងទទួល នូវទុក្ខទោមនស្ស
ដែលប្រព្រឹត្តទៅ ក្នុងចិត្តផង ព្រោះបច្ច័យ គឺការសម្ងាប់សត្ត ឯ
ណា, កំ្ចយ ពៀរនោះ របស់បុគ្គលអ្នកវៀរចាកបាណាតិបាតបាន
ហើយ រមែងស្ងប់រម្ងាប់ហើយ ដោយប្រការយ៉ាងនេះ ។ ម្នាល
គហបតី បុគ្គលអ្នកកាន់យករបស់ដែលគេមិនបានឲ្យ រមែងបាន
នូវកំ្ចយ នូវពៀរ ឯណា ... ព្រោះបច្ច័យ គឺអទិន្នាទាន ... ម្នាល
គហបតី បុគ្គលអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ រមែងបាន
នូវកំ្ចយ នូវពៀរ ឯណា... ព្រោះបច្ច័យគឺការប្រព្រឹត្តិខុស ក្នុងកាម
ទាំងឡាយ ... ម្នាលគហបតី បុគ្គលអ្នកនិយាយកុហក រមែងបាន
នូវកំ្ចយ នូវពៀរឯណា... ព្រោះបច្ច័យគឺមុសាវាទ... ម្នាលគហបតី
បុគ្គលអ្នកផឹកទឹកស្រវឹង គឺសុរា និង មេរ័យ ដែលជាហេតុជាទី
តាំងនៃសេចក្តីធ្វេសប្រហែស រមែងបាន នូវកំ្ចយ នូវពៀរ ឯណា
ជាបច្ចុប្បន្នផង បាននូវកំ្ចយ នូវពៀរ ទៅខាងមុខផង បានទទួល
នូវទុក្ខ ទោសមនស្ស ដែលប្រព្រឹត្តទៅ ក្នុងចិត្តផង ព្រោះបច្ច័យ
គឺ សុរាមេរយមជ្ជប្បមាទដ្ឋាន, កំ្ចយ ពៀរនោះ របស់បុគ្គលអ្នក
វៀរចាក សុរាមេរយមជ្ជប្បមាទដ្ឋាន ហើយ រមែងស្ងប់រម្ងាប់អស់

មន្តលត្ថទីបនីប្រែ

ហើយ ដោយប្រការយ៉ាងនេះ ។ ភ័យ ពៀរទាំងឡាយ ៥ យ៉ាង នេះ រមែងស្ងប់រម្ងាប់អស់ហើយ " ។

*(១៩៥) អដ្ឋកថាបឋមភយសូត្រនោះថា " បណ្តាបទទាំង នោះ ២ បទថា **ភយានិ វេរានិ** បានដល់ ចេតនា អ្នកបង្ក្ភ័យ និង ពៀរទាំងឡាយ ។ បទថា **បាណាតិបាតប្បច្ចយា** គឺ ព្រោះ កម្ម គឺបាណាតិបាត ជាហេតុ ។ ២ បទថា **ភយំ វេរំ** ដោយ សេចក្តី គឺជាបទតែមួយ ។ ក៏ធម្មតាពៀរនុ៉ះ មាន ២ យ៉ាង គឺ ពៀរខាងក្រៅ ១ ពៀរខាងក្នុង ១ ។ មែនពិត បិតា របស់បុរស ម្នាក់ ជាអ្នកត្រូវបុរសម្នាក់ សម្ងាប់ហើយ ។ បុរសនោះ គិតថា បានញ្ចថា បិតា របស់អញ ត្រូវបុរសនុ៉ះ សម្ងាប់ហើយ, សូម្បី អញ ក៏នឹងសម្ងាប់បុរសនោះ ផងដែរ ដូច្នេះហើយ ក៏កាន់យក សស្ត្រា ដែលសំលៀងហើយ ដើរទៅ ។ ចេតនា អ្នកបង្ក្ពៀរ ដែលកើតឡើងហើយ ក្នុងសណ្តាន នៃបុរសនោះ ឯណា, ចេតនា-កម្មនេះ ឈ្មោះថា ពៀរខាងក្រៅ ។ ចំណែក ចេតនា របស់បុរស ក្រៅអំពីនេះ ឯណា ថា បានញ្ចថា បុរសនេះរមែងត្រាច់ទៅដោយ ប្រាថ្នាថា នឹងសម្ងាប់អញ ដូច្នេះ, អញ នេះឯង នឹងសម្ងាប់បុរស នោះឲ្យបានមុន ដូច្នេះ រមែងកើតឡើង, ចេតនាកម្មនេះ ឈ្មោះ ថា ពៀរ ខាងក្នុង ។ សូម្បីពៀរទាំង ២ យ៉ាងនេះ ក៏ជាពៀរ*

១០ចវិរតិមជ្ឈបានសំយមកថា

ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នប៉ុណ្ណោះ ជាមុនសិន ។ ចំណែកឯ ចេតនា របស់នាយនិរយបាល អ្នកឃើញ នូវបុរសនោះ ដែលកើត ក្នុងនរកហើយ ចាប់ដំបងដែក ដែលឆេះសន្ធោសន្ធៅហើយ ដោយគិតថា អញ នឹងប្រហារ នូវបុរសនុ៎ះ ដូច្នេះ ឯណា រមែងកើតឡើង, ចេតនាកម្មនេះ របស់នាយនិរយបាននោះ ឈ្មោះថា ពៀរខាងក្រៅ ដែលប្រព្រឹត្តទៅ ក្នុងសម្បរាយភព ។ ចេតនា ឯណា របស់សត្វនរកនោះថា នាយនិរយបាលនេះ កំពុងដើរមក ដោយគិតថា នឹងប្រហារអញអ្នកមិនមានទោស ដូច្នេះ, អញ នេះ ឯង នឹងប្រហារនូវបុរសនោះ ឲ្យបានមុន ដូច្នេះ រមែងកើតឡើង, ចេតនាកម្មនេះ របស់សត្វនរកនោះ ឈ្មោះថា ពៀរខាងក្នុង ដែលប្រព្រឹត្តទៅ ក្នុងសម្បរាយភព ។ ក៏ពៀរខាងក្រៅនេះ ឯណា, ពៀរខាងក្រៅនោះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថា ថា ពៀរបស់បុគ្គល ។ ២ បទថា **ទុក្ខំ ទោមនស្សំ** ដោយសេចក្តី គឺបទតែមួយនុ៎ះឯង ។ ក៏សេចក្តី ក្នុងបាទទី១ នេះ ខ្ញុំបានពោលទុកហើយ យ៉ាងណា, សេចក្តីសូម្បីក្នុងបទដែលសេសសល់ទាំងឡាយ បណ្ឌិត ក៏គប្បីជ្រាប យ៉ាងដូច្នោះដែរ ។ កិរិយាកើតឡើងនៃពៀរ បណ្ឌិត គប្បីជ្រាប ដោយនយជាអាទិ៍ ថា ភណ្ឌៈរបស់អញ ត្រូវបុរសនេះ លួចយកហើយ, ភាពជាអ្នកប្រព្រឹត្តកន្ទង ក្នុង

មន្តលត្ថទីបនីប្រែ

ភរិយា និង បុត្រទាំងឡាយ របស់អញ ត្រូវបុរសនេះ ពោលមុសា កាច់បំផ្ទាញហើយ, កម្មឈ្មោះនេះ គឺបុគ្គលអ្នកស្រវឹងហើយ ព្រោះស្រវឹងសុរា បានធ្វើហើយ ដូច្នេះ" ។

(១៩៦) ដីកាបឋមកយសូត្រនោះ ថា " ចេតនា ទាំងឡាយ ដែលនាំភ័យ និង ពៀរ មកឲ្យ ឈ្មោះថា ចេតនាអ្នកបង្ក្ភ័យ និង ពៀរទាំងឡាយ ។ ម៉ូរាងទៀត ចេតនាទាំងឡាយដែលបានឈ្មោះ ថា ភ័យ ព្រោះអត្ថថា គឺបុគ្គលគប្បីខ្ជាច, ដែលបានឈ្មោះថាពៀរ ព្រោះអត្ថថា ជាហេតុឲ្យប្រសព្វនូវពៀរ ។ មែនពិត បាបធម៌ទាំង ឡាយ មានបាណាតិបាត ជាដើម រមែងប្រព្រឹត្តទៅ ដល់បុគ្គល ណា និង ដែលបុគ្គលឲ្យប្រព្រឹត្តទៅ ចំពោះបុគ្គល ឯណា រមែង ជាបាបធម៌ នាំភ័យ និង ពៀរ មកឲ្យ ដល់បុគ្គលទាំង ២ ពួក នោះ, ព្រោះជាបាបធម៌ ដែលនាំភ័យ និង ពៀរ មកឲ្យនោះឯង ទើបជាបាបធម៌ ដែលបុគ្គលគប្បីខ្ជាច និង ញ្ជាំងពៀរឲ្យកើតឡើង ដូច្នេះ ។ បទថា ***បាណាតិបាតកម្មការណា*** *គឺ ព្រោះធ្វើកម្ម ដ៏ លាមក ពោលគឺបាណាតិបាត ជាហេតុ ។ សេចក្តីក្រោធទឹង ព្រះ មានព្រះភាគ ទ្រង់ត្រាស់ហៅថា ពៀរ ។ ពៀរនោះឯង ឈ្មោះថា ភ័យ ព្រោះភាពជាពៀរ ដែលបុគ្គលគប្បីខ្ជាច ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា* ***ភយំ វេរន្តិ អត្ថតោ ឯកំ*** *ដូច្នេះ ។*

ឧបនិរតិមជ្ជបានសំយមកថា

ពៀរនេះ ឈ្មោះថា ពៀរខាងក្រៅ ព្រោះជាពៀរខាងក្រៅ ចាកបុគ្គលអ្នកបង្ក្គពៀរ ដែលជាមូលហេតុនៃពៀរនោះ, ព្រោះហេតុនោះឯង ទើបព្រះអដ្ឋកថាចារ្យ ពោលសំដៅយកពៀរ ដែលកើតឡើងហើយដល់បុគ្គលអ្នកបង្ក្គពៀរនោះថា **ឥទំ អជ្ឈត្តិកវេរំ នាម** ដូច្នេះ ។ អធិប្បាយថា ចេតនា រមែងកើតឡើង ដល់បុគ្គលអ្នកបង្ក្គពៀរ ដែលជាមូលហេតុនៃពៀរ ដែលអាស្រ័យពៀរខាងក្រៅនោះ សូម្បីជាអ្នកមិនអាច ដើម្បីនឹងប្រហារបាន ។ មែនពិត ពួកសត្វនរកទាំងឡាយ នឹងមិនអាច ដើម្បីនឹងប្រហារតបពួកនាយនិរយាបាលបានឡើយ ។ ដោយបទថា **និរយបាលស្ស ចេតនា ឧប្បជ្ជតិ** ដូច្នេះនេះ ព្រះអដ្ឋកថាចារ្យសម្តែង ថា ក្នុងនរក មាននាយនិរយបាលពិតមែន ដូច្នេះ ។ ពាក្យថា **យម្បនេតំ ពាហិរវេរំ** មានសេចក្តីថា ពៀរខាងក្រៅនេះ ឯណា ជាពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ននេះផង ដែលប្រព្រឹត្តទៅ ក្នុងសម្បរាយភពផង, ពៀរខាងក្រៅនោះ ព្រះអដ្ឋកថាចារ្យពោលហើយថា ពៀររបស់បុគ្គល ។ បទថា **សេសបទេសុ** បានដល់ក្នុងចំណែកដែលសេសសល់ទាំងឡាយ ដែលមកហើយដោយន័យជាដើមថា **អទិន្នាទាយី** ដូច្នេះ ។ បទថា **ភគ្គោ** គឺប្រយោជន៍ គឺបុគ្គលនេះ ធ្វើឲ្យវិនាសហើយ " ។

ក៏បឋមភយសូត្រន៉ុះឯង លោក បានចងក្រងទុកហើយ

មង្គលត្ថទីបនីប្រែ

ក្នុងទសកនិបាត អង្គុត្តរនិកាយ ដោយឈ្មោះថា រវសូត្រ, ព្រោះហេតុនោះ បឋមកយសូត្រនោះ អ្នកសិក្សាទាំងឡាយ គប្បីត្រួតមើល សូម្បីក្នុងទសកនិបាត អង្គុត្តរនិកាយនោះផង ។

(១៩៧) ចេតនា អ្នកបង្ក្ការទាំង ៥ យ៉ាង គឺបុគ្គលគប្បីកន្ទ្រាច ដោយប្រការដូច្នេះ ព្រោះហេតុនោះ បុគ្គលអ្នកកន្ទ្រាចគប្បីវៀរចាកពៀរទាំង ៥ យ៉ាងនោះឲ្យបាន ។ ព្រោះថា បុគ្គលកាលធ្វើយ៉ាងដូច្នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា " ឈ្មោះថា រមែងកន្ទ្រាច តែរបស់ដែលគួរកន្ទ្រាច " និង ថា " ឈ្មោះថា រមែងជាអ្នកមិនរង្ខ្ងងរង្ខ្ងាន់ " ។ ចំណែក បុគ្គលណា តែងកន្ទ្រាចតែរបស់ដែលមិនគួរកន្ទ្រាច, បុគ្គលនោះ ឈ្មោះថា ជាអ្នករង្ខ្ងងរង្ខ្ងាន់ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថា ព្រាហ្មណធម្មិកសូត្រ ក្នុងទុតិយវគ្គ នៃសុត្តនិបាតថា " បានញ្ញថា សត្វទាំងឡាយ ៤ ពួក គឺ សត្វជន្ទេនសត្វត្រជេវរិច សត្វក្រៀល ព្រាហ្មណ៍ រមែងកន្ទ្រាច នូវរបស់ដែលមិនគួរកន្ទ្រាច " ។

(១៩៨) បានញ្ញមកថា សត្វជន្ទេនទាំងឡាយ ជាសត្វមានប្រក្រតីស៊ីដី (តែ) មិនស៊ីដីច្រើន ព្រោះកន្ទ្រាចមហាប្រ៊ីជពី ទ្ធ៏ងអស់ទៅ ។ ពួកសត្វ ត្រជេវរិចទាំងឡាយ រមែងដេកផ្ទ្ការ លើស៊ុត

១០ និងវិតិមជ្ឈបានសំយមកថា

ព្រោះភ័យខ្លាចក្រែងអាកាស មេឃ រលំសង្កត់លើ ។ ពួកសត្វក្រៀល រមែងមិនយកជើងទាំង ២ ជាន់លើផែនដី ដោយស្រួលទេ ព្រោះភ័យខ្លាចក្រែផែនដីកម្រើករញ្ជួយ ។ ពួកព្រាហ្មណ៍ ទាំងឡាយ រមែងស្វែងរកនូវកិរិយា ព្រោះភ័យខ្លាចនូវការបាត់បង់វង្សត្រកូល ។ ក្នុងរឿងនៃសត្វ ដែលភ័យខ្លាច ក្នុងហេតុដែលមិនគួរភ័យខ្លាចនេះ បូរាណាចារ្យទាំងឡាយ ពោលថា ៖

“ ជនទាំងឡាយ (សត្វ) ដែលវង្វេងវង្វាន់ ៤ ពួកនេះ គឺសត្វជនេ្ជន ១ សត្វត្រដេរវិប ១ សត្វក្រៀល ១ ព្រាហ្មណ៍អ្នកប្រកាន់ខ្ជាប់នឹងទំនៀម ១ រមែងភ័យខ្លាច នូវរឿងដែលមិនគួរភ័យខ្លាច ” ។

(១៩៩) ព្រោះហេតុនោះ បុគ្គលមិនត្រូវជាអ្នកវង្វេងវង្វាន់ គប្បីលះបង់នូវពៀរហើយ សមាទានចេតនា ជាហេតុបណ្តេញនូវពៀរ ។ ព្រោះថា បុគ្គលកាលធ្វើយ៉ាងដូច្នេះ ឈ្មោះថាជាអ្នកមានសីល ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងធម៌ដល់អនាថបិណ្ឌិកៈ ទើបទ្រង់ត្រាស់ ក្នុងវេរសូត្រ ក្នុងឧបាសក-វគ្គ ក្នុងចតុត្ថបណ្ណាសកៈ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ថា ៖

“ នរៈណា សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យក នូវទ្រព្យដែលគេមិនបានឱ្យ ក្នុងលោកផង ក្បត់នឹង

មន្តលត្ថនីបនីប្រែ

ប្រពន្ធជនដទៃផង, ម្ជយទៀត នរៈណា ប្រកបរឿយៗ នូវ
ការផឹកសុរា និង មេរ័យ, នរៈ អ្នកមិនលះបង់ពៀរទាំង ៤
យ៉ាងនោះ បណ្ឌិតហៅថា ជាអ្នកទ្រុស្ពសីល ជាអ្នកអ័ប្ប
ឥតបញ្ហា លុះបែកធ្លាយរាងកាយទៅ រមែងទៅកើត ក្នុង
នរក ។ នរៈណា មិនសម្លាប់សត្វ មិននិយាយពាក្យកុហក
មិនកាន់យកទ្រព្យដែលគេមិនបានឱ្យ ក្នុងលោក មិនក្បត់
នឹងប្រពន្ធនៃជនដទៃ និង មិនប្រកបរឿយៗ នូវការផឹក
សុរានិងមេរ័យ នរៈនោះ លះបង់ពៀរទាំង ៤ យ៉ាងបាន
ហើយ បណ្ឌិតហៅថា ជាអ្នកមានសីល ជាអ្នកប្រកប
ដោយបញ្ញា លុះបែកធ្លាយរាងកាយតទៅ រមែងទៅកើត
ក្នុងសុគតិ (១) " ។

*(២០០) បណ្តាគាថាទាំងនោះ កន្ទះគាថា ខាងដើម មក
ហើយ ក្នុងមលវគ្គ នៃធម្មបទ ក៏មាន ។*

*នយ ក្នុងអដ្ឋកថាធម្មបទ ថា " បទថា **បាណំ** បានដល់
ឥន្ទ្រីយ៍ គឺជីវិត របស់សត្វដទៃ ។ បទថា **អតិមាបេតិ** គឺ រមែង
ចូលទៅកាត់ផ្តាច់ ។ បទថា **មុសាវាទំ** គឺ នូវពាក្យមុសា ដែល
បំផ្ទាញ នូវប្រយោជន៍ របស់ជនដទៃ ។ បទថា **លោកេ** បានដល់*

១- សុត្តន្តបិដក ភាគទី ៤៥ ទំព័រទី ១៥៥ ។

ឧបវិរតិមជ្ជបានសំយមកថា

ក្នុងសត្វលោក ។ ២ បទថា **អទិន្នំ អាទិយតិ** មានសេចក្តីថា រមែងកាន់យក គឺ រមែងលួចយករបស់ដែលអ្នកដទៃ មិនបានឲ្យ ហើយដោយកាយ និងវាចា គឺដែលអ្នកដទៃហួងហែងរក្សាហើយ ។ បទថា **បរទារំ** បានដល់ នូវទារ: គឺ ភរិយារបស់បុរសដទៃ ។ បទថា **គច្ឆតិ** បានដល់ រមែងចូលទៅគប់រក ដោយអំណាចការ ប្រព្រឹត្តិកន្ធង ។ អធិប្បាយថា រមែងខុស ក្នុងភណ្ឌ: ដែលជា ទារ: របស់បុរសដទៃ គឺ ក្នុងភណ្ឌ: ដែលអ្នកដទៃ រក្សាគ្រប់គ្រង ហើយ ។ បទថា **សុរាមេរយបានំ** បានដល់ ការផឹកសុរា និង មេរ័យ ។ បទថា **អនុយុញ្ជតិ** បានដល់ រមែងសេព គឺ រមែងធ្វើ ឲ្យច្រើន " ។

(២០១) ព្រោះហេតុដែលព្រះអដ្ឋកថាទាំងឡាយ ពោល ទុកហើយ ក្នុងពួកនៃធាតុ មាន **ចុរ** ធាតុជាដើមថា " **មាប** ធាតុ ប្រព្រឹត្តទៅ ក្នុងការកសាង ដូចជាខទាហរណ៍ ថា **បណ្ណសាលំ មាបេតិ** បុគ្គល រមែងកសាង នូវបណ្ណសាលា ដូច្នេះខ្ញុះ, ថា **យោ បាណមតិ មាបេតិ** នរជនណា រមែងបំផ្ទាញសត្វមានជីវិត ដូច្នេះខ្ញុះ ។ ព្រោះហេតុនោះ បាឬ:ថា "**មាបេតិ**" ដូច្នេះឯង ទើប សមគួរជាង ។

ចំណែក បុគ្គល ណា មិនភ័យខ្ជាច អំពីពៀរ រមែងធ្វើនូវ

ពៀរនោះជារៀយៗ, បុគ្គលនោះ រមែងបានជួបប្រទះនូវទុក្ខ មានទុក្ខ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន ជាដើម ។

ក្នុងការទទួលទុក្ខនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ។

(រឿង នាយគោឃាតក៏)

(២០២) បានឮមកថា ក្នុងក្រុងសាវត្ថី អ្នកសម្លាប់គោម្នាក់ ឈ្មោះនន្ទ: ធ្វើកម្មរបស់អ្នកសម្លាប់គោ ចិញ្ចឹមជីវិត ដោយការលក់សាច់ អស់រយៈពេល ៥៥ ឆ្នាំ ក្នុងមួយថ្ងៃ មិនដែលប្រគេនយាគូ ឬ ភត្ត សូម្បីត្រឹមតែមួយវែក ដល់ព្រះពុទ្ធ ឬ ព្រះសាវ័ក សោះ ។ ក៏នាយគោឃាតក៏នោះ ជ្រាសចាកសាច់ហើយ ក៏មិនបរិភោគអាហារដែរ ។ ព្រោះហេតុនោះ ក្នុងថ្ងៃមួយ គាត់លក់សាច់ដទៃទៀត ក្នុងពេលថ្ងៃ ហើយក៏បានឲ្យដុំសាច់មួយដុំ ដល់ភរិយា ដោយបានជ្រាប់ថា " ចូរនាងចំអិនសាច់មួយដុំនេះ ដើម្បីប្រយោជន៍ដល់បង " ដូច្នេះហើយ ក៏បានដើរទៅ ដើម្បីងូតទឹក ។ ក្នុងគ្រានោះ សំឡាញ់ម្នាក់ របស់នាយគោឃាតក៏នោះ បានមកកាន់ផ្ទះ របស់គាត់ហើយ និយាយថា "ចូរនាងឲ្យសាច់បន្តិច ដល់ខ្ញុំចុះ, ភ្ញៀវបានមកដល់ផ្ទះរបស់ខ្ញុំ " ដូច្នេះ, កាលបើភរិយា របស់នាយនន្ទ:នោះ ពោលថា "សាច់ដទៃ ដែលគប្បីលក់ មិនមានទេ, ក៏សាច់មួយដុំនេះ ជាសាច់ដែលសំឡាញ់ របស់អ្នកគប្បីបរិភោគ "

១០ និតិមជ្ឈានសំយមកថា

ដូច្នេះ, ទើបពោល ថា " ចូរនាងឲ្យសាច់នោះ ដល់ខ្ញុំចុះ " ដូច្នេះ, កាលបើកវិយានាយនន្ទ:នោះ មិនឲ្យក៏ដោយ, ក៏បានចាប់យកជុំសាច់នោះ ដោយពលការហើយ ក៏ចៀសចេញទៅ ។ នាយគោ-ឃាតក៏ មកវិញ ស្តាប់ទូវសេចក្តីនោះហើយ ក៏ចាប់ពាំបិត លូតដៃចូលទៅ ក្នុងមាត់គោមួយ ដែលឈរនៅខាងក្រោយផ្ទះ ហើយ ក៏ទាញយកអណ្តាត ចេញមកក្រៅហើយ កាត់យកទៅអាំង លើរងើកភ្លើង ប្រាវឲ្យដើម្បីនឹងបរិភោគ ។ ក្នុងខណ:គ្រាន់តែ នាយ-ន្ទ:នោះ បរិភោគជុំកត្តមួយជុំ ហើយជាក់ជុំសាច់មួយជុំ ក្នុងមាត់ ន៏ុ:ឯង អណ្តាតក៏ដាច់ធ្លាក់ទៅ ក្នុងថាសនៃកត្តហើយ ។ នាយនន្ទ:-នោះ បានទូវវិបាកដែលឃើញសមនឹងកម្ម (ដែលខ្លួនបានធ្វើ) ក្នុង-ខណ:នោះឯង ដោយប្រការដូច្នេះ ។ ក៏គោនោះឯង មានលោហិត-ហូរចេញ អំពីមាត់ហើយ ក៏ស្លាប់ ក្នុងទីនោះតែម្តង ។ ឯនាយ-គោឃាតក៏នោះសោត ដើរ ស្រែកវេទ៍ ត្រង់កណ្តាលផ្ទះ ដូចជាគោ-ធ្វើកាល:ហើយ បានទៅកើត ក្នុងអវិចីនរក ។

រឿង នាយគោឃាតក៏ ឈ្លោះនន្ទ: មកក្នុងមលវគ្គ នៃធម្មបទ ។

សូម្បីរឿងនាយចុន្ទសូករិក ក្នុងយមកវគ្គ នៃធម្មបទនោះ ដូចគ្នា បណ្ឌិត ក៏គប្បីប្រមូលមក (ពណ៌នាផងដែរ) ។

(២០៣) ក្នុងអតីតកាល ក្នុងក្រុងពារាណសី ព្រាហ្មណ៍ជា

មង្គលត្ថទីបនីប្រែ

(រឿង មតកភត្តជាតក)

អាចារ្យទិសាបាមោក្ខ សម្ងាប់សត្វពពែមួយហើយ បានថ្វាយនូវ មតកភត្ត ។ ព្រោះកម្មនោះ ព្រាហ្មណ៍នោះ ត្រូវកាត់ក្បាល ៤៩៩ អត្តភាព ក្នុងអត្តភាពជាគម្រប់ ៥០០ ក៏បានកើតជាពពែ របស់ ព្រាហ្មណ៍ប្រាកដដូច្នោះឯង ។ ឯព្រាហ្មណ៍នោះ ក៏ប្រាថ្នាដើម្បីនឹង ធ្វើមតកភត្ត ទើបប្រារព្ធដើម្បីសម្ងាប់ពពែនោះ ។ ពពែ រលឹកនូវ កម្ម ដែលខ្លួនបានធ្វើហើយ ដោយញាណគ្រឿងរលឹកជាតិ សើច ហើយ ក៏ស្រែកយំ វិញទៀត ត្រូវព្រាហ្មណ៍សួរហើយ បាន ប្រាប់កម្មដែលខ្លួនបានធ្វើហើយ ពោលថា " ខ្ញុំ មានចិត្តត្រេកអរ ហើយ ថា ក្នុងថ្ងៃនេះ អាត្មាអញ នឹងរួចចាកទុក្ខ ប្រាកដដូច្នេះ យ៉ាងដូច្នេះ ទើបបានសើច, ខ្ញុំបែរមកស្រែកយំវិញ ព្រោះសេចក្តី អាណិតចំពោះលោក ថា សូម្បីព្រាហ្មណ៍នេះ សម្ងាប់អញហើយ ក៏នឹងបានកាត់ក្បាល អស់ ៥០០ ជាតិ ដូចអាត្មាអញដែរ យ៉ាង ដូច្នេះ " ។ ព្រាហ្មណ៍ ពោលថា " នែពពែ ចូរអ្នកកុំកំយល់ឡើយ, ខ្ញុំនឹងមិនសម្ងាប់អ្នកទេ " ដូច្នេះ, កាលបើពពែ ពោលថា " កាល បើលោកសម្ងាប់ខ្ញុំ ក្តី មិនសម្ងាប់ខ្ញុំ ក្តី, ខ្ញុំ ក៏មិនអាច ដើម្បីនឹងរួច ផុត អំពីសេចក្តីស្លាប់ ក្នុងថ្ងៃនេះ បានឡើយ " ដូច្នេះ, ទើបបាន លែងពពែនោះ ទៅហើយ គិតថា " អាត្មាអញ នឹងមិនឲ្យអ្នកណា

១០ និងវិតិមជ្ឈបានសំយមកថា

មួយ សម្ងាប់ពពែនេះ បានឡើយ " ដូច្នេះហើយ ក៏បាននាំពពួកអន្តេវាសិក ដើរទៅជាមួយពពែនោះឯង ។ ចំណែក ពពែគ្រាន់តែ ព្រាហ្មណ៍ លែងទៅហើយប៉ុណ្ណោះ ក៏ងើយ-ក១ឡើង ត្រង់គុម្ពឈើ ដែលកើត អាស្រ័យផ្ទាំងថ្មជាមួយដុំ ប្រាថ្នាដើម្បីនឹងស៊ីស្លឹកឈើ ក្នុងខណៈនោះឯង រន្ទះ ក៏បានធ្លាក់ (ចាញ់) ហើយ លើផ្ទាំងថ្មជានោះ ។ បំណែកថ្មមួយដុំ បានបែកទៅកាត់-ក ដែលពពែបានលាតចេញហើយ ។ ពពែនោះ បានធ្វើកាលៈហើយ ក្នុងទីនោះឯង ។

រឿងព្រាហ្មណ៍អ្នកសម្ងាប់ពពែ មកក្នុងអដ្ឋកថា មតកកត្ត ជាតក ក្នុងទុតិយវគ្គ នៃឯកនិបាត ។

ពណ៌នារឿង ក្នុងបាណាតិបាត ចប់ ។

(សីលវិមំសជាតក)

(២០៤) ក្នុងទីក្រុងសាវត្ថី ព្រាហ្មណ៍ម្នាក់ ឈ្មោះថា សីលវិមំសកៈ ជាអ្នកដល់នូវសរណៈ ៣ មានសីល ៥ មិនធ្លុះធ្លាយ អាស្រ័យព្រះរាជា ព្រះនាមកោសល ចិញ្ចឹមជីវិត ។ ព្រះរាជា ទ្រង់ធ្វើការរាប់អាន ដល់ព្រាហ្មណ៍នោះ ព្រមទាំងព្រាហ្មណ៍ឯទៀត ដោយព្រះតម្រិះ ថា " ព្រាហ្មណ៍នេះ ជាអ្នកមានសីល " ។ ក្នុងថ្ងៃមួយ ព្រាហ្មណ៍នោះ គិតថា "ព្រះរាជា ទ្រង់អាស្រ័យការដល់ព្រម ដោយជាតិ គោត្រ ត្រកូល ប្រទេស និង សិល្បៈ របស់

មន្ថលត្ថទីបនីប្រែ

អាត្មាអញហើយ ទើបទ្រង់ធ្វើសេចក្តីរាប់អាន ឬក៏ ទ្រង់អាស្រ័យនូវការដល់ព្រម ដោយសីល (របស់អាត្មាអញ) ទើបទ្រង់ធ្វើ ឬហ្នឹ?, អាត្មាអញ នឹងសាកល្បងមើល " ដូច្នេះហើយ ក៏ទៅកាន់ទីឧបដ្ឋាន នៃព្រះរាជា កាលនឹង (ត្រឡប់) ទៅផ្ទះ មិនបានលាសោះ ឡើយ បានយកទ្រព្យមួយកហាបណៈអំពីបន្ទះក្តារ របស់ហិរញ្ញិកម្នាក់ទៅហើយ ។ ហិរញ្ញិក មិននិយាយពាក្យអ្វីៗ ឡើយ អង្គុយ (នៅស្ងៀម) ព្រោះសេចក្តីគោរព ចំពោះព្រាហ្មណ៍ ។ ក្នុងថ្ងៃទី ២ ព្រាហ្មណ៍នោះ បានយកទ្រព្យ ២ កហាបណៈ ។ ហិរញ្ញិក ក៏បានអត់ទ្រាំយ៉ាងដូច្នោះដែរ ។ ក្នុងថ្ងៃទី ៣ ព្រាហ្មណ៍នោះ ក៏បានយកកហាបណៈ មួយក្តាប់ដែ ។ ហិរញ្ញិក ក្រោធខឹងហើយ ស្រែកប្រាប់ ៣ ដង ថា " ខ្ញុំ ចាប់ចោរ ដែលប្ងន់ទ្រព្យបានហើយ " ។ មនុស្សទាំងឡាយបាននាំគ្នាមក អំពីទីនុ៉ះផង ទីនេះផង ពោលថា "ឥឡូវនេះ អ្នកធ្វើដូចជាអ្នកមានសីល ត្រាច់ទៅហើយ អស់កាលដ៏យូរ" ដូច្នេះហើយ ក៏ឲ្យការប្រហារ ២-៣ ដង ចងហើយ បានសម្តែង ដល់ព្រះរាជាហើយ ។ ព្រះរាជា ទ្រង់មានព្រះវិប្បដិសារី ទ្រង់មានព្រះរាជឧង្ការ ថា " នែព្រាហ្មណ៍ ព្រោះហេតុអ្វី ទើបអ្នកធ្វើកម្មនៃបុគ្គលអ្នកទ្រុស្តសីល យ៉ាងដូច្នេះ? " ហើយ ទ្រង់ត្រាស់បញ្ជាថា " អ្នកទាំងឡាយចូរទៅ, ចូរធ្វើរាជអាជ្ញា ដល់ព្រាហ្មណ៍

១០០ និងវិតិមជ្ឈបានសំយមកថា

នោះចុះ ” ។ ព្រាហ្មណ៍ បានក្រាបទូលថា “ បពិត្រព្រះមហារាជ ទូលព្រះបង្គំ មិនមែនជាចោរទេ, តាមពិត ទូលព្រះបង្គំ បានធ្វើ ហើយ យ៉ាងនេះ ព្រោះហេតុនេះ ” ដូច្នេះហើយ បានក្រាបទូលថា “ ឥឡូវនេះ ទូលព្រះបង្គំ បានដឹងហើយ ដោយច្បាស់លាស់ថា ព្រះអង្គ ទ្រង់អាស្រ័យសីលប៉ុណ្ណោះ ទើបទ្រង់ធ្វើសេចក្តីរាប់អាន ដល់ទូលព្រះបង្គំ, ពុំមែនអាស្រ័យជាតិជាដើមធ្វើទ្បើយ ហើយ ក្រាបទូលថា “ពិតមែនដូច្នោះ ឥឡូវនេះ ព្រះអង្គទ្រង់ត្រាស់បញ្ជា ឲ្យធ្វើព្រះរាជអាជ្ញា ដល់ទូលព្រះបង្គំ, ដោយហេតុនេះ ទូលព្រះ បង្គំនោះ ទើបដល់ការសន្និដ្ឋាន ថា ក្នុងលោកនេះ សីលប៉ុណ្ណោះ ប្រសើរបំផុត, សីល ជាប្រធាន ដូច្នេះ, មួយទៀត ទូលព្រះបង្គំ កាលធ្វើនូវកម្ម ដែលសមគួរ ដល់សីលនេះ ស្ថិតនៅ ក្នុងផ្ទះ បរិភោគ នូវកិលេសទាំងឡាយ នឹងមិនអាចដើម្បីធ្វើបានទ្បើយ ” ដូច្នេះហើយ ក្រាបទូលសុំព្រះរាជានុញ្ញាត ថា “ក្នុងថ្ងៃនេះឯង ទូល ព្រះបង្គំ នឹងបួស ក្នុងសំណាក់ នៃព្រះសាស្តា, បពិត្រព្រះសម្មតិ-ទេព សូមព្រះអង្គទ្រង់ព្រះរាជទាន នូវបព្វជ្ជា ដល់ទូលព្រះបង្គំផង” ដូច្នេះហើយ ក៏បានទៅកាន់វត្តជេតពន សូមបព្វជ្ជានឹងព្រះសាស្តា បានហើយនូវបព្វជ្ជា និង ឧបសម្ប៉ទ មិនលះបង់កម្មដ្ឋាន ហើយ ចម្រើនវិបស្សនា បានសម្រេចព្រះអរហត្តហើយ ។ ក៏ការវាយ

មន្តលត្ថនីបនីប្រែ

ហើយចង នូវព្រាហ្មណ៍នោះ ឯណា, ការវាយ ហើយចងនោះ បណ្ឌិត គប្បីយើញ ថា " ជាផលនៃអទិន្នាទាន " ។

រឿងព្រាហ្មណ៍ មកហើយ ក្នុងអដ្ឋកថា សីលវិមំសជាតក ក្នុងនវមវគ្គ នៃឯកនិបាត ។

សូម្បីរឿងដែលកន្ងងទៅហើយ ក្នុងនវមវគ្គ នៃឯកនិបាត នោះ ជូចគ្នា បណ្ឌិត ក៏គប្បីប្រមូលមក (ពណ៌នាផងដែរ) ។

(រឿង តាបសកុហក)

(២០៥) ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានតាបសកុហក ១ រូប ចូលទៅអាស្រ័យស្រុកមួយ នៅក្នុងបណ្ណសាលាដែលកុដុម្ពីក៍ម្នាក់សាងប្រគេន ក្នុងព្រៃ តែងធាន់ជាប្រចាំ ក្នុងផ្ទះរបស់កុដុម្ពីក៍នោះ ។ កុដុម្ពីក៍ ជឿថា " តាបសនេះ ជាអ្នកមានសីល " ព្រោះខ្លាចចោរ ទើបនាំយកមាស ១០០ និក្ខៈ ទៅកាន់បណ្ណសាលានៃតាបសនោះ បានកប់ទុក ក្នុងផែនដីហើយ ពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ ជួយមើលទ្រព្យនេះផង " ។ តាបស តបថា "នែអាវុសោ ធម្មតាពួកបព្វជិតធ្វើយ៉ាងនេះ រមែងមិនសមគួរ, ឈ្មោះថា ការចង់បាន ក្នុងទ្រព្យរបស់អ្នកដទៃ រមែងមិនមានដល់ពួកអាត្មាទ្បើយ" ។ កុដុម្ពីក៍នោះ ពោលថា "ប្រពៃណាស់" ហើយក៏គេចចេញទៅ ។ តាបសកុហក

១០០ និងវិតិមជ្ឈបានសំយមកថា

បានគិតថា "អាត្មាអញអាចចិញ្ចឹមជីវិត ដោយមាសមានប្រមាណ ប៉ុណ្ណុះបាន" ដូច្នេះ បានញ៉ាំងពេលវេលាឲ្យកន្ទងទៅបាន ២-៣ ថ្ងៃ ហើយ ទើបលួចយកមាសនោះ ទៅលាក់ទុកនៅ ក្នុងទីកន្លែង មួយ ក្នុងចន្លោះផ្ទះ មកហើយ ក្នុងថ្ងៃស្អែកឡើង ធ្វើកត្តកិច្ច ក្នុង ផ្ទះ របស់កុដុម្ពីក៍នោះ ហើយពោល ថា " ម្នាលអ្នកដ៏មានអាយុ អាត្មាភាពអាស្រ័យពួកអ្នក នៅយូរណាស់ហើយ, ក៏កាលបើពួក បព្វជិតទាំងឡាយនៅ ក្នុងទីកន្លែងមួយ យូរហួសពេក, ការជាប់ ជំពាក់ជាមួយពួកមនុស្ស រមែងមាន, ក៏ធម្មតា ការជាប់ពាក់ ជា មន្ទិល របស់បណ្ឌិតទាំងឡាយ, ព្រោះហេតុនោះ អាត្មាភាព នឹង ទៅ " ដូច្នេះ សូម្បីត្រូវកុដុម្ពីក៍នោះ សុំអង្វរហើយ អង្វរទៀត ក៏ មិននៅ ទៅបានបន្ទិចហើយ គិតថា "ការដែលអាត្មាអញបញ្ឆោត កុដុម្ពីក៍នេះទើបគួរ " ហើយ ជាក់ស្តៅត្រង់ចន្លោះនៃជដា ត្រឡប់ មកវិញ ។ កុដុម្ពីក៍សួរថា "បពិត្រលោកម្ចាស់ ព្រោះហេតុអ្វីបាន ជាម្ចាស់ ត្រឡប់មកវិញ? " ។ តាបស តបថា " ម្នាលអាវុសោ ស្តៅមួយសរសៃ (ជ្រុះ) អំពីជំបូលផ្ទះ របស់អ្នក ជាប់នៅ ក្នុងជដា របស់អាត្មាភាព, អាត្មាភាព ជាអ្នកមកហើយ ដោយគិតថា ឈ្មោះ ថា អទិន្នាទាន រមែងមិនសមគួរ ដល់បព្វជិតទាំងឡាយ ដូច្នេះ " ។ កុដុម្ពីក៍ពោលថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់ ចាល (វា)

មន្តលត្ថនីបនីប្រែ

ហើយនិមន្តទៅចុះ " ហើយ ក៏បានជ្រះថ្លា ថា " ព្រះគុណម្ចាស់ របស់អញ មិនកាន់យក នូវរបស់នៃជនដទៃ សូម្បីសរសៃនៃស្មៅ, ឧ! ព្រះគុណម្ចាស់ របស់អញជាអ្នករង្កៀសមែន " ដូច្នេះហើយ ក៏ថ្វាយបង្គំ បញ្ជូនទៅហើយ ។ គ្រានោះ ព្រះពោធិសត្ត ទៅកាន់ បច្ចន្តជនបទ ដើម្បីប្រយោជន៍ដល់ភណ្ឌ: ទិញរបស់បរិភោគ ក្នុងផ្ទះនោះ បានឫពាក្យ របស់តាបសហើយ ក៏គិតថា " វត្ថុ អ្វីមួយ របស់កុដុម្ពីក៍នេះ នឹងត្រូវបានតាបសអាក្រក់រូបនេះ លួចយក ហើយ ដោយពិត " ហើយ ក៏បានសួរកុដុម្ពីក៍ ស្តាប់សេចក្តីនោះ ហើយ ពោលថា " ម្នាលសំឡាញ់ បើដូច្នោះ ចូរអ្នកទៅ ឲ្យបាន ឆាប់ ចូរត្រួតមើលទ្រព្យដែលអ្នកបានកប់ទុកនោះ" ។ កុដុម្ពីក៍បាន ទៅកាន់បណ្ណសាលាហើយ មិនឃើញមាស ទើបប្រញាប់ត្រឡប់ មកវិញ ប្រាប់ ថា " ម្នាលសំឡាញ់ កំណប់នោះ មិនមានទេ " ។ ជនទាំង ២ នាក់នោះ បានទៅតាមតាបសនោះ យ៉ាងប្រញាប់ ចាប់ រាយ ទាត់នូវតាបសកុហក ដោយដៃ និង ជើង ឲ្យតាបសនោះ យកមាសមកឲ្យវិញហើយ ទទួលយកហើយ ។ ព្រះពោធិសត្ត ឃើញមាសហើយ ក៏តិះដៀលតាបសនោះ ថា " នែជដិលកោង អ្នកធ្វើសេចក្តីរង្កៀស ក្នុងសរសៃស្មៅ មួយសរសៃ ជាអ្នកបាន ជាប់ជំពាក់ហើយ ក្នុងវត្ថុត្រឹមតែស្មៅ ក៏ប៉ុន្តែ មាស (របស់គេ)

១០០ និក្ខ: នេះ អ្នកលួចយកទៅ មិនមានជាប់ជំពាក់សោះទ្បើយ" ដូច្នេះហើយ ទើបឲ្យ១ារ ១ា ១ា

ជាបវិរតិមជ្ឈបានសំយមកថា

១០០ និក្ខ: នេះ អ្នកលួចយកទៅ មិនមានជាប់ជំពាក់សោះទ្បើយ" ដូច្នេះហើយ ទើបឲ្យ១ារ ១ា ១ា "នែជដ្ឋិលកោង ចូរអ្នកកុំធ្វើកម្ម យ៉ាងដូច្នេះ តទៅទៀតទ្បើយ " ដូច្នេះហើយ លែងតាបសកុហក នោះហើយ ក៏ត្រឡប់ទៅ (ផ្ទះ១ួន) វិញ ហើយ ។

រឿងតាបសកុហក មក ក្នុងអដ្ឋកថា កុហកជាតក ក្នុង នវមវគ្គ នៃឯកនិបាតនោះ ដូចគ្នាដែរ ។

ពណ៌នាអំពីរឿង ក្នុងអទិន្នាទាន ចប់ ។

(ទោសក្នុងការប្រព្រឹត្តិខុសក្នុងកាម)

(២០៦) ក្នុងអតីតកាល ព្រះរាជ១ិរស ៤ ព្រះអង្គ ក្នុង ក្រុងសាវត្ថី ប្រព្រឹត្តខុស ក្នុងមាតុគ្រាម ដែលជនដទៃកា្ស១ាគ្រប់ គ្រងហើយ លេងសប្បាយតាមទំនើងចិត្ត ធ្វើបាបកម្មជាច្រើន ធ្វើ កាលៈហើយ ក៏បានទៅកើត ក្នុងលោហកុម្ភីនរក ទាំង ៤ ក្នុងទី ជិតនៃទីក្រុងសាវត្ថី ។ ព្រះរាជបុត្រទាំង ៤ អង្គនោះ នេះនៅ ក្នុង ទីកដែលប្រែផ្សា ពុះសម្ពូលទ្បើង ចេញមកទៅជាពពុះ (ជ្ជាក់ចុះ) ទៅបាតខាងក្រោម ប៉ះនឹងបាតឆ្នាំង ដោយកាលប្រមាណ ៣ ម៉ឺន ឆ្នាំ កាលទ្បើងមកខាងលើ ឃើញមាត់ឆ្នាំង ដោយកាលប្រមាណ ៣ ម៉ឺនឆ្នាំ ដូចគ្នាដែរ ហើយគិត ថា " ពេលណាទៅហ្ន៎ ពួកយើង នឹងបានរួច អំពីសេចក្ដីទុក្ខនេះ?" ដូច្នេះ សូម្បីប្រាជ្ញានឹងពោល

មង្គលត្ថទីបនីប្រែ

គាថា ៤ គាថា ឲ្យគ្រប់បរិបូណ៌ ក៏មិនអាចដើម្បីនឹងធ្វើ យ៉ាងដូច្នោះបានដែរ ទើបពោលបានតែម្នាក់ៗ អក្សរ ១ ១ ប៉ុណ្ណោះ ថា " ទុ. ស. ន. សោ. " យ៉ាងដូច្នេះហើយ ក៏បានលិចចុះទៅ ក្នុងលោហកុម្ភីនរក ជាថ្នមួងទៀត ។

*បណ្តាសត្វនរកទាំង ៤ នោះ សត្ត ដែលពោល **ទុ** អក្សរ ហើយលិចចុះទៅ (វិញ) ជាអ្នកប្រាថ្នាចង់ពោល យ៉ាងដូច្នេះ ថា ៖*

*(២០៧) " **ទុជ្ជីវិតមជីវិម្ហា យេសំ នោ ន ទទាម្ហសេ**
វិជ្ជមានេសុ ភោគេសុ ទីបំ នាកម្ម អត្តនោ " ។*

យើងទាំងឡាយណា, កាលភោគៈ ទាំងឡាយមាន, មិនបានឲ្យទាន មិនបានធ្វើ នូវទីពឹងបម្រុងខ្លួនសោះ (ហេតុនោះ) បានជាយើងទាំងឡាយនោះ រស់នៅ ដោយត្រជាបត្រដួស ។

*បណ្តាបទទាំងនោះ បទថា " **ទុជ្ជីវិតំ** " មានសេចក្តីថា សត្ត ទាំងឡាយ កាលប្រព្រឹត្តទុច្ចរិតទាំងបីយ៉ាង ឈ្មោះថា រមែងរស់នៅ ដោយត្រជាបត្រដួល គឺ រស់នៅ យ៉ាងអាក្រក់ ។ សត្វនរក នោះ សំដៅយកការរស់នៅ ដ៏អាក្រក់នោះឯង ទើបពោលយ៉ាងដូច្នេះ ។ ២ បទថា " **យេសំ នោ** " មានសេចក្តីថា យើងទាំងឡាយណា, កាលបើទេយ្យធម៌ និង កាលបើបដិគ្គាហកៈ មាននៅនុ៎ះឯង, រមែងមិនឲ្យទាន ។ ២ បទថា " **ទីបំ នាកម្ម** " ប្រែថា មិនធ្វើ*

ឧបនិរតិមជ្ជឧនសំយមកថា

ហើយ នូវទីពឹង ។

*សត្ត ដែលពោល **ស** អក្សរ ហើយលិចចុះទៅ (វិញ) ជា អ្នកប្រាថ្នាចង់ពោល យ៉ាងដូច្នេះ ថា ៖*

*(២០៨) “ **សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ***

***និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ** ” ។*

យើងទាំងឡាយដែលធេះនៅ ក្នុងនរក គ្រប់ជា ៦០,០០០ ឆ្នាំ ដោយអាការទាំងពួងហើយ, កាលណា នឹងមានទីបំផុត (ទុក្ខ) ។

*បណ្តាបទទាំងនោះ បទថា “ **សព្វសោ** ” ប្រែថា ដោយ អាការទាំងពួង ។ បទថា “ **បរិបុណ្ណានិ** ” គឺ មិនខ្វះមិនលើស ។ បទថា “ **បច្ចមានានំ** ” មានសេចក្តីថា កាលយើងទាំងឡាយ ធេះនៅ ក្នុងនរកនេះ ។*

*សត្ត ដែលពោល **ន** អក្សរ ហើយលិចចុះទៅ (វិញ) ជា អ្នកប្រាថ្នាចង់ពោល យ៉ាងដូច្នេះ ថា ៖*

*(២០៩) “ **នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ***

***តទា ហិ បកតំ ឧាបំ តុយ្ហំ មញ្ញញ្ញ មារិស** ” ។*

ម្នាលអ្នកស្មើនឹងខ្ញុំ ទីបំផុត (នៃទុក្ខរបស់យើង) មិនមានទេ, ទីបំផុត នឹងមានមកអំពីណា, ទីបំផុត នឹងមិនប្រាកដទេ, ព្រោះថា ខ្ញុំ និង អ្នក ឧានធ្វើឧាបហើយ ក្នុងកាលនោះ ។

មង្គលត្ថទីបនីប្រែ

*បណ្តាបទទាំងនោះ ២ បទថា " **នត្ថិ អន្តោ** " មានសេចក្តីថា ការកំណត់រវាល យ៉ាងនេះថា " ការរួចផុតនឹងមាន ដល់ពួកយើង ឈ្នះក្នុងកាលនោះ " ដូច្នេះ រមែងមិនមាន ។ ២ បទថា " **កុតោ អន្តោ** " មានសេចក្តីថា ទីបំផុត នឹងប្រាកដ ព្រោះហេតុអ្វី? ។ បទថា " **ន អន្តោ** " មានសេចក្តីថា ទីបំផុតនៃទុក្ខ នឹងមិនប្រាកដ ដល់ពួកយើងសូម្បីជាអ្នកប្រាថ្នាចង់ឃើញនូវទីបំផុត ។ បទថា " **តទា ហិ** " គឺ ក្នុងកាលនោះ ។ បាឋៈថា " **តថា ហិ** " ក៏មានខ្លះដែរ ។ អធិប្បាយថា " ទីបំផុតនៃទុក្ខនោះ ពួកយើង មិនអាចដើម្បីនឹងមើលឃើញបាន ដោយអាការណា, ពួកយើងបានធ្វើបាបទុកហើយ ដោយអាការនោះ" ។ បទថា " **បកតំ** " មានសេចក្តីថា បាប គឺកម្មដែលបណ្ឌិតស្អប់ខ្ពើម គឺទុំផង អ្នកផងបានធ្វើហើយ គឺ បានធ្វើ យ៉ាងច្រើន ក្រៃលែងតែម្តង ។ បទថា " **មារិស** " ប្រែថា ម្នាលអ្នកស្នេហ៍ទ្ធ ។ ពាក្យថា " **មារិស** " ន៏ុះ ជាពាក្យសម្រាប់ហៅបុគ្គលដែលជាទីស្រលាញ់ " ។*

*សត្ត្ว ដែលពោល **សោ** អ្ករ ហើយលិចចុះទៅ (វិញ) ជាអ្នកប្រាថ្នាចង់ចំពោល យ៉ាងដូច្នេះ ថា ៖*

*(២១០) **សោហំ ន្ទូន ឥតោ គន្ត្ថា យោនិ លទ្ធាន មានុសិ***
***ទ្ធេ ញ្ញ សីលសម្ប្ប ន្ទោ កាហាមិ កុសលំ ពហុំ** " ។*

១០០ និងវិតិមជ្ឈបានសំយមកថា

ខ្ញុំនោះ លុះទៅអំពីនេះ បានទូវកំណើតជាមនុស្សហើយ ជាអ្នកដឹងនូវពាក្យនៃស្នូម ជាអ្នកបរិបូណ៌ដោយសីល នឹងធ្វើនូវកុសល ឲ្យបានច្រើន ដោយពិត ។

សព្ទថា " **ទ្ទ** " ក្នុងគាថានោះ ជានិបាត ចុះក្នុងអត្ថថា ដោយចំណែកមួយ ។ អធិប្បាយថា " ខ្ញុំនោះ ទៅអំពីទីនេះ ហើយ បានហើយ ទូវកំណើតជាមនុស្ស ជាអ្នកដឹងនូវពាក្យ នៃ ស្នូម ជាអ្នកបរិបូណ៌ដោយសីល នឹងធ្វើនូវកុសល ឲ្យបានច្រើន ដោយចំណែកមួយប៉ុណ្ណោះ " ។

ក្នុងកាលនោះ ព្រះរាជាព្រះនាមកោសលទ្រង់ព្រះសណ្ដាប់ នូវសំឡេង របស់សត្វនរកទាំងនោះ ក្នុងចំណែកនៃរាត្រី ហើយ ទ្រង់មានព្រះទ័យភ័យខ្លាច ក្នុងថ្ងៃ ទី២ ទើបស្ដេចយាងទៅ កាន់ សំណាក់នៃព្រះសាស្ដាហើយ បានក្រាបទូល (រឿងនោះ) ។

ព្រះសាស្ដា លុះទ្រង់ធ្វើរឿងនោះ ឲ្យជាអតុប្ផត្ដិហេតុហើយ ទើបទ្រង់សម្ដែងលោហកុម្ភីជាតក ក្នុងទុតិយវគ្គ នៃចតុក្កនិបាត ។

រឿង ព្រះរាជឱរស ចប់ ។

សូម្បីរឿងព្រះនាងមល្លិកា ក្នុងជរាវគ្គ នៃធម្មបទ បណ្ឌិត ក៏គប្បីប្រមូលមក (សម្ដែងផងដែរ) ។

ពណ៌នាអំពីរឿង ក្នុងការប្រព្រឹត្ដិខុស ចប់ ។

មង្គលត្ថទីបនីប្រែ

(រឿង ទេវបុត្រ ៤ អង្គ)

(២១១) ក្នុងអតីតកាល បានមានមហោស្រពយ៉ាងធំ ក្នុងក្រុងពារាណសី ។ ពួកនាគ គ្រុឌ និង ពួកទេវតា ដែលនៅលើផែនដី ជាច្រើន បាននាំគ្នាមកមើល (មហោស្រព) ។ ក៏ទេវបុត្រទាំង ៤ អង្គ បានធ្វើផ្ការ៉ាត្រឡាច ដ៏ជាទិព្ធ ឲ្យជាឆ្នូត ពួដ៏សិរីសៅ ហើយមកអំពីកពតាវត្តិង្ស ដើម្បីមើលមហោស្រព បានឈរនៅ ហើយ ពួដ៏អាកាស លើព្រះលានៃព្រះរាជា ដោយកាយដែលប្រាកដ ។ ក្ងិនផ្ការ ដ៏ជាទិព្ធ បានក្រអូប គ្របទៅពេញព្រះនគរ ពារាណសី ដែលមានទំហំប្រមាណ ១២ យោជន៍ ។ មនុស្សទាំងឡាយ ក្រឡេកមើលឃើញទេវបុត្រទាំងនោះហើយ ទើបបានសូមបុជ្ជាទិព្ធ និងពួកទេវបុត្រទាំងនោះ ។ ទេវបុត្រទាំងនោះ កាលនឹងសម្តែងថា " បុជ្ជាទាំងនេះ មិនសមគួរ ដល់បុគ្គលអ្នកទ្រុស្តសីលទាំងឡាយទេ, តែជនទាំងឡាយណា ប្រកបហើយ ដោយគុណទាំងឡាយនេះ, បុជ្ជាទាំងឡាយនុ៎ះ សមគួរ ដល់ជនទាំងឡាយនោះ " ដូច្នេះ បានពោលគាថាទាំងឡាយ ៤ ដោយលំដាប់ ។ ក៏បណ្តាទេវបុត្រទាំង ៤ អង្គនោះ ទេវបុត្រ ដែលជាធំ ពោលហើយ យ៉ាងនេះ ថា ៖

(២១២) " បុគ្គលណា មិនលួច (ទ្រព្យគេ) ដោយកាយ

ឧបនិរតិមជ្ជបានសំយមកថា

មិនតិយាយកុហក ដោយវាចា បានយសសក្តិហើយ មិនគប្បីស្រវឹង, បុគ្គលនោះឯង គ្លរប្រដាប់ផ្ការត្រឡាច ជាទិព្ធទាំងឡាយ [(1)] " ។

*បណ្តាបទទាំងនោះ បទថា "**នាវហរេ**" មានសេចក្តីថា រមែងមិនលួច សូម្បីនូវសរសៃនៃស្មៅ ដែលជារបស់នៃជនដទៃ ។ បទថា "**មុសា**" ជាដើម មានសេចក្តីថា មួយទៀត សូម្បីលះបង់ជីវិត ក៏មិនពោលពាក្យមុសា ដោយវាចា ។ មែនពិត ពាក្យថា "**មុសា**" ន៉ុះ ជាកំពូលនៃទេសនាតែម្តង ។ ក្នុង ២ បាទគាថានោះ មានអធិប្បាយ យ៉ាងដូច្នេះថា "ក៏បុគ្គលឯណា មិនធ្វើនូវអកុសលកម្មបថ ១០ យ៉ាង ដោយកាយទ្វារ វចីទ្វារ និង មនោទ្វារ ៣ ។ បាទកាថា ថា " **យសោ លទ្ធា ន មជ្ជយ្យ** " មានសេចក្តីថា មួយទៀត បុគ្គលណា បានឥស្សរិយយសហើយ មិនគួរស្រវឹង ដោយសេចក្តីស្រវឹងនឹងឥស្សរិយយស ដល់នូវសេចក្តីប្រមាទ ។ បទថា "**សរេ**" ជាដើម មានសេចក្តីថា បុគ្គលអ្នកប្រកបហើយ ដោយគុណទាំងឡាយនេះនោះ រមែងសមគួរ ដើម្បីនឹងសុំ និង ដើម្បីនឹងប្រដាប់នូវផ្ការទិព្ធ ដែលឈ្មោះថាផ្ការត្រឡាច, អធិប្បាយថា " ខ្ញុំ នឹងឲ្យ ដល់បុគ្គលនោះ " ដូច្នេះ ។*

1- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ២១៣ ។

មង្គលត្ថទីបនីប្រែ

ចំណែក ទេវបុត្រអង្គ ទី ២ ពោលថា ៖

(២១៣) " បុគ្គលឯណា គប្បីស្វះស្វែងរកទ្រព្យជាគ្រឿងពេញចិត្ត ដោយធម៌ មិនគប្បីលួចយកនូវទ្រព្យគេ ដោយការបោកប្រាស បានទ្រព្យទាំងឡាយហើយ មិនគួរស្រវឹង, បុគ្គលនោះឯង ទើបគួរប្រដាប់ នូវផ្លាត្រឡាបបាន " ។

*បណ្តាបទទាំងនោះ បទថា " **ធម្មេន វិត្តំ** " មានសេចក្តីថា គប្បីស្វះស្វែង គឺគប្បីស្វែងរក នូវទ្រព្យគ្រឿងពេញចិត្ត មានមាសប្រាក់ជាដើម ដោយអាជីវៈដ៏បរិសុទ្ធ ។ បទថា " **និកត្យា** " ប្រែថា ដោយការបោកបញ្ឆោត ។ បទថា " **ភាគេ** " គឺ នូវទ្រព្យទាំងឡាយ មានសំពត់ និង គ្រឿងអាភរណៈ ជាដើម ។*

ចំណែក ទេវបុត្រអង្គ ទី ៣ ពោលថា ៖

(២១៤) " បុគ្គលណា មានចិត្តមិនធាប់ហើរ ដូចជារមៀត, មានសទ្ធាមិនរសាយ និង បុគ្គលណា មិនគប្បីបរិភោគ នូវវត្ថុមានរសជាតិឆ្ងាញ់តែម្នាក់ឯង, បុគ្គលនោះឯង ទើបគួរប្រដាប់ នូវផ្លាត្រឡាបបាន " ។

*បណ្តាបទទាំងនោះ បទថា " **អហាលិទ្ធំ** " មានសេចក្តីថា ចិត្ត របស់បុគ្គលណា មិនមែនជាធម្មជាតស្មើ ដោយរមៀត គឺ រមែងមិនហើរទៅ យ៉ាងធាប់រហ័ស ដូចជាទឹកជ្រលក់រមៀត បាន*

ធាបទិវតិមង្ងធានសំយមកថា

ដល់ ជាធម្មជាតស្ថិតស្ថេរគង់វង្សតែម្តង ។ បទថា “ ***អវិរាគិនី*** *” គឺ កំណាត់នូវកម្ម និង វិបាក ។ ម៉្យាងទៀត សទ្ធា របស់បុគ្គលណា គឺអ្នកជឿនូវពាក្យ រមែងមិនរសាយ គឺ មិនបែកធ្លាយ ព្រោះហេតុ មានប្រមាណ តិចតួចប៉ុណ្ណោះ ។ ២ បទថា “* ***ឯកោ សាទុំ*** *” មានសេចក្តីថា បុគ្គលណា មិនធ្វើនូវពួកយាចក ឬ បុគ្គលដទៃ ដែលជាអ្នកគួរដល់ការបែងចែក (ឲ្យទៅ) ខាងក្រៅហើយ រមែង បរិភោគនូវភោជន ដែលមានរសជាតិឆ្ងាញ់ តែម្នាក់ឯង គឺ ចែក រំលែកហើយ ទើបបរិភោគ ។*

ចំណែក ទេវបុត្រអង្គ ទី ៤ ពោលថា ៖

(២១៥) “ បុគ្គលណា មិនជេរប្រទេច នូវសប្បុរសទាំង ឡាយ ក្នុងទីចំពោះមុខ ឬ កំបាំងមុខ ជាអ្នកនិយាយ យ៉ាង ណា ធ្វើយ៉ាងនោះ, បុគ្គលនោះឯង ទើបគួរប្រដាប់ នូវផ្កា ត្រឡាបបាន ” ។

បណ្តាបទទាំងនោះ បទថា “ ***សន្តេ*** *” មានសេចក្តីថា បុគ្គលណា មិនជេរប្រទេច គឺ មិនជេរស្តី នូវបុរសទាំងឡាយ ជាអ្នកស្ងប់រម្ងាប់ហើយ គឺបុរសដែលជាបណ្ឌិត អ្នកប្រកបហើយ ដោយគុណមានសីលជាដើម ។ បទថា “****យថាវាទី****” មានសេចក្តី ថា រមែងពោល នូវរឿងណា ដោយវាចា, រមែងធ្វើរឿងនោះឯង*

មន្តលត្ថទីបនីប្រែ

ដោយកាយ ។

(២១៦) ក៏នៅក្នុងទីបញ្ចប់ នៃគាថា របស់ទេវបុត្រនោះ ៗ បុរោហិត គិតថា "បណ្តាគុណទាំងនេះ សូម្បីគុណតែមួយ ក៏មិនមាន ដល់អាត្មាអញទ្បើយ, អាត្មាអញ នឹងធ្វើការពោលមុសាវាទ សុំនូវគ្រឿងប្រដាប់ទាំងនេះ ហើយនាំយកមក ប្រដាប់តាក់តែង, ធ្វើយ៉ាងនេះ ជននឹងស្គាល់អាត្មាអញ ថា បុរោហិតនេះ ជាអ្នកបរិបូណ៌ហើយ ដោយគុណ ដូច្នេះ" ក៏បានធ្វើហើយ យ៉ាងដូច្នោះ ។ ទេវបុត្រទាំង ៤ អង្គនោះ បានឲ្យកម្រងផ្កាទាំងឡាយ ៤ ដល់បុរោហិតនោះឯង ហើយក៏ទៅកាន់ទេវលោក ។ ក្នុងពេលដែលទេវបុត្រទាំង ៤ អង្គនោះ ទៅហើយ, សេចក្តីវេទនា ដ៏ច្រើន បានកើតឡើងហើយ ព្ធដ៏ក្បាល របស់បុរោហិតនោះ ។ ក្បាល របស់បុរោហិតនោះ ប្រៀបដូចជាដែកស្រួចដោតហើយ និង ប្រៀបដូចជាយន្តដែកកិនកំទេចហើយ ។ បុរោហិតនោះ ទទួលវេទនាហើយ ស្រែកយំ ដោយសំឡេងដ៏ខ្ទាំងថា "ខ្ញុំ និយាយមុសាវាទ កាន់យកនូវកម្រងផ្កាទាំងឡាយនេះ មកប្រដាប់ហើយ, អ្នកទាំងឡាយ ចូរជួយយកកម្រងផ្កាទាំងនេះ ចេញអំពីក្បាល របស់ខ្ញុំផង " ។ ពួកមនុស្សទាំងឡាយ សូម្បីជួយគ្នា យកកម្រងផ្កាទាំងនោះចេញ ក៏មិនអាច ដើម្បីនឹងជួយយកចេញបានឡើយ ។ ផ្កាទាំងឡាយ បាន

១០០ និងវិតិមជ្ឈបានសំយមកថា

មានហើយ ដូចជាគេរុំព័ន្ធហើយ ដោយបន្ទះដែក ។ មនុស្សទាំងឡាយ បានលើក បីពបុរោហិតនោះ នាំទៅផ្ទះហើយ ។ បុរោហិតនោះ ស្រែកយំហើយ រហូត ៧ ថ្ងៃ ។ ដោយកាលកន្ទងទៅ ៧ ថ្ងៃ ព្រះរាជា ទ្រង់ព្រះតម្រិះ ថា " បុរោហិត អ្នកទ្រុស្តសីល កុំបីស្ងាប់ទ្បើយ" ហើយ ទ្រង់ត្រាស់បញ្ជា ឲ្យលេងមហោស្រពម្តងទៀត ។ ទេវបុត្រទាំង ៤ អង្គនោះ បានមកម្តងទៀតហើយ ។ ព្រះរាជា ទ្រង់ត្រាស់បញ្ជា ឲ្យនាំយកបុរោហិតមកហើយ ទ្រង់ញ្ជាំងទេវបុត្រទាំងនោះឲ្យអត់ទោស ដល់បុរោហិតនោះហើយ ។ ទេវបុត្រទាំងឡាយ បានតិះដៀលបុរោហិតនោះ ក្នុងកណ្ណាលជំនុំ នៃបរិស័ទ ថា " ផ្ការាទាំងឡាយនេះ មិនសមគួរ ដល់អ្នកជាបុគ្គលទ្រុស្តសីលទ្បើយ, អ្នកជាអ្នកមានសេចក្តីសម្គាល់ថា អាត្មាអញ ទីងបញ្ជោតទេវបុត្រទាំង ៤ អង្គនេះ ដូច្នេះ, ផល នៃមុសាវាទ របស់ខ្លួន គឺអ្នកបានហើយ " ដូច្នេះហើយ ទើបបាននាំយកនូវកម្រងចេញ អំពីក្បាល នៃបុរោហិតនោះ ស្រេចហើយ ក៏ទៅកាន់ទីហាន របស់ខ្លួនដូចដើមវិញ ។

រឿងព្រាហ្មណ៍ និយាយមុសាវាទ មក ក្នុងអដ្ឋកថាកក្ការ-ជាតក ក្នុងតតិយវគ្គ នៃចតុក្កនិបាត ។

(២១៧) ក្នុងអតីតកាល អាចេលម្នាក់ ឈ្មោះថា ការម្ជិយ:

-៣៣៩-

មន្តលត្តទីបនីប្រែ

(រឿង អចេល ឈ្មោះករម្ឃិយ:)

អាស្រ័យស្រុកឈ្មោះករម្ឃិយបដ្ពន: ឈប់នៅក្នុងទីជិតសមុទ្រ ។ ស្តេចនាគមួយ ឈ្មោះ បណ្ឌរ: ក្តី ស្តេចគ្រុឌ ក្តី រមែងមកកាន់ទីឧបដ្ឋាន របស់អចេលនោះ ។ ថ្ងៃមួយ បណ្តាសត្វទាំង ២ នោះ ស្តេចគ្រុឌ មកមុនហើយ ពោលថា "បពិត្រលោកដ៏ចម្រើន ពួកញាតិ របស់យើងខ្ញុំទាំងឡាយ កាលចាប់នូវពួកនាគ រមែងវិនាសទៅ ជាច្រើន, យើងខ្ញុំទាំងឡាយ តែងមិនដឹង នូវពិធីចាប់នាគទេ, បានញ្ចមកថា ហេតុនៃសេចក្តីស្វាត់កំបាំង របស់នាគទាំងនោះ មាន, សូមលោកម្ចាស់ សួរស្តេចនាគនោះ ហើយប្រាប់ ដល់ពួកខ្ញុំផង" ដូច្នេះហើយ ក៏ចៀសចេញទៅ ។ អចេលនោះ ទទួលថា " ប្រពៃណាស់ " ហើយសួរ នូវហេតុអាថិកំបាំងនោះ នឹងស្តេចនាគ ជារឿយៗ ។ ស្តេចនាគ មិនប្រាប់ រហូត ២ ថ្ងៃ ក្នុងថ្ងៃ ទី ៣, កាលបើអចេលនោះពោលថា "ខ្ញុំនឹងមិនប្រាប់ ដល់អ្នកណាឡើយ, ចូរអ្នកកុំមានការភ័យខ្លាច ប្រាប់មកចុះ " ដូច្នេះ, ទើបពោល ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់កុំប្រាប់ ដល់បុគ្គលដទៃឡើយ " ដូច្នេះ បានទទួលពាក្យប្តេជ្ញាហើយ ប្រាប់ ហេតុនៃសេចក្តីអាថិកំបាំង របស់ខ្លួន ដល់អចេលទ្រុស្តសីល ជាអ្នកចូលចិត្តពោលពាក្យមុសានោះ ថា " បពិត្រលោកម្ចាស់ ដ៏

១២ចវិរតិមជ្ជបានសំយមកថា

ចម្រើន យើងខ្ញុំទាំងឡាយ លេបនូវដុំថ្មធំ ១ ទាំងឡាយ ជាអ្នកធ្ងន់ ដេកហើយ ក្នុងពេលដែលពួកគ្រុឧមក បែរមុខ បើកធ្មេញហើយ ប្រាថ្នា ដើម្បីនឹងទាំ នូវគ្រុឧទាំងនោះ, ពួកគ្រុឧទាំងនោះ មកហើយ តែងចាប់ក្បាល របស់យើងខ្ញុំទាំងឡាយ, កាលបើគ្រុឧទាំងនោះ ព្យាយាម ដើម្បីនឹងលើក នូវពួកយើងខ្ញុំ ដែលមានភារៈដ៏ធ្ងន់ ដេកហើយនុ៎ះឯង, ទឹកក៏ឡើងមក (ទឹកជន់) ។ គ្រុឧទាំងឡាយនោះ ក៏លិចចុះទៅស្ងាប់ ឲ្ជដ៏ខាងក្នុងទឹកនុ៎ះឯង, គ្រុឧទាំងឡាយ ជាច្រើនរមែងវិនាសទៅ ព្រោះហេតុនេះ, កាលបើពួកគ្រុឧទាំងនោះ ចាប់នូវពួកយើងខ្ញុំ, ប្រយោជន៍អ្វី ដោយក្បាល ដែលពួកគ្រុឧទាំងនោះ ចាប់ហើយ, ពួកគ្រុឧទាំងឡាយ ចាប់ត្រង់កនុយ ហើយធ្វើពួកយើងខ្ញុំ ឲ្យមានក្បាលចុះក្រោម ឲ្យសម្រេកអាហារ ដែលពួកយើងខ្ញុំទទួលហើយ ធ្វើឲ្យពួកយើងស្រាលហើយ រមែងអាចដើម្បីនឹងទៅបាន" ដូច្នេះហើយ ទើបចៀសចេញទៅ ។ កាលបើស្ដេចនាគនោះ ចៀសចេញទៅហើយ, ស្ដេចគ្រុឧ ក៏មកហើយ ។ អ្នកបួសអាចល បានប្រាប់នូវហេតុទាំងអស់នោះ ដល់ស្ដេចគ្រុឧហើយ ។ ស្ដេចគ្រុឧ ស្ដាប់ពាក្យនោះហើយ ក៏ចាប់ស្ដេចនាគនោះ ត្រង់កនុយ ហើយបានធ្វើស្ដេចនាគ ឲ្យមានក្បាលចុះក្រោម ឲ្យសម្រេកអាហារ ដែលស្ដេចនាគទទួលហើយ ទើបបានហោះទៅកាន់អាកាស ក្នុង

មន្ថលត្ថទីបនីប្រែ

ថ្ងៃនោះឯង ។ ស្តេចនាគ ទម្លាក់ក្បាលចុះក្រោម ពោលថា "អាត្មាអញ មិនបានរក្សាសេចក្តីអាថិកំបាំង ហើយប្រាប់ ដល់បុគ្គលអ្នកទ្រុស្តសីល ទើបបាននាំសេចក្តីទុក្ខមក ដល់អាត្មាអញ " ហើយក៏បានស្រែកយំ ដោយប្រការផ្សេងៗ ។ ស្តេចគ្រុឌ បានតិះដៀលស្តេចនាគនោះ ថា " អ្នកប្រាប់រឿងអាថិកំបាំង របស់ខ្ជូន ដល់អ្នកបូសអចេល ឥឡូវនេះ តើស្រែកយំ ដើម្បីប្រយោជន៍អ្វី? " ដូច្នេះ, កាលស្តេចនាគនោះ សុំនូវជីវិត, ទើបបានឲ្យហើយនូវជីវិត ដល់ស្តេចនាគនោះ ។ សត្វទាំង ២ នោះ ជាអ្នកសាមគ្គីគ្នា សប្បាយរីករាយ ជាមិត្រមិនបែកបាក់គ្នា ចាប់ផ្តើមតាំងពីពេលនោះមក ។ ចំណែកស្តេចនាគ ក្រោធខឹងចំពោះអចេល បានទៅកាន់អាសមរបស់អចេលនោះហើយ ក៏តិះដៀលអចេលនោះ ដោយប្រការផ្សេងៗ កាលនឹងដាក់ផ្តាសា បានពោលគាថានេះ ក្នុងបណ្ឌរក-ជាតក ក្នុងតឹសនិបាត [1] ថា ៖

(២១៣) "ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្រ ដែលមិនបានប្រទូស្តវិញផង ជាអ្នកញុះញង់ផង, ដោយពាក្យសច្ចៈនេះ សូមឱ្យក្បាល របស់អ្នកឯង បែកជា ៣ ភាគ " ។

បណ្តាបទទាំងនោះ បទថា " **អទុដ្ឋស្ស** " មានសេចក្តីថា

១- សុត្តន្តបិដក ភាគទី ៦០ ទំព័រទី ២០៨ ។

១០០ និងវិតិមជ្ឈបានសំយមកថា

ម្នាលលោកដ៏ចម្រើន លោកជាអ្នកប្រទូស្តមិត្ត ។ ដោយពាក្យ សច្ចៈនេះ ថា " លោកជាអ្នកប្រទូស្តផង ជាអ្នកញុះញង់ផង " ។ កាលបើស្តេចនាគ មើលឃើញនុ៎ះឯង, ក្បាលរបស់អចេល បាន បែកហើយ ដោយ ៧ ភាគ ។ ផែនដី ក៏បានឲ្យប្រហោង ដល់ អចេលនោះ ក្នុងទីដែលគេអង្គុយហើយនុ៎ះឯង ។ អ្នកបួសអចេល នោះ ពោលមុសា ត្រូវផែនដីស្រូប ចូលទៅកាន់ផែនដីហើយ ក៏បានទៅកើត ក្នុងអវិចីនរក ដោយប្រការដូច្នេះឯង ។

រឿង អចេល ឈ្មោះ ករម្ប្យៃ: ចប់ ។

ពណ្ណនាអំពីរឿង ក្នុងមុសាវាទ ចប់ ។

(រឿង ព្រះរាជា សោយព្រះរាជបុត្រ)

(២១៩) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី ព្រះរាជា មួយព្រះអង្គ ប្រាសចាកទឹកស្រវ៉ាងហើយ ទ្រង់មិនអាច សូម្បី ដើម្បីទ្រង់ប្រព្រឹត្តព្រះរាជកិច្ច ដើម្បីនឹងទ្រង់សោយព្រះក្រយាហារ ដែលមិនមានសាច់បានឡើយ ។ ក្នុងព្រះនគរ ក្នុងថ្ងៃឧបោសថ ទាំងឡាយ មិនមានការសម្ងាប់សត្វទេ ។ បុគ្គល អ្នកធ្វើអាហារ (ចុងភៅ) ទិញសាច់ ក្នុងតិបី ទី ១៣ នៃបក្សនុ៎ះឯង ហើយបាន យកមកទុក ។ សាច់នោះ អ្នកធ្វើអាហារ ទុកមិនបានល្អឡើយ, ផ្ទៃទាំងឡាយ បានខាំស៊ីហើយ ។ បុគ្គល អ្នកធ្វើអាហារ មិនបាន

មន្តលត្ថនីបនីប្រែ

សាច់ ក្នុងថ្ងៃឧបោសថ មិនអាចដើម្បីនាំក្រយាហារ ចូលទៅថ្វាយ ដល់ព្រះរាជាបាន ទើបក្រាបទូលសេចក្តីនោះ ដល់ព្រះនាងទេវី ។ ព្រះនាង ទ្រង់មានព្រះតម្រាស់ថា " នែអ្នក ព្រះរាជបុត្រ របស់យើង ជាទីស្រលាញ់ ពេញព្រះរាជហឫទ័យ របស់ព្រះរាជា, ព្រះរាជា កាលទតព្រះនេត្រយើញព្រះរាជបុត្រនោះហើយ ទ្រង់ថើប បបោសអង្អែល នូវព្រះរាជបុត្រនោះឯង រមែងមិនទ្រង់ជ្រាបសូម្បីនូវព្រះក្រយាហារ របស់ព្រះអង្ត មានសាច់ ឬ មិនមានសាច់, ឱ្ងុំនឹងប្រដាប់ព្រះរាជបុត្រហើយ ឲ្យគង់នៅលើព្រះឧរុ (ភ្លៅ) របស់ព្រះរាជា, ក្នុងពេលដែលព្រះរាជាទ្រង់ក្រសាល (លេងប្រឡែង) ជាមួយនឹងព្រះរាជបុត្រ របស់ព្រះអង្គនោះ អ្នកគប្បីបង្អោនព្រះក្រយាហារ ចូលទៅថ្វាយ " ដូច្នេះហើយ ទ្រង់បានធ្វើ យ៉ាងដូច្នោះហើយ ។ ក្នុងកាលនោះ អ្នកធ្វើអាហារ បាននាំព្រះក្រយាហារ ចូលទៅហើយ ។ ព្រះរាជា ទ្រង់ស្រវឹងហើយ ព្រោះការស្រវឹងសុរា ទ្រង់ទតព្រះនេត្រមិនយើញសាច់ ក្នុងថាស ទើបទ្រង់ត្រាស់សួរថា "សាច់ នៅឯណា?" ។ បុគ្គលអ្នកធ្វើអាហារ ក្រាបទូលថា " បពិត្រព្រះសម្ងតិទេព ថ្ងៃនេះ គឺជាថ្ងៃឧបោសថ, ទូលព្រះបង្គំមិនបានសាច់ទ្បើយ" ។ ព្រះរាជា ទ្រង់ត្រាស់ថា "ឈ្មោះថាសាច់សម្រាប់អញ រកបាន ដោយក្រណាស់" ហើយមួលកព្រះរាជបុត្រ

១០០ និងវិតិមជ្ឈ១០០ សំយមកថា

ឲ្យដល់ការក្ស័យព្រះជន្មហើយ ទើបបោះទៅ ខាងមុខ នៃអ្នកធ្វើ អាហារ ហើយត្រាស់បញ្ជាថា "ចូរអ្នកចាត់ចែងហើយ នាំយកមក ដោយប្រញាប់ " ។ បុគ្គល អ្នកធ្វើអាហារនោះ បានធ្វើអាហារ នោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ សូម្បីបុគ្គលម្នាក់ ក៏មិនអាច ដើម្បីនឹងស្រែកយំ ឬ ក្រាបទូលបានឡើយ ព្រោះកំយ្ងាចចំពោះ ព្រះរាជា ។ ព្រះរាជា ទ្រង់សោយព្រះក្រយាស្ងោយ ដោយសាច់ របស់ព្រះឱរស ទ្រង់ព្រះបន្ទំហើយ ក្នុងវេលាទៀបភ្ញី ទ្រង់តើន ឡើង ស្ងាងពីស្រវឹងហើយ ទ្រង់ត្រាស់ ថា "ចូរអ្នកទាំងឡាយ នាំ យកព្រះរាជបុត្រ របស់ខ្ញុំមក" ។ ក្នុងខណៈនោះ ព្រះនាងទេវីទ្រង់ ព្រះកន្សែងក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ក្នុងថ្ងៃម្សិលមិញ ព្រះអង្គទ្រង់សម្ងាប់ព្រះរាជបុត្រហើយ ទ្រង់បានសោយព្រះក្រយា ស្ងោយ ជាមួយព្រះមំសៈ របស់ព្រះរាជបុត្រ" ។ ព្រះរាជា ទ្រង់ព្រះ កន្សែង ព្រោះសេចក្ដីសោក ក្នុងព្រះរាជបុត្រ ទ្រង់ទតឃើញទោស ក្នុងការសោយទឹកស្រវឹងថា "ទុក្ខនេះ កើតឡើងហើយ ដល់អាត្មា អញ ព្រោះអាស្រ័យការផឹកសុរា " ដូច្នេះ ទ្រង់បានចាប់ធុលី មក ជូតព្រះកត្ត្រាហើយ ទ្រង់អធិដ្ឋាន ថា " ចាប់តាំងអំពីពេលនេះទៅ អាត្មាអញ ពុំទាន់បានសម្រេចព្រះអរហត្ត ដរាបណា, អាត្មាអញ នឹងមិនផឹកនូវសុរា ដែលជាហេតុ នៃសេចក្ដីវិនាស ប្រាកដដូច្នេះ

ជ្ជាបនោះ " ។ តាំងតែអំពីពេលនោះមក ព្រះរាជាអង្គនោះ ទ្រង់
មិនសោយ នូវសុរាទ្បើយ ។

រឿងព្រះរាជាសោយព្រះរាជឱ្យ មក ក្នុងអដ្ឋកថាធម្មទ្ធជ-
ជាតក ក្នុងសត្តមវគ្គ នៃទុកនិបាត ។

(**រឿង ក្ជយ** របស់**អនាថ**បិណ្ឌិ**ក**សេ**ដ្ឋី**)

(២២០) ក្ជយ របស់អនាថបិណ្ឌិកសេដ្ឋី ញ្ជាំងប្រាក់ចំនួន
៤០ កោដិ ដែលជារបស់នៃមាតាបិតា ឲ្យវិនាសហើយ ដោយការ
ប្រើប្រាស់ឲ្យអស់ទៅ ព្រោះការធ្វើកសុរ បានទៅកាន់សំណាក់
នៃសេដ្ឋីហើយ ។ ឯសេដ្ឋីនោះ ក៏បានឲ្យទ្រព្យ ១ ពាន់កហាបណៈ
ដល់ក្ជយនោះ ដោយប្រាប់ ថា " ចូរអ្នកធ្វើ នូវការលក់ដូរចុះ " ។
ក្ជយនោះ បានធ្វើប្រាក់ ១ ពាន់កហាបណៈនោះឯង ឲ្យវិនាស
ហើយ បានទៅរកម្តងទៀត ។ សេដ្ឋី ឲ្យទ្រព្យ ៥០០ កហាបណៈ
ថ្មីទៀត, កាលបើក្ជយនោះ ញ្ជាំងទ្រព្យ ៥០០ កហាបណៈនោះឯង
ឲ្យវិនាសអស់ហើយ មកថ្មីម្តងទៀត, ទើបបានឲ្យសំពត់សាដក
សាច់គគ្រើម ២ កំណាត់ទៅ និង ញ្ជាំងបុគ្គល ឲ្យចាប់ក្ជយនោះ
ដែលធ្វើសំពត់សាដកនោះឯង ឲ្យវិនាសទៅហើយ មករក ម្តង
ទៀត ត្រង់-ក ហើយក៏បានបណ្តេញចេញទៅហើយ ។ ក្ជយនោះ
ជាអ្នកគ្មានទីពឹងពាក់ នៅអាស្រ័យជញ្ជាំងផ្ទះ នៃជនដទៃ បានធ្វើ

១០០ និងវិតិមជ្ឈបានសំយមកថា

កាលកិរិយាហើយ ។ ពួកមនុស្សទាំងឡាយ បាននាំគ្នាអូសខ្ទាចនេះនោះ យកទៅចោល ខាងក្រៅហើយ ។ ឯសេដ្ឋី បានទៅកាន់វត្តហើយ ក្រាបទូលនូវរឿងរ៉ាវរបស់ក្ងួយ ទាំងអស់នោះ ដល់ព្រះសាស្តាហើយ ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា " ក្នុងកាលមុន តថាគត សូម្បីឲ្យឆ្នាំងកំណប់ ដែលឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន ក៏មិនអាចដើម្បីនឹងញ៉ាំងបុរសណា ឲ្យឆ្អែតស្កប់ស្កល់បានឡើយ, អ្នកនឹងញ៉ាំងបុរសនោះ ឲ្យឆ្អែតស្កប់ស្កល់បាន យ៉ាងដូចម្តេចទៅ " ដូច្នេះហើយ ទ្រង់នាំអតីតនិទាន មក (សម្តែងថា) ៖

(រឿង អ្នកលេងសុរា)

(២២១) ក្នុងអតីតកាល ក្នុងក្រុងពារាណសី ព្រះពោធិសត្ត្ववកើតជាសេដ្ឋី មានទ្រព្យកប់ទុក ក្នុងផែនដីចំនួន ៤០ កោដិ បានធ្វើបុណ្យទាំងឡាយ មានទានជាដើម ស្ងាប់ (អំពីអត្តភាពនោះ) ហើយ ក៏បានទៅកើតជាស្តេចសក្ក្ववជ ។ ក៏បុត្ត របស់ព្រះពោធិសត្ត្ववនោះ មានតែមួយប៉ុណ្ណោះ ។ បុត្ត្ववនោះ, កាលបើបិតាធ្វើកាលៈទៅហើយ, ក៏បានឲ្យបុគ្គលធ្វើមណ្ឌប មានមហាជនចោមរោមហើយ ផឹកនូវសុរា ។ បុត្ត្ववនោះ ឲ្យទ្រព្យម្តង ១ ពាន់ៗ ដល់ជនទាំងឡាយ អ្នកធ្វើ នូវការលោត ហក់ រចាំ រ និង ច្រៀង

-៣៤៧-

មន្តលត្ថនីបនីប្រែ

ជាដើម ដល់នូវភាពជាអ្នកលេង មានអ្នកលេងស្រី អ្នកលេងសុរា និង អ្នកលេងស៊ីសាច់ជាដើម ជាអ្នកស្ថិតនៅ ឈ្លក់វង្វេងហើយ ក្នុងមហោស្រព មានការរាំច្រៀង និង ប្រគំជាដើម ត្រាច់ចរទៅ ញ្ចាំងទ្រព្យចំនួន ៤០ កោដិ និង ភណ្ឌៈ ដែលជាគ្រឿងឧបករណ៍ នៃគ្រឿងឧបភោគ និង បរិភោគ ឲ្យវិនាសអស់ហើយ ក្នុងកាលមិនយូរឡើយ ជាបុគ្គលក្រីក្រ កំព្រា ស្ងៀកសំពត់ដែលកញ្ចាស់ ដើរទៅហើយ ។ សក្កទេវរាជ ទ្រង់ជ្រាប ថា កូននោះ ជាអ្នកក្រីក្រលំបាក ទើបស្តេចយាងមក ព្រោះសេចក្តីស្រលាញ់ចំពោះបុត្រ ទ្រង់ប្រទានឆ្នាំងកំណប់ ដែលឲ្យសេចក្តីប្រាថ្នា គ្រប់យ៉ាងហើយ ទ្រង់ត្រាស់ថា "នែកូនសំឡាញ់ ឆ្នាំងនេះនឹងមិនបែកដោយវិធីណា, អ្នកចូររក្សាឆ្នាំងនោះទុក ដោយវិធីនោះចុះ, ព្រោះថា កាលបើឆ្នាំងនេះមានដល់អ្នក, ឈ្មោះថា ការកំណត់នៃទ្រព្យនឹងមិនមាន, ចូរអ្នកកុំបីប្រមាទឡើយ" ដូច្នេះហើយ ទើបស្តេចយាងទៅឋាន របស់ព្រះអង្គដូចដើមវិញ ។ ចាប់តាំងពីពេលនោះមក បុត្រនោះ តែងដើរផឹកសុរា ។ ក្រោយមកថ្ងៃមួយ គេស្រវឹងហើយ ចោះហើយទទួលៗ នូវឆ្នាំងនោះ លើអាកាស (ទទួល) ផ្ទាតហើយ មួយគ្រា ។ ឆ្នាំង បានធ្លាក់មកលើផែនដី បែកហើយ ។ តាំងពីពេលនោះមក បុត្រនោះ ជាអ្នកទីទ័លក្រ ម្តងទៀត ស្ងៀក

១០ជាតិមជ្ឈបានសំយមកថា

សំពត់កញ្ចាស់ មានដៃកាន់អំបែងក្បឿង នៅអាស្រ័យជញ្ជាំងផ្ទះ នៃជនដទៃ បានធ្វើកាលកិរិយាហើយ ។

(២២២) ព្រះសាស្តា លុះទ្រង់នាំអតីតនិទានេះមកហើយ កាលទ្រង់សម្តែងធម៌ ដល់សេដ្ឋី ទ្រង់បានត្រាស់គាថាទាំងឡាយ ៣ ក្នុងកទ្រុយជជាតក ក្នុងបញ្ចមវគ្គ នៃតិកនិបាត ថា ៖

" អ្នកលេងនោះ បានផ្ទូរវ៉ាំងកំណាប់ ដែលឱ្យផ្ទូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយថែរក្សាវ៉ាំងនោះ ដរាបណា, អ្នកលេងនោះ រមែងដល់ផ្ទូរសេចក្តីសុខ ដរាបនោះ ។ ក្នុងកាលណា អ្នកលេងនោះស្រេកវ៉ាំងហើយផង គឃ្លើនផង បានបំបែកវ៉ាំងហើយ ព្រោះសេចក្តីប្រមាទ, ក្នុងកាលនោះ គេជាអ្នកអាក្រាតផង ជាអ្នកស្លៀកកំណាត់សំពត់កន្ទបផង ជាពាលផង រមែងក្តៅក្រហល់ក្រហាយ ក្នុងកាលជាខាងក្រោយ, បុគ្គលណា បានផ្ទូរទ្រព្យ យ៉ាងដូច្នេះហើយ ប្រើប្រាស់ ដោយសេចក្តីប្រមាទ បុគ្គលនោះ ជាអ្នកឥតប្រាជ្ញា រមែងក្តៅក្រហាយ ក្នុងកាលជាងខាងក្រោយ ដូចជាអ្នកលេង ដែលក្តៅក្រហាយ ស្តាយក្រោយ ព្រោះតែបំបែកវ៉ាំងចោល យ៉ាងដូច្នោះឯង [(១)] " ។

១- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ១៧៦ ។

មង្គលត្ថទីបនីប្រែ

(២២៣) បណ្តាបទទាំងនោះ បទថា "**សព្វកាមទទំ**" មានសេចក្តីថា នូវឆ្នាំងដែលអាចដើម្បីនឹងឲ្យ នូវវត្ថុកាមទាំងពួងបាន ។ បទថា " **ភូដំ** " ជាពាក្យវេវចនៃឆ្នាំង ។ បទថា " **ឃាវ** " បានដល់ អស់កាលមានប្រមាណត្រឹមណា ។ បទថា "**អនុបាលេតិ**" គឺ រមែងរក្សា ។ បទថា "**មត្តា**" គឺ ស្រវឹងហើយព្រោះការស្រវឹងសុរា ។ បទថា "**ទិត្តា**" គឺ គយ្លើនហើយ ព្រោះសេចក្តីគយ្លើន ។ បានគាថា ថា "**បមាទ កុម្ភមព្ភិទ**" បានដល់ បានបំបែកហើយនូវឆ្នាំង ដោយសេចក្តីប្រមាទ ។ ២ បទថា "**ទគ្ធា ច ឧបេត្តា ច**" មានសេចក្តីថា គ្រាខ្លះ ជាអ្នកអាក្រាត គ្រាខ្លះ ជាអ្នកស្លៀកកំណាត់សំពត់កន្ទុប ព្រោះជាអ្នកស្លៀកកំណាត់សំពត់ចាស់ និង កំណាត់កន្ទុប ។ បទថា "**ឧមត្តា**" មានសេចក្តីថា ដោយសេចក្តីប្រមាទ ។ បទថា " **តប្ឋតិ** " គឺ រមែងសៅសោក ។

រឿង អ្នកលេងសុរា ចប់ ។

រឿងបុត្រ របស់សេដ្ឋីអ្នកមានទ្រព្យច្រើន ក្នុងជរាវគ្គ នៃធម្មបទ ក្តី កុម្ភជាតក ក្តី ក្នុងតិ្ថសនិបាត បណ្ឌិត គប្បីប្រមូលមក ។

ពណ៌នាអំពីរឿង ក្នុងការផឹកទឹកស្រវឹង ចប់ ។

ក៏រឿង ដែលខ្ញុំបានពោលហើយទាំងអស់នោះ គឺលោកបានហើយអំពីទីផ្សេង ៗ ។ ចំណែក រឿងតទៅនេះ គឺលោកបានហើយ

១០ និងវិតិមជ្ឈបានសំយមកថា

អំពីទីជាមួយគ្នា ។

(រឿង នាងយក្ខិនី ដែលប្រព្រឹត្តក្បត់ចិត្ត)

(២២៤) ក្នុងអតីតកាល ព្រះអគ្គមហេសី របស់ព្រះរាជា ក្រុងពារាណសី ប្រព្រឹត្តក្បត់ព្រះទ័យ ត្រូវព្រះរាជា ត្រាស់សួរ ហើយ ទើបទ្រង់ធ្វើព្រះសម្បថ ថា " ប្រសិនបើ ទូលបង្គំប្រព្រឹត្ត ក្បត់ព្រះហប្ញទ័យព្រះអង្គ, ទូលព្រះបង្គំនឹងកើតជានាងយក្ខិនី មាន មុខ ដូចជាមុខនៃសេះ " ដូច្នេះហើយ ទើបទ្រង់ទិវង្គតទៅ ក៏បាន ទៅកើតជានាងយក្ខិនី មានមុខដូចជាសេះ ក្នុងរូងភ្នំ ជាទីសម្រាក ក្បែរជើងភ្នំមួយ ឧបដ្ឋាកស្តេចវេស្សវ៉ណ អស់ ៣ ឆ្នាំ បានហើយ ដើម្បីនឹងស៊ីមនុស្សទាំងឡាយ ក្នុងទីប្រមាណ ៣០យោជន៍ ដោយ បណ្តាយ ក្នុងទីប្រមាណ ៥ យោជន៍ ដោយទទឹង ។ ថ្ងៃមួយ នាងយក្ខិនីនោះ ចាប់ព្រាហ្មណ៍រូបស្អាតបានហើយ ឲ្យដេក លើខ្នង នាំទៅកាន់គុហា បានទទួលសម្ផស្ស នៃបុរសហើយ ក៏ញ្ចុំង សេចក្តីស្រលាញ់ ឲ្យកើតឡើងហើយ ក្នុងព្រាហ្មណ៍នោះ ដោយ អំណាចនៃកិលេស មិនបានស៊ីនូវព្រាហ្មណ៍នោះទេ បានយកធ្វើ ជាប្តីហើយ តាំងអំពីពេលនោះមក កាលចាប់ពួកមនុស្សបាន ក៏ យកវត្ថុទាំងឡាយ មានសំពត់ អង្ករ និង ប្រេងជាដើម ហើយឲ្យ ភោជនដែលមានរសជាតិឆ្ងាញ់ផ្សេងៗ ដល់ព្រាហ្មណ៍នោះ ខ្លួនឯង

មង្គលត្ថទីបនីប្រែ

ស៊ីសាច់មនុស្ស ។ មួយទៀត ក្នុងពេលដែលទៅរកចំណីអាហារ ព្រោះខ្ជាចព្រាហ្មណ៍នោះរត់ចេញ នាងយក្ខិនីនោះ បានយកសីលា យ៉ាងធំ មកបិទទ្វារហើយទើបទៅ ។ ក្នុងកាលនោះ ព្រះពោធិ-សត្ត្ব បានកើត ក្នុងផ្ទៃពោះ នៃនាងយក្ខិនីនោះ ។ ដោយកាល កន្ទ្ធងទៅបាន ១០ ខែ នាងយក្ខិនីនោះ ក៏បានសម្រាលកូនមក ជា អ្នកមានសេចក្ដីស្រលាញ់ ដ៏មានកម្លាំង ក្នុងបិតា និង បុត្រទាំង ឡាយនោះ បានដាក់បិតា និង បុត្រទាំង ២ នោះ ពួងដ៏ខាងក្នុង បិទទ្វារហើយទើបទៅ ។ ព្រះពោធិសត្ត្ব ចម្រើនវ័យហើយ ដោយ លំដាប់ ថ្ងៃមួយ ក្នុងពេលដែលនាងយក្ខិនីនោះ ទៅហើយ ទើប ប្រមៀលសីលាចេញហើយ ដាក់បិតា (ឲ្យនៅ) ខាងក្រៅ ។ នាង យក្ខិនី មកហើយ បានស្ដាប់ឮថា " បពិត្រអ្នកម្ដាយ កូនបានយក សីលាចេញ, យើងខ្ញុំ មិនអាច ដើម្បីអង្គុយនៅ ក្នុងទីងងឹតបាន ឡើយ " ដូច្នេះ មិនបានពោលពាក្យអ្វីមួយឡើយ ព្រោះសេចក្ដី ស្រលាញ់ចំពោះបុត្រ ។ ក្រោយមក ថ្ងៃមួយ កុមារ បានសួរថា "បពិត្រលោកឪពុក មុខរបស់អ្នកម្ដាយ និង លោកឪពុក របស់ខ្ញុំ មិនដូចគ្នាទេ, តើមានហេតុអ្វីទៅ? " ។ បិតា បានតប ថា " នែកូន សំណាញ់ មាតា របស់អ្នក គឺជាយក្ខិនី, យើងទាំង ២ នាក់ គឺជា មនុស្ស " ។ កុមារ បានស្ដាប់ពាក្យបិតានោះហើយ ក្នុងថ្ងៃមួយ,

១០០ជាតិមជ្ឈបានសំយមកថា

កាលបើមាតា ទៅហើយ, ក៏នាំបិតារត់ចេញ ។ នាងយក្ខិនី មកហើយ មិនឃើញជនទាំង ២ នាក់នោះ ទើបរត់ចេញទៅ ដោយកម្ហាំងល្បឿនដូចជាខ្យល់ បានចាប់ជនទាំង ២ នាក់នោះ ត្រឡប់មកវិញហើយ ។ ក្នុង ២-៣ ថ្ងៃ មកទៀត កាលបើកូននាំគ្នា រត់ចេញទៅ យ៉ាងដូច្នេះ, នាងយក្ខិនី ក៏បាននាំយកមកវិញ ។ ព្រះពោធិសត្ត គិតថា "ឱកាសដែលជាទីកំណត់ គប្បីមាន ដល់មាតារបស់អាត្មាអញ, ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ត្រូវតែសួរខេត្ត នៃទីដែលប្រព្រឹត្តទៅ នៃអាជ្ញារបស់មាតា អាត្មាអញនោះហើយ គប្បីកន្ទ្រង់នូវខេត្តនោះ រត់គេចចេញទៅ" ហើយ ក៏សួរខេត្តដែននោះ ។ ឯនាងយក្ខិនីនោះ បានប្រាប់ដល់កូននោះហើយ ។ ព្រះពោធិសត្តនោះ ដោយកាលកន្ទ្រង់ទៅបាន ២-៣ ថ្ងៃ ទើបបញ្ជិះបិតា ដាក់លើស្មា ហើយ ក៏រត់ទៅ ដោយល្បឿនលឿន ដូចជាខ្យល់ បានទៅដល់ច្រាំងសមុទ្រ ដែលជាខេត្តកំណត់ ទើបបានទៅ កាន់កណ្តាលសមុទ្រហើយ ។ ឯនាងយក្ខិនីនោះ បានទៅតាម ឈរនៅ ត្រង់ច្រាំងនៃសមុទ្រហើយ សូម្បីសុំអង្វរការនូវប្តី និង កូនទាំង ២ នាក់នោះ ដោយប្រការផ្សេងៗ ក៏មិនអាចដើម្បីឲ្យប្តី និង កូនទាំង ២ នាក់នោះ ត្រឡប់វិញបានឡើយ សូម្បីសេចក្តីទុក្ខ ប្រាកដដូច្នោះ គ្របសង្កត់ហើយ ក៏ប្រាថ្នានឹងឲ្យមន្ត ព្រោះតែសេចក្តីស្រលាញ់

មង្គលត្ថទីបនីប្រែ

ចំពោះកូន ទើបបានពោលយ៉ាងដូច្នេះថា "នែកូនសំឡាញ់ ប្រសិនបើ កូនឯងមិនត្រឡប់មកវិញទេ, ធម្មតាការរស់នៅ ក្នុងមនុស្សលោក ជាទុក្ខ, ព្រោះថា អ្នកមិនចេះសិប្ប: រមែងមិនអាចចិញ្ចឹមជីវិតបានឡើយ, ម្តាយ ចេះវិជ្ជាមួយ ឈ្មោះថា ចិន្តាមណី, ដោយអានុភាពនៃវិជ្ជា ឈ្មោះចិន្តាមណីនោះ បុគ្គលអាច ដើម្បីនឹងទៅតាមគន្ធងជើង នៃជនទាំងឡាយ សូម្បីអ្នកលួចកណ្ហ:ហើយ ទៅហើយបាន ក្នុងទីបំផុតនៃ ១២ ឆ្នាំ បាន, វិជ្ជា ឈ្មោះ ចិន្តាមណីនេះ នឹងជាគ្រឿងចិញ្ចឹមជីវិត របស់កូនឯង, នែកូនសំឡាញ់ ចូរកូនរៀនយកមន្ត ដែលមានតម្លៃកាត់មិនបានចុះ " ។ ព្រះពោធិសត្ត ឈរនៅត្រង់កណ្តាលសមុទ្រនុ:ឯង ថ្វាយបង្គំម្តាយហើយ រៀនយកនូវមន្ត ថ្វាយបង្គំម្តាយ (ម្តងទៀត) ហើយ ទើបពោលថា " បពិត្រអ្នកម្តាយ សូមអ្នកម្តាយអញ្ជើញទៅចុះ" ។ នាងយក្ខិនីនោះ ពោលថា " នែកូនមាសម្តាយ កាលបើអ្នកទាំង ២ នាក់ មិនត្រឡប់មកវិញទេ, ជីវិត របស់ម្តាយ គង់មិនមានទេ" ដូច្នេះហើយ ក៏ប្រហារដើមទ្រូង មានហឫទ័យបែកហើយ ព្រោះសេចក្តីសោកចំពោះបុត្រស្លាប់ហើយ បានដួលចុះ ក្នុងទីនោះភ្លាម ។ ព្រះអគ្គមហេសីនោះ ក្នុងកាលមុន បានធ្វើមិច្ឆាចារ និយាយកុហកហើយ កើតជានាងយក្ខិនី ព្រោះកម្លាំងនៃការស្បថ ដល់ហើយនូវសេចក្តីស្លាប់ យ៉ាង

១០ និរតិមជ្ឈបានសំយមកថា

អនាថា ដោយប្រការដូច្នេះឯង ។

រឿង នាងយក្ខិនី ដែលប្រព្រឹត្តក្បត់ចិត្ត ចប់ ។

(២២៥) គ្រានោះ ព្រះពោធិសត្ត្ব បានធ្វើទីសម្រាប់ដុត បូជា (ដុត) មាតាហើយ បានញ្ជាំងទីប៉ាតាឲ្យរលត់ស្រេច ក៏ធ្វើការបូជា ដោយផ្ការឈើ ថ្វាយបង្គំហើយ ទើបទូញយំ បាននាំបិតា ទៅកាន់ ក្រុងពារាណសី បានឈរនៅ ត្រង់ទ្វារព្រះរាជវាំងហើយ ឲ្យបុគ្គល ក្រាបទូល ដល់ព្រះរាជា ថា "មាណព ដែលឆ្នាត ក្នុងគន្ធង់ជើងមក ហើយ " ដូច្នេះ, កាលព្រះរាជា ទ្រង់ត្រាស់ថា " បុរសនោះ ចូរមក ចុះ " ដូច្នេះហើយ ក៏ចូលទៅ ក្រាបថ្វាយបង្គំហើយ ត្រូវព្រះរាជា អង្គនោះ ត្រាស់សួរហើយ ទើបបានក្រាបទូលនូវសិប្ប: ដែលខ្លួន ចេះ, កាលបើព្រះរាជា ទ្រង់ត្រាស់បញ្ជា ថា " បើដូច្នោះ ចូរអ្នក ឧបដ្ឋាកនូវយើង" ដូច្នេះ, ទើបក្រាបទូលថា "ទូលព្រះបង្គំ កាល បានទ្រព្យ ១ ពាន់កហាបណ: ជារៀងរាល់ថ្ងៃ នឹងឧបដ្ឋាក " ។ ព្រះរាជា ទ្រង់ត្រាស់ថា "ប្រពៃណាស់" ហើយ ទ្រង់ត្រាស់បញ្ជា ឲ្យព្រះរាជទានទ្រព្យ ១ ពាន់កហាបណ: រៀងរាល់ថ្ងៃ ។ ក្រោយ មក ថ្ងៃមួយ បុរោហិត ក្រាបទូលថា "បពិត្រព្រះមហារាជ យើង ទាំងឡាយ មិនដឹងថា បុរសនេះ មានសិប្ប:នោះ ឬក៏ មិនមានទេ, ពួកយើង នឹងសាកល្បងមើល នូវបុរសនោះ ជាមុនសិន " ដូច្នេះ ។

មន្តលត្ថនីបនីប្រែ

ព្រះរាជា ទ្រង់ព្រមទទួលហើយ ។ ព្រះរាជា និង បុរោហិត ទាំងពីរ
នាក់នោះ កាលធ្វើនូវចោរកម្ម ទើបលួចយករបស់ដែលមានតម្លៃ
គឺរតន: ចុះអំពីប្រាសាទហើយ ទម្ជុះ ព្ធដ៏ខាងក្នុងព្រះរាជនិវេសន៍
៣ ដង ដាក់ជណ្តើរហើយ ទើបចុះទៅខាងក្រៅ តាមកំពូលនៃ
កំពែង បានចូលទៅកាន់សាលាវិនិច្ឆ័យហើយ ក៏បានមកវិញ ម្តង
ទៀត ដាក់ជណ្តើរហើយ ទើបចុះទៅតាមកំពូលនៃកំពែង បានទៅ
កាន់មាត់ស្រះបោក្ខរណីហើយ បានធ្វើប្រទក្សិណ ៣ ដង ទើប
បានចុះទៅ (កាន់ស្រះ) លាក់ភណ្ឌ: ព្ធដ៏ខាងក្នុងស្រះបោក្ខណី
ហើយ ទើបបានឡើងទៅ កាន់ប្រាសាទ ។ ក្នុងថ្ងៃស្អែកឡើង
សេចក្តីកោលាហលតែមួយ បានកើតឡើងហើយ ថា " បានព្ថ
ពួកចោរ បានលួចយករតន:ចេញ អំពីព្រះរាជនិវេសន៍ហើយ" ។
ព្រះរាជា ទ្រង់ធ្វើដូចជាមិនទ្រង់ជ្រាប ទ្រង់បានត្រាស់បញ្ជា ឲ្យហៅ
ព្រះពោធិសត្វមកហើយ មានព្រះរាជឧង្ការ ថា " ចូរអ្នកពិចារណា
រកមើលចោរ " ។ ព្រះពោធិសត្វនោះ បានក្រាបទូលថា " បពិត្រ
ព្រះសម្មតិទេព ប្រពៃហើយ " ដូច្នេះ ថ្វាយបង្គំមាតាហើយ ទើប
បានរាយមន្ត ឈរនៅ ត្រង់ផ្ទៃព្រះរាង ក្រាបទូលថា " បពិត្រព្រះ
មហារាជ ស្នាមជើង នៃចោរទាំងឡាយ ២ នាក់ រមែងប្រាកដ "
ហើយទៅ ក្នុងទីទាំងពួង តាមគន្ធងស្នាមជើង នៃចោរទាំង ២ នោះ

ធាបវិរតិមជ្ឈបានសំយមកថា

បាននាំយកបញ្ចប់កណ្ឌៈ ដូចជាខ្ទួនបានដាក់ទុកហើយ ចេញមកសម្តែង ដល់ព្រះរាជ ហើយក្រាបទូល ថា “ បពិត្រព្រះមហារាជ ចោរទាំង ២ នាក់នោះ គឺទូលព្រះបង្គំបានស្គាល់ច្បាស់ហើយ ” ។

ព្រះរាជា. តើអ្នកអាចចាប់ពួកចោរ មកឲ្យបានឬទេ ? ។

ព្រះពោធិសត្វ. បពិត្រព្រះសម្មតិទេព ចោរទាំង ២ នោះនៅក្នុងទីនេះឯង, មិនមែននៅទីឆ្ងាយទេ ។

ព្រះរាជា. ក៏អ្នកណា ជាចោរ ?, អ្នកណា ជាចោរ ? ។

ព្រះពោធិសត្វ. បពិត្រព្រះសម្មតិទេព អ្នកណា ប្រាថ្នា, អ្នកនោះឯង ជាចោរ, ហេតុនោះ ចូរលើកទុកសិនចុះ, នឹងមានប្រយោជន៍អ្វីទៅ ដោយពួកចោរ ចាប់ដើមអំពីកាលដែលព្រះអង្គទ្រង់បានកញ្ចប់ នៃកណ្ឌៈហើយ, សូមព្រះអង្គ កុំបីត្រាស់សួរឡើយ ។

ព្រះរាជា. នៃអ្នក ខ្ញុំនឹងឲ្យទ្រព្យ ១ ពាន់កហាបណៈ ដល់អ្នក, ចូរអ្នកចាប់ចោរទាំងឡាយហើយ យកមកឲ្យខ្ញុំ (ឲ្យបាន) ។

ព្រះពោធិសត្វ ព្រោះសេចក្តីអនុគ្រោះដល់ព្រះរាជា សូម្បីប្រាថ្នានឹងបិទបាំង នូវចោរមក្ខ របស់ព្រះអង្គ ក៏ត្រូវព្រះអង្គ ទ្រង់ត្រាស់សួរហើយញយៗ ទើបនាំរឿងទាំង ៨ ក្នុងអតីតកាលមក ។

(២២៦) ក្នុងអតីតកាល អ្នករបាំម្នាក់ ដែលនៅ ក្នុងស្រុក

មន្ថលត្ថទីបនីប្រែ

(រឿង ទី ១)

ក្នុងទីមិនឆ្ងាយ អំពីក្រុងពារាណសី ឈ្មោះថា បាតលី ស្រវឹងសុរាហើយ ដើរឆ្ងងស្ទឹង ត្រូវទឹកកួចយកទៅហើយ ពោលថា " ទឹកជាទីពឹងអាស្រ័យ របស់មហាជន រមែងសម្ងាប់អាត្មាអញ " ដូច្នេះហើយ ក៏បានធ្វើកាលកិរិយាហើយ ។

(រឿង ទី ២)

(២២៧) ក្នុងអតីតកាល ស្ទូនឆ្នាំង ដែលនៅ ក្នុងស្រុកក្បែរមាត់ទ្វារក្រុងពារាណសី ម្នាក់ បានយកដីស្អិត ក្នុងអន្ទុងមួយដើម្បីប្រយោជន៍ដល់ការធ្វើភាជនៈ ។ ក្នុងខណៈនោះឯង ភ្លៀង ក៏ធ្លាក់ចុះមកហើយ ។ ទឹកជន់មកលិច ញ្ចាំងជើងនៃអន្ទុង ឲ្យបាក់រលំហើយ ។ ក្បាល របស់ស្ទូនឆ្នាំងនោះ បែកហើយ ព្រោះបាក់ជើងអន្ទុងនោះ ។ នាយស្ទូនឆ្នាំងនោះ ទួញយំ ថា " មហាប្រឹថពី ដែលជាទីពឹងអាស្រ័យ របស់មហាជន បានទំលាយក្បាល របស់អាត្មាអញហើយ " ។

(រឿង ទី ៣)

(២២៨) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសីកាលបើផ្ទះ ត្រូវភ្លើងឆេះ, ក៏មិនអាច ដើម្បីនឹងចេញមកបាន ទើបពោល ថា " ភ្លើង ជាទីពឹងអាស្រ័យ របស់មហាជន រមែងឆេះនូវ

អាត្មាអញ " ដូច្នេះហើយ ក៏បានធ្វើកាលៈហើយ ។

(រឿង ទី ៤)

(២២៩) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសី នោះឯង បរិភោគច្រើនហួសពេក ក៏មិនអាច ដើម្បីនឹងញ្ចុាំងម្ហូបអាហារ ឲ្យរលាយទៅបាន ទើបពោលថា " ភត្ត ដែលជាទីពឹងអាស្រ័យ របស់មហាជន រមែងញ្ចុាំងអាត្មាអញឲ្យស្លាប់ " ដូច្នេះបានស្លាប់ហើយ ។

(រឿង ទី ៥)

(២៣០) ក្នុងអតីតកាល ខ្យល់ បានបក់បោកឡើងហើយ បំផ្លាញនូវកាយ របស់បុរសម្នាក់ ក្នុងក្រុងពារាណសីនោះឯង ។ បុរសនោះ បានទួញយំ ថា " ខ្យល់ ដែលជាទីពឹងអាស្រ័យ របស់មហាជន ក្នុងរដូវក្តៅ រមែងទម្លាយនូវកាយ របស់អាត្មាអញ " ។

(រឿង ទី ៦)

(២៣១) ក្នុងអតីតកាល ក្នុងហិមវន្តប្រទេស បានមានដើមឈើធំ មួយដើម ជាទីនៅអាស្រ័យ របស់សត្វបក្សី ជាច្រើនពាន់ ។ មែកទាំងគូ នៃដើមឈើធំនោះ បានសង្ឿតគ្នាហើយ ញ្ចុាំងផ្សែងនិង កំទេច នៃភ្លើង ឲ្យធ្លាក់ចុះហើយ ។ សត្វបក្សីទាំងឡាយឃើញនូវផ្សែង និង កំទេចភ្លើងនោះហើយ ទើបពោលថា "ដើមឈើ ធំនេះ

មន្ថលត្ថទីបនីប្រែ

ជាទីពឹងអាស្រ័យ របស់ពួកយើង, ឥឡូវនេះ រាបានញ្ញាំងភ័យ ឲ្យ កើតឡើងហើយ" ដូច្នេះហើយ ក៏ហើរចេញទៅ ។ រឿង ទី៦ ចប់ ។

(រឿង ទី ៧)

(រឿង កូនប្រសាស្រីសម្លាប់ម្តាយក្មេក)

(២៣២) ក្នុងអតីតកាល កុលបុត្រ ម្នាក់ ក្នុងស្រុកឈ្មោះ កាសី, កាលបើបិតា ធ្វើកាលៈទៅហើយ, ក៏ប្រតិបត្តិ នូវមាតា ។ មាតា បាននាំយកស្រីម្នាក់មក ដើម្បីកូនប្រុសនោះ អ្នកមិនប្រាថ្នា ចង់បានន៉ុះឯង ។ ក៏ស្ត្រីនោះ បាននាំមាតា របស់ខ្លួន មកនៅ ក្នុង ទីនោះ ជាដំបូង បានធ្វើឲ្យម្តាយក្មេកស្រលាញ់ហើយ ក្រោយមក ចម្រើន ដោយបុត្រ និង ធីតាទាំងឡាយ ក៏ប្រាថ្នាសម្លាប់ម្តាយ ក្មេកនោះចោល ទើបប្រាប់ដល់ស្វាមី ។

ស្វាមី. ឈ្មោះថា ការសម្លាប់មនុស្ស ជាកម្មធ្ងន់ណាស់, ពួកយើង នឹងសម្លាប់មាតានោះ បានយ៉ាងដូចម្តេចទៅ? ។

ភរិយា. បពិត្រលោកប្តី ក្នុងពេលដែលគាត់សម្រានលក់ ពួកយើង នឹងនាំយកគាត់ជាមួយនឹងគ្រែន៉ុះឯង ទៅបោះចោល ក្នុង ស្ទឹង ដែលមានសត្វក្រពើកាចៗ ក្នុងទីខាងក្រោយផ្ទះ របស់យើង, ក្នុងកាលនោះ សត្វក្រពើទាំងឡាយ នឹងត្របាក់លេបគាត់ " ។

ស្វាមី. នែនាងដ៏ចម្រើន មាតា របស់អូន សម្រាននៅ

១០ និតិមជ្ឈបានសំយមកថា

ត្រង់ទីឯណា ? ។

ភរិយា. គាត់សម្រាន់នៅ ក្បែរមាតា របស់បងឯង ។

ស្វាមី. បើដូច្នោះ ចូរអ្នកទៅចុះ, ចូរអ្នកចង់ខ្សែ ត្រង់ត្រែ ដែលមាតា របស់បងសម្រាន់ហើយ ធ្វើនូវសញ្ញាទុក ។

ភរិយានោះ បានធ្វើហើយ យ៉ាងដូច្នោះឯង ។

ស្វាមីក្រៅនេះ ពោលថា " ចូរអ្នករង់ចាំបន្ទ្ចសិនចុះ, ចាំ ឲ្យពួកមនុស្ស ដេកលក់សិន " ដូច្នោះហើយ ក៏ធ្វើទំនង ដូចជា ដេកលក់ ហើយទៅចង់ខ្សែនោះ ត្រង់ត្រែ របស់ម្តាយ នៃភរិយា ស្រេចហើយ ទើបជាស់ភរិយាឲ្យក្រោកឡើង ។ ភរិយា និង ស្វាមី ទាំង ២ នោះ បានលើកនូវមាតា របស់ភរិយានោះ មួយអន្ទៀដោយ ត្រែ ទ្ុះឯង ទៅទម្លាក់ចោល ក្នុងស្ទឹងហើយ ។ សត្វក្រពើទាំង ឡាយ បានត្រចាក់ស៊ី នូវមាតា របស់ភរិយានោះហើយ ។ ក្នុងថ្ងៃ ស្អែកឡើង ភរិយានោះ បានដឹងថា មាតា បានផ្ទាស់ប្តូរគ្នា ទើប ពោលថា " នែលោកប្តី បងឯង បានសម្ងាប់ម្តាយ របស់អ្នកហើយ, ឥឡូវនេះ ពួកយើង នឹងធ្វើទីសម្រាប់ដុត ក្នុងទីចាំ៉ធាហើយ ដាក់ មាតារបស់បងឯង ក្នុងភ្ជើងឲ្យស្ងាប់ទៅ" ។ ស្វាមីនោះ យល់ព្រម ថា "ល្អហើយ" ។ ស្វាមី និង ភរិយា ទាំង ២ នោះ បាននាំយក មាតា ដែលកំពុងតែដេកលក់នោះ ទៅដាក់ (លើទីសម្រាប់ដុតនោះ)

មន្តលត្ថនីបនីប្រែ

ហើយ ។ គ្រានោះ ស្វាមីនោះ ពោលថា " នែនាងដ៏ចម្រើន តើអូន បានយកភ្លើងមកទេ ?" ។

ភរិយា. បពិត្រអ្នកប្តី អូនភ្លេចទៅហើយ ។

ស្វាមី. បើដូច្នោះ ចូរអូនទៅយកមក ។

ភរិយា. បពិត្រលោកប្តី អូនមិនអាច (មិនហ៊ានទៅទេ), សូម្បីបើបងទៅហើយ, អូនក៏មិនអាចនៅបានដែរ, ពួកយើង នឹងទៅទាំង ២ នាក់ ។

កាលបើស្វាមី និង ភរិយាទាំង ២ នាក់នោះ ទៅហើយ, ស្ត្រីចាស់ ត្រូវខ្យល់ត្រជាក់ផាត់ ឲ្យក្រោកឡើងហើយ ដឹង ថា " អ្នកទាំង ២ នាក់នេះ ប្រាថ្នាចង់សម្លាប់អាត្មាអញ បានទៅហើយ ដើម្បីប្រយោជន៍ភ្លើង " ដូច្នេះហើយ ទើបគិត ថា " ពួកវាទាំង ២ នាក់នេះ មិនដឹងកម្លាំងរបស់អញទេ " យ៉ាងដូច្នេះ បានញ្ចុាំងសាកសពមួយ ឲ្យដេក លើគ្រែហើយ យកកំណាត់សំពត់ចាស់ៗ មកបិទបាំង ស្រេចហើយ ក៏ដើរចូលទៅ កាន់គុហាជាទីសម្រាកមួយ ក្នុងទីប៉ាឆានោះឯង ។ ម្តាយចាស់នោះ នាំកូនប្រសាស្រីមក ដើម្បីប្រយោជន៍ទីពឹងអាស្រ័យ របស់ខ្លួន តែត្រឡប់ជាមានភ័យ កើតឡើង អំពីកូនប្រសានោះទៅវិញ ដោយប្រការដូច្នេះ ។ ស្វាមី និង ភរិយាទាំង ២ នាក់ ក្រៅពីនេះ នាំយកភ្លើងមកហើយ ក៏ដុតសាក

១០០ និងវិធីមជ្ឈបានសំយមកថា

សព ដោយសេចក្ដីសម្គាស់ ថា ស្ត្រីចាស់ ហើយបានចៀសចេញ ទៅហើយ ។ ក៏ក្នុងទីសម្រាក ក្នុងគុហានោះ ចោរម្នាក់ បានលាក់ កញ្ចប់កណ្ដ:ទុកមុន ។ ចោរនោះ មកហើយ ដើម្បីយកនូវកញ្ចប់ កណ្ដ:នោះ បានឃើញ នូវស្ត្រីចាស់នោះហើយ ក៏មានសេចក្ដី សម្គាល់ថា ជានាងយក្ខិនី ទើបគិតថា " កញ្ចប់កណ្ដ: របស់អញ ត្រូវអមនុស្សហួងហែងហើយ " ដូច្នេះហើយ ក៏បានទៅ នាំយកគ្រូ ខ្មោចមក ។ គ្រូធ្វើនូវមន្ត ចូលទៅកាន់គុហាហើយ ។ ស្ត្រីចាស់ នោះ ពោលថា " ខ្ញុំមិនមែនជានាងយក្ខិនី ទេ, អ្នកចូរអញ្ជើញមក ចុះ, យើងទាំង ២ នាក់ នឹងចែកទ្រព្យគ្នា " ។ គ្រូពោល ថា " ខ្ញុំ គប្បីជឿបាន យ៉ាងដូចម្ដេច? " ។ ស្ត្រីចាស់នោះ ពោលថា " ចូរ អ្នកដាក់អណ្ដាត របស់អ្នក មកលើអណ្ដាត របស់នាងខ្ញុំចុះ " ។ គ្រូនោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ ស្ត្រីចាស់នោះ បានកាត់ អណ្ដាត របស់គ្រូនោះ ឲ្យដាច់ហើយ ។ គ្រូនោះ គិតថា " នាង នេះ ជានាងយក្ខិនី ពិតមែន " ដូច្នេះហើយ ក៏ស្រែកយំ បានគេច ចេញទៅហើយ ។ ចំណែក ចោរក៏បានវត់គេច ទៅហើយដែរ ។ ក្នុងថ្ងៃស្អែកឡើង ម្ដាយចាស់នោះ បាននាំយកកញ្ចប់រតន:ផ្សេងៗ ដើរទៅកាន់ផ្ទះហើយ ។ កូនប្រសាស្រី ឃើញទ្រព្យនោះហើយទើប សួរថា "បពិត្រអ្នកម្ដាយ តើអ្នកម្ដាយបានទ្រព្យនេះ ក្នុងទីណា?" ។

ម្តាយចាស់នោះ ឆ្លើយថា "នែនាង ជនទាំងឡាយ ដែលត្រូវគេជុតហើយ លើឧសជុតខ្ចោច ក្នុងទីប៉ាន ។ រមែងបាននូវទុក្ខជួរច្នេះ" ។ កូនប្រសាស្រីនោះ សួរថា " បពិត្រអ្នកម្តាយ តើកូនស្រីអាចបានដែរឬទេ " ។ ម្តាយចាស់ ឆ្លើយថា " កូនឯង ជាអ្នកប្រាថ្នាស្មើដូចម្តាយ នឹងបាន " ។ កូនប្រសាស្រីនោះ ជាមនុស្សល្ងង់ខ្លៅ បានពោលប្រាប់ ដល់ប្តីដែលជាមនុស្សល្ងង់ខ្លៅ ព្រោះសេចក្តីល្មោកក្នុងទ្រព្យ ទើបឲ្យគេជុតខ្លួន ក្នុងប៉ានានោះ បានធ្វើ នូវកាលៈហើយ ។ កូនប្រសាស្រីនោះ ដល់ហើយនូវសេចក្តីស្លាប់ ខ្លួនឯងតែម្តង ព្រោះប្រាថ្នាចង់ឲ្យអ្នកដទៃស្លាប់ ដោយប្រការដូច្នេះ ។

រឿង កូនប្រសាស្រីសម្លាប់ម្តាយក្មេក ចប់ ។

(រឿង ទី ៨)

(២៣៣) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសី ប្រាថ្នាបុត្រ បានបុត្រនោះហើយ ចិញ្ចឹម ដោយគិតថា " បុត្រនេះ នឹងចិញ្ចឹមអញ ក្នុងពេលខ្លួនចាស់ជរា" ។ ប៉ុន្តែបុត្រ បានបណ្តេញ ឪពុកនោះ ដែលដល់ជរាភាពហើយ ចេញអំពីផ្ទះ ដោយពោល ថា "លោកឪពុក មិនអាចដើម្បីធ្វើការងារបាន, ចូរលោកឪពុក ចេញអំពីផ្ទះនេះទៅចុះ " ។ ឪពុកនោះ ចិញ្ចឹមជីវិត ដោយការសុំទានគេ ដោយសេចក្តីលំបាក ទើបទួញយំ ថា " អាត្មាអញ ចិញ្ចឹមហើយ

១០ជាតិមជ្ឈបានសំយមកថា

នូវបុត្រណា ដោយគិតថា បុត្រ នឹងជាទីពឹងអាស្រ័យ របស់អញ ក្នុងពេលដែលខ្ជិនចាស់ ដូច្នេះ, ក័យ កើតឡើងហើយ ដល់អាត្មាអញ ព្រោះបុត្រនោះ” ដូច្នេះ ។

ព្រះពោធិសត្វនោះ លុះនាំអតីតនិទានទាំងឡាយ មកយ៉ាងដូច្នេះហើយ ទើបក្រាបទូលថា “បុគ្គលម្នាក់ ដែលជាទីពឹងអាស្រ័យ របស់មហាជន ដូចជាវត្ថុទាំងឡាយ មានទឹកជាដើម ជាទីពឹងអាស្រ័យ របស់មហាជន ដូចជាដើមឈើជាទីពឹងអាស្រ័យ របស់សត្វស្លាបទាំងឡាយ ដូចជាកូនប្រសា ជាទីពឹងអាស្រ័យ របស់ម្តាយក្មេក និង ដូចជាកូនជាទីពឹងអាស្រ័យរបស់ឪពុក ចានលួចយកកញ្ចប់កណ្ដាះហើយ, បពិត្រព្រះសម្មតិទេព សូមព្រះអង្គ ទ្រង់ជ្រាបថា បុរស ឈ្មោះនុ៎ះ ជាចោរ យ៉ាងដូច្នេះ ព្រោះហេតុនេះ” ។ ព្រះរាជា ទ្រង់មានព្រះរាជឱ្ការ ថា “ បើដូច្នោះ ចូរអ្នកប្រកាសក្នុងកណ្ដាលបរិស័ទថា អ្នកឈ្មោះនុ៎ះ ជាចោរ និង អ្នកឈ្មោះនុ៎ះ ជាចោរ ដូច្នេះ ” ។ ព្រះពោធិសត្វ ពោលថា “ ព្រះរាជា ព្រះអង្គនេះ រ៉ាមងមិនឲ្យ ដើម្បីរក្សានូវព្រះអង្គ, ឥឡូវនេះ ខ្ញុំនឹងចាប់នូវចោរ ” ដូច្នេះហើយ ទើបពោល ថា “ ម្នាលអ្នកជ័ចម្រើនទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ (ពាក្យ) របស់ខ្ញុំ, ព្រះរាជា និង បុរោហិត ចានធ្វើហើយ នូវចោរកម្ម, ចាប់ដើមអំពីពេលនេះតទៅ អ្នកទាំង

ឡាយ ចូរកាត់ទូវទ្រព្យ និង ស្រូវ ដែលជារបស់នៃខ្លួន " ។ ពួកមនុស្សទាំងឡាយ ស្តាប់ពាក្យនោះហើយ និយាយថា " ព្រះរាជ ព្រះអង្គនេះ ទ្រង់ប្រាថ្នា ដើម្បីលើកឡើងនូវទោស មកលើបុគ្គលដទៃ ទើបទ្រង់លាក់ពាក្ខ: របស់ព្រះអង្គ ទុកក្នុងស្រះបោក្ខរណី ដោយព្រះអង្គឯង តែម្តងហើយ ទ្រង់ត្រាស់ឲ្យសែងវកពួកចោរ, ពេលឥឡូវនេះ តាំងអំពីពេលនេះតទៅ ពួកយើងទាំងឡាយ នឹងសម្ងាប់ព្រះរាជាអាក្រក់នោះចោល ដើម្បីកុំឲ្យធ្វើ នូវចោរកម្ម បន្ត ទៀត" ដូច្នេះហើយ មានដៃកាន់ដំបង និង អន្ទងជាដើម បានក្រោកឡើងហើយ រាយព្រះរាជា ព្រមទាំងបុរោហិត ឲ្យដល់ការក្សយជីវិត បានអភិសេកព្រះពោធិសត្ត ក្នុងរាជសម្បត្តិហើយ ។

ក៏បណ្តាជនទាំងនោះ អ្នករបាំ ឈ្នះបាតលី ដល់ហើយនូវសេចក្តីស្ងាប់ យ៉ាងអនាថា ព្រោះទោសនៃសុរា, កូនប្រសាស្រី ដល់ហើយ នូវសេចក្តីស្ងាប់ យ៉ាងអនាថា ព្រោះទោស នៃការសម្ងាប់សត្វមានជីវិត ក្នុងចំណែកនៃកាលជាខាងដើម, ព្រះរាជា និង បុរោហិត ទាំង ២ រូបនេះ ដល់ហើយ នូវសេចក្តីស្ងាប់ យ៉ាងអនាថា ព្រោះទោសនៃអទិន្នាទាន ដោយប្រការដូច្នេះឯង ។

ក៏រឿងទាំងអស់ ដូចបានពោលមកនេះ បណ្ឌិត គប្បីទាញយក ដោយពិស្តារ ពីអដ្ឋកថាបទកុសលជាតក ក្នុងនវកនិបាត ។

ចាបវិរតិមជ្ឈានសំយមកថា

(២៣៤) បុគ្គល អ្នកបង្ក្រៀវ រមែងដល់ នូវសេចក្ដីទុក្ខ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ បុគ្គលអ្នកកន្ជ្ងាចតែពៀ គប្បីវៀរចាកពៀរនោះ ។ មួយទៀត បុគ្គល អ្នកដែលកន្ជ្ងាចខ្ជាច អំពីនរក គប្បីវៀរចាកពៀរ ។ ដោយហេតុនោះ ព្រះមានព្រះ ភាគ កាលទ្រង់សម្ដែងធម៌ ដល់ព្រះសារីបុត្តត្ថេរ ទើបទ្រង់ត្រាស់ ហើយ ក្នុងគិហិសូត្រ ក្នុងចតុត្ថបណ្ណាសក: [1] នៃបញ្ចកនិបាត អង្គុត្តរនិកាយ ថា ៖

> " អ្នកប្រាជ្ញ ឃើញភ័យ ក្នុងនរកហើយ ត្រូវវៀរបាបទាំង ឡាយ, ត្រូវសមាទានគ្ងីរអរិយធម៌ហើយវៀរ ។ កាលបើ មានសេចក្ដីព្យាយាម, មិនត្រូវបៀតបៀនសត្វទាំងឡាយ ផង កាលដឹង មិនត្រូវនិយាយកុហកផង មិនត្រូវកាន់យក ទ្រព្យដែលគេមិនបានឱ្យផង ត្រូវសន្ដោសតែនឹងភរិយា របស់ខ្លួន មិនត្រូវត្រេកត្រអាលនឹងភរិយា របស់ជនដទៃ ផង មិនត្រូវផឹកមេរ៉ាយនិងសុរាដែលនាំបិត្ដឱ្យវង្វេងផង " ។

*អដ្ឋកថាគិហិសូត្រនោះថា "សីល ៥ ព្រះមានព្រះភាគ ទ្រង់ ត្រាស់ថា អរិយធម៌ ក្នុងពាក្យថា **អរិយធម្មំ សមាទាយ** នេះ ។ ២ បទថា **មេរយំ ភារុណី** មានសេចក្ដីថា នូវមេរ៉ាយ ៤ យ៉ាង*

១- សុត្ដន្ដបិដក ភាគទី ៤៥ ទំព័រទី ១៧១ ។

និង សុភ ៥ យ៉ាង " ។

(២៣៥) ព្រោះហេតុនោះ កុសលចេតនាអ្នកបណ្តេញពៀរ ពោលគឺអរិយធម៌ បណ្ឌិតត្រូវតែសមាទាន ដោយពិត ។ ព្រោះបុគ្គល កាលសមាទានកុសលចេតនា អ្នកបណ្តេញពៀរនោះ ឈ្មោះថា ឲ្យទាន ពោលគឺ វិរតិ ដែលមានផលច្រើនជាង ។ ពិតមែនដូច្នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ទាន ៤ យ៉ាង ក្នុងកូដទន្តសូត្រ ដោយឈ្មោះថាយញ្ញ យ៉ាងដូច្នេះថា "យញ្ញ ពោលគឺការឲ្យកត្តប្រចាំ មានផលច្រើនជាង យញ្ញជាប្រក្រតី, យញ្ញ ពោលគឺ ការឲ្យវិហារ មានផលច្រើនជាង យញ្ញ ពោលគឺការឲ្យកត្តជាប្រចាំនោះ, យញ្ញ ពោលគឺ ការដល់សរណៈ មានផលច្រើនជាង យញ្ញ ពាលគឺ ការឲ្យវិហារនោះ, យញ្ញ ពោលគឺ សីល ៥ មានផលច្រើនជាង យញ្ញ ពោលគឺការដល់សរណៈនោះ" ដូច្នេះ ។

(២៣៦) ក៏ក្នុងអដ្ឋកថា កូដទន្តសូត្រនោះ លោកពោលសេចក្តីថា " ព្រោះការដល់សរណៈ ជាគុណជាតឈ្មោះថា យញ្ញ ដោយអំណាចការលះបង់នូវជីវិត ដល់ព្រះរតនៈទាំង ៣ រមែងឲ្យនូវសម្បត្តិ ក្នុងឋានសួគ៌ ព្រោះហេតុនោះ ការដល់សរណៈ ទើបមានផលច្រើនជាង ការឲ្យវិហារទៅទៀត ។ មួយទៀត សីល ៥ នោះ មានផលច្រើនជាង ការដល់សរណៈនោះទៅទៀត ព្រោះ

១០ ១០ ១០ ១០ ១០ ១០ ១០ ១០ ១០ ១០

ការមិនមានទាន ដែលជូចជាសីល ៥ " ដូច្នេះហើយ ដើម្បីនឹងញ៉ាំងសេចក្ដីនោះ ឲ្យសម្រេច ដោយចាស់ ទើបសម្ដែងចាស់ ថា " ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះ ចាត់ជាមហាទាន ជាទានដែលបណ្ឌិតដឹងថា ជារបស់ប្រសើរ ដឹងថា ជារបស់ប្រពៃ ទៅអស់រាត្រីយូរ ដឹងថា ជាវង្សនៃ (កុលាណជន) ជារបស់មានមកក្នុងកាលមុន ជារបស់មិនរោយរាយ ជារបស់មិនជ្ងាប់ រោយរាយហើយ រមែងមិនខ្ជាត់ខ្ជាយ (ក្នុងពេលឥឡូវនេះ) នឹងមិនខ្ជាត់ខ្ជាយ(ក្នុងអនាគត) ជាទានដែលសមណៈ ឬព្រាហ្មណ៍ទាំងឡាយ ជាវិញ្ញូជន មិនបានតិះដៀលហើយ " ។ ទាន ៥ យ៉ាង តើដូចម្ដេចខ្លះ? [1] ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ លះបង់ចាណាតិបាតហើយ ជាអ្នកវៀរចាកចាណាតិបាត, ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកវៀរចាកចាណាតិបាតហើយ រមែងឈ្នះថា ឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន, លុះឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែក នៃសេចក្ដីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ

១- សុត្តន្តបដិក ភាគទី ៤៨ ទំព័រទី ១៧៨ ។

មន្ទលត្ថទីបនីប្រែ

មានប្រមាណមិនបានវិញ ។ ម្នាលភិក្ខុទាំងឡាយ ទាននេះ ចាត់ជាមហាទាន ជាទាន ដែលបណ្ឌិតជឹងថា ជារបស់ប្រសើរ ជឹងថា ជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ជឹងថា ជាវង្សនៃ (កល្យាណជន) ជារបស់មានមក ក្នុងកាលមុន ជារបស់មិនរោយរាយ ជារបស់មិនធ្លាប់រោយរាយហើយ រមែងមិនខ្ចាត់ខ្ចាយ នឹងមនិខ្ចាត់ខ្ចាយ ជាទានដែលពួកសមណៈ ឬ ព្រាហ្មណ៍ ជាវិញ្ញូជន មិនតិះដៀលឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក លះបង់អទិន្នាទាន រៀរចាកអទិន្នាទាន .... លះបង់កាមេសុមិច្ឆាចារ រៀរចាកកាមេសុមិច្ឆាចារ.... លះបង់មុសាវាទ រៀរចាកមុសាវាទ ..... លះបង់ នូវសុរាមេរយមជ្ជប្បមាទដ្ឋាន រៀរចាកសុមេរយមជ្ជ-ប្បមាទដ្ឋាន..... ម្នាលភិក្ខុទាំងឡាយ ទានទាំង ៥ យ៉ាងនេះឯង ចាត់ជាមហាទាន..... ជាទានដែលសមណៈ ឬ ព្រាហ្មណ៍ ទាំងឡាយ មិនតិះដៀលឡើយ" ដូច្នេះហើយ ពោលទៀតថា "ក៏សីល ៥ នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា យញ្ញ ព្រោះភាវៈជាសីលដែលព្រះអរ័យសាវ័ក បានសមាទានហើយ ដោយតាំងចិត្តថា អញនឹងលះបង់នូវសេចក្តីស្រលាញ់ខ្លួន និង សេចក្តីស្រលាញ់ជិវិត ហើយរក្សា ដោយប្រការដូច្នេះ" ។

(២៣៧) ជីកាកូដទន្តសូត្រនោះ ថា "ទានទាំងឡាយ ឈ្មោះ

ចាបវិរតិមជ្ឈបានសំយមកថា

ថា **អគ្គញ្ញ:** ព្រោះភាវ:ជាទានដែលបណ្ឌិត ជឹងថា ប្រសើរ ។ ឈ្មោះថា **រត្តញ្ញ:** ព្រោះភាវ:ជាទានដែលបណ្ឌិតជឹងហើយ ដោយ ភាត្រី ដ៏ឃ្យរ ។ ឈ្មោះថា **រិសញ្ញ:** ព្រោះភាវ:ជាទានដែលបណ្ឌិត ជឹងថា ជាវង្សនៃអរិយជនទាំងឡាយ គឺ នៃសាធុជនទាំងឡាយ ។ ឈ្មោះថា **ពោ្ធ:ណ:** ព្រោះអត្ថថា ទានទាំងឡាយនុ៎ះ ជារបស់ នៃ ពួកបូ:ណ គឺពួកបុរស ក្នុងជំនាន់ដើម ។ ឈ្មោះថា **អសង្ខ្ជ:ណ:** ព្រោះអត្ថថា ទានទាំងនោះ គឺសាធុជនទាំងឡាយ មិនពោយ:ពាយ គឺ មិនចោះ:ចោល មិនចោះ:បង់:ចោលហើយ ដោយប្រការទាំងពួង គឺ សូម្បីដោយប្រការណាៗ មួយ ។ មួយទៀត ទានទាំងឡាយ នោះ មានន័យ ដូចតទៅនេះ ទានទាំងនុ៎ះ គឺសាធុជនទាំងឡាយ មិនពោយ:ពាយហើយ ក្នុងអតីតកាល យ៉ាងណាមិញ, ក្នុងកាល ឥឡូវនេះ និង ក្នុងអនាគត ក៏មិនធ្លាប់ពោយ:ពាយហើយ យ៉ាងដូច្នោះ ដែរ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ ថា **អសង្ខ្ជ:ណ្ណ:ឬ:ឬ:ានិ ន សង្ខ្ជ:ិយន្ត:ិ ន សង្ខ្ជ:ិយ:ិ:ស្ស:ន្ត:ិ** ។ ព្រោះភាវ: ជាទានដែលលោកមិនពោយ:ពាយនោះឯង ទើបឈ្មោះថា ជាទាន ដែលសមណ: ឬ ព្រាហ្មណ៍ទាំងឡាយ មិនតិះដៀលហើយ គឺ មិនបដិសេធហើយ ។ ព្រោះថា ក្នុងកាលណាក៏ដោយ សមណ: និង ព្រាហ្មណ៍ទាំងឡាយ ជាវិញ្ញ: រមែងមិនអំណោយបាបធម៌ មាន

មង្គលត្ថទីបនីប្រែ

*ការបៀតបៀនជាដើម ។ ច្រើនបទថា " **អបរិមាណានំ សត្តានំ អភយំ ទេតិ** " មានសេចក្តីថា ឈ្មោះថា រមែងឲ្យនូវភាពមិនមានភ័យ ដល់ពួកសត្វ សូម្បីទាំងអស់ ព្រោះការៈជាអ្នកមានអាជ្ញាក្នុងសត្វទាំងពួង បានទម្លាក់ចោលហើយ ។ ព្រោះភ័យអំពីព្រះអរិយសាវ័ក រមែងមិនមាន ដល់ជនណាមួយឡើយ ។ បទថា **អវេរំ** ប្រែថា ភាពមិនមានពៀរ ។ បទថា **អព្យាបជ្ឈំ** ប្រែថា ភាពជាអ្នកមិនមានទុក្ខ " ដូច្នេះ ។*

(២៣៨) អាចារ្យអ្នកចោទ គប្បីចោទ ថា " បញ្ចសីលប្រព្រឹត្តទៅ ក្នុងកាលទាំងពួង, មួយទៀត បញ្ចសីលនោះ មិនមែនជាទីកើតនៃវិមុត្តិ ដោយចំណែកមួយ, ចំណែក សរណគមន៍ មានកិរិយាឧបត្ថម្ភនៃ ព្រះពុទ្ធជាហេតុ ជាទីកើតឡើង នៃវិមុត្តិ ដោយចំណែកមួយ មែនពិត មិនមែនទេឬ?, ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ការៈនៃបញ្ចសីលថា មានផលច្រើនជាង សរណគមន៍ ក្នុងកូដទន្តសូត្រនោះ? " ។ ខ្ញុំ នឹងឆ្លើយ ។ ការៈនៃបញ្ចសីល មានផលច្រើនជាង សរណគមន៍ទុ+ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកត្រឹមតែសីល ៥ ប៉ុណ្ណោះ ។ ប៉ុន្តែ ព្រះអង្គ ត្រាស់សំដៅយកបញ្ចសីល ដែលបុគ្គលតាំងនៅ ក្នុងសរណៈហើយ ទើបរក្សា ។ ហេតុនោះ ក្នុងអដ្ឋកថាកូដទន្តសូត្រ

ចាបវិរតិមជ្ឈបានសំយមកថា

ព្រះអដ្ឋកថាចារ្យ ទើបពោលថា "សរណគមន៍ទុ:ឯង ប្រសើរជាង បញ្ចសីល ក៏ពិតមែន, ទោះជាដូច្នោះ បញ្ចសីលនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា មានផលច្រើន ដោយអំណាចសីលដែលបុគ្គលតាំងនៅ ក្នុងសរណ:ហើយ ទើបរក្សា ដូច្នេះ" ។

ដីកាកូដទន្តសូត្រនោះ ថា " បទថា **ជេដ្ឋកំ** គឺ ខ្ពង់ខ្ពស់ ។ ដោយ ២ បទថា **សរណ បតិដ្ឋាយ** នេះ ព្រះអដ្ឋកថាចារ្យ ពោលនូវភាព:នៃសីលនោះ គឺ សរណគមន៍ តាក់តែងហើយ" ។

អដ្ឋកថា កថាវត្ថុថា " វិរតិ ឈ្មោះថា ទាន ព្រោះអត្ថថា កាត់ទម្លាក់ និង ព្រោះអត្ថថា កាត់ផ្តាច់ ។ មែនពិត វិរតិនោះ កាលកើតឡើង រមែងកាត់ចោល និង រមែងកាត់ផ្តាច់ នូវចេតនាគ្រឿងទ្រុស្តសីល ពោលគឺ ហេតុដែលគួរខ្ជាច និង ហេតុដែលគួរកន្ត្រាក់ ខ្ជាចជាដើម ព្រោះហេតុនោះ វិរតិ នោះ ទើបឈ្មោះថា ទាន" ។

ដីកានៃកូដទន្តសូត្រ ថា " ពួកនៃធាតុ មាន **ទិ** ធាតុ ជាដើម ថា **ទា** ធាតុ ប្រព្រឹត្តទៅ ក្នុងអត្ថកថា កាត់ទម្លាក់ សម្រេចរូបជា **ទិយតិ** ។ ភាព:នៃសីលជាគុណជាត ឈ្មោះថា ទាន ព្រោះភាព:នៃសីលនោះ ជាអភ័យទាន, ម្យ៉ាងទៀត បុគ្គល រមែងចិញ្ចឹម គឺ រមែងរក្សា នូវពួកសត្វ មិនមានសេសសល់ ដោយចេតនាកម្មនោះ ព្រោះហេតុនោះ ចេតនាកម្មនោះ ឈ្មោះថា ទាន គឺសីល" ។

មង្គលត្ថទីបនីប្រែ

*ពួកនៃធាតុ មាន **ភូ** ជាតុជាដើម ថា " **ទេ** ធាតុ ប្រព្រឹត្ត ទៅ ក្នុងអត្ថថា ចិញ្ចឹម, ចេតនាកម្ម ណា រមែងចិញ្ចឹម គឺ រមែងរក្សា ព្រោះហេតុនោះ ចេតនាកម្ម នោះ ឈ្មោះថា អ្នកចិញ្ចឹម គឺ ចេតនាកម្ម អ្នករក្សា ។*

ចាបវិរតិមជ្ជចានសំយមកថា ចប់ ។

សូមអ្នកដឹកនាំខ្មែរ គ្រប់គណៈបក្ស ទាំងអស់
រួមសាមគ្គីគ្នា ឲ្យបានជាជាប់ខាត ដើម្បីបង្កើតនូវយុត្តិធម៌
ព្រោះបើមានយុត្តិធម៌ហើយ ពិតជានឹងមានសន្តិភាព
នៅក្នុងប្រទេសកម្ពុជា ។

ពណ៌នាអំពីសេចក្តីមិនប្រមាទ

(២៣៩) ធម៌មួយ ដែលជាសឹកសត្រូវ ដល់សេចក្តីប្រមាទ ឈ្មោះថា សេចក្តីមិនប្រមាទ ។ បណ្តាសេចក្តីប្រមាទ និង សេចក្តីមិនប្រមាទទាំង ២ យ៉ាងនោះ អាការ គឺការស្រវឹងទូទៅ ឈ្មោះថា សេចក្តីប្រមាទ ។ មែនពិត ព្រះមានព្រះភាគ [1] ទ្រង់ត្រាស់ ថា " បណ្តាសេចក្តីប្រមាទ និង សេចក្តីមិនប្រមាទ ទាំង ២ នោះ សេចក្តីប្រមាទ តើដូចម្តេច? ។ ការបណ្តោយចិត្ត ការឲ្យកម្លាំង ដល់ការបណ្តោយចិត្ត ដោយកាយទុច្ចរិត ក្តី ដោយវចីទុច្ចរិត ក្តី ដោយមនោទុច្ចរិត ក្តី ក្នុងកាមគុណទាំង ៥ ក្តី ឬ ការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនឆ្ងាប់ឆ្ងួន ការប្រព្រឹត្តិទំរន់ ការដាក់ចុះនូវធនុ: ការដាក់ចុះនូវធរុ: ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការធ្វេសប្រហែស ក្នុងការចម្រើន នូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាព យ៉ាងនេះណា, នេះហៅថា សេចក្តីប្រមាទ ។

ចាលីឧទ្ទកាវត្ថុវិភង្គ ចប់ ។

1- សុត្តន្តបិដក ភាគទី ៨២ ទំព័រទី ១៥១ ។

មជ្ឈលត្តនីបនីប្រែ

(២៤០) អដ្ឋកថាវិកង្ខ្ថា " ២ បទថា **ចិត្តស្ស ឱសារ្ជនា** គឺ ការមិនអត់សង្ក្ត់ចិត្ត ដោយសតិ ហើយបណ្ដោយចិត្តទៅ ក្នុងទីទាំងឡាយ មានប្រមាណប៉ុណ្ណេះនេះ, អធិប្បាយថា កិរិយា ប្រាសចាកសតិ ។ បទថា **ឱសារ្ជនានុប្បទានំ** បានដល់ កិរិយា ឲ្យកម្ចាំង ដល់ការបណ្ដោយ, អធិប្បាយថា ការបណ្ដោយចិត្តទៅ ញយៗ ។ ការមិនធ្វើដោយគោរព ដោយអំណាចការធ្វើ ដោយ មិនគោរព ដល់បុគ្គល ក្តី ដល់ទេយ្យធម៌ ក្តី ក្នុងការចម្រើន នូវ កុសលធម៌ទាំងឡាយ មានទាន ជាដើមនេះ ឈ្មោះថា ការមិនធ្វើ ដោយគោរព " ។

ដីកាឆដ្ឋវគ្គ ក្នុងឯកនិបាត អង្គុត្តរនិកាយថា " ការមិនធ្វើ ដោយគោរព ដល់បុគ្គល ក្តី ដល់ទេយ្យធម៌ ក្តី ក្នុងការប្រព្រឹត្តិនូវ កុសលធម៌ មានទានជាដើមនោះ ឈ្មោះថា **អសក្កច្ចកិរិយតា** ។ ការមាន នៃសេចក្តីជាប់តគ្នា ឈ្មោះថា ភាវៈនៃសេចក្តីព្យាយាម ប្រព្រឹត្តទៅរឿយៗ, ការធ្វើដោយភាវៈ នៃសេចក្តីព្យាយាម ដែល ប្រព្រឹត្តទៅរឿយៗ ឈ្មោះថា កិរិយាធ្វើដោយសេចក្តីជាប់តគ្នា, **សាតច្ចកិរិយា** នោះឯង ឈ្មោះថា ការធ្វើដោយសេចក្តីជាប់តគ្នា ។ កិរិយាធ្វើដោយជាប់តគ្នា មិនមាន ឈ្មោះថា ការធ្វើដោយសេចក្តី មិនជាប់តគ្នា ។ បទថា **អនដ្ឋិតកិរិយតា** គឺ ការធ្វើដោយមិនឈប់

ពណ៌នាអំពីសេចក្តីមិនប្រមាទ

មិនមាន បានដល់ ការធ្វើដោយគ្មានចន្ទោះ មិនមាន ឈ្មោះថា ភាវៈមិនមានការធ្វើដោយមិនឈប់ " ។

*(២៤១) អដ្ឋកថាវិភង្គថា "ការធ្វើដោយមិនឈប់ មិនមាន ឈ្មោះថា ភាវៈមិនមានការធ្វើ ដោយមិនឈប់ ។ ធម្មតា សត្ត បង្ហួយ (លូន) ទៅបានបន្តិចហើយ ក៏ឈប់បន្តិច មិនលូនទៅជាប់ តគ្នាទេ យ៉ាងណាមិញ, បុគ្គលឯណា ក្នុងថ្ងៃមួយ ថ្វាយទានក្តី ធ្វើការបូជា ក្តី ស្តាប់ធម៌ ក្តី បំពេញសមណធម៌ ក្តី ហើយ តមក អស់កាលដ៏យូរ ទើបបានធ្វើម្តងទៀត មិនបានញ៉ាំងកុសលទាំង នោះ ឲ្យប្រព្រឹត្តទៅ ជាប់តគ្នាឡើយ ក៏យ៉ាងជូច្នោះដែរ, កិរិយា ធ្វើនោះ របស់បុគ្គលនោះ ព្រះមានព្រះភាគ ត្រាស់ហៅថា ភាវៈ មិនមានការធ្វើ ដោយមិនជាប់តគ្នា ។ បទថា " **ឧលីនវុត្តិតា**" គឺ ឈ្មោះថា ភាវៈជាអ្នកប្រព្រឹត្តទំនន់ ព្រោះមិនមានសេចក្តីខ្ទះខ្ទែង ពោលគឺការធ្វើមិនមានចន្ទោះ ។ ភាវៈជាអ្នកមានសេចក្តីពេញចិត្ត ដោយអំណាចនៃសេចក្តីព្យាយាម ក្នុងការបំពេញកុសល បាន ទម្លាក់ចោសហើយ ឈ្មោះថា ភាវៈជាអ្នកមានធនូ: បានទម្លាក់ ចោលហើយ ។ កិរិយាទម្លាក់ចុះនូវធុរ: ដោយអំណាចនៃសេចក្តី ព្យាយាម ឈ្មោះថាភាវៈជាអ្នកមានធុរៈដាក់ចុះហើយ, អធិប្បាយ ថា ភាវៈជាអ្នកមានចិត្តចុះខ្ជិនថយ" ។ ការមិនមានកិរិយាតាំងនៅ*

មន្តលត្ថទីបនីប្រែ

ក្នុងការបំពេញកុសល ឈ្មោះថា កិរិយាមិនតាំងមាំ" ។

ដីកាឯកនិបាត អង្គុត្តរនិកាយថា "កិរិយាមិនប្រកបរឿយៗ ឈ្មោះថា ការមិនតាមប្រកប ។ ការមិនមាន នៃកិច្ចទាំងឡាយ មានកិរិយាគប់រកជាដើម ក្នុងកុសលធម៌ទាំងឡាយ ឈ្មោះថា អាការមានការមិនសេពគប់ជាដើម ។ សព្ទថា **បមទោ** ជាសព្ទសម្តែងដោយសរុប ។ សព្ទថា **បមជ្ជនា** ជាសព្ទសម្តែងអាការ ។ សព្ទថា **បមជ្ជិតត្តំ** ជាសព្ទសម្តែងនូវភាវ:" ។

(២៤២) អដ្ឋកថាវិភង្គ ថា " ការធ្វេសប្រហែស ឈ្មោះថា សេចក្តីប្រមាទ ។ ពាក្យថា **យោ ឯវរូបោ បមាទោ** នេះ ឈ្មោះថា ជាពាក្យសម្តែង នូវអាការ ព្រោះមិនមានទីបំផុត នៃការបរិយាយ អត្ត និង ការបរិយាយព្យញ្ជន:" ។

ដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ អធិប្បាយថា សេចក្តីប្រមាទ នេះឯណា ដែលតថាគតបានសម្តែងហើយ តាំងតែអំពីដើម, មួយទៀត សេចក្តីប្រមាទ ឯណាដទៃទៀត ដែលមានអាការ យ៉ាងដូច្នេះ មានជាតិ យ៉ាងដូច្នេះ ដែលដល់នូវ ការរាប់ថា សេចក្តីធ្វេសប្រហែស ដោយអំណាចនៃអាការ គឺ កិរិយាស្រវឹងទូទៅ ថា សេចក្តីប្រមាទ ដោយអំណាចនៃភាវ: ជា ធម្មជាតិ គឺការស្រវឹងទូទៅ, សេចក្តីស្រវឹងទូទៅនេះ តថាគត

ពណ៌នាអំពីសេចក្តីមិនប្រមាទ

ហៅថា សេចក្តីប្រមាទ ។ ក៏សេចក្តីប្រមាទនេះ បណ្ឌិត គប្បីជ្រាប ដោយលក្ខណៈថា មានការលះបង់សតិទៅ ក្នុងកាមគុណទាំង ៥ ជាលក្ខណៈ, មានការលះបង់នូវសតិទៅ ក្នុងកាមគុណទាំង ៥ នោះ ដូចគ្នាដែរ ជាអាការ " ។

(២៤៣) ក្នុងសេចក្តីប្រមាទ និង សេចក្តីមិនប្រមាទទាំង ២ យ៉ាងនោះ សេចក្តីប្រមាទ រមែងប្រព្រឹត្តទៅ ដើម្បីកិរិយាកើតឡើងនៃអកុសល និង ដើម្បីសេចក្តីសាបសូន្យនៃកុសល, សេចក្តីមិនប្រមាទ រមែងប្រព្រឹត្តទៅ ដើម្បីកិរិយាកើតឡើង នៃកុសល និង ដើម្បីសេចក្តីសាបសូន្យទៅនៃអកុសល ។ ដោយហេតុនោះ ក្នុងវគ្ត ទី៦ នៃឯកនិបាត អង្គុត្តរនិកាយ [1] ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ តថាគត រពឹងរកមិនឃើញ នូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុាំងពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅវិញក្តី ដូចជាសេចក្តីប្រមាទនេះ សោះឡើយ, ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលប្រមាទហើយ, ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង"

---

[1]- សុត្តន្តបិដក ភាគទី ៤០ ទំព័រទី ២១ ។

មន្ទលត្ថទីបនីប្រែ

និង ទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ តថាគត រំពឹងរកមិន យើញនូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ្ចុាំងពួកកុសលធម៌ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅវិញក្តី ដូចជាសេចក្តីមិនប្រមាទនេះសោះឡើយ, ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនប្រមាទហើយ, ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង, ពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង " ។

(២៤៤) អដ្ឋកថានៃសូត្រទាំង ២ នោះ ថា " បណ្តាពាក្យទាំងនោះ ក្នុងពាក្យថា **យថយិទំ ភិក្ខវេ បមាទោ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ភិក្ខវេ** ជាអាលបនៈ ។ អធិប្បាយថា សេចក្តីប្រមាទនេះ យ៉ាងណា ។ អាការ នៃសេចក្តីស្រវឹងទួទៅ ឈ្មោះថា សេចក្តីប្រមាទ ។ ពាក្យថា **ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តិ** នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃឈាន និង វិបស្សនា ។ ក៏កាលបើមគ្គ និង ផល កើតឡើងហើយ អស់រយៈមួយដង, ឈ្មោះថា សេចក្តីសាបសូន្យម្តងទៀត រមែងមិនមាន ។ សេចក្តីមិនប្រមាទ បណ្ឌិត គប្បីជ្រាប ដោយពិស្តារ

ដោយអំណាចនៃប្រតិបក្ស នៃសេចក្ដីប្រមាទ " ។

(២៤៥) ដីកានៃសូត្រទាំង ២ នោះថា " បទថា **ឥទំ** ជាបទសម្ដែង ដោយការខុសផ្ទាត់នៃលិङ្ग, ម្យ៉ាងទៀត បទថា **ឥទំ** នេះ ជាបទនិបាត ដូចជាបទថា **ឥទំ** ក្នុងសព្ទទាំងឡាយថា **យទិទំ** ដូច្នេះជាដើម ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **អយំ បមាទោតិ អត្ថោ** ។ កិរិយាដល់នូវសេចក្ដីប្រមាទ ឈ្មោះថា អាការនៃការស្រវឹងទូទៅ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងនូវភាវៈនៃសេចក្ដីប្រមាទជាធម៌មានទោស ដោយបទថា **បរិហាយន្តិ** នេះ ។ បទថា **បរិហាយន្តិ** នេះនោះ ព្រះអង្គទ្រង់សម្ដែង ដោយអំណាចនៃលោកិយធម៌ មិន មែនទ្រង់សម្ដែង ដោយអំណាចនៃលោកុត្តរធម៌ទេ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **ឧប្ផន្នា** ។បេ។ **ឥទំ** ដូច្នេះជាដើម ។ បុគ្គលរមែងស្រវឹងទូទៅ ដោយធម៌ទុ៎ះ មិនមាន ហេតុនោះ ធម៌ទុ៎ះ ទើបឈ្មោះថា អប្ផមាទ (ធម៌ដែលមិនមែនជាហេតុស្រវឹងទូទៅ) គឺ ធម៌ដែលជាប្រតិបក្ស ដល់សេចក្ដីប្រមាទ បានដល់ ការមិននៅ ប្រាសចាកសតិ ។ ពាក្យថា សេចក្ដីមិនប្រមាទទុ៎ះ ដោយសេចក្ដី ជាឈ្មោះ នៃសតិ ដែលតម្កល់នៅមាំជានិច្ច ។ ចំណែកសេចក្ដីប្រមាទ បណ្ឌិត គប្បីឃើញថា ជាការកើតឡើងនៃចិត្ត ជាផ្នែកខាងអកុសល ដែលជា

មន្ទលត្ថទីបនីប្រែ

ប្រតិបក្ស ដល់សតិ ឬ ដល់សតិ និង សម្បជញ្ញៈ យ៉ាងដូច្នេះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា បណ្ឌិត គប្បីជ្រាបសេចក្តីមិនប្រមាទ ដោយពិស្តារ ដោយអំណាចនៃភាវៈជាប្រតិបក្ស ដល់សេចក្តីប្រមាទ " ។

(២៤៦) សេចក្តីមិនប្រមាទនេះ ជាធម៌មានឧបការៈច្រើន ក្នុងធម៌ដែលមិនមានទោសទាំងឡាយ ព្រោះអត្ថថា "តែងប្រព្រឹត្តទៅ សូម្បីដើម្បីកិរិយាកើតឡើងនៃកុសល" ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ព្រះធម្មសេនាបតី កាលនឹងសម្តែងធម៌ ដល់ភិក្ខុទាំងឡាយ ទើបពោលថា " ម្នាលអ្នកដ៏មានអាយុទាំងឡាយ ធម៌មួយមានឧបការៈច្រើន ។ ធម៌មួយ មានឧបការៈច្រើន តើដូចម្តេច? ។ គឺសេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌មួយនេះ ជាធម៌មានឧបការៈច្រើន " ដូច្នេះ ។

បាលីទសុត្តរសូត្រ មកក្នុងបាដិកវគ្គ ។

(២៤៧) អដ្ឋកថាទសុត្តរសូត្រនោះ ថា " បណ្តាបទទាំងនោះ ព្រះថេរៈ សម្តែងសេចក្តីមិនប្រមាទ ដែលមានឧបការៈច្រើន ដែលជាប្រយោជន៍ទូទៅ ដោយបាលីថា **អប្បមាទោ កុសលេសុ ធម្មេសុ** ដូច្នេះ ។ មែនពិត ឈ្មោះថា សេចក្តីមិនប្រមាទនេះ ជាធម៌មានឧបការៈច្រើន ក្នុងធម៌ទាំងពួង ដែលឈ្មោះថាកុសលធម៌

ពណ៌នាអំពីសេចក្តីមិនប្រមាទ

ព្រោះអត្ថថា មិនមានទោស គឺ ក្នុងការបំពេញសីល, ក្នុងការ
សង្រួមឥន្ទ្រីយ៍, ក្នុងភាពជាអ្នកស្គាល់ប្រមាណ ក្នុងភោជន, ក្នុងការ
ប្រកបរឿយៗ នូវសេចក្តីភ្ញាក់រលឹក, ក្នុងធម៌ទាំង ៧ ប្រការ, ក្នុង
កិរិយាញ៉ាំងវិបស្សនា ឲ្យកាន់យកនូវគតិ (ដើម្បីបានមគ្គ និង ផល),
ក្នុងបដិសម្ភិទាទាំង ៤ មានអត្ថបដិសម្ភិទាជាដើម, ក្នុងធម្មក្ខន្ធ ៥
មានសីលក្ខន្ធជាដើម, ក្នុងហានៈ និង មិនមែនហានៈ, ក្នុងសមាបត្តិ
ដែលជាគ្រឿងនៅដ៏ធំ, ក្នុងអរិយសច្ច, ក្នុងពោធិបក្ខិយធម៌ មាន
សតិបដ្ឋាន ជាដើម, ក្នុងវិជ្ជាទាំង ៨ មាន វិបស្សនាញាណ ជា
ដើម ។ ដោយហេតុនោះឯង ព្រះមានព្រះភាគ កាលទ្រង់ប្រៀប
ធៀប នូវសេចក្តីមិនប្រមាទនោះ ដោយសេចក្តីឧបមាទាំងឡាយ
មានព្រះសាស្តា និង គន្ធង់ជើងនៃដំរីជាដើម ដោយនយជាដើមថា
ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានប្រមាណប៉ុន្មាន ទោះ
មិនមានជើង ក្តី មានជើង ២ ក្តី មានជើង ៤ ក្តី មានជើងច្រើន ក្តី
មានរូប ក្តី មិនមានរូប ក្តី មានសញ្ញា ក្តី មិនមានសញ្ញា ក្តី មាន
សញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ក្តី, ព្រះតថាគត បណ្ឌិត
ពោលថា ជាអ្នកប្រសើរបំផុតជាងសត្វទាំងឡាយនោះ យ៉ាងណា
មិញ, ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយ ឯណា នីមួយ
កុសលទាំងអស់នោះ មានសេចក្តីមិនប្រមាទជាមូល ប្រជុំរួមចុះ

មង្គលត្ថទីបនីប្រែ

ក្នុងសេចក្តីមិនប្រមាទ, សេចក្តីមិនប្រមាទ បណ្ឌិត ពោលថា ជាកំពូលនៃកុសលធម៌ទាំងឡាយនោះ ដូច្នេះ ទ្រង់ត្រាស់សរសើរហើយ នូវសេចក្តីមិនប្រមាទនោះ មានប្រការផ្សេងៗ ក្នុងអប្បមាទវគ្គ ក្នុងសំយុត្តនិកាយ ។ ព្រះថេរៈ រួបរួមសេចក្តីមិនប្រមាទទាំងអស់នោះ ដោយបទតែមួយបុណ្ណោះ ហើយពោលថា **អប្បមាទោ កុសលេសុ ធម្មេសុ** ។ ក៏ការៈនៃសេចក្តីមិនប្រមាទនោះ ជាធម៌មានឧបការៈច្រើន បណ្ឌិត គប្បីសម្តែង សូម្បីដោយអប្បមាទវគ្គ ក្នុងធម្មបទ ។ សូម្បីដោយរឿងព្រះបាទអសោក ក៏គប្បីសម្តែងបានដូចគ្នាដែរ ។

សេចក្តីសង្ខេបថា ព្រះរាជា ទ្រង់ព្រះនាមអសោក ទ្រង់ព្រះសណ្ដាប់នូវកថា របស់និគ្រោធសាមណេរ ថា សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់ យ៉ាងដូច្នេះជាដើម ហើយទ្រង់ត្រាស់ ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ ឈប់ប៉ុណ្ណេះសិនចុះ, លោកម្ចាស់ បានសម្តែងព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈ ដល់ញោមហើយ ដូច្នេះ ទ្រង់ជ្រះថ្លាហើយ ក្នុងសាមណេរ ទ្រង់ត្រាស់បញ្ជា ឲ្យសាងហើយនូវព្រះវិហារ ៨៤,០០០ ខ្នង ។ ការៈនៃសេចក្តីមិនប្រមាទជាធម៌មានឧបការៈច្រើន គឺកិក្ខុអ្នកដល់ព្រម ដោយកម្លាំង គប្បីសម្តែង គប្បីពោលសូម្បីដោយព្រះត្រៃបិដក ដោយប្រការដូច្នេះ ។

ពណ៌នាអំពីសេចក្តីមិនប្រមាទ

ព្រះធម្មកថិក កាលនាំមកនូវសូត្រ ឬ គាថាណាមួយ ដើម្បីសម្តែងនូវសេចក្តីមិនប្រមាទ គឺបុគ្គលណាមួយ មិនគួរពោលថា លោកស្ថិតនៅហើយ ក្នុងឋានៈដែលមិនគួរនាំមកហើយ, ជាអ្នកស្ទុះទៅហើយ ដោយទីដែលមិនមែនជាកំពង់ ។ ក្នុងការនាំយកនូវសូត្រ ឬគាថាមក ដើម្បីសម្តែងសេចក្តីមិនប្រមាទនេះ កម្ចាំង និង កម្ចាំងកំហែង របស់ព្រះធម្មកថិក ន៉ុះឯង ជាប្រមាណ " ។

(២៤៨) ជីកាទសុត្តរសូត្រនោះថា " ២ បទថា **សព្ចត្តកំ ឧបការកំ** គឺមានឧបការៈ ជល់សេចក្តីប្រតិបត្តិត្រឹមត្រូវ ដែលមានប្រយោជន៍គ្រប់បែបយ៉ាងមែនពិត ។ ឥឡូវនេះ ព្រះអដ្ឋកថាចារ្យពោលពាក្យថា **អយញ្ញិ** ដូច្នេះជាដើម ដើម្បីសម្តែងសេចក្តីនោះដោយពិស្តារ ។ បទថា **វិបស្សនាគព្ភគ្គណ្ហាបនេ** មានសេចក្តីថា វិបស្សនាជាន់ខ្ពស់ រមែងចាស់ក្ចា ជាបញ្ញា ជ៏មោះមុត និង ទូលំទូលាយ រមែងតក្ជាប់ ដោយមគ្គ យ៉ាងណាមិញ, ក្នុងការចម្រើនវិបស្សនា ដែលជាចំណែកខាងដើម ក៏យ៉ាងដូច្នោះដែរ ។ បទថា **អត្ថប្បដិសម្ភិទាទីសុ** គឺក្នុងបដិសម្ភិទាជាដើម ដែលព្រះយោគាវចរគប្បីឲ្យសម្រេច ។ អធិប្បាយថា ជាគ្រឿងឧបត្ថម្ភ និង គាំទ្រនូវបដិសម្ភិទាទាំងនោះ ។ សូម្បីក្នុងបទដទៃទៀត ក្រៅអំពីបទនេះ ក៏នយនេះដូចគ្នាដែរ ។ បទថា **ឋានាឋានេសុ** គឺក្នុងឋានៈ និង មិន

មជ្ឈលត្ថនីបនីព្យ

មែនហាន:ដែលបុគ្គលគប្បីដឹង ។ បទថា **មហាវិហារសមាបត្តិយំ** គឺ ក្នុងសមាបត្តិជាគ្រឿងនៅ មានឈាន ជាដើមដ៏ធំ ។ ព្រះអដ្ឋ-កថាចារ្យ រមែងសង្គ្រោះនូវ វិបស្សនាញាណ ទាំងឡាយ មានឫទ្ធិ ខាងផ្លូវចិត្ត ជាដើម ដោយ **អាទិ** សព្ទ ក្នុងបទថា **វិបស្សនាញា-ណាទីសុ** ។ ២ បទថា **អដ្ឋសុ វិជ្ជាសុ** គឺ ក្នុងវិជ្ជាទាំង ៨ ប្រការ ដែលមកហើយ ក្នុងអម្ពដ្ឋសូត្រ ។ ឯចាជាគ្រឿងប្រកបថា ដោយ ហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់ត្រាស់សរសើរ ។ បទថា **ន** ចានដល់ សេចក្តីមិនប្រមាទ ។ បទថា **ថាមសម្ជ្ជន្ត** គឺ អ្នក ប្រកបព្រម ដោយកម្លាំងនៃញាណ ។ បទថា **ទីបេត្វា** គឺ ប្រកាស ហើយថា សេចក្តីមិនប្រមាទ ជាធម៌មានឧបការ:ច្រើន ក្នុងកិរិយា ញុំងកុសលធម៌ទាំងឡាយ ឲ្យដល់ព្រម ដោយប្រការយ៉ាងនេះ ឯង, មានឧបការ:ច្រើន ដោយប្រការយ៉ាងនេះឯង ។ ព្រះអដ្ឋ-កថាចារ្យ ពោលពាក្យថា **យង្ហិ ញ្ចិ** ដូច្នេះជាដើម ដើម្បីសម្តែង ថា កិរិយាពោលទាញយកសេចក្តី ដែលជាបក្សពួក នៃធម៌ដែល មិនមានទោស ឯណា នីមួយ មកប្រមូលគ្នា ក្នុងសេចក្តីមិនប្រមាទ ក៏សមគួរ ដូច្នេះ" ។

(២៤៩) អដ្ឋកថាអប្បមាទវគ្គ ក្នុងមហាវគ្គសំយុត្ត ថា បណ្ឌិត គប្បីឃើញសេចក្តី ក្នុងពាក្យថា **ឯវមេវ ខោ** នេះ ថា

ពណ៌នាអំពីសេចក្តីមិនប្រមាទ

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរលើស ជាងសត្វទាំងពួង យ៉ាងណាមិញ, សេចក្តីមិនប្រមាទ ដែលជាអ្នកឲ្យធ្វើ (ជាតួអង្ត) ជាកំពូលនៃកុសលធម៌ទាំងឡាយទាំងពួង ក៏យ៉ាងនោះដែរ ។ សួរថា ក៏សេចក្តីមិនប្រមាទន៉ុះ ត្រឹមតែជាលោកិយ:, ចំណែក កុសលធម៌ ទាំងឡាយ ជាលោកុត្តរ: ក៏មាន, មួយទៀត សេចក្តីមិនប្រមាទនេះ ជាកាមាវចរប៉ុណ្ណោះ, ចំណែក កុសលធម៌ទាំងឡាយ ជាធម៌ប្រព្រឹត្តទៅ ក្នុងភូមិ ៤ មិនមែនទេឬ?, សេចក្តីមិនប្រមាទនេះ ជាកំពូលនៃកុសលធម៌ទាំងនោះ បានយ៉ាងដូចម្តេចទៅ? ។ ឆ្លើយថា សេចក្តីមិនប្រមាទនេះ ជាកំពូល នៃកុសលធម៌ទាំងនោះ ព្រោះអត្ថថា ជាហេតុឲ្យបានចំពោះ ។ មែនពិត កុសលធម៌ទាំងនោះ គឺបុគ្គលតែងបាន ដោយសេចក្តីមិនប្រមាទ, ព្រោះហេតុនោះ សេចក្តីមិនប្រមាទនោះ ទើបឈ្មោះថា ជាកំពូលៃនកុសលធម៌ទាំងឡាយនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះតម្រាស់នេះ ថា **សព្វេ តេ អប្ឋមាទមូលកា** ដូច្នេះជាដើម ដោយប្រការដូច្នេះ" ។

អដ្ឋកថាទុតិយវគ្គ ក្នុងទសកនិបាត អង្គុត្តរនិកាយ ក៏យ៉ាងដូច្នោះដែរ ។

(២៥០) ជីកានៃសូត្រទាំង ២ នោះថា "សេចក្តីមិនប្រមាទ

ដែលប្រព្រឹត្តទៅ ដោយអំណាចការវៀរចាកធម៌ ដែលគួរវៀរចាក និង ការញ៉ាំងធម៌ ដែលគួរឲ្យដល់ព្រម ឲ្យដល់ព្រមនោះៗ ថា អកុសលធម៌ទាំងឡាយនេះគឺបុគ្គលគប្បីលះបង់, កុសលធម៌ទាំងឡាយនេះ គឺបុគ្គលគប្បីឲ្យដល់ព្រម ដូច្នេះ ឈ្មោះថា សេចក្ដីមិនប្រមាទដែលជាអ្នកឲ្យធ្វើ ។ បទថា ***ឯសោ*** *គឺទាញយក* ***អប្បមាទោ*** *ចូលមក ។ សេចក្ដីមិនប្រមាទនេះ ជាលោកិយៈ តែម៉្យាងប៉ុណ្ណោះ, មិនមែនជាលោកុត្តរៈទេ ។ ក៏ព្រះអដ្ឋកថាចារ្យ ពោលនូវសេចក្ដីមិនប្រមាទនុ៎ះឯង ដោយពាក្យថា* ***អយញ្ច ឯសោ*** *។ បទថា* ***តេសំ*** *គឺ នៃធម៌ដែលប្រព្រឹត្តទៅ ក្នុងភូមិ ៤ ទាំងឡាយ ។ បទថា* ***បដិលាភកត្តេន*** *គឺ ព្រោះអត្ថថា ជាហេតុឲ្យបានចំពោះ” ។*

(២៥១) បទថា “ ***សត្តុហត្ថិបទាទីហិ*** *” គឺ ដោយសេចក្ដីឧបមាទាំង ១០ ប្រការ ពោលគឺ ព្រះតថាគត គន្លងជើង នៃដំរី ជំបូលនៃផ្ទះកំពូល ក្លាំពាក់ ចន្ទក្រហម ផ្កាម្លិះ ស្ដេចចក្រពត្តិ រស្មី នៃព្រះចន្ទ ព្រះអាទិត្យ និង សំពត់អ្នកដែនកាសី ។ សេចក្ដីឧបមាទាំងអស់នោះ អ្នកសិក្សាគួរត្រួតមើល ក្នុងមហាវគ្គសំយុត្ត ។*

សេចក្ដីឧបមា ដោយគន្លងជើងនៃដំរី ក្នុងមហាវគ្គសំយុត្ត អ្នកសិក្សាគប្បីជ្រាប ដូចតទៅនេះ ថា “ ម្នាលភិក្ខុទាំងឡាយ បទជាតទាំងឡាយ របស់សត្វទាំងឡាយ ដែលត្រាច់ទៅលើផែនដី

ពណ៌នាអំពីសេចក្តីមិនប្រមាទ

ឯណាមួយ, បទជាត ទាំងអស់នោះ រមែងដល់នូវការរួមចុះ ក្នុងគន្ធងជើងនៃដំរី, មនុស្សលោក ពោលថា គន្ធងជើងនៃដំរី ជាស្នាមជើងដែលធំជាង ស្នាមជើងនៃសត្វទាំងឡាយនោះ ព្រោះគន្ធងជើងដំរី ជាគន្ធងជើងធំ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយ ឯណាមួយ, កុសលធម៌ទាំងអស់នោះ មានសេចក្តីមិនប្រមាទជាមូល រួមចុះ ក្នុងសេចក្តីមិនប្រមាទ, សេចក្តីមិនប្រមាទ បណ្ឌិត តែងពោលថា ជាកំពូលនៃកុសលធម៌ទាំងឡាយនោះ ក៏យ៉ាងដូច្នោះដែរ " ។

(២៥២) អដ្ឋកថាមហាវគ្គសំយុត្ត និង ទសកនិបាត ក្នុងអង្គុត្តរនិកាយ និង អដ្ឋកថាមហាហត្ថិបទោបម្មសូត្រ ក្នុងមូល-បណ្ណាសក: ថា " បណ្តាបទទាំងនោះ បទថា **ជង្គ្លានំ** គឺ ដែលមានប្រក្រតីត្រាច់ទៅ លើផ្ទៃនៃផែនដី ។ បទថា **បាណានំ** គឺ នៃពួកសត្វដែលមានជើង ។ គន្ធងជើង ឈ្មោះថា បទជាត ។ ២ បទថា **សមោធានំ គច្ឆន្តិ** គឺ រមែងដល់នូវការតាំងចុះ បានដល់ការរួមចុះ ។ បទថា **អគ្គមក្ខាយតិ** គឺ ដែលមនុស្សលោក តែងពោលថា ប្រសើរបំផុត ។ ២ បទថា **យទិទំ មហន្តត្តេន** គឺ គន្ធងជើង នៃដំរីនេះ មនុស្សលោក តែងពោលថា ជារបស់ប្រសើរ ព្រោះជាគន្ធងជើងដែលធំ, អធិប្បាយថា មិនពោលថា ជារបស់

មន្តលត្ថទីបនីប្រែ

ប្រសើរ ដោយអំណាចនៃគុណឡើយ ដូច្នេះ" ។

ដីកាមហាវារវគ្គសំយុត្ត ជាដើមនោះថា "បទថា **ជន្តលានំ** គឺ ដែលមានប្រក្រតីត្រាច់ទៅលើផែនដី ។ ក៏ **ជន្តលៈ** សព្ទ ក្នុងបទថា **ជន្តលានំ** នេះ ជាសព្ទបរិយាយអំពីផែនដី ដោយភាពជាធម្មជាតិស្មើគ្នា ដោយភាពជារបស់រឹង, មិនមែនជាសព្ទប្រាប់នូវប្រទេសដ៏ឆ្ងាយ ដែលមិនប្រាកដមានឡើយ ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **បឋវីតលសញ្ហារីនំ** ដូច្នេះ ។ ពាក្យថា **សបាទកឃ្យាណានំ** ព្រះអដ្ឋកថាចារ្យ ពោលធ្វើឲ្យបានពិស្តារ ព្រោះលោកកំពុងតែពោល នូវគន្ធងជើង ។ បទថា **សមោជានំ** គឺ នូវភាវៈ គឺការជ្ងាប់ចុះ ព្ធដ៏ខាងក្នុង ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **ឧជានំ ឧបក្ខេបំ** ។ អធិប្បាយថា បុគ្គល គឃ្យីនាំចូលទៅរួបរួម ដូច្នេះ" ។

(២៥៣) សេចក្តីមិនប្រមាទ គឺបុគ្គលគឃ្យីបំពេញ មែនពិត ព្រោះសេចក្តីមិនប្រមាទនោះ ជាធម៌មានឧបការៈច្រើន ដោយប្រការដូច្នេះ ។ មែនពិត បុគ្គលអ្នកបំពេញសេចក្តីមិនប្រមាទនោះ រមែងបានសម្រេចនូវគុណ មានការមិនភ័យខ្លាច ចំពោះមរណៈ ជាដើម ។ ព្រោះហេតុនោះ ក្នុងតតិយបណ្ណាសកៈ នៃចតុក្កនិបាត អង្គុត្តរនិកាយ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុ

ពណ៌នាអំពីសេចក្តីមិនប្រមាទ

ទាំងឡាយ ភិក្ខុគប្បីបំពេញសេចក្តីមិនប្រមាទ [១] ដោយហេតុ ៤ យ៉ាង ។ ដោយហេតុ ៤ យ៉ាង តើដូចម្តេច? ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវកាយទុច្ចរិត ចូរចម្រើន នូវកាយសុចរិតវិញ ទាំងកុំបីប្រមាទ ក្នុងការលះបង់នូវកាយទុច្ចរិត ចម្រើននូវកាយសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវវចីទុច្ចរិត ចូរចម្រើន នូវវចីសុចរិតវិញ ទាំងកុំបីធ្វេសប្រហែស ក្នុងការលះបង់វចីទុច្ចរិត ចូរចម្រើន នូវវចីសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវមនោទុច្ចរិត ចូរចម្រើននូវមនោសុចរិតវិញ ទាំងកុំបីធ្វេសប្រហែស ក្នុងការលះបង់មនោទុច្ចរិត ចម្រើនមនោសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវមិច្ឆាទិដ្ឋិ ចូរចម្រើននូវសម្មាទិដ្ឋិ វិញ ទាំងកុំបីធ្វេសប្រហែស ក្នុងការលះបង់មិច្ឆាទិដ្ឋិ ចម្រើនសម្មាទិដ្ឋិនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពេលណា ភិក្ខុ លះបង់នូវកាយទុច្ចរិត ចម្រើននូវកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់នូវមនោទុច្ចរិត ចម្រើនមនោសុចរិត លះបង់នូវមិច្ឆាទិដ្ឋិ ចម្រើននូវសម្មាទិដ្ឋិ ហើយ, ក្នុងពេលនោះ ភិក្ខុនោះ តែងមិនខ្វាចសេចក្តី

១- សុត្តន្តបិដក ភាគទី ៤២ ទំព័រទី ៣០១ ។

មន្តលត្ថនីបនីប្រែ

ស្ថាប់ ដែលប្រព្រឹត្តទៅ ក្នុងខាងមុខ " ដូច្នេះ និង ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនប្រមាទ គឺការថែរក្សាចិត្ត ដោយសតិ គឺ ភិក្ខុ គប្បីធ្វើ តាមសមគួរដល់ខ្លួន ក្នុងហេតុ ៤ យ៉ាង ។ ហេតុ ៤ យ៉ាង តើដូចម្តេចខ្លះ? ។ គឺ សេចក្តីមិនប្រមាទ បានដល់ ការថែរក្សាចិត្ត ដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួនថា ចិត្ត របស់អាត្មាអញ កុំត្រេកត្រអាលទៅ ក្នុងធម៌ទាំងឡាយដែលគួរត្រេកត្រអាលឡើយ ១ ។ សេចក្តីមិនប្រមាទ បានដល់ ការថែរក្សាចិត្ត ដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួនថា ចិត្ត របស់អាត្មាអញ កុំប្រទូស្ត ក្នុងធម៌ទាំងឡាយ តែគួរប្រទូស្តឡើយ ១ ។ សេចក្តីមិនប្រមាទ បានដល់ ការថែរក្សាចិត្ត ដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួនថា ចិត្ត របស់អាត្មាអញ កុំភាន់ច្រឡំ ក្នុងធម៌ទាំងឡាយ ដែលគួរភាន់ច្រឡំឡើយ ១ ។ សេចក្តីមិនប្រមាទ បានដល់ ការថែរក្សាចិត្ត ដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួនថា ចិត្ត របស់អាត្មាអញកុំស្រវឹង ក្នុងធម៌ទាំងឡាយដែលគួរស្រវឹងឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណា បើភិក្ខុ មានចិត្តមិនត្រេកអរ ក្នុងធម៌ដែលគួរត្រេកអរ ព្រោះប្រាសចាករាគៈ, មានចិត្តមិនប្រទូស្ត ក្នុងធម៌ដែលគួរប្រទូស្ត ព្រោះប្រាសចាកទោសៈ, មានចិត្តមិនវង្វេង ក្នុងធម៌ដែលគួរវង្វេង

ពណ៌នាអំពីសេចក្តីមិនប្រមាទ

ព្រោះប្រាសចាកមោហ:, មានចិត្តមិនស្រវឹង ក្នុងធម៌ដែលគួរ ស្រវឹង ព្រោះប្រាសចាកពីសេចក្តីស្រវឹងហើយ, ក្នុងកាលនោះ ភិក្ខុនោះ រមែងមិនញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនដល់នូវ សេចក្តីតក់ស្ទុត ទាំងមិនប្រព្រឹត្តទៅ ព្រោះហេតុតែពាក្យ របស់ សមណ:" ។

(២៥៤) អដ្ឋកថាឋានសូត្រថា " បណ្តាបទទាំងនោះ បទ ថា **យតោ ខោ** គឺ ក្នុងកាលឯណា ។ បទថា **សម្ឆរាយិកស្ស** នុ៉ះ គ្រាន់តែជាទេសនា ។ ក៏ព្រះខីណាស្រព រមែងមិនភ័យខ្លាច ចំពោះសេចក្តីស្លាប់ដែលប្រព្រឹត្តទៅក្នុងសម្ឆរាយភព និងប្រព្រឹត្ត ទៅ ក្នុងទិដ្ឋធម្ម ។ ក៏ព្រះខីណាស្រពនោះ ព្រះមានព្រះភាគ ទ្រង់ ព្រះបំណងយកហើយ ក្នុងទីនេះ ។ ប៉ុន្តែអាចារ្យពួកខ្លះ ពោលថា " ព្រះមានព្រះភាគ ទ្រង់ព្រះបំណងយកព្រះអរិយបុគ្គលទាំងពួង ចាប់តាំងអំពីព្រះសោតាបន្ន ជាដើម ទ្បើងទៅ ព្រោះព្រះបាលី ថា **សម្មាទិដ្ឋិ ភាវិតា** ដូច្នេះ" ។

អដ្ឋកថាអារក្ខសូត្រថា "បទថា **អត្តរូបេន** បានដល់ តាម សមគួរ គឺ តាមគួរ ដល់ខ្លួន, អធិប្បាយថា តាមសេចក្តីប្រាថ្នា ចំពោះប្រយោជន៍សុខ ។ បទថា **រជនីយេសុ** បានដល់ ជាបច្ចុ័យ នៃរាគ: ។ បទថា **ធម្មេសុ** គឺក្នុងសភាវ:ទាំងឡាយ, អធិប្បាយថា

មន្តលត្ថទីបនីប្រែ

ក្នុងអារម្មណ៍ ដែលជាទីប្រាថ្នាទាំងឡាយ ។ នយ ក្នុងបទទាំងពួងបណ្ឌិត គប្បីជ្រាប យ៉ាងដូច្នេះដែរ ។ បទថា **នច្ចម្ភតិ** គឺ តែងមិនញាប់ញ័រ ដោយអំណាចទិដ្ឋិ ។ សូម្បីក្នុងបទ ដ៏សេសសល់ទាំងឡាយ ក៏នយនេះ ដូចគ្នាដែរ ។ ច្រើនបទថា **ន ច បន សមណវចនហេតុបិ គច្ចតិ** មានសេចក្តីថា ភិក្ខុមិនបានលះបង់ទិដ្ឋិ របស់ខ្លួនហើយ ប្រព្រឹត្តទៅ ដោយអំណាចទិដ្ឋិ នៃបុគ្គលទាំងនោះ សូម្បីព្រោះពាក្យ របស់សមណៈទាំងឡាយ អ្នកមានប្រក្រតីពោលរឿងផ្សេង ជាហេតុឡើយ ។ សូម្បីក្នុងទីនេះ ក៏ព្រះមានព្រះភាគ ទ្រង់ព្រះបំណងយកព្រះខីណាស្រព ដូចគ្នាដែរ " ។

(២៥៥) សេចក្តីមិនប្រមាទន៉ុះ ជាធម៌មានឧបការៈច្រើនក្នុងធម៌ដែលមិនមានទោសទាំងឡាយ រមែងនាំគុណ មានការមិនខ្វាច ចំពោះមរណៈជាដើម មកឲ្យដល់បុគ្គល អ្នកបំពេញសេចក្តីមិនប្រមាទនោះ យ៉ាងដូច្នេះឯង, ព្រោះហេតុនោះ សេចក្តីមិនប្រមាទ ទើបឈ្មោះថា ជាមង្គល ។ សូម្បីក្នុងអដ្ឋកថា ក៏លោកសំដៅយកសេចក្តីនេះឯង ទើបពោលថា សេចក្តីមិនប្រមាទនោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុបានសម្រេចកុសលធម៌ មានប្រការផ្សេងៗ ឬ ព្រោះជាហេតុបានសម្រេចអមតធម៌ យ៉ាងដូច្នេះហើយ សម្តែងបទនៃព្រះសូត្រ ថា កាលបើបុគ្គលមិនប្រមាទ ជា

ពណ៌នាអំពីសេចក្តីមិនប្រមាទ

អ្នកមានសេចក្តីព្យាយាម ដុតកិសេលឲ្យក្តៅ និង ថា សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ ដូច្នេះជាដើម ។ បណ្តាបទ នៃព្រះសូត្រទាំង ២ នោះ ២ បទថា ***អប្បមត្តស្ស អាតាបិនោ*** *នេះ មកហើយ ក្នុងព្រះសូត្រជាច្រើនកន្លែង ។ ម្យ៉ាងទៀត ២ បទនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងវិមុត្តិសូត្រ ក្នុងបញ្ចក-និបាត អង្គុត្តរនិកាយ ថា កាលបើបុគ្គលមិនប្រមាទហើយ មានព្យាយាមញ្ចុំងកិសេលឲ្យក្តៅ មានចិត្តបញ្ជូនទៅហើយ រស់នៅ, ចិត្ត ដែលមិនទាន់រួចផុតស្រឡះ រមែងរួចផុតស្រឡះ ឬ អាសវៈទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏រមែងដល់នូវការអស់ទៅ " ។*

(២៥៦) អដ្ឋកថានៃព្រះសូត្រ ដែលមក ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយ ជាដើមថា "ឈ្មោះថា ជាអ្នកមិនប្រមាទ ព្រោះការមិននៅប្រាសចាកសតិ ។ ឈ្មោះថា ជាអ្នកមានព្យាយាម ញ្ចុំងកិលេសឲ្យក្តៅ ព្រោះដុតកំដៅកិលេស ដោយសេចក្តីព្យាយាម ។ ឈ្មោះថា ជាអ្នកមានខ្លួនបានបញ្ជូនទៅហើយ, អធិប្បាយថា ជាអ្នកមានខ្លួនបានផ្ញើទៅហើយ ព្រោះជាអ្នកមិនអាឡោះអាល័យ ក្នុងកាយ និង ជីវិត " ។

ដីកានៃព្រះសូត្រនោះ ថា " សេចក្តីព្យាយាម ឈ្មោះថា អាតបៈ ព្រោះអត្ថថា ជាគ្រឿងដុត និង ជាគ្រឿងដុតកំទេច នូវ

មន្ទលត្ថទីបនីប្រែ

កិលេសទាំងឡាយ ព្រោះហេតុនោះ ទើបព្រះអដ្ឋថាចារ្យ ពោលថា ***វីរិយាតាបេន អាតាបិនោ*** *។ អធិប្បាយថា ជាអ្នកមានសេក្តីព្យាយាម ។ បទថា* ***បេសិតត្តស្ស*** *គឺ ជាអ្នកមានចិត្តបានចូលទៅកាន់សេចក្តីសម្រេចប្រយោជន៍ តាមដែលខ្ជួនប្រាថ្នា " ។*

(២៥៧) ពាក្យជាគាថានេះ ថា ៖

" សេបក្តីមិនប្រមាទ ជាផ្លូវនៃសេបក្តីមិនស្លាប់, សេបក្តីប្រមាទ ជាផ្លូវនៃសេបក្តីស្លាប់, ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់, ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាស្លាប់បាត់ទៅហើយ " *ដូច្នេះ*

គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងធម្មបទ ក៏មាន ។ រុក្ខទេវតា ដែលអាស្រ័យនៅ លើដើមទំលាប់ ដែលមិនមានក្រម៉ កាលឲ្យឱវាទ ដល់ព្រះរាជាព្រះនាមបញ្ចាល: បានពោលហើយ ក្នុងភណ្ឌុតិណ្ឌុកជាតក ក្នុងទីបញ្ចប់ នៃតឹសនិបាត ក៏មាន ។

(២៥៨) អដ្ឋកថានៃជាតកនោះ ថា " បណ្តាបទទាំងនោះ ការមិននៅប្រាសចាកសតិ ឈ្មោះថា សេចក្តីមិនប្រមាទ ។ ២ បទថា ***អមតំ បទំ*** *គឺ ជាផ្លូវឲ្យទៅដល់ បានដល់ ជាហេតុបានសម្រេចអមត: គឺព្រះនិព្វាន ។ ២ បទថា* ***មច្ចុនោ បទំ*** *គឺ ជាហេតុនៃសេចក្តីស្លាប់ ។ ក៏បុគ្គលដែលប្រមាទហើយ កាលមិន*

ពណ៌នាអំពីសេចក្តីមិនប្រមាទ

អាច ដើម្បីនឹងចម្រើនវិបស្សនាហើយ សម្រេចនូវភាពជាអ្នកមិនមានបដិសន្ធិបាន ឈ្មោះថា រមែងកើត និង ស្លាប់ ក្នុងសំសារវដ្ត រឿយៗ, ព្រោះហេតុនោះ សេចក្តីមិនប្រមាទ ទើបឈ្មោះថា ជាផ្លូវនៃសេចក្តីមិនស្លាប់ ។ បទថា ***ន មីយន្តិ*** *មានសេចក្តីថា បុគ្គលអ្នកមិនប្រមាទ ចម្រើនវិបស្សនា ហើយដល់នូវភាពជាអ្នកមិនមានបដិសន្ធិ ឈ្មោះថា រមែងមិនស្លាប់ ព្រោះភាវៈជាអ្នកមិនកើតហើយ ក្នុងសំសារវដ្ត រឿយៗ ។ ២ បទថា* ***យេ បមត្តា*** *ជាដើមមានសេចក្តីថា បពិត្រព្រះមហារាជ បុគ្គលទាំងឡាយឯណា ជាអ្នកប្រមាទហើយ, បុគ្គលទាំងឡាយនោះ ព្រះអង្គគប្បីឃើញ ថាដូចជាបុគ្គលដែលស្លាប់ទៅហើយ ។ សួរថា ព្រោះហេតុអ្វី? ។ ឆ្លើយថា ព្រោះភាពនៃបុគ្គលនោះ ជាអ្នកមិនញ្ចាំងកិច្ចឲ្យសម្រេច ។ អធិប្បាយថា ក៏សេចក្តីសង្ស៊ឹម សេចក្តីប្រាថ្នា ឬ សេចក្តីតាំងចិត្តមាំថា អាត្មាអញ នឹងឲ្យទាន នឹងរក្សាសីល នឹងធ្វើឧបោសថកម្ម នឹងធ្វើនូវកម្មដ៏ល្អ ដូច្នេះ រមែងមិនមានសូម្បីដល់បុគ្គលដែលបានស្លាប់ទៅហើយ ព្រោះជាអ្នកមានវិញ្ញាណទៅប្រាសហើយ, សូម្បីបុគ្គលដែលប្រមាទហើយ ក៏រមែងមិនមានសេចក្តីសង្ស៊ឹម ជាដើមនោះ ព្រោះមិនមានសេចក្តីមិនប្រមាទ ព្រោះហេតុដូច្នេះនោះ បុគ្គលទាំង ២ ពួកនោះ ទើបដូចគ្នាតែមួយ ដោយពិត" ។*

មន្ថលត្ថទីបនីប្រែ

អដ្ឋកថាធម្មបទថា " សូម្បីសេចក្តីគិត តែមួយថា អាត្មាអញ នឹងថ្វាយទាន នឹងរក្សាសីល នឹងធ្វើនូវឧបោសកម្ម ដូច្នេះ រមែងមិនកើតឡើង ដល់បុគ្គលអ្នកប្រមាទ ដែលជាគ្រហស្ថ ជាមុនសិន, សូម្បីជាបព្វជិតទាំងឡាយ ក៏រមែងមិនកើតសេចក្តីគិត តែមួយ ថា អាត្មាអញ នឹងបំពេញវត្ត មានអាចារិយវត្ត និងឧបជ្ឈាយវត្ត ជាដើម នឹងសមាទាននូវធុតង្គទាំងឡាយ នឹងចម្រើនភាវនា ដូច្នេះដែរ, បុគ្គលអ្នកប្រមាទហើយទាំងនោះ នឹងមានអ្វីជាហេតុ ឲ្យឧុសផ្សេងពីគ្នា ចាកបុគ្គលដែលបានស្លាប់បាត់ទៅ ហើយហ្នឹ ?" ។

ពណ៌នាអំពីសេចក្តីមិនប្រមាទ ចប់ ។

(២៥៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់មង្គល ៣ ប្រការ គឺ ការវៀរចាកបាប ១ ការស្រងួមចាកកិរិយាផឹកទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ១ ដោយព្រះគាថានេះឯង ដោយប្រការ ដូច្នេះ ។ ក៏ភិក្ខុទាំងឡាយ ក្នុងពេលនេះ ភាគច្រើន រមែងសូត្រ តាមអំណាច ***ន*** *គណៈ ថា* ***រតិវិ*** *" ។*

ប៉ុន្តែ ***ន*** *គណៈ រមែងមិនត្រឹមត្រូវ ព្រោះភាវៈនៃពាក្យថា "****ន ស្នាទុម្ហា****" ជាពាក្យដែលលោកអាចារ្យ បានហាមឃាត់ហើយ ក្នុងពាក្យនេះ ថា "****ស*** *គណៈ និង* ***ន*** *គណៈ រមែងមិនមាន អំពី*

ពណ៌នាអំពីសេចក្តីមិនប្រមាទ

*ខាងមុខអក្សរខាងដើម ក្នុងបទទាំងឡាយដែលមានអក្សរ ៨ តួ, **យ** គណៈ រមែងមានបាន ខាងមុខ ៤ អក្សរ ក្នុងព្រឹទ្ធិ ឯណា, ព្រឹទ្ធិនោះ ឈ្មោះ ថា " វត្តធនូ " ដូច្នេះ , **ជ** គណៈ ថា " **រតីវិ** " នុ៉ះឯង រមែងត្រឹមត្រូវ ព្រោះលោកមិនបានហាមឃាត់ហើយ ។ សូម្បី **យ** គណៈ ថា " **រតីបា** " រមែងត្រឹមត្រូវ ព្រោះពាក្យថា " **យោណ្ណវា** " ដូច្នេះ និង រមែងសមដោយ **យ** គណៈថា " **ចធម្មេ** " ដូច្នេះ ។ សូម្បីពាក្យជាគាថានេះ ក៏ជាបឡាវត្ត ដោយ ប្រការដូច្នេះឯង ។*

ពណ៌នាសេចក្តីនៃគាថា ទី ៦ ចប់ ។

ប្រែបច់ ថ្ងៃសុក្រ ៤ រោច ខែទុតិយាសាធ បញ្ចស័ក ព. ស. ២៥៣៦
ត្រូវនឹង ថ្ងៃ ទី ៦ ខែសីហា ឆ្នាំ ១៩៩៣ វេលាយប់

♣ ♣ ♣

សាមគ្គីជាកម្លាំង សាមគ្គីនាំឲ្យបានសេចក្តីសុខ
ប្រទេសជាតិ ដែលខ្វះការសាមគ្គី មិនបានសុខឡើយ ។

ពណ៌នាសេចក្ដីនៃគាថា ទី ៧

(២៦០) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ៧ ដូចតទៅនេះ ៖ ភាពជាអ្នកធ្ងន់ ឈ្មោះថា **គារវ:** ។ ភាពជាអ្នកប្រព្រឹត្ដបន្ទាបខ្លួន ឈ្មោះថា **និវាត:** ។ សេចក្ដីសន្ដោស ឈ្មោះថា **សន្ទុដ្ឋី** ។ ភាពគឺការដឹងឧបការ: ដែលលោកបានធ្វើហើយ ឈ្មោះថា កតញ្ញូតា ។ កិរិយាស្ដាប់ធម៌ ក្នុងសម័យ ឈ្មោះថា **ការស្ដាប់ធម៌តាមកាល** ។

បទថា "**ឯតំ**" មានសេចក្ដីថា ម្នាលទេវតា ចូរអ្នកប្រកាន់យកថា " សេចក្ដីគោរព ១ សេចក្ដីប្រព្រឹត្ដិបន្ទាបខ្លួន ១ សេចក្ដីត្រេកអរដោយវត្ថុរបស់ខ្លួន ១ ភាពជាអ្នកដឹងឧបការ: ដែលលោកបានធ្វើហើយ ១ ការស្ដាប់ ១, កម្មទាំង ៥ យ៉ាង មានសេចក្ដីគោរព ជាដើមនេះ ជាមង្គលដ៏ឧត្ដម " ។

សេចក្ដីសង្ខេប ក្នុងគាថានេះ មានតែប៉ុណ្ណេះ ។

ចំណែក សេចក្ដីពិស្ដារ ក្នុងគាថានេះ មានដូចតទៅនេះ ៖

* * *

ពណ៌នាអំពីសេចក្តីគោរព

(២៦១) បុគ្គលទាំងឡាយ ដែលគួរធ្វើឲ្យធ្ងន់ ឈ្មោះថា គ្រូ ។ ព្រោះហេតុនោះ ក្នុងសទ្ទនីតិ ទើបព្រះអគ្គវង្សមហាថេរៈ ពោលថា " **គរុ** ធាតុ ប្រព្រឹត្តទៅ ក្នុងអត្ថថាខ្ពង់ខ្ពស់ " ។ បុគ្គលដែលគួរដល់សេចក្តីគោរពទាំងឡាយ មានមាតា និង បិតា ជាដើម ឈ្មោះថា គ្រូ ។ មែនពិត បុគ្គល ដែលគួរគោរពទាំងឡាយនោះ អ្នកប្រាជ្ញទាំងឡាយហៅថា " គ្រូ " ព្រោះអត្ថថា " អណ្តែតឡើង គឺ រះឡើង បានដល់ បើកឡើង គឺ ជាអ្នកខ្ពង់ខ្ពស់ហើយ គឺជាអ្នកប្រាកដជាក់ស្តែង " ។ មួយទៀត មាតា និង បិតា ជាដើមនោះ លោកហៅថា " គ្រូ " ព្រោះអត្ថថា ធ្ងន់ ដូចជាឆត្រថ្ម ។ ភាវៈ នៃបុគ្គលដែលធ្ងន់ទាំងឡាយ ឈ្មោះថា **គារវៈ** បានដល់ កិរិយាធ្វើឲ្យធ្ងន់ ក្នុងបុគ្គលដែលគួរគោរព មានមាតា និង បិតាទាំងឡាយ ជាដើមនោះ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា "កិរិយាធ្វើឲ្យធ្ងន់ គឺ ភាពជាអ្នកមានសេចក្តីគោរព តាមសមគួរ ក្នុងបុគ្គលទាំងឡាយ មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវ័ករបស់ព្រះតថាគត អាចារ្យ ព្រះឧបជ្ឈាយ៍ មាតា បិតា បងប្អូនប្រុស និង បងប្អូនស្រី ជាដើម ដែលគួរដល់ការប្រកប ដោយកិរិយាធ្វើឲ្យធ្ងន់ ឈ្មោះថា សេចក្តីគោរព " ។ សេចក្តីគោរពនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា " **ជាមង្គល** " ព្រោះជាហេតុ នៃ

មង្គលត្ថទីបនីប្រែ

ឥដ្ឋផល មានការទៅកាន់សុគតិភពជាដើម ។ ក៏ភាវៈនៃសេចក្តីមិនគោរពនោះ មិនមែនជាមង្គល គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយការត្រាស់សំដែង នូវភាវៈនៃសេចក្តីគោរពនោះ ជាមង្គល ។ មែនពិត សេចក្តីមិនគោរព គប្បីជ្រាបថា មិនមែនជាមង្គល ព្រោះជាហេតុនៃអនិដ្ឋផល មានការទៅកាន់ទុគ្គតិជាដើម ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ដល់សុភមាណព ទើបទ្រង់ត្រាស់ ថា ៖

" ម្នាលមាណព ក៏ស្ត្រី ឬ បុរសពួកខ្លះ [១] ក្នុងលោកនេះ ជាអ្នកវ៉ែនតាវ៉ែង មានមានះក្រៃលែង (មើលងាយគេ) មិនសំពះនូវបុគ្គលដែលគួរសំពះ មិនក្រាកទទួលបុគ្គលដែលគួរក្រាកទទួល មិនឲ្យអាសនៈ ដល់បុគ្គលដែលគួរដល់អាសនៈ មិនឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈ ដល់បុគ្គលដែលគួរធ្វើសក្ការៈ មិនធ្វើសេចក្តីគោរព ដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អាន ដល់បុគ្គលដែលគួររាប់អាន មិនបូជា ដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញ យ៉ាងនេះ បានកាន់ខ្ជាប់មក យ៉ាងនេះ បុគ្គលនោះ លុះទំលាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើត ក្នុងកំណើតតិរច្ឆាន

១- សុត្តន្តបិដក ភាគទី ២៨ ទំព័រទី ៦៤ ។

ពណ៌នាអំពីសេចក្ដីគោរព

ប្រេតវិស័យ អសុរកាយ នរក, បើបុគ្គលនោះ ទំលាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ មិនបានទៅកើត ក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ទេ, បើបានត្រឡប់មកកាន់ភាពជាមនុស្សវិញ ក្រោយមក កើតក្នុងទីណាៗ រមែងជាអ្នកមានត្រកូលថោកទាប ក្នុងទីនោះៗ ។ ម្នាលមាណព បុគ្គលដែលរឹងត្អឹង មើលងាយ ។លម។ មិនបូជាដល់បុគ្គលដែលគួរបូជា នេះឈ្មោះថា ជាបដិបទាប្រព្រឹត្តទៅ ដើម្បីមានត្រកូលថោកទាប ។

ម្នាលមាណព មួយទៀត ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនរឹងត្អឹង មិនមើលងាយ សំពះនូវបុគ្គលដែលគួរសំពះ ក្រោកទទួល នូវបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈ ដល់បុគ្គលដែលគួរឲ្យអាសនៈ ឲ្យផ្លូវ ដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈ ដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្ដីគោរព ដល់បុគ្គលដែលគួរធ្វើសេចក្ដីគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាបុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្ជួនបំពេញយ៉ាងនេះ បានកាន់ខ្ជាប់មកយ៉ាងនេះ បុគ្គលនោះ លុះទំលាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិ សួគ៌ ទេវ-លោក, បើបុគ្គលនោះ ទំលាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ មិនទៅកើត ក្នុងសុគតិ សួគ៌ ទេវលោកទេ, បើបានត្រឡប់

មង្គលត្ថទីបនីប្រែ

មកកាន់ភាពជាមនុស្ស ក្រោយមក កើតក្នុងទីណាៗ រមែងជាអ្នកមានត្រកូលដ៏ខ្ពង់ខ្ពស់ ក្នុងទីនោះៗ ។ ម្នាលមាណព បុគ្គលដែលមិនរឹងត្អឹង មិនមើលងាយ ។បេ។ រមែងបូជានូវបុគ្គលដែលគួរបូជា នេះ ឈ្មោះថា ជាបដិបទាប្រព្រឹត្តទៅ ដើម្បីមានត្រកូលខ្ពង់ខ្ពស់ " ដូច្នេះ ។

បាលីក្នុងចូឡកម្មវិភង្គសូត្រ ក្នុងចតុត្ថវគ្គ នៃឧបរិបណ្ណាសកៈ ។

(២៦២) ន័យ មកក្នុងអដ្ឋកថាចូឡកម្មវិភង្គសូត្រនោះ ថា " បទថា ***អភិវាទេតព្វំ*** *គឺ បុគ្គល ដែលគួរដល់ការអភិវាទ បានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬ ព្រះអរិយសាវ័ក ។ សូម្បីក្នុងបុគ្គលដែលគួរក្រោកទទួលជាដើម ក៏ន័យនេះដូចគ្នាដែរ ។ បទថា* ***សមត្តេន*** *គឺ ដែលខ្លួនបានបំពេញហើយ ។ បទថា* ***សមាទិន្នេន*** *គឺ ដែលខ្លួនកាន់ខ្ជាប់ហើយ គឺពាល់ត្រូវហើយ ។ បទថា* ***យទិទំ*** *មានសេចក្ដីថា កម្ម គឺភាពជាអ្នករឹងត្អឹង មានមានះក្រៃលែងនេះឯណា, បដិបទានេះ " ។*

ដីកានៃចូឡកម្មវិភង្គសូត្រនោះ ថា " បទថា ***សមត្តេន*** *គឺ ដែលអាច បានដល់ ដែលមានសមត្ថភាព ។ អធិប្បាយថា កម្មនោះ ជាកម្មអាច ដើម្បីនឹងឲ្យផល ដោយប្រការណា, ព្រោះកម្មដែលខ្លួនបានធ្វើ គឺ បានសន្សំទុកហើយ ដោយប្រការនោះ ។*

ពណ៌នាអំពីសេចក្ដីគោរព

ក៏កម្មប្រាកដដូច្នោះ ឈ្មោះថា មិនមានខ្វះខាត ដោយកិច្ចរបស់ខ្លួន ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា គឺខ្លួនបំពេញហើយ ។ ក្នុងបទថា **សមាទិន្នេន** នេះ ការកាន់ខ្ជាប់ គឺការពាល់ត្រូវ ដោយ តណ្ហា និង ទិដ្ឋិ ឈ្មោះថា ការសមាទាន ព្រោះហេតុនោះ ទើប ព្រះអដ្ឋកថាចារ្យ ពោលថា ដែលខ្លួនកាន់ខ្ជាប់ហើយ គឺ ដែលខ្លួន ពាល់ត្រូវហើយ ។ ឈ្មោះថា បដិបទា ព្រោះវិគ្រោះថា ជាគ្រឿង ធ្វើដំណើរទៅកាន់សុគតិ ឬ ទុគ្គតិ នៃបុគ្គល បានដល់ កម្ម " ។

(២៦៣) ម្យ៉ាងទៀត សេចក្ដីគោរព ឈ្មោះថា ជាមង្គល ព្រោះជាហេតុបានសម្រេច នូវភាពជាអ្នកមិនវិនាសសាបសូន្យ ។ ដោយហេតុនោះ ទើបទេវតា មួយអង្គ ពោលហើយ ក្នុងសំណាក់ នៃព្រះមានព្រះភាគ ថា " បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ ៧ ប្រការនេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសាន្យ ដល់ភិក្ខុ ។ ធម៌ទាំង ៧ ប្រការនោះ តើដូចម្តេចខ្លះ? ។ គឺ ភាពជាអ្នកគោរព ក្នុងព្រះសាស្តា ១ ភាពជាអ្នកគោរពក្នុងព្រះធម៌ ១ ភាពជាអ្នក គោរពក្នុងព្រះសង្ឆ ១ ភាពជាអ្នកគោរពក្នុងការសិក្សា ១ ភាព ជាអ្នកគោរព ក្នុងសមាធិ ១ ភាពជាអ្នកគោរព ក្នុងសេចក្ដីមិន ប្រមាទ ១ ភាពជាអ្នកគោរពក្នុងការធ្វើបដិសណ្ឋារៈ ១ ។ បពិត្រ ព្រះអង្គដ៏ចម្រើន ធម៌ទាំង ៧ ប្រការនេះ រមែងប្រព្រឹត្តទៅ ដើម្បី

មន្ទលត្ថទីបនីប្រែ

មិនសាបសន្យ ដល់ភិក្ខុ " ។ ទេវតាអង្គនោះ លុះបានថ្ថែងយ៉ាងនេះហើយ ក៏បាត់ហើយ ក្នុងទីនោះឯង ។

ចំណែកព្រះសាស្តា ក្នុងថ្ថៃស្អែកឡើង ទ្រង់បានត្រាស់ នូវពាក្យដែលទេវតានោះពោលហើយ ដល់ភិក្ខុទាំងឡាយ ហើយទ្រង់ត្រាស់គាថាទាំងឡាយ ២ នេះ ក្នុងអប្បមាទសូត្រ ក្នុងចតុត្ថវគ្គ នៃបឋមបណ្ណាសក: ក្នុងសត្តកនិបាត អង្គុត្តរនិកាយ [1] ថា ៖

ភិក្ខុ មានសេបក្តីព្យាយាមជាគ្រឿងុតកម្ទៅកិលេស មានសេបក្តីគោរពព្រះសាស្ទាផង មានសេបក្តីគោរពព្រះធម៌ផង មានសេបក្តីគោរព ដ៏ក្លៀវក្លា បំពោះព្រះសង្ឆផង មានសេបក្តីគោរព បំពោះសមាធិផង មានសេបក្តីគោរព ដ៏ក្លៀវក្លា បំពោះការសិក្សាផង មានសេបក្តីគោរព បំពោះសេបក្តីមិនប្រមាទផង មានសេបក្តីគោរព បំពោះការធ្វើបដិសណ្ឋារៈផង មិនគ្ជរនឹងសាបស្ងន្យឡើយ រមែងស្ថិតនៅ ក្នុងទីជិតនៃព្រះនិញ្ជន ។

(២៦៤) អដ្ឋកថានៃអបរិហានសូត្រ ក្នុងចតុត្ថវគ្គ នៃបឋមបណ្ណាសក: ក្នុងឆក្កនិបាត អង្គុត្តរនិកាយ ថា " បណ្ណាសេចក្តីគោរពទាំង ៧ យ៉ាងនោះ ការធ្វើសេចក្តីគោរព ក្នុងព្រះសាស្តា

---

[1]- សុត្តន្តបដិក ភាគទី ៤៧ ទំព័រ ៥៦ ។

ពណ៌នាអំពីសេចក្ដីគោរព

ឈ្មោះថា **សត្ថុគារវតា** ។ សេចក្ដីគោរព ក្នុងលោកុត្តរធម៌ទាំង ៩ ប្រការ ឈ្មោះថា **ធម្មគារវតា** ។ សេចក្ដីគោរព ក្នុងព្រះសង្ឆ ឈ្មោះថា **សង្ឆគារវតា** ។ ការធ្វើសេចក្ដីគោរព ក្នុងសិក្ខាទាំង ៣ យ៉ាង ឈ្មោះថា **សិក្ខាគារវតា** ។ សេចក្ដីគោរព ក្នុងសេចក្ដីមិនប្រមាទ ឈ្មោះថា **អប្ឌមាទគារវតា** ។ សេចក្ដីគោរព ក្នុងការធ្វើបដិសណ្ឋារៈ ២ យ៉ាង ដោយអំណាចនៃ ធម៌ និង អាមិស ឈ្មោះថា **បដិសណ្ឋារគារវតា** ។

គប្ឍីជ្រាបវិនិច្ឆ័យ ក្នុងគាថា ដូចតទៅនេះ ៖ ព្រះសាស្ដា ជាទីគោរព របស់ភិក្ខុនោះ មាន ហេតុនោះ ភិក្ខុនោះ ឈ្មោះថា មានព្រះសាស្ដាជាទីគោរព ។ ធម៌ ជាទីគោរពរបស់ភិក្ខុនោះ មាន ហេតុនោះ ភិក្ខុ នោះ ឈ្មោះថា មានធម៌ជាទីគោរព ។ បទថា **ឥ**ព្ធ**គារវ**ោ គឺ មានសេចក្ដីគោរពដ៏ខ្លាំងក្លា ។ សេចក្ដីគោរព ក្នុងការធ្វើបដិសណ្ឋារៈ មាន ដល់ភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុ នោះ ឈ្មោះថា មានសេចក្ដីគោរព ក្នុងការធ្វើបដិសណ្ឋារៈ " ។

អដ្ឋកថាអប្ឌមាទវគ្គ ក្នុងធម្មបទ ថា " ជាទគាថា ថា **អ**ក**ត្ថ**ោ **ប**រ**ិ**ហ**ានាយ** មានសេចក្ដីថា ភិក្ខុនោះ គឺ អ្នកប្រាកដ ដូច្នោះ ជាអ្នកមិនគួរ ដើម្បីនឹងសាបសូន្យ ចាកធម៌ គឺសមថៈ និង វិបស្សនា ឬ ចាកមគ្គ និង ផល គឺថា រមែងសាបសូន្យ ចាកមគ្គ

មន្ទលត្ថទីបនីប្រែ

ទាំងឡាយ ក៏ទេដែរ ទាំងមិនបានសម្រេចនូវមគ្ត និង ផល ដែល ខ្ជួនមិនទាន់បានសម្រេច ក៏ទេដែរ ។ បាទគាថាថា ***និញានស្សេវ សន្តិកេ*** *មានសេចក្តីថា រមែងមាន ក្នុងទីជិត សូម្បីនៃកិលេស បរិនិញាន សូម្បីនៃអនុបាទាបរិនិញាន ដោយពិត" ។*

(សេចក្តីមិនគោរពក្នុងព្រះរតនត្រៃ)

(២៦៥) ក៏ព្រោះកាលបើសេចក្តីមិនគោរព គឺខ្ញុំបានពោលទុកជាមុនហើយ, សេចក្តីគោរព ក៏រមែងយល់បាន ដោយងាយដែរ ហេតុនោះ ខ្ញុំ នឹងប្រមូលការពណ៌នាអំពីសេចក្តីមិនគោរព មកទុកជាមុន ។ ពាក្យនេះ ព្រះអដ្ឋកថាចារ្យ បានពោលហើយ ក្នុងអដ្ឋកថាឆក្កនិទ្ទេស ក្នុងខុទ្ទកវិភង្ត និង ក្នុងអដ្ឋកថាឆក្កនិទ្ទេស ក្នុងសង្គីតិសូត្រ ថា ៖

" ភិក្ខុ ឯណា កាលបើព្រះសាស្តា ទ្រង់ព្រះធរមាននៅ ទ្បើយ, មិនបានទៅកាន់ទីឧបដ្ឋាន ក្នុងកាលទាំង ៣ , កាលបើ ព្រះសាស្តា មិនទ្រង់ឆ្ងងព្រះបាទុក (មិនពាក់ស្បែកជើង) ស្តេច យាងចង្ក្រម, (ភិក្ខុនេះ) ពាក់ស្បែកជើង ដើរចង្ក្រម, កាលបើព្រះ សាស្តា ទ្រង់ស្តេចចង្ក្រម លើទីចង្ក្រមទាប, (ភិក្ខុនេះ) ដើរចង្ក្រម លើទីចង្ក្រមខ្ពស់, កាលបើព្រះសាស្តាទ្រង់គង់នៅ ញ្ជង៏ខាងក្រោម, (ភិក្ខុនេះ) នៅញ្ជង៏ខាងលើ គ្រង (ចីពរ) គ្របស្មាទាំងសងខាង

ពណ៌នាអំពីសេចក្តីគោរព

បាំងធត្រ ពាក់ស្បែកជើង ស្រង់ទឹក បន្ទោបង់ខច្ចារ: ឬ បស្សាវ: ក្នុងទីដែលព្រះសាស្តាទ្រង់ទតព្រះនេត្រឃើញ ឬ ក៏កាលបើព្រះសាស្តា ទ្រង់ស្តេចបរិពាន្ធបាត់ទៅហើយ, ភិក្ខុនេះ មិនទៅថ្វាយបង្គំព្រះចេតិយ ធ្វើនូវសេចក្តីមិនគោរពគ្រប់បែបយ៉ាង តាមដែលបានពោលហើយ ក្នុងទីដែលព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញ ក្នុងទីជាទីប្រាកដ នៃព្រះចេតិយ, ភិក្ខុ នេះ ឈ្មោះថា មិនគោរព ក្នុងព្រះសាស្តា ។

មួយទៀត ភិក្ខុ ណា, កាលបើគេប្រកាសការស្តាប់ធម៌, មិនទៅ ដោយគោរព មិនស្តាប់ធម៌ដោយគោរព (គិតតែ) សិងលក់ ឬក៏ អង្គុយនិយាយគ្នាលេង មិនរៀន មិនចាំទុក មិនប្រាប់ដោយគោរព, ភិក្ខុ នេះ ឈ្មោះថា មិនគោរព ក្នុងព្រះធម៌ ។

មួយទៀត ភិក្ខុ ណា គឺភិក្ខុជាថេរ: មិនបាននិមន្តហើយ (ក៏) សម្តែងធម៌ ប្រាប់នូវបញ្ហា ដើរ ឈរ អង្គុយ បៀតត្រសៀតនូវភិក្ខុ ទាំងឡាយដែលចាស់ៗ យកសំពត់រឹតក្បាលជង្គង់ ឬក៏យកដៃ ត្របោមក្បាលជង្គង់ គ្រង (ចីពរ) គ្របស្មាទាំងសងខាង បាំងធត្រ ពាក់ស្បែកជើង នៅកណ្តាលជំនុំព្រះសង្ឆ, ភិក្ខុ នេះ ឈ្មោះថា មិនគោរព ក្នុងព្រះសង្ឆ ។ មែនពិត កាលបើភិក្ខុធ្វើសេចក្តីមិនគោរព សូម្បីក្នុងភិក្ខុមួយរូប ក៏ឈ្មោះថា រមែងមិនធ្វើ

សេចក្តីគោរព ក្នុងព្រះសង្ឆ ដូចគ្នាដែរ " ។

*(២៦៦) ដីកាសង្ខ្តីតិសូត្រថា " កម្ម ដែលភិក្ខុបានធ្វើហើយ ចំពោះព្រះចេតិយ ក៏ដូចជាកម្មដែលភិក្ខុបានធ្វើហើយ ចំពោះព្រះសាស្តាដែរ យ៉ាងណាមិញ, កម្ម ដែលភិក្ខុបានធ្វើហើយ ខាងមុខនៃព្រះចេតិយ ក៏ដូចជាកម្មដែលភិក្ខុបានធ្វើហើយ ខាងមុខនៃព្រះសាស្តា ដូចគ្នាដែរ ក៏យ៉ាងដូច្នោះ ព្រោះហេតុនោះ ព្រះអដ្ឋកថា-ចារ្យ ទើបពោលពាក្យថា **ឋានិ ពុ្ធ ០ ០ ០** ដូច្នេះជាដើម ។ ២ បទថា **សក្ខ ០ ០ ០** គឺ ញ្ជាំងសេចក្តីមិនគោរព ឲ្យកើតឡើងហើយចូលទៅរក ។ កាលបើចំណែកមួយនៃសិក្ខា គឺភិក្ខុធ្វើឲ្យកម្រើកហើយ និង សេចក្តីមិនគោរព គឺភិក្ខុបានធ្វើហើយ, សិក្ខារមែងកម្រើក និង សេចក្តីមិនគោរព ក៏ឈ្មោះថា គឺភិក្ខុបានធ្វើហើយ ក្នុងសិក្ខាទាំងអស់ដែរ, ការសមាទានទូវសំវរៈ រមែងមានដោយការប្រជុំគ្នា, ការបែកធ្លាយនៃសំវរៈ រមែងមាន ដោយអវយវៈ យ៉ាងណាមិញ, កាលបើភិក្ខុធ្វើសេចក្តីមិនគោរព សូម្បីក្នុងភិក្ខុមួយរូបហើយ ក៏ឈ្មោះថា រមែងធ្វើសេចក្តីមិនគោរព ក្នុងព្រះសង្ឆ ដូចគ្នា ក៏យ៉ាងដូច្នោះដែរ " ។*

(២៦៧) អដ្ឋកថាកសរ្យបសំយុត្ត ក្នុងនិទានវគ្គ ថា " ភិក្ខុណា កាលដើរទៅ កាន់លានព្រះចេតិយ ជាំងឆត្រ ពាក់ទ្រនាប់

ពណ៌នាអំពីសេចក្តីគោរព

ជើង ដើរក្រឡេកមើលទៅផ្លូវផ្សេង និយាយបណ្តើរ, ភិក្ខុ នេះ ឈ្មោះថា មិនគោរព ក្នុងព្រះសាស្តា ។ ភិក្ខុ ណា, កាលបើគេ ប្រកាសពេលស្តាប់ធម៌, មានពួកភិក្ខុកំលោះ និងសាមណេរ ចោម រោមហើយ អង្គុយក្តី ធ្វើកិច្ចទាំងឡាយផ្សេងៗ ទៀត មានវកម្ម ជាដើមក្តី អង្គុយលក់ ក្នុងសាលាស្តាប់ធម៌ក្តី ឬក៏ ជាអ្នកមានចិត្ត រវើរវាយ អង្គុយនិយាយរឿងផ្សេងៗ, ភិក្ខុ នេះ ឈ្មោះថា មិន គោរព ក្នុងព្រះធម៌ ។ ភិក្ខុ ណា ទៅកាន់ទីឧបដ្ឋានព្រះថេរៈហើយ មិនបានថ្វាយបង្គំ អង្គុយយកដៃ ទៅត្របោមក្បាលជង្គង់ ឬក៏ យកសំពត់មករឹតក្បាលជង្គង់ ឬក៏ ធ្វើការគ្រវាសដៃ និង ជើង ជទៃទៀត គឺព្រះថេរៈមិនបាននិមន្តហើយ ក៏និយាយ ក្នុងសំណាក់ នៃភិក្ខុទាំងឡាយដែលចាស់, ភិក្ខុ នេះ ឈ្មោះថា មិនគោរព ក្នុង ព្រះសង្ឆ " ។

អដ្ឋកថាសង្គីតិសូត្រ ថា " ក៏ភិក្ខុ កាលមិនញ្ញាំងសិក្ខាទាំង ៣ យ៉ាង ឲ្យបានបរិបូណ៌ន៉ុះឯង ឈ្មោះថា មិនគោរពក្នុងសិក្ខា" ។

ជីកាសង្គីតសូត្រថា "ភិក្ខុ ដែលឈ្មោះថា មិនធ្វើឲ្យបរិបូណ៌ ក្នុងសិក្ខា សូម្បីព្រោះហេតុត្រឹមតែការមិនអើពើប៉ុណ្ណោះ ឈ្មោះថា មិនគោរពក្នុងសិក្ខា ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា កាលមិនឲ្យបរិបូណ៌ន៉ុះឯង ឈ្មោះថា មិនមានសេចក្តីគោរព

មន្ថលត្ថទីបនីប្រែ

ក្នុងសិក្ខា ដូច្នេះ " ។

អដ្ឋកថាកស្សបសំយុត្តថា " ភិក្ខុ អ្នកមិនញ្ញាំងសមាបត្តិ ៨ ឲ្យកើតឡើង ឬក៏ មិនធ្វើសេចក្តីព្យាយាម ដើម្បីប្រយោជន៍ ដល់ការញ្ញាំងសមាបត្តិទាំង ៨ នោះ ឲ្យកើតឡើង ឈ្មោះថា ជាអ្នកមិនគោរព ក្នុងសមាធិ " ។

អដ្ឋកថាសង្គីតសូត្រថា " ភិក្ខុ អ្នកមិនចំរើនធម៌ ដែលមានសេចក្តីមិនប្រមាទជាលក្ខណៈ ឈ្មោះថា មិនគោរព ក្នុងសេចក្តីមិនប្រមាទ ។ ភិក្ខុ អ្នកមិនធ្វើបដិសណ្ឋារៈ សូម្បីទាំង ២ យ៉ាង ឈ្មោះថា មិនគោរព ក្នុងការធ្វើបដិសណ្ឋារៈ ។ សេចក្តីគោរពបណ្ឌិតគប្បីជ្រាប ដោយអំណាចនយ ដែលផ្ទុយអំពីគ្នា នឹងពាក្យដែលបានពោលមកហើយ " ។

ដីកាសង្គីតិសូត្រនោះថា "ធម៌ ដែលមានសេចក្តីមិនប្រមាទជាលក្ខណៈ ឈ្មោះថា សម្មាបដិបត្តិ ។ បទថា **ទុវិធំ** គឺ មាន ២ យ៉ាង ដោយអំណាចធម៌ និង អាមិស " ។

(២៦៨) បទទាំង ២ គឺ សណ្ឋារៈ ១ បដិសណ្ឋារៈ ១ ដោយសេចក្តី ជាបទតែមួយ ។ ពិតមែនដូច្នោះ ក្នុងចតុត្ថវគ្គនៃតតិយបណ្ណាសកៈ ក្នុងទុកិបាត អង្គុត្តរនិកាយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រ ទី១ ថា " ម្នាលភិក្ខុទាំងឡាយ ការរាក់

ពណ៌នាអំពីសេចក្ដីគោរព

ទាក់ទាំងឡាយនេះ [១] មាន ២ យ៉ាង, ការរាក់ទាក់ ២ យ៉ាង តើដូចម្តេចខ្លះ?, គឺ ការរាក់ទាក់ដោយអាសិម ១ ការរាក់ដោយ ធម៌ ១, ម្នាលភិក្ខុទាំងឡាយ ការរាក់ទាក់ មាន ២ យ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ បណ្ដាការរាក់ទាក់ទាំង ២ យ៉ាងនេះ ការរាក់ ទាក់ដោយធម៌នេះ ប្រសើរជាង " យ៉ាងដូច្នេះ និង ទ្រង់ត្រាស់ព្រះ សូត្រទី ២ ថា " ម្នាលភិក្ខុទាំងឡាយ បដិសណ្ឋារៈ ទាំងឡាយ នេះ មាន ២ យ៉ាង, បដិសណ្ឋារៈ ២ យ៉ាង តើដូចម្តេចខ្លះ?, គឺ បដិសណ្ឋារៈ ដោយអាមិស ១ បដិសណ្ឋារៈ ដោយធម៌ ១ " ដូច្នេះ ជាដើម ។

(២៦៩) អដ្ឋកថានៃសូត្រទាំង ២ នោះ ថា " ការបិទបាំង ដោយអំណាចការបិទបាំងនូវទោស របស់ខ្លួន និង អ្នកដទៃ ដោយ បច្ច័យទាំងឡាយ ៤ ឈ្មោះថា ការរាក់ទាក់ ដោយអាមិស ។ ការ បិទបាំង ដោយធម៌ ឈ្មោះថា ការរាក់ទាក់ ដោយធម៌ ។ ពាក្ស ត្រឹមតែឧបសគ្គ ជាសេចក្ដីប្លែកគ្នា ក្នុងគាថា ទី ២ " ។

អដ្ឋកថាសង្គ្ដីតិសូត្រថា "លោកសន្ធិវាសនេះ មានប្រហោង ដោយហេតុ ២ យ៉ាង គឺ ដោយអាមិស ១ ដោយធម៌ ១, ការ បិទបាំង នូវប្រហោង នៃលោកសន្ធិវាសនោះ ដោយអាមិស និង

១-សុត្តន្តបិដក ភាគទី ៤០ ទំព័រទី ២០៨ ។

មន្ទលត្ថទីបនីប្រែ

ដោយធម៌ ដោយប្រការដែលប្រហោងនោះ នឹងប្រាកដមិនបានដូចជាការបិទបាំងនូវកៅអី ដោយគ្រឿងកម្រាលដូច្នោះឯង ឈ្មោះថា បដិសណ្ឋារៈ ។ ក៏បណ្តាបដិសណ្ឋារៈ ទាំង ២ យ៉ាងនោះ ការសង្គ្រោះដោយអាមិស ឈ្មោះថា អាមិសបដិសណ្ឋារៈ ។ ភិក្ខុអ្នកធ្វើអាមិសបដិសណ្ឋារៈនោះ សូម្បីមិនកាន់យក នូវរបស់ដ៏ល្អហើយ ឲ្យដល់មាតា និង បិតាទាំងឡាយ ដល់វេយ្យាវច្ចករ អ្នកបម្រើភិក្ខុ ដល់ព្រះរាជា និង ដល់ពួកចោរ ក៏សមគួរ ។ ព្រោះថា កាលបើរបស់ដ៏ល្អ គឺភិក្ខុពាល់ត្រូវហើយឲ្យ, ព្រះរាជា និង ពួកចោរ រមែងធ្វើនូវសេចក្តីវិនាសក៏មាន ធ្វើឲ្យដល់នូវការអស់ទៅនៃជីវិតក៏មាន, កាលបើរបស់ដ៏ល្អ គឺភិក្ខុមិនបានពាល់ត្រូវហើយឲ្យទៅ, ព្រះរាជា និង ពួកចោរទាំងនោះ រមែងមានចិត្តត្រេកអរ ។ ក៏ក្នុងការធ្វើបដិសណ្ឋារៈនេះ គប្បីសំដែងរឿងទាំងឡាយ មានរឿងព្រះបាទចោរនាគ ជាដើម ។ ការសង្គ្រោះ ដោយធម៌ យ៉ាងនេះ គឺការឲ្យឧទ្ទេស ការពណ៌នាបាលី ការសំដែងធម៌ ដោយសេចក្តីគោរព ឈ្មោះថា ធម្មបដិសណ្ឋារៈ ។

ដីកាសង្គីតិសូត្រនោះ ថា " លោកសន្និវាសនេះ មានប្រហោង ដោយហេតុ ២ យ៉ាង គឺ ដោយអាមិស ដែលខ្ជួនមិនបាន ១ ដោយធម៌ យ៉ាងដូច្នោះឯង ១, ក៏ការបិទ គឺ ការបិទបាំង

ពណ៌នាអំពីសេចក្តីគោរព

បានដល់ ការញ៉ុក នូវប្រហោង គឺ រន្ធ គឺ កន្ទែងដែលបែកធ្លាយ ដែលមាននៅ ក្នុងចន្លោះ នៃខ្លួន និង បុគ្គលដទៃ ព្រោះមិនបាន អាមិស និង ធម៌ ឈ្មោះថា បដិសណ្ឋារៈ ។ ២ បទថា ***អគ្គំ អគ្គហេតូ*** *គឺ មិនចាប់យកនូវរបស់ដ៏ល្អដើម្បីខ្លួន ។ ការសំដែង បាលី និង អដ្ឋកថា ឈ្មោះថា ការឲ្យឧទ្ទេស ។ ការពណ៌នា សេចក្តីនៃបាលី ឈ្មោះថា ការពណ៌នាបាលី ។ ការប្រាប់ធម៌ ដោយអំណាចនៃវិធីមានការប្រាប់ ដោយសំឡេង និង ដោយបទ ជាដើម ឈ្មោថា ការប្រាប់នូវធម៌ " ។*

(២៧០) សូម្បីក្នុងនិក្ខេបកណ្ឌ ព្រះធម្មសេនាបតី ក៏បាន ពោលហើយថា " ក្នុងមាតិកាដែលបានលើកឡើងមក តាំងទុក នោះ បដិសណ្ឋារៈ តើដូចម្តេចទៅ? ។ គឺ អាមិសបដិសណ្ឋារៈ ១ ធម្មបដិសណ្ឋារៈ ១, បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទទួល ដោយ អាមិសបដិសណ្ឋារៈខ្លះ ដោយធម្មបដិសណ្ឋារៈខ្លះ, នេះ ព្រះមាន ព្រះភាគ ទ្រង់ត្រាស់ហៅថា បដិសណ្ឋារៈ " ។

(២៧១) អដ្ឋកថានិក្ខេបកណ្ឌ ថា " ២ បទថា ***បដិសណ្ឋា-រកោ ហោតិ*** *មានសេចក្តីថា ក៏ប្រហោងទាំងឡាយ នៃលោក-សន្និវាស មាន ២ យ៉ាងប៉ុណ្ណោះឯង, បុគ្គល ជាអ្នកបិទបាំងនូវ ប្រហោងទាំង ២ នោះ គឺ រមែងធ្វើបដិសណ្ឋារៈ មិនដែលដាច់ ។*

មន្តលត្តនីបនីប្រែ

ក៏ភិក្ខុ អ្នកធ្វើបដិសណ្ឋារ: គ្រាន់តែឃើញភិក្ខុអាគន្តុក: កំពុងតែ
និមន្តមក គប្បីក្រោកទទួល ហើយទទួលយក នូវបាត្រ និង ចីពរ
គប្បីឲ្យអាសន: គប្បីបក់ ដោយផ្ទិតស្ទឹកត្នោត គប្បីលាងជើង
ហើយលាប ដោយប្រេង, កាលបើទឹកដោះរាវថ្ថា ទឹកអំពៅ និង
ប្រេង មាន, គប្បីប្រគេនភេសជ្ជ: គប្បីសួរដោយទឹកសម្រាប់ឆាន់
គប្បីបោសសំអាតអាវាស ។ អាមិសបដិសណ្ឋារ: ឈ្មោះថា គឺ
ភិក្ខុបានធ្វើហើយ ដោយឯកទេស យ៉ាងដូច្នេះឯង ។ មួយទៀត
ក្នុងវេលាល្ងាច កាលបើភិក្ខុអាគន្តុក: សូម្បីជាអ្នកខ្ចីវស្សាជាង មិន
បានន៏មន្តមកកាន់ទីឧបដ្ឋាន របស់ខ្លួនទេ, ភិក្ខុ អ្នកធ្វើបដិសណ្ឋារ:
គប្បីនិមន្តទៅកាន់សំណាក់ នៃភិក្ខុអាគន្តុក:នោះ អង្គុយហើយ
កុំសួរបញ្ហា ក្នុងរឿងដែលមិនមែនជាវិស័យ គប្បីសួរបញ្ហា ក្នុង
វិស័យ របស់ភិក្ខុអាគន្តុក:នោះ ។ ភិក្ខុ អ្នកធ្វើនូវបដិសណ្ឋារ:
មិនគួរសួរថា អ្នកទាំងឡាយ ជាអ្នកពោលគម្ពីរអ្វីដែរ? ដូច្នេះ ត្រូវ
សួរថា អាចារ្យ និង ព្រះឧបជ្ឈាយ៍ តែងប្រើគម្ពីរណាខ្ទះ? ដូច្នេះ
ហើយ គប្បីសួរបញ្ហា ក្នុងឋាន: ដែលល្មមសមគួរ ។ បើភិក្ខុ
អាគន្តុក:នោះ អាចធ្វើយបាន, ការធ្វើបានយ៉ាងនេះន៉ុះ ជាការល្អ,
បើភិក្ខុអាគន្តុក:នោះ មិនអាចធ្វើយបានទេ, ត្រូវតែធ្វើយឲ្យខ្លួន
ឯង ។ ធម្មបដិសណ្ឋារ: ឈ្មោះថា គឺ ភិក្ខុបានធ្វើហើយ ដោយ

ពណ៌នាអំពីសេចក្ដីគោរព

ឯកទេស ដោយប្រការដូច្នេះ ។ បើកិក្ខុអាគន្ដុក:នោះ នៅក្នុងសំណាក់របស់ខ្លួន, គប្បីនាំកិក្ខុអាគន្ដុក:នោះទៅបិណ្ឌបាត ជាញឹកញាប់, បើកិក្ខុអាគន្ដុក:នោះ មិនចង់ទៅទេ, ក្នុងថ្ងៃស្អែកឡើង កិក្ខុធ្វើបដិសណ្ឋារ: គប្បីនាំកិក្ខុអាគន្ដុក:នោះទៅ ដោយការទៅ តាមប្រក្រតី និមន្ដបណ្ដិបាត ក្នុងផ្ទះមួយហើយ គប្បីបញ្ជូនមកវិញ ។ បើកិក្ខុទាំងឡាយ ជាអ្នកគឺពួកទាយនិមន្ដហើយ ក្នុងទិសភាគជវ៉ៃ, កិក្ខុ អ្នកធ្វើបដិសណ្ឋារ: គប្បីនាំកិក្ខុអាគន្ដុក: អ្នកប្រាថ្នានោះ ទៅផង ។ កាលបើកិក្ខុអាគន្ដុក:នោះ ពោលថា ទិសភាគនុ៎ះ មិនត្រូវចិត្ដខ្ញុំទេ ដូច្នេះហើយ មិនប្រាថ្នា (ដើម្បីនឹងទៅ), កិក្ខុម្ចាស់វត្ដ ត្រូវបញ្ជូនកិក្ខុដែលនៅសល់ទាំងឡាយទៅ ហើយត្រូវនាំកិក្ខុអាគន្ដុក:នោះ ទៅបិណ្ឌបាត ។ គប្បីប្រគេនអាមិស ដែលខ្លួនបានមក ដល់កិក្ខុអាគន្ដុក:នោះ ។ អាមិសបដិសណ្ឋារ: ឈ្មោះថា គឺកិក្ខុបានធ្វើហើយ ដោយឯកទេស ដោយប្រការដូច្នេះ ។ សួរថា ក៏កិក្ខុអ្នកធ្វើបដិសណ្ឋារ: គប្បីឲ្យអាមិស ដែលខ្លួនបានមកហើយ ដល់បុគ្គលដូចម្ដេច? ។ ឆ្លើយថា គប្បីប្រគេន ដល់កិក្ខុអាគន្ដុក: មុនគេ ។ បើកិក្ខុទាំងឡាយដែលអាពាធ ឬ កិក្ខុទាំងឡាយដែលមិនមានវស្សា មាននៅ, គប្បីប្រគេន ដល់កិក្ខុទាំងឡាយនោះឯង, គប្បីប្រគេន ដល់ព្រះអាចារ្យ និង ព្រះឧបជ្ឌាយ៍ ។ គប្បីឲ្យដល់កិក្ខុអ្នក

មङ្គលត្ថទីបនីប្រែ

ថែរក្សាយ៉ាងណ ។ ចំណែក ភិក្ខុ អ្នកបំពេញសាវណ៍យធម៌ គប្បីប្រគេន ដល់ភិក្ខុអាគន្ត្តុកៈទាំងឡាយ ដែលនិមន្ត្តមកហើយៗ សូម្បី ១០០ ដង សូម្បី ១,០០០ ដង ចាប់តាំងអំពីអាសនៈនៃព្រះថេរៈចុះមក ។ មួយទៀត ភិក្ខុ រូបណាៗ មិនទាន់បានកត្ត, ភិក្ខុ អ្នកធ្វើបដិសណ្ឋារៈ គប្បីប្រគេន ដល់ភិក្ខុរូបនោះៗ ។ ភិក្ខុ អ្នកធ្វើបដិសណ្ឋារៈ និមន្ត្តចេញទៅខាងក្រៅផ្ទះ ឃើញមនុស្សចាស់ជរ មនុស្សអនាថា ឬ នាងភិក្ខុនី គប្បីឲ្យសូម្បីដល់បុគ្គលទាំងនោះ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍)

(អ្នកធ្វើអាមិសបដិសណ្ឋារៈ)

(២៧២) បានឮមកថា កាលបើកុត្ត្តសាលគ្រាម ត្រូវពួកចោរប្លន់, ព្រះថេរី ជាទីណាស្រេព ១ រូប ចេញពីនិវេធសមាបត្តិ ក្នុងខណៈនោះឯង បានឲ្យនាងភិក្ខុនីក្រមុំកាន់កញ្ចប់ក្ណៈ ហើយដើរផ្លូវ ព្រមជាមួយនឹងមហានជន ក្នុងវេលាថ្ងៃត្រង់ បានមកដល់មាត់ទ្វារស្រុកនង្គ្ត្លនគរ ទើបអង្គ្ត្យ (សំពាក) ក្ស្ត្ររគល់ឈើ ។

ក្នុងសម័យនោះ ព្រះមហានាគថេរ អ្នកមានប្រក្រតីនៅក្នុងកាឡ្ស្ត្ល្ងីមណ្ឌប បាននិមន្ត្តទៅបិណ្ឌបាត ក្នុងស្រុកនង្គ្ត្លនគរ ហើយនិមន្ត្តចេញមក ជួបនូវព្រះថេរី ទើបសួរដោយអើពើ ដោយកត្ត ។ ព្រះថេរីនោះ ផ្ញើយថា ជាត្រ របស់នាងខ្ញុ ំ មិនមានទេ ។

ពណ៌នាអំពីសេចក្តីគោរព

ព្រថេះរ: ពោលថា សូមអ្នកនិមន្តធាន់ ដោយបាត្រនេះឯង ដូច្នេះ ហើយ ទើបបានប្រគេនព្រមទាំងបាត្រទៅ ។ ព្រះថេរី ធាន់ស្រេច ហើយ លាងបាត្រប្រគេន ដល់ព្រះថេរ: ហើយពោល ថា ក្នុងថ្ងៃ នេះ ព្រះគុណម្ចាស់នឹងលំបាក ដោយភិក្ខាចារសិនចុះ, បពិត្រព្រះ គុណម្ចាស់ ក៏ចាប់តាំងពីពេលនេះទៅ ឈ្មោះថា ការក្តៅក្រហាយ ដោយភិក្ខា នឹងមិនមាន ដល់ព្រះគុណម្ចាស់ឡើយ ។ ចាប់តាំង ពីពេលនោះមក ឈ្មោះថា បិណ្ឌបាត ដែលមានតម្លៃ តិចជាងអំពី ១ កហាបណ: មិនដែលកើតឡើងហើយ ដល់ព្រះថេរ: ។ នេះ ឈ្មោះថា អាមិសបដិសណ្ឋារ: ។

(ធម្មបដិសណ្ឋារ:)

ភិក្ខុ អ្នកធ្វើបដិសណ្ឋារ:នេះ គប្បីតាំងនៅ ក្នុងចំណែកនៃ ការសង្ត្រោះហើយ ប្រាប់កម្មដ្ឋាន ដល់ភិក្ខុនោះ ។ គប្បីបង្រៀន ធម៌ ។ គប្បីបន្ទោបង់នូវសេចក្តីរាយមាយចិត្ត ។ គប្បីធ្វើកិច្ចដែល គួរធ្វើ ដែលកើតឡើងហើយ ។ គប្បីឲ្យអញ្ពាន រុដ្ឋាន មានត និង បរិវាសកម្ម ។ បុគ្គល អ្នកគួរដល់បព្វជ្ជា គប្បីឲ្យបព្វជ្ជា ។ អ្នកគួរ ដល់ឧបសម្ប៉ទ គប្បីឲ្យឧបសម្ប៉ទ ។ សូម្បីនាងភិក្ខុនីដែលប្រាថ្នា ចង់ឧបសម្ប៉ទ ក្នុងសំណាក់របស់ខ្លួន ភិក្ខុ នឹងធ្វើកម្មវាចា ក៏សម គួរ ។ នេះ ឈ្មោះថា ធម្មបដិសណ្ឋារ: " ។

មន្តលត្ថទីបនីប្រែ

ដីកានិក្ខេបកណ្ឌនោះ ថា " ២ បទថា ***សង្គហបក្ខេ ឋត្វា*** *មានសេចក្តីថា គឺភិក្ខុអ្នកប្រាថ្នា នូវសេចក្តីសង្គ្រោះនុ៉ះឯង គប្បីប្រាប់ឲ្យ, អធិប្បាយថា មិនមែនប្រាប់ឲ្យ ព្រោះហេតុត្រឹមតែលាភនិង សក្ការៈ ជាដើមឡើយ ។ ការងារដែលត្រូវធ្វើ ដោយពិតប្រាកដ ចាត់ទុកថាជាកិច្ច ។ ការងារក្រៅអំពីនេះ គឺ គ្រាន់តែជាករណីយ៍ ។ ការចេញអំពីអាបត្តិដទៃ ចាកអញ្ពានកម្ម ជាវុដ្ឋាន" ។*

(អនាមដ្ឋបិណ្ឌបាត ភិក្ខុគួរឱ្យដល់មាតាបិតា)

(២៧៣) អដ្ឋកថាភេសជ្ជករណវត្ថុ ក្នុងតតិយបារាជិក ថា " អនាមដ្ឋបិណ្ឌបាត (បិណ្ឌបាត ដែលភិក្ខុមិនទាន់បានចាប់កាន់) ភិក្ខុ គប្បីឲ្យ ដល់មាតាបិតាទាំងឡាយ ជាមុនសិន ។ ប្រសិនបើបិណ្ឌបាតនោះ ជារបស់មានតម្លៃដល់ទៅ ១ កហាបណៈ, ក៏មិនចាត់ថា ជាការញ្ចាំងទាន ដែលទាយកឲ្យ ដោយសទ្ធា ឲ្យធ្លាប់ចុះឡើយ ។ គប្បីឲ្យសូម្បីដល់បុគ្គលទាំងនេះគឺ ពួកជនដែលឧបដ្ឋាកមាតាបិតា វេយ្យាវច្ចករ បណ្ឌុបលាសៈ ។ បណ្តាជនទាំងនោះ សូម្បីដាក់ក្នុងភាជនៈ ហើយឲ្យ ដល់បណ្ឌុបលាសៈ ក៏សមគួរ ។ លើកលែងតែបណ្ឌុបលាសៈ នោះចេញ នឹងដាក់ ក្នុងភាជនៈ ហើយឲ្យ ដល់គ្រហស្ថទាំងឡាយ ដទៃទៀត សូម្បីជាមាតាបិតា ក៏មិនគួរ ។ ព្រោះថា គ្រឿងប្រើប្រាស់របស់បព្វជិត ជារបស់ស្ថិត

ពណ៌នាអំពីសេចក្ដីគោរព

នៅ ក្នុងឋាន: ជាចេតិយ របស់ពួកគ្រហស្ថ ។ ម្យ៉ាងទៀត ធម្មតា អនាមជ្ជបិណ្ឌបាតនេះ ភិក្ខុគប្បីឲ្យសូម្បីដល់ចោរ ដែលមានឈ្មោះ សំឡេង សូម្បីដល់ឥស្សរជន ដែលមកដល់ហើយ ។ ព្រោះហេតុ អ្វី? ។ ព្រោះថា ទាំងចោរ ទាំងឥស្សរជន ទាំងនោះ, កាលបើ បិណ្ឌបាត សូម្បីភិក្ខុមិនឲ្យក្ដី, ក៏ក្រោធ ថា មិនឲ្យ ដូច្នេះ, សូម្បី ភិក្ខុចាប់ឲ្យក្ដី ក៏រមែងក្រោធថា ឲ្យរបស់ដែលជាដែល ។ មែនពិត ទាំងចោរ ទាំងឥស្សរជនទាំងនោះ ក្រោធហើយ រមែងផ្ដាច់បង់ភិក្ខុ ចាកជីវិត ក៏មាន រមែងធ្វើសេចក្ដីអន្ដរាយ ដល់ព្រះសាសនា ក៏ មាន ។ ក៏ក្នុងរឿងនេះ គប្បីសម្ដែងរឿងព្រះបាទចោរនាគ ទ្រង់ ប្រាថ្នាវាជសម្បត្ដិស្ដេចយាងទៅ (ជាឧទាហរណ៍) ។ បដិសណ្ឋារ: គឺភិក្ខុគប្បីធ្វើ ដល់បុគ្គលណាមួយ ដែលមកដល់វិហារហើយ ទោះ ជាក្ងៀវក្ដី ជាមនុស្សក្រីក្រក្ដី ជាចោរក្ដី ជាឥស្សរជនក្ដី ដោយ ពិត ។ សួរថា គប្បីធ្វើ យ៉ាងដូចម្ដេច? ។ ឆ្លើយថា ភិក្ខុ ឃើញ ក្ងៀវដែលអស់ស្បៀង មកដល់វិហារហើយ គប្បីឲ្យទឹកសម្រាប់ ផឹក ដោយប្រាប់ ថា សូមអ្នកអញ្ជើញពិសាទឹក ដូច្នេះ ជាមុន ។ គប្បីឲ្យប្រេងសម្រាប់លាបជើង ។ អាគន្ដុក: ដែលមកហើយ ក្នុង កាល ភិក្ខុគប្បីឲ្យយាគូ និង ភត្ត ។ អាគន្ដុក: ដែលមកហើយ ក្នុង សម័យវិកាល បើអង្ករ មាន, គប្បីឲ្យអង្ករ ។ ភិក្ខុ មិនត្រូវពោល

មङ្គលត្ថទីបនីប្រែ

ថា អ្នកមកដល់ហើយ ក្នុងសម័យមិនមែនជាកាល ចូរអ្នកទៅវិញចុះ ។ គប្បីឲ្យទីដេក ។ ភិក្ខុ មិនប្រាថ្នា (អ្វី) ទ្បើយ គប្បីធ្វើកិច្ចការគ្រប់បែបយ៉ាង ។ ភិក្ខុ មិនគួរញ្ជាំងចិត្ត ឲ្យកើតទ្បើង ថាធម្មតា ពួកមនុស្ស អ្នកប្រគេនបច្ច័យ ៤, កាលបើអាត្មាអញ ធ្វើសេចក្ដីសង្គ្រោះ យ៉ាងនេះ, នឹងជ្រះថ្លាហើយ ធ្វើឧបការៈរឿយៗ ។ សូម្បីវត្ថុជារបស់សង្ឆ ក៏ភិក្ខុគប្បីឲ្យ ដល់ពួកចោរបានដែរ " ។

(២៧៤) ដីកានៃកេសជ្ជករណវត្ថុនោះ ថា "បិណ្ឌបាត ដែលភិក្ខុបានមកហើយ អំពីដៃនៃបុគ្គល ដែលមិនមែនជាបព្វជិត មានចំណែកដ៏ប្រសើរ គឺខ្លួន ឬ បព្វជិត ដទៃទៀត មិនទាន់បានប៉ះពាល់ហើយ ឈ្មោះថា អនាមដ្ឋបិណ្ឌបាត " ។

នវដីកាថា " បិណ្ឌបាត ដែលមានចំណែកដ៏ប្រសើរ គឺភិក្ខុមិនទាន់បានប៉ះពាល់, អធិប្បាយថា គឺអ្នកណាមួយ មិនទាន់បានបរិភោគ ឈ្មោះថា អនាមដ្ឋបិណ្ឌបាត ។ បទថា **ថាលកេ** បានដល់ ក្នុងភាជនៈដែលធ្វើហើយ ដោយសំរឹទ្ធិជាដើម ដែលជារបស់នៃសង្ឆ ។ ចំណែក ចាត្រ ក៏លោកសង្គ្រោះ ចូលក្នុងពាក្យនេះផងដែរ ។ ដោយពាក្យថា មិនគួរ នេះ ព្រះអដ្ឋកថាចារ្យ សម្ដែងថា ជាអាបត្តិទុក្កដ ដូច្នេះ " ។

ដីកានៃកេសជ្ជករណវត្ថុនោះ ថា "បទថា **ទាមរិកចោរស្ស**

ពណ៌នាអំពីសេចក្តីគោរព

បានដល់ ចោរ អ្នកមានឈ្មោះល្បីល្បាញ ដែលប្រាថ្នាចង់បានន្ទូវ រាជសម្បត្តិ ។ ក្នុងពាក្យថា រឿងរបស់ព្រះបាទចោរនាគនេះ គប្បីជ្រាបសេចក្តី ដូចតទៅនេះ ៖

បានញ្ញមកថា ព្រះថេរ: គិតថា កាលបើអាត្មាអញ ថ្វាយបិណ្ឌបាត ដែលអាត្មាអញប៉ះពាល់ហើយ ដល់ព្រះបាទចោរនាគ, ព្រះអង្ត នឹងទ្រង់ព្រះពិរោធ, អាត្មាអញ នឹងថ្វាយបិណ្ឌបាត ដែលមានចំណែកដ៏ប្រសើរ ដែលអាត្មាអញមិនទាន់បានប៉ះពាល់ហើយ នឹងមិនគួរ ដូច្នេះហើយ ក៏បានចាប់យកចំណែកបិណ្ឌបាត ដោយដៃ ដែលចាប់បាត្រន៉ុះឯងហើយ ក៏បានថ្វាយភត្ត ក្នុងបាត្រ ទាំងអស់ទៅ ។ ព្រះអង្ត ទ្រង់បានសព្វព្រះរាជហប្ចទ័យហើយ ដោយភត្តនោះ" ។

(២៧៥) អដ្ឋកថានិក្ខេបកណ្ឌ ថា " ភិក្ខុ អ្នកធ្វើបដិសណ្ឋារ: ដោយបដិសណ្ឋារ: ២ យ៉ាងនេះ រមែងញ្ញាំងលាភ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង រមែងធ្វើលាភដែលកើតឡើងហើយ ឲ្យបានស្ថិតនៅគង់វង្ស រមែងថែរក្សាជីវិត របស់ខ្លួនបាន ក្នុងទីដែលមានសេចក្តីរង្កៀសសង្ស័យ ដូចជាព្រះថេរ: ដែលបានចាប់យកចំណែកបិណ្ឌបាតដ៏ប្រសើរ ដោយដៃដែលចាប់បាត្រន៉ុះឯងហើយ ចាក់ភត្តដោយបាត្រន៉ុះឯង ថ្វាយដល់ព្រះបាទចោរនាគដូច្នោះឯង ។

មង្គលត្ថទីបនីប្រែ

ក៏ក្នុងការញ្ជាំងលាក ដែលមិនទាន់បានឲ្យកើតឡើង គឃ្យីសំដែងរឿងមហាកេសជ្ជទាន ដែលព្រះរាជា ទ្រង់ព្រះនាម ព្រះមហានាគ ស្តេចយាងចេញ អំពីច្រាំងខាងអាយនោះ ស្តេចយាងទៅ កាន់ច្រាំងខាងនាយ ទ្រង់បានទ្ទូរសេចក្តីសង្គ្រោះ ក្នុងសំណាក់ នៃព្រះថេរៈមួយរូបហើយ ស្តេចយាងត្រឡប់មក ទ្រង់បានស្ថិតនៅ ក្នុងព្រះរាជសម្បត្តិ ម្ខងទៀត ទ្រង់ឲ្យប្រព្រឹត្តទៅ ក្នុងបត្តមុគ្គណវិហារ ជរាបជណ្ដ់អស់ព្រះជន្មាយុ ។ ក្នុងការធ្វើលាក ដែលកើតឡើងហើយ ឲ្យបានស្ថិតស្ថេរគង់វង្ស គឃ្យីសម្ដែងរឿង ដែលពួកចោរបានទទួលបដិសណ្ឋារៈ អំពីដៃ នៃព្រះទីឃកាណកអកយត្ថេរ ហើយ មិនបាននាំគ្នាប្លន់កណ្ហៈ ក្នុងចេតិយបព្ជិតវិហារ ” ។

(២៧៦) អដ្ឋកថា កេសជ្ជករណវត្ថុ ថា “ ដើម្បីសម្ដែងអានិសង្ស នៃការធ្វើបដិសណ្ឋារៈ ព្រះអដ្ឋកថាចារ្យ បានពោលរឿងទាំងឡាយ យ៉ាងច្រើន ដោយពិស្តារ ក្នុងមហាអដ្ឋកថា មានជាអាទិ៍ យ៉ាងនេះ គឺ រឿងព្រះបាទចោរនាគ រឿងព្រះរាជាព្រះនាមមហានាគ ដែលទ្រង់ស្តេចយាងទៅ កាន់ជម្ពូទ្វីប ជាមួយនឹងព្រះរាជកាតា រឿងអាមាត្យទាំង ៤ នាក់ ក្នុងរជ្ជកាល នៃព្រះបាទបិតុរាជ រឿងអកយចោរ ។

បណ្ដារឿងទាំងនោះ នឹងសម្ដែងរឿងមួយ ដូចតទៅនេះ ៖

ពណ៌នាអំពីសេចក្ដីគោរព

(រឿង អភយចោរ)

បានឮមកថា ក្នុងកោះសីហឬ: ចោរ ឈ្មោះអភ័យ មានបរិវារប្រមាណ ៥០០ នាក់ ចោះបន្ទាយនៅ ក្នុងទីកន្លែងមួយ ញ៉ាំងប្រជាជនឲ្យកៀសខ្លួនចេញទៅ អស់ទីប្រមាណ ៣ យោជន៍ ដោយជុំវិញ ។ ប្រជាជន អ្នកនៅក្នុងអនុរាធបុរី ឆ្ងងទន្ទ្ រកលម្ហក-នទី មិនបាន ។ លើផ្លូវទៅចេតិយគិរីវិហារ ការសញ្ជ្ជារទៅមក នៃប្រជាជន ជាច់ខាតហើយ ។ ក្រោយមក ថ្ងៃមួយ ពួកចោរ បាននាំគ្នាទៅហើយ ដោយគិតថា ពួកយើង នឹងប្លន់ នូវចេតិយគិរី-វិហារ ។ ពួកញោមវត្ត បានឃើញហើយ ទើបប្រាប់ ដល់ព្រះទីឃភាណកអកយត្ថេរ ។ ព្រះថេរ: សួរថា តើវត្ថុទាំងឡាយ មានទឹកដោះរាវ ថ្ងា និង ទឹកអំពៅ ជាដើម មានដែរឬទេ? ។

ពួកញោមវត្ត. បពិត្រព្រះគុណម្ចាស់ មាន ។

ព្រះថេរ:. ពួកអ្នកទាំងឡាយ ចូរឲ្យដល់ពួកចោរចុះ ។ តើអង្ករ មានឬទេ? ។

ពួកញោមវត្ត. បពិត្រព្រះកុណម្ចាស់ អង្ករ បន្ទ្ស្រស់ និងគោរស ដែលគេនាំយកមកហើយ ដើម្បីព្រះសង្ឆ្ យ មាន ។

ព្រះថេរ:. ពួកអ្នកចូរចាត់ចែងកត្ត ឲ្យដល់ពួកចោរផង ។

ពួកញោម. បានធ្វើហើយ ដូចជាព្រះថេរ:ប្រាប់ ។

មន្ទលត្ថទីបនីប្រែ

ពួកចោរ បរិភោគភត្តហើយ សួរថា តើបដិសណ្ឋារៈនេះ អ្នកណា ធ្វើហើយ? ។

ពួកញោមវត្ត. ព្រះអភយត្ថេរ ជាម្ចាស់របស់ពួកយើងខ្ញុំ ។

ពួកចោរ បានទៅសំណាក់របស់ព្រះថេរៈ ថ្វាយបង្គំហើយ ពោលថា ពួកខ្ញុំព្រះករុណា មកហើយ ដោយគិតថា ពួកយើង នឹងប្លន់យក នូវវត្ថុជារបស់ព្រះសង្ឆ និង ព្រះចេតិយ ដូច្នេះ, ប៉ុន្តែ ពួកខ្ញុំព្រះករុណា ជាអ្នកជ្រះថ្លាហើយ ដោយការធ្វើបដិសណ្ឋារៈនេះ របស់ព្រះគុណម្ចាស់, ចាប់តាំងអំពីថ្ងៃនេះតទៅ ការថែរក្សា ដែលប្រកបដោយធម៌ ក្នុងព្រះវិហារ ចូរជានាទី នៃពួកយើងខ្ញុំចុះ, ពួកអ្នកនគរ ចូរមកថ្វាយទាន, ចូរថ្វាយបង្គំព្រះចេតិយចុះ ។

ក៏ចាប់ដើមអំពីពេលនោះមក កាលបើអ្នកនគរ មកដើម្បីថ្វាយទាន, ពួកចោរទាំងនោះ ក៏ទៅទទួលដល់មាត់ទន្លេតែម្តង ចាំថែរក្សា នាំទៅវិហារ, កាលបើពួកអ្នកនគរ កំពុងថ្វាយទាន ក្នុងវិហារ, ក៏នាំគ្នាឈរចាំធ្វើការថែរក្សា ។ ចំណែក ពួកអ្នកនគរទាំងនោះ ក៏ឲ្យភត្តដ៏សេសសល់ ដែលភិក្ខុទាំងឡាយឆាន់ហើយ ដល់ពួកចោរ ។ សូម្បីក្នុងពេលត្រឡប់ទៅវិញ ពួកចោរទាំងនោះ ក៏ជូនពួកអ្នកនគរទាំងនោះ ដល់មាត់ច្រាំងទន្លេស្រេចហើយ ទើបវិលត្រឡប់មកវិញ ។

ពណ៌នាអំពីសេចក្ដីគោរព

ក្រោយមក ថ្ងៃមួយ បានកើតមានពាក្យតិះដៀល ចំពោះ ភិក្ខុសង្ឆ ថា ព្រះថេរៈ បានឲ្យវត្ថុជារបស់នៃសង្ឆ ដល់ពួកចោរ ព្រោះប្រកាន់ថា ខ្លួនជាធំ ។ ព្រះថេរៈ បញ្ជាឲ្យធ្វើការប្រជុំសង្ឆ ហើយ ពោលថា ពួកចោរ បាននាំគ្នាមកហើយ ដោយតាំងចិត្ត ថា ពួកយើង នឹងប្លន់យកទ្រព្យថ្ងៃចង្ហាន់ តាមប្រក្រតី របស់សង្ឆ និង ទ្រព្យរបស់ចេតិយ ដូច្នេះ, កាលបើដូច្នោះ ទើបខ្ញុំធ្វើបដិ-សណ្ឋារៈ ដល់ពួកចោរទាំងនោះ មានប្រមាណប៉ុណ្ណេះ ដោយគិត ឃើញថា ពួកចោរ នឹងមិនប្លន់ ដោយប្រការយ៉ាងនេះ ដូច្នេះ, ពួក អ្នកទាំងឡាយ ចូរយករបស់ទាំងអស់ រួមបញ្ចូលគ្នាហើយ រាយ តម្លៃចុះ, ពួកអ្នកទាំងឡាយ ចូរយករបស់ដែលពួកចោរ មិនបាន ប្លន់យកទៅ ដោយហេតុនោះ រួមបញ្ចូលជាមួយគ្នាហើយ រាយ តម្លៃមើលចុះ ។ ទ្រព្យសម្បត្ដិ ដែលព្រះថេរៈឲ្យទៅទាំងអស់ អំពី ទ្រព្យរបស់សង្ឆនោះ មានតម្លៃមិនស្មើនឹងគ្រឿងកម្រាល ដែល វិចិត្រដ៏ល្អ មួយផ្ទាំង ក្នុងរោងព្រះចេតិយឡើយ ។ លំដាប់នោះ ពួកភិក្ខុទាំងឡាយ ពោលថា ព្រះថេរៈ ធ្វើបដិសណ្ឋារៈល្អហើយ, អ្នកណាមួយ មិនបានដើម្បីចោទ ឬ ដើម្បីឲ្យលោក ឲ្យការណ៍ ឡើយ, សំណង ឬ ការលួចយក មិនមាន ។ បដិសណ្ឋារៈ មាន អានិសង្សច្រើន យ៉ាងដូច្នេះឯង, ភិក្ខុ ជាបណ្ឌិត កំណត់ដូចបាន

ពោលមកហើយ គប្បីធ្វើបដិសណ្ឋារៈ ” ។

*ដីកាភេសជ្ជករណវត្ថុនោះ ថា “ បទថា **ឧញ្ញាសេត្វា** មាន សេចក្តីថា អភយចោរ ប្ញូន់រហូតទីប្រមាណ ៣ យោជន៍ ដោយជុំវិញ បណ្តេញពួកមនុស្ស ឲ្យរត់ហើយ ធ្វើទីកន្លែងនោះ មិនឲ្យជាទីនៅ របស់ពួកជនដទៃ ។ ពាក្យថា **សង្ឃស្ស អត្ថាយ អាហជា** បានដល់ នាំមកអំពីទ្រព្យថ្លៃអាហារ ដែលសម្រាប់ដាំស្ល ដើម្បីប្រយោជន៍ដល់ថ្ងៃនោះ ។ បទថា **វរបោត្ថកចិត្តត្ថរកំ** បានដល់ គ្រឿងកម្រាលដ៏វិចិត្រ ដោយរូបភាពដ៏ប្រសើរៗ ច្រើនជាអនេកប្បការ ” ។*

រឿង អភយចោរ ចប់ ។

(២៧៧) ក៏ក្នុងពាក្យថា “ ក្នុងរជ្ជកាលនៃព្រះបាទបិតុរាជ ” នេះ មានការពណ៌នា ដោយពិស្តារ ដូចតទៅនេះ ៖

(រឿង ព្រះបាទបិតុរាជ)

បានឮមកថា ព្រះរាជា ទ្រង់ព្រះនាមសទ្ធាតិស្សៈ ទ្រង់មានព្រះរាជបុត្រ ៤ ព្រះអង្គ គឺ ព្រះរាជបុត្រព្រះនាម លញ្ជតិស្សៈ ១ ព្រះនាម ថូលត្ថនកៈ ១ ព្រះនាម ខល្លាដនាគៈ ១ ព្រះនាម វដ្ដគាមណីអភ័យ ១ ។ បណ្តាព្រះរាជបុត្រទាំងនោះ ព្រះបាទខល្លាដនាគ ទ្រង់មានព្រះឱរសព្រះនាម មហាចូឡិកៈ ។ ព្រះបាទ

ពណ៌នាអំពីសេចក្តីគោរព

វដ្តគាមណីអភ័យ មានព្រះឱរស ទ្រង់ព្រះនាម មហានាគ ។ ក៏ ព្រះបាទវដ្តគាមណីអភ័យ ទ្រង់សោយរាជ្យហើយ ក៏ទ្រង់បានតែងតាំងព្រះរាជនត្តា របស់ព្រះអង្គ ក្នុងព្រះតំណែងនៃព្រះរាជបុត្រ ។ ព្រោះហេតុនោះ ព្រះរាជាព្រះអង្គនោះ ទើបប្រាកដព្រះនាម ថា ព្រះបាទបិតុរាជ ។ កាលបើព្រះរាជាអង្គនោះ ទ្រង់គ្រងរាជសម្បត្តិ បាន ៥ ខែ, មានពួកទមិឡ ៥ នាក់ គឺ ចូឡហត្ថ: ពាហិយ: បុនយមារ: បីឡយមារ: និង ទាធិយ: បាននាំគ្នាមកហើយ ដើម្បីដណ្តើមយករាជសម្បត្តិ ។ ព្រះរាជា ទ្រង់បានតយុទ្ធ ជាមួយនឹងពួកទមិឡទាំងនោះ ទ្រង់បរាជ័យហើយ ទើបទ្រង់នាំយកជន ទាំងឡាយ ៣ នាក់ គឺ ព្រះនាងអនុឡាទេវី ១ ព្រះរាជនត្តា ព្រះនាម មហាចូឡិក: ១ ព្រះរាជឱរស ព្រះនាមហានាគ ១ ស្តេចយាងគេចចេញទៅហើយ ។ ព្រះអង្គ ព្រមទាំងព្រះរាជឱរស និង ព្រះអគ្គមហេសី ទ្រង់ពួនសម្ងំហើយ ក្នុងព្រៃក្បែរវេស្សគិរីវិហារ ក្នុងមលយប្រទេស ។

លំដាប់នោះ ព្រះថេរ: មួយអង្គ ឈ្មោះថា កុធិក្កលមហាតិស្សត្ថេរ ជាកុលុបក: របស់ព្រះអង្គ បានថ្វាយព្រះក្រយាហារ ដល់ព្រះរាជា ។ ដោយហេតុនោះ ទើបព្រះមហានាមត្ថេរ បានពោលពាក្យជាគាថា ក្នុងបរិច្ឆេទ ទី ៣៤ នៃគម្ពីរមហាវង្ស ថា ៖

មន្ទលត្ថទីបនីប្រែ

ក៏ ព្រះកុធិក្ពលមហាតិស្សត្ថេរ បានឃើញព្រះបាទបិតុរាជ
នោះ ក្នុងព្រៃក្សែរវេស្សគិរីវិហារនោះហើយ ក៏រៀរស្រឡះ
អនាមដ្ឋបិណ្ឌបាតទាន បានថ្វាយព្រះក្រយាស្វោយ (ដល់
ព្រះអង្គ) ហើយ ។

*បណ្តាបទទាំងនោះ ២ បទថា "**តហឹ តុ តំ**" គឺបានឃើញ
នូវព្រះរាជាអង្គនោះ ក្នុងព្រៃក្សែរវេស្សគិរីវិហារនោះ ។ បទថា
"**បាទា**" គឺ បានថ្វាយហើយ សូម្បីនូវព្រះក្រយាស្វោយ ។ ពាក្យ
ថា "**អនាមដ្ឋបិណ្ឌបាតទានំ រិវជ្ជិយ**" មានសេចក្តីថា ការបែងចែក
នូវចំណែកនៃបិណ្ឌៈ ចាកបិណ្ឌបាត ដែលទាយកគប្បីឲ្យ ដោយ
សទ្ធាគឺទាយកប្រគេនហើយ ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឲ្យ
ដល់ពួកគ្រហស្ថ មុនន៉ុះឯង ឈ្មោះថា អនាមដ្ឋបិណ្ឌបាត, រៀរ
ស្រឡះហើយ នូវអនាមដ្ឋបិណ្ឌបាតទាននោះ, អធិប្បាយថា ខ្លួន
ឯង រៀរស្រឡះ ព្រោះជាអ្នកប្រាថ្នា ក្នុងសិក្ខា ហើយទើបបាន
ថ្វាយព្រះក្រយាស្វោយ ដល់ព្រះរាជា ។*

*(២៧៨) ចំណែកព្រះរាជា ទ្រង់គង់ប្រមូលយកព្រះកម្ចាំង
ក្នុងទីនោះៗ ក្នុងមលយប្រទេស ទ្រង់បានហើយ នូវអមាត្យ ៨
នាក់ មានកវិសីសអមាត្យ និង ឧត្តិយអមាត្យ ជាដើម ដែលគេ
សន្ធតថា ជានាយទាហានជាន់ខ្ពស់ ។ ក្រោយមក ថ្ងៃមួយ ព្រះ*

 រាជា ទ្រង់ព្រះពិរោធ ចំពោះកវិសីសអមាត្យ ទើបទ្រង់ត្រាស់បញ្ជា ឲ្យប្រហារជីវិត កវិសីលអមាត្យនោះចាល ។

លំដាប់នោះ ពួកអមាត្យ ដទៃទៀត ៧ នាក់ បានក្រោធខឹង ចំពោះព្រះរាជា ថា " ព្រះរាជានេះ ទ្រង់ជាអ្នកប្រទូសរ៉ាយមិត្ត " ហើយ បានបោះបង់ព្រះរាជានោះ ចៀសចេញទៅ តាមសេចក្ដី ពេញចិត្ត ត្រូវពួកចោរ ដណ្ដើមយកសំពត់ (ខោ និង អាវ) ក្នុង ចន្ទោះផ្លូវ ទើបស្លៀកពាក់មែកឈើហើយ បានចូលទៅកាន់វិហារ ឈ្មោះ ហម្ពកល្លក: ។ ព្រះតិស្សត្ថេរ ជាអ្នកទ្រទ្រង់និកាយ ៤ មួយរូប ក្នុងវិហារនោះ ឃើញអមាត្យទាំងនោះហើយ ទើបបាន នាំយកសំពត់ និង ទឹកអំពៅជាដើម ដែលខ្លួនបានមកហើយ អំពី ទីនិមន្ត ក្នុងថ្ងៃនោះ មកឲ្យ ដោយពាក្យថា " ម្នាលឧបាសកទាំង ឡាយ កាលបើសេចក្ដីស្និទ្ធស្នាល ក្នុងព្រះកិកូ្ខសង្ឆមាន, ពួកអ្នក ទាំងឡាយ ចូរទទួលយក នូវរបស់ទាំងឡាយនេះចុះ " ។ ពួក អមាត្យទាំងនោះ ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ពួកខ្ញុំ ព្រះករុណា ជាអ្នកស្និទ្ធស្នាល ក្នុងព្រះកិកូ្ខសង្ឆ ទាំងមាតា និង បិតា របស់ពួកខ្ញុំព្រះករុណា ក៏ជាឧបាសក ឧបាសិកាដែរ" ដូច្នេះ ហើយ ក៏បានទទួលយករបស់របរទាំងនោះ ។ ព្រះថេរ: សួរថា " តើពួកអ្នកទាំងឡាយ អញ្ជើញទៅ ក្នុងទីណា? " ។ ពួកអមាត្យ

ទាំងនោះ បានប្រាប់រឿងរ៉ាវទាំងអស់ហើយ ។ ព្រះថេរៈនោះ បានសួរថា "ព្រះរាជាអង្គនោះ គឺពួកអ្នកទាំងឡាយ បានឧបត្ថម្ភហើយ តើអាចដើម្បីធ្វើការលើកស្ទួយព្រះសាសនាបាន ឬ មិនបាន? " ។ ពួកអមាត្យទាំងនោះ ពោលថា " បពិត្រព្រះគុណម្ចាស់ ដ៏ចម្រើន កិរិយាធ្វើការលើកស្ទួយព្រះសាសនា ក្នុងទ្វីបនេះ របស់ព្រះរាជា ចូរស្ទុះទុកមួយអន្ទើសិនចុះ, សូម្បីក្នុងជម្ពូទ្វីប ក៏ព្រះអង្គទ្រង់ធ្វើ បាន ដោយពិតណាស់ " ។ ព្រះថេរៈ បានស្តាប់ពាក្យនោះហើយ ទើបគិតថា " ព្រះបាទបិតុរាជ ត្រូវបានពួកនាយទាហាន ជាន់ខ្ពស់ ដែលមិនមែនជាសឹកសត្រូវ ចំពោះព្រះសាសនាទាំងនេះឯង ជួយ ឧបត្ថម្ភហើយ ទ្រង់បានបក្សពួកហើយ នឹងទ្រង់អាច ដើម្បីនឹង លើកតម្កើងព្រះសាសនាបាន, បានពួកជនដទៃឧបត្ថម្ភហើយ នឹង ទ្រង់មិនអាច ដើម្បីនឹងលើកស្ទួយព្រះសាសនាបានទេ, ព្រោះហេតុ នោះ អាត្មាអញ នឹងញុំងព្រះរាជា ឲ្យទ្រង់អត់ទោស ដល់ពួក អមាត្យទាំងនេះ " ដូច្នេះហើយ ក៏បាននាំពួកអមាត្យទាំងនោះ ទៅ កាន់ព្រះដំណាក់ នៃព្រះរាជា ព្រមជាមួយនឹងព្រះកុធិក្ខលមហា-តិស្សត្ថេរ ដែលបាននិមន្តមក ក្នុងវិហារនោះ ។ ព្រះថេរៈ ទាំង ២ អង្គនោះ បានញុំងព្រះរាជា និង ពួកអមាត្យទាំងនោះ ឲ្យអត់ ទោស ដល់គ្នានឹងគ្នាហើយ ទើបបាននិមន្តទៅកាន់ទីស្ថានី ដូចដើម

ពណ៌នាអំពីសេចក្តីគោរព

វិញ ។ ចំណែកព្រះរាជា ទ្រង់ស្តេចគង់នៅ ក្នុងមលយប្រទេសអស់ ១៤ ឆ្នាំ ៧ ខែ ហើយ មានពួកអមាត្យទាំងនោះ ចោររោមស្តេចយាងមក អំពីមលយប្រទេសនោះ ទ្រង់បានធ្វើគុត ព្រះបាទទាធិយៈទមិឡ ដែលកំពុងគ្រប់គ្រងរាជសម្បត្តិ ខាងក្រោយទមិឡទាំងអស់ហើយ ទ្រង់បានជាព្រះរាជា ម្ពងទៀត ទើបទ្រង់បានត្រាស់បញ្ជា ឲ្យសាងអភយគិរីវិហារឡើងហើយ ។ ដូច្នោះ អ្នកប្រាជ្ញ គប្បីជ្រាបថា " ព្រះរាជា ព្រះនាមវដ្តគាមណីអភ័យ ទ្រង់កសាងអភយគិរីវិហារ ក្នុងទីបំផុត នៃ ៤៤៣ ឆ្នាំ ១ ខែ រាប់តាំងអំពីព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះបរិនិព្វានមក ខាងក្រោយ អំពីព្រះមហាវិហារ ដែលព្រះបាទទេវានម្បិយតិស្សៈ ទ្រង់បានកសាងឡើងហើយ ក្នុងឆ្នាំខាងដើម " ។ ព្រះរាជា អង្គនោះ ទ្រង់បានឲ្យកសាងព្រះវិហារនោះ រួចស្រេចហើយ ទ្រង់អារាធនា និមន្តព្រះកុធិក្កលមហាតិស្សត្ថេរ ដែលថ្វាយព្រះក្រយាស្វាយ ដល់ព្រះអង្គ ក្នុងកាលមុន មកហើយ ទើបទ្រង់វេរ ប្រគេនព្រះវិហារនោះ ដល់ព្រះកុធិក្កលមហាតិស្សត្ថេរនោះ ហើយទ្រង់នឹករលឹក នូវឧបការគុណ ដែលព្រះថេរៈលោកបានធ្វើហើយ ក្នុងកាលមុន ទើបទ្រង់បានទំនុកបំរុង ដោយសេចក្តីគោរព ។

រឿង ព្រះបាទបិតុរាជ ចប់ ។

មង្គលត្ថទីបនីប្រែ

(រឿង អមាត្យរបស់ព្រះបាទបិតុរាជ)

(២៧៩) ពួកអមាត្យទាំង ៧ នាក់នោះឯង បានឲ្យគេសាង
ហើយ នូវព្រះវិហារ ៥ ខ្នង ។ មែនពិត បណ្ដាអមាត្យទាំងនោះ
អមាត្យ ឈ្មោះថា ឧត្តិយៈ បានឲ្យគេសាងវិហារ ឈ្មោះ ទក្ខិណៈ
ក្នុងទិសទក្សិណ អំពីក្រុងអនុរាធបុរី ។ អមាត្យ ឈ្មោះចូឡៈ បាន
ឲ្យគេសាងវិហារ ឈ្មោះថា ចូឡៈ ក្នុងទិសខាងកើត អំពីទក្ខិណ-
វិហារ ។ អមាត្យ ឈ្មោះ សាលិយៈ បានឲ្យគេសាងវិហារ ឈ្មោះ
សាលិយៈ ។ អមាត្យ ឈ្មោះបព្ជតៈ បានឲ្យគេសាងវិហារ ឈ្មោះ
បព្ជតៈ ។ អមាត្យ ឈ្មោះតិស្សៈ បានឲ្យគេសាងវិហារ ឈ្មោះ
ឧត្តរតិស្សៈ ។ អមាត្យទាំងនោះ បានឲ្យគេសាងវិហារ ទាំងអស់
រួចស្រេចហើយ ទើបអាជ្ញាធនានិមន្ត្រីព្រះហម្ពកណ្ណកមហាតិស្សត្ថេ
ដែលធ្លាប់ធ្វើឧបការគុណ ដល់ខ្លួន មកហើយ ក៏បានវេរប្រគេន
ព្រះវិហារទាំងនោះ ដល់ព្រះថេរៈនោះហើយ ។ ដោយហេតុនោះ
ទើបព្រះមហានាមត្ថេរ ពោលពាក្យជាគាថា ក្នុងគម្ពីរមហាវង្សថា៖

ក៏អមាត្យទាំងឡាយនោះ ពោលថា ដោយអំណាចនៃបដិ-
សណ្ឋារៈ របស់ព្រះគុណម្ចាស់ទាំងឡាយ ពួកខ្ញុំព្រះករុណា
ទើបសូមថ្វាយព្រះវិហារទាំងឡាយ ដែលពួកខ្ញុំព្រះករុណា
បានឱ្យកសាងហើយ ដល់ព្រះគុណទាំងឡាយ ដូច្នេះហើយ

ពណ៌នាអំពីសេចក្ដីគោរព

ក៏បានវេរប្រគេនហើយ, ព្រះបេរ: បានឱ្យភិក្ខុទាំងឡាយ នោះៗ នៅក្នុងព្រះវិហារទាំងពួង តាមសមគួរហើយ, ពួកអមាត្យទាំងឡាយ បានថ្វាយហើយ នូវគ្រឿងបរិក្ខាផ្សេងៗ ដែលសមគួរ ដល់សមណ: ដល់ព្រះសង្ឆ ។

*បណ្ដាបទទាំងនោះ បទថា "**បដិសណ្ដារវសេន**" មានសេចក្ដីថា ក៏អមាត្យទាំងនោះ ពោលថា បពិត្រព្រះគុណម្ចាស់ ដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមប្រគេនព្រះវិហារទាំងឡាយ ដែលពួកខ្ញុំព្រះករុណា បានឲ្យគេសាងរួចស្រេចហើយ ដល់ព្រះគុណម្ចាស់ទាំងឡាយ ដោយអំណាចនៃបដិសណ្ដារ: ដែលព្រះគុណម្ចាស់ទាំងឡាយ បានធ្វើហើយ ដល់ខ្ញុំព្រះករុណាទាំងឡាយ ជាអ្នកមិនមានទីពឹងក្នុងកាលមុន ។ បទថា "**សព្ពត្ត**" មានសេចក្ដីថា ព្រះបេរ: បានឲ្យពួកភិក្ខុ មាននិកាយ ៥ នោះៗ នៅ ក្នុងព្រះវិហារទាំងឡាយ តាមសមគួរ ។ បទថា "**សមណារហោ**" មានសេចក្ដីថា ពួកអមាត្យទាំងឡាយ បានប្រគេននូវបច្ច័យ ៤ មានចីវរជាដើម ដែលសមគួរ គឺ ដែលជាកប្ប្យ: ដល់សមណ:ទាំងឡាយ ដល់ព្រះសង្ឆហើយ ដូច្នេះឯង ។*

រឿង អមាត្យរបស់ព្រះបាទបិតុរាជ ចប់ ។

(២៨០) ក៏ព្រះបាទបិតុរាជ ទ្រង់ស្ថិតនៅ ក្នុងរាជសម្ផត្តិ

ម្ដងទៀតហើយ ទ្រង់បានបំពេញបុណ្យជាច្រើន និង ទ្រង់ត្រាស់បញ្ជា ឲ្យសរសេរព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ទុកក្នុងស្លឹករ៉ាត ទ្រង់ស្ថិតនៅ រហូតព្រះជន្មាយុហើយ ទើបទ្រង់ស្ដេចសោយទិវង្គតទៅ ។ កាលបើព្រះអង្គ ទ្រង់ស្ដេចទិវង្គទៅហើយ, ពួកអមាត្យ ក៏បានអភិសេក នូវព្រះបាទមហាចូឡិកៈ ដែលជាព្រះរាជនត្តា របស់ព្រះអង្គ ក្នុងរាជសម្បត្តិ ។

គ្រានោះ ព្រះរាជាព្រះនាមមហានាគ ដែលជាព្រះរាជបុត្ត របស់ព្រះអង្គ ទ្រង់ព្រះពិរោធហើយ កាលទ្រង់ធ្វើចោរកម្ម ព្រោះហេតុតែរាជសម្បត្តិ ទ្រង់បានគង់នៅ ក្នុងទីនោះៗ ក្នុងជនបទ, ព្រះអង្គ ទ្រង់បានទីជាទីគង់នៅ ក្នុងព្រះវិហារណាៗ ទ្រង់សព្វព្រះទ័យហើយ ។ ចំណែក ក្នុងវិហារណា, ពួកភិក្ខុទាំងឡាយ មិនថ្វាយទីគង់នៅ ដល់ព្រះអង្គ, ព្រះអង្គ ទ្រង់ព្រះពិរោធហើយ ចងពៀរ ក្រោយមក ទ្រង់បានគ្រងរាជសម្បត្តិហើយ ទើបទ្រង់ត្រាស់បញ្ជា ឲ្យគេរើរុះវិហារទាំងឡាយនោះៗ ចោលទាំងអស់ហើយ ។ ដោយហេតុនោះ ព្រះមហានាមត្ថេរ ទើបពោលពាក្យជាគាថា ក្នុងបរិច្ឆេទ ទី ៣៥ នៃគម្ពីរមហាវង្ស ថា ៖

“ ក្នុងកាលនោះ ព្រះឱរស របស់ព្រះរាជា ទ្រង់ព្រះនាម វដ្ដ-
គាមណីអភ័យ ទ្រង់បានប្រព្រឹត្តជាចោរ ក្នុងរជ្ជកាល នៃ

ពណ៌នាអំពីសេចក្តីគោរព

ព្រះបាទមហាចូឡិក: ទ្រង់ប្រាកដ ព្រះនាមថា ព្រះបាទ
ចោរនាគ កាលបើព្រះមហាចូឡិក: ទ្រង់បានលះបង់
រាជសម្បត្តិហើយ, ទើបព្រះអង្គស្តេចយាងមក គ្រប់គ្រង
នូវរាជសម្បត្តិ, ព្រះអង្គជាក្សត្រ មានព្រះបញ្ញាលូង់ខ្លៅ ព្រះ
អង្គ មិនបាននូវទីគង់នៅ ក្នុងវិហារទាំងឡាយណា ក្នុង
ពេលដែលព្រះអង្គជាចោរ ព្រះអង្គ ទ្រង់បានត្រាស់បញ្ជាឱ្យ
គេរុះរើ នូវវិហារទាំងឡាយនោះ ១៨ កន្លែង " ។

*បណ្តាបទទាំងឡាយ បទថា "**អាគតោ**" គឺ ស្តេចយាង
មកអំពីជនបទ កាន់អនុរាជបុរី ។ បទថា "**យេសុ**" គឺ ក្នុងវិហារ
ទាំងឡាយណា ។ ព្រះបាទចោរនាគនោះ ជាព្រះរាជា លាមក
អាក្រក់ ត្រូវព្រះទេវី របស់ព្រះអង្គ ឲ្យសោយថ្នាំពិស ទ្រង់ទិវង្គត
ហើយ ក៏បានទៅកើត ក្នុងលោកន្តរិកនរក ដោយប្រការដូច្នេះ ។*

រឿង ព្រះបាទចោរនាគ ចប់ ។

ពណ៌នាអំពីការធ្វើបដិសណ្ឋារ: ចប់ ។

(ការមិនធ្វើបដិសណ្ឋារ: ជាអពមង្គល)

*(២៨១) ម៉ាងទៀត ធម្មតាគ្រហស្ត គប្បីជាអ្នកមានសេចក្តី
គោរព ក្នុងព្រះពុទ្ធ ជាដើម ដូចជាពួកជនដែលរស់នៅ ក្នុងនិគម
ឈ្មោះ អស្សបុរ: ក្នុងជនបទ ដូច្នោះឯង ។*

-៤៣៧-

មន្តលត្ថនីបនីប្រែ

នយដែលមក ក្នុងអដ្ឋកថានៃមហាអស្សបុរសូត្រនោះ ថា៖ “ បានញ្ចមកថា មនុស្សទាំងឡាយ ក្នុងនិគមនោះ ជាអ្នកមានសទ្ធាជ្រះថ្លាហើយ ជាពុទ្ធមាមក: ធម្មមាមក: សង្ឆមាមក: យើញ សូម្បីនូវសាមណេរ ដែលបានបួសហើយ ក្នុងថ្ងៃនោះ ក៏ធ្វើដូចជាព្រះថេរ:ដែលមានវស្សាដល់ទៅ ១០០, បានយើញ នូវភិក្ខុសង្ឆ ដែលនិមន្តចូលទៅបិណ្ឌបាត ក្នុងបុព្វណ្ហសម័យហើយ កំពុងតែកាន់នូវគ្រឿងឧបករណ៍ មានពូជស្រូវ និង នង្គ័ល ជាដើម ដើរទៅកាន់ស្រែក្តី កំពុងតែកាន់នូវគ្រឿងសស្ត្រា មានកាំបិតព្រា ជាដើម ដើរចូលទៅ កាន់ព្រៃក្តី ក៏បានទម្លាក់គ្រឿងឧបករណ៍ ទាំងនោះ ចោលហើយ នាំគ្នាបោសសំអាត នូវទីសម្រាប់គង់ សាលាធាន់ មណ្ឌប ឬ គល់ឈើ ក្រាលនូវអាសន:ទាំងឡាយ ចាត់តាំងជើងបាត្រ និង ទឹកសម្រាប់ធាន់ ទុកស្រេចហើយ ដើម្បីព្រះភិក្ខុសង្ឆ បាននិមន្តភិក្ខុសង្ឆ ឲ្យគង់ហើយ ក៏ប្រគេននូវយាគូ និង គ្រឿងចង្ហាន់ជាដើម បានជូនដំណើរភិក្ខុសង្ឆ ដែលលោកបានធ្វើភត្តកិច្ចស្រេចហើយ បន្ទាប់អំពីនោះ ទើបបានកាន់យកឧបករណ៍ ទាំងឡាយនោះ ទៅកាន់ស្រែ ឬ ព្រៃ ហើយ ធ្វើការងារ របស់ខ្លួនៗ ។ សូម្បីក្នុងកន្លែងធ្វើការងារ ឈ្មោះថា ការសន្ទនាប្រាស្រ័យគ្នាដទៃមិនមាន ដល់ជនទាំងឡាយនោះឡើយ ។ ពួកជនទាំងឡាយនោះ

ពណ៌នាអំពីសេចក្ដីគោរព

តែងពោលសរសើរនូវគុណ របស់ព្រះកិក្ខុសង្ឆ តែប៉ុណ្ណោះ ថា បុគ្គលទាំងឡាយ ៨ ពួក លោកអ្នកដែលតាំងនៅ ក្នុងមគ្គ ៤ លោកអ្នកដែលតាំងនៅ ក្នុងផល ៤ ឈ្មោះថា ព្រះអរិយសង្ឆ, បុគ្គលទាំង ៨ ពួកនោះ ជាអ្នកប្រកបព្រម ដោយសីល យ៉ាងដូច្នេះ ដោយការប្រព្រឹត្ត យ៉ាងដូច្នេះ ដោយការប្រតិបត្ដិ យ៉ាងដូច្នេះ ជាអ្នកមានសេចក្ដីអៀនខ្មាស មានសីលជាទីស្រលាញ់ មានគុណដ៏ល្អប្រសើរ ដូច្នេះ ។ ពួកជនអ្នកនៅ ក្នុងអស្សបុរនិគមទាំងនោះ មកអំពីធ្វើការងារ ទទួលទានអាហារល្ងាចស្រេចហើយ អង្គុយនៅ ត្រង់មាត់ទ្វារផ្ទះក្ដី ចូលទៅកាន់បន្ទប់ដេកហើយ អង្គុយក្ដី រមែងពោលសរសើរ នូវគុណរបស់ព្រះកិក្ខុសង្ឆតែម្យ៉ាង ។

ព្រះមានព្រះភាគ ទ្រង់ទតព្រះនេত্রឃើញការនមស្សការគោរព នៃពួកមនុស្សទាំងឡាយនោះហើយ កាលទ្រង់អាស្រ័យនូវនិគមនោះ ស្ដេចគង់នៅ ទើបទ្រង់សម្ដែង នូវមហាអស្សបុរសូត្រ ក្នុងចតុត្ថវគ្គ នៃមូលបណ្ណាសក: " ។

(២៨២) ដីកាមហាអស្សបុរសូត្រនោះ ថា " ក្នុងពាក្យថា ***ឯវរូបេន សីលេន*** *ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖ ព្រះអដ្ឋកថាចារ្យ ពោល ភវិតសីល (សីល ដែលព្រះពុទ្ធទ្រង់ហាម ដែលជាព្រះពុទ្ធអាជ្ញា) ដោយ* ***សីល*** *សព្ទ ។ សំដែង*

មង្គលត្ថទីបនីប្រែ

*សម្ចាវាចា សម្ចាកម្មន្ត: និង សម្ចាអាជីវ: ដោយ **សីល** សពួ នោះ ។ សម្តែង ចារិត្តសីល (សីលគឺជាចរិយាដែលគប្បីប្រព្រឹត្ត) ដោយ **អាចារ** សពួ ។ សម្តែងកាយសមាចារ និង វចីសមាចារ ដែលបរិសុទ្ធល្អ ដោយ **អាចារ** សពួនោះ ។ សម្តែង សម្ចា-បដិបត្តិ ដែលសង្គ្រោះ ដោយសមថ: វិបស្សនា មគ្គ និង ផល ដោយ **បដិបត្តិ** សពួ ។ ដោយបទថា **លជ្ជិនោ** នេះ ព្រះអដ្ឋកថា-ចារ្យ សម្តែងនូវហេតុ ដែលជាឫសគល់ នៃសីល និង អាចារ ដូចបានពោលមកហើយ ។ ដោយបទថា **ឧបាសកា** នេះ ព្រះ អដ្ឋកថាចារ្យសម្តែងសេចក្តីបរិសុទ្ធិ ។ ដោយបទថា **ឧឡារគុណា** នេះ ព្រះអដ្ឋកថាចារ្យ សម្តែងសេចក្តីបរិបូណ៌នៃការប្រតិបត្តិ ។ ព្រះអដ្ឋកថាចារ្យ សម្តែងពាក្យនេះ ថា **ភិក្ខុសង្ឆ្យេវ ឯណ្ណ ភវន្តិ** ព្រោះភាវ:នៃឧបាសកឧបាសិកាទាំងនោះ ជាអ្នកខ្ជាប់ខ្ជួយ ក្នុងកិត្តិគុណ របស់ភិក្ខុទាំងឡាយ ដោយច្រើន ។ ក៏ជនទាំងឡាយ នោះ ជាអ្នកជ្រះថ្លា យ៉ាងក្រៃលែង ទាំងក្នុងព្រះសទ្ធម្ម ទាំងក្នុងព្រះ សម្មាសម្ពុទ្ធ ដោយពិត ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **ពុទ្ធមាមកា ធម្មមាមកា សង្ឆមាមកា** ដូច្នេះ ។ មែនពិត ក្នុងវត្ថុទាំងបី ជនទាំងឡាយ ជ្រះថ្លាក្រៃលែងហើយ ក្នុង វត្ថុ ១ ឈ្មោះថា ជ្រះថ្លាក្រៃលែងហើយ ក្នុងវត្ថុទាំង ២ ដទៃទៀត*

ដែរ ព្រោះការៈនៃវត្ថុទាំងបីនោះ គ្មានការបែកចេញពីគ្នាបាន " ។

(២៨៣) ចំណែក បព្វជិត ក៏គប្បីជាអ្នកមានសេចក្ដីគោរព ដល់គ្នានឹងគ្នា ដូចសត្វទាំងបី ដែលជាសំឡាញ់នឹងគ្នាយ៉ាងដូច្នោះ ។

(រឿង សត្វទាំង ៣ ចេះគោរពគ្នា)

បានឮថា ក្នុងអតីតកាល សត្វទាំងឡាយ ៣ ជាសំឡាញ់គ្នា គឺ សត្វទទា ១ សត្វស្វា ១ សត្វជ្រូ ១ អាស្រ័យ នូវដើមជ្រៃដ៏ធំ មួយដើម រស់នៅ ក្នុងហិមវន្តប្រទេស ។ ជាដំបូង សត្វទាំង ៣ នោះ រស់នៅ មិនគោរព ដល់គ្នានឹងគ្នាទេ ព្រោះមិនដឹងថា "អ្នកនេះ ជាអ្នកចាស់ជាង " ។ ថ្ងៃមួយ សត្វទាំងនោះ គិតគ្នា ថា "ការដែលពួកយើងរស់នៅ ដោយអាការយ៉ាងនេះ មិនសមគួរទេ្ធយ, បើដូច្នោះ មានតែពួកយើងទាំងឡាយ, បុគ្គល ណាមួយ ដែលជាអ្នកចាស់ ជាងពួកយើង, គប្បីធ្វើនូវការកិច្ចទាំងឡាយ មានការក្រាបថ្វាយបង្គំជាដើម ដល់បុគ្គលនោះ តាំងនៅ ក្នុងឱវាទ នៃបុគ្គលនោះចុះ " ដូច្នេះហើយ ទើបបានសួរគ្នានឹងគ្នាថា "ម្នាលសំឡាញ់ទាំងឡាយ ! ពួកអ្នកទាំងឡាយ ស្គាល់ នូវដើមជ្រៃនេះ ចាប់តាំងអំពីដើមជ្រៃនេះ មានទំហំប៉ុនណាមក ? " ។

លំដាប់នោះ សត្វជ្រូ ពោលថា "ម្នាលសំឡាញ់ទាំងឡាយ ក្នុងកាលដែលខ្ញុំនៅជាកូនជ្រូតូចៗ ខ្ញុំ ដើរទៅ ប៉ះគុម្ពជ្រៃនេះ នៅ

មន្ថលត្ថទីបនីប្រែ

ត្រង់ចន្ទោះនៃភ្ជៅទាំង ២ និង ក្នុងពេលដែលខ្ញុំធំឡើងហើយ មែក
បណ្ណូល នៃដើរជ្រៃនេះ តែងកកិតនូវផ្ទិត របស់ខ្ញុំ, ដូច្នេះ ខ្ញុំ ស្គាល់
នូវដើមជ្រៃនេះ តាំងពីពេលដែលខ្ញុំនៅជាក្មេងតូចៗ មកម្ល៉ះ " ។

សត្វស្វា ពោលថា " ម្នាលសំឡាញ់ទាំងឡាយ ! ខ្ញុំ កាល
នៅជាកូនស្វា ជៅដោះនៅឡើយ អង្គុយ លើផែនដី មិនចាំបាច់
ងើយ-ក ឡើយ ខាំស៊ីបណ្ណូល (ត្រួយខ្ចី) នៃដើមជ្រៃនេះបាន,
ដូច្នេះ ខ្ញុំ ស្គាល់នូវដើមជ្រៃនេះ តាំងតែពីពេលដែលខ្ញុំនៅពីក្មេង
តូចៗ មកម្ល៉ះ " ។

លំដាប់នោះ សត្វទទា ពោលថា " ម្នាលសំឡាញ់ទាំង
ឡាយ ! ក្នុងកាលមុន ដើមជ្រៃធំនេះ មាននៅក្នុងទីឯណោះ, ខ្ញុំ ស៊ី
ផ្ទែ នៃដើមជ្រៃធំនោះហើយ បានជុះអាចម៍ ក្នុងទីនេះ, ដើរជ្រៃ
ធំនេះ កើតហើយ អំពីអាចម៍ របស់ខ្ញុំនោះ, ដូច្នេះ ខ្ញុំ ស្គាល់ដើមជ្រៃ
ធំនេះ តាំងពីពេលដែលដើមជ្រៃនេះកើតហើយ, ព្រោះហេតុនោះ ខ្ញុំ
ជាអ្នកចាស់ ជាងពួកអ្នកទាំងឡាយ " ។

ចាប់តាំងតែអំពីពេលនោះមក សត្វស្វា និង សត្វជំរីទាំង ២
នោះ ក៏ប្រព្រឹត្តឧនលំទោនសត្វទទានោះ ដោយការធ្វើសក្ការៈ
គោរព និង កិរិយាថ្វាយបង្គំជាដើម បានស្ថិតនៅហើយ ក្នុងឧវាទ
របស់សត្វទទានោះ ។ ឯសត្វទទានោះ ក៏បានឲ្យសត្វទាំង ២ នោះ

ពណ៌នាអំពីសេចក្ដីគោរព

តាំងនៅ ក្នុងសីល ៥ សូម្បីខ្លួនឯង ក៏សមាទានហើយ នូវសីល ៥ ។ សត្វទាំង ៣ នោះ តាំងនៅហើយ ក្នុងបញ្ចសីល មានសេចក្ដីគោរព គោតក្រែង ដល់គ្នាទៅវិញទៅមក ក្នុងពេលអស់អាយុ ក៏បានទៅកើត ក្នុងទេវលោក ។ រ្ត ដែលសត្វជាសំឡាញ់នឹងគ្នា ទាំង ៣ នោះ បានសមាទានហើយ បានឈ្មោះថា ជា ***តិត្ថិរព្រហ្មចរិយៈ*** *។*

ចំណែកព្រះសាស្តា លុះទ្រង់នាំអតីតនិទានមក (សម្ដែង) យ៉ាងនេះហើយ កាលទ្រង់ឧ្រាទនូវភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏ឈ្មោះថា សត្វទាំងឡាយនោះ គ្រាន់តែជាសត្វតិរច្ឆាន រស់នៅ មានសេចក្ដីគោរព គោតក្រែង ដល់គ្នានឹងគ្នា, ចំណែក អ្នកទាំងឡាយ បួសហើយ ក្នុងព្រះធម្មវិនយ ដែលតថាគត សម្ដែងល្អហើយ យ៉ាងនេះ ព្រោះហេតុអ្វី ទើបរស់នៅ មិនមានសេចក្ដីគោរព គោតក្រែង ដល់គ្នាទៅវិញទៅមក? " ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ ទើបទ្រង់បានត្រាស់ នូវព្រះគាថានេះ ក្នុងតិត្ថិរជាតក ក្នុងចតុត្ថវគ្គ នៃឯកនិបាត [១] ថា ៖

(២៨៤) ពួកជនណា ជាអ្នកឈ្លាស ក្នុងធម៌ ប្រព្រឹត្ត**គោ**ត
ក្រែងបំពោះបុគ្គលដ៏ចំណេះ**ហើ**យ, ពួ**ក**ជ**ន**នោ**ះ** **អ**្ន**ក**ផ**ង**

១- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ១៧ ។

មន្តលត្ថនីបនីប្រែ

គប្បីសរសើរ ក្នុងបច្ចុប្បន្នផង, សម្បរលោក របស់ពួក ជននោះ ក៏ជាសុគតិផង ។

*បណ្តាបទទាំងនោះ ក្នុងបទថា " **វុឌ្ឍំ** " នេះ បានដល់ បុគ្គលអ្នកចម្រើនទាំងឡាយ ៣ គឺ ជាតិវុឌ្ឍ វយវុឌ្ឍ គុណវុឌ្ឍ ។ បណ្តាវុឌ្ឍបុគ្គលទាំង ៣ ពួកនោះ បុគ្គល អ្នកដល់ព្រមហើយ ដោយជាតិ ឈ្មោះថា **ជាតិវុឌ្ឍ** ។ បុគ្គល អ្នកតាំងនៅហើយ ក្នុងវ័យ ឈ្មោះថា **វយវុឌ្ឍ** ។ បុគ្គល អ្នកដល់ព្រមហើយ ដោយគុណ ឈ្មោះថា **គុណវុឌ្ឍ** ។ បណ្តាវុឌ្ឍបុគ្គលទាំង ៣ ពួកនោះ បុគ្គល អ្នកចម្រើនដោយវ័យ បរិបូណិហើយ ដោយគុណ ព្រះមានព្រះភាគ ទ្រង់ព្រះបំណងថា " វុឌ្ឍ: " ក្នុងបទថា " **វុឌ្ឍំ** " នេះ ។ បទថា " **អបចាយន្តិ** " គឺ រមែងបូជា ដោយកម្ម គឺការប្រព្រឹត្តិ កោតក្រែង ចំពោះអ្នកដែលចម្រើន ។ ២ បទថា " **ធម្មស្ស កោវិទោ** " បានដល់ ជាអ្នកឆ្លាត រាងវៃ ក្នុងជេដ្ឋាបចាយនធម៌ ។ ២ បទថា " **ទិដ្ឋេ ធម្មេ ច** " បានដល់ ក្នុងអត្តភាពនេះឯង ។ បទថា " **បាសំសា** " គឺ គួរដល់ការសរសើរ ។ បាទគាថា ថា " **សម្បរាយោ ច សុគ្គតិ** " មានសេចក្តីថា ភព ឈ្មោះថា សម្បរាយ: ព្រោះអត្ថថា សត្វទាំងឡាយ គប្បីដល់ព្រម ព្ធដ៏ខាងមុខ គឺលះលោកនេះទៅហើយ គប្បីដល់ បានដល់ បរលោក*

ពណ៌នាអំពីសេចក្ដីគោរព

អធិប្បាយថា បរលោក របស់ពួកជននោះ រមែងជាសុគតិ ពិត ។

ក៏ក្នុងគាថានេះ ប្រមូលយកសេចក្ដី មានដូចតទៅនេះ ថា៖ "ម្នាលកិកូទាំងឡាយ សត្វទាំងឡាយ ឯណាមួយ ទោះជាក្សត្រីក្ដី ព្រាហ្មណ៍ក្ដី អ្នកជំនួញក្ដី អ្នកថោកទាបក្ដី គ្រហស្ថក្ដី បព្វជិតក្ដី សត្វតិរច្ឆានក្ដី ជាអ្នកឈ្លាសវាងវៃ គឺធ្លាត ក្នុងជេដ្ឋាបចាយនធម៌ រមែងធ្វើសេចក្ដីគោរព កោតក្រែង ចំពោះបុគ្គលអ្នកចម្រើន ដោយវ័យទាំងឡាយ ដែលដល់ព្រម ដោយគុណ, សត្វទាំងឡាយនោះ រមែងបាននូវសេចក្ដីសរសើរ គឺ កោតសរសើរ និង ការស្ងើចសរសើរ ថា ជាអ្នកប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលអ្នកដែលចម្រើនបំផុត ដូច្នេះ ក្នុងអត្តភាពនេះ និង ព្រោះការបែកធ្លាយទៅនៃរាងកាយ រមែងទៅកើត ក្នុងឋានសួគ៌ " ។

រឿង សត្វដែលជាសំណាញ់នឹងគ្នា ចប់ ។

ការពណ៌នាអំពីបទថា សេចក្ដីគោរព ចប់ ។

❊ ❊ ❊

បានប្រែចប់សព្វគ្រប់
ថ្ងៃសៅរ៍ ១២ រោច ខែទុតិយាសាធ ឆ្នាំរកា បញ្ចស័ក ព. ស. ២៥៣៦
ត្រូវនឹងថ្ងៃ ទី ១៤ ខែសីហា ១៩៩៣ វេលាយប់

ពណ៌នារំពឹការប្រព្រឹត្តិបន្ទាបខ្លួន

(២៨៥) ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថា ថា " ភាពជាអ្នកមានចិត្តឱនលំទោន គឺ ភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ឈ្មោះថា **និវាត:** ។ បុគ្គល អ្នកប្រកបព្រមហើយ ដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ឯណា មានមានះដាក់ចុះហើយ ជាអ្នកមានសេចក្តីរឹងត្អឹង ដាក់ចុះហើយ ជាអ្នកប្រាកដ ស្មើដោយកំណាត់សំពត់សម្រាប់ជូតជើង ជាអ្នកស្មើដោយគោឧសភ ដែលមានស្នែងបាក់ហើយ និង ជាអ្នកស្មើដោយពស់មានពិស ដែលត្រូវគេដកយកចង្ក្ពូមចេញហើយ ជាអ្នកមានវាចាដ៏ទន់ភ្ងន់ មានវាចានាំមកនូវភាវ: នៃបុគ្គលជាទីស្រលាញ់ មានវាចាពោល នាំមកនូវសេចក្តីសុខ, នេះ ឈ្មោះថា **និវាត:** (សេចក្តីប្រព្រឹត្តិបន្ទាបខ្លួន) " ។

(២៨៦) ចំណែកក្នុងអដ្ឋកថា បញ្ចកនិបាត អង្គុត្តរនិកាយ លោកពោលថា " (ព្រះអរិយសាវ័កទាំងឡាយ រមែងសេពគប់) នូវបុគ្គលអ្នកប្រព្រឹត្តបន្ទាប់ខ្លួន " ។

ដីកាបញ្ចកនិបាត អង្គុត្តរនិកាយនោះ ថា " នូវបុគ្គលអ្នកមានសេចក្តីឱនលំទោន ជាប្រក្រតី " ។

អដ្ឋកថាកុលទូសកសិក្ខាបទ ថា " បទថា **សណ្ហា** មានសេចក្តីថា ដ៏ល្អិត គឺឆ្ងាត ដើម្បីបង្អោនចូលទៅកាន់ជនជាឧបាសកក្នុងឋាន: ដ៏សមគួរ យ៉ាងដូច្នេះថា បពិត្រអ្នកម្តាយ លោកឪពុក

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

*បង្ស្រី ។ បទថា **សទិលា** បានដល់ ប្រកបហើយដោយសេចក្តីនឹមនួន ។ ពាក្យថា **សុខសម្ភាសា** នេះ ជាពាក្យពោលដល់ហេតុនៃពាក្យខាងដើម ។ មែនពិត វាចា របស់ព្រះអស្សជិ និង ព្រះបុនព្វសុក: ទាំងឡាយណា ជាវាចាពោល នាំមកនូវសេចក្តីសុខ ជាវាចានាំមកនូវសេចក្តីរីករាយ ជាវាចាមិនមានទោស ពីរោះដល់ត្រចៀក, ព្រះអស្សជិ និង ព្រះបុនព្វសុក:ទាំងឡាយនោះ ជនអ្នកនៅក្នុងកិដាគិរីជនបទ ហៅថា ជាអ្នកមានវាចា នាំមកនូវភាវ: នៃបុគ្គលជាទីស្រលាញ់ យ៉ាងដូច្នេះ " ។*

*អដ្ឋកថាទុកនិបាត អង្គុត្តរនិកាយនោះថា "ភាវ:នៃបុគ្គលជាអ្នករីករាយសប្បាយ ដោយអំណាចវាចាដ៏ផ្អែមល្ហែម ឈ្មោះថា **សាខល្យំ** " ។*

*ជីកាទុកនិបាត អង្គុត្តរនិកាយនោះថា " បុគ្គល អ្នកមានវាចាផ្អែមល្ហែម លោកហៅថា **សទិល:** ។ ភាវ:នៃបុគ្គលអ្នកមានវាចាដ៏ផ្អែមល្ហែមនោះ ឈ្មោះថា **សាខល្យំ** គឺភាពជាអ្នកមានវាចាដ៏ផ្អែមល្ហែម ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **សណ្ហវាចាវសេន សម្មោទមានភាវោ** ដូច្នេះ ។ មែនពិត ឈ្មោះថា ភាវ:នៃបុគ្គលអ្នករីករាយ ដោយអំណាចវាចាដ៏ទន់ភ្ងន់ ឈ្មោះថា ភាវ:នៃបុគ្គលជាអ្នកមានវាចាដ៏ទន់ភ្ងន់ " ។*

មន្ថលត្ថទីបនីប្រែ

អដ្ឋកថាសង្គីតិសូត្រ ថា " ភាវៈនៃបុគ្គលជាអ្នកវីកវាយ សប្បាយ និង ត្រេកអរ ឈ្មោះថា **សាខល្យំ** " ។

ជីកាសង្គីតិសូត្រ ថា " ភាវៈនៃបុគ្គលអ្នកវីកវាយ ជាអ្នកត្រេកអរ ឈ្មោះថា **មទូវៈ** គឺ ភាវៈនៃបុគ្គលអ្នកវីកវាយ និង ត្រេកអរ " ។

ចាលីនិក្ខេបកណ្ឌ ថា " ភាវៈជាអ្នកមានវាចាជ៏ទន់ភ្លន់ ភាវៈជាអ្នកមានវាចាជាទីស្រលាញ់ ភាវៈជាអ្នកមានវាចាមិនអាក្រក់ ក្នុងបុគ្គលនោះ ឯណា, នេះ តថាគត ហៅថា **សាខល្យំ** " ។

អដ្ឋកថានិក្ខេបកណ្ឌនោះ ថា " ២ បទថា **យា តត្ត** គឺ ក្នុងបុគ្គលនោះ ឯណា ។ ភាវៈនៃបុគ្គលជាអ្នកមានវាចា ជ៏ល្អិតម៉ដ្ឋ ឈ្មោះថា **សណ្ហវាចតា** ។ ភាវៈនៃបុគ្គលជាអ្នកមានវាចា ជ៏ទន់ភ្លន់ ឈ្មោះថា **សខិលវាចតា** ។ ភាវៈនៃបុគ្គលជាអ្នកមានវាចា មិនរឹងរូស ឈ្មោះថា **អផរុសវាចតា** " ។

(២៨៧) មែនពិត ទោះបីបុគ្គលណា (ក៏ដោយ) កាលឃើញ ទោសនៃភាពជាអ្នករឹងត្អឹង ដោយអំណាចនៃការប្រកាន់ខ្ជួន ក្រៃលែង គប្បីជាអ្នកមានការប្រព្រឹត្តិបន្ទាបខ្ជួន មិនរឹងត្អឹង ។ ព្រោះថា ភាវៈនៃបុគ្គលជាអ្នករឹងត្អឹង ជាហេតុនៃសេចក្តីវិនាស ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា ៖

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

(២៨៤) " នរជនឯណា ជាអ្នកប្រកាន់ដោយជាតិ ប្រកាន់ដោយទ្រព្យ ប្រកាន់ដោយគោត្រ រមែងមើលងាយ នូវញាតិរបស់ខ្លួន, កម្មទាំង ៤ យ៉ាង របស់នរជននោះ ជាប្រធាននៃសេចក្តីវិនាស " ។

អដ្ឋកថាបរាភវសូត្រនោះ ថា " បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា ញុាំងមានះ ឲ្យកើតឡើងហើយ ថា អាត្មាអញ ជាអ្នកបរិបូណិហើយ ដោយជាតិ ដូច្នេះ ជាអ្នករឹងរូស ដោយមានះ នោះ ជាអ្នកថ្យ៉ាងឡើងហើយ ដូចជាស្នប់ដែលពេញ ដោយឧ្យល់ មិនឌ៉ិនលំទោន ដល់អ្នកណាមួយ, បុគ្គលនោះ ឈ្មោះថា ជាអ្នករឹងរូស ដោយជាតិ ។ ក្នុងបុគ្គលអ្នករឹងរូស ដោយទ្រព្យ និងដោយគោត្រ ក៏នយនេះដូចគ្នាដែរ ។

*២ បទថា **សញ្ញាតឹ អតិមញ្ញតិ** មានសេចក្តីថា តែងមើលងាយសូម្បីនូវញាតិរបស់ខ្លួន ដោយជាតិ ដូចពួកស្តេចសាកិយ: ទ្រង់មើលងាយ នូវព្រះរាជកុមារព្រះនាមវិឌូឌភ: យ៉ាងដូច្នោះឯង, មួយទៀត រមែងមើលងាយ ដោយទ្រព្យផងថា អ្នកនេះ ជាមនុស្សកំព្រា ក្រីក្រ ដូច្នេះ មិនធ្វើសូម្បីនូវកិច្ចត្រឹមតែសាមីចិកម្ម ។ ពួកញាតិទាំងនោះ រមែងប្រាថ្នា នូវសេចក្តីវិនាសតែម្យ៉ាង ដល់បុគ្គលនោះ ។ ដោយព្រះគាថានេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់កម្ម*

ទាំង ៤ យ៉ាង ដោយហេតុថា ជាប្រធាននៃសេចក្ដីវិនាសតែម្យ៉ាង ប៉ុណ្ណោះឯង ដោយលក្ខណៈ" ។

*ក៏ក្នុងពាក្យថា " **សក្យា ឯវ ឯ ១ ១ ១ ១** " នេះ មានសេចក្ដីថា ដូចជាស្ដេចសាកិយៈទាំងឡាយ មើលងាយព្រះរាជកុមារ ទ្រង់ព្រះនាមថា ១ ១ ១ ១ ដូច្នោះឯង ។*

(១ ១ ១ ១ ១ ១ ១ ១ ១ ១ ១ ១)

(២៨៨) បានឮមកថា ស្ដេចសាកិយៈ ទ្រង់ព្រះនាមថា ព្រះមហានាម ជាព្រះជេដ្ឋភាតា របស់ព្រះអនុរុទ្ធ ជាព្រះរាជបុត្ត របស់ចូឡបិតា នៃព្រះសាស្ដា ទ្រង់នៅរួមជាមួយនាងទាសី របស់ព្រះអង្គ ឈ្មោះនាងមុណ្ឌា ទ្រង់បានព្រះធីតា ព្រះនាមថា ព្រះនាងវាសភ១ត្ថិយា ទ្រង់ថ្វាយព្រះរាជធីតា ដែលមានព្រះជន្ម ១៦ ព្រះវស្សា ដល់ព្រះបាទបសេនទិកោសល ។ ព្រះនាងវាសភ១ត្ថិយានោះ ទ្រង់អាស្រ័យនូវព្រះរាជា ទ្រង់បានហើយ នូវព្រះរាជបុត្ត ទ្រង់ព្រះនាមថា ១ ១ ១ ១ ។ ព្រះរាជកុមារ ព្រះនាម ១ ១ ១ ១ ក្នុងកាលដែលព្រះអង្គ មានព្រះជន្មបាន ១៦ ព្រះវស្សា ទ្រង់មានព្រះបំណងចង់គាល់ព្រះញាតិទាំងឡាយ របស់ព្រះអង្គ ទ្រង់ស្ដេចយាងទៅក្រុងកបិលព័ស្ដុ ទ្រង់បានគង់នៅ ក្នុងព្រះនគរនោះ ២-៣ ថ្ងៃ ហើយ ទើបស្ដេចយាងត្រឡប់មកវិញ ។

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

លំដាប់នោះ នាងទាសីម្នាក់ ត្រូវស្តេចសាកិយៈទាំងឡាយ ត្រាស់បញ្ជាហើយ ទើបបានជេរប្រទេចផ្ទួនៗ ថា " នេះ ជាបន្ទុះ ក្តារ ដែលកូននាងទាសីអង្គុយ " ដូច្នេះហើយ ទើបយកទឹកដោះ សុទ្ធ ទៅលាងបន្ទុះក្តារ ដែលព្រះរាជកុមារ ព្រះនាម វិឌូឌភ: នោះ ទ្រង់បានគង់ហើយ ។

ក្នុងខណៈនោះ រាជបុរស របស់ព្រះបាទវិឌូឌភរាជកុមារ ក្ងេចហើយនូវអាវុធ ទើបត្រឡប់មក ដើម្បីយកអាវុធនោះ បានឮ សំឡេងជេរប្រទេចនោះ ហើយទើបសួរ បានដឹងរឿងនោះអំពីនាង ទាសីនោះហើយ ក៏តាមទៅទាន់ហើយ ប្រាប់ដល់ពួកពល ។ សេចក្តីកោលាហលដ៏ធំ បានកើតឡើងហើយ ថា " បានឮមកថា ព្រះនាងវាសភខត្តិយា ជាធីតា របស់នាងទាសី " ។

ព្រះបាទវិឌូឌភ: រាជកុមារ ទ្រង់ព្រះសណ្តាប់សំឡេងនោះ ហើយ ទើបទ្រង់បានចង់នូវពៀរទុកថា " ពួកស្តេចសាកិយ: ទាំង ន៏ុ: ចូរលាងបន្ទុះក្តារ ដែលអញអង្គុយហើយ ដោយទឹកដោះសុទ្ធ មុនសិនចុះ, តែអាត្មាអញ ស្ថិតនៅ ក្នុងរាជសម្បត្តិហើយ នឹងញ៉ាំង បុគ្គលឲ្យលាងនូវបន្ទុះក្តារនោះ ដោយលោហិត ក្នុងបំពង់ក របស់ ស្តេចសាកិយៈទាំងនោះ " ដូច្នេះ ក្រោយមក ទ្រង់បានជាព្រះរាជា ហើយ បានស្តេចយាងទៅក្រុងកបិលព័ស្តុ ដោយពួកពលជាច្រើន

ទ្រង់បានត្រាស់បញ្ជា ថា " នែនាយ ស្តេចសាកិយ: ទាំងឡាយ ណាៗ ពោលថា យើងទាំងឡាយ ជាស្តេចសាកិយ: ដូច្នេះ, អ្នកទាំងឡាយ ចូរសម្ងាបពួកស្តេចសាកិយ:ទាំងអស់នោះៗ ចោល, ប៉ុន្តែ ពួកជនទាំងឡាយណា ឈរនៅហើយ ក្នុងព្រះដំណាក់ នៃស្តេច ព្រះមហានាម ដែលជាព្រះរាជអយ្យកោ, អ្នកទាំងឡាយ ចូរឲ្យនូវជីវិត ដល់ជនទាំងឡានោះចុះ " ដូច្នេះហើយ ទ្រង់ត្រាស់ បញ្ជា ឲ្យសម្ងាប់ពួកស្តេចសាកិយ:ទាំងអស់ ចាប់ផ្តើមពីពួកទារក ដែលនៅថ្មដោះ ហើយឲ្យលាងបន្ទះក្ការនោះ ដោយហិត ក្នុងបំពង់ក នៃស្តេចសាកិយ:ទាំងឡាយនោះ ។ ត្រកូលវង្សស្តេចសាកិយ: បានត្រូវព្រះបាទវិឌូឌភរាជកុមារ បំផ្លាញអស់ហើយ ដោយប្រការដូច្នេះ ។ សាកិយ:ទាំងឡាយនោះ បានដល់ហើយ នូវសេចក្តីវិនាស ដោយអំណាចកាពជាអ្នកមានមាន: ដ៏រ៉ាងគ្ម៉ីង ដោយជាតិ យ៉ាងដូច្នេះឯង ។ សេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនុ៎ះ មានតែប៉ុណ្ណេ: ។ ចំណែកឯ សេចក្តីពិស្តារ អ្នកសិក្សា គប្បីត្រួតពិនិត្យមើល ក្នុងអដ្ឋកថាបុប្ផវគ្គ នៃធម្មបទ និង ក្នុងអដ្ឋកថា ឆទ្ទសាលជាតក ក្នុងទ្វាទសនិបាត ។

រឿង ស្តេចសាកិយ: ចប់ ។

(២៨៩) ធម្មតាបុគ្គលអ្នកមានមាន: ដ៏ក្រៃលែង រមែងញ្ជាំង

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

យស ដែលកើតឡើងហើយ ឲ្យវិនាស បាត់ទៅ តែម្យ៉ាង ។ ក្នុងដំណើរនោះ មានរឿងដូចតទៅនេះ (ជាឧទាហរណ៍) ៖

(រឿង ឆ្កែចចកចង់ធ្វើជាស្តេច)

ក្នុងអតីតកាល បុរោហិត របស់ព្រះរាជាក្រុងពារាណសី បានជាអ្នកចេះមន្ត ឈ្មោះថា បឋវីជយៈ ។ មន្ត សម្រាប់បង្វិលចិត្ត លោកហៅថា “ បឋវីជយមន្ត ” ។

ក្នុងថ្ងៃមួយ បុរោហិតនោះ គិតថា “អាត្មាអញ នឹងទន្ទេញនូវមន្ត” ដូច្នេះ ទើបបានអង្គុយ លើខ្នងនៃថ្ម លើទីទួលមួយ ក្នុងព្រៃ ធ្វើការស្វាធ្យាយហើយ ក៏បានចៀសចេញទៅ ។ ក៏ក្នុងពេលដែលបុរោហិតនោះ ធ្វើការស្វាធ្យាយ ឆ្កែចចកមួយ ដេកនៅ ក្នុងរូងមួយ បានស្តាប់មន្តនោះហើយ ទើបបានធ្វើឲ្យស្ងាត់ជំនាញ ។ បានឮថា ឆ្កែចចកនោះ ក្នុងអត្តភាពដែលកន្ទង់ទៅហើយ ដោយលំដាប់ បានកើតជាព្រាហ្មណ៍ម្នាក់ ជាអ្នកមានមន្ត ឈ្មោះបឋវី-ជយៈ ដែលខ្លួនបានចាំស្ងាត់ជំនាញហើយ ។ ឆ្កែចចកនោះ ចូលទៅកាន់ព្រៃ ស្វាធ្យាយមន្តនោះហើយ បញ្ជាពួកឆ្កែចចក ជាច្រើនរយហើយ ធ្វើសត្វជើង ៤ ទាំងឡាយ ទាំងពួង មាន ដំរី សីហៈ ខ្លាធំ ជ្រូក និង ម្រីគជាដើម (ឲ្យនៅ) ក្នុងអំណាចរបស់ខ្លួន ហើយបានកើតជាស្តេច ឈ្មោះថា សព្វទាឋៈ បានធ្វើឆ្កែចចកញីមួយ ជា

មង្គលត្ថទីបនីប្រែ

អគ្គមហេសី ។ សត្វ រាជសីហ៍ ឈរនៅលើខ្នង នៃដំរីទាំងឡាយ ២ ។ ស្តេចក្អែចចក ឈ្មោះថា សព្វទាឋៈ អង្គុយនៅ លើខ្នង រាជសីហ៍ ជាមួយក្អែចចកញី ដែលជាអគ្គមហេសី ។ ស្តេចក្អែចចកនោះ បានជាសត្វមានយសសក្តិ យ៉ាងធំសម្បើមហើយ ។ ស្តេចក្អែចចកនោះ ស្រវឹងពេញទំហឹងហើយ ដោយភាពជាសត្វមានយសសក្តិធំ បានញ៉ាំងមានះ ឲ្យកើតឡើងហើយ ថា “អាត្មាអញ នឹងដណ្តើមយកនូវរាជសម្បត្តិ ក្នុងទីក្រុងពារាណសី ” ដូច្នេះ មានសត្វជើង ៤ ទាំងអស់ ចោមរោម បានទៅហើយ ។ បរិស័ទបានមានហើយ ១២ យោជន៍ ។ ស្តេចក្អែចចកនោះ បានបញ្ជូនព័ត៌មានទៅថ្វាយ ដល់ព្រះរាជា ដោយទូត ក្នុងទីដែលមិនឆ្ងាយអំពីព្រះនគរ មានជាអាទិ៍ ថា “ ព្រះរាជា ចូរឲ្យរាជសម្បត្តិ ឬក៏ចូរឲ្យនូវការធ្វើសង្គ្រាម ” ដូច្នេះ ។

មនុស្សទាំងឡាយ បានភ័យខ្លាចស្លុតស្លន់ហើយ ទើបបានបិទហើយនូវទ្វារនៃព្រះនគរ ។ បុរោហិត បានញ៉ាំងព្រះរាជា និងមនុស្សទាំងឡាយទាំងពួង ឲ្យត្រេកអរហើយ ពោលថា “អ្នកទាំងឡាយ ចូរកុំភ័យខ្លាចឡើយ, ការធ្វើសង្គ្រាម ជាមួយនឹងស្តេចក្អែចចកនោះ ចូរជាភារកិច្ច របស់ខ្ញុំ ” ហើយឡើងទៅ លើប៉ម ក្បែរទ្វារ ពោលថា “ នែសព្វទាឋៈសំឡាញ់ តើអ្នកនឹងធ្វើឧបាយ ដូច

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

ម្តេច ទើបដណ្តើមយករាជសម្បត្តិនេះបាន ?" ។

សិគាលរាជ ពោលថា " ខ្ញុំ នឹងញ្ញាំងស្តេចរាជសីហ៍ ឲ្យបន្ទឺ នូវសីហនាទហើយ ធ្វើឲ្យមនុស្សទាំងឡាយ ដល់នូវការអស់ទៅ នៃជីវិតហើយ ទើបដណ្តើមយក " ។

បុរោហិតនោះ (ស្តាប់ហើយ) ក៏ចុះអំពីប៉មហើយ ញ្ញាំងបុគ្គលឲ្យវាយស្គរ ត្រាច់ទៅ ប្រកាលថា " ជនទាំងឡាយទាំងពួងចូរញ៉ុក នូវរន្ធត្រចៀកទាំងឡាយ ដោយម្សៅសណ្តែក " ។ ពួកមនុស្សទាំងឡាយ បានបិទហើយ នូវរន្ធត្រចៀក របស់សត្វជើង ៤ ទាំងឡាយ ដោយទីបំផុត រហូតដល់សត្វឆ្មាទាំងឡាយ និងរន្ធត្រចៀក របស់ខ្ជូនៗ ដោយម្សៅសណ្តែក ។

បុរោហិត បានឡើងទៅកាន់ប៉ម ជាថ្មីម្តងទៀត ហើយពោលថា " នែសព្វទាឋ: អ្នកឯង នឹងមិនអាចញ្ញាំងរាជសីហ៍ ឲ្យបន្ទឺ នូវសីហនាទបានឡើយ, ព្រោះថា ស្តេចកេសររាជសីហ៍ ជាសត្វដល់ព្រមហើយដោយជាតិ មានជើងមុខនិងជើងក្រោយ មានសម្បុរក្រហមល្អ នឹងមិនធ្វើតាមបញ្ជា របស់ឆ្កែចចកកញ្ជាស់ ដូចជាអ្នកឯងឡើយ, ប្រសិនបើ អ្នកឯងអាច, អ្នកឯង ចូរញ្ញាំងស្តេចរាជសីហ៍ ឲ្យបន្ទឺ (សីហនាទ) ចុះ " ។

សិគាលរាជនោះ ជាសត្វរឹងត្អឹង ដោយមានះ ពោលឡើង

មន្ទលត្ថទីបនីប្រែ

ថា "សីហៈទាំងឡាយដទៃ ចូរស្ងៈទុកសិនចុះ, ខ្ញុំអង្គុយនៅលើ ខ្នង របស់សីហៈណា, ខ្ញុំ នឹងឲ្យសីហៈនោះឯងបន្ទឺ " ដូច្នេះហើយ ក៏បានឲ្យសញ្ញា ដោយជើង ។ ស្តេចរាជសីហ៍ ច្របាច់មាត់ ត្រង់ ពោងនៃដំរី បន្ទឺសីហនាទ ដែលសត្វដទៃ ឲ្យប្រព្រឹត្តទៅមិនបាន អស់រាវៈ ៣ ដង ។ ដំរីទាំងឡាយ ជាសត្វដល់ហើយ នូវសេចក្តី តក់ស្ទុត បានជាន់ក្បាលឆ្កែចចកដែលធ្លាក់ហើយ ក្បែរជើង ធ្វើឲ្យ ខ្ទេចល្អិតល្អន់ ញ្ញាំងឆ្កែចចកនោះ ឲ្យដល់ហើយ នូវការអស់ទៅ នៃជីវិត ។ ដំរីទាំងឡាយនោះ ចាក់គ្នាទៅវិញទៅមក បានដួល ស្លាប់ហើយ ។ លើកលែងតែសត្វសីហៈទាំងឡាយចេញ សត្វ ជើង ៤ ដែលសេសសល់ទាំងអស់ បានស្លាប់ហើយ ក្នុងទីនោះ ឯង ។ សត្វសីហៈទាំងឡាយ បានរត់គេចចូលព្រៃអស់ហើយ ។ គំនរសាច់ បានមានហើយ ដល់ទៅ ១២ យោជន៍ ។ បុរោហិត បានញ្ញាំងបុគ្គល ឲ្យវាយស្គរ ដើរប្រកាស ថា " ជនទាំងឡាយ ដែលចង់បានសាច់ ចូរនាំយកសាច់ទៅចុះ" ។ មនុស្សទាំងឡាយ បរិភោគសាច់ហើយ ក៏បានហាលសាច់ដែលនៅសល់ ធ្វើជាសាច់ ងៀតហើយ ។

អាចារ្យពួកខ្ងៈ ពោលថា " បានព្ថមកថា សាច់ងៀត បាន កើតឡើងហើយ ក្នុងកាលនោះ " ។ ក៏ក្នុងពួកធាតុ មាន **ភូ** ធាតុ

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

*ជាដើម លោកពោលថា " **វល្ល** ជាតុ ប្រព្រឹត្តទៅ ក្នុងអត្ថថា ការពារពាក់ព័ន្ធ, ជនទាំងឡាយ រមែងការពារ គឺ ពាក់ព័ន្ធ រក្សានូវ សត្វទាំងឡាយ មានក្អែក និង ខ្វែងជាដើម ដើម្បីប្រយោជន៍ ដល់ កិរិយាមិនឲ្យស៊ី អំពីចំណែកនៃសាច់នេះ ហេតុនោះ ចំណែកនៃ សាច់នេះ ទើរឈ្មោះថា **វល្ហេ** (ជាដែនរក្សានៃជន)" ។ **វល្ហេ** សព្ទ ចុះ **ឆ** បច្ច័យ ដោយសទ្ទនីតិសូត្រថា " **ឆ ភេ ១ ១ ១ ១** " (**ឆ** បច្ច័យ រមែងចុះបាន អំពីខាងមុខនៃជាតុ មាន **១** ជាតុ ជាដើម) ។*

(២៩០) ស្តេចឆ្កែចចកនោះ ញ្ជាំងយស ដែលកើតឡើង ហើយ ឲ្យសាបសូន្យអស់ហើយ សូម្បីខ្លួនឯង ក៏បានដល់ហើយ នូវសេចក្តីទុក្ខ គឺ មរណៈ ដោយអំណាចការៈជាសត្វមានមានៈ រឹងត្អឹង ដោយប្រការដូច្នេះឯង ។

ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែង នូវធម៌ ដល់ភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ ថា ៖

ក៏ឆ្កែបបកវ៉ាងត្ងឹងដោយមានៈ ត្រូវការដោយបរិវារ(ប្រើន)
ក៏ដល់ នូវភូមិសម្បត្តិ ដ៏ធំ បានជាស្តេច នៃពួកសត្វមាន
បង្ហូមទាំងពួង, បណ្តាមនុស្សទាំងឡាយ ក៏យ៉ាងដូច្នោះដែរ
មនុស្សណា ជាអ្នកមានបរិវារ, មនុស្សនោះ ឈ្មោះថា ជាធំ

មន្តលត្ថនីបនីប្រែ

ក្នុងពួកបរិវារនោះ ដូចជាឆ្កែចចក (បានជាធំ) ជាងសត្ត មានបង្ហូមទាំងឡាយ [1] ដូច្នោះឯង ។

*បណ្តាបទទាំងនោះ បទថា "**មានត្ថន្ទោ**" មានសេចក្តីថា ជាសត្វរឹងត្អឹង ដោយមានះ ដែលកើតឡើងហើយ ព្រោះអាស្រ័យបរិវារ ។ បទថា "**អត្ថិកោ**" គឺ ជាសត្វត្រូវការ ដោយបរិវារ យ៉ាងក្រៃលែង ។ ២ បទថា "**មហតឹ ភូមឹ**" គឺ នូវសម្បត្តិ យ៉ាងធំ ។ បាទគាថាថា "**រាជាសិ សព្វទាឱនំ**" មានសេចក្តីថា បានជាស្តេចនៃពួកសត្វមានចង្ហូមទាំងពួង ។ ច្រើនបទថា "**សោ ហិ តត្ថ មហា**" មានសេចក្តីថា បរុសនោះ គឺ អ្នកដែលបរិបូណិហើយ ដោយបរិវារ រមែងឈ្មោះថា ជាធំ ក្នុងបរិវារទាំងឡាយនោះ ។ បាទគាថា ថា " **សិគាលោ រិយ ទាឱនំ** " មានសេចក្តីថា រមែងបានជាធំ ដូចជាឆ្កែចចក បានជាធំ ជាងពួកសត្វមានចង្ហូមទាំងឡាយ យ៉ាងដូច្នោះ, កាលបើដូច្នោះ បរុសនោះ ដល់ហើយ នូវមានះ អាស្រ័យបរិវារនោះហើយ រមែងដល់នូវសេចក្តីវិនាស ដូចជាឆ្កែចចក យ៉ាងដូច្នោះឯង " ។*

រឿងឆ្កែចចក មកក្នុងអដ្ឋកថា សព្វទាឱជាតក ក្នុងទសមវគ្ត នៃទុកនិបាត ។

---

[1]- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ១៣១ ។

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

(កិរិយាប្រព្រឹត្តិបន្ទាបខ្លួនជាមង្គល)

(២៩១) ភាវៈនៃបុគ្គលជាអ្នករឹងត្អឹង បណ្ឌិត គប្បីជ្រាបថា "មិនមែនជាមង្គល" ព្រោះជាហេតុនៃសេចក្តីវិនាស ដោយប្រការដូច្នេះ ។ ចំណែកការប្រព្រឹត្តិបន្ទាបខ្លួន ពោលគឺភាពជាអ្នកមិនរឹងត្អឹង ឈ្មោះថា ជាមង្គល ព្រោះជាហេតុឲ្យបាននូវគុណ មានយសសក្តិ ជាដើម ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ក្នុងសិគាលសូត្រ ថា ៖

> បុគ្គលជាបណ្ឌិត ដែលបរិបូណិ ដោយសីល មានភាពជាអ្នកល្អិតហ្មត់ចត់ មានប្រាជ្ញាវាងវៃ មានសេចក្តីប្រព្រឹត្តិបន្ទាបខ្លួន និង ជាអ្នកមិនរឹងត្អឹង, បុគ្គល ប្រាកដដូច្នោះ រមែងបាននូវយសសក្តិ ។

អដ្ឋកថាសិគាលសូត្រនោះ ថា "បណ្តាបទទាំងនោះ បទថា ***បណ្ឌិតោ*** *មានសេចក្តីថា ជាបណ្ឌិត ក្នុងឋានៈដែលថ្វាយបង្គំ នូវទិសទាំងឡាយ ។ បទថា* ***សណ្ហោ*** *មានសេចក្តីថា ជាអ្នកល្អិតហ្មត់ចត់ ដោយការយើញអត្ថយ៉ាងសុខុម ឬក៏ ដោយការពោលនូវពាក្យដ៏ទន់ភ្ងន់ផ្អែមល្ហែម ។ បទថា* ***បដិភានវា*** *មានសេចក្តីថា ជាអ្នកឆ្លាត វាងវៃ ដោយឋានៈដែលថ្វាយបង្គំទិសទាំងឡាយ ។ បទថា* ***និវាតវុត្តី*** *ប្រែថា ប្រព្រឹត្តបន្ទាបខ្លួន ។ បទថា* ***អត្ថទ្ធោ***

មន្តលត្ថទីបនីប្រែ

ប្រែថា រៀរចាកភាពជាអ្នកប្រកាន់ខ្ជួន " ។

យោជនា ថា " បទថា **ទិសានមស្សនជ្ជានេ** មានសេចក្តីថា ជាបណ្ឌិត គឺ ជាអ្នកឆ្ងាត ជាអ្នកឈ្ងាសវាងវៃ ក្នុងហេតុដែលថ្វាយបង្គំទិស តាមដែលបានពោលហើយ ដែលខ្ជួនសម្គាល់ ថា ជាការចូលទៅតាំងនៅចំពោះ រមែងបាននូវយសសក្តិ " ។

ជីកានៃសិគាលសូត្រនោះ ថា " ក៏ក្នុងបទថា **សណ្ហោ សណ្ហគុណោ** នេះ ដើម្បីនឹងសម្តែង ថា បញ្ញា យ៉ាងសុខុម និងល្អិត វាចា ដ៏ទន់ភ្ងន់ ដូច្នេះ ព្រោះប្រកបដោយគុណ យ៉ាងល្អិតហ្ចត់ចត់ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **សុខុម... ភណនេន វា** ដូច្នេះ ។ បទថា **ទិសានមស្សនជ្ជានេន** នេះ មានការវិនិច្ឆ័យ ថា បុគ្គល កាលប្រតិបត្តិ ដោយន័យ តាមដែលបានពោលមកហើយ ឈ្មោះថា រមែងថ្វាយបង្គំទិសទាំងឡាយ តាមដែលបានពោលហើយ ដោយញាណឯណា, ញាណនោះ ជាហេតុនៃការថ្វាយបង្គំទិសទាំងឡាយ, បុគ្គលនោះ ជាអ្នកឈ្ងាសវាងវៃ ដោយញាណនោះ, ម៉ាងទៀត បុគ្គលនោះ កាលប្រតិបត្តិ នូវកិច្ច ដែលជាប្រយោជន៍ ដោយញាណនោះ ដោយអំណាចប្រកបខ្ងល់ខ្ងាយ ហើយ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ជាអ្នកឈ្ងាសវៃ ក្នុងគាថានេះ ។ បទថា **និវាតវុត្តី** គឺ ជាអ្នកប្រព្រឹត្តឌ៉ិនលំទោន

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

*ជាប្រក្រតី ។ បទថា **អត្តទ្ធោ** គឺ ជាអ្នកវឹងត្អឹង មិនមាន ។ បទថា **ថម្ភរហិតោ** មានសេចក្តីថា រៀរចាកភាពជាអ្នកប្រកាន់ខ្លួន ដែលមានការប៉ោ៉ងឡើងនៃចិត្ត ជាលក្ខណៈ" ។*

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន ចប់ ។

បានប្រែចប់សព្វគ្រប់
នៅថ្ងៃពុធ ១ កើត ខែស្រាពណ៌ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនឹងថ្ងៃទី ១៨ សីហា ១៩៩៣
វេលាល្ងាច

ពណ៌នាអំពីសេចក្ដីសន្ធោស

(២៩២) សេចក្ដីសន្ធោស ដោយបច្ច័យតាមមានតាមបាន ឈ្មោះថា **សន្ទុដ្ឋី** ។ ក្នុងបទថា "**សន្ទុដ្ឋី**" នោះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖ បុគ្គលឈ្មោះថា ជាអ្នកសន្ធោស ព្រោះវិគ្រោះថា "រមែងត្រេកអរដោយបច្ច័យតាមមានតាមបាន" ។ ក៏បទថា "**សំ**" គ្រាន់តែជាឧបសគ្គ ។ មួយទៀត បទថា "**សំ**" នេះ រមែងប្រកបនូវសេចក្ដីបាន ៣ យ៉ាង គឺ **សកំ សន្ធំ សមំ** ។

ដោយហេតុនោះ ក្នុងអដ្ឋកថាមេត្តសូត្រ ក្នុងបឋមវគ្គ នៃសុត្តនិបាត ទើបព្រះអដ្ឋកថាចារ្យ ពោលថា " ភិក្ខុ ឈ្មោះថា ជាអ្នកសន្ធោស ព្រោះអត្ថវិគ្រោះថា រមែងត្រេកអរ ដោយសេចក្ដីសន្ធោស ១២ យ៉ាង ។ ម៉្យាងទៀត ភិក្ខុ ឈ្មោះថា ជាអ្នកត្រេកអរ ព្រោះអត្ថវិគ្រោះថា រមែងត្រេកអរ ។ ភិក្ខុ ឈ្មោះថា ជាអ្នកសន្ធោស ព្រោះអត្ថវិគ្រោះថា ជាអ្នកត្រេកអរ ដោយបច្ច័យ របស់ខ្លួន ត្រេកអរ ដោយបច្ច័យដែលមាន ត្រេកអរស្មាំស្មើ ។

បណ្ដាអត្ថទាំង ៣ យ៉ាងនោះ បច្ច័យ ៤ ឯណា ដែលព្រះឧបជ្ឈាយ៍បានសម្ដែងហើយ ក្នុងមណ្ឌលដែលជាទីឧបសម្ប៉ៃ ថា **ចីវ**ៈ**ណ្ឌ**ិ**យ**ៈ**ណ**ៈ**ប**ៈ**ណ**ៈ**ជ**ៈ**ន**ៈ **ទ**ិ**ស**ៈ**ភ**ៈ**យ** ដូច្នេះជាដើម ដែលខ្លួនឯងទទួលហើយ, បច្ច័យនោះ ឈ្មោះថា **សកំ** (បច្ច័យរបស់ខ្លួន) ។ ភិក្ខុ មិនសម្ដែង នូវវិការ: ទាំងក្នុងវេលាទទួល ទាំងក្នុងវេលា

ពណ៌នាអំពីសេចក្តីសន្តោស

បរិភោគ ញ្ជាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយបច្ចយ ៤ នោះ ដែលល្អ ឬក៏ មិនល្អ ដែលពួកទាយកប្រគេនហើយ ដោយគោរព ឬ មិនគោរព ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាអ្នកសន្តោស ដោយបច្ចយរបស់ខ្ជួន ។

*បច្ចយ ៤ ឯណា ជារបស់ដែលខ្ជួនបានហើយ គឺមានដល់ខ្ជួន, បច្ចយ ៤ នោះ ឈ្មោះថា **សន្តំ** (បច្ចយដែលមាន), ភិក្ខុ កាលត្រេកអរ ដោយបច្ចយ ៤ នោះ ដែលមានប៉ុណ្ណោះ មិន ប្រាថ្នាបច្ចយដទៃទៀត ក្រៅអំពីបច្ចយទាំង ៤ នោះ លះបង់ចោល នូវភាពជាអ្នកប្រាថ្នាច្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាអ្នក សន្តោស ដោយបច្ចយដែលមាន ។*

*ការលះបង់ នូវសេចក្តីត្រេកអរ និង សេចក្តីថ្នាំងថ្នាក់ចិត្ត ក្នុងឥដ្ឋារម្មណ៍ និង អនិដ្ឋារម្មណ៍ ឈ្មោះថា **សមំ** (ស្ងាំស្ងើ) ។ ភិក្ខុ កាលសន្តោស ក្នុងអារម្មណ៍ទាំងពួង ដោយបច្ចយដែលស្ងាំស្ងើ នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាអ្នកសន្តោស ដោយ បច្ចយដែលស្ងាំស្ងើ យ៉ាងដូច្នេះ" ។*

*(២៩៣) សូម្បីក្នុងជីកាកស្សបសំយុត្ត ក៏លោកពោល ថា " បទថា **សន្តុដ្ឋោ** មានសេចក្តីថា ព្រះមហាកស្សបត្ថេរ ជាអ្នក សន្តោស ដោយបច្ចយខ្ពស់ ៗ ទាប ៗ ដែលជារបស់ខ្ជួន ដែលជា*

របស់ដែលមាន ឬ ស្នាំស្មើ ប៉ុណ្ណោះ " ។

*ដីកាឯកនិបាត អង្គុត្តរនិកាយថា "សេចក្ដីសន្ទោស ឈ្មោះ ថា **តុដ្ឋី**, ម្យ៉ាងទៀត សេចក្ដីសន្ទោស ដោយស្នាំស្មើ របស់កិកូ្ខ នោះ មាន ហេតុនោះ កិកូ្ខនោះ ឈ្មោះថា **សន្ទុដ្ឋិ** (អ្នកមានសេចក្ដី សន្ទោស ដោយស្នាំស្មើ) " ។*

*ការៈនៃបុគ្គលជាអ្នកមានសេចក្ដីត្រេកអរ ដោយអាការ ដែលស្នាំស្មើ ឬ ជាអ្នកសន្ទោស ឈ្មោះថា **សន្ទុដ្ឋី** ។ **ណ** បច្ច័យ ចុះក្នុងអត្ថនៃការៈ ដោយសូត្រថា " **ណ វិសមាទីហិ** (**ណ** បច្ច័យ រមែងចុះបានតែខាងមុខ នៃសព្ទទាំងឡាយ មាន **វិសម** សព្ទ ជា ដើម) " ។ **ឥ** បច្ច័យ រមែងចុះបានតែខាងមុខ នៃលិង្គ ដែល ប្រព្រឹត្តទៅ ក្នុងឥត្ថីលិង្គ មាន **ណ** បច្ចយ៍ជាទីបំពុត ដោយសូត្រ ថា " **ណវ ណិក ណោយ្យ ណន្ធូហិ** (**ឥ** បច្ច័យដែលប្រព្រឹត្តទៅ ក្នុងឥត្ថីលិង្គ រមែងចុះបានតែខាងមុខ នៃបច្ច័យទាំងឡាយ ដែល មាន **ណវ ណិក ណោយ្យ** និង **ណ** បច្ច័យ ជាទីបំផុត) " ។*

*(២៩៤) ចំណែក ក្នុងអដ្ឋកថាកស្សបសំយុត្ត សង្គីតិសូត្រ និង ចតុក្កនិបាត អង្គុត្តរនិកាយ ព្រះអដ្ឋកថាចារ្យទាំងឡាយ បាន ពោលថា " បទថា **ឥតរីតរេន** មានសេចក្ដីថា ព្រះមហាកស្សបៈ ត្រេកអរហើយ បណ្ដាបច្ច័យទាំងឡាយ ដែលគ្រោតគ្រាត ល្ហិត*

ពណ៌នាអំពីសេចក្តីសន្តោស

បរិសុទ្ធ សៅហ្មង ប្រណីត ធន់ និង ចាស់ ដោយបច្ចយឯណាមួយ ក៏ទេ, តាមពិត ជាអ្នកត្រេកអរហើយ ដោយបច្ចយក្រៅនេះ និង ក្រៅនេះ គឺដោយបច្ចយឯណាមួយ បណ្តាបច្ចយទាំងឡាយ មាន បច្ចយដែលខ្ជូនបានហើយ យ៉ាងដូចម្តេច ជាដើម " ។

*ដីកាកស្សបសំយុត្ត ថា " **ឥតរីតរ** បច្ចយ ក្នុងបទថា **ឥតរីតរេន** នោះ មាន ២ យ៉ាង គឺ បច្ចយដែលកើតឡើង តាម ប្រក្រតី ១ ដែលកើតឡើងដោយញាណ ១ ។ បណ្តា **ឥតរីតរ** បច្ចយទាំង ២ យ៉ាងនោះ ព្រះអដ្ឋកថាចារ្យ លើកទុកស្ថេះសិន ហើយ នូវបច្ចយដែលកើតឡើងដោយប្រក្រតី សម្តែងតែបច្ចយ ដែលកើតឡើងដោយញាណ តែម្យ៉ាងប៉ុណ្ណោះ ទើបពោលពាក្យ ថា **ន ថូលសុខុម** ដូច្នេះជាដើម " ។*

*ដីកាសង្គីតិសូត្រ និង ចតុក្កនិបាត នៃអង្គុត្តរនិកាយ ថា " បទថា **ឥតរីតរេន** គឺ ដោយបច្ចយក្រៅនេះៗ ។ **ឥតរ** សព្ទ ជាសព្ទពោលសេចក្តីមិននិយម ដោយពិតប្រាកដ កាលពោល ២-៣ ដង រមែងមានសេចក្តីស្មើគ្នា នឹង **យង្កិញ្ចិ** សព្ទ ហេតុ នោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **យេន កេនចិ** ។ **ឥតរីតរ** បច្ចយសព្ទនេះនោះ ជាសព្ទពោលបច្ចយណាមួយ សូម្បីបណ្តា បច្ចយទាំងឡាយ ដែលខ្ជូនបានហើយ យ៉ាងដូចម្តេចជាដើម ដូចជា*

មន្ធលត្ថទីបនីប្រែ

ឥតរីតរ *សព្ទ ដែលពោលដល់បច្ចយទាំងឡាយ មានបច្ចយដែលគ្រោតគ្រាត ជាដើម បច្ចយណាមួយ ដូច្នោះឯង ព្រោះពោលដោយមិនពិតប្រាកដន៉ុះឯង ដោយប្រការដូច្នេះ ។ បណ្តាបច្ចយទាំង ២ យ៉ាងនោះ ព្រះអដ្ឋកថាចារ្យ កាលសម្តែងនូវភាវ: នៃព្រះមហាកស្សបត្ថេរ ប្រាថ្នាចំពោះតែបច្ចយផ្នែក ទី២ ប៉ុណ្ណោះ ក្នុងព្រះសូត្រនេះ ទើបពោលថា* ***អថ ខោ*** *ដូច្នេះជាដើម ។ មានពាក្យសួរថា ក៏ឥតរីតរបច្ចយទាំងឡាយ សូម្បីតាមដែលខ្ជួនបានហើយ យ៉ាងដូចម្តេចជាដើម គឺជាបច្ចយដែលគ្រោតគ្រាត ជាដើមន៉ុះឯង មិនមែនទេឬ? ។ ឆ្លើយថា ពាក្យន៉ុះពិត ។ សូម្បីជាយ៉ាងដូច្នោះក៏ដោយ សេចក្តីប្លែកគ្នាតែងមាន, ព្រោះថា សេចក្តីសន្តោសក្នុងឥតរីតរបច្ចយទាំងឡាយ ដែលគ្រោតគ្រាតជាដើម តាមដែលខ្ជួនបានហើយ យ៉ាងដូចម្តេចឯណា, សេចក្តីសន្តោសនោះ ឈ្មោះថា យថាលាភសន្តោស (ត្រេកអរតាមមានតាមបាន) ដោយពិត, ដទៃក្រៅអំពីនេះ មិនបានឈ្មោះថា យថាលាភសន្តោសឡើយ ។ ព្រោះថា សេចក្តីសន្តោស ក្រៅអំពីនេះនោះ អាស្រ័យត្រឹមតែបច្ចយ គឺព្រះមហាកស្សបត្ថេរ មិនប្រាថ្នាហើយ ដោយពិតន៉ុះ លោកប្រាថ្នាសេចក្តីសន្តោស ដែលជាទីអាស្រ័យ នូវភាវ: គឺ សេចក្តីសមគួរ ដល់កម្លាំងកាយ របស់ខ្ជួនដូច្នេះឯង ។ គប្បីជ្រាប*

ពណ៌នាអំពីសេចក្តីសន្ធោស

សន្ទិដ្ឋានថា ក៏បច្ច័យទាំងឡាយ ៣ យ៉ាង មានបច្ច័យដែលគ្រោតគ្រាត ជាដើម រមែងបាន ក្នុងចីពរ ។ បច្ច័យ ដែលជាកណ្តាលទូទៅ ដល់បច្ច័យទាំង ៤ យ៉ាង, ចំណែក បច្ច័យ ចុងក្រោយគេ រមែងបាន ទាំងក្នុងចីពរ ទាំងក្នុងសេនាសនៈ ដូច្នេះ ” ។

(២៩៥) ក៏ក្នុងដីកាសាមញ្ញផលសូត្រ កស្សបសំយុត្ត និងឯកនិបាត អង្គុត្តរនិកាយ លោកពោលថា “ ម្យ៉ាងទៀត វត្ថុដែលអាក្រក់ លោកហៅថា ក្រៅអំពីនេះ ព្រោះភាវៈជាវត្ថុដែលដទៃផ្សេងក្រៅពីវត្ថុដែលប្រណីត, មួយទៀត សូម្បីវត្ថុដែលប្រណីត ក៏ឈ្មោះថា ក្រៅអំពីនេះដែរ ព្រោះភាវៈជាវត្ថុដទៃក្រៅអំពីវត្ថុដែលអាក្រក់, ក៏ភាវៈនៃវត្ថុជារបស់ដទៃ ក្រៅអំពីនេះ សម្រេចហើយដោយការសំឡឹងរំពៃ ” ។

*វត្ថុក្រៅអំពីនេះផង ក្រៅអំពីនេះផង ឈ្មោះថា ឥតរីតរ-បច្ច័យ, ឥតរីតរបច្ច័យនោះឯង ឈ្មោះថាបច្ច័យ, សេចក្តីសន្ធោសដោយឥតរីតរបច្ច័យនោះ ឈ្មោះថា ឥតរីតរបច្ច័យសន្ធោស, ឥតរីតរបច្ច័យសន្ធោសនោះ គឺ សេចក្តីមិនលោភលន់ទុ៎ះឯង, ដោយហេតុនោះ ក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ទើប ព្រះអដ្ឋកថាចារ្យ ពោលថា “សេចក្តីសន្ធោស ពោលគឺការមិនលោភ ឈ្មោះថា **សន្ទុដ្ឋិតា** ” ។*

មន្តលត្ថទីបនីប្រែ

ជីកាឯកនិបាត អង្គុត្តរនិកាយនោះ និង ជីកាសាមញ្ញផល-សូត្រ និង កស្សបសំយុត្តថា " ភិក្ខុ រមែងត្រេអករ ដោយបច្ចុយមាន ចីវរជាដើម ដែលអាក្រក់ ឬ ប្រណីត ប្រកបដោយធម៌ ឯណាមួយ, ធម៌នោះ ប្រព្រឹត្តទៅហើយ យ៉ាងដូច្នោះ គឺ សេចក្តីមិនលោភលន់ ឈ្មោះថា ឥតរីតរបច្ចុយសន្តោស " ។

(២៩៦) សេចក្តីសន្តោស គឺ ការមិនលោភលន់ មានតែមួយប៉ុណ្ណោះក៏ពិតមែន, ទោះបីជាយ៉ាងដូច្នោះ ដោយប្រភេទ នៃអារម្មណ៍ រមែងមាន ៤ យ៉ាង ដោយអំណាចបច្ចុយ ៤, មួយទៀត រមែងមាន ១២ យ៉ាង ដោយប្រភេទ នៃតិកៈទាំងឡាយ ៤ (៣ ពួក, ១ ពួក មាន ៤ ៗ) ព្រោះធ្វើវិភាគថា សេចក្តីសន្តោស ក្នុងបច្ចុយទាំងឡាយ ៤ បច្ចុយមួយ ៗ មាន ៣ ៗ ដោយអំណាចនៃយថាលាភសន្តោស យថាពលសន្តោស និង យថាសារុប្ប-សន្តោស ។ ដោយហេតុនោះ ក្នុងអដ្ឋកថាទាំងពួង ព្រះអដ្ឋកថាចារ្យទាំងឡាយ ទើបពោលថា " សេចក្តីសន្តោសនោះ មាន ១២ យ៉ាង " ។

(២៩៧) មែនពិត ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលសេចក្តីសន្តោស ១២ យ៉ាង ទុកហើយ ក្នុងឋានៈទាំងឡាយនេះ គឺ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ក្នុងទីឃនិកាយ, ក្នុងអដ្ឋកថា

ពណ៌នាអំពីសេចក្ដីសន្លោស

រថវិនីតសូត្រ ក្នុងតតិយវគ្គ មូលបណ្ណាសក: ក្នុងមជ្ឈិមនិកាយ, ក្នុងអដ្ឋកថាកស្សបសំយុត្ត ក្នុងសំយុត្តនិកាយ, ក្នុងអដ្ឋកថា ឯកនិបាត ក្នុងអង្គុត្តរនិកាយ, ក្នុងអដ្ឋកថាមង្គលសូត្រ ក្នុងខុទ្ទកបាឋ: និង សុត្តនិបាត ក្នុងខុទ្ទកនិកាយ ។

(សន្លោស ១២ យ៉ាង)

អដ្ឋកថាមង្គលសូត្រ ក្នុងខុទ្ទកបាឋ: ជាដើមថា "លោកពោលសេចក្ដីសន្លោស ១២ យ៉ាង តើដូចម្ដេច? ។ ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ បាននូវចីវរល្អ ឬ មិនល្អក៏ដោយ, ភិក្ខុនោះ រមែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយចីវរនោះប៉ុណ្ណោះ មិនប្រាថ្នានូវចីវរដទៃទៀត សូម្បីបានក៏មិនទទួលដែរ, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាលាភសន្តោស ក្នុងចីវរ ។ ក៏ប្រសិនបើ ភិក្ខុ ជាអ្នកមានអាពាធ កាលគ្រង់ចីវរដែលធ្ងន់ រមែងទ្រោមចុះ ឬ លំបាក, ភិក្ខុនោះ ប្តូរចីវរដ៏ធ្ងន់នោះ ជាមួយនឹងភិក្ខុដែលជាទីពេញចិត្តហើយ ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយចីវរដែលស្រាលឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាពលសន្តោស ក្នុងចីវរ ។ ភិក្ខុ ដទៃទៀត ជាអ្នកបានបច្ច័យដែលប្រណីត, បណ្ដាបច្ច័យទាំងឡាយ មានបាត្រ និង ចីវរ ជាដើម ភិក្ខុនោះ បាននូវចីវរដែលមានតម្លៃច្រើន ឯណា

មន្ថលត្ថទីបនីប្រែ

មួយហើយ ក៏គិតថា ចីវរនេះ សមគួរ ដល់ព្រះថេរៈទាំងឡាយ ដែលបួសយូរហើយ, ចីវរនេះ សមគួរ ដល់ភិក្ខុទាំងឡាយដែលជាពហុស្សូត ដូច្នេះហើយ ក៏បានប្រគេនចីវរដែលមានតម្លៃច្រើននោះ ដល់ព្រះថេរៈដែលបួសយូរ ឬ ភិក្ខុដែលជាពហុស្សូត ទាំងឡាយនោះ ហើយបានស្វះស្វែងរកសំពត់ទាំងឡាយ ដែលឥតជាយ អំពីទីឋាន ឯណាមួយ គឺ អំពីគំនរសម្រាម ឬ អំពីព្រៃ ដោយខ្ជូនឯង សូម្បីធ្វើសង្ឆាដី ដោយសំពត់ ដែលមិនមានជាយ ទាំងនោះ ហើយប្រើប្រាស់ ក៏ឈ្មោះថា ជាអ្នកសន្តោស មែនពិត, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាសារុប្បសន្តោស ក្នុងចីវរ (ត្រេកអរតាមសមគួរក្នុងចីវរ) ។

មួយទៀត ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ បាននូវបិណ្ឌបាតសៅហ្មង ឬ ប្រណីត, ភិក្ខុនោះ រមែងញ្ចាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតនោះ តែប៉ុណ្ណោះ មិនប្រាថ្នា នូវបិណ្ឌបាតដទៃ សូម្បីបាន ក៏មិនទទួល, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាលាភសន្តោសក្នុងបិណ្ឌបាត ។ ក៏ប្រសិនបើ ភិក្ខុជាអ្នកមានអាពាធ ធាន់បិណ្ឌបាតដែលសៅហ្មងហើយ រមែងដល់នូវការ ទាស់នឹងរោគ យ៉ាងខ្លាំង, ភិក្ខុ នោះ ប្រគេនបិណ្ឌបាតនោះ ដល់ភិក្ខុដែលជាទីស្រលាញ់ ចេញចិត្តគ្នា ហើយធាន់ នូវទឹកដោះរាវថ្លា

ពណ៌នាអំពីសេចក្ដីសង្ហេស

ទឹកដោះជូរ ទឹកឃ្មុំ និង ទឹកដោះស្រស់ជាដើម អំពីដៃរបស់ភិក្ខុ ដែលជាទីស្រលាញ់ពេញចិត្តនឹងគ្នានោះ សូម្បីធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្ទ្ធាស ដោយពិត, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាពលសន្ទ្ធាសក្នុងបិណ្ឌបាត ។ ភិក្ខុមួយទៀត បានទទួលបិណ្ឌបាតដ៏ប្រណីត, ភិក្ខុនោះ នឹកគិតថា បិណ្ឌបាតនេះ សមគួរ ដល់ព្រះថេរៈទាំងឡាយដែលបួសយូរហើយ និង សមគួរដល់ពួកភិក្ខុ ដែលជាសព្រហ្មចារីដទៃទៀត ដែលប្រាសចាកបិណ្ឌបាតដ៏ប្រណីត មិនញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដូច្នេះហើយ ក៏ប្រគេនទទួលបិណ្ឌបាតនោះ ដល់ព្រះថេរៈទាំងឡាយ ដែលបួសយូរហើយ ឬ ភិក្ខុ ដែលជាសព្រហ្មចារីទាំងឡាយនោះ ហើយ ត្រាច់ចរទៅបិណ្ឌបាត ដោយខ្លួនឯង សូម្បីឆាន់ទទួលអាហារដែលច្របូកច្របល់គ្នា ក៏ឈ្មោះថា ជាអ្នកសន្ទ្ធាស ដោយពិត, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាសារុប្បសន្ទ្ធាស ក្នុងបិណ្ឌបាត ។

មួយទៀត សេនាសនៈ បានមកដល់ភិក្ខុ ក្នុងព្រះធម្មវិនយនេះ, ភិក្ខុនោះ រមែងត្រេកអរ ដោយសេនាសនៈនោះតែប៉ុណ្ណោះ មិនទទួល នូវសេនាសនៈដទៃ សូម្បីតែប្រសើរជាង ដែលបានមកដល់ (ខ្លួន) ម្តងទៀត, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថា-លាភសន្ទ្ធាស ក្នុងសេនាសនៈ ។ ក៏ប្រសិនបើភិក្ខុនោះ ជាអ្នក

មន្តលត្ថនីបនីប្រែ

មានអាពាធ, ភិក្ខុនោះ កាលនៅ ក្នុងសេនាសនៈដែលគ្មានខ្យល់ រមែងរសាប់រសល់ យ៉ាងក្រែលែង ព្រោះរោគទាំងឡាយ មានរោគប្រមាត់ជាដើម, ភិក្ខុនោះ សូម្បីប្រគេនសេនាសនៈនោះ ដល់ភិក្ខុដែលជាទីស្រលាញ់ពេញចិត្តនឹងគ្នា ហើយនៅ ក្នុងសេនាសនៈដែលមានខ្យល់ចេញ-ចូល ត្រជាក់ (ស្រួស) ដែលបានមក ដល់ភិក្ខុដែលត្រូវចិត្តនឹងគ្នានោះ ធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការ របស់ភិក្ខុនេះ នោះ ឈ្មោះថា យថាពលសន្តោស ក្នុងសេនាសនៈ ។ ភិក្ខុ មួយទៀត មិនបានទទួលនូវសេនាសនៈដ៏ប្រសើរ សូម្បីបានមកដល់ (ខ្លួន) ហើយ, ភិក្ខុនោះ គិតថា ធម្មតា សេនាសនៈ ដ៏ប្រសើរ រមែងជាទីតាំងនៃសេចក្តីប្រមាទ ព្រោះហេតុនោះ បីនមិទ្ធៈ គឺសេចក្តីងងុយងោកងក់ រមែងគ្របសង្កត់ ដល់ភិក្ខុដែលអង្គុយនៅ ក្នុងសេនាសនៈ ដ៏ប្រសើរនោះបាន, ក៏កាលបើភិក្ខុនោះ ត្រូវសេចក្តីងងុយដេក គ្របសង្កត់ហើយ ក្រោកឡើងមកម្តងទៀត, សេចក្តីវិតក្កៈ ទាំងឡាយដ៏លាមក រមែងពុះពោររាលដាលឡើង ដូច្នេះ ហើយក៏ហាមឃាត់សេនាសនៈនោះ សូម្បីនៅ ក្នុងទីកណ្តាលវាល ក្រោមដើមឈើនិង កុដិ ដែលបាំងដោយស្ថឹកឈើ ទីកន្ថែង ឯណាមួយ ក៏ឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការ របស់ភិក្ខុនេះនោះ ឈ្មោះ

ពណ៌នាអំពីសេចក្ដីសន្លោស

ថា យថាសារុប្បសន្ដោស ក្នុងសេនាសនៈ ។

មួយទៀត ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ បាននូវកេសជ្ជៈ សម្រាប់បំបាត់ជម្ងឺ ដែលសៅហ្មង ឬ ប្រណីត, ភិក្ខុនោះ រមែងញ៉ាំងអត្ដភាព ឲ្យប្រព្រឹត្ដទៅ ដោយគិលានកេសជ្ជៈនោះ មិនប្រាថ្នា នូវគិលានកេសជ្ជៈ ដទៃទៀត សូម្បីបាន ក៏មិនទទួល, អាការ របស់ភិក្ខុនេះ នោះ ឈ្មោះថា យថាលាភសន្ដោស ក្នុងគិលានប្បច្ចយ ។ ក៏ប្រសិនបើភិក្ខុនោះមានអាពាធ ប្រាថ្នាចង់បានប្រេង តែបាននូវទឹកអំពៅ, ភិក្ខុនោះ ប្រគេនទឹកអំពៅនោះ ទៅដល់ភិក្ខុដែលជាទីស្រលាញ់ពេញចិត្ដនឹងគ្នា ហើយធ្វើ នូវកេសជ្ជៈ ដោយប្រេងនោះ អំពីដៃរបស់ភិក្ខុ ដែលជាទីស្រលាញ់ ពេញចិត្ដនឹងគ្នានោះ សូម្បីធ្វើនូវសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្ដោសដោយពិត, អាការ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាពល-សន្ដោស ក្នុងគិលានប្បច្ចយ ។ ភិក្ខុមួយទៀត កាលត្រូវឧបាសកជាក់ផ្ទៃសម៉ ត្រាំដោយទឹកមូត្រ ក្នុងភាជនៈមួយ ហើយដាក់កេសជ្ជៈ ដែលមានរសជាតិ ៤ យ៉ាង ក្នុងភាជនៈមួយ ហើយពោលថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ចូរព្រះគុណម្ចាស់ទទួលយកចុះ បើព្រះគុណម្ចាស់ត្រូវការ ដូច្នេះ, ប្រសិនបើ អាពាធរបស់ភិក្ខុនោះ ស្ងប់រម្ងាប់ទៅបាន ដោយកេសជ្ជៈ ទាំង ២ យ៉ាង

មន្តលត្ថទីបនីប្រែ

នោះ សូម្បីភេសជ្ជ: ណាមួយក៏ដោយ, លំដាប់នោះ ភិក្ខុនោះ កាលនឹកឃើញ នូវព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ឈ្មោះថា ផ្ថែសម៉ ដែលត្រាំដោយទឹកមូត្រ គឺអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធ ជាដើម ទ្រង់បានត្រាស់សរសើហើយ, និងការបួសនេះ អាស្រ័យនូវទឹកមូត្រត្រាំ (ស្អុយ) ធ្វើជាថ្នាំ, អ្នកគប្បីធ្វើសេចក្តីព្យាយាម ក្នុងថ្នាំផ្ថែសម៉ ដែលត្រាំដោយទឹកមូត្រស្អុយ នោះ ដរាបដល់អស់ជីវិត ដូច្នេះ ហាមឃាត់ នូវភេសជ្ជ: ដែលមានរសជាតិ ៤ យ៉ាង កាលធ្វើភេសជ្ជ: ដោយផ្ថែសម៉ ដែលត្រាំដោយទឹកមូត្រស្អុយ ក៏ឈ្មោះថា ជាអ្នកសន្តោស យ៉ាងកៃលែង, អាការ របស់ភិក្ខុនេះ នោះ ឈ្មោះថា យថាសារុប្បសន្តោស ក្នុងគិលានប្បច្ចយ " ។

(២៩៨) អដ្ឋកថាសាមញ្ញផលសូត្រ ជាដើម ឃើញប្រែកខុសគ្នា បន្តិចបន្តួច ។ សូម្បីអដ្ឋកថាសាមញ្ញផលសូត្រនោះ ក៏គប្បីត្រួតពិនិត្យមើលផងដែរ ។

ក្នុងជីកាសាមញ្ញផសូត្រជាដើម លោកពោលថា "សេចក្តីសន្តោស ដោយបច្ចយតាមដែលបាន គឺ បច្ចយសមគួរដល់លាភ របស់ខ្លួន ឈ្មោះថា យថាលាភសន្តោស ។ សូម្បីក្នុង ២ បទ ដែលនៅសេសសល់ ក៏មានន័យដូចគ្នានេះដែរ ។

ពណ៌នាអំពីសេចក្ដីសន្ទោស

*បច្ចយ ឈ្មោះថា **លាភ** ព្រោះអត្ថថា គឺកិក្ខុត្រូវបាន ។ លាភណាៗ ឈ្មោះថា លាភតាមដែលខ្លួនបានយ៉ាងណា, សេចក្ដីសន្ទោស ដោយលាភ តាមដែលខ្លួនបានយ៉ាងណានោះ ឈ្មោះថា យថាលាភសន្ទោស ។ បទថា **ពលំ** គឺ កម្លាំងកាយ ។ បទថា **សារុប្ប** គឺតាមសមគួរដល់កិក្ខុ ។ ឈ្មោះថា ការមិនប្រាថ្នាបច្ចយ ជនៃ ក្រៅអំពីបច្ចយដែលខ្លួនបានហើយយ៉ាងណា គប្បីជាអាការ នៃកិរិយាប្រព្រឹត្តិទៅ សូម្បីដើម្បីភាពជាអ្នកប្រាថ្នាតិច ព្រោះហេតុ នោះ ព្រះអដ្ឋកថាចារ្យ កាលសម្ដែងសេចក្ដីសរុប (បំព្រួញ) នៃ សេចក្ដីសន្ទោស ដែលមិនខុសផ្សេងពីគ្នា ចាកសេចក្ដីមិនប្រាថ្នា ន៏ុះឯង ទើបពោលថា **លកន្ដោ**ปิ **ន គណ្ហាติ** ដូច្នេះ " ។*

*ក្នុងអដ្ឋកថាមង្គលសូត្រនេះ លោកពោលថា "**អาพาธิโก โหติ** " ។*

(២៩៩) ចំណែក ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ជាដើម លោកពោលថា " ក៏កិក្ខុណា ជាអ្នកទុព្ភលភាព ដោយប្រក្រតី ឬ ជាអ្នកត្រូវអาพาธ និង ជរា ត្រូបសង្គ្រត់, កិក្ខុនោះ កាលត្រង់ចីវរ ដែលធ្ងន់ រមែងលំបាក " ។

*២ បទថា "**តํ ปริวตฺเตตฺวา**" មានសេចក្ដីថា ផ្ទាស់ប្តូរនូវ ចីវរនោះ ដោយអំណាចប្រយោជន៍ថា ចីវរ ដែលធ្ងន់ តែងមិននាំ*

មង្គលត្ថទីបនីប្រែ

សេចក្តីផាសុក មកឲ្យទេ តែនាំសេចក្តីលំបាកសរីរ: មកឲ្យ ដល់ភិក្ខុទាំងឡាយ ដែលទុព្វភាព ដោយប្រក្រតីជាដើម ដូច្នេះ, មិនមែនផ្ទាស់ប្តូរ ដោយអំណាចនៃភាពជាអ្នកប្រាថ្នាច្រើនឡើយ ។ ការប្រើប្រាស់ចីវរដែលស្រាល មិនមែនជាការខុស ចាកសេចក្តីសន្តោសទេ ព្រោះហេតុដូច្នោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា "**លហុកេន យាបេន្តោបិ សន្តុដ្ឋោ វ ហោតិ**" ដូច្នេះ ។

ក្នុងអដ្ឋកថាមង្គលសូត្រនេះ លោកពោលថា "បានហើយ នូវចីវរ ដែលមានតម្លៃច្រើន" ។

អដ្ឋកថានៃសូត្រជទៃអំពីនេះ ថា "បានហើយ នូវចីវរ ដែលមានតម្លៃច្រើន ឬ បាត្រ និង ចីវរ ដែលស្រាល" ។

ដីកានៃសូត្រ ជទៃអំពីនេះនោះ ថា "ការបានចីវរ ដែលមានតម្លៃច្រើន ឬ ចីវរ ដែលស្រាល ហើយលះបង់ចីវរ ដែលមានតម្លៃច្រើនជាដើមនោះ ទទួលយកចីវរ ជទៃទៀតក្រៅអំពីនោះ មិនមែនជាការខុស ចាកសេចក្តីសន្តោសឡើយ ព្រោះជាអ្នកតាំងនៅហើយ ក្នុងន័យ នៃយថាសារុប្បសន្តោស ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **តេសំ** ។បេ។ **ជារេន្តោបិ សន្តុដ្ឋោ វ ហោតិ** ដូច្នេះ ។ គប្បីជ្រាបអធិប្បាយ សូម្បីក្នុងបច្ចយដែលនៅសេសសល់ទាំងឡាយ ដោយប្រកាន់យក **អបិ** សព្ទ ក្នុងនិទ្ទេស

ពណ៌នាអំពីសេចក្ដីសន្លោស

នៃយថាពលសន្ទោស និង យថាសារុប្ប្យសន្ទោស ដូច្នេះឯង ” ។

(៣០០) ក្នុងអដ្ឋកថា មង្គលសូត្រនេះ លោកពោល ថា “ ភិក្ខុ ជាអ្នកមានអាពាធ ធាន់ហើយ នូវបិណ្ឌបាត ដែលសៅហ្មង រមែងដល់នូវការទំនាស់នឹងរោគ យ៉ាងខ្លាំង ” ។

អដ្ឋកថានៃសូត្រ ក្រៅអំពីនេះ ថា “ ក៏ភិក្ខុ រូបណា បាននូវ បិណ្ឌបាត ដែលជាសត្រូវដោយប្រក្រតី ឬ ដែលជាទំនាស់នឹង រោគរបស់ខ្លួន, ភិក្ខុនោះ មិនមានសេចក្ដីសប្បាយ ដោយបិណ្ឌបាត ណា ដែលខ្លួនបានធាន់ហើយ, ភិក្ខុនោះ ប្រគេនបិណ្ឌបាតនោះទៅ ដល់ភិក្ខុដែលត្រូវចិត្តនឹងគ្នា ហើយធាន់ភោជន ដែលសប្បាយ អំពីដៃ របស់ភិក្ខុ ដែលត្រូវចិត្តនឹងគ្នានោះ ” ។

*ដីកាកសរ្ដ្ យបសំយុត្ត ថា “ បទថា **បកតិ** បានដល់ រោគ ទាំងឡាយ មានរោគខ្យល់ជាប្រក្រតីជាដើម ។ សេចក្ដីវិតក្ក: ទាំង ឡាយ ដ៏លាមក រមែងប្រាកដមាន យ៉ាងតាប់ រហ័ស ដល់ភិក្ខុដែល ក្រោកឡើងហើយ ព្រោះត្រូវការងងុយងក់គ្រប សង្ក្ដត់ ” ។*

ក្នុងអដ្ឋកថា មង្គលសូត្រនេះ លោកពោលហើយ ថា “ ធ្វើ នូវកេសជ្ជ: ដោយប្រេង អំពីដៃ របស់ភិក្ខុនោះ ” ។

អដ្ឋកថាសូត្រ ដទៃអំពីនេះ ថា “ សូម្បីទទួល នូវប្រេង អំពី ដៃ របស់ភិក្ខុនោះហើយ ឬ ស្វែងរកកេសជ្ជ:ដទៃទៀតនុ៎ះឯង ហើយ

មន្តលត្ថទីបនីប្រែ

ធ្វើនូវកេសជ្ជ: " ។

ជីកាសាមញ្ញផលសូត្រជាដើម ថា " បទថា **មុត្តហរីតកំ** មានសេចក្តីថា ផ្ទែសម៉ ដែលបុគ្គលចោលហើយ ដោយភាពជារបស់ស្អុយ ដែលបុគ្គលត្រាំហើយដោយទឹកមូត្រគោ ។ ២ បទថា **ពុទ្ធទីហិ វណ្ណិតំ** មានសេចក្តីថា ដែលអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ទ្រង់ត្រាស់សរសើរហើយ ដោយពាក្យថាបព្វជ្ជា អាស្រ័យថ្នាំ ដែលត្រាំដោយទឹកមូត្រស្អុយ ដូច្នេះជាដើម ដើម្បីនឹងទ្រង់បបួល នូវភិក្ខុទាំងឡាយ ក្នុងភាពជាអ្នកមានសេចក្តីប្រាថ្នាតិច និង ភាពជាអ្នកសន្តោស ។ ភិក្ខុ ឈ្មោះថា ជាអ្នកសន្តោស យ៉ាងក្រៃលែងពិត ព្រោះជាអ្នកប្រកប ដោយសេចក្តីសន្តោស យ៉ាងក្រៃលេង គឺ យ៉ាងឧក្រិដ្ឋ " ។

អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ និង រថវិនីតសូត្រ ថា "បណ្តាសេចក្តីសន្តោស ក្នុងបច្ចុ័យចំពោះមួយៗ ទាំង ៣ យ៉ាងនេះ យថាសារុប្បសន្តោស ប៉ុណ្ណោះ ជាសេចក្តីសន្តោសដ៏ប្រសើរ " ។

ជីកានៃសូត្រទាំង ២ នោះ ថា " ភិក្ខុ ឈ្មោះថា ជាអ្នកប្រសើរ ព្រោះប្រព្រឹត្តទៅ ក្នុងបច្ចុ័យនោះៗ ដោយអំណាចសេចក្តីត្រេកអរ អាស្រ័យនូវសេចក្តីសមគួរនុ៉ះឯង " ។

ពណ៌នាអំពីសេចក្តីសន្តោស ១២ យ៉ាង ចប់ ។

ពណ៌នាអំពីសេចក្ដីសន្លោស

(៣០១) អដ្ឋកថាសាមញ្ញផលសូត្រ ចូឡហត្ថិបទោបម-សូត្រ និង អដ្ឋកថាចតុត្ថបណ្ណាសក: ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ ថា "មួយទៀត បរិក្ខារទាំងឡាយ ៨ គឺ ត្រៃចីវរ បាត្រ កូនកាំបិត សម្រាប់ចិតឈើជម្រះធ្មេញ ម្ជុល ១ វត្ថុពន្ធន៍ចង្កេះ សំពត់សម្រាប់ត្រងទឹក រមែងសមគួរ ដល់ភិក្ខុដែលប្រកបព្រម ដោយ សេចក្ដីសន្ទោស ដោយ ឥតរីតរបច្ច័យ ទាំង ១២ យ៉ាងនេះ ។

មែនពិត សូម្បីពាក្យនេះ បូរាណាចារ្យ បានពោលហើយថា:

បរិក្ខារទាំងឡាយនេះ គឺត្រៃចីវរ បាត្រ កាំបិត(ការ) ម្ជុល និង វត្ថុពន្ធន៍បង្កេះ ត្រូវជា ៨ និង សំពត់សម្រាប់ត្រងទឹក រមែងសមគួរ ដល់ភិក្ខុដែលប្រកបសេចក្ដីព្យាយាម ។

គ្រឿងបរិក្ខារ ទាំងអស់នោះ ជាគ្រឿងបរិហារកាយ ក៏បាន បរិហារពោះក៏បាន ។ បើមានពាក្យសួរថា គ្រឿងបរិក្ខារ ទាំងឡាយនោះ ជាគ្រឿងបរិហារកាយ បរិហារពោះ បាន យ៉ាងដូចម្ដេច? ។ គប្បីឆ្លើយថា នឹងពណ៌នាចីវរ ជាមុន, ចីវរ រមែងបរិហារ គឺ ចិញ្ចឹមនូវកាយ ក្នុងពេលដែលស្លៀក និង ត្រង ហើយត្រាច់ទៅ ព្រោះហេតុនោះ ទើបឈ្មោះថា ជាគ្រឿង បរិហារកាយ, ចីវរ រមែងបរិហារ គឺ ចិញ្ចឹមនូវពោះ ក្នុងពេល ដែលយកជាយចីពរ មកត្រងទឹក ហើយឆាន់ និង ក្នុងពេលដែល

មន្តលត្តទីបនីប្រែ

រៃចខ្ចប់ផ្ទៃឈើដែលត្រូវធាន់ ដោយជាយចីវរនុ៉ះ យកទៅ ព្រោះ
ហេតុនោះ ទើបឈ្មោះថា ជាគ្រឿងបរិហារនូវពោះ ។ ចំណែក
បាត្រ ក៏ជាគ្រឿងបរិហារ នូវរាងកាយ ក្នុងពេលដែលយកបាត្រ
នោះ មកជងទឹកហើយស្រង់ និង ក្នុងពេលដែលយកបាត្រនោះ
ទៅជងទឹកហើយ ធ្វើការប្រោះព្រំនូវកុដិ, បាត្រ ជាគ្រឿងបរិហារ
នូវពោះ ក្នុងពេលដែលទទួលអាហារ ដោយបាត្រនោះ ហើយ
យកមកធាន់ ។ ឯកាំបិតព្រា រមែងជាគ្រឿងបរិហារ នូវរាងកាយ
ក្នុងពេលដែលចិតឈើជម្រះធ្មេញ និង ក្នុងពេលដែលធ្វើជើង
គ្រែ កៅអី តាំង និង ជងក្រុត, កាំបិតព្រា រមែងជាគ្រឿងបរិហារ
នូវពោះ ក្នុងពេលដែលកាប់អំពៅ និង បកផ្ទៃដូង ជាដើម ។
ចំណែក ម្ជុល ជាគ្រឿងបរិហារពោះ ក្នុងពេលដែលចាក់នំ ឬ ផ្ទៃ
ឈើ ហើយធាន់ ។ សូម្បីវត្ថពន្ធន៍ចង្កេះ ក៏ជាគ្រឿងបរិហាររាង
កាយ ក្នុងពេលដែលក្រវាត់ ហើយត្រាច់ទៅ ជាគ្រឿងបរិហារពោះ
ក្នុងពេលដែលចងនូវវត្ថុទាំងឡាយ មានអំពៅជាដើមហើយ កាន់
យកទៅ ។ ចំណែក សំពត់សម្រាប់ត្រងទឹក ជាគ្រឿងបរិហាររាង
កាយ ក្នុងពេលដែលត្រងទឹក ដោយសំពត់នោះហើយស្រង់ និង
ក្នុងពេលដែលត្រងទឹក ដោយសំពត់នោះហើយ ធ្វើការប្រោះព្រំ
សេនាសនៈ, សំពត់សម្រាប់ត្រងទឹក ជាគ្រឿងបរិហារពោះ ក្នុង

ពណ៌នាអំពីសេចក្តីសន្តោស

ពេលដែលត្រងទឹកសម្រាប់ធាន់ និង ទឹកបាន: និង ក្នុងពេលដែលវេចខ្ចប់នូវអង្ករ និង អំបុកជាដើម ដោយសំពត់នោះឯង ហើយធាន់ ។ នេះ គឺជាប្រមាណ នៃគ្រឿងបរិក្ខារ របស់ភិក្ខុអ្នកមានគ្រឿងបរិក្ខារ ៨ ប៉ុណ្ណោះឯង ។ ចំណែកភិក្ខុអ្នកមានគ្រឿងបរិក្ខារ ៩ ចូលទៅ កាន់ទីកន្លែងសិង និងមានគ្រឿងកម្រាល សម្រាប់សេនាសន:នោះ ឬ កូនសោ ក៏សមគួរ ។ ភិក្ខុ មានគ្រឿងបរិក្ខារ ១០ និងមានសំពត់និសីទន: ឬ កំណាត់ស្បែក ក៏សមគួរ ។ ភិក្ខុ អ្នកមានគ្រឿងបរិក្ខារ ១១ និងមានឈើច្រត់សម្រាប់មនុស្សចាស់ ឬ ត្រឡោកប្រេង ក៏គួរ ។ ភិក្ខុ អ្នកមានគ្រឿងបរិក្ខារ ១២ (និងមាន) ធត្រ ឬ ទ្រនាប់ជើង ក៏សមគួរ ។ ក៏បណ្តាភិក្ខុទាំងនោះ ភិក្ខុអ្នកមានគ្រឿងបរិក្ខារ ៨ ប៉ុណ្ណោះ ឈ្មោះថា ជាអ្នកសន្តោស, ភិក្ខុទាំងឡាយ ក្រៅអំពីនេះ គឺអ្នកណាមួយ ក៏មិនគួរពោល ថា ជាអ្នកមិនសន្តោស ជាអ្នកមានសេចក្តីប្រាថ្នាច្រើន ជាអ្នកស្វែងរកធំ ដូច្នេះឡើយ ។ ភិក្ខុទាំងឡាយ ទាំងពួងនេះ ជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោល ជាអ្នកដែលគេចិញ្ចឹមងាយ ជាអ្នកមានសេចក្តីប្រព្រឹត្តិស្រាល មែនពិត " ។

(៣០២) ដីកានៃសូត្រទាំងនោះថា "ព្រះអដ្ឋកថាចារ្យ កាលសម្តែងថា ការប្រមូលបរិក្ខារ ក្រៅអំពីនោះ ចូលក្នុងចំណោម នៃ

មន្តលត្ថនីបនីប្រែ

*បរិក្ខារទាំងឡាយ ៨ រមែងមានព្រម ដោយមិនប្រែកគ្នា ដោយ
កិរិយាចោទ ក្នុងហេតុត្រឹមតែចីវរ និង បិណ្ឌបាតទាំងឡាយ ជា
គ្រឿងបរិហាររាងកាយ និង ពោះ ដោយលំដាប់ ដូច្នេះ ទើបពោល
នូវពាក្យថា ភិក្ខុទាំងអស់នោះ ដូច្នេះជាដើម ។*

បទថា **ឯតេបិ** *ជាដើម អធិប្បាយថា សូម្បីភិក្ខុទាំងឡាយ
អ្នកមានបរិក្ខារ ៩ ជាដើម ក៏ឈ្មោះថា ជាអ្នកមានសេចក្តីប្រាថ្នា
តិច ជាអ្នកសន្តោស ដូចគ្នាដែរ, ព្រោះថា នឹងចាត់ថា ជាអ្នកមាន
សេចក្តីប្រាថ្នាច្រើន ឬ ជាអ្នកមិនសន្តោស ដោយគ្រឿងបរិក្ខារ
មានប្រមាណប៉ុណ្ណេះ ក៏មិនបានឡើយ " ។*

*នយមក ក្នុងអដ្ឋកថានៃសូត្រនោះ ៗ ថា " ក៏ភិក្ខុ អ្នកមាន
បរិក្ខារ ៨ រវចខ្ចប់នូវកូនកាំបិតតូច (កាំបិតកោរ) និង ម្ជុល ក្នុង
សំពត់ត្រងទឹកហើយ ដាក់ខាងក្នុងនៃបាត្រ ស្ពាយបាត្រដាក់លើ
ចុងស្មា ស្រៀក និង គ្រងត្រៃចីវរ ចងវត្ថុពន្ធន៍ចង្កេះ ហើយចៀស
ចេញទៅ យ៉ាងសុខសប្បាយ តាមសេចក្តីប្រាថ្នា ។ ភិក្ខុនោះ
ឈ្មោះថា មិនចាំបាច់ត្រឡប់មកយកអ្វីទៀតឡើយ ។ ព្រោះហេតុ
នោះ ទេសនា ក្នុងសាមញ្ញផលសូត្រ ជាដើម មកហើយ ដោយ
អំណាចនៃភិក្ខុអ្នកមានបរិក្ខារ ៨ ប៉ុណ្ណោះ, មិនមែនមក ដោយ
អំណាចនៃពួកភិក្ខុអ្នកមានបរិក្ខារ ៩ ជាដើមឡើយ " ។*

ពណ៌នាអំពីសេចក្តីសន្តោស

(៣០៣) សេចក្តីសន្តោស មានដល់ទៅ ១២ យ៉ាង ក៏ពិត មែនហើយ, ទោះជាដូច្នោះ ដោយសង្ខេប មាន ៣ យ៉ាង ដោយ អំណាចសេចក្តីសន្តោសតាមមានតាមបាន សន្តោសតាមកម្ចាំង និង សន្តោសតាមសមគួរ ។ ភិក្ខុអ្នកត្រេកអរ ដោយបច្ច័យទាំង ឡាយ ៣ យ៉ាង នោះ ឈ្មោះថា ជាអ្នកត្រេកអរ ដោយបច្ច័យ តាមល្មមសមគួរ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា នៃអរិយវង្ស ៤ ក្នុងសង្គីតិសូត្រ និង ក្នុងអដ្ឋកថា អរិយវង្សសូត្រ ក្នុងបឋម-បណ្ណាសក: នៃចតុក្កនិបាត អង្គុត្តរនិកាយ ព្រះអដ្ឋកថាចារ្យ ពោលហើយ ថា " ខ្ញុំ សំដៅយកសេចក្តីសន្តោស ទាំងឡាយ ៣ យ៉ាងនេះ ទើបពោលថា ភិក្ខុជាអ្នកសន្តោស គឺ ជាអ្នកសន្តោស ដោយចីវរ តាមល្មមសមគួរ គឺ បណ្តាចីវរទាំងឡាយ តាមដែល បានហើយ ជាដើម ដោយចីវរ យ៉ាងណាមួយ ដូច្នេះ " ។

ដីកានៃអរិយវង្សចតុក្ក: ក្នុងសង្គីតិសូត្រ និង អរិយវង្ស-សូត្រនោះថា "ពាក្យថា **ឥមេ តយោ សន្តោសេ** នេះ ព្រះអដ្ឋកថា-ចារ្យ ពោលហើយ ដោយអំណាចសេចក្តីសន្តោសទាំង ៣ យ៉ាង ជាទីរួបរួម នៃសេចក្តីសន្តោស គ្រប់យ៉ាង ។ ក៏ព្រះអដ្ឋកថាចារ្យ បំព្រួញនូវគិលានបច្ច័យ ខាងមុខ ចូលក្នុងបិណ្ឌបាត យ៉ាងដូច្នេះ ហើយពោលសេចក្តីសន្តោស ឯណា គ្រប់ ៥០ យ៉ាង គឺ សេចក្តី

មន្តលត្ថនីបនីប្រែ

សន្តោស ក្នុងចីវរ ២០, សន្តោស ក្នុងបិណ្ឌបាត ១៥, សន្តោស ក្នុងសេនាសនៈ ១៥, សេចក្តីសន្តោសទាំងអស់នោះ រមែងដល់នូវការសង្ត្រោះ គឺ ការរួបរួមចូល ក្នុងសេចក្តីសន្តោសទាំងឡាយ ៣ យ៉ាងនេះឯង តាមសមគួរ " ។

(៣០៤) អដ្ឋកថា នៃសង្គីតិសូត្រ និង ចតុក្កនិបាត នៃ អង្គុត្តរនិកាយ ថា " ក៏សេចក្តីសន្តោស ក្នុងចីវរ មាន ២០ យ៉ាង គឺ សេចក្តីសន្តោស ក្នុងការត្រិះរិះ, សន្តោស ក្នុងការដើរផ្លូវ, សន្តោស ក្នុងការស្វែងរ, សន្តោស ក្នុងការបានចំពោះ, សន្តោស ក្នុងការទទួលល្មមតាមប្រមាណ, សន្តោស ក្នុងការវៀរចាកអំពី សេចក្តីឡូឡេ, សន្តោសតាមមានតាមបាន, សន្តោសតាមកម្លាំង, សន្តោស តាមសមគួរ, សន្តោស ក្នុងទឹក, សន្តោស ក្នុងការលាងជម្រះ, សន្តោស ក្នុងការធ្វើ, សន្តោស ក្នុងការប៉ាន់ប្រមាណ, សន្តោស ក្នុងអំបោះ, សន្តោស ក្នុងការដេរ, សន្តោស ក្នុងការជ្រលក់, សន្តោស ក្នុងការធ្វើកប្បៈ, សន្តោស ក្នុងការប្រើប្រាស់, សន្តោស ក្នុងការវៀរចាកការសន្សំ និង សន្តោស ក្នុងការលះបង់ ។ បណ្តាសេចក្តីសន្តោសទាំង ២០ យ៉ាងនោះ ភិក្ខុអ្នកមានសេចក្តីត្រេកអរ នៅចាំវស្សា រហូតត្រៃមាស ហើយត្រិះរិះ ត្រឹមតែមួយខែ ក៏សមគួរ ។ ព្រោះថា ភិក្ខុនោះ បវារណាចញ្ចវស្សា

ពណ៌នាអំពីសេចក្ដីសន្តោស

ហើយ រមែងធ្វើនូវចីវរ ក្នុងខែដែលជាទីកើតឡើងនៃចីវរ ។ ភិក្ខុ អ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត រមែងធ្វើបាន ដោយ កន្ទះខែ តែប៉ុណ្ណោះឯង ។ កិរិយាត្រិះរិះ អស់កាលត្រឹមតែមួយខែ ឬ កន្ទះ ខែ យ៉ាងដូច្នេះ ឈ្មោះថា វិតក្កសន្តោស ។

(៣០៥) ក៏ភិក្ខុ អ្នកត្រេអករហើយ ដោយវិតក្កសន្តោស គប្បីដូចជាព្រះថេរ: អ្នកមានកិរិយាទ្រទ្រង់ នូវសំពត់បង្សុកូល ជាវត្ត ដែលនៅ ក្នុងបាចីនខណ្ឌរាជីវិហារ ។

បានឫមកថា ព្រះថេរ: និមន្តមកហើយ ដោយនឹកគិត ថា អាត្មាអញ នឹងថ្វាយបង្គំ នូវព្រះចេតិយ ក្នុងចេតិយបព៌តវិហារ ដូច្នេះ ថ្វាយបង្គំចេតិយហើយ ក៏គិតថា ចីវរ របស់អាត្មាអញ ចាស់ហើយ, អាត្មាអញ នឹងបាន ក្នុងទីជាទីនៅ នៃភិក្ខុទាំងឡាយដែលច្រើន ។ ភិក្ខុអង្គនោះ និមន្តទៅកាន់មហាវិហារ ជួបនឹងព្រះសង្ឆ-ត្ថេរ ហើយសួរទីជាទីនៅហើយ នៅក្នុងមហាវិហារនោះ លុះស្អែកឡើង ទើបបានយកចីវរ មកហើយ ថ្វាយបង្គំព្រះថេរ: ។

ព្រះថេរ: សួរថា ម្នាលលោកដ៏មានអាយុ មានហេតុអ្វី? ។

ភិក្ខុនោះ ឆ្លើយថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះ ករុណា នឹងនិមន្តទៅ កាន់មាត់ទ្វារនៃផ្ទះ ។

ព្រះថេរ: ពោលថា ម្នាលអាវុសោ ឯខ្ញុំ ក៏នឹងទៅដែរ ។

មង្គលត្ថទីបនីប្រែ

ភិក្ខុនោះ ទទួលថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ល្អណាស់ ដូច្នេះហើយ ក៏និមន្តទៅ ឈរនៅ ក្បែរស៊ុមមាត់ទ្វារ នៃមហាពោធិ៍ គិតថា អាត្មាអញ នឹងបាននូវចីវរ ដែលជាទីពេញចិត្ត ក្នុងទីជាទីនៅ នៃអ្នកមានបុណ្យទាំងឡាយ ដូច្នេះហើយ គិតថា សេចក្តីត្រិះរិះ របស់អាត្មាអញ មិនបរិសុទ្ធឡើយ ហើយទើបត្រឡប់ចេញអំពីទីនោះឯង, លុះដល់ព្រឹកឡើង ភិក្ខុនោះ ក៏និមន្តទៅកាន់ទីជិតនៃទីទួល ឈ្មោះបេណ្ណម្ភៈ, ថ្ងៃស្អែកឡើង បានត្រឡប់មកពីទ្វារនៃទិសឧត្តរ នៃមហាចេតិយ យ៉ាងដូច្នោះដែរ សូម្បីក្នុងថ្ងៃទី ៤ ក៏បាននិមន្តទៅហើយ កាន់សំណាក់នៃព្រះថេរៈ ។ ព្រះថេរៈ គិតថា សេចក្តីត្រិះរិះ របស់ភិក្ខុរូបនេះ នឹងមិនបរិសុទ្ធ ហើយកាន់យកចីវរ សួរបញ្ហា និមន្តទៅផ្ទះ ព្រមជាមួយភិក្ខុរូបនោះឯង ។

ក៏ក្នុងរាត្រីនោះ មនុស្សម្នាក់ ត្រូវឧច្ចារៈ ជាប់ជំពាក់ហើយ (ក្លៀនលាមក) បានបន្ទោបង់ឧច្ចារៈ ជាក់ លើសំពត់សាជកនេះឯង ហើយបានចោលសំពត់ជសាជកនោះ ក្នុងគំនរសម្រាម ។ ព្រះថេរៈ អ្នកមានកិរិយាទ្រទ្រង់ នូវសំពត់បង្សុកូលជាវត្ត បានឃើញនូវសំពត់សាជកនោះ ដែលមានសត្វរុយ ក្បាលខៀវទាំងឡាយ ទំរោម ជុំជិតអស់ហើយ ទើបបានផ្គងនូវអញ្ជលីឡើង ។

ព្រះមហាថេរៈ សួរថា ម្នាលអ្នកដ៏មានអាយុ តើព្រោះ

ពណ៌នាអំពីសេចក្ដីសង្ហេស

ហេតុអ្វីទៅ បានជាលោកផ្ដង នូវអញ្ជលី ចំពោះទីជាទីសម្រាប់ចោលនូវសម្រាម ? ។

ព្រះថេរៈ អង្គនោះ ឆ្លើយថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា មិនបានផ្ដងអញ្ជលី ចំពោះទីជាទីចោលសម្រាមទេ, ខ្ញុំព្រះករុណា បានផ្ដងអញ្ជលី ចំពោះព្រះទលពល ដែលជាព្រះបិតា របស់ខ្ញុំព្រះករុណាទេតើ, បពិត្រព្រះគុណម្ចាស់ ដ៏ចម្រើន ព្រះទសពល ព្រះអង្គទ្រង់រលាស់ចោល នូវសត្វតូចតាចទាំងឡាយ ដែលមានប្រមាណ ១ តុម្ព: ហើយទ្រង់កាន់យកនូវសំពត់បង្ហ្ករ្ដ ដែលគេរុំព័ទ្ធ (ពងកាយ) របស់នាងបុណ្ណទាសី (យកទៅ) ចោះចោលហើយ អំពីព្រៃខ្ចោច ទ្រង់ធ្វើកម្ម ដែលគេធ្វើបានដោយក្រ ។ ព្រះមហាថេរៈ គិតហើយថា សេចក្ដីត្រិះរិះ របស់ព្រះថេរៈ ដែលមានកិរិយាទ្រទ្រង់នូវសំពត់បង្ហ្ករ្ដ ជាវត្ត បរិសុទ្ធហើយ ។ ឯព្រះថេរៈ អ្នកមានកិរិយាទ្រទ្រង់ នូវសំពត់បង្ហ្ករ្ដ ជាវត្ត បានឈរនៅហើយ ក្នុងទីនោះឯង ចម្រើនវិបស្សនា ក៏បានសម្រេចផល ៣ ហើយ កាន់យកនូវសំពត់សាដកនោះមក ធ្វើជាចីវរ គ្រងហើយ ក៏បាននិមន្ដទៅ កាន់ជាចីនទ្រណ្ហាពជីវិហារ បានសម្រេចព្រះអរហត្ត ដែលមានផលដ៏ប្រសើរហើយ ។

(៣០៦) ក៏ការដែលកិក្ខុនិមន្ដទៅ ដើម្បីប្រយោជន៍ ដល់ចីវរ

មន្ទលត្ថទីបនីប្រែ

មិនបានគិត ថា អាត្មាអញ នឹងបាន ក្នុងទីណាមួយហ្នឹ? ហើយ
និមន្តទៅ ដោយយកកម្មដ្ឋាន ជាធំប៉ុណ្ណោះ ឈ្មោះថា សន្តោស ក្នុង
ការដើរផ្ទូវ ។ ក៏ការដែលភិក្ខុស្វែងរក (ចីវរ) មិនបានស្វែងរក
ព្រមជាមួយនឹងភិក្ខុសាមញ្ញធម្មតា ឡើយ បាននាំយកភិក្ខុ អ្នកមាន
សេចក្តីអៀនខ្មាស មានសីលជាទីស្រលាញ់ ទៅហើយ ស្វែងរក
ឈ្មោះថា សន្តោស ក្នុងការស្វែងរក ។ ការដែលភិក្ខុស្វែងរក
យ៉ាងដូច្នេះ ឃើញនូវចីវរ ដែលទាយកនាំយកមក អំពីទីឲ្យាយន៉ុះ
ឯង មិនបានត្រិះរិះ យ៉ាងនេះថា ចីវរនោះ នឹងជាទីពេញចិត្ត, ចីវរ
នោះ នឹងមិនជាទីពេញចិត្ត ហើយត្រេអករ ក្នុងចីវរដែលគ្រោត
គ្រាត និង ប្រណីត ជាដើម ដោយចីវរ តាមដែលខ្ជូនបានហើយ
យ៉ាងណាប៉ុណ្ណោះ ឈ្មោះថា សន្តោស ក្នុងការបានចំពោះ ។ ការ
ដែលភិក្ខុសូម្បីកាន់យកនូវចីវរ ដែលខ្ជូនបានហើយ យ៉ាងដូច្នោះ
ត្រេកអរ ដោយចីវរត្រឹមតែល្មមគ្រប់គ្រាន់ ដល់ខ្ជូនឯង ថា សំពត់
មានប្រមាណប៉ុណ្ណោះ នឹងមាន ដើម្បីចីវរ ២ ជាន់, សំពត់ មាន
ប្រមាណប៉ុណ្ណោះ នឹងមាន ដើម្បីចីវរ ១ ជាន់ ដូច្នេះ តែប៉ុណ្ណោះ
ឈ្មោះថា សន្តោស ក្នុងការកាន់យកតែល្មមប្រមាណ ។ មួយទៀត
ការដែលភិក្ខុស្វែងរកចីវរ មិនគិតថា អាត្មាអញ នឹងបានចីវរ ដែល
ជាទីពេញចិត្ត ត្រង់មាត់ទ្វារផ្ទះ នៃបុគ្គលឈ្មោះន៉ុះ ដូច្នេះហើយ

ពណ៌នាអំពីសេចក្ដីសន្លោស

និមន្ដទៅ តាមលំដាប់ទ្វារ ឈ្មោះថា សន្ដោស ក្នុងការវៀរចាក ការលោភលន់ ។ ការដែលកិក្ខុអាចញ៉ាំងអត្ដភាព ឲ្យប្រព្រឹត្ដទៅ ដោយបណ្ដាចីវរដែលស្ដៅហ្នង ឬ ប្រណីត ចីវរណាមួយ ញ៉ាំង អត្ដភាព ឲ្យប្រព្រឹត្ដទៅ ដោយចីវរតាមដែលខ្លួនបានហើយ យ៉ាង ណានុ៎ះឯង ឈ្មោះថា សន្ដោស ក្នុងបច្ចយ តាមដែលខ្លួនបាន ហើយ ។ ការដែលកិក្ខុដ៏ងនូវកម្ចាំងរបស់ខ្លួនហើយ ញ៉ាំងអត្ដភាព ឲ្យប្រព្រឹត្ដទៅ ដោយចីវរដែលជាគ្រឿងអាច ដើម្បីនឹងឲ្យប្រព្រឹត្ដ ទៅបាន ឈ្មោះថា សន្ដោសក្នុងបច្ចយតាមកម្ចាំង ។ ការដែលកិក្ខុ ប្រគេនចីវរ ដែលជាទីពេញចិត្ដ ដល់កិក្ខុដទៃហើយ ញ៉ាំងអត្ដភាព ឲ្យប្រព្រឹត្ដទៅ ដោយចីវរ ណាមួយ របស់ខ្លួន ឈ្មោះថា សន្ដោស ក្នុងបច្ចយតាមសមគួរ ។ ការមិនជ្រើសរើសថា ទឹក ក្នុងណា ជា ទីពេញចិត្ដ, ក្នុងទីណា មិនជាទីពេញចិត្ដ ដូច្នេះហើយ ជោកដោយ ទឹក ដែលសមគួរនឹងជោកបាន ឯណាមួយ ឈ្មោះថា សន្ដោស ក្នុងទឹក ។ ក៏ការដែលកិក្ខុវៀរចាកទឹក ដែលស្ដៅហ្នង (ពកវណ្ណ) ដោយដីលឿង ជ័ររលើ និង ទឹក ដែលមានស្ជ៊ីករលើស្ងួយ ទើប សមគួរ ។ ក៏ការដែលកិក្ខុជោក (ចីវរ) មិនយកកំណាត់ឈើ ជា ដើម ដំ ហើយជោក ប្រជាច់ ដោយដៃ ឈ្មោះថា សន្ដោស ក្នុង ការជោក ។ មួយទៀត ការដែលកិក្ខុជោកចីវរ ដែលមិនស្អាត

មង្គលត្ថទីបនីប្រែ

សូម្បីដោយទឹកដែលគេជាក់ស្ទឹកឈើហើយ ដាំទឹកឲ្យក្តៅ (ស្ងោរ) ក៏សមគួរ ។ ការដែលកិក្ខុបោកធ្វើ យ៉ាងដូច្នេះ មិនញ៉ាំងចិត្ត ឲ្យកម្រើកថា ចីវរនេះ គ្រោតគ្រាត, ចីវរនេះ ហ្មត់ល្អ ដូច្នេះហើយ ធ្វើ ដោយទំនងដែលសមល្មមនុ៎ះឯង ឈ្មោះថា សន្ទ្ធាស ក្នុងការធ្វើ ។ ការធ្វើចីវរគ្រាន់តែល្មមសមគ្នានឹងបិទបាំងមណ្ឌលទាំង ៣ ឈ្មោះថា សន្ទ្ធាសក្នុងការធ្វើឲ្យសមប្រមាណ ។ មួយទៀត ការដែលកិក្ខុមិនត្រាច់ទៅ ដោយគិតថា អាត្មាអញ នឹងស្វែងរកអំបោះដែលជាទីពេញចិត្ត ដើម្បីនឹងធ្វើចីវរ ដូច្នេះហើយ កាន់យកអំបោះបែបណាមួយនុ៎ះឯង ដែលបុគ្គលនាំយកមកតាំងទុកហើយ ត្រង់ទីទាំងឡាយ មានថ្នល់ជាដើម ឬ ទេវដ្ឋាន ឬ ដែលបុគ្គលនាំមក តាំងទុកហើយ ក្បែរជើង ហើយធ្វើ ឈ្មោះថា សន្ទ្ធាស ក្នុងអំបោះ ។ ក៏ក្នុងវេលាដែលក្ជាប់សំពត់កុសិ គប្ជាចោះ (ដេ)រ ៧ ជង ក្នុងទីប្រមាណមួយចង្អ្ជុលដៃ ។ ព្រោះថា កាលបើកិក្ខុធ្វើ យ៉ាងដូច្នេះ, កិក្ខុ រូបណា ដែលមិនមែនជាទីស្រលាញ់, សូម្បីវត្ត្ជកេទ រ៉ាមង៉ាមិនមាន ដល់កិក្ខុរូបនោះ ។ តែសូម្បីក្នុងទីប្រមាណ ៣ អង្ជ្ជុលី ក៏គប្ជីចោះ (ដេ)រ ៧ ជង ។ កាលបើកិក្ខុធ្វើ យ៉ាងដូច្នេះ, សូម្បីកិក្ខុអ្នកដើរផ្លូវ ក៏គប្ជីជាសំឡាញ់បាន ដោយពិត ។ កិក្ខុ រូបណា មិនជាសំឡាញ់, វត្ត្ជកេទ ក៏មិនមាន ដល់កិក្ខុរូបនោះ ។ ក៏កិរិយាធ្វើនេះ

ពណ៌នាអំពីសេចក្ដីសន្តោស

ឈ្មោះថា សន្តោស ក្នុងការដេរ ។ ក៏ភិក្ខុកាលនឹងជ្រលក់ (ចីវរ) មិនគួរដើរស្វែងរក នូវទឹកជ្រលក់ទាំងឡាយ មានទឹកជ្រលក់ដើមជ្រៃខ្មៅជាដើមឡើយ ។ បណ្តាទឹកជ្រលក់ទាំងឡាយ មានទឹកជ្រលក់ដើមកន្ធូត ជាដើម ភិក្ខុនោះ បាននូវទឹកជ្រលក់បែបណា, គប្បីជ្រលក់ដោយទឹកជ្រលក់នោះ ។ ភិក្ខុកាលបើមិនបាន (ដូច្នោះ) ទេ គប្បីកាន់យក នូវទឹកជ្រលក់ ដែលពួកមនុស្សកាន់យក នូវក្រចៅ ក្នុងព្រៃហើយ ទម្លាក់ចោល ឬក៏ កាកដែលពួកភិក្ខុស្វោរហើយចោល ហើយទើបជ្រលក់ ។ ការធ្វើ យ៉ាងនេះ ឈ្មោះថា សន្តោស ក្នុងទឹកជ្រលក់ ។ ការដែលភិក្ខុកាន់យកបណ្តាពណ៌ខៀវ ពណ៌ភក់ ពណ៌ខ្មៅ និង ពណ៌ខ្មៅស្ទើរខៀវ ពណ៌ ឯណាមួយ ហើយ ធ្វើកប្បពិន្ទុ ដែលប្រាកដមាន ដល់បុគ្គលអ្នកអង្អុយ លើ ខ្នងដំរី ឈ្មោះថា សន្តោស ក្នុងការធ្វើកប្បពិន្ទុ ។ ការប្រើប្រាស់ ដោយអំណាចល្មមគ្រាន់តែ នឹងបិទបាំង នូវអវយវ: ដែលញ្ចាំង សេចក្តីអៀនខ្មាស ឲ្យកម្រើកប៉ុណ្ណោះ ឈ្មោះថា សន្តោស ក្នុងការប្រើប្រាស់ ។

ព្រះមហាសិវត្ថេរ ពោលថា ក៏ការដែលភិក្ខុបាន នូវសំពត់ហើយ តែនៅមិនទាន់បាន នូវអំបោះ ឬ ម្ជុល ឬ អ្នកធ្វើ នឹងទុកសិន ក៏សមគួរ, កាលបើបាន នូវអំបោះ ជាដើមនោះ នឹងទុកសិន

មន្ថលត្ថទីបនីប្រែ

មិនសមគួរទេ ។ សូម្បីចីវរដែលបានធ្វើហើយ បើភិក្ខុនោះ ជាអ្នកប្រាថ្នាចង់ឲ្យ ដល់សហធម្មិកទាំងឡាយ មានអន្តេវាសិក ជាដើម, ក៏សហធម្មិកទាំងឡាយ មានអន្តេវាសិក ជាដើមនោះ ជាអ្នកមិនទាន់មកជុំគ្នាទេ, នឹងរក្សាទុកសិន រហូតដល់មក(ជុំគ្នា) ក៏សមគួរ, កាលបើអន្តេវាសិក ជាដើមនោះ គ្រាន់តែមកដល់ហើយ, គប្បីឲ្យដោយពិត, កាលបើមិនអាចដើម្បីនឹងឲ្យបានទេ, គប្បីអធិដ្ឋានទុកសិន ។ កាលបើចីវរដទៃ មិនមានទេ, នឹងអធិដ្ឋានសូម្បីនូវសំពត់សម្រាប់ក្រាលសិង ក៏សមគួរ ។ ព្រោះថា ចីវរ ដែលមិនទាន់បានអធិដ្ឋានហើយនុ៉ះឯង រមែងជាសន្និធិ (ការសន្សំទុក) ដោយពិត ។ ចីវរ ដែលបានអធិដ្ឋានហើយ មិនមែនជាសន្និធិ ឡើយ ដូច្នេះ ។ ការធ្វើនេះ ឈ្មោះថា សន្តោស ក្នុងកិរិយាវៀរចាកការសន្សំទុក ។ មួយទៀត ភិក្ខុ កាលនឹងលះបង់ មិនគប្បីឲ្យព្រោះយល់មុខឡើយ, គប្បីតាំងនៅ ក្នុងសារាណីយធម៌ ហើយទើបលះឲ្យ ដូច្នេះ, ការធ្វើនេះ ឈ្មោះថា ជាការសន្តោស ក្នុងការលះបង់ ។

(សន្តោស ក្នុងបិណ្ឌបាត ១៥ យ៉ាង)

ចំណែក សេចក្តីសន្តោស ក្នុងបិណ្ឌបាត មាន ១៥ យ៉ាង គឺ វិតក្កសន្តោស គមនសន្តោស បរិយេសនសន្តោស បដិ-លាភសន្តោស បដិគ្គហណសន្តោស មត្តបដិគ្គហណសន្តោស

ពណ៌នាអំពីសេចក្តីសន្តោស

លោលុប្បវិវជ្ជនសន្តោស យថាលាភសន្តោស យថាពល-សន្តោស យថាសារុប្បសន្តោស ឧបការសន្តោស បរិមាណ-សន្តោស បរិភោគសន្តោស សន្ទិធិបរិវជ្ជនសន្តោស និង វិស្សជ្ជនសន្តោស ។

បណ្តាសេចក្តីសន្តោស ទាំង ១៥ យ៉ាងនោះ ភិក្ខុ អ្នកត្រេកអរ លុបមុខហើយ រមែងត្រិះរិះ ។ ក៏ភិក្ខុ អ្នកមានកិរិយាត្រាច់ទៅបិណ្ឌតជាវត្ត និមន្តទៅ ជាមួយនឹងពួកគណៈហើយ ក្នុងពេលឧបដ្ឋាកព្រះថេរ: ក្នុងវេលាល្ងាច, កាលបើព្រះថេរ: សួរថា ក្នុងថ្ងៃស្អែកនេះ ពួកយើង នឹងទៅបិណ្ឌបាត ក្នុងទីណា? ដូច្នេះ, ពោលថា បពិត្រព្រះគុណម្ចាស់ ដ៏ចម្រើន ពួកយើង នឹងទៅបិណ្ឌបាត ក្នុងស្រុកនោះ ដូច្នេះ នឹកគិតនូវទីមានប្រមាណប៉ុណ្ណោះ ចាប់ដើមអំពីទីនោះ មិនគួរត្រិះរិះឡើយ ។ ភិក្ខុ អ្នកត្រាច់ទៅ តែម្នាក់ឯង គប្បីឈរត្រិះរិះ ក្នុងរោងសម្រាប់ត្រិះរិះ ។ ភិក្ខុ កាលបើត្រិះរិះ ចាប់ដើមអំពីទីនោះទៅ រមែងជាអ្នកឃ្លាត មានទៅ ខាងក្រៅអំពីអរិយវង្ស ។ នេះ ឈ្មោះថា សន្តោស ក្នុងការត្រិះរិះ ។ ក៏ភិក្ខុ ចូលទៅដើម្បីបិណ្ឌបាត មិននឹកគិតថា អាត្មាអញ នឹងបានក្នុងទីណា? ដូច្នេះ គប្បីនិមន្តទៅ ដោយគិតយកកម្មដ្ឋានជាធំ ។ នេះ ឈ្មោះថា សន្តោស ក្នុងការធ្វើដំណើរ ។ ភិក្ខុ កាលស្វែងរក

មន្ទលត្ថទីបនីប្រែ

មិនត្រូវនាំយកភិក្ខុសាមញ្ញធម្មតា ទៅទេ គប្បីនាំយកភិក្ខុអ្នកមានការអៀនខ្មាស មានសីលជាទីស្រលាញ់ ទៅស្វែងរកប៉ុណ្ណោះ ។ នេះ ឈ្មោះថា សន្តោស ក្នុងការស្វែងរក ។ ភិក្ខុ យើញទាយកនាំយកអាហារមក អំពីទីឆ្ងាយ មិនគប្បីញុាំងចិត្ត ឲ្យកើតឡើងថា អាហារន៉ុះ ជាទីពេញចិត្ត, អាហារន៉ុះ មិនជាទីពេញចិត្ត ។ នេះ ឈ្មោះថា សន្តោស ក្នុងការបានចំពោះ ។ ភិក្ខុ មិនគួរគិតថា អាត្មាអញនឹងទទួល នូវបិណ្ឌបាត ដែលជាទីពេញចិត្តនេះ, នឹងមិនទទួលបិណ្ឌបាត ដែលមិនជាទីពេញចិត្តនេះ ដូច្នេះហើយ គប្បីទទួលនូវបិណ្ឌបាត ឯណាមួយ ដែលល្មមគ្រាន់នឹងញុាំងអត្តភាព ឲ្យប្រព្រឹត្ត ទៅប៉ុណ្ណោះ ។ នេះ ឈ្មោះថា សន្តោស ក្នុងការទទួលយក ។

មួយទៀត ក្នុងបិណ្ឌបាតនេះ ទេយ្យធម៌ មានច្រើន, តែទាយកប្រាថ្នានឹងប្រគេនបន្តិចបន្ទួច, ភិក្ខុ គួរទទួលតែបន្តិចបន្ទួច ។ សូម្បីតែទេយ្យធម៌ មានច្រើន, ទាំងទាយក ក៏ជាអ្នកប្រាថ្នា នឹងប្រគេនច្រើន, ភិក្ខុគប្បីទទួល តែល្មមប្រមាណប៉ុណ្ណោះ ។ ទេយ្យ-ធម៌ មានមិនច្រើន, ទាំងទាយក ជាអ្នកប្រាថ្នា នឹងប្រគេនតែបន្តិចបន្ទួច, ភិក្ខុ គប្បីទទួលតែបន្តិចបន្ទួច ។ ទេយ្យធម៌ មានមិនច្រើន, តែទាយកប្រាថ្នានឹងប្រគេនច្រើន, ភិក្ខុ គប្បីទទួលតែល្មមប្រមាណប៉ុណ្ណោះ ។ ព្រោះថា ភិក្ខុ កាលមិនដឹងនូវប្រមាណ ក្នុងការទទួល

ពណ៌នាអំពីសេចក្តីសន្តោស

រមែងកំចាត់សេចក្តីជ្រះថ្លា របស់មនុស្សទាំងឡាយ ឲ្យខូចខាតទៅ រមែងញ្ចុាំងទាន ដែលគេគប្បីប្រគេន ដោយសទ្ធា ឲ្យធ្លាប់ចុះទៅ រមែងមិនធ្វើ តាមពាក្យប្រៀនប្រដៅ រមែងមិនអាច ដើម្បីផ្គងចិត្ត សូម្បីនៃមាតាបង្កើតបានឡើយ ។ លុះត្រាតែដឹង នូវប្រមាណន៉ុះ ឯង ហើយទើបគួរទទួល យ៉ាងនេះ ព្រោះហេតុដូច្នេះ នេះ ឈ្មោះ ថា សន្តោស ក្នុងការទទួលតែល្មមប្រមាណ ។ ភិក្ខុ មិនគួរនិមន្ត ទៅកាន់ត្រកូល ដែលស្តុកស្តម្ភតែប៉ុណ្ណោះទេ គប្បីនិមន្តទៅ តាម លំដាប់ទ្វារ ។ នេះ ឈ្មោះថា សន្តោស ក្នុងការវៀរចាកការលោភ លន់ចង់បានច្រើន ។ សេចក្តីសន្តោសទាំងឡាយ មានសេចក្តី សន្តោស តាមមានតាមបានជាដើម មានន័យដូចបានពោលហើយ ក្នុងចីវរន៉ុះឯង ។ ការដឹងឧបការ: យ៉ាងនេះថា អាត្មាអញ បរិភោគ នូវបិណ្ឌបាតហើយ នឹងតាមរក្សា នូវសមណធម៌ ដូច្នេះហើយ ទើបបរិភោគ ឈ្មោះថា សន្តោស ក្នុងការដឹងឧបការ: ។ ភិក្ខុ មិន គួរទទួលនូវបិណ្ឌបាត ដែលទាយកដាក់ពេញបាត្រហើយ នាំយក មក ។ កាលបើអនុបសម្បន្ន មាន, ភិក្ខុ គប្បីឲ្យអនុបសម្បន្ន នោះទទួល, បើមិនមានអនុបសម្បន្នទេ, គប្បីឲ្យទាយកនាំយកទៅ ហើយ ទទួលយករបស់ ដែលល្មមគ្រាន់តែទទួលប្រគេនបាន ។ នេះ ឈ្មោះថា សន្តោស ក្នុងការស្គាល់ប្រមាណ ។ ការធាន់ ដោយ

មន្តលត្ថទីបនីប្រែ

គិតយ៉ាងដូច្នេះ ថា ការធាន់នេះ ជាហេតុបន្ទោបង់ នូវសេចក្តីស្រេកឃ្លានបាន, ការចេញចាកទុក្ខ រមែងមាន ព្រោះការធាន់នេះ ដូច្នេះ ឈ្មោះថា សន្តោស ក្នុងការធាន់ ។ ភិក្ខុ មិនគួរតម្កល់ទុកហើយៗ ធាន់, អាការ ដូចពោលមកនេះ ឈ្មោះថា សន្តោស ក្នុងការវៀរ ចាកការសន្សំទុក ។ ភិក្ខុ មិនគួរយល់មុខ ហើយតាំងនៅ ក្នុងសារាណីយធម៌ លះបង់ឲ្យ ។ នេះ ឈ្មោះថា សន្តោស ក្នុងការ លះបង់ឲ្យ ។

សូម្បីក្នុងសេនាសន: ក៏មានសេចក្តីសន្តោស ១៥ យ៉ាង មាន វិតក្កសន្តោស ជាដើម ។ សេចក្តីសន្តោស ទាំងឡាយនោះ គប្បីជ្រាប ដោយន័យដូចបានពោលហើយ ក្នុងបិណ្ឌបាតន៉ុះឯង ។ ចំណែក គិលានបច្ចយ ចូលជាមួយគ្នានឹងបិណ្ឌបាតន៉ុះឯង ។ ក្នុងគិលានបច្ចយនោះ ភិក្ខុ គប្បីត្រេកអរ ដោយយថាលាភសន្តោស យថាពលសន្តោស និង យថាសារុប្បសន្តោស តែប៉ុណ្ណោះ " ។

ពណ៌នាអំពីសេចក្តីសន្តោស ១៥ យ៉ាង ចប់ ។

(៣០៧) ដីកាសង្គីតិសូត្រ និង ចតុក្កនិបាត អង្គុត្តរនិកាយ នោះថា "បទថា ***សាទកភិក្ខុនា*** *បានដល់ ភិក្ខុ ដែលត្រេកអរចំពោះ ចីពរ របស់គហបតី ។ បទថា* ***ឯកមាសមត្តំ*** *មានសេចក្តីថា ភិក្ខុ នឹងត្រិះរិះត្រឹមតែមួយខែ ដែលដឹងថា ជាខែសម្រាប់ធ្វើចីវរ ក៏សម*

ពណ៌នាអំពីសេចក្ដីសន្លោស

គួរ, អធិប្បាយថា នឹងត្រិះរិះ ឲ្យលើសហួសអំពីនោះទៅ មិនសម គួរទេ ។ មែនពិត ការប្រតិបត្តិ ក្នុងព្រះពុទ្ធសាសនា រមែងប្រព្រឹត្ត ទៅ ដើម្បីប្រយោជន៍ ដល់កិរិយាគ្របសង្កត់ នូវសេចក្ដីចង់ចាន សូម្បីនូវវត្ថុទាំងពួង ព្រោះហេតុនោះ ភិក្ខុ អ្នកមានកិរិយាទ្រទ្រង់នូវ សំពត់បង្សុកូលជាវត្ត រមែងធ្វើបាន ដោយពេលកន្លះខែប៉ុណ្ណោះ ព្រោះភាវៈនៃការបានចំពោះ ជារបស់ដែលមិនជាប់ជំពាក់ នឹងអ្នក ជនៃ ។ តែព្រះមានព្រះភាគ ទ្រង់អនុញ្ញាត ប្រមាណមួយខែ ព្រោះ ការបានរបស់ភិក្ខុដែលត្រេកអរ ដោយគហបតីចីវរក្រៅនេះ ជាប់ ជំពាក់នឹងអ្នកជនៃ, ការត្រិះរិះត្រឹមតែមួយខែ ឬ កន្លះខែ ដូចបាន ពណ៌នាមកនេះ ឈ្មោះថា សន្លោស ក្នុងការត្រិះរិះ ព្រោះភាវៈនៃ ការត្រិះរិះ ប្រព្រឹត្តទៅ តាមកាលវេលា គឺលោកកំណត់ហើយ ។ ភិក្ខុ សូម្បីកាលប្រាថ្នា នូវព្រះមហាថេរៈ ធ្វើជាសំឡាញ់ របស់ខ្លួន ក្នុងការស្វែងរកនោះ ពោលហើយ ដោយសេចក្ដីគោរព យ៉ាងខ្ជាំង យ៉ាងដូច្នេះថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា នឹង ទៅកាន់ទ្វារផ្ទះ ។ ចំណែក ព្រះថេរៈ យល់អធ្យាស្ស័យ របស់ភិក្ខុ នោះហើយ ពោលថា ម្នាលលោកដ៏មានអាយុ ចំណែក ខ្ញុំ ក៏នឹង ទៅដែរ ។ ព្រះថេរៈ សួរនូវបញ្ហា ដោយគិតថា ឱកាសនៃសេចក្ដី ត្រិះរិះ ចូរកុំមាន ដល់ភិក្ខុរូបនេះ ដូច្នេះ ទើបចូលទៅ កាន់ស្រុក ។

មន្តលត្ថនីបនីប្រែ

បទថា ***ឧច្ចារបលិពុទ្ធោ*** *គឺ ជាអ្នកត្រូវឧច្ចារៈបៀតបៀនហើយ ។ ក្នុងកាលនោះ ព្រះថេរៈ អ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត ឈរនៅ ក្នុងទីនោះឯង ចម្រើនវិបស្សានាហើយ ក៏បានសម្រេចផលទាំងឡាយ ៣ ព្រោះភាវៈ នៃកិលេសទាំងឡាយ គឺលោកគ្របសង្កត់បានហើយ ព្រោះភាវៈនៃកម្លាំង របស់បីតិ និង សោមនស្ស ដែលកើតឡើងហើយ ក្នុងព្រះតថាគត ដោយការរលឹកដល់ទុក្ការកិរិយា របស់ព្រះមានព្រះភាគ ជាប្រមុខជាធម្មជាតិ មានកម្លាំង ។ សូម្បីការនឹកគិតថា អាត្មាអញ នឹងបានក្នុងទីឯណា? ដូច្នេះ គឺ ហេតុដំបូងនៃការប្រាថ្នានូវលាភ ព្រោះហេតុនោះ ក្នុងគមនសន្តោសនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា* ***អចិន្តេត្វា*** *ដូច្នេះ ។ នឹងចាំបាច់ពោលធ្វើអ្វី ក្នុងការនឹកគិតជាដើមយ៉ាងដូច្នេះថា អាត្មាអញ នឹងបាននូវរបស់ដែលល្អ, នឹងបាន នូវរបស់ដែលជាទីពេញចិត្ត ដូច្នេះ ។*

ដើម្បីនឹងចៀសវាង នូវពាក្យសួរថា ក៏ភិក្ខុ គប្បីនិមន្តទៅយ៉ាងដូចម្តេច? ដូច្នេះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ***កម្មដ្ឋានសីសេនេវ គមនំ*** *។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យសម្តែងថា ភិក្ខុ មិនគួរគិត សូម្បីនូវវត្ថុអ្វីមួយ ព្រោះអាស្រ័យចីវរឡើយ ។ ភិក្ខុ អ្នកមានសីលមិនជាទីស្រលាញ់ គប្បីជាបច្ចយ ក្នុង*

ពណ៌នាអំពីសេចក្តីសន្តោស

ការស្វែងរកដែលមិនសមគួរ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថា-ចារ្យ ពោលថា ***បេសលំ ភិក្ខុំ គហេទ្វា*** *ដូច្នេះ ។*

បទថា ***អាហរិយមានំ*** *មានសេចក្តីថា នូវសំពត់ដែលធ្លាក់ហើយ ក្នុងទីបា៉ធា ដែលបុរសឯណាមួយ ដឹងថា ភិក្ខុទាំងឡាយនេះ ត្រាច់ទៅស្វែងរកនូវសំពត់បង្សុកូល ដូច្នេះហើយ នាំយកមកអំពីទីបា៉ធានោះ ។ ច្រើនបទថា* ***ឯវំ លទ្ធំ គណ្ហន្តស្សាបិ*** *មានសេចក្តីថា សូម្បីមិនញ្ចាំងសេចក្តីសន្តោស ក្នុងការបានចំពោះ ឲ្យកម្រើកឡើយ កាន់យកចីវរ ដែលខ្ជួនបានហើយ យ៉ាងដូច្នោះ ។ ២ បទថា* ***អត្តនោ បហោនកមត្តេនេវ*** *មានសេចក្តីថា ដោយប្រមាណដែលគ្រប់គ្រាន់ ដល់ខ្ជួនន៉ុះឯង ដើម្បីប្រយោជន៍ ដល់សំពត់បង្សុកូល មួយជាន់ ឬ ពីរជាន់ តាមដែលខ្ជួនបាន ។ ព្រះអដ្ឋកថាចារ្យ ហាមឃាត់ការប្រាថ្នាចំពោះ ខ្ពស់ឡើងទៅ ដោយ* ***ឯវ*** *សព្ទ ដែលជាអវធារណៈ ។ ការដែលភិក្ខុនិមន្តទៅ ដើម្បីភិក្ខាក្នុងផ្ទះ ត្រាច់ទៅ តាមលំដាប់ទ្វារ ដូចជានិមន្តទៅ តាមលំដាប់នៃច្រក ឈ្មោះថា ការវៀរចាកកិរិយាលោភលន់ច្រើន ព្រោះសេចក្តីលោភលន់ច្រើន ក្នុងចីវរ គឺ លោកបានលើកឡើងធ្វាយហើយ ។ បទថា* ***យាបេតុំ*** *ប្រែថា ញ្ចាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។ បទថា* ***ជោវនុបគេន*** *ប្រែថា គួរដល់ការបោកគក់ ។ បទថា* ***បណ្ណានិ***

មង្គលត្ថទីបនីប្រែ

បានដល់ ស្ងឹកឈើទាំងឡាយ មានស្ងឹកស្ងាយ និង ស្ងឹកព្រឹង ជាដើម ។ បទថា ***អកោបេត្វា*** *គឺ មិនញ៉ាំងសេចក្តីសន្ទ្ធាស ឲ្យកម្រើកហើយ ។ បទថា* ***បហោនកនីហារេនេវ*** *មានសេចក្តីថា ខ្ជួន ប្រាជ្ញានឹងធ្វើបណ្តាត្រៃចីពរ មានស្បង់ ជាដើម នូវបស់ណាមួយ, ការកាន់យកនូវសំពត់សាច់គ្រោតគ្រាត ឬ សាច់ម៉ដ្ត ជាដើម តាមដែលខ្ជួនបានហើយ ធ្វើដោយទំនង ដែលនឹងគ្រប់គ្រាន់ ដល់ត្រៃចីវរ មានស្បង់ ជាដើមនោះ ។*

បទថា ***តិមណ្ឌលបរិជ្ជិច្ចាទនមត្តេស្ស*** *មានសេចក្តីថា ធ្វើចីវរ ល្មមគ្រាន់បិទបាំង នូវមណ្ឌប ៣ ប៉ុណ្ណោះ យ៉ាងដូច្នេះ គឺ បើសិនជាសំពត់សម្រាប់ស្ងៀក បិទបាំងមណ្ឌលផ្ចិត មណ្ឌលជង្គង់, បើសិនជាសំពត់ ក្រៅអំពីនេះ បិទបាំងមណ្ឌលចង្កេះ និងមណ្ឌលជង្គង់ ។ ក៏ប្រមាណនោះ ដោយសេចក្តី ក៏ជាប្រមាណ ដូចបានពោលមកហើយ ដោយទាបបំផុត នៃត្រៃចីពរនុ៎ះឯង ។ បទថា* ***អវិចរិត្វា*** *ប្រែថា មិនគ្រាច់ផ្ទ្ធាត់ទៅហើយ ។ បទថា* ***កុសិពន្ធនកាលេ*** *បានដល់ ក្នុងពេលប្រកប នូវមណ្ឌល ហើយដេរបញ្ចូលជាមួយគ្នា ។ ២ បទថា* ***សត្ត ១ារេ*** *គឺ អស់ ១ារ: ដែលដេរ ៧ ដង ។*

ការមិនធ្វើឲ្យប្លែកអ្វី ๆ ដោយសម្តែងកប្ប៖ពិន្ទុ ឈ្មោះថា

ពណ៌នាអំពីសេចក្តីសន្តោស

សន្តោស ក្នុងការធ្វើកប្បពិន្ទុ ។ ដើម្បីនឹងសម្តែងប្រយោជន៍ ក្នុងការប្រើប្រាស់ចីវរ ដោយត្រង់នុ៉ះឯង ថា ការប្រើប្រាស់ចីវរ រមែងសម្រេចបាន ព្រោះឲ្យបានសម្រេចប្រយោជន៍ មានការជួយការពារ នូវត្រជាក់ជាដើម ដូច្នេះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **ហិរិកោបិនប្បដិច្ជាទនមត្តវសេន** ដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ដើម្បីគ្រាន់តែបិទបាំងអវយវ: ដែលញ្ចាំងសេចក្តីអៀនខ្មាស ឲ្យកម្រើក ។ បទថា **វដ្តតិ** មានសេចក្តីថា សេចក្តីសន្តោស រមែងមិនកម្រើកជាមុន ព្រោះមិនទាន់បានសម្ភារ: និង ទក្ខិណេយ្យបុគ្គល ។ ២ បទថា **សារាណីយ-ធម្មេ ឋត្វា** មានសេចក្តីថា ស្ថិតនៅហើយ ក្នុងភាវ:ជាអ្នកមានការបរិភោគ ដោយទូទៅ ជាមួយភិក្ខុទាំងឡាយ ដែលមានសីល ។ ភិក្ខុ អ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាវត្ត រមែងត្រិះរិះ ថា ក្នុងថ្ងៃនេះ អាត្មាអញ នឹងត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងទីឯណាហ្នុ៉ ។ កាលបើព្រះថេរ: ពោលថា ក្នុងថ្ងៃស្អែកនេះ ពួកយើង នឹងត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងទីឯណា? ដូច្នេះ, ភិក្ខុនោះ ពោលថា បពិត្រព្រះគុណម្ចាស់ ដ៏ចម្រើន ពួកយើង នឹងត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងផ្ទះឈ្មោះនុ៉ះ ។ នេះជាការឲ្យនូវពាក្យតប ក៏ពិតមែនហើយ, ទោះបីជាដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលថា **ឯត្តកំ**

មន្តលត្ថទីបនីប្រែ

ចិន្តេត្វា ដូច្នេះ ព្រោះសំដៅយកចិត្តដែលជាហេតុគិតហើយ ទើបពោល ។ ២ បទថា ***តតោ បដ្ឋាយ*** មានសេចក្តីថា ចាប់ដើមតាំងអំពីពេលដែលភិក្ខុនោះ ឈរត្រិះរិះនៅ ក្នុងរោងសម្រាប់ត្រិះរិះគឺថា បន្ទាប់អំពីពេលនោះទៅ ។ ពាក្យថា ***អរិយវំសា ចុតោ ហោតិ*** នេះ អ្នកសិក្សាគប្បីកាន់យក ដោយអំណាច នៃភិក្ខុដែលតាំងនៅ ក្នុងអរិយវង្សទាំង ៣ យ៉ាង, មិនគប្បីកាន់យក ដោយអំណាចភិក្ខុដែលប្រព្រឹត្ត តែម្នាក់ឯងប៉ុណ្ណោះឡើយ ។ មែនពិតភិក្ខុទាំងអស់ ដែលតាំងនៅ ក្នុងអរិយវង្ស តែងបានដើម្បីនឹងត្រិះរិះតែមួយជង ប៉ុណ្ណោះឯង, ក្រៅអំពីនោះ រមែងមិនបាន ដើម្បីនឹងត្រិះរិះឡើយ ។ បទថា ***បរិពាហិរោ*** គឺ ជាអ្នកមាននៅ ខាងក្រៅអំពីភាវៈជាអ្នកតាំងនៅ ក្នុងអរិយវង្ស ។ វិតក្កសន្តោស នេះនោះ រមែងមិនកម្រើក និង បរិសុទ្ធបាន ដោយការធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋាន ។ សូម្បីក្នុងសេចក្តីសន្តោស ដទៃទៀត ក្រៅអំពី វិតក្ក-សន្តោសនេះ ក៏នយនេះដូចគ្នាដែរ ។ ដោយហេតុនោះឯង ទើបព្រះអដ្ឋកថាចារ្យ ពោលថា ***កម្មដ្ឋានសីសេន គន្តព្វំ*** ។ ***ឯវ*** សព្ទក្នុងបទថា ***គហេតព្វមេវ*** នេះ ប្រកប ក្នុងឋានៈដែលមិនសមគួរ, គប្បីប្រកបថា ***យាបនមត្តមេវ គហេតព្វំ*** ។ បទថា ***ឯត្ត*** គឺ ក្នុងការទទួល នូវបិណ្ឌបាតនេះ ។ បទថា ***អប្បំ*** មានសេចក្តីថា ភិក្ខុ

ពណ៌នាអំពីសេចក្តីសន្តោស

គប្បីទទួលតែបន្តិចបន្ពួច សូម្បីដោយប្រមាណ ដែលល្មមគ្រប់គ្រាន់នឹងញ្ចាំងអត្តភាព ឲ្យប្រព្រឹត្តទៅនៃខ្ជួន ដើម្បីញ្ចាំងចិត្ត របស់ទាយក ឲ្យត្រេកអរ ។ បទថា **បមាណេនេវ** គឺ គប្បីទទួលតែបន្តិចបន្ពួច ដោយប្រមាណដែលល្មមគ្រប់គ្រាន់ នឹងញ្ចាំងអត្តភាព របស់ខ្ជួនឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ។ ព្រះអដ្ឋកថាចារ្យ ដើម្បីសម្តែងហេតុ ក្នុងពាក្យនេះថា **អប្បំ គហេតព្វំ បមាណេន គហេតព្វំ** ដូច្នេះ ទើបពោលពាក្យថា **បដិគ្គហណស្មឹ** ដូច្នេះជាដើម ។ បទថា **មក្ខេតិ** ប្រែថា រមែងកំចាត់ ។ បទថា **វិនិបាតេតិ** គឺ រមែងធ្វើឲ្យវិនាស ព្រោះប្រកប ក្នុងឋានៈដែលមិនសមគួរ ។ បទថា **សាសនំ** គឺ ពាក្យប្រៀនប្រដៅ បានដល់ ពាក្យទូន្មាន របស់ព្រះសាស្តា ។ បទថា **ន ករោតិ** គឺរមែងមិនប្រតិបត្តិ ។ កិរិយាត្រាច់ទៅ តាមលំដាប់ទ្វារ ដូចជាភិក្ខុអ្នកត្រាច់ទៅ តាមលំដាប់ច្រកឈ្មោះថា សន្តោស ក្នុងវៀរចាកសេចក្តីលោភលន់ច្រើន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **ទ្វារប្បដិបាដិយាគន្តព្វំ** ។ បទថា **ហរាបេត្វា** បានដល់ នាំយករបស់ដែលលើសចេញ ។ ភិក្ខុ រមែងរលាស់ចេញចាកសេចក្តីត្រេកអរ ក្នុងអាហារ ដោយការបរិភោគនោះ ហេតុនោះ ការបរិភោគនោះ ឈ្មោះថានិស្សរណៈ គឺ ភាពជាអ្នកមានសេចក្តីត្រូវការ ដើម្បីបន្ទោបង់នូវ

មន្តលត្ថទីបនីប្រែ

សេចក្តីស្រេកឃ្លាន ។ ក៏ប្រយោជន៍ មានការតាំងនៅ នៃរាងកាយជាដើម មកហើយ ដោយការដល់នូវសេចក្តីត្រូវការនុ៉ះឯង ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **ជិយច្ឆាយ** ... **សន្តោសោ នាម** ដូច្នេះ ។ អធិប្បាយថា ភិក្ខុ មិនគួរតម្ពល់ទុកហើយៗ បរិភោគ សូម្បីក្នុងថ្ងៃនោះ ។ ឯប្រយោជន៍ ដទៃក្រៅអំពីនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហាមហើយ ដោយសិក្ខាបទនុ៉ះឯង ។ ២ បទថា **សារាណីយធម្មេ ឋិតេន** មានសេចក្តីថា ជាអ្នកតាំងនៅហើយ ក្នុងភាពជាអ្នកមានការបរិភោគ ជាសាធារណៈ ជាមួយនឹងភិក្ខុទាំងឡាយអ្នកមានសីល ។ ២ បទថា **បិណ្ឌបាតេ វុតន្តយេនេវ** មានសេចក្តីថា សេចក្តីសន្តោស ក្នុងសេនាសនៈ ទាំងនោះ គប្បីជ្រាប ដោយនយដែលពោលហើយ ក្នុងបិណ្ឌបាតនុ៉ះឯង តាមសមគួរ ដោយនយជាដើម ថា ភិក្ខុ អ្នកត្រេកអរ រមែងត្រិះរិះ ថា ក្នុងថ្ងៃនេះ អាត្មាអញ នឹងនៅ ក្នុងទីឯណា? ដូច្នេះ ។ ភិក្ខុ កាលត្រិះរិះ លើសហួសអំពីនោះទៅ រមែងឃ្លាត គឺ នៅខាងក្រៅ ចាកអរិយវង្ស ។ មួយទៀត ពាក្យទាំងអស់ មានជាអាទិ៍ យ៉ាងដូច្នេះថា ភិក្ខុ សូម្បីកាលស្វែងរកនូវសេនាសនៈ មិនត្រូវគិតថា អាត្មាអញ នឹងបាន ក្នុងទីឯណា? ដូច្នេះ គប្បីត្រាច់ទៅ ដោយយកកម្មដ្ឋាន ជាធំប៉ុណ្ណោះ ដូច្នេះ ក៏មានន័យដូចន័យមុននុ៉ះឯង ។

ពណ៌នាអំពីសេចក្ដីសន្លោស

បើមានពាក្យសួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ កាលទ្រង់សម្ដែង នូវសេចក្ដីសន្ធោស ក្នុងបច្ច័យ ក្នុងសង្ខ្ដីតិសូត្រ នេះ មិនទ្រង់កាន់យកសេចក្ដីសន្ធោស ក្នុងគិលានបច្ច័យផង? ។ ព្រះអដ្ឋកថាចារ្យ កាលសម្ដែង (ពាក្យនេះ) ថា ក៏រឿងនោះ លោកមិនត្រូវយល់ឃើញ យ៉ាងនោះទេ ទើបពោលថា **គិលាន-ប្ឋច្ចយោ បន ចិណ្ណាបាតំយេវ ឋបេត្វា** *ដូច្នេះ ។ អធិប្បាយថា ព្រោះភាវៈនៃគិលានប្ឋច្ចយនោះ ជារបស់ស្មើគ្នា (នឹងចិណ្ណាបាត) ដោយភាពជារបស់ដែលកិក្ខុគប្បីលេបចូលទៅ ។*

បើមានពាក្យចោទសួរថា បើសិនជា មានការប្រកាន់យក សេចក្ដីយ៉ាងដូច្នោះ, គប្ឋីជ្រាជ្ញាសេចក្ដីសន្ធោស ១៥ យ៉ាង មាន វិតក្ដសន្ធោស ជាដើមផង សូម្ប៉ីក្នុងគិលានប្ឋច្ចយនោះ ដូចជាក្នុង ចិណ្ណាបាតផងដែរ? ដូច្នេះ, ព្រះអដ្ឋកថាចារ្យ កាលនឹងសម្ដែង ថា មិនគួរជ្រាជ្ញា ទើបពោលពាក្យថា **ឥត្ថ** *ដូច្នេះជាដើម ។*

ដីកានៃសេចក្ដីសន្ធោស ៥០ យ៉ាង ចប់ ។

(៣០៨) ក្នុងអដ្ឋកថាមង្គលសូត្រនេះ ព្រះអដ្ឋកថាចារ្យ បានពោលហើយ ថា "សេចក្ដីសន្ធោស សូម្ប៉ីទាំងអស់នេះ ដែល មានប្រភេទដូចបានពោលមកហើយយ៉ាងនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា **សេចក្ដីសន្ធោស** *។ សេចក្ដីសន្ធោសនោះ*

គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃការបានសម្រេច នូវការលះបង់ចាបធម៌ទាំងឡាយ មានការប្រាថ្នាច្រើន ហួសប្រមាណ ការប្រាថ្នាធំ និង សេចក្ដីប្រាថ្នា ដ៏លាមក ជាដើម ព្រោះជាហេតុនៃសុគតិ ព្រោះជាហេតុនៃការឧបត្ថម្ភគាំទ្រព្រះអរិយមគ្គ និង ព្រោះភាពជាហេតុនៃសេចក្ដីចម្រើន មានការមិនដាប់ជំពាក់ ក្នុងទិសទាំង ៤ ជាដើម " ។

*អដ្ឋកថាខុទ្ទកវិភង្គ ថា " ភាវៈគឺសេចក្ដីប្រាថ្នាក្រៃលែង នូវលាភរបស់ខ្លួន នៃបព្វជិតដែលមិនសន្ដោសហើយ ដោយបច្ច័យមានចីវរបច្ច័យ ជាដើម ដែលខ្លួនបានហើយនោះៗ ឬក៏ នៃគ្រហស្ថអ្នកមិនសន្ដោសហើយ ដោយរូប សំឡេង ក្លិន រស និង ផោដ្ឋព្វៈ ដែលខ្លួនបានហើយនោះៗ ឈ្មោះថា **អតិច្ឆតា** ។ សូម្បីពាក្យថា **អត្រិច្ឆតា** គឺ ជាឈ្មោះនៃ **អតិច្ឆតា** នុ៎ះឯង " ។*

*(៣០៩) ដីកានៃខុទ្ទកវិភង្គនោះ ថា " មានអត្ថវិគ្រោះ ថា បុគ្គល ណា តែងប្រាថ្នាច្រើន ហេតុនោះ បុគ្គលនោះ ឈ្មោះថា **អតិច្ឆិច្ឆោ** (អ្នកប្រាថ្នាច្រើន) ។ កាលបើព្រះអដ្ឋកថាចារ្យ គួរពោលពាក្យថា ភាវៈនៃបុគ្គលជាអ្នកប្រាថ្នាច្រើននោះ ឈ្មោះថា **អតិច្ឆិច្ឆតា** ដូច្នេះ, ប៉ុន្ដែ លោកធ្វើនូវការលុប **ច** អក្សរ ចោលចេញ ហើយពោលថា **អតិច្ឆតា** ដូច្នេះ ។ ក៏ **អតិច្ឆតា** នោះឯង*

ពណ៌នាអំពីសេចក្តីសន្តោស

គឺព្រះអដ្ឋកថាចារ្យ ហៅថា **អត្រិច្ឆតា** ព្រោះហេតុនោះ គប្បីជ្រាបបទសម្រេច សូម្បីក្នុងពាក្យថា **អត្រិច្ឆតា** នោះ ដោយពិធីដែលមកហើយ ក្នុងនិរុត្តិបករណ៍ ។ មួយទៀត សេចក្តីប្រាថ្នាក្នុងបច្ចុ័យនោះៗ កន្ងងហួសនូវបច្ចុ័យ តាមដែលខ្ជួនបានហើយ ឈ្មោះថា **អត្រិច្ឆតា** ។ **អត្រិច្ឆតា** នោះឯង ព្រះអដ្ឋកថាចារ្យ ហៅថា **អតិច្ឆតា** ព្រោះធ្វើអាទេស **ត្រ** អក្សរ ទៅជា **ត** អក្សរ " ។

អនុដីកានៃខុទ្ទកវិភង្គនោះថា "បទថា **នេរុត្តិវិជានេន** មានសេចក្តីថា ដោយការផ្ងាស់ **ត្រ** អក្សរ ឲ្យដល់ភាពជា **ត** អក្សរ " ។

ដីកានៃឯកនិបាត អង្គុត្តរនិកាយជាដើម ថា "សេចក្តីប្រាថ្នាក្នុងបច្ចុ័យនោះ ៗ ឈ្មោះថា **អត្រិច្ឆតា** " ។

អដ្ឋកថា រថវិនីតិសូត្រ និង ឯកនិបាត អង្គុត្តរនិកាយ ជាដើម ថា "សេចក្តីប្រាថ្នានូវលាភរបស់បុគ្គលដទៃ នៃបុគ្គលអ្នកមិនចេះផ្អែតផ្អន់ហើយ ក្នុងលាភរបស់ខ្ជួន ឈ្មោះថា **អត្រិច្ឆតា** " ។

(៣១០) មែនពិត វត្ថុ ដែលខ្ជួនបានហើយ សូម្បីជារបស់ប្រណីត ក៏រមែងប្រាកដ ដល់បុគ្គលអ្នកប្រាថ្នាច្រើនហួស ដូចជារបស់ដែលអាក្រក់ដូច្នោះ, វត្ថុ ដែលអ្នកដទៃបានហើយ សូម្បីជារបស់ដែលអាក្រក់ ក៏រមែងប្រាកដ ដូចជារបស់ដែលប្រណីតដូច្នោះ ។ យាគូ ដែលបុគ្គលចំអិនហើយ ភត្ត ឬ នំ ក្នុងភាជនៈ ជា

មន្តលត្ថនីបនីប្រែ

មួយគ្នា ដែលទាយកដាក់ចូលទៅ ក្នុងបាត្ររបស់ខ្លួន រមែងប្រាកដ ដូចជារបស់អាក្រក់, (ចំណែក) យាគូ ជាដើម ដែលពួកទាយក ដាក់ចូលទៅហើយ ក្នុងបាត្ររបស់ភិក្ខុដទៃ រមែងប្រាកដ ដូចជា របស់ដែលប្រណីត ក៏សេចក្តីប្រាថ្នាច្រើនហួសនេះ រមែងមាន ទាំងពួកគ្រហស្ថ និង បព្វជិត ទាំងពួកសត្វតិរច្ឆាន ។

ក្នុងដំណើរនេះ មានរឿងនេះ (ជាខទាហរណ៍) ។

បានញ្ញមកថា កុដុម្ពីក៍ម្នាក់ និមន្តនាងភិក្ខុនី ៣០ រូប ហើយ បានប្រគេនទូវភត្ត ព្រមទាំងនំ ។ ព្រះសង្ឃថេរី បានឲ្យដូរនំ ក្នុង បាត្រ របស់នាងភិក្ខុនីទាំងឡាយហើយ ទើបបានឆាន់នូវនំ ដែល ខ្លួនបានហើយនុ៉ះឯង ជាខាងក្រោយ ។

រឿងនេះ មកក្នុងអដ្ឋកថាខុទ្ទកវិភង្ក ។

(រឿង ព្រះរាជបុត្រ)

(៣១១) ក្នុងអតីតកាល ព្រះរាជឧរស របស់ព្រះរាជាក្រុង ពារាណសី ត្រូវព្រះរាជបិតា និរទេសចោលហើយ ទើបបាននាំព្រះ នាងអសិតាភូ ដែលជាព្រះទេវី របស់ព្រះអង្ត ចូលទៅកាន់ព្រៃ ហេមពាន្ត ទ្រង់សោយនូវត្រីសាច់ និង ផ្លែឈើ គង់នៅហើយ ក្នុងបណ្ណសាលា ។ ព្រះរាជឧរសនោះ ទ្រង់ទតឃើញនាងកិន្នរី មួយ ទ្រង់មានព្រះទ័យប្រតិព័ទ្ធ ទ្រង់បានលះបង់ នូវព្រះទេវីហើយ

ពណ៌នាអំពីសេចក្តីសន្តោស

ស្តេចយាងទៅ តាមគន្ធងជើង នៃនាងកិន្នរីនោះ ។

ព្រះនាងទេវី ទ្រង់ព្រះតម្រិះ ថា "ព្រះរាជា អង្គនេះ ទ្រង់មិន រាប់អាន នូវអាត្មាអញទេ ទើបស្តេចយាងទៅ តាមនាងកិន្នរី" ដូច្នេះ ហើយ ទ្រង់យាងទៅរកតាបសមួយអង្គ បានរៀនបរិកម្មកសិណ ហើយ ទ្រង់ញុាំងឈាន និង អភិញ្ញា ឲ្យកើតឡើងហើយ បាន ស្តេចយាងមក ទ្រង់គង់នៅ ក្បែរទ្វារ នៃបណ្ណសាលា របស់ព្រះ អង្គ ។ ឯព្រះរាជកុមារ អង្គនោះ កាលទ្រង់យាង តាមនាងកិន្នរី ទ្រង់ទតព្រះនេត្រមិនឃើញ នូវផ្ទូវដែលនាងកិន្នរីនោះទៅ ទើបទ្រង់ អស់សេចក្តីសង្ឃឹមហើយ ទ្រង់ស្តេចយាងវិលមកវិញ ។ ព្រះនាង ទេវី ទ្រង់ទតព្រះនេត្រឃើញព្រះរាជកុមារនោះ កំពុងតែយាងមក ក៏បានហោះឡើងទៅ ព្ធដ៏អាកាស ហើយយាងទៅទីដទៃ ។ ក្នុង ពេលដែលព្រះនាងទេវីនោះ យាងទៅហើយ, ព្រះរាជកុមារនោះ ទ្រង់ព្រះកន្សែង ទ្រង់បានត្រាស់ នូវគាថានេះ ក្នុងអសិតាភូជាតក ក្នុងវគ្គ ទី ៩ នៃទុកនិបាត [1] ថា ៖

បុគ្គល អ្នកមានសេចក្តីប្រាថ្នា ដ៏លើសលប់ រមែងសាប
សូន្យ បាកប្រយោជន៍ ព្រោះសេចក្តីលោភ ហ្លួសហេតុផង
ព្រោះសេចក្តីស្រវឹង ក្នុងការបង់បាន ហ្លួសហេតុផង ដូប

១- សុត្តន្តបិដក ភាពទី ៥៨ ទំព័រទី ១២៥ ។

មន្តលត្ថទីបនីប្រែ

ជាយើងសាបសូន្យ ចាកព្រះរាជធីតា ព្រះនាម អសិតាភ្ជ
យ៉ាងដូច្នោះឯង ។

*បណ្តាបទទាំងនោះ បាទគាថាថា "**អត្រិច្ជំ អតិលោភេន**" មានសេចក្តីថា សេចក្តីចង់បាន ដែលមិនមានទីបំផុត ពោលគឺ សេចក្តីប្រាថ្នា ក្នុងកាមគុណនោះៗ ព្រះរាជកុមារ ទ្រង់ត្រាស់ហៅ ថា **អត្រិច្ជា**, សេចក្តីលោភលន់ ដែលប្រព្រឹត្តទៅ ហួសកម្រិត ព្រះរាជកុមារ ទ្រង់ត្រាស់ហៅថា **អតិលោភោ** ។*

*បទថា " **អតិលោភមទេន ច** " មានសេចក្តីថា ធម្មតា សេចក្តីស្រវឹង ដោយអំណាចសេចក្តីលោភលន់ហួសហេតុ ព្រោះ ញ្ជាំងសេចក្តស្រីវឹងថា ខ្ជូនជាបុរសឲ្យកើតឡើង បានកើតឡើង ហើយ ។ មានព្រះតម្រាស់ ដែលព្រះរាជកុមារ ត្រាស់អធិប្បាយ យ៉ាងដូច្នេះ ថា "បុគ្គល អ្នកប្រាថ្នា ហួសហេតុ ដោយអំណាច សេចក្តីប្រាថ្នា ក្រៃលែង រមែងសាបសូន្យ ចាកប្រយោជន៍ ដូចជា យើង សាបសូន្យហើយ ចាកព្រះនាងអសិតាភូរាជធីតា យ៉ាង ដូច្នោះឯង ព្រោះសេចក្តីលោភលន់ ហួសហេតុផង ព្រោះសេចក្តី ស្រវឹង ដោយអំណាចការចង់បាន ហួសហេតុផង " ដូច្នេះ ។*

(៣១២) ចាប់តាំងអំពីពេលនោះមក ព្រះរាជកុមារនោះ ទ្រង់គង់នៅក្នុងព្រៃ តែមួយព្រះអង្គឯងគត់ ដោយកាលកន្ថងទៅ នៃ

ពណ៌នាអំពីសេចក្តីសន្តោស

ព្រះរាជបិតា ទើបបានស្តេចយាងទៅទទួលរាជសម្បត្តិហើយ ។

ចំណែក ក្នុងអដ្ឋកថានៃវិកង្ត ព្រះអដ្ឋកថាចារ្យ ពោលថា "ទេវតា ដែលស្ថិតនៅ លើដើមឈើ បានពោលគាថានេះ ថា ៖

បុគ្គលមានសេចក្តីប្រាថ្នាលើសលប់នោះ រមែងសាបសូន្យ
ចាកប្រយោជន៍ខ្លួន ដូចព្រះរាជកុមារ ទ្រង់ប្រាថ្នានាងបន្ទ
កិន្នរី ទ្រង់សាបសូន្យហើយ ចាកព្រះនាងអសិតាភ្ជ យ៉ាង
ដូច្នោះឯង ព្រោះសេចក្តីលោភលន់ ហ្លសហេតុផង ព្រោះ
សេចក្តីស្រវឹង ក្នុងការបង់បាន ហ្លសហេតុផង ។

ទេវតា បានធ្វើនូវការចំអកឡកឡឺយ ជាមួយនឹងព្រះរាជា ថា បុគ្គល អ្នកប្រាថ្នាលើសលប់ រមែងសាបសូន្យចាកប្រយោជន៍ របស់ខ្លួន គឺ រមែងញ្ចាំងប្រយោជន៍ របស់ខ្លួន ឲ្យហិនហោចទៅ ព្រោះសេចក្តីលោភលន់ហួសហេតុ ដូចព្រះរាជកុមារ ទ្រង់ប្រាថ្នានូវនាងចន្ទកិន្នរី ទ្រង់បានសាបសូន្យហើយ ចាកព្រះរាជទេវី ទ្រង់ព្រះនាមអសិតាភូ ដូច្នោះឯង " ។

ជីកានៃវិកង្តនោះ ថា " បទថា **អត្រិច្ឆំ** មានសេចក្តីថា ប្រាថ្នាហួសហេតុ គឺប្រាថ្នាដ៏ក្រៃលែង ។ ព្រោះហេតុអ្វី? ។ ព្រោះ សេចក្តីលោភលន់ ហួសហេតុផង ព្រោះសេចក្តីស្រវឹង ដោយ អំណាចសេចក្តីចង់បានហួសហេតុ ពោលគឺសេចក្តីប្រាថ្នា ដោយ

មន្តលត្ថទីបនីប្រែ

អំណាចសេចក្តីល្មោភ ហួសហេតុផង ។ ប្រយោជន៍ របស់ខ្ជួន ទេវតា ហៅថា **អត្តា** ។ បទថា **ហាយតិ ជីយតិ** មានសេចក្តីថា ប្រយោជន៍ដែលខ្ជួនបានកាន់យកហើយ ឬ ប្រយោជន៍ដែលខ្ជួន បានសម្រេចហើយ ព្រោះហេតុនោះ ប្រយោជន៍នោះ ទើបឈ្មោះ ថា **អត្តា**, អធិប្បាយថា រមែងញ្ជាំងប្រយោជន៍ដែលខ្ជួនបានកាន់ យកហើយ ឬ ដែលខ្ជួនបានសម្រេចហើយនោះ ឲ្យហិនហោចទៅ ដូចព្រះរាជកុមារ ទ្រង់ប្រាថ្នានាងចន្ទកិន្នរី ទ្រង់បានសាបសូន្យ ហើយ ចាកព្រះនាងអសិតាភូទេវី ដូច្នោះឯង " ។

អនុដីកាវិភង្គនោះថា " ក្នុង ២ បទថា **អត្តហិតំ អត្តា** នេះ ព្រះដីកាចារ្យ ពោលនិទ្ទេស ដោយការលុបបទខាងចុង ដូចជា ឧទាហរណ៍ ថា **រូបកវៅ រូបំ** និង ថា **ភីមសេនោ ភីមោ** ដូច្នោះ ឯង ។ គប្បីជ្រាបបទសម្រេច ដោយនយ នៃនិរុត្តិបករណ៍ ថា **អាទិន្នោ បត្តោ វា អត្តោតិ អត្តា** យ៉ាងដូច្នេះ " ។

ពាក្យទាំងអស់នោះ រមែងខុសចាកបាលី ក្នុងជាតក តាម ដែលបានពោលហើយ ព្រមទាំងអដ្ឋកថា ។

រឿង ព្រះរាជបុត្រ ចប់ ។

(៣១៣) នយមក ក្នុងអដ្ឋកថាខុទ្ទកវិភង្គ និង អដ្ឋកថា សង្គីតិសូត្រ ថា " ក្នុងកាលនៃព្រះពុទ្ធ ទ្រង់ព្រះនាមកស្សបៈ កូន

ពណ៌នាអំពីសេចក្តីសន្តោស

របស់សេដ្ឋី ឈ្មោះ មិត្តវិន្ទុក: ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លា ហើយ ត្រូវមាតាប្រាប់ថា នែកូនប្រុសសំឡាញ ថ្ងៃនេះ ចូរកូន រក្សានូវឧបោសថ ស្តាប់ធម៌ ក្នុងព្រះវិហារ រហូតមួយរាត្រី, ម្តាយ នឹងឲ្យទ្រព្យ ១ ពាន់ ដល់អ្នក ដូច្នេះហើយ បានសមាទាន នូវ ឧបោសថ ព្រោះសេចក្តីលោភក្នុងទ្រព្យ ហើយកំណត់សម្គាល់ថា ទីនេះ នឹងមិនមានភ័យ ពីណាមក ហើយ ក៏បានដេកលក់ ក្រោម ធម្មាសន: រហូតទាំងរាត្រី ដល់ព្រឹកឡើង ទើបបានទៅផ្ទះ ទទួល យកទ្រព្យ ១ ពាន់ ភ្លាមហើយ ញ្ជាំបបរ ។ នាយមិត្តវិន្ទុក: នោះ ប្រាថ្នាចង់អុំទូកឆ្លងសមុទ្រ ដោយសង្ឃឹមថា អញនឹងរួបរួមទ្រព្យ ។

លំដាប់នោះ មាតា បានហាមឃាត់នាយមិត្តវិន្ទុក:នោះ ថា នែកូនសំឡាញ់ ក្នុងត្រកូលនេះ មានទ្រព្យ ដល់ទៅ ៤០ កោដិ, កូនកុំទៅឡើយ ។ នាយមិត្តវិន្ទុក:នោះ មិនស្តាប់ហើយ ចចេស ទៅទាល់តែបាន ។ មាតានោះ បានឈររាំងហើយនៅខាងមុខ ។ នាយមិត្តវិន្ទុក:នោះ ក្រោធហើយ គិតថា មាតា (របស់អញ) នេះ ឈររាំង នៅពីខាងមុខ ដូច្នេះ ក៏បានកន្ងមាតា ដែលខ្ជូនប្រហារ ឲ្យដួលចុះហើយ ដោយជើង ទើបបានទៅហើយ ។ កាលបើនាយ មិត្តវិន្ទុក:នោះ ចុះទូកទៅ, ក្នុងថ្ងៃ ទី ៧ ទូកក៏បានកៀងហើយ ។ មនុស្សទាំងឡាយ បានឲ្យចាប់ស្លាកកាឡកណ្ណីហើយ ។ ស្លាក

មន្ទលត្ថទីបនីប្រែ

នោះ បានធ្លាក់ ដល់នាយមិត្តវិន្ទុកៈនោះឯង ដល់ទៅ ៣ ដង ។ ពួកមនុស្សបានឲ្យក្សួន ដល់នាយមិត្តវិន្ទុកៈនោះហើយ បោះទម្លាក់ ចោលទៅ ក្នុងសមុទ្រ ។ នាយមិត្តវិន្ទុកៈនោះ អណ្តែតទៅ ដល់ កោះមួយហើយ សោយសម្បត្តិ ជាមួយនឹងពួកនាងវិមានិកប្រេត សូម្បីត្រូវពួកវិមានិកប្រេតទាំងនោះ ហាមប្រាមថា សូមលោក កុំ ទៅខាងមុខៗ ឡើយ ដូច្នេះ កាល (ដើរ) ទស្សនាមើលនូវសម្បត្តិ ទ្វីគុណនោះៗ ក៏បានឃើញប្រេតមួយ ដែលទូលកងចក្រ ដ៏មុត ដោយលំដាប់ ។ កងចក្រនោះ បានប្រាកដហើយ ដល់នាយ មិត្តវិន្ទុកៈនោះ ប្រៀបដូចជាផ្ការឈូក ។ នាយមិត្តវិន្ទុកៈ បង្វរករ សុំថា ចូរអ្នកឲ្យនូវផ្ការឈូកនោះ ដល់ខ្ញុំ ។ ប្រេតនោះ ពោលថា ម្នាលអ្នក នេះ មិនមែនជាផ្ការឈូកទេ, ន៉ុះ ជាកងចក្រ ដ៏មុតទេតើ ។ នាយមិត្តវិន្ទុកៈនោះ ពោលថា អ្នកមិនចង់ឲ្យដល់ខ្ញុំ ទើបបញ្ជោតខ្ញុំ, តើខ្ញុំមិនធ្លាប់ឃើញផ្ការឈូកឬ? ។ ប្រេតក្រៅនេះ គិតថា ឯបុរសនេះ ពិតជាធ្វើកម្ម ដូចជាកម្មដែលអាត្មាអញបានធ្វើហើយ ទើបប្រាថ្នា ចង់ទទួល នូវផលនៃកម្មនោះ ដូច្នេះហើយ ទើបបានពាក់កងចក្រ ទៅ លើអំបែងក្បាល របស់នាយមិត្តវិន្ទុកៈនោះហើយ ក៏បានរត់ គេចចេញទៅ " ។

(៣១៤) ដីកាសង្គីតិសូត្រថា " អធិប្បាយថា ព្រោះសេចក្តី

ពណ៌នាអំពីសេចក្ដីសង្ហេស

*លោក ក្នុងទ្រព្យ មិនមែនព្រោះការពេញចិត្ត ក្នុងធម៌ទេ ។ ឈ្មោះ ថា មិនមានភ័យមកអំពីទីណា ព្រោះភាវៈជាសភាពដែលអ្នកណា មួយ គប្បីឲ្យក្រោកឡើងមិនបាន ។ មាតា បានហាមប្រាមហើយ ដោយបំណងថា ធម្មតាការធ្វើដំណើរ តាមសមុទ្រ មានអន្ដរាយ ច្រើន ។ ២ បទថា **អន្ដរំ កត្វា** មានសេចក្ដីថា បានធ្វើមាតា ត្រង់ចន្លោះ នៃជើងទាំង ២ ដោយអំណាច នៃការកន្ទងទៅលើ ។ ទូកបានឈប់នៅនឹងហើយ ព្រោះខ្យល់មិនបក់ប៉ះ ដោយកម្លាំង នៃកម្មដ៏លាមក របស់នាយមិត្ដវិនុកៈនោះ ។*

*នាយមិត្ដវិនុកៈនោះ សោយនូវសម្បត្ដិ ដោយអានុភាពនៃ ឧបោសថកម្ម ដែលខ្លួនបានរក្សាហើយ អស់រយៈពេល ១ ថ្ងៃ ត្រូវពួកនាងវិមានិកប្រេត ឯទៀតៗ ហាមប្រាមហើយ ដូចជានាង វិមានិកប្រេត ពួកមុន ។ ហាមប្រាមថា ចូរលោក កុំអញ្ជើញទៅ ខាងមុខ១ ឡើយ យ៉ាងដូច្នេះ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថា-ចារ្យ ពោលថា **តាហិ ឋរតោ ឋរតោ មា អគមាសីតិ រុច្ចមានោ** ដូច្នេះ ។ បទថា **ទុរចក្ក្ធរំ** មានសេចក្ដីថា នូវបុរសម្នាក់ ដែល ទ្ទួលកង់ចក្រដ៏មុត ដូចជាកាំបិតកោរដ៏មុត ។ កង់ចក្រនោះ បាន ប្រាកដហើយ ដោយកម្លាំងនៃកម្មដ៏លាមក " ។*

(៣១៥) ក្នុងគ្រានោះ ព្រះពោធិសត្ដ្ব សោយព្រះជាតិ ជា

មន្តលត្ថនីបនីប្រែ

ស្តេចនៃទេវតា មួយអង្ត ត្រាច់ចារិកទៅ ក្នុងឧស្សុទនរក បានទៅ ដល់ទីនោះហើយ ។ នាយមិត្តវិន្ទុក: បានឃើញព្រះពោធិសត្ត នោះហើយ ទើបសួរថា "បពិត្រស្តេចទេវតាជាម្ចាស់ កងចក្រនេះ រមែងគ្របសង្កត់កិន ដូចជាគ្រឿងកិន (ត្បាល់កិន) កិនកំទេច នូវ គ្រាប់ល្ង ដូច្នោះ, បាបអ្វីហ្នឹ ដែលខ្ញុំបានធ្វើហើយ?" ។

លំដាប់នោះ ព្រះពោធិសត្ត កាលសម្តែង នូវកម្ម ដែល គេបានធ្វើហើយ ដល់គេ ទើបពោលគាថា ៣ ក្នុងចតុទ្វារជាតក ក្នុងទសកនិបាត [1] ថា ៖

អ្នកបានទ្រព្យជាង ២០ សែន មិនបានធ្វើតាមពាក្យ របស់ ញាតិទាំងឡាយ ដែលជាអ្នកជួយអនុគ្រោះ ដោយល្អ, អ្នក បានស្ទុះលឿនទៅកាន់ទូក ដែលអណ្តែតទៅ កាន់សមុទ្រ សាគរ ដ៏ធំធេង ដែលជាទីសម្រេបប្រយោជន៍ តិបត្ថប បានសោយ នូវសម្បត្តិ ជាមួយនឹងនាងវេមានិកប្រេត ៤ នាក់ ហើយបាននាងវេមានិកប្រេត ៨ នាក់ លុះបេញអំពី នាងវេមានិកប្រេត ៨ នាក់ហើយ ក៏បានសូវនាងវេមានិក-ប្រេត ១៦ នាក់, អ្នកបេញពីនាងវេមានិកប្រេត ១៦ នាក់ ហើយ ក៏បាន នូវនាងវេមានិកប្រេត ៣២ នាក់, អ្នកជា

១- សុត្តន្តបិដក ភាគទី ៥៩ ទំព័រទី ១៦២ ។

ពណ៌នាអំពីសេចក្តីសន្តោស

មនុស្សមានសេចក្តីប្រាថ្នា ដ៏លើសលប់ បានមកប្រទះនឹងកងបក្រ, ទាំងកងបក្រ ក៏វិលកិនន្ទវអំបែងក្បាល នៃបុរសដែលមានសេចក្តីប្រាថ្នា ត្របសង្កត់ហើយ ។

(៣១៦) អដ្ឋកថាជាតក ថា " បណ្តាបទទាំងនោះ បទថា ***លទ្ធា*** *មានសេចក្តីថា ធ្វើឧបោសថកម្ម និង ទទួលយកទ្រព្យ ១ ពាន់ អំពីសំណាក់នៃមាតា កាលធ្វើនូវការលក់ដូរ បានហើយ នូវទ្រព្យជាង ២០ សែន (ទៀត) ។ បទថា* ***នាកវិ*** *មានសេចក្តីថា អ្នកមិនសន្តោសហើយ ដោយទ្រព្យនោះ ស្ទុះទៅកាន់សមុទ្រ ដោយទូក សូម្បីត្រូវមាតាសម្តែងទោស ក្នុងសមុទ្រហើយ ហាមប្រាម ក៏មិនបានធ្វើ តាមពាក្យ របស់ញាតិទាំងឡាយ អ្នកជួយអនុគ្រោះ ដោយល្អទ្បើយ បានស្ទុះលឿនទៅ កាន់ទូកដែលទៅកាន់សមុទ្រសាគរ ដ៏ធំធេង ដែលអាចធ្វើឲ្យទូកលោតផ្ទោះទៅបាន ។ បទថា* ***អប្បសិទ្ធិយំ*** *គឺ ដែលមានសេចក្តីសម្រេចតិច បានដល់មានសេចក្តីវិនាសច្រើន ។ ២ បទថា* ***ចតុព្ភិ អដ្ឋ*** *មានសេចក្តីថា ដោយអានិសង្ស នៃឧបោសថកម្ម ដែលខ្ជួនបានធ្វើហើយ អស់រយៈពេល ១ ថ្ងៃ ព្រោះអាស្រ័យមាតា ទើបអ្នកបានហើយ នូវស្រី ៤ នាក់ ក្នុងវិមានកែវផលិក, បន្ទាប់អំពីនោះមក អ្នកបានហើយ នូវស្រី ៨ នាក់ ក្នុងវិមានប្រាក់ បានស្រី ១៦ នាក់ ក្នុង*

មន្តលត្ថទីបនីប្រែ

វិមានកែវមណី បានស្រី ៣២ នាក់ ក្នុងវិមានមាស " ។

*(៣១៧) ជីកានៃសង្គីតិសូត្រថា "បទថា **ចតុព្ពិ** មានសេចក្តីថា ព្រមជាមួយនឹងនាងវេមានិកប្រេតទាំងឡាយ ៤ នាក់ ដែលជូចជានាងទេពអប្សរ ។ ២ បទថា **សម្បត្តឹ អនុកវិត្វា** គឺជាពាក្យដែលនៅសល់ (គួរនាំយកមកបញ្ចូល) ។ បទថា **អជ្ឌជ្ឈគមា** មានសេចក្តីថា បានជួបប្រទះនាងវេមានិកប្រេត ៨ នាក់ ដែលប្រសើរជាងនោះ ដោយគុណ មានរូបជាដើម ។ បទថា **អត្រិច្ចំ** មានសេចក្តីថា ឈ្មោះថា ប្រាថ្នាក្នុងកាមគុណនោះៗ ព្រោះភាវៈជាអ្នកប្រកបព្រម ដោយសេចក្តីលោភលន់ ហួសហេតុ ពោលគឺ ប្រាថ្នាចង់បាន ដ៏លើសលប់ " ។*

*អដ្ឋកថាជាតកថា " ២ បទថា **អត្រិច្ចំ ចក្កមាសទោ** មានសេចក្តីថា អ្នកជាមនុស្សអាក្រក់ មិនត្រេកអរហើយ ដោយទ្រព្យតាមដែលខ្ជួនបានហើយ ឈ្មោះថា ប្រាថ្នាចង់បាន ហួសហេតុ ព្រោះភាពជាអ្នកប្រកបព្រមហើយ ដោយសេចក្តីប្រាថ្នា ដ៏លើសលប់ ពោលគឺសេចក្តីលោភលន់ ដែលកន្ងងហួសនូវទ្រព្យ ដែលខ្ជួនបានហើយៗ យ៉ាងដូច្នេះថា អាត្មាអញនឹងបានលើស គឺច្រើនឡើងទៅៗ ដូច្នេះ ព្រោះភាវៈនៃខបោសថកម្មនោះ អស់ហើយ ទើបបានកន្ងងស្រីទាំងឡាយ ៣២ នាក់ ហើយ បានទៅដល់ស្រុក*

ពណ៌នាអំពីសេចក្តីសន្តោស

ប្រេតនេះ បានទទួលហើយ នូវចក្រដ៏មុត ដោយផលនៃអកុសល គឺការវាយប្រហារ នូវមាតានោះ ។ បាឯ:ថា **អតិច្ចំ** ដូច្នេះ ក៏មានខ្ជះដែរ ។ អធិប្បាយថា ប្រាថ្នាចង់បាន ហួសហេតុ " ។

ដីកានៃសង្គីតិសូត្រ ថា " បទថា **ចក្តំ** បានដល់ នូវចក្រដ៏មុត ដូចកាំបិតកោរ ។ បទថា **អាសាទោ** មានសេចក្តីថា រមែងត្រេកអរទូទៅ ព្រោះភាវ:នៃអកុសលកម្មនោះ ជាហេតុនាំសេចក្តីវិនាសមកឲ្យ " ។

ដីកាវិភង្គថា " បទថា **ឥច្ចាហតស្ស** គឺ ជាអ្នកត្រូវសេចក្តីប្រាថ្នាចង់បានបៀតបៀនហើយ " ។

អដ្ឋកថាជាតក ថា " បទថា **ភមតិ** មានសេចក្តីថា ចក្រនេះ កាលកិននូវអំបែងក្បាល របស់អ្នកនោះ ដែលជាអ្នកត្រូវសេចក្តីប្រាថ្នាចង់បានគ្របសង្កត់ហើយ ក្នុងពេលឥឡូវនេះ រមែងវិលនៅលើអំបែងក្បាល ដូចចក្រនៃនាយស្ងួនឆ្នាំង យ៉ាងដូច្នោះឯង " ។

រឿងនាយមិត្តវិន្ទុក: អ្នកសិក្សា គប្បីត្រួតពិនិត្យមើល ក្នុងមិត្តវិន្ទុកជាតក ក្នុងនវមវគ្គ នៃឯកនិបាត និង ក្នុងទុតិយវគ្គ នៃបញ្ចកនិបាត ។

(រឿង ខ្ជាឃ្ចុំ)

(៣១៨) ក្នុងអតីតកាល ខ្ជាឃ្ចុំមួយ នៅក្នុងគុម្ពោតព្រៃ

មជ្ឈលត្ថនីបនីប្រែ

ក្បែរបណ្ណសាលា របស់តាបស មួយរូប ជាសត្វត្រូវសេចក្ដីប្រាថ្នាដ៏លើសលប់ គ្របសង្កត់ហើយ បានចេញអំពីព្រៃ ចូលទៅកាន់ បច្ចន្តគ្រាម ហើយចូលទៅ កាន់គុម្ពោតព្រៃ ។ ពួកមនុស្ស កាន់ធ្នូ និង ដំបង ជាដេមី នៅនឹងដៃ បានឡោមព័ទ្ធគុម្ពោតព្រៃនោះហើយ ក៏បានយកធ្នូ និង ដំបង វាយខ្លាឃ្មុំនោះដែលកំពុងតែចោលរត់ចេញ ទៅ ។ ខ្លាឃ្មុំនោះ ប៉ែកក្បាលហើយ មានឈាមហូរចេញ បានចោលទៅកាន់ទីនៅ របស់ខ្លួនហើយ គិតថា "សេចក្ដីទុក្ខនេះ បានកើតឡើងហើយ ដល់អាត្មាអញ ដោយអំណាចសេចក្ដីលោភលន់ គឺការចង់បានដ៏លើសលប់, ឥឡូវនេះ អញ គ្របសង្កត់ (សេចក្ដីលោភ) មិនបានហើយ នឹងមិនទទួលអាហារចំណីឡើយ " ដូច្នេះ ហើយ បានទៅកាន់អាសមបទ អធិដ្ឋានអង្គនៃឧបោសថ ហើយ ក៏ដេក ត្រូវតាបសសួរ ថា " ថ្ងៃនេះ អ្នកឯងរក្សាឧបោសថ ដើម្បីប្រយោជន៍អ្វី? " ដូច្នេះហើយ បានពោលគាថាទាំងឡាយ ២ នោះ ក្នុងបញ្ចោបោសថជាតក [1] ក្នុងបកិណ្ណកៈ ថា ៖

ខ្ញុំ មើលងាយ ផ្ទរ្យាលំនៅ របស់ខ្លួន បានចូលទៅកាន់ស្រុក
ដែមល្ហជន ព្រោះតែសេចក្ដីប្រាថ្នាដ៏លើសលប់ ។ ពួកជន
បេញ្ញមក អំពីស្រុកនោះហើយ ក៏វាយខ្ញុំដោយធ្នូ ។ ខ្ញុំនោះ

១- សុ. ភាគទី ៦០ ទំព័រទី ៣០ ។

ពណ៌នាអំពីសេចក្ដីសន្លោស

បៃកក្សាល ប្រឡាក់ឈាម អស់ទាំងខ្លួន ហើយបានត្រឡប់
មកកាន់ទីលំនៅ ដែលខ្លួនធ្លាប់នៅវិញ ។ ហេតុនោះ បាន
ជាខ្ញុំរក្សាខ្មបោសឯ, ស្ងមកុំឲ្យសេចក្ដីប្រាថ្នា ដ៏លើសលប់
មកគ្របសង្កត់បានទៀតឡើយ ។

*អដ្ឋកថាជាតក ថា " បណ្ដាបទទាំងនោះ បទថា **អតិហីឡ-
យានោ** គឺមើលងាយ បានដល់ តិះដៀល ។ បទថា **កោទណ្ឌកេន**
បានដល់ ដោយដងធ្នូទាំងឡាយ និង ដោយដំបងទាំងឡាយ " ។*

អដ្ឋកថាខុទ្ទកវិភង្គ ថា " ខ្ញុំ បានទៅកាន់មលតជនបទ " ។

*ដីកានៃវិភង្គ ថា " បទថា **អតិហេឡយានោ** ប្រែថា កាល
មើលងាយ ។ បទថា **មលតំ** បានដល់ កាន់ជនបទដែលមាន
ឈ្មោះយ៉ាងដូច្នោះ ឬ កាន់ទីវាល ។ បទថា **កោទណ្ឌកេន** គឺ
ដោយដង នៃកោទណ្ឌ (ធ្នូ) ។ អាចារ្យ ពួកខ្លះ ពោលថា ដោយ
ដំបង ។ បទថា **រុហិរមក្ខិតង្គោ** ប្រែថា មានខ្លួនប្រឡាក់ឈាម
ជោកហើយ " ។*

រឿង ខ្លាឃ្មុំ ចប់ ។

ពណ៌នាអំពីរឿងនៃសេចក្ដីប្រាថ្នាដ៏លើសលប់ ចប់ ។

*(៣១៩) អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ថា "ដែលឈ្មោះ
ថា **មហិច្ឆតា** បានដល់ សេចក្ដីលោភលន់ច្រើន ដែលព្រះអដ្ឋ-
កថាចារ្យ បានសំដៅយក ពោលទុកហើយថា បណ្ដាធម៌ទាំងនោះ*

មន្តលត្ថទីបនីប្រែ

ភាពជាអ្នកប្រាថ្នាច្រើន តើដូចម្តេច? គឺ សេចក្តីប្រាថ្នាដ៏ក្រៃលែងរបស់បព្វជិត អ្នកមិនត្រេកអរហើយ ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ បរិក្ខារ តាមដែលខ្ជួនបានហើយ ឬ របស់គ្រហស្ថ អ្នកមិនត្រេកអរហើយ ដោយកាមគុណទាំង ៥, សេចក្តីប្រាថ្នា គឺ ការប្រព្រឹត្តិទៅ នៃសេចក្តីប្រាថ្នា ភាពជាអ្នកមានសេចក្តីប្រាថ្នាច្រើន សេចក្តីស្រលាញ់ សេចក្តីត្រេកត្រអាលដ៏ខ្លាំងខ្លា នៃចិត្ត នេះឯណា, នេះ លោកហៅថា ***មហិច្ឆតា*** *" ។*

ដីកាឯកនិបាត អង្គុត្តរនិកាយនោះថា " សេចក្តីប្រាថ្នា របស់បុគ្គលន៉ុះ ច្រើន ហេតុនោះ បុគ្គលនោះ ឈ្មោះថា ***មហិច្ឆោ*** *(អ្នកមានសេចក្តីប្រាថ្នាច្រើន) ។ ភាវៈនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាច្រើននោះ ឈ្មោះថា* ***មហិច្ឆតា*** *។ សេចក្តីលោភ ដែលមានអារម្មណ៍ច្រើន ឈ្មោះថា* ***មហាលោភោ*** *ព្រោះសេចក្តីចង់បានចំពោះវត្ថុដែលធំ និង វត្ថុដែលច្រើន ។ ដោយពាក្យថា* ***ឥតរីតរ*** *ជាដើម លោកពោលភាវៈជាអ្នកប្រាថ្នាធំ ដែលកើតឡើង ដល់បព្វជិតទាំងឡាយ ។ ពាក្យថា* ***បញ្ចហិ វា កាមគុណេហិ*** *ដូច្នេះ ជាដើម លោកពោលហើយ ដោយអំណាចគ្រហស្ថទាំងឡាយ" ។*

អដ្ឋកថាវិភង្គថា "ភាពជាអ្នកប្រាថ្នា ដោយវិសេស ឈ្មោះថា ***ភិយ្យោកម្យតា*** *។ សេចក្តីប្រាថ្នា ដោយអំណាច នៃសេចក្តី*

ពណ៌នាអំពីសេចក្ដីសង្ខេស

ចង់បាន, សេចក្ដីប្រាថ្នានុ៎ះឯង ឈ្មោះថា ការប្រព្រឹត្តិទៅ នៃសេចក្ដីប្រាថ្នា ឬ អាការនៃសេចក្ដីប្រាថ្នា " ។

*ជីកាឯកនិបាត អង្គុត្តរនិកាយថា " កិរិយាប្រព្រឹត្តិទៅ ដោយអំណាចនៃសេចក្ដីប្រាថ្នា ឈ្មោះថា **ឥច្ឆាគតំ** ។ ភាពជាអ្នកប្រាថ្នាច្រើន ឈ្មោះថា **មហិច្ឆតា** ។ ប៉ុន្តែដោយសេចក្ដី ភាពជាអ្នកប្រាថ្នាច្រើននេះ ក៏គឺភគ:នុ៎ះឯង ព្រោះហេតុនោះ ទើបលោកពោលថា **ភគោ សាភគោ** ដូច្នេះជាដើម " ។*

*អដ្ឋកថាឈ្មោះអដ្ឋសាលិនី ថា "សភាវ: ណា រមែងត្រេកអរក្រៃលែង ព្រោះហេតុនោះ សភាវ:នោះ ឈ្មោះថា **សភគោ** (សភាវ:ដែលត្រេកអរក្រៃលែង) " ។*

*អដ្ឋកថាវិភង្គ ថា " បុគ្គល រមែងប្រាថ្នា នូវវត្ថុច្រើន ឬថា សេចក្ដីប្រាថ្នា របស់បុគ្គលនោះធំ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **មហិច្ឆោ** (អ្នកមានសេចក្ដីប្រាថ្នានូវវត្ថុច្រើន ឬក៏ មានសេចក្ដីប្រាថ្នាធំ) ។ ភាពនៃបុគ្គលជាអ្នកមានសេចក្ដីប្រាថ្នាច្រើននោះ ឈ្មោះថា **មហិច្ឆតា** " ។*

*(៣២០) អដ្ឋកថារបវិនីតសូត្រ និង ឯកនិបាត អង្គុត្តរ-និកាយ ថា " ក៏ភាវ:គឺការសរសើរ នូវគុណដែលមាន និង ភាពជាអ្នកមិនស្គាល់ប្រមាណ ក្នុងការទទួល ឈ្មោះថា **មហិច្ឆតា** ។*

មង្គលត្ថទីបនីប្រែ

ឯកាពជាអ្នកជ្រាជ្ញាច្រើននោះ មកហើយ ដោយនយ័នេះឯង ថា " បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសទ្ធា រមែងជ្រាជ្ញ ថា ជនចូរជឿ នូវអាត្មាអញ ថា ជាអ្នកមានសទ្ធា ដូច្នេះ, ជាអ្នកមានសីល រមែងជ្រាជ្ញ ថា ជនចូរជឿ នូវអាត្មាអញ ថា ជាអ្នកមានសីល ដូច្នេះឯង " ។

ជីកានៃវជិរ៉ាតសូត្រ និង ឯកនិបាត អង្គុត្តរនិកាយនោះ ថា " កិរិយាស្ថិតនៅ ក្នុងការប្រព្រឹត្ត ដោយសេចក្តីជ្រាជ្ញ ហើយ ប្រកាស នូវគុណមានសីល និង ធុតង្គធម៌ជាដើម ដែលមាននៅ ក្នុងខ្លួន ឈ្មោះថា សេចក្តីពោលសរសើរគុណដែលមាន ។ ក៏ សូម្បីកាពជាអ្នកមិនស្គាល់ប្រមាណ ក្នុងការទទួល រមែងមាន ដល់បុគ្គលអ្នកជ្រាកដ ដូច្នោះ ។ មានសម្ពន្ធ ថា សូម្បីកាពជា អ្នកមិនស្គាល់ នូវប្រមាណនោះ ក៏មកហើយ ក្នុងព្រះអកិធម្ម ដូចគ្នាដែរ " ។

(៣២១) អដ្ឋកថាវិកង្ខ្ថា "មែនពិត បុគ្គលអ្នកមានសេចក្តី ជ្រាជ្ញាច្រើន រមែងជាអ្នកមានបំណងនឹងប្រកាស នូវសីលគន្ធ: ឬក៏ គុណនៃធុតង្គ ដោយហោចទៅ សូម្បីនូវគុណត្រឹមតែការ នៅ ក្នុងព្រៃរបស់ខ្លួន សូម្បីមានប្រមាណតិចតួច ដល់មហាជនអ្នក ដែលស្គាល់ទ:ឯង ប្រៀបដូចជាអ្នកជំនួញ ដែលវេចខ្ចប់នូវរបស់

ពណ៌នាអំពីសេចក្ដីសន្ធោស

របរ ដោយថ្នក់ កាន់យកនូវកញ្ចប់នៃគ្រឿងប្រដាប់ដោយដៃហើយ ដាក់នូវរបស់របរដែលគួរដាក់ ក្នុងថ្នក់ន៏ុះឯង, កាលបើមហាជន មើលឃើញន៏ុះឯង, រមែងចាត់ចែង ពពាយនាយលក់ថា អ្នកទាំងឡាយ ចូរអញ្ជើញជួយទទួល (ជួយទិញ) នូវរបស់ឈ្មោះន៏ុះ១ យ៉ាងដូច្នោះឯង, ក៏លុះប្រកាសហើយ មិននិយាយថា ល្ងមគ្រប់គ្រាន់ហើយ ដូច្នេះ រមែងទទួលនូវបច្ច័យទាំងឡាយ ដែលទាយកនាំចូលមកហើយសូម្បីដោយរ១ទេ ។ មែនពិត សភាពទាំងឡាយ ៣ យ៉ាង គឺ បុគ្គលមិនអាច ដើម្បីឲ្យពេញបានឡើយ គឺ ភ្លើង បុគ្គលមិនអាចឲ្យពេញបាន ដោយប្រនេះ, សមុទ្រ បុគ្គលមិនអាចឲ្យពេញបាន ដោយទឹក, បុគ្គល អ្នកមានសេចក្ដីប្រាថ្នាច្រើន គឺ បុគ្គលមិនអាចឲ្យពេញ ដោយបច្ច័យទាំងឡាយបានឡើយ ដោយប្រការដូច្នេះឯង ។

> បុគ្គលកាលឪ្យបច្ច័យទាំងឡាយដ៏ច្រើន ក៏មិនគប្បីញ្ជុំង សូម្បីសភាពទាំងឡាយ ៣ យ៉ាងនេះ គឺ គំនរភ្លើង ១ សមុទ្រ ១ បុគ្គលអ្នកប្រាថ្នាច្រើន ១ ឪ្យពេញបរិបូណ៌បាន១ឡើយ ។

ដីកានៃវិកន្ធ្ម១ោះ ថា " រមែងជាអ្នកមានបំណង ដើម្បីនឹងប្រកាស ដល់មហាជនអ្នកស្គាល់ន៏ុះឯង ឲ្យក្រៃលែងឡើងៗ ដូចជា ១ៅចាំជាស់គឿន យ៉ាងដូច្នោះ ។ បទថា **ឋ**ច្ចយ *បានដល់*

មន្ថលត្ថទីបនីប្រែ

នូវបច្ចយ មានប្រធេះភ្លើងជាដើម " ។

អនុដីកាថា "បទថា ***ឧបាទានាទិប្បច្ចយេ*** *មានសេចក្តីថា បច្ចយដែលជាហេតុ ឲ្យពេញបរិបូណិ មានប្រធេះ ទឹក និង ចីពរ ជាដើម " ។*

(៣២២) ក៏បុគ្គលអ្នកមានសេចក្តីប្រាថ្នាច្រើន រមែងមិនអាច ដើម្បីយកចិត្ត សូម្បីនៃមាតាបង្កើតបានឡើយ, នឹងចាំបាច់ពោល ធ្វើអ្វី ដល់ឧបដ្ឋាកទាំងឡាយន៉ុះឡើយ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(រឿង ភិក្ខុកំលោះ)

បានញ្ចថា ភិក្ខុកំលោះ មួយរូប ចូលចិត្ត (ធាន់) នំអំបែង ។ លំដាប់នោះ មាតា របស់ភិក្ខុនោះ កាលសាកល្បង នូវសេចក្តី បដិបត្តិ គិតថា " បើកូនប្រុស របស់ខ្ញុំ ស្គាល់ប្រមាណ ក្នុងការ ទទួល, ខ្ញុំ នឹងប្រគេននូវនំ ដល់លោកកូននោះ រហូតត្រៃមាស ទាំងអស់ " ដូច្នេះហើយ ក្នុងថ្ងៃចូលព្រះវស្សា បានប្រគេននំមួយ ជាដំបូង, កាលបើភិក្ខុរូបនោះ ធាន់នំនោះហើយ, បានប្រគេននំ ទី ២, កាលបើភិក្ខុរូបនោះ ធាន់នំ ទី២ នោះហើយ, ក៏បានប្រគេន ហើយនូវនំ ទី៣ ។ ភិក្ខុ កំលោះ មិនបានពោល ថា "គ្រប់គ្រាន់ ហើយ " គិតតែពីធាន់ប៉ុណ្ណោះ ។ មាតា បានដឹងថា ភិក្ខុនោះ មិន

ពណ៌នាអំពីសេចក្ដីសង្ហេស

ស្គាល់នូវប្រមាណ ទើបគិតថា " នំសម្រាប់ត្រៃមាសទាំងអស់ គឺ លោកកូនខ្ញុំ បានធាន់ហើយ ក្នុងថ្ងៃនេះឯង " ហើយ ក៏មិនបាន ប្រគេនសូម្បីតែនំមួយដុំ ដល់ភិក្ខុនោះ ចាប់តាំងពីថ្ងៃ ទី២ មក ។

រឿងភិក្ខុកាំលោះ ចប់ ។

(រឿង ព្រះរាជាព្រះនាមតិស្ស:)

(៣២៣) ចំណែកព្រះបាទតិស្សមហារាជ កាលទ្រង់ថ្វាយ ទាន ដល់ព្រះភិក្ខុសង្ឆ ក្នុងចេតិយបព្ពតវិហារ ជារៀងរាល់ថ្ងៃ ត្រូវពួកអ្នកជនបទ ក្រាបទូលថា " បពិត្រព្រះមហារាជ ព្រោះ ហេតុអ្វី បានជាព្រះអង្គ ទ្រង់សេពគប់នូវទីស្ថាន តែមួយកន្លែង ប៉ុណ្ណោះ?, ការដែលព្រះអង្គ ទ្រង់ថ្វាយទាន ក្នុងទីកន្លែងដទៃទៀត រមែងមិនសមគួរទេឬ? " យ៉ាងដូច្នេះហើយ ក្នុងថ្ងៃ ទី២ ទ្រង់បាន ត្រាស់បញ្ជា ឲ្យថ្វាយមហាទាន ក្នុងទីក្រុងអនុរាធបុរី ។

សូម្បីភិក្ខុ មួយរូប ក៏មិនស្គាល់ប្រមាណ ក្នុងការទទួល ។ ខាទនីយ: និង ភោជនីយាហារ ដែលភិក្ខុមួយរូបៗ បានទទួល ហើយ មនុស្សទាំងឡាយ ២-៣ នាក់ ទើបលើកយូច ។

ក្នុងថ្ងៃ ទី២ ព្រះរាជា ទ្រង់ត្រាស់បញ្ជា ឲ្យនិមន្តភិក្ខុសង្ឆ ក្នុងចេតិយបព្ពតវិហារហើយ ទ្រង់ត្រាស់ថា "សូមព្រះគុណម្ចាស់ ទាំងឡាយ ឲ្យនូវបាត្រមក " យ៉ាងដូច្នេះ ក្នុងពេលដែលភិក្ខុទាំង

មន្តលត្ថនីបនីប្រែ

ឡាយនោះ និមន្តមកដល់ខាងក្នុងនៃព្រះបរមរាជវាំងហើយ សូម្បីភិក្ខុមួយរូប ក៏មិនបានថ្វាយហើយនូវបាត្រ ដោយបានថ្វាយព្រះពរ ថា " បពិត្រព្រះមហារាជ ល្ងមគ្រប់គ្រាន់ហើយ, ពួកភិក្ខុទាំងឡាយ នឹងទទួលនូវភិក្ខា តាមប្រមាណ របស់ខ្លួន " ។ ភិក្ខុទាំងឡាយ ទាំងពួង បានទទួលហើយ នូវភិក្ខា ដ៏សមគួរ នឹងប្រមាណ នុ+ះឯង ។

ព្រះរាជា ទ្រង់មានព្រះរាជឧង្ការថា អ្នកទាំងឡាយចូរមើលចុះ, បណ្តាភិក្ខុទាំងឡាយ របស់ពួកអ្នក សូម្បីភិក្ខុមួយរូប ក៏មិនស្គាល់នូវប្រមាណឡើយ, កាលពីថ្ងៃម្សិលមិញ មិនបានមានវត្ថុអ្វីនៅសេសលស់ឡើយ, ក្នុងថ្ងៃនេះ ព្រះគុណម្ចាស់ ទទួលយកហើយតែបន្តិច, វត្ថុជាច្រើនណាស់ មាននៅសល់តែម្តង " ហើយទ្រង់សព្វព្រះរាជហប្ចទ័យ ក្នុងភាពនៃភិក្ខុទាំងឡាយ ក្នុងចេតិយ-បព៌តវិហារនោះ ជាអ្នកស្គាល់ប្រមាណ និង ទ្រង់មិនបានសព្វព្រះរាជហប្ចទ័យហើយ ក្នុងភាពនៃភិក្ខុក្រៅអំពីនេះ ជាអ្នកមិនស្គាល់នូវប្រមាណ ។

រឿង ព្រះរាជាព្រះនាមតិស្សៈ ចប់ ។

រឿង ទាំងពីរ មកក្នុងអដ្ឋកថាខុទ្ទកវិភង្ត ។

(៣២៤) ឧបាសកម្នាក់ ក្នុងទីក្រុងសាវត្ថី បានបវារណា

ពណ៌នាអំពីសេចក្តីសន្តោស

(រឿង នាងថូលនន្ទាភិក្ខុនី)

នាងភិក្ខុនីសង្ឆ ដោយមើមខ្ចឹមហើយ បានបញ្ជាបុគ្គលអ្នករក្សាស្រែ ថា " បើនាងភិក្ខុនី និមន្តមក, អ្នកចូរប្រគេនន្ទូវមើមខ្ចឹមដល់នាងភិក្ខុនី មួយរូប ៗ ២-៣ កញ្ចប់ផង " ។ ក្រោយមក ថ្ងៃមួយ នាងភិក្ខុនី ឈ្មោះថូលនន្ទា ព្រមទាំងបរិវារ និមន្តទៅកាន់ស្រែ ហើយ មិនស្គាល់ប្រមាណ បានឲ្យគេនាំយកមើមខ្ចឹមទៅ យ៉ាងច្រើន ។ ចំណែក អ្នករក្សាស្រែ បានលើកទោសហើយ ។

ព្រះសាស្តា ទ្រង់ជ្រាបរឿងនោះហើយ ទ្រង់បានតិះដៀលនាងថូលនន្ទាភិក្ខុនី ហើយ ទើបទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា បុគ្គលអ្នកមានសេចក្តីប្រាថ្នាច្រើន រមែងមិនជាទីស្រលាញ់ មិនជាទីពេញចិត្ត សូម្បីរបស់មាតាបង្កើតឡើយ ទាំងមិនអាចដើម្បីញ្ចាំងមហាជន អ្នកដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាបានឬ ដើម្បីញ្ចាំងមហាជនអ្នកដែលជ្រះថ្លាហើយ ឲ្យជ្រះថ្លា ដោយប្រមាណយ៉ាងក្រៃលែងបានឡើយ ទាំងមិនអាច ដើម្បីញ្ចាំងលាភ ដែលមិនទាន់បានកើតឡើងហើយ ឲ្យកើតឡើងបាន ឬ ដើម្បីធ្វើលាភ ដែលកើតឡើងហើយ ឲ្យស្ថិតនៅគង់វង្ស បានឡើយ, ចំណែក បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច រមែងអាច" ដូច្នេះហើយ ទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ នាងថូលនន្ទាភិក្ខុនី ជាអ្នក

មង្គលត្ថទីបនីប្រែ

ប្រាជ្ញាប្រើន មិនមែនតែក្នុងពេលឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុន ក៏ជាអ្នកប្រាជ្ញាប្រើន ដូចគ្នាដែរ " ដូច្នេះហើយ ទើបទ្រង់បាននាំ នូវអតីតនិទាន មកត្រាស់សម្តែង ថា ៖

(៣២៥) ក្នុងអតីតកាល ព្រាហ្មណ៍ម្នាក់ក្នុងក្រុងពារាណសី ធ្វើមរណកាលហើយ ក៏បានទៅកើត ក្នុងកំណើតនៃហង្សមាស ។ ហង្សមាសនោះ កាលពិចារណា ដោយញាណដែលជាគ្រឿងរាប្ជាតជាតិបាន ក៏បានឃើញភរិយា និង ពួកកូនស្រី របស់ខ្លួន កំពុងតែធ្វើការស៊ីឈ្នួលអ្នកដទៃ មកចិញ្ចឹមជីវិត ហើយក៏បានទៅ ក្នុងទីនោះ ព្រោះសេចក្តីស្រលាញ់ ចំពោះភរិយា និង កូនស្រីទាំងនោះ បាននិយាយប្រាប់រឿងរ៉ាវទាំងអស់ហើយ ទើបឲ្យនូវពោមស្ងាបមួយ ដល់ភរិយា និង កូនស្រីទាំងនោះ ហើយបានប្រាប់ថា "ចាប់តាំងអំពីថ្ងៃនេះទៅ សូមអ្នកទាំងអស់គ្នា កុំបីធ្វើការស៊ីឈ្នួលអ្នកដទៃទ្បើយ, ពួកអ្នក ចូរលក់ពោមស្ងាមនេះហើយ ចិញ្ចឹមជីវិត តាមសប្បាយចុះ " ដូច្នេះហើយ ក៏បានចៀសចេញទៅ ។ បានឮថា ពោមស្ងាបហង្សនោះ សម្រេចដោយមាស ជារបស់គួរដល់ការជំនិង ផែបាន ។ ហង្សមាសនោះ ហើរទៅ (ជម្រុះ) ពោមស្ងាមឲ្យ ម្តងមួយៗ ក្នុងចន្ទោះៗ (ដល់ភរិយា និង កូនស្រីទាំងនោះ) ដោយទំនងនេះ ។ នាងព្រាហ្មណី និង កូនស្រីទាំងឡាយ បានជា

ពណ៌នាអំពីសេចក្ដីសន្តោស

អ្នកមានស្តុកស្តម្ភហើយ ។ ក្រោយមក ថ្ងៃមួយ នាងព្រាហ្មណី បានពោល ថា " នែនាងទាំងឡាយ ធម្មតាចិត្ត របស់សត្វតិរច្ឆាន ទាំងឡាយ ជាធម្មជាតដែលជីងបានដោយពិបាក, ជួនកាលឪពុក របស់កូនឯង ទាំងអស់គ្នា មិនគប្បីមក ក្នុងទីនេះ, ឥឡូវនេះ ក្នុង ពេលដែលឪពុក របស់កូនឯងនោះ មកហើយ ពួកយើង នឹងចាប់ ជករោមស្ងាបទាំងអស់ " ។ ពួកកូនស្រី បានហាមឃាត់ម្តាយ នោះហើយ ។ ក៏ក្នុងថ្ងៃស្អែកឡើង កាលបើសត្វហង្សមាសនោះ ហើរមក ដល់ហើយ, នាងព្រាហ្មណីនោះ បានធ្វើហើយ យ៉ាង ដូច្នោះ ព្រោះភាពនៃខ្លួនជាអ្នកប្រាថ្នាច្រើន ។ រោមស្ងាបទាំង អស់ បានក្លាយ ដូចជារោមស្ងាប របស់សត្វកុកក្រក អស់ហើយ ព្រោះភាវៈជារបស់ ដែលនាងព្រាហ្មណី ប្រាចយកហើយ ដោយ ការធ្វើតាមកម្លាំង ប្រាសចាកសេចក្តីចេញចិត្ត របស់សត្វហង្ស ។ សត្វហង្ស មិនអាចហើរទៅបានឡើយ ។ នាងព្រាហ្មណី បាន ក្រុងសត្វហង្សនោះ ក្នុងទ្រុងដ៏ធំ ចិញ្ចឹមហើយ ។ រោមស្ងាបរបស់ សត្វហង្សនោះ បានដុះឡើងជាថ្មីហើយ ក៏បានក្លាយទៅជារោម ពណ៌ាស ។ សត្វហង្សនោះ មានរោមស្ងាបដុះឡើងហើយ បាន ហើរទៅទីលំនៅឋានរបស់ខ្លួន លែងត្រឡប់មកវិញហើយ ។

(៣២៦) ព្រះសាស្តា លុះទ្រង់បាននាំយកអតីតនិទាន មក

មង្គលត្ថទីបនីប្រែ

ហើយទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ នាងភិក្ខុនី ឈ្មោះ ចូលនន្ទាជាអ្នកប្រាជ្ញាច្រើន មិនមែនតែក្នុងពេលឥឡូវនេះប៉ុណ្ណោះ ទេ, សូម្បីក្នុងលកាលមុន នាងចូលនន្ទាភិក្ខុនីនេះ ក៏ជាអ្នកប្រាជ្ញា ច្រើនដូចគ្នាដែរ, ក៏ព្រោះភាពជាអ្នកប្រាជ្ញាច្រើន ទើបនាងសាប សូន្យហើយ ចាកមាស ក្នុងកាលមុន, មួយទៀត ក្នុងពេល ឥឡូវនេះ នាង ក៏បានសាបសូន្យ ចាកមើមខ្ទឹម យ៉ាងដូច្នោះដែរ ព្រោះភាពនៃខ្លួនជាអ្នកប្រាជ្ញាច្រើន, ព្រោះហេតុនោះ ចាប់តាំងអំពី ថ្ងៃនេះតទៅ នាងចូលនន្ទាភិក្ខុនី នឹងមិនបាន ដើម្បីធាន់ នូវមើម ខ្ទឹមបានឡើយ, ក៏សូម្បីនាងភិក្ខុនី ដែលសេសសល់ ទាំងឡាយ អាស្រ័យនាងចូលនន្ទាភិក្ខុនីនោះហើយ ក៏មិនអាចធាន់បាន ដូចជា នាងចូលនន្ទាភិក្ខុនីដែរ, ព្រោះហេតុនោះ ភិក្ខុសូម្បីបានច្រើនក៏គប្បី ស្គាល់ប្រមាណដោយពិត, តែបានតិច ក៏គប្បីធ្វើសេចក្ដីសន្ដោស ដោយបច្ច័យ តាមដែលខ្លួនបានហើយប៉ុណ្ណោះ, ភិក្ខុមិនត្រូវប្រាជ្ញា ឲ្យខ្ពស់ហួសឡើយ " ដូច្នេះហើយ ទើបទ្រង់ត្រាស់ នូវព្រះគាថានេះ ក្នុងសុវណ្ណហំសជាតក ក្នុងចុទ្ទសមវគ្គ ឯកនិបាត ថា ៖

> បុគ្គលបានទ្រព្យណាហើយ, បុគ្គលគប្បីត្រេកអរដោយទ្រព្យ នោះ, ព្រោះថា សេចក្ដីល្មោភហួស ជារបស់លាមក, (ដ្ឋិបជា នាងព្រាហ្មណី) ក៏សាបសូន្យ ចាកមាស ព្រោះចាប់រាងជាហង្ស ។

ពណ៌នាអំពីសេចក្ដីសន្ទោស

*បណ្ដាបទទាំងនោះ បទថា " **តុដ្ឌ្ពុ** " ប្រែថា គប្បីត្រេកអរ ។*

ក៏ព្រះដ៏មានព្រះភាគ លុះទ្រង់ត្រាស់ យ៉ាងដូច្នេះ ហើយ ទ្រង់បានបញ្ញត្ត នូវសិក្ខាបទ ថា " ក៏ភិក្ខុនី រូបណា គប្បីធាន់ខ្ជីម, ភិក្ខុនី រូបនោះ ត្រូវអាបត្តិបាចិត្តីយ៍ ។

រឿង នាងថ្ងូលនន្ទាភិក្ខុនី ចប់ ។

(៣២៧) សូម្បីរឿងត្នែចចក ដែលឃើញជ័រ មួយស្ងាប់ ហើយបានចូលទៅ ខាងក្នុងពោះ តាមទ្វារចូមគ្ត របស់ជ័រនោះ ដោយអំណាច នៃសេចក្ដីល្មោភច្រើន, កាលបើទ្វារមគ្ត បិទជិត ហើយ, ក៏មិនអាចចេញមកបានឡើយ ទើបនៅកើតទុក្ខ យ៉ាងយូរ ក្នុងពោះជ័រនោះ ថ្ងៃមួយ កាលបើភ្ជៀងធ្លាក់, ទ្វារមគ្តបើកហើយ, ទើបបានចេញទៅ កាន់អាសមបទ របស់តាបសមួយរូប ហើយ សមាទានអង្គនៃឧបោសថ ដើម្បីប្រយោជន៍ ដល់ការគ្របសង្កត់ នូវសេចក្ដីលោភ ហើយទើបដេក ក្នុងអដ្ឌកថាបញ្ចុបោសថជាតក ក៏គប្បីប្រមូលយកមក (សម្ដែងផងដែរ) ។

ពណ៌នាអំពីរឿងនៃភាពជាអ្នកប្រាថ្នាច្រើន ចប់ ។

(៣២៨) អដ្ឌកថារបស់ វិនីតសូត្រ និង ឯកនិបាត អង្គុត្ត-និកាយ ថា " ក៏ការៈ គឺការប្រកាសនូវគុណ ដែលមិនមាន និង

មន្តលត្ថនីបនីប្រែ

ភាពនៃបុគ្គលជាអ្នកមិនស្គាល់ទូវប្រមាណ ក្នុងការទទួល ឈ្មោះ ថា ភាពនៃបុគ្គលជាអ្នកមានសេចក្ដីប្រាថ្នាដ៏លាមក ។ **ចាបិច្ចតា** នោះ មកហើយ ក្នុងព្រះអភិធម្មនុ៎ះឯង ដោយនយ័ជាដើម ថា បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា បានគិតហើយ ថា សូមជនដ៏ឯនទូវអាត្មាអញ ថា ជាអ្នកមានសទ្ធា ដូច្នេះ ។ បុគ្គល អ្នកប្រកបព្រមហើយ ដោយភាពជាអ្នកប្រាថ្នា ដ៏លាមកនោះ រមែងតាំងនៅ ក្នុងភាពជាអ្នកបោកបញ្ឆោត ដោយពិត " ។

ដីកានៃវជិរ៉ាទីតសូត្រ និង ឯកនិបាត អង្គុត្តរនិកាយនោះ ថា " សេចក្ដីប្រាថ្នាដ៏អាក្រក់ គឺ ដ៏លាមក ដ៏ទាបថោក ព្រោះ ភាវ: គឺការប្រកាសគុណដែលមិនមាន ឈ្មោះថា **ចាបិច្ចតា** ។ កិរិយាប្រកាសគុណ ដែលមិនមាននៅ ក្នុងខ្លួន ធ្វើដូចជាមាននៅ ក្នុងខ្លួន ដល់ពួកជនដទៃ ឈ្មោះថា ភាពគឺការប្រកាសគុណ ដែល មិនមាន " ។

(៣២៩) ក៏ក្នុងពាក្យថា " ***អ**ស្ស**ទ្ធោ** **ស**មា**នោ*** " ដូច្នេះជា ដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖ " បុគ្គលណា ជាអ្នកមិន មានសទ្ធា រមែងសម្ដែងអាការ ដូចជាមានសទ្ធា, មិនមែនជាព្រះ ខីណាស្រព រមែងសម្ដែងអាការ ដូចជាព្រះខីណាស្រព, បុគ្គល នោះ ឈ្មោះថា ជាអ្នកមានសេចក្ដីប្រាថ្នាដ៏លាមក ។ រមែងសំដែង

ពណ៌នាអំពីសេចក្ដីសន្តោស

យ៉ាងដូចម្តេច? ។ គឺ ភិក្ខុអ្នកមិនមានសទ្ធា ក្នុងពេលដែលពួក មនុស្ស មកកាន់ព្រះវិហារ ក្នុងថ្ងៃឆ្ងព្រះវិហារ រមែងបោស នូវ ព្រះវិហារ ជាមុន ចោលសំរាម ដឹងថា មនុស្សទាំងនោះ យើញ ហើយ ក៏និមន្តទៅកាន់លានព្រះចេតិយ បោសសំអាត ចោល សំរាម កៀរដីខ្សាច់ឲ្យស្មើ លាងសេនាសនៈទាំងឡាយ ស្រោច ទឹកត្រង់ដើមពោធ៍ ។ ពួកមនុស្ស យើញភិក្ខុនោះហើយ គិតថា ភិក្ខុអ្នកថែរក្សាព្រះវិហារ រូបដទៃ យើញដូចជាមិនមាន, ព្រះថេរៈ អ្នកមានសទ្ធារូបនេះប៉ុណ្ណោះ រមែងថែរក្សាព្រះវិហារ ដូច្នេះហើយ ក្នុងពេលទៅវិញ និមន្តហើយ ទើបទៅ ។ ចំណែកភិក្ខុដែលមិន មែនជាព្រះខីណាស្រព យើញពួកក្មេងអ្នកស្រុកហើយ ក៏ស្ងរថា មាតាបិតា របស់ពួកអ្នកទាំងឡាយ តែងនិយាយ ដល់អាត្មា ថា ដូចម្តេចខ្ងះ? ដូច្នេះហើយ, កាលបើពួកក្មេងទាំងនោះ ពិតថេរដីកា ថា បពិត្រព្រះគុណម្ចាស់ ដ៏ចម្រើន មាតាបិតា របស់ពួកខ្ញុំព្រះ ករុណា តែងនិយាយថា ព្រះគុណម្ចាស់ ជាព្រះអរហន្ត ដូច្នេះ ហើយ, ទើបគិតថា ពួកគហបតីទាំងឡាយជាអ្នកឆ្ងាត ដរាបណា, អាត្មាអញ ក៏មិនអាច ដើមបោកបញ្ជោត ដរាបនោះ បានឡើយ ហើយ សម្តែងភាវៈនៃខ្លួនជាព្រះខីណាស្រព ។ ក៏ចំណែក ពួក បាបបុគ្គល ដទៃទៀត មានព្រះអរហន្តពាងទឹក និង ព្រះអរហន្ត

មន្តលត្ថនីបនីប្រែ

ពួរដ្រៃ ជាដើម ក៏គប្បីជ្រាប ក្នុងបាបិច្ចតានិទ្ទេសនេះ ។

(រឿង ព្រះអរហន្តពាងទឹក)

(៣៣០) បានញ្ចថា មនុស្សអ្នកកុហក ម្នាក់ កប់ពាងទឹក ទុក ខាងក្នុងបន្ទប់ ក្នុងពេលដែលពួកមនុស្សមក ក៏តែងចូលទៅ លាក់ខ្លួន ។ ពួកមនុស្ស បានសួរថា " ព្រះថេរ: និមន្តទៅទីណា ហើយ? " ដូច្នេះ, កាលបើពួកកូនសិស្សប្រាប់ថា " ព្រះថេរ: នៅ ខាងក្នុងបន្ទប់ " ដូច្នេះ, សូម្បីចូលទៅ ត្រូតពិនិត្យមើល ក៏មិន ឃើញហើយ ទើបចេញមកវិញ ។

ក្នុងខណ:នោះ មនុស្សកុហកនោះ បានចេញអំពីពាងទឹក មកហើយ អង្គុយ លើកៅអី ។ ពួកមនុស្សទាំងនោះ ពោលថា " ព្រះថេរ: មិនមាន " ដូច្នេះ, កាលបើពួកកូនសិស្ស ពោលថា " ព្រះថេរ: នៅខាងក្នុងបន្ទប់ន៉ុះឯង " ដូច្នេះ ទើបបានចូលទៅ ទៀត បានឃើញមនុស្សកុហកនោះហើយ ក៏សួរថា " បពិត្រព្រះ គុណម្ចាស់ដ៏ចម្រើន ក្នុងគ្រាដំបូង ឃើងខ្ញុំទាំងឡាយ មិនឃើញ ទើបបានចេញមកហើយ, តើព្រះគុណម្ចាស់ និមន្តទៅហើយ ក្នុង ទីឯណា? " ។ មនុស្សកុហកនោះ រមែងសម្តែង នូវភាពនៃខ្លួន ដូចជាព្រះអរហន្ត ដោយពាក្យថា "ធម្មតាពួកសមណ: រមែងទៅ កាន់ទីឋានដែលខ្លួនប្រាថ្នាហើយ ៗ " ។

រឿង ព្រះអរហន្តពាងទឹក ចប់ ។

ពណ៌នាអំពីសេចក្ដីសង្ហេស

(រឿង ព្រះអរហន្ដពួរជ្រៃ)

(៣៣១) មនុស្សកុហកម្នាក់ទៀត រស់នៅក្នុងបណ្ណសាលាក្បែរភ្នំមួយ ។ ដើមជ្រៃមួយដើម មាននៅ ខាងក្រោយ នៃបណ្ណ-សាលា របស់មនុស្សកុហកនោះឯង ។ ពួរនៃដើមជ្រៃនោះ បានជុះសំយុងទៅ ស្ថិតនៅ លើផែនដី ក្នុងកាលជាខាងក្រោយមក ។ មនុស្សទាំងឡាយ ទៅតាមផ្លូវនោះហើយ ក៏និមន្ដមនុស្សកុហកនោះ ។ មនុស្សកុហកនោះ កាន់ជាត្រ និង ចីវរហើយ ចុះមកតាមពួរជ្រៃហើយ សម្ដែងខ្លួន ក្បែរមាត់ទ្វារផ្ទះ ។

មនុស្សទាំងឡាយ មកហើយខាងក្រោយ សួរថា "បពិត្រ ព្រះគុណម្ចាស់ ដ៏ចម្រើន តើព្រះគុណម្ចាស់ និមន្ដមក តាមផ្លូវណាដែរ? " ។ មនុស្សកុហកនោះ សម្ដែងនូវការៈនៃខ្លួន ដូចជាព្រះខីណាស្រព ដោយពាក្យថា " ធម្មតា ផ្លូវមករបស់សមណៈទាំងឡាយ មិនត្រូវសួរឡើយ, សមណៈទាំងឡាយ តែងមកកាន់ទីហានដែលខ្លួនប្រាថ្នាហើយៗ ប៉ុណ្ណោះឯង " ។

គ្រានោះ ឧបាសក ម្នាក់ នៅចាំចាប់ បានឃើញមនុស្សកុហកនោះ កំពុងតែចុះមក តាមពួរជ្រៃ បានកាត់ (ពួរជ្រៃ) ពីខាងក្រោយ បន្សល់ទុក តែប្រមាណតិចតួច ។ មនុស្សកុហក មិនដឹងហេតុនោះ ក៏ចុះមកតាមពួរជ្រៃ បានជ្ជាប់ចុះហើយ ។ ជាត្រដី

បែកហើយ ។ មនុស្សកុហកនោះ គិតថា " អាត្មាអញ ត្រូវពួកមនុស្ស ដ៏ធំហើយ " ដូច្នេះហើយ ក៏បានរត់ចេញទៅហើយ ។

រឿង ព្រះអរហន្ត ពួរជ្រៃ ចប់ ។

ចំណែកឯសេចក្ដីពិស្តារ ក្នុងរឿងនេះ គប្បីកាន់យក អំពីអដ្ឋកថាខុទ្ទកវិភង្គ ។

ពណ៌នាអំពីរឿងភាពនៃបុគ្គលអ្នកប្រាថ្នាលាមក ចប់ ។

(៣៣២) ក្នុងអដ្ឋថាទាំងឡាយ ព្រះអដ្ឋកថាចារ្យ សម្ដែងសូម្បីភាពនៃបុគ្គលជាអ្នកមិនស្គាល់ប្រមាណ របស់ពួកភិក្ខុ អ្នកមានសេចក្ដីប្រាថ្នាដ៏លាមក និង អ្នកប្រាថ្នាច្រើន ដោយប្រការដូច្នេះ ។ មែនពិត ចាបបុគ្គលទាំងនោះ រមែងញ៉ាំងសេចក្ដីប្រាថ្នាដ៏លាមក និង សេចក្ដីប្រាថ្នាច្រើន ឲ្យកើតឡើង ព្រោះភាវៈ គឺការមិនស្គាល់ប្រមាណ ក្នុងការទទួល, ហេតុនោះ បុគ្គលអ្នកទទួលគប្បីជាអ្នកស្គាល់ប្រមាណ ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ ដល់ភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ ក្នុងបដិគ្គាហកសូត្រ ក្នុងតេរសមវគ្គ ឯកធម្មបាលី ក្នុងឯកនិបាតអង្គុត្តរនិកាយ ថា " ភិក្ខុ អ្នកទទួល គប្បីស្គាល់ប្រមាណ " ដូច្នេះ ។

អដ្ឋកថាបដិគ្គាហកសូត្រនោះ ថា " បណ្ដាបទទាំងនោះ ២ បទថា ***មត្តា ជានិតព្វា*** *មានសេចក្ដីថា បុគ្គល អ្នកទទួល គប្បី*

ពណ៌នាអំពីសេចក្តីសន្តោស

ស្គាល់ប្រមាណ ។ គប្បីស្គាល់ យ៉ាងដូចម្តេច? ។ មែនពិត បុគ្គលអ្នកទទួលនោះ គប្បីដឹងអំណាចនៃទាយក គប្បីដឹងអំណាចនៃទេយ្យធម៌ គប្បីដឹងកម្ចាំង របស់ខ្ជួន " ។

ដីកាបដិគ្គាហកសូត្រនោះថា " អធ្យាស្រ័យ ដែលផ្សេងគ្នាដោយការទូលំទូលាយ និង មិនទូលំទូលាយ ឈ្មោះថា អំណាចនៃទាយក ។ ភាវៈនៃវត្ថុមានតិច ឬ ច្រើនន៉ុះឯង ឈ្មោះថា អំណាចនៃទេយ្យធម៌ ។ ប្រមាណដែលល្មមគ្រាន់តែញ្ចាំងអត្តភាពឲ្យប្រព្រឹត្តទៅ ឈ្មោះថា កម្ចាំងរបស់ខ្ជួន " ។

(៣៣៣) ក៏បុគ្គលណា ស្គាល់នូវប្រមាណ, បុគ្គលនោះ ឈ្មោះថា ជាអ្នកប្រាថ្នាតិច ក្នុងបច្ច័យ បណ្តាបុគ្គលអ្នកប្រាថ្នាតិច ៤ ពួក នេះ គឺ អ្នកប្រាថ្នាតិច ក្នុងបច្ច័យ ១ អ្នកប្រាថ្នាតិច ក្នុងធុតង្គ ១ អ្នកប្រាថ្នាតិច ក្នុងព្រះបរិយត្តិ ១ អ្នកប្រាថ្នាតិច ក្នុងមគ្គ និង ផល ដែលខ្ជួនសម្រេច ១ ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងព្រះអដ្ឋកថាអប្បិច្ឆតាសូត្រ ក្នុងវគ្គ ទី៧ ក្នុងឯកនិបាត អង្គុត្តរនិកាយ និង ក្នុងអដ្ឋកថារថវិនីត-សូត្រ ថា " បុគ្គល អ្នកមានសេចក្តីប្រាថ្នាតិច ក្នុងបច្ច័យទាំង ៤ ឈ្មោះថា អ្នកមានសេចក្តីប្រាថ្នាតិច ក្នុងបច្ច័យ ។ បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងបច្ច័យនោះ រមែងដឹង នូវអំណាចនៃទាយក

មន្ទលត្ថទីបនីប្រែ

រមែងដឹងនូវអំណាំចនៃទេយ្យធម៌ រមែងដឹងនូវកម្ចាំង របស់ខ្ជូន ។ ក៏ប្រសិនបើទេយ្យធម៌មានច្រើន, ទាយក ជាអ្នកមានបំណងចង់ ប្រគេនតែបន្តិចបន្តួច, ភិក្ខុទទួលតែបន្តិចបន្តួច ដោយអំណាច នៃ ទាយក ។ ទេយ្យធម៌ មានបន្តិចបន្តួច, ទាយក មានបំណងចង់ ប្រគេនច្រើន, ភិក្ខុ ទទួលតែបន្តិចបន្តួច ដោយអំណាចនៃទេយ្យ-ធម៌ ។ សូម្បីទេយ្យធម៌ មានច្រើន, ទាំងទាយក ក៏ជាអ្នកមាន បំណងចង់ប្រគេនច្រើន, ភិក្ខុនោះ ដឹងនូវកម្ចាំងរបស់ខ្ជូន ហើយ ទទួលយក តែល្មមប្រមាណប៉ុណ្ណោះ " ។

អដ្ឋកថាទសុត្តរសូត្រ ក្នុងបាដិកវគ្គ ថា " ភិក្ខុ អ្នកប្រាថ្នា តិច ក្នុងបច្ចយ, កាលបើទាយក ប្រគេនច្រើន, រមែងទទួលយក តែបន្តិចបន្តួច, កាលបើទាយក ប្រគេនបន្តិចបន្តួច, រមែងទទួល យកតែបន្តិចបន្តួចចុះមក ឬក៏ មិនទទួលយកឡើយ, មិនមែនជា អ្នកទទួលយក ដោយមិនមានសេសល់ឡើយ " ។

(៣៣៦) អដ្ឋកថាបដិគ្គាហកសូត្រ ថា " មែនពិត ភិក្ខុអ្នក ស្គាល់នូវប្រមាណហើយ ទទួលយក ដោយអាការ យ៉ាងដូច្នោះ ឈ្មោះថា រមែងបំពេញអប្បិច្ឆបដិបទា ។ លាភដែលមិនទាន់កើត ឡើង រមែងកើតឡើង ដល់ភិក្ខុនោះ, លាភដែលកើតឡើងហើយ រមែងស្ថិតនៅគង់វង្ស, ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាហើយ

ពណ៌នាអំពីសេចក្តីសន្តោស

រមែងជ្រះថ្លា, ជនទាំងឡាយ ដែលជ្រះថ្លាហើយ រមែងដល់ នូវ សេចក្តីជ្រះថ្លា ច្រើនឡើងទៀត, ភិក្ខុរូបនោះ រមែងដូចជាកែវភ្នែក របស់មហាជន, រមែងធ្វើនូវព្រះសាសនា ឲ្យស្ថិតនៅ បានជាយូរ អង្វែង ថែមទៀតផង ។

ក្នុងជំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(៣៣៥) បានញ្ញថា ក្នុងរោហនជនបទ ភិក្ខុកំលោះ មួយរូប ក្នុងកុឡុម្ពរិយវិហារ ក្នុងសម័យដែលភិក្ខារកបានដោយកម្រ បាន នូវបាយមួយវែក ដើម្បីប្រយោជន៍ ដល់ការឆាន់ ក្នុងផ្ទះរបស់ កុលបុត្រម្នាក់ ឈ្មោះ លម្ពកណ្ណក: ក្នុងស្រុកនោះ និង បាននូវ បាយមួយវែក ប៉ុណ្ណោះ ដើម្បីត្រូវការចង់កាន់យកទៅ ។ ថ្ងៃមួយ ភិក្ខុរូបនោះ ឃើញភិក្ខុអាគន្តុក:មួយរូប ក្នុងផ្ទះនោះ ក៏បានទទួល យកបាយតែមួយវែកប៉ុណ្ណោះ ។ លំដាប់នោះ កុលបុត្រនោះ បាន ជ្រះថ្លា ចំពោះភិក្ខុរូបនោះ ព្រោះហេតុនោះហើយ ទើបបានប្រាប់ ដល់មិត្រ និង អាមាត្យទាំងឡាយ ក្នុងមាត់ទ្វារនៃព្រះរាជវាំង ថា "ព្រះគុណម្ចាស់ ដ៏ចម្រើន ដែលចូលទៅ កាន់ត្រកូល របស់ពួក យើងខ្ញុំ មានព្រះនាមយ៉ាងនេះ" ។ ពួកមិត្រ និង អាមាត្យទាំង ពួងនោះ ជ្រះថ្លា ក្នុងអប្បិច្ឆគុណ របស់ភិក្ខុរូបនោះ ហើយក៏បាន តាំងភត្ត ជាប្រចាំ ៦០ សម្រាប់ ដោយពេលមួយថ្ងៃតែប៉ុណ្ណោះ ។

មន្តលត្ថទីបនីប្រែ

ភិក្ខុ អ្នកមានសេចក្តីប្រាថ្នាតិច រមែងញ្ញាំងលាភ ដែលមិនទាន់ កើតឡើងហើយ ឲ្យកើតឡើង ដោយប្រការដូច្នេះឯង ។

(៣៣៦) ក៏ព្រះបាទសទ្ធាតិស្សមហារាជ ទ្រង់បានសាក ល្បងមើលនូវតិស្សអាមាត្យ ដែលជាចូឡុបដ្ឋាក ទ្រង់ត្រាស់បញ្ជា ឲ្យតិស្សអាមាត្យនោះ អាំងនូវសត្ងទទា មួយហើយ ទ្រង់ត្រាស់ បញ្ជា ឲ្យនាំយកមក ។ ត្រានោះ ក្នុងពេលស្ងាយ ព្រះអង្គទ្រង់ ព្រះតម្រិះ ថា អាត្មាអញ នឹងឲ្យចំណែកដ៏ល្អហើយ ទើបសោយ ហើយ ទ្រង់ប្រគេនសាច់ទទា ដល់សាមណេរ ក្នុងបរិវេណនៃ កណ្ឌកសលវិហារ, កាលបើសាមណេររូបនោះ ទទួលតែបន្តិច ប៉ុណ្ណោះ, ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងគុណនៃការប្រាថ្នាតិច របស់ សាមណេរនោះហើយ ទ្រង់ត្រាស់ថា បពិត្រសាមណេរ ខ្ញុំព្រះ ករុណា មានចិត្តជ្រះថ្លាហើយ ខ្ញុំព្រះករុណា នឹងប្រគេននូវភត្ត ជា ប្រចាំ ៨ សម្រាប់ដល់សាមណេរ ។

សាមណេរ. បពិត្រព្រះមហារាជ អាត្មាភាព សូមប្រគេន ដល់ព្រះឧបជ្ឈាយ៍ ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនភត្តជាប្រចាំ ដទៃទៀត ៨ សម្រាប់ ។

សាមណេរ. អាត្មាភាព សូមប្រគេនភត្តទាំងនោះ ដល់ព្រះ

ពណ៌នាអំពីសេចក្តីសន្តោស

អាចារ្យ ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនកត្ត ៨ សម្រាប់ទៀត ។

សាមណេរ. អាត្មាភាព សូមប្រគេនកត្តទាំងនោះ ដល់ពួកសហធម្មិក អ្នករួមព្រះឧបជ្ឈាយ៍ជាមួយគ្នា ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនកត្ត ៨ សម្រាប់ទៀត ។

សាមណេរ. អាត្មាភាព ប្រគេនកត្តទាំងនោះ ដល់ព្រះកិក្ខុសង្ឆ ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនកត្ត ៨ សម្រាប់ទៀត ។

សាមណេរ ទទួលយកហើយ ។ លាក ដែលកើតឡើងហើយ ដល់សាមណេរ អ្នកមានសេចក្តីប្រាថ្នាតិចនោះ រមែងជាលាកស្ថិតស្ថេរគង់វង្ស យ៉ាងដូច្នេះឯង ។

(៣៣៧) បានញ្ញថា ទីយព្រាហ្មណ៍ អញ្ជើញព្រាហ្មណ៍ទាំងឡាយមកបរិភោគ បានឲ្យកត្ត ម្នាក់ៗ ៥ ផ្តឹល ក៏មិនអាច ដើម្បីនឹងឲ្យព្រាហ្មណ៍ទាំងនោះ ឆ្អែតឆ្អន់បានឡើយ ។

ថ្ងៃមួយ ព្រាហ្មណ៍នោះ បានដឹងរឿងរ៉ាវថា បានញ្ញមកថាធម្មតាសមណៈទាំងឡាយ ជាអ្នកមានសេចក្តីប្រាថ្នាតិច ដូច្នេះ ដើម្បីនឹងសាកល្បងមើល ទើបបានឲ្យមនុស្សនាំយកកត្ត ទៅកាន់ព្រះវិហារ ក្នុងពេលដែលព្រះកិក្ខុសង្ឆ ធ្វើកត្តកិច្ចហើយ ក៏បាន

មន្ថលត្ថទីបនីប្រែ

យើញភិក្ខុទាំងឡាយ ប្រមាណ ៣០ រូប កំពុងតែធាន់ ក្នុងសាលាសម្រាប់ធាន់ ក៏បានកាន់យកភត្តមួយផ្តឹល ដើរទៅកាន់សំណាក់នៃព្រះសង្ឆត្ថេរ ។ ព្រះថេរ: បានញ្ចាំងម្រាមដៃ ឲ្យកម្រើកហើយ ចាប់យកតែបន្តិចប៉ុណ្ណោះ ។ ដោយទំនងនេះឯង ភត្តមួយផ្តឹល បានដល់ទៅភិក្ខុទាំងឡាយ គ្រប់អង្គហើយ ។

លំដាប់នោះ ព្រាហ្មណ៍គិតថា បានញ្ចថា សមណ:ទាំងនេះមានគុណ ពិតមែនតែម្តង ដូច្នេះហើយ ជ្រះថ្លា ក្នុងភាពជាអ្នកមានសេចក្តីប្រាថ្នាតិច បានលះបង់ទ្រព្យ ១ ពាន់ ឲ្យកសាងព្រះចេតិយ ក្នុងព្រះវិហារនោះឯងហើយ ។ ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាហើយ រមែងជ្រះថ្លា ដោយប្រការដូច្នេះ ។

(៣៣៨) កិច្ចដោយរឿង (ដែលសំដែងជាឧទាហរណ៍) ក្នុងពាក្យនេះថា ***បសន្នា ភិយ្យោ បសាទមាបជ្ជន្តិ*** *មិនមាន ។ ក៏សេចក្តីជ្រះថ្លា រមែងចំរើន ដោយក្រៃលែង ដល់ពួកជនអ្នកដែលជ្រះថ្លាហើយ ដោយពិត ព្រោះយើញភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ។ ក៏មហាជន យើញភិក្ខុទាំងឡាយ អ្នកមានសេចក្តីប្រាថ្នាតិច ដូចជាព្រះមជ្ឈន្តិកត្ថេរ ជាដើមហើយ រមែងសម្ពាល់ ដើម្បីកើតជាអ្នកមានសេចក្តីប្រាថ្នាតិច ព្រោះហេតុនោះ ភិក្ខុអ្នកប្រាថ្នាតិចឈ្មោះថា ជាអ្នកប្រៀបបាននឹងកែវភ្នែកនៃមហាជន ។*

ពណ៌នាអំពីសេចក្តីសន្តោស

(៣៣៩) មួយទៀត ភិក្ខុ អ្នកមានសេចក្តីប្រាថ្នាតិច ឈ្មោះ ថា ធ្វើព្រះសាសនា ឲ្យស្ថិតនៅយូរអង្វែងបាន ព្រោះព្រះតម្រាស់ ថា ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច រមែង ប្រព្រឹត្តទៅ ដើម្បីស្ថិតនៅគង់វង្ស ដើម្បីមិនសាបសូន្យ ដើម្បី មិនអន្តរធានទៅ នៃព្រះសទ្ធម្ម ដូច្នេះ " ។

(៣៤០) ដីកានៃបដិគ្គាហកសូត្រនោះ ថា " បទថា **អនុ-ប្បន្នស្ស** មានសេចក្តីថា លាភដែលមិនទាន់បានកើតឡើង រមែង កើតឡើង ដល់បុគ្គលនោះ ។ ២ បទថា **ចក្ខុភូតោ ហោតិ** មាន សេចក្តីថា រមែងដូចជាកែវភ្នែករបស់មហាជន ។ បទថា **ចិរដ្ឋិតិកំ** មានសេចក្តីថា រមែងធ្វើនូវព្រះសាសនា ឲ្យស្ថិតនៅ យូរអង្វែង បាន ដោយការញ្ចាំញលាភ ដែលមិនទាន់បានកើតឡើង ឲ្យកើត ឡើង និង ដោយការញ្ចាំងសេចក្តីជ្រះថ្លា ឲ្យកើតឡើង ដល់ មហាជន ។ បទថា **កុឡុម្ពរិយវិហារេ** គឺ ក្នុងព្រះវិហារ ដែល អាស្រ័យនៅជិតស្រុកឈ្មោះ កុឡុម្ពរិយៈ ។ បទថា **កុញ្ជានត្ថាយ** មានសេចក្តីថា ដើម្បីប្រយោជន៍ ដល់ការគង់ឆាន់ ក្នុងផ្ទះនោះឯង ។ ២ បទថា **គហេត្វា គមនត្ថាយ** មានសេចក្តីថា ដើម្បីប្រយោជន៍ ដល់ការទទួលយកទៅ ព្ធដ៏ខាងក្រៅនៃផ្ទះ ។ បទថា **ធុវភត្តានិ** បានដល់ ភត្ត ជាប្រចាំ ។ បទថា **ចូឡុបដ្ឋាកំ** គឺ អ្នកធ្វើការខ្ងល់

មង្គលត្ថទីបនីប្រែ

ខ្វាយ ។ ២ បទថា **អប្ឆិច្ចោ ភវិតុំ** មានសេចក្តីថា មហាជន រមែងសម្គាល់ ដើម្បីកើត ជាអ្នកមានសេចក្តីប្រាថ្នាតិចខ្ជិនឯង ដោយការដល់នូវកិរិយាប្រព្រឹត្តិទៅ តាមសេចក្តីយល់ឃើញ " ។

(៣៤១) ចាលីនៃអប្ឆិច្ចតាសូត្រ មាននៅ ក្នុងទសមវគ្គ នៃឯកនិបាត អង្គុត្តរនិកាយ យ៉ាងនេះ ថា " ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច រមែងប្រព្រឹត្តទៅ ដើម្បីការស្ថិតនៅ យូរអង្វែង នៃព្រះសទ្ធម្ម " ដូច្នេះជាដើម ។

ព្រោះហេតុនោះ ភិក្ខុ អ្នកមានបំណង ដើម្បីការស្ថិតនៅ ជាយូរអង្វែង នៃព្រះសាសនា គប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ដូចជាព្រះនិគមគ្គាវសីតិស្សត្ថេរ និង កណ្ហតាបស ដូច្នេះឯង ។

(រឿង ព្រះតិស្សត្ថេរ)

(៣៤២) ចានញ្ចថា ព្រះតិស្សត្ថេរ ជាកុលបុត្រ ក្នុងស្រុកនិគម មិនឆ្ងាយអំពីក្រុងសាវត្ថី លុះបព្វជ្ជាហើយ ជាអ្នកមានសេចក្តីប្រាថ្នាតិច សន្តោស និមន្តទៅបិណ្ឌបាត ជាប្រចាំ តែក្នុងផ្ទះនៃពួកញាតិប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយ ពោលថា "ព្រះតិស្សត្ថេរ នោះ នៅច្រឡូកច្រឡំ ដោយក្រុមញាតិ, កាលបើទាយកទាំងឡាយ មានអនាថបិណ្ឌិកសេដ្ឋី ជាដើម ថ្វាយមហាទានក្តី, កាល

ពណ៌នាអំពីសេចក្តីសន្តោស

បើព្រះបាទបសេនទិកោសល ទ្រង់ថ្វាយអសទិសទានក្តី, ក៏លោកមិននិមន្តមកកាន់ក្រុងសាវត្ថី ទ្បើយ " ហើយ ក៏បានក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់មានព្រះបំណងនឹងប្រទាន នូវសាធុការពរដល់ព្រះថេររនោះ ទ្រង់ត្រាស់ឲ្យហៅព្រះថេរៈនោះមកហើយ ទើបទ្រង់ត្រាស់សួរ ។ ព្រះថេរៈ បានក្រាបទូល ថា " ខ្ញុំព្រះករុណាមិនបានមកហើយ ដោយនឹកគិតថា អាត្មាអញអាស្រ័យពួកញាតិទាំងនេះហើយ រមែងបាន នូវអាហារ ល្មមគួរនឹងទំពាលេបបាន, កាលបើអាត្មាអញ បានអាហារល្មមគ្រាន់ញុាំងអត្តភាព ឲ្យប្រព្រឹត្តទៅហើយ, នឹងមានប្រយោជន៍អ្វី ដោយការទៅស្វែងរកនូវអាហារមកទៀត ដូច្នេះ " ។

*ព្រះសាស្តា ទ្រង់ត្រាស់ថា "ប្រពៃណាស់ៗ" ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ភាពជាអ្នកមានសេចក្តីប្រាថ្នាតិចនេះ ជាបែបផែន ជាប្រពៃណី របស់តថាគត " ហើយសំដែងចូឡសុវកជាតក ទ្រង់ត្រាស់ថា " ធម្មតា ភិក្ខុ គប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ដូចជាព្រះនិគមគ្គាមវាសីតិស្សៈ ដូច្នោះឯង" ហើយ ទ្រង់ត្រាស់ នូវព្រះគាថា ក្នុងអប្បមាទវគ្គ នៃព្រះធម្មបទ ថា " **អប្បមាទរតោ ភិក្ខុ** " ដូច្នេះជាដើម ។*

មង្គលត្ថទីបនីប្រែ

ក្នុងទីបញ្ចប់នៃព្រះគាថា ព្រះតិស្សត្ថេរ បានសម្រេចហើយ នូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

(រឿង កណ្ណតាបស)

(៣៤៣) ចំណែក កណ្ណតាបស ធ្វើដើមតាសក់ក្អែកមួយ ក្នុងហេមវន្តប្រទេស ឲ្យជាទីគោចរគ្រាម មិនបានកសាងបណ្ណ-សាលា បាននៅហើយ ក្បែរគល់ឈើនោះឯង ។ តាបសរូបនោះ ជាអ្នកមានសេចក្តីជ្រាជ្ញាតិចក្រៃលែង អាស្រ័យនៅ តែក្នុងទីនោះ ប៉ុណ្ណោះ មិននិមន្តទៅ ក្នុងទីដទៃទៀត ដើម្បីផលាផលឡើយ ក្នុងពេលដែលដើមឈើមានផ្លែ ក៏ឆាន់នូវផ្លែ ក្នុងពេលដែលដើមឈើ ចេញផ្កា ក៏ឆាន់ផ្កា ក្នុងពេលដែលដើមឈើ លាស់សន្ទ្ធីក ក៏ឆាន់សន្ទ្ធីក ក្នុងពេលដែលដើមឈើ ចេញក្រមរ ក៏ឆាន់ក្រមរ ។

ក្នុងថ្ងៃមួយ តាបសនោះ កាលនឹងបេះយកផ្លែទាំងឡាយ នៃដើមឈើនោះ មិនបានក្រោកឡើងបេះយក ក្នុងប្រទេសដទៃ ដោយកិរិយាប្រព្រឹត្តិលោកលន់ គង់នៅតាមដើមនុ៎ះឯង បានលាតដៃទៅ បេះយកផ្លែឈើ ដែលស្ថិត ក្នុងទីប្រមាណ ១ ហត្ថ មិនបានរើស ថា ជាទីពេញចិត្ត ឬ មិនពេញចិត្ត សូម្បីក្នុងផ្លែឈើទាំងនោះឡើយ ហើយចាប់យកតែផ្លែ ដែលមកដល់ប៉ុណ្ណោះ ។ ដោយតេជនៃសីល របស់តាបសអ្នកសន្ធ្ធាសជ្ជ ខ្ជ ខ្ជ (យ៉ាង

ពណ៌នាអំពីសេចក្តីសន្តោស

ដូច្នេះនោះ អាសនៈ របស់ស្តេចសក្កទេវរាជ បានកើតក្តៅហើយ ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ស្តេចយាងមក ក្នុងទីនោះ ទ្រង់ជ្រះថ្លាហើយ បានប្រទានពរ ដល់តាបសនោះ ទ្រង់បានធ្វើដើមឈើនោះ ឲ្យមានផល ជាប់ជានិច្ច មានរសជាតិផ្អែមហើយទ្រង់ស្តេចយាងទៅកាន់ទីស្ថានរបស់ព្រះអង្ត ដូចដើមវិញ ។

រឿងកណ្ហតាបស មកក្នុងកណ្ហជាតក ក្នុងទសកនិបាត ។

រឿង អ្នកប្រាថ្នាតិច ក្នុងបច្ច័យ ចប់ ។

(៣៤៤) អដ្ឋកថាទសុត្តរសូត្រថា " ភិក្ខុ អ្នកមានសេចក្តីប្រាថ្នាតិច ក្នុងធុតង្ត រមែងមិនឲ្យពួកជនដទៃដឹង ថា ខ្ជូន ជាអ្នករក្សាធុតង្តឡើយ ដូចជាព្រះថេរៈ ដែលជាបង បណ្តាព្រះថេរៈដែលត្រូវជាបងប្អូននឹងគ្នា ២ រូប យ៉ាងដូច្នេះឯង " ។

(រឿង ព្រះថេរៈ ២ រូប បងប្អូននឹងគ្នា)

ព្រះថេរៈ បងប្អូនគ្នា ២ រូប នៅហើយក្នុងចេតិយបព៌ត ។ ព្រះថេរៈ ជាប្អូន កាន់យកបាច់អំពៅ ដែលឧបដ្ឋាកបានផ្ញើទៅប្រគេនហើយ ក៏បាននិមន្តទៅសំណាក់ របស់ព្រះថេរៈ ដែលជាបង ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ធ្វើនូវការធាន់ចុះ" ។ ក៏រៀលានោះ គឺ ជាវេលាដែលព្រះថេរៈ ធ្វើភត្តកិច្ច ខ្ពុរមាត់ស្រេចហើយ ។ ព្រះថេរៈនោះ ពោលហើយ ថា

មន្ទលត្ថទីបនីប្រែ

ម្នាលអ្នកដ៏មានអាយុ គ្រប់គ្រាន់ហើយ " ។ ព្រះថេរ: ដែលជាប្អូនបានសួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន តើព្រះគុណម្ចាស់ជាអ្នករក្សាធុតង្ត នៃបុគ្គលអ្នកធាន់ ក្នុងអាសន: តែមួយឬ? " ។ ព្រះថេរ: ពោលថា "ម្នាលអ្នកដ៏មានអាយុ អ្នក ចូរនាំយកបាច់អំពៅមកចុះ" ដូច្នេះ សូម្បីជាអ្នករក្សាឯកាសនិកធុតង្ត អស់រយ: ពេល ៥០ ឆ្នាំ ក៏បិទបាំង នូវអង្គនៃធុតង្ត ធ្វើការធាន់ហើយ ទើបអធិដ្ឋានអង្គនៃធុតង្គស្រេចហើយ ក៏បាននិមន្តទៅ ។

រឿងព្រះថេរ: ជាបងប្អូននឹងគ្នា ២ រូប មកក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ និង រថវិនីតសូត្រ ។

រឿងព្រះមហាកុមារកស្សបត្ថេរ អ្នករក្សាធុតង្ត គឺ កិរិយានៅក្នុងទីប៉ាធាជាវត្ត ក៏គួរត្រួតមើល ក្នុងអដ្ឋកថាទាំងឡាយនោះ ។

រឿង ភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងធុតង្ត ចប់ ។

(៣៤៥) អដ្ឋកថាទសុត្តរសូត្រ ថា " ភិក្ខុ អ្នកមានសេចក្តីប្រាថ្នាតិច ក្នុងព្រះបរិយត្តិ សូម្បីជាអ្នកចេះព្រះត្រៃបិដក ក៏មិនប្រាថ្នាចង់ឲ្យអ្នកណាមួយដឹង ថា ខ្ជួនជាពហុស្សូតដែរ ដូចជាព្រះតិស្សត្ថេរ ដែលអាស្រ័យនៅ ក្នុងទីក្រុងសាកេត ដូច្នោះឯង" ។

អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយជាដើម ថា " បានញ្ចមកថាព្រះថេរ: គិតថា ខណ: មិនមាន យ៉ាងដូច្នេះ មិនបានធ្វើនូវឧទ្ទេស

ពណ៌នាអំពីសេចក្តីសន្តោស

និង បរិបុច្ឆា ត្រូវពួកសិស្សដាស់តឿនថា បពិត្រព្រះគុណម្ចាស់ ដ៏ចំរើន ព្រះគុណម្ចាស់ នឹងបាននូវខណៈជាទីមរណភាព នៅ ពេលណា? ដូច្នេះហើយ ទើបបានលះបង់ចោល នូវពួកគណៈ ហើយ និមន្តទៅកាន់ព្រះវិហារ ក្បែរមាត់សមុទ្រដែលមានដីខ្សាច់ ដូចផ្តាកណ្ណការ ជាអ្នកមានឧបការៈ ដល់ភិក្ខុជាព្រះថេរៈ ជាអ្នក ទើបនឹងបួសថ្មី និង ជាកណ្តាល ក្នុងព្រះវិហារនោះ រហូតខាងក្នុង រដូវវស្សា ក្នុងថ្ងៃឧបោសថ ក្នុងថ្ងៃមហាបវរណា បានញ្ចាំងអ្នក ជនបទ ឲ្យរំជើបរំជួលហើយ ដោយធម្មកថា ទើបបាននិមន្តទៅ ហើយ " ។

ដីកានៃឯកនិបាត អង្គុត្តរនិកាយជាដើមនោះថា " ២ បទ ថា ***ឧបការោ ហុត្វា*** *មានសេចក្តីថា ជាអ្នកមានឧបការៈ ដោយ ការរៀននិងការសាកសួរជាដើម ដោយអំណាចព្រះបរិយត្តិធម៌ ។ ២ បទថា* ***ជនបទំ ខោភេត្វា*** *មានសេចក្តីថា ញ្ចាំងមហាជនដែល ប្រជុំគ្នាហើយ ឲ្យរំជើបរំជួលហើយ ដោយអំណាចការធ្វើឲ្យព្រឹ រោម ការឲ្យនូវសាធុការពរ និង ការលើកឡើងនូវកំណាត់សំពត់ ជាដើម និង ញ្ចាំងមហាជនដទៃទៀត ឲ្យរំជើបរំជួលហើយ ដោយ អំណាចនៃសេចក្តីកោលាហល ថា ធ្វើដូចម្តេចទៅហ្នឹ? អាត្មាអញ នឹងបានស្តាប់ធម៌ ក្នុងសំណាក់ព្រះគុណម្ចាស់ដ៏ចំរើន ។ ប្រសិនបើ*

មន្តលត្ថទីបនីប្រែ

ព្រះថេរ: គប្បីប្រាថ្នា ដើម្បីនឹងញ្ជាំងអ្នកជនបទ ឲ្យដឹងថា ខ្ជូន លោកជាពហុស្សូត, ព្រះថេរ: ក៏គប្បីញ្ជាំងអ្នកជនបទ ឲ្យរំដើបរំជួល សំដែងធម៌ ក្នុងពេលខាងដើមតែម្តង ។ បទថា **គតោ** មានសេចក្តីថា ព្រះថេរ: និមន្តទៅហើយ មុនព្រះអរុណរះឡើងតែម្តង ព្រោះភាវ:ជាអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងព្រះបរិយត្តិ ដោយ ភាវ:គឺការខ្វាចក្រែងមហាជនដឹងថា ធម្មកថា គឺព្រះថេរ:ណា ធ្វើហើយ ក្នុងរាត្រី, ព្រះថេរ: រូបនោះ គឺព្រះថេរ:នេះឯង ។

រឿង ភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងព្រះបរិយត្តិ ចប់ ។

(៣៤៦) អដ្ឋកថាទសុត្តរសូត្រ ថា " ភិក្ខុ អ្នកមានសេចក្តីប្រាថ្នាតិច ក្នុងកិរិយាត្រាស់ដឹង រមែងមិនឲ្យពួកជនដទៃដឹងបានថា ខ្ជូនបានសម្រេចមគ្គផលឡើយ ដូចជាព្រះមជ្ឈន្តិកត្ថេរ យ៉ាងដូច្នោះឯង " ។

អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយជាដើមថា " បានព្ចមកថា ព្រះថេរ: បានជាព្រះមហាខីណស្រព ។ ក៏បាត្រ និង ចីវរ របស់ព្រះថេរ:នោះ មានតម្លៃប្រមាណ ១ បាទប៉ុណ្ណោះ ។ ព្រះថេរ: នោះ បានជាព្រះសង្ឈត្ថេរ ក្នុងថ្ងៃឆ្ងន្ធព្រះវិហារ របស់ព្រះបាទអសោកធម្មរាជា ។ ពេលនោះ មនុស្សទាំងឡាយ ឃើញនូវភាពនៃព្រះថេរ:នោះ ជាអ្នកសៅហ្មងក្រៃពេក ទើបបានពោល ថា

ពណ៌នាអំពីសេចក្តីសន្តោស

បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ នៅចាំ ឰដ៏ខាងក្រៅបន្ទិចសិនចុះ ។ ព្រះថេរៈ គិតថា កាលបើព្រះវីណាស្រេព អ្នកប្រាកដដូចជាអាត្មាអញ ធ្វើនូវសេចក្តីសង្គ្រោះ ដល់ព្រះរាជា, ព្រះថេរៈដទៃទៀត រូបណាទៅហ្ន៎ នឹងធ្វើបាន? ដូច្នេះហើយ ទើបមុជចូលទៅ ក្នុងផែនដី ហើយបានងើបផុសឡើង ទទួលយកដុំបាយ ដែលព្រះរាជា ទ្រង់លើកប្រគេនព្រះសង្ឃត្ថេរនុ៎ះឯង ” ។

ដីកានៃឯកនិបាត អង្គុត្តរនិកាយ ជាដើមនោះថា “ បទថា ***អតិលូខភាវំ*** *មានសេចក្តីថា មនុស្សទាំងឡាយ បានឃើញនូវកាពសៅហ្មងដ៏ក្រៃលែង ដោយអំណាចនៃបាត្រ និង ចីពរហើយ គិតថា ថ្ងៃនេះ គឺ ជាថ្ងៃមង្គល, ព្រះរាជា គប្បីធ្វើព្រះគុណម្ចាស់ដ៏ចំរើន ជាអ្នកមានបាត្រ និង ចីពរដែលបានរៀបចំល្អប្រសើរហើយ ឲ្យជាប្រធាន ហើយពោលថា បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ គង់រង់ចាំនៅ ខាងក្រៅ បន្តិចសិនចុះ ។ បទថា* ***និម្មុជ្ជិត្វា*** *បានដល់ កាលបើពួកមនុស្ស មិនដឹងនុ៎ះឯង, ព្រះថេរៈ បានមុជចូលក្នុងផែនដីហើយងើបផុសឡើងទទួលភ្លាម ។ ប្រសិនបើព្រះថេរៈ គប្បីប្រាថ្នាថា សូមឲ្យមនុស្សទាំងឡាយដឹងថា អាត្មាអញ ជាព្រះវីណាស្រេព ដូច្នេះ, មនុស្សទាំងឡាយ ក៏មិនគប្បីពោល នឹងព្រះថេរៈនោះថា សូមព្រះគុណម្ចាស់ នៅចាំខាងក្រៅ*

មន្តលត្ថទីបនីប្រែ

សិនចុះ ដូច្នេះ ។ ប៉ុន្តែសេចក្តីគិត យ៉ាងដូច្នោះឯង មិនគប្បីកើត ឡើង ដល់ព្រះខីណាស្រពទាំងឡាយឡើយ " ។

រឿង ភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងអធិគម ចប់ ។

(៣៤៧) ក៏ភិក្ខុទាំងឡាយទាំងពួងនោះ លោកហៅថា " ជាអ្នកមានសេចក្តីប្រាថ្នាតិច" ព្រោះមិនមានសេចក្តីប្រាថ្នា ក្នុងបច្ចយទាំងឡាយជាដើម ។ ក៏ **អប្ប** សព្ទ ក្នុងបទថា " **អប្បិច្ឆា** " នេះ ជាសេចក្តីនៃ **អភាវ:** ។

ដោយហេតុនោះ ក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ទើបលោកពោល ថា " បទថា **អប្បិច្ឆស្ស** ប្រែថា ជាអ្នកមិនមានសេចក្តីប្រាថ្នា ។ ក៏ក្នុងបទថា **អប្បិច្ឆស្ស** នេះ ព្យញ្ជន: ប្រៀបដូចជាមាននៅសេសសស់, ចំណែកសេចក្តី មិនមាននៅសេសសល់ឡើយ ។ ពិតមែន ព្រះខីណាស្រពនោះ ព្រះមានព្រះភាគមិនទ្រង់ត្រាស់ថា " **អប្បិច្ឆោ** " ព្រោះសេចក្តីប្រាថ្នា ដែលមានប្រមាណតិចតួច នៅមាននៅឡើយ ។ តែព្រះអង្គ ទ្រង់ត្រាស់ ថា " **អប្បិច្ឆោ** " ដូច្នេះ ក៏ព្រោះមិនមានសេចក្តីប្រាថ្នា គឺ ព្រោះមានការមិនលោភ ដែលខ្ជួនសេពថ្នឹកហើយរឿយៗ នុ៉ះឯង " ។

(៣៤៨) ដីកានៃឯកនិបាត អង្គុត្តរនិកាយនោះ ថា " **អប្ប** សព្ទ ជាអត្ថនៃ **អភាវ:** ដូចជា **អប្ប** សព្ទ ក្នុងប្រយោគជាដើម

ពណ៌នាអំពីសេចក្ដីសង្ខេប

*ថា **អប្ប៉ាពាធោ អប្ប៉ាតង្កោ** ដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា **អនិច្ចស្ស** ។ មែនពិត ព្រះដ៏ព្រះភាគទ្រង់សំដៅយកការមិនមាននៃអាពាធ ផ្សេងដោយរោគ មានរោគភ្នែក និង រោគក្នុងពោះជាដើម ដែលប្រាកដមានក្នុងលោក ទើបទ្រង់ត្រាស់ថា **អប្ប៉ាពោធា អប្ប៉ាតង្កោ** ដូច្នេះ ។ ឥឡូវនេះ ដើម្បីធ្វើសេចក្ដីដែលបានពោលហើយនុ៎ះឯង ឲ្យច្បាស់ជាងមុន ទើបលោកពោលថា **ឯត្ត ហិ** ដូច្នេះជាដើម ។ ព្យញ្ជនៈ ប្រៀបដូចជាមានសេចក្ដីនៅសេសសល់ ព្រោះ **អប្ប** សព្ទ ប្រាកដមាន សូម្បីក្នុងអត្ថ ថាបន្ដិចបន្ដួច ។ ចំណែកសេចក្ដី មិនមានសេចក្ដីនៅសេសសល់ទ្បើយ ព្រោះភាវៈនៃការមិនមានសេចក្ដីប្រាថ្នា ក្នុងបច្ច័យ គឺលោកបានអធិប្បាយហើយ ដោយប្រការទាំងពួង ។ ព្រោះហេតុនោះ ទើបលោកពោលថា **ន ហិ** ដូច្នេះជាដើម " ។*

*ភាវៈនៃ **អប្ប** សព្ទ ជាអត្ថនៃ **អភាវៈ** គប្បីត្រួតមើល ក្នុងអដ្ឋកថាវជិរនីតសូត្រ និង ទសុត្តរសូត្រ និង ដីកានៃសូត្រនោះ ។*

ពួក ៤ នៃភិក្ខុអ្នកមានសេចក្ដីប្រាថ្នាតិច ចប់ ។

(៣៤៩) ភិក្ខុ អ្នកប្រាថ្នាដើម្បីនឹងបំពេញបដិបទា ដែលជាប់ទាក់ទងនឹងការប្រាថ្នាតិច ក្នុងបច្ច័យ គប្បីជាអ្នកដឹងប្រមាណ ក្នុងការទទួល ដោយប្រការដូច្នេះ ។ មែនពិត ភិក្ខុ កាលរស់នៅ យ៉ាង

មន្តលត្ថនីបនីប្រែ

ដូច្នេះ ឈ្មោះថា ជាអ្នកសន្តោស, ក៏បាបធម៌ទាំងឡាយ មានភាព ជាអ្នកមានសេចក្តីប្រាថ្នា ដ៏លើសលប់ជាដើម គឺ ភិក្ខុអ្នកសន្តោស តែងលះបង់បាន ។ ព្រោះហេតុនោះ សេចក្តីសន្តោស របស់ភិក្ខុ រូបនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាមង្គល ។ ក៏ភិក្ខុទាំង ឡាយ ជាអ្នកសន្តោស ទៅកាន់សុគតិ ហួសផុតពីការគណនា (រាប់មិនអស់) ។ នឹងមានប្រយោជន៍អ្វី ដោយរឿងរ៉ាវ (ដែលត្រូវ យកមកសំដែង) ។ ក៏ភិក្ខុ អ្នកស្ថិតនៅ ក្នុងសេចក្តីសន្តោសនោះ រមែងបានសម្រេចព្រះអរិយមគ្គ ។ ហេតុនោះ សេចក្តីសន្តោស នោះ របស់ភិក្ខុរូបនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅថា "ជាគ្រឿងឧបត្ថម្ភនូវអរិយមគ្គ" ។ ក៏ក្នុងដំណើរនេះ មានព្រះថេរ: អ្នកមានកិរិយាទ្រទ្រង់ នូវសំពត់បង្សុកូលជាវត្ត ដែលអាស្រ័យ នៅ ក្នុងបាចីនខណ្ឌរាជីវិហារ ជាឧទាហរណ៍ ។ រឿង ខ្ទុំពោល ហើយ ក្នុងចីវរសន្តោសន៉ុះឯង ព្ធដ៏ខាងក្រោយ ។

(៣៥០) ក៏ភិក្ខុ អ្នកសន្តោសហើយ រមែងជាអ្នកប្រព្រឹត្ត ដូចជាកុយរមាស ។ ហេតុនោះ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ជាដើម ទើបលោកពោល ថា " ភិក្ខុ អ្នកសន្តោសនោះ កាលប្រើ ប្រាស់ នូវសេនាសន: ដែលខ្ជូនប្រាថ្នាហើយៗ គឺ ដងព្រៃ គល់ ឈើ ញកព្រៃ ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង នៅតែម្នាក់ឯង

ពណ៌នាអំពីសេចក្ដីសន្តោស

មិនមានសំឡាញ់ ក្នុងឥរិយាបថទាំងពួង ប្រៀបដូចជាកូនសរ ដែលរបូតចេញផុតអំពីខ្សែ និង ប្រៀបដូចជាជំរីចុះប្រេង ចៀសចេញអំពីហ្ខូង ដូច្នោះឯង រមែងដល់ នូវភាពជាអ្នកប្រៀបដូចជាកុយរមាស ដែលលោកពណ៌នាហើយ យ៉ាងដូច្នេះ ថា ៖

ភិក្ខុអ្នកសន្តោសហើយ រមែងរស់នៅជាសុខ ក្នុងទិសទាំង ៤ និង ជាអ្នកមិនមានសេចក្ដីថ្នាំងថ្នាក់បិត្ត កាលសន្តោសដោយបច្ច័យក្រៅនេះ និង ក្រៅនេះ (តាមមានតាមបាន) ត្របសង្កត់ នូវសេចក្ដីអន្ទរាយទាំងឡាយបាន ជាអ្នកមិនភ័យខ្លាច ជាបុគ្គលម្នាក់ឯង ប្រៀបដូចជាកុយរមាស គប្បីត្រាប់បរទៅ ។

សួរថា " តើអ្នកណា ពណ៌នាទុកហើយ? " ។ ឆ្លើយថា " ព្រះបច្ចេកពុទ្ធ មួយអង្គ បានពណ៌នាទុកហើយ " ។

*បានញ្ចថា ព្រះបច្ចេកពុទ្ធ អង្គនោះ ជាព្រះរាជា ក្នុងទីក្រុងពារាណសី ទ្រង់គង់នៅ លើព្រះរាជបល្ល័ង្ក ទ្រង់ញ្ញាំងវិបស្សនាឲ្យចំរើនហើយ ក៏បានសម្រេចព្រះបច្ចេកពោធិញ្ញាណ ទ្រង់បានភាសិតហើយ នូវខទានគាថា ថា "**ចាតុទ្ទិសោ**" ដូច្នេះជាដើម ។ គាថានោះ មកហើយ ក្នុងខគ្គវិសាណសូត្រ ក្នុងបឋមវគ្គ សុត្តនិបាត ។*

មង្គលត្ថទីបនីប្រែ

(៣៥១) អដ្ឋកថាខគ្គវិសាណសូត្រ ថា " បណ្តាបទទាំងនោះ បទថា **ចាតុទ្ទិសោ** មានសេចក្តីថា ជាអ្នកមានប្រក្រតីនៅតាមសប្បាយក្នុងទិសទាំង ៤ ។ ព្រហ្មវិហារភាវនា គឺភិក្ខុរូបនោះផ្សព្វផ្សាយទៅហើយ ដោយនយថា **ឯកំ ទិសំ ផរិត្វា វិហរតិ** ជូរច្នេះជាដើម ។ ទិសទាំងឡាយ ៤ របស់ភិក្ខុអ្នកសន្តោសនោះ តែងមាន ព្រោះហេតុនោះឯង ភិក្ខុ អ្នកសន្តោសនោះ ឈ្មោះថា **ចាតុទ្ទិសោ** ។ ភិក្ខុអ្នកសន្តោស រមែងមិនក្រហល់ក្រហាយ ព្រោះភ័យខ្លាច ក្នុងសត្វ ឬ សង្ខារ ក្នុងទីណា ក្នុងទិសទាំងឡាយនោះ ព្រោះហេតុនោះ ភិក្ខុ អ្នកសន្តោសនោះ ឈ្មោះថា **អប្ផដិឃោ** (អ្នកមិនក្រហល់ក្រហាយ) ។ បទថា **សន្ទុស្សមានោ** មានសេចក្តីថា ជាអ្នកសន្តោស ដោយអំណាចសេចក្តីសន្តោស ១២ យ៉ាង ។ បទថា **ឥតរីតរេន** គឺ ដោយបច្ច័យដែលខ្ពស់ៗ ទាបៗ ។ ក្នុងពាក្យថា **បរិស្សយានំ សហិតា** នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ៖ សេចក្តីអន្តរាយទាំងឡាយ រមែងបៀតបៀន ដោយជុំវិញ គឺ រមែងញ៉ាំងកាយ និង ចិត្តឲ្យតក់ស្លុត ទើបឈ្មោះថា **បរិស្ស-យានិ** ។ ម្យ៉ាងទៀត សេចក្តីអន្តរាយទាំងឡាយ ដល់ព្រមហើយ ដល់កាយ និង ចិត្តទាំងឡាយនោះ ទើបឈ្មោះថា **បរិស្សយានិ** ។ ពាក្យថា **បរិស្សយានិ** នេះ ជាឈ្មោះនៃសេចក្តីអន្តរាយ ខាងផ្លូវ

ពណ៌នាអំពីសេចក្តីសន្តោស

កាយ និង ចិត្ត ដែលប្រព្រឹត្តទៅ ព្ធដ៏ខាងក្រៅ មានសីហ: និង ខ្ញាធំជាដើម និង ដែលប្រព្រឹត្តទៅព្ធដ៏ខាងក្នុង មានកាមច្ឆន្ទ ជាដើម ។ ភិក្ខុអ្នកសន្តោស រមែងគ្របសង្កត់ នូវសេចក្តីអន្តរាយទាំងឡាយនោះ ដោយអធិវាសនខន្តី និង ដោយធម៌ទាំងឡាយ មានសេចក្តីព្យាយាមជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា អ្នកគ្របសង្កត់ នូវសេចក្តីអន្តរាយទាំងឡាយបានហើយ ។ ឈ្មោះថា ជាអ្នកមិនតក់ស្ទុត ព្រោះមិនមានភ័យ ដែលធ្វើនូវភាពជាអ្នកតក់ស្ទុត " ។

ជីកានៃចូឡហ្ថិបទោបមសូត្រ និង ចតុក្កនិបាត អង្គុត្តរ-និកាយថា "ជាបុគ្គលម្នាក់ឯង មិនមានសំឡាញ់ ទៅហើយន៉ុះឯង, អធិប្បាយថា ឈ្មោះថា ជាអ្នកប្រៀបបាននឹងកុយរមាស ព្រោះភាវ:ជាអ្នកដូចជាស្នែង នៃសត្វម្រឹគ ដែលបានឈ្មោះថា រមាសគប្បីត្រាច់ចរទៅ ដូច្នេះ " ។

*អដ្ឋកថាខគ្គវិសាណសូត្រថា " កុយនៃសត្វរមាស ឈ្មោះថា **ខគ្គវិសាណ** ។ **កប្ប** សព្ទ ជាអត្ថនៃបដិភាគ (ភាគប្រដូច) ។ សមដូចជាពាក្យ ដែលព្រះបច្ចេកពុទ្ធ ទ្រង់ត្រាស់ អធិប្បាយទុកថា ប្រៀបដូចជាកុយរមាស ដូច្នេះ " ។*

(៣៥២) សេចក្តីនេះថា "មួយវិញទៀត ភិក្ខុអ្នកដែលមិនសន្តោសហើយ រមែងសាបសូន្យ ចាកទ្រព្យខ្ញះ ចាកជីវិតខ្ញះ, ភិក្ខុ

អ្នកសន្ធោសហើយ រមែងមិនសាបសូន្យ" យ៉ាងដូច្នេះ គប្បីសំដែងសូម្បីដោយជរូទបានជាតក ក្នុងបឋមវគ្គ នៃតិកនិបាត ។

មែនពិត ទ្រព្យ របស់បុគ្គលអ្នកសន្ធោសហើយ សូម្បីបាត់បង់ទៅហើយ ក៏រមែងមាននៅជាប្រក្រតី ដូចដើមវិញ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿងស្តេចសេក)

ក្នុងអតីតកាល ព្រះពោធិសត្ត្ব សោយជាតិជាស្តេចសេកក្នុងព្រៃឧទុម្ពរ (ព្រៃល្វា) ក្បែរមាត់ច្រាំងទន្លេគង្គា, កាលបើផ្លែឈើរបស់ខ្លួនអស់ហើយ, ក៏ចឹកស៊ីតែពន្ធក (ត្រួយ) សន្ទ្ធីក សំបក ឬក្រមរ ដែលមាននៅសល់ហើយប៉ុណ្ណោះឯង ហើយបានផឹកទឹកក្នុងទន្លេគង្គា ជាសត្ত្বមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្ធោសយ៉ាងក្រៃលែង មិនហើរទៅ ក្នុងទីស្ថានដទៃទៀយ ។ ដោយគុណនៃភាពជាអ្នកមានសេចក្តីប្រាថ្នាតិច និង សន្ធោស របស់ស្តេចសេកនោះ ភព របស់ស្តេចសក្ក្ត្ត ទេវរាជបានកម្រើកហើយ ។ ស្តេចសក្ក្ត ទេវរាជ ជ្រាបហេតុនោះហើយ ទ្រង់បានញ្ជាំងដើមឈើនោះ ឲ្យក្រៀមស្ងួតអស់ហើយ ដោយអានុភាពរបស់ព្រះអង្គ ដើម្បីនឹងសាកល្បង នូវស្តេចសេកនោះ ។ ដើមឈើ មាននៅត្រឹមតែជង្គ ត់ជ្ញុ ជាប់អស់ហើយ, កាលបើឲ្យល់ បក់ជ្ញុកមក, ក៏បញ្ចេញ

មជ្ឌលត្ថនីបនីប្រែ

សំឡេង ដូចជាត្រូវបុគ្គលគោះ បានតាំងនៅហើយ ។ លំអង ទាំងឡាយ ក៏ចេញមកអំពីប្រហោងទាំងឡាយ នៃដើមឈើនោះ ។ ស្តេចសេក បានចឹកស៊ីលំអងទាំងនោះហើយ មិនបានហើរទៅ ក្នុងទីស្ថានដទៃទៀត មិនបាននឹកគិតដល់ខ្យល់ និង កំដៅថ្ងៃឡើយ បានទំនៅ លើចុងដង្គត់ដើមឧទុម្ពរហើយ ។ ស្តេចសក្ក្រទេវរាជ ទ្រង់ជ្រះថ្លាហើយ ទើបបានជងទឹក ក្នុងទន្ទេគង្គា មកស្រោចដង្គត់ឈើនោះហើយ ។ ក្នុងពេលជាមួយគ្នានោះឯង ដើមឈើក៏បានសម្ជូរដោយមែក និង បង្ហាប មានផ្ការ៉ាផ្អែម ជុះឡើងហើយ ។

រឿងស្តេចសេក មកក្នុងអដ្ឋកថា ចូឡសុវណ្ណជាតក
ក្នុងនវកនិបាត ។

(៣៥៣) ព្រោះហេតុនោះ ភិក្ខុអ្នកមានបំណង ចង់ឲ្យព្រះសាសនា ស្ថិតនៅ អស់កាលយូរអង្វែង គប្បីជាអ្នកសន្ទោសចុះ ។ ព្រោះថា ការ:ជាអ្នកមានសេចក្តីសន្ទោស រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនវិនាស នៃព្រះសាសនា, ភាពជាអ្នកមិនមានសេចក្តីសន្ទោស ទើបប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសនៃព្រះសាសនា ។

ព្រោះហេតុនោះ ក្នុងទសមវគ្គ នៃឯកនិបាត អង្គុត្តរនិកាយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញ នូវសការ:ដទៃ សូម្បីតែសការ: ១ ដែល

មङ្គលត្ថទីបនីប្រែ

ប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ដូចជាសេចក្តីមិនសន្ទោសនេះសោះឡើយ, ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនសន្ទោសទេ ទើបប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម " ដូច្នេះ និង ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគត រំពឹងរកមិនឃើញ នូវសភាវៈដទៃ សម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្ម ដូចជាសេចក្តីសន្ទោសនេះសោះឡើយ, ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្ទោសទេ ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្ម " ដូច្នេះ ។

(៣៥៤) អដ្ឋកថានៃសូត្រទាំង ២ នោះថា " បណ្តាបទទាំងនោះ បទថា **សទ្ធម្មស្ស** គឺ នៃធម៌ដ៏ល្អ, អធិប្បាយថា នៃព្រះសាសនា ។ បទថា **សម្មោសាយ** គឺ ដើម្បីសេចក្តីវិនាស ។ បទថា **អន្តរធានាយ** គឺដើម្បីសេចក្តីមិនប្រាកដ ។ បទថា **ឋិតិយា** គឺ ដើម្បីឋិតនៅ អស់កាលដ៏យូរ ។ ពាក្យថា **អសម្មោសាយ អនន្តរធានាយ** គប្បីជ្រាប ដោយនយដែលជាប្រតិបក្ស ដូចបានពោលមកហើយនុ៎ះឯង " ។

ដីកានៃសូត្រទាំង ២ នោះ ថា " គប្បីប្រកាន់យកសេចក្តីដោយពាក្យ យ៉ាងនេះថា ដើម្បីមិនវិនាស ដូច្នេះជាដើម ក្នុងបទ

ពណ៌នាអំពីសេចក្តីសន្តោស

ថា **រុត្តប្បបក្ខនយេន** ដូច្នេះ" ។

(៣៥៥) ក៏ព្រះតម្រាស់ទាំងអស់នុ៉ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយក នូវភាពជាអ្នកមានសេចក្តីសន្តោស និង ភាពជាអ្នកមិនមានសេចក្តីសន្តោស ក្នុងបច្ចយទាំងឡាយ មានចីវរបច្ចយជាដើម ។ ក៏ភាពជាអ្នកមានសេចក្តីសន្តោស ក្នុងធម៌ទាំងឡាយ ដែលមិនមានទោស មានទាន និង សីស ជាដើម មិនសមគួរឡើយ, ភាពជាអ្នកមិនសន្តោស ក្នុងធម៌ទាំងឡាយនោះ ឯង ទើបសមគួរ ។

ហេតុនោះ ក្នុងតតិយបណ្ណាសក: ទុកនិបាតអង្គុត្តរនិកាយ ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់ភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ថា "**អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ**" ដូច្នេះ ។

(៣៥៦) ក្នុងអដ្ឋកថាទុកនិបាត អង្គុត្តរនិកាយនោះ លោកពោលហើយ ថា " ភាពជាអ្នកមិនសន្តោស ក្នុងកុសលធម៌ទាំងឡាយ លើកលែងតែការបានសម្រេចព្រះអរហត្តចេញ ឈ្មោះថា **អសន្តុដ្ឋិតា** " ។

ដីកានៃតតិយបណ្ណាសក:នោះ ថា " ២ បទថា **អញ្ញត្រ អរហត្តប្បត្តា** បានដល់ រៀរចាកការបានសម្រេចព្រះអរហត្ត " ។

មន្តលត្ថទីបនីប្រែ

ចាលីនិក្ខេបកណ្ឌថា "ពាក្យថា **អសន្ត្ដ្ឋិតា ច កុសលេសុ ធម្មេសុ** មានសេចក្តីថា សេចក្តីប្រាថ្នា ដ៏ក្រៃលែង នៃបុគ្គលអ្នកមិនសន្តោស ដោយការចំរើនកុសលធម៌ទាំងឡាយឯណា " ។

ដីកានៃសង្គីតិសូត្រថា " ២ បទថា **កុសលានំ ធម្មានំ** គឺ នូវធម៌ដែលមិនមានទោសទាំងឡាយ មានសីលជាដើម ។ បទថា **ភាវនាយ** ចានដល់ ដោយកិរិយាធ្វើឲ្យកើតឡើង និង ដោយកិរិយាធ្វើឲ្យចំរើនឡើង ។ បទថា **អសន្ត្ដ្ឋស្ស** មានសេចក្តីថា អ្នកមិនសន្តោស ដោយអំណាចនៃការដល់ នូវសេចក្តីរួញរាស្ទាក់ស្ទើរ ដោយគិតថា ដោយហេតុមានប្រមាណប៉ុណ្ណេះ ក៏គ្រប់គ្រាន់ហើយ, ដោយហេតុមានប្រមាណប៉ុណ្ណេះ ក៏គ្រប់គ្រាន់ហើយ ។ សេចក្តីប្រាថ្នា ក្នុងកិរិយាធ្វើឲ្យកើតឡើង ដោយក្រៃលែងៗ ឈ្មោះថា **ភិយ្យោកម្យតា** " ។

(៣៥៧) អដ្ឋកថានិក្ខេបកណ្ឌ ថា " សេចក្តីប្រាថ្នា ដោយវិសេស ឈ្មោះថា **ភិយ្យោកម្យតា** ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាដំបូងនុ៉ះឯង រមែងប្រគេនបក្ខិកភត្តខ្លះ សលាកភត្តខ្លះ, បុគ្គលនោះ ជាអ្នកមិនសន្តោស ដោយការប្រគេននោះ ទើបប្រគេនភត្តប្រចាំ សង្ឆភត្ត សំពត់ចំណាំវស្សា ឲ្យកសាងអាវាស ប្រគេន

ពណ៌នាអំពីសេចក្ដីសន្លោស

*បច្ច័យទាំង ៤ ថែមទៀតផង, ជាអ្នកមិនសន្ទោស សូម្បីក្នុងការ ប្រគេននោះ ក៏ទទួលនូវសរណៈ សមាទានសីល ៥, ជាអ្នកមិន សន្ទោស សូម្បីក្នុងការទទួលសរណៈជាដើមនោះ ទើបបួស, លុះ បួសហើយ ក៏រៀន ១ និកាយ ២ និកាយ ព្រះពុទ្ធវចនៈ គឺ ព្រះ ត្រៃបិដក ញ្ជាំងសមាបត្តិទាំង ៨ ឲ្យកើតឡើង ចំរើនវិបស្សនា ហើយ ក៏ឈានយកព្រះអរហត្ត, ចាប់តាំងពីបានសម្រេចនូវព្រះ អរហត្តហើយ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានសេចក្ដីសន្ទោស យ៉ាងធំ ។ ក៏សេចក្ដីប្រាថ្នា ដោយវិសេស ក្នុងព្រះអរហត្ត យ៉ាង ដូច្នេះ ឈ្មោះថា **កិយ្យាកម្យតា** " ។*

អដ្ឋថាសង្គ្ដីតិសូត្រ ថា "ក៏បុគ្គលជាអ្នកព្រមព្រៀង ដោយ សេចក្ដីប្រាថ្នាយ៉ាងក្រៃលែងនោះ បំពេញសីលហើយ រមែងញ្ជាំង ឈាន ឲ្យកើតឡើង, បានឈានហើយ រមែងប្រារព្ធវិបស្សនា, ប្រារព្ធវិបស្សនាហើយ ក៏ចាប់យកនូវព្រះអរហត្ត រមែងមិនដល់ នូវការឈប់សម្រាក (រសាយចិត្ត) ក្នុងចន្លោះ ។

(៣៥៨) ព្រោះហេតុនោះ កុលបុត្រ មិនគួរធ្វើសេចក្ដី សន្ទោស ដោយការញ្ជាំងកុសល ឲ្យកើតឡើងឡើយ ។ ព្រោះថា បុគ្គលកាលធ្វើ នូវបុណ្យជារៀយៗ រមែងបានសម្រេចសូម្បីនូវ សេចក្ដីសុខ ដែលជាលោកុត្តរៈ ដូចជាព្រាហ្មណ៍ម្នាក់ អាស្រ័យនៅ

មន្តលត្ថនីបនីប្រែ

ក្នុងទីក្រុងសាវត្ថី ដូច្នោះឯង ។

(រឿង ព្រាហ្មណ៍ម្នាក់)

បានញ្ញថា ថ្ងៃមួយ ព្រាហ្មណ៍នោះ ចេញ (ពីផ្ទះ) តាំងតែ អំពីព្រឹកព្រលឹមហើយ ក្រឡេកមើលភិក្ខុទាំងឡាយ ដែលកំពុង តែគ្រងចីវរ ក្នុងទីកន្លែងមួយ ដែលមានស្មៅដុះឡើង បានឃើញ នូវមុមចីវរ របស់ភិក្ខុមួយអង្ត មកប៉ះរះ លើស្មៅទាំងឡាយ ទទឹក ជោក ដោយតំណក់ទឹកសន្សើមហើយ ទើបគិត ថា " អាត្មាអញ ធ្វើទីកន្លែងនេះ ឲ្យអស់ស្មៅ ទើបសមគួរ " ដូច្នេះហើយ លុះថ្ងៃ ស្អែកឡើង ទើបយកចប មកចាំងជម្រះទីកន្លែងនោះហើយ ធ្វើឲ្យ ដូចជាទីមណ្ឌលនៃឈាន សូម្បីក្នុងថ្ងៃស្អែកឡើងទៀត ក៏បានទៅ ហើយ ក្នុងទីនោះ បានឃើញមុមចីវរ របស់ភិក្ខុមួយរូប ធ្លាក់មក លើផែនដី ប្រឡាក់ដោយធូលី ទើបគិត ថា " ការដែលអាត្មាអញ កៀរនូវដីឧ្យាច់ ក្នុងទីនេះ ទើបសមគួរ " ដូច្នេះហើយ ក៏បានធ្វើ ហើយ យ៉ាងដូច្នោះឯង ។

ក្រោយមក ថ្ងៃមួយ ក្នុងពេលមុនភត្ត កើតមានកំដៅថ្ងៃ ក្តៅយ៉ាងខ្លាំង ។ សូម្បីក្នុងគ្រានោះ ព្រាហ្មណ៍នោះ ក៏បានទៅ ក្នុងទីនោះ បានឃើញញើស កំពុងហូរចេញ យ៉ាងសស្រាក់ អំពី

ពណ៌នាអំពីសេចក្ដីសង្ហេស

សរីរៈរាងកាយ របស់ភិក្ខុទាំងឡាយ ដែលកំពុងតែគ្រងចីវរ ទើប បានឲ្យគេកសាងមណ្ឌបឡើង ក្នុងទីនោះ ។ ថ្ងៃក្រោយមកទៀត មានភ្លៀងធ្លាក់ តាំងតែអំពីព្រលឹមស្រាង ។ សូម្បីក្នុងពេលនោះ ព្រាហ្មណ៍នោះ ក៏បានទៅ ក្នុងទីនោះ បានឃើញហើយ នូវភិក្ខុទាំង ឡាយ មានចីវរទទឹកជោក ក៏ឲ្យគេរុះរើមណ្ឌបចេញហើយ ឲ្យ កសាងសាលា ក្នុងទីនោះ ជាអ្នកមានបំណងចង់ធ្វើការឆ្លងសាលា ទើបបាននិមន្តព្រះសាស្តា ព្រមទាំងព្រះសង្ឆ មកគង់នៅ ក្នុង សាលានោះ ហើយថ្វាយទាន ក្នុងពេលចប់ភត្តកិច្ចស្រេចហើយ ទើបបានក្រាបទូលនូវកម្ម ដែលខ្លួនបានធ្វើហើយ គ្រប់ប្រែបយ៉ាង ចាប់ដើមតាំងអំពីគ្រាដំបូងមក ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍ ធម្មតាបណ្ឌិត កាលធ្វើកុសល ម្ដងបន្ដិចៗ រាល់ៗ ខណៈ រមែងកំចាត់បង់ នូវ សេចក្ដីសៅហ្មងរបស់ខ្លួន ដោយលំដាប់ បានដោយពិតប្រាកដ " ដូច្នេះហើយ ទើបទ្រង់ត្រាស់ហើយ នូវព្រះគាថានេះ ក្នុងមលវគ្គ នៃធម្មបទ ថា ៖

(៣៥៩) " អ្នកមានប្រាជ្ញា គួរកំចាត់បង់ចោល នូវមន្ទិល
របស់ខ្លួន បន្ដិចម្ដងៗ រាល់ៗ ខណៈ ដោយលំដាប់ ប្រៀប

មន្តលត្ថនីបនីប្រែ

ដូចជាងមាស ជំរះចោលនូវស្នឹម ឬប្រែះ របស់មាស យ៉ាង ដូច្នោះឯង " ។

*បណ្តាបទទាំងនោះ បទថា "**អនុបុព្វេន**" គឺតាម លំដាប់ បានដល់ ដោយហូរហែ ។ បទថា "**មេធាវី**" មានសេចក្តីថា បុគ្គលអ្នកប្រកបព្រមហើយ ដោយបញ្ញា ដ៏រុងរឿង ក្នុងព្រះធម៌ កាលធ្វើកុសល បន្តិចម្តងៗ រាល់ៗ ខណៈ គឺ រាល់ៗ ពេល ។*

*បាទគាថា ថា "**កម្មារោ រជតស្សេវ**" មានសេចក្តីថា ដូចជាជាងមាស ជំរះចោលនូវស្នឹម ឬ ប្រែះ នៃមាស ដូច្នោះឯង ។*

*បទថា "**និទ្ធមេ**" មានសេចក្តីថា គប្បីកំចាត់ គឺយកចេញ នូវមន្ទិល គឺរាគៈ ជាដើម របស់ខ្លួន, អធិប្បាយថា "ប្រៀបដូចជាជាងមាស ធ្វើមាសឲ្យក្តៅហើយ ដំ នាំយកស្នឹម ឬ ប្រែះ ចេញ អស់រាវៈ ពេលមួយដង ប៉ុណ្ណោះ រមែងមិនអាច ដើម្បីធ្វើគ្រឿង ប្រដាប់ យ៉ាងទំនើបៗ បានឡើយ, ប៉ុន្តែ កាលបើដុត ដំ នាំយកស្នឹម ឬ ប្រែះ ចេញរឿយៗ បន្ទាប់អំពីនោះមក ទើបធ្វើនូវគ្រឿង ប្រដាប់ ដ៏ទំនើបៗ ច្រើនជាអនេក យ៉ាងណាមិញ, បុគ្គល ជាបណ្ឌិត កាលធ្វើនូវកុសល ជារឿយៗ កំចាត់ចោលនូវមន្ទិល មានរាគៈ ជាដើម របស់ខ្លួនបានហើយ ជាអ្នកបានកំចាត់មន្ទិល*

ពណ៌នាអំពីសេចក្តីសន្តោស

ចោលហើយ គឺ មិនមានកិលេស ក៏យ៉ាងដូច្នោះដែរ " ។

ក្នុងទីបញ្ចប់នៃព្រះគាថា ព្រាហ្មណ៍នោះ ក៏បានសម្រេចជាព្រះសោតាបន្នបុគ្គលហើយ ។

រឿង ព្រាហ្មណ៍ម្នាក់ ចប់ ។

ពណ៌នាអំពីបទថា សេចក្តីសន្តោស ចប់ ។

(មន្តលត្តទីបនីប្រែ ភាគទី ៣ ចប់ ៧)

ប្រែចប់ថ្ងៃព្រហស្បហតិ៍ ៨ កើត ខែភទ្របទ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦
ត្រូវនឹងថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៣
វេលាម៉ោង ១០ : ១១ នាទី ព្រឹក

សូមសេចក្តីសម្រេច កើតមាន ដល់អ្នកសិក្សាគ្រប់ៗ រូបកុំបីខាន ។

រាយចម្ងសាច្ចី ចប់សព្វគ្រប់
នៅថ្ងៃ ពុធ ៤ កើត ខែ ភទ្របទ ឆ្នាំរោង ព.ស. ២៥៥៦
ត្រូវនឹងថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១២ វេលាម៉ោង ១:២៩ នាទី យប់

សូមឱ្យព្រះពុទ្ធសាសនា បានរីកចំរើន ! សូឱ្យសព្វសត្ត បានរួចផុតចាកទុក្ខ !

សៀវភៅ "**មង្គលត្ថទីបនីប្រែ**" ទាំង ៤ ភាគនេះ ខ្ញុំបានឱ្យវាយបម្លង និង បានរៀបរៀងកែសម្រួលសាជាថ្មីម្តងទៀត នៅក្នុង ព. ស. ២៥៥៦ - ២៥៥៧ ដោយបានសហការគ្នា យ៉ាងសកម្ម ពីព្រះសង្ឃជាប្រើនអង្គ ដូបមានរាយព្រះនាមខាងក្រោមនេះ ៖

មង្គលត្ថទីបនី ភាគទី ១ បានវាយបម្លងដោយ ភិក្ខុ អេប- បាប បានបប់បរិបូរ នៅថ្ងៃអង្គារ ៤ រោប ខែដេស្ត ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី ០៥ ខែមិថុនា ឆ្នាំ ២០១២ ។

មង្គលត្ថទីបនី ភាគទី ២ បានវាយបម្លងដោយ ភិក្ខុ ផាង-សាន្ត និង ភិក្ខុ សុិន-សុខ បានបប់បរិបូរ នៅថ្ងៃព្រហស្សតិ៍ ១ កើត ខែទុតិយាសាឍ ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី ១៩ ខែកក្កដា ឆ្នាំ ២០១២ ។

មង្គលត្ថទីបនី ភាគទី ៣ បានវាយបម្លងដោយ ភិក្ខុ យន់-សុផា បានបប់បរិបូរ នៅថ្ងៃពុធ ៤ កើត ខែភទ្របទ ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី១៩ ខែកញ្ញា ឆ្នាំ ២០១២ ។

មង្គលត្ថទីបនី ភាគទី ៤ បានវាយបម្លងដោយ ភិក្ខុ គុណ-សារីម បានបប់បរិបូរ នៅថ្ងៃពុធ ៩ រោប ខែដេស្ត ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី១៣ ខែមិថុនា ឆ្នាំ ២០១២ ។

សូមខេមរជនគ្រប់ៗ រូប ជួយនាំគ្នាស្តារ និង លើកស្ទួយនូវ សាមគ្គីធម៌, ព្រហ្មវិហារធម៌ និង សង្គហធម៌ ដែលយើងធ្លាប់មាន មកពីកាលមុន ជាយូរអង្វែងហើយ ឲ្យបានស្ថិតនៅជាប់ ក្នុងដួងចិត្ត របស់យើងគ្រប់ៗ គ្នា ឡើងវិញ ហើយនាំគ្នាកំចាត់ចោល នូវការ ចងក្រោធទុក ការចងកម្ម ចងពៀរវេរានឹងគ្នា មិនចេះឈប់ឈរ ឲ្យ ប្រាសចាកពីខន្ធសន្តាន របស់យើង ដើម្បីទទួលយកនូវសេចក្តី សុខសន្តិភាព ដ៏ពិតប្រាកដ តាមមាគ៌ា នៃព្រះពុទ្ធសាសនា ។

មែនពិត អំពើអាក្រក់ទាំងប៉ុន្មាន ខាងលើនេះ ពុំដែលធ្វើឲ្យ យើងបានសុខចំរើន ម្តងណាសោះឡើយ គឺ មានតែធ្វើឲ្យយើង វិនាសហិនហោច តែម៉ាងប៉ុណ្ណោះឯង ។

ចូរកុលបុត្រខ្មែរ នាំគ្នាថែរក្សាធឹកជីខ្មែរឱ្យបានគង់ទង្ស

វត្តខេមរពុទ្ធិការាម ទីក្រុងឡងប៊ិច

សហរដ្ឋអាមេរិច

១៥ កើត ខែវិសាខ ឆ្នាំមមែ ត្រីស័ក ព.ស.២៥៣៤

ភិក្ខុវិនយធរោ មហាយិន-ឌឿន

សៀវភៅមង្គលត្ថទីបនីប្រែ ដែលព្រះតេជគុណ អស់លោក លោកស្រី ពុទ្ធបរិស័ទ កំពុងតែអាននៅនឹងដៃនេះ គឺជាស្នាព្រះហស្ត ប្រែនិងរៀបរៀងដោយ ព្រះកិត្ថុវិនយឌភេ មហាយិន ឌឿន ដែលគណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ បានទទួលយល់ព្រមយកទៅបោះពុម្ពផ្សាយជាធម្មទាន ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់ (The Corporate Body of the Buddha Educational Foundation) ។

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាននេះ ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាជ្ញាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

MAHA PANNA VIHARA FOUNDATION ORGANIZATION

大般若寺基金會

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់នៅកន្លែងណា ឬបានឃើញនូវកំហុសធ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម:

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

"Wherever the Buddha's teachings have flourished,

either in cities or countrysides,

people would gain inconceivable benefits.

The land and people would be enveloped in peace.

The sun and moon will shine clear and bright.

Wind and rain would appear accordingly,

and there will be no disasters.

Nations would be prosperous

and there would be no use for soldiers or weapons.

People would abide by morality and accord with laws.

They would be courteous and humble,

and everyone would be content without injustices.

There would be no thefts or violence.

The strong would not dominate the weak

and everyone would get their fair share."

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

✻ The Vows of Samantabhadra ✻

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

✻ The Vows of Samantabhadra Avatamsaka Sutra ✻